# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៤០

បាលីប្រែ ៥៦

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# បេតវត្ថុ បញ្ចមភាគ

# ៤០

# បាលីប្រែ ៥៦



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤០

# សុត្តន្តបិដក ខុទ្ទកនិកាយ

# បេតវត្ថុ បញ្ចមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## ឧរគវគ្គ ទី ១

## រឿង ខេត្តូបមាប្រេត ទី ១

*[ ១ ] ពួកព្រះអរហន្តដូចស្រែ ពួកទាយកដូចអ្នកភ្ជួររាស់ ទេយ្យធម៌ដូចពូជ ផលតែងកើតមកអំពីព្រះអរហន្តនិងទាយកនិងទេយ្យធម៌នុ៎ះ ឯពូជនិងការភ្ជួររាស់និងស្រែនុ៎ះ តែងមានដល់ពួកប្រេតទាំងឡាយផង ដល់ទាយកផង ប្រេតទាំងឡាយ តែងបរិភោគនូវផលនៃទាននោះ ទាយកអ្នកឲ្យទាន តែងចម្រើនដោយបុណ្យក្នុងលោកនេះ បុគ្គលធ្វើកុសលហើយ គួរតែបូជាចំពោះប្រេតទាំងឡាយ ព្រោះថា បុគ្គលធ្វើកុសលកម្មដ៏ចម្រើន រមែងទៅកាន់ឋានសួគ៌ ។*

*ចប់ រឿងខេត្តូបមាប្រេតទី ១ ។*

# បរមត្ថទីបនី អដ្ឋកថា

# បេតវត្ថុ

## កថាផ្ដើមបករណ៍

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមនមស្ការ នូវព្រះលោកនាថ ទ្រង់ប្រកបដោយមហាករុណាគុណ ជាអ្នកដល់នូវត្រើយនៃសាគរ គឺញេយ្យធម៌ ទ្រង់មានទេសនាដ៏ល្អិតសុខុម និងវិចិត្រ ។

ខ្ញុំព្រះករុណា សូមនមស្ការនូវព្រះធម៌ដ៏ឧត្តមនោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បូជាហើយ ជាគ្រឿងនាំសត្វដែលដល់ព្រមដោយវិជ្ជា និងចរណៈ ឲ្យចេញចាកលោក ។

ខ្ញុំព្រះករុណា សូមនមស្ការនូវព្រះអរិយសង្ឃ ដែលដល់ព្រមដោយសីលគុណជាដើម តាំងនៅក្នុងមគ្គ និងផល ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។

ដោយតេជះនៃបុណ្យ ដែលកើតអំពីកិរិយានមស្ការព្រះរតនត្រ័យ ដូចពោលមកហើយនេះ ខ្ញុំព្រះករុណាសូមជាអ្នកកុំបីមានអន្តរាយ ដែលជំនន់នៃបុណ្យនោះកម្ចាត់ហើយ ក្នុងទីសព្វអន្លើ ទេសនាណារបស់ព្រះពុទ្ធទាំងឡាយប្រកាសដល់កម្ម ដែលប្រេតទាំងឡាយធ្វើទុកក្នុងកាលមុន ជាហេតុនាំមកនូវភាពជាប្រេត ដោយការផ្សេងគ្នានៃផលកម្មរបស់ប្រេតទាំងនោះ ដែលនាំមកនូវការសង្វេគឲ្យកើតដោយវិសេស ធ្វើកម្មនិងផលនៃកម្មឲ្យប្រចក្ស ទេសនា

នោះ មានរឿងដែលជ្រាបល្អហើយ ដោយឈ្មោះ ឈ្មោះថា **បេតវត្ថុ** ដែលលោកអ្នកស្វែងរកគុណធំសង្គាយនាទុកហើយ ក្នុងខុទ្ទកនិកាយ ។ ខ្ញុំនឹងកាន់យកន័យរបស់អដ្ឋកថាបុរាណរបស់បេតវត្ថុនោះ មកចង្អុលបង្ហាញដល់ហេតុក្នុងរឿងនោះៗឲ្យជាក់ច្បាស់ដោយពិសេស និងធ្វើអត្ថសំវណ្ណនាដ៏ល្អបរិសុទ្ធដោយប្រពៃ មិនច្រឡូកច្រឡំ មានអត្ថនិងវិនិច្ឆ័យដ៏ល្អិត មិនជំទាស់នឹងលទ្ធិរបស់ព្រះមហាថេរៈដែលនៅក្នុងមហាវិហារ តាមកម្លាំង សូមសាធុជនទាំងឡាយតាំងចិត្តស្តាប់អត្ថវណ្ណនានោះរបស់ខ្ញុំ ដែលពោលដោយគោរពចុះ ។

ក្នុងបទទាំងនោះ បទថា **បេតវត្ថុ** បានដល់ កម្មដែលជាហេតុឲ្យសត្វនោះៗមានកូនសេដ្ឋីជាដើមកើតជាប្រេត ។ ព្រះបរិយត្តិធម៌ដែលប្រព្រឹត្តទៅដោយប្រកាសដល់កម្មនោះ មានពាក្យថា ព្រះអរហន្តទាំងឡាយដូចស្រែ ជាដើម លោកបំណងយកបេតវត្ថុ ក្នុងទីនេះ ។

សួរថា បេតវត្ថុនោះ អ្នកណាពោល ពោលក្នុងទីណា ពោលកាលណា ព្រោះហេតុអ្វីទើបពោល ខ្ញុំនឹងឆ្លើយថា បេតវត្ថុនេះ កើតដោយហេតុ ២ យ៉ាង គឺកើតដោយអត្ថុប្បត្តិហេតុ ១ ដោយពាក្យសួរនិងពាក្យឆ្លើយ ១ ។ ក្នុង ២ យ៉ាងនោះ កើតដោយអត្ថុប្បត្តិហេតុ ព្រះមានព្រះភាគត្រាស់ ក្រៅអំពីនោះ ព្រះនារទត្ថេរជាដើម ជាអ្នកសួរ ពួកប្រេតនោះៗជាអ្នកឆ្លើយ ។ ព្រោះកាលព្រះនារទត្ថេរជាដើម ក្រាបទូលដល់ពាក្យសួរនិងពាក្យឆ្លើយនោះៗ ព្រះសាស្តាក៏ធ្វើរឿងនោះៗ ឲ្យជាអត្ថុប្បត្តិហេតុ ហើយសម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ ព្រោះហេតុនោះ ទើបបេតវត្ថុទាំងអស់ ក៏ឈ្មោះថា

ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ពិតហើយ កាលព្រះសាស្តាទ្រង់ប្រកាសព្រះធម្មចក្រដ៏បវរ គង់នៅក្នុងទីនោះៗ មានក្រុងរាជគ្រឹះជាដើម បេតវត្ថុនោះៗ ក៏ឡើងកាន់ទេសនា ដោយធ្វើកម្មនិងផលនៃកម្ម របស់សត្វទាំងឡាយ ឲ្យប្រចក្ស ដោយការសាកសួរ និងការឆ្លើយអត្ថុប្បត្តិហេតុនោះៗ ដោយច្រើនហេតុនោះ ក្នុងទីនេះទេសនានោះ ជាការឆ្លើយធ្ងន់ដោយទូទៅនៃបទទាំងឡាយថា **កេនេ ភាសិតំ** ( បេតវត្ថុនេះនរណាពោល ) ដូច្នេះជាដើម ជាលំដាប់ដំបូង ។ តែដោយមិនទូទៅ ទេសនានេះនឹងមកក្នុងអត្ថវណ្ណនានៃរឿងនោះៗឯង ។

បេតវត្ថុនេះទាក់ទងក្នុងសុត្តន្តបិដក ក្នុងបណ្តាបិដក ៣ គឺ វិនយបិដក សុត្តន្តបិដកនិងអភិធម្មបិដក ទាក់ទងក្នុងខុទ្ទកនិកាយ ក្នុងនិកាយ ៥ គឺ ទីឃ-និកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយនិងខុទ្ទកនិកាយ សង្គ្រោះចូលក្នុងគាថា ក្នុងបណ្តានវង្គសត្ថុសាសនៈ គឺសុត្តៈ គេយ្យ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្ម និងវេទល្លៈ សង្គ្រោះចូលក្នុងបកិណ្ណកធម្មក្ខន្ធ ក្នុងបណ្តាធម្មក្ខន្ធ ៨៤០០០ ដែលព្រះអានន្ទ ជាភណ្ឌាគា-រិកៈ បានប្តេជ្ញាទុកយ៉ាងនេះថា

> សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ ( ក្នុងហឫទ័យ ) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះមាន ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ម៉ឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ដូច្នេះ ។

ពោលដោយកាណវារ មានត្រឹម ៤ ភាណវារ ពោលដោយវគ្គ មាន ៤ វគ្គ គឺឧរគវគ្គ ១ ឧព្វរិវគ្គ ១ ចូឡវគ្គ ១ មហាវគ្គ ១ ។ ក្នុង ៤ វគ្គនោះ វគ្គទី ១ មាន ១២ រឿង វគ្គទី ២ មាន ១៣ រឿង វគ្គទី ៣ មាន ១០ រឿង វគ្គទី ៤ មាន ១៦ រឿង បើសរុបរឿង ប្រដាប់ដោយរឿង ៥១ ។ ក្នុងបណ្តាវគ្គនៃរឿងនោះ ឧរគវគ្គជាវគ្គដើម ។ ក្នុងបណ្តារឿង ខេត្តូបមប្រេតជារឿងដើម គាថានៃរឿងដើមនោះ មានពាក្យផ្តើមថា **ខេត្តូបមា អរហន្តោ** ជាដើម ជាគាថាដំបូង ។

# ឧរគវគ្គទី ១

## អដ្ឋកថា ខេត្តូបមាប្រេត

[១] ព្រះមានព្រះភាគកាលទ្រង់គង់នៅក្នុងវត្តវេឡុវនកលន្ទកនិវាបវិហារ ជិតក្រុងរាជគ្រឹះ ទ្រង់ប្រារព្ធសេដ្ឋីបុត្តម្នាក់ ទើបត្រាស់រឿងនោះ ដូចតទៅ

បានឮថា ក្នុងក្រុងរាជគ្រឹះ មានសេដ្ឋីម្នាក់ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានគ្រឿងឧបករណ៍នៃទ្រព្យដែលគួរជាទីត្រេកអរ សន្ទឹកសន្ធាប់ សន្សំទ្រព្យទុកច្រើនកោដិ ។ សេដ្ឋីនោះ មានកូនប្រុសម្នាក់ ជាទីស្រឡាញ់ ជាទីពេញចិត្ត ។ កាលកូនប្រុសនោះធំដឹងក្តី មាតាបិតានាំគ្នាគិតយ៉ាងនេះថា បើកូនរបស់យើងចាយទ្រព្យ ឲ្យអស់មួយថ្ងៃមួយពាន់រាល់ៗថ្ងៃ អស់ ១០០ ឆ្នាំ ក៏ទ្រព្យដែលសន្សំទុកនេះ មិនអស់ទៅឡើយ ។ ប្រយោជន៍អ្វីដោយការឲ្យកូនរបស់យើងលំបាក ក្នុងការសិក្សាសិប្បៈ សូមបុត្តនេះកុំលំបាកកាយនិងចិត្ត បរិភោគសម្បត្តិតាមសប្បាយចុះ ដូច្នេះហើយទើបមិនឲ្យបុត្តសិក្សាសិប្បៈ ។ កាលកូននោះចម្រើនវ័យហើយ មាតាបិតា បាននាំទារិកាសម្បូរដោយត្រកូល រូបរាង ក្មេង ស្អាត ជាអ្នកឆ្អែតដោយកាមគុណ បែរមុខចេញអំពីធម្មសញ្ញា ។ សេដ្ឋីបុត្តនោះ អភិរម្យជាមួយស្រីនោះ មិនកើតសូម្បីការគិតដល់ធម៌ មិនមានសេចក្តីអើពើក្នុងសមណព្រាហ្មណ៍និងបុគ្គលដែលគួរគោរព ហោមរោមដោយពួកអ្នកលេង ពោរពេញទៅដោយតម្រេក សេចក្តីត្រេកអរ ជាប់ក្នុងកាមគុណ ៥ ជាអ្នកងងឹតដោយមោហៈ ឲ្យពេលវេលាកន្លងទៅ កាលមាតាបិតាអនិច្ចកម្ម ឲ្យវត្ថុដែលគួរប្រាថ្នាដល់អ្នករាំ អ្នកច្រៀងជាដើម បំផ្លាញទ្រព្យឲ្យអន្តរធានទៅ មិនយូរប៉ុន្មាន ក៏អស់

ទ្រព្យផ្ទាល់ខ្លួន ខ្ជីបុលអ្នកដទៃចិញ្ចឹមជីវិត ត្រូវម្ចាស់បំណុលតឹងទារ ក៏ត្រូវឲ្យស្រែចម្ការនិងផ្ទះជាដើមរបស់ខ្លួន ដល់ពួកម្ចាស់បំណុលទាំងនោះ កាន់នូវអំបែង ដើរសូមទានបរិភោគ ស្នាក់នៅតាមសាលាជនអនាថា ក្នុងព្រះនគរនោះឯង ។

ថ្ងៃមួយ ពួកចោរមកប្រជុំគ្នា ពោលនឹងបុរសនោះយ៉ាងនេះថា នែអ្នកដ៏ចម្រើន ប្រយោជន៍អ្វីដោយការរស់នៅលំបាកយ៉ាងនេះ អ្នកនៅក្មេង មានកម្លាំងសម្បុរ ហេតុអ្វី ទើបដូចជាមានដៃនិងជើងពិការ មករួមជាមួយពួកយើង ដើរប្លន់ទ្រព្យពួកអ្នកស្រុក រស់នៅសប្បាយជាង ។ បុរសនោះពោលថា ខ្ញុំមិនចេះវិធីសាស្រ្តក្នុងការធ្វើចោរកម្ម ។ ពួកចោរឆ្លើយថា ពួកយើងនឹងជួយបង្រៀន ឲ្យតែអ្នកស្តាប់ពាក្យរបស់ពួកយើងតែម្យ៉ាង ។ បុរសនោះទទួលពាក្យហើយ បានទៅជាមួយពួកចោរទាំងនោះ ។ លំដាប់នោះ ពួកចោរបានឲ្យបុរសនោះកាន់ដំបងធំ[១]កាត់ទីតឡើងលើផ្ទះ ឲ្យបុរសនោះ ឈរត្រង់មាត់ច្រក ហើយបង្រៀនថា បើមនុស្សដទៃមកក្នុងទីនេះ ចូរអ្នកយកដំបងនេះវាយបុគ្គលនោះៗឲ្យស្លាប់ ។ គាត់ជាមនុស្សល្ងង់ខ្លៅ ដូចជាមនុស្សខ្វាក់ មិនដឹងវត្ថុជាប្រយោជន៍និងមិនជាប្រយោជន៍ បានឈរក្នុងទីនោះ សម្លឹងមើលការមករបស់អ្នកដទៃតែម្យ៉ាង ។ ឯពួកចោរចូលទៅកាន់ផ្ទះហើយ កាន់យកវត្ថុដែលគួរកាន់យក គ្រាន់តែមនុស្សក្នុងផ្ទះដឹងខ្លួនប៉ុណ្ណោះ ក៏នាំគ្នារត់ទៅក្នុងទិសផ្សេងៗ ម្នាក់មួយផ្លូវៗ ។ ពួកមនុស្សក្នុងផ្ទះក្រោកឡើង ក៏នាំគ្នារត់ដេញដោយ

---

១- មុគ្គរំ ក្នុងនាគប្រេតលោកប្រែថា ដំបង ទើបយើងកាន់យកតាមនោះ ។

របស់ ហើយក្រឡេកមើលក្នុងទិសផ្សេងៗ ក៏ឃើញបុរសនោះឈរត្រង់ប្រក ទ្វារ ក៏ស្រែកថា វ៉ឺយមនុស្សអាក្រក់ ហើយនាំគ្នាចាប់ យកដំបងជាដើម វាយដៃនិងជើង ហើយក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ បុរសនេះ ជាចោរ ពួកទូលបង្គំចាប់បានត្រង់មាត់ប្រក ។ ព្រះរាជាទ្រង់មានបញ្ជាឲ្យអ្នក រក្សានគរដាក់ទោស ដោយព្រះតម្រាស់ថា ចូរកាត់ក្បាលរបស់បុរសនេះ ។ អ្នករក្សានគរ ទទួលស្នងព្រះបរមរាជឱង្ការហើយ ទើបឲ្យចាប់បុរសនោះចង ក្រពាត់ស្ទាបសេកយ៉ាងមាំទាំ ពាក់កម្រងផ្កាពណ៌ក្រហមត្រង់ក មានក្បាល ប្រឡាក់ដោយកម្ទេចឥដ្ឋ បណ្តើរស្រែកអាក្រោស មួយអន្ទើដោយសំឡេង ស្គរ វាយផ្ចាញ់ផ្ចាល ចេញតាមផ្លូវរថ បញ្ចប់តាមផ្លូវរថ ចេញអំពីផ្លូវបែក ជា ៤ បញ្ចប់ត្រង់ផ្លូវបែកជា ៤ វាយដោយផ្តៅ បណ្តើរទៅកាន់ទីប្រហារ ជីវិត ។ មហាជននាំគ្នាភ្ញាក់ផ្អើលថា ក្នុងព្រះនគរនេះគេចាប់ចោរប្លន់បាន ។

សម័យនោះ ក្នុងព្រះនគរនោះ មានស្រីនគរសោភិនីម្នាក់ឈ្មោះ សុលសា ឈរត្រង់ប្រាសាទ មើលតាមបង្អួច ឃើញបុរសនោះត្រូវគេបណ្តើរទៅយ៉ាង នោះ គិតថា បុរសនេះ ធ្លាប់មានគេបម្រើក្នុងកាលមុន កើតនូវសេចក្តីករុណា ថា បុរសនេះ ធ្លាប់សោយសម្បត្តិជាច្រើនក្នុងនគរនេះឯង ឥឡូវនេះ ដល់នូវ សេចក្តីវិនាសដល់ម្ល៉េះ ទើបយកនំ ( អន្សម ) ៤ និងទឹកផឹកទៅឲ្យ ហើយ ប្រាប់អ្នករក្សាព្រះនគរថា សូមលោកបង្អង់សិន ទម្រាំបុរសនេះ បរិភោគនំ ទាំងនេះ ហើយផឹកទឹកសិន ។

ក្នុងវេលានោះ ព្រះមហាមោគ្គល្លានប្រមើលមើលដោយទិព្វចក្ខុ ឃើញ

បុរសនោះដល់នូវសេចក្តីវិនាស ដោយកម្លាំងនៃករុណាជាស់តឿន គិតថា បុរសនេះមិនធ្លាប់ធ្វើបុណ្យ សន្សំតែបាប ព្រោះហេតុនោះ បុរសនេះនឹងកើតក្នុងនរក កាលបើអាត្មាអញទៅ គេនឹងប្រគេននំនិងទឹក ហើយកើតក្នុងភុម្មទេវតា បើដូច្នោះ អាត្មាអញគប្បីជាទីពឹងរបស់បុរសនេះ ដូច្នេះហើយ បានទៅប្រាកដខាងមុខបុរសនោះ ក្នុងខណៈដែលគេនាំទឹកផឹកនិងនំមកឲ្យ ។

បុរសនោះឃើញព្រះថេរៈ ក៏មានចិត្តជ្រះថ្លា គិតថា អញត្រូវមនុស្សទាំងនេះសម្លាប់ ក្នុងកាលឥឡូវនេះឯង ប្រយោជន៍អ្វីដោយនំដែលអញបរិភោគចូលទៅ ផលទាននេះ នឹងបានជាស្បៀងសម្រាប់អញក្នុងបរលោក ទើបប្រគេននំនិងទឹកដល់ព្រះថេរៈ ដើម្បីនឹងចម្រើនការជ្រះថ្លា របស់បុរសនោះ កាលបុរសនោះកំពុងសម្លឹងមើលនោះឯង ព្រះថេរៈក៏អង្គុយក្នុងទីនោះ ឆាន់នំនិងទឹកហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។ ចំណែកបុរសនោះ ត្រូវពេជ្ឈឃាតនាំទៅកាន់ទីប្រហារ ហើយកាត់ក្បាល ។

ដោយបុណ្យដែលបុរសនោះធ្វើទុកក្នុងព្រះមហាមោគ្គល្លានត្ថេរ ដែលជាបុញ្ញក្ខេត្តដ៏កំពូល សូម្បីជាបុគ្គលគួរកើតក្នុងទេវលោកជាន់ខ្ពស់ តែព្រោះមានចិត្តសៅហ្មង ក្នុងពេលជិតស្លាប់ ព្រោះសេចក្តីស្នេហា ដែលគិតដល់នាងសុលសាថា អញបានទេយ្យធម៌នេះ ព្រោះអាស្រ័យនាងសុលសា ដូច្នោះ កាលនឹងកើតជាពួកទេវតាជាន់ទាប ទើបកើតជារុក្ខទេវតាត្រង់ដើមជ្រៃធំ មានម្លប់ត្រជាក់ក្បែរជើងភ្នំ ។

អាចារ្យពួកខ្លះពោលថា បានឮថា បើក្នុងបឋមវ័យ បុរសនោះខ្វល់ខ្វាយ

ក្នុងការតម្កល់វង្សត្រកូលសោត គេនឹងក្លាយជាសេដ្ឋីដែលក្រៃលែងជាងសេដ្ឋីទាំងឡាយ ក្នុងព្រះនគរនោះឯង បើខ្វល់ខ្វាយក្នុងមជ្ឈិមវ័យ នឹងកើតជាសេដ្ឋីក្នុងវ័យកណ្តាល បើខ្វល់ខ្វាយក្នុងបច្ឆិមវ័យ នឹងបានជាសេដ្ឋី ក្នុងវ័យចុងក្រោយ ។ តែបើក្នុងបឋមវ័យគេបានបួសសោត ក៏នឹងបានជាព្រះអរហន្ត បើបួសក្នុងមជ្ឈិមវ័យ នឹងបានជាសកទាគាមី ឬអនាគាមី បើបួសក្នុងបច្ឆិមវ័យ នឹងបានជាព្រះសោតាបន្ន ។ តែព្រោះគេប្រឡូកប្រឡំដោយបាបមិត្ត ទើបគេក្លាយជាអ្នកលេងស្រី លេងស្រា ត្រេកអរក្នុងទុច្ចរិត ជាបុគ្គលមិនអើពើសាបសូន្យចាកសម្បត្តិទាំងពួង ដល់នូវសេចក្តីវិនាសយ៉ាងធំដោយលំដាប់ ។

សម័យក្រោយមក ទេវបុត្តនោះឃើញនាងសុលសាទៅកាន់ឧទ្យាន កើតនូវកាមរាគៈ ធ្វើឲ្យទីនោះងងឹត ហើយនាំទៅកាន់កពរបស់ខ្លួន សម្រេចការនៅរួមគ្នាអស់ ៧ ថ្ងៃ ហើយបានណែនាំខ្លួនដល់នាង ។ មាតារបស់នាងសុលសា កាលមិនឃើញកូនស្រី យំរត់ទៅកាន់ទិសផ្សេងៗ ។ មហាជនឃើញស្ត្រីនោះ ក៏ពោលថា ព្រះមហាមោគ្គល្លានជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន គប្បីដឹងគតិរបស់នាង នាងគប្បីចូលទៅរកលោក ហើយសាកសួរចុះ ស្ត្រីនោះទទួលពាក្យថា សាធុ ហើយចូលទៅរកព្រះមហាមោគ្គល្លានសាកសួរសេចក្តីនោះ ។ ព្រះថេរៈពោលថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីនេះ កាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ ក្នុងវត្តវេឡុវនមហាវិហារ នាងនឹងឃើញក្នុងទីបំផុតនៃបរិស័ទ ។ លំដាប់នោះ នាងសុលសាបានពោលនឹងទេវបុត្តនោះថា ការដែលខ្ញុំនៅក្នុងកពរបស់លោកមិនសមគួរ ថ្ងៃនេះជាថ្ងៃទី ៧

*មាតារបស់ខ្ញុំ កាលមិនឃើញខ្ញុំ ក៏នឹងកន្ទក់កន្ទេញ សោយសោក សូមលោកនាំខ្ញុំទៅកាន់ទីនោះចុះ ។ ទេវបុត្តនាំនាងទៅដាក់ខាងចុងបរិស័ទ ក្នុងកាលដែលព្រះមានព្រះភាគកំពុងសម្តែងធម៌ក្នុងវត្តវេឡុវ័ន បានឈរមិនប្រាកដខ្លួន ។*

*លំដាប់នោះ មហាជនឃើញនាងសុលសាហើយ ពោលយ៉ាងនេះថា នែនាងសុលសា នាងទៅឯណាអស់ ៧ ថ្ងៃ មាតារបស់នាង កាលមិនឃើញនាង ក៏បានដល់នូវការកន្ទក់កន្ទេញ សោយសោក ដូចមនុស្សឆ្កួត ទើបនាងប្រាប់រឿងនោះដល់មហាជន កាលមហាជនសួរថា បុរសនោះធ្វើសេចក្តីខ្វល់ខ្វាយតែក្នុងបាប មិនធ្វើកុសល គង់កើតជាទេវតាបាន ។ នាងសុលសាពោលថា គេបានប្រគេននំនិងទឹកផឹកដែលខ្ញុំឲ្យ ដល់ព្រះមហាមោគ្គល្លាន ដោយបុណ្យនោះទើបកើតជាទេវបុត្ត មហាជនបានស្តាប់ដូច្នោះ ក៏កើតនូវអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់មាន គិតថា បុរសនោះសូម្បីធ្វើបុញ្ញកម្មតិចតួច ក្នុងព្រះអរហន្តទាំងឡាយ ជាបុគ្គលឈ្មោះថា ជាបុញ្ញក្ខេត្តដ៏កំពូលនៃសត្វលោកទើបនាំសត្វមកកើតជាទេវបុត្ត ដូច្នេះហើយ ទើបបានសោយនូវបីតិនិងសោមនស្សដ៏ឧឡារ ។ ភិក្ខុទាំងឡាយ ទូលសេចក្តីនោះ ដល់ព្រះមានព្រះភាគ ព្រោះអត្ថុប្បត្តិហេតុនេះ ព្រះមានព្រះភាគទ្រង់ក៏បានភាសិតគាថានេះថា*

*ពួកព្រះអរហន្តដូចស្រែ ពួកទាយកដូចអ្នកភ្ជួររាស់ ទេយ្យធម៌ដូចពូជ ផលតែងកើតមកអំពីព្រះអរហន្តនិងទាយកនិងទេយ្យធម៌នុ៎ះ ឯពូជនិងការភ្ជួររាស់និងស្រែនុ៎ះ តែងមានដល់ពួកប្រេតទាំងឡាយផង ដល់ទាយកផង ប្រេតទាំងឡាយតែងបរិភោគ*

នូវផលនៃទាននោះ ទាយកអ្នកឲ្យទាន តែងចម្រើនដោយ
បុណ្យ ក្នុងលោកនេះ បុគ្គលធ្វើកុសលហើយ គួរតែបូជា
ចំពោះប្រេតទាំងឡាយ ព្រោះថា បុគ្គលធ្វើកុសលកម្មដ៏ចម្រើន
រមែងទៅកាន់ឋានសួគ៌ ។

ក្នុងបទទាំងនោះ បទថា **ខេត្តូបមា** បានដល់ ឈ្មោះថា ស្រែ ព្រោះជាទីជ្រកកោន គឺរក្សាពូជដែលបាចទៅ គឺសាបព្រោះ ដោយធ្វើការៈឲ្យផលច្រើន បានដល់ ស្ថានទីដែលគប្បីដុះនៃពូជ មានស្រូវសាលីជាដើម ។ ព្រះអរហន្តទាំងឡាយ ឈ្មោះថា **ខេត្តូបមា** ព្រោះមានស្រែជាឧបមា អធិប្បាយថា ដូចជាភ្លឺស្រែ ។ បទថា **អរហន្តោ** បានដល់ ជាអ្នកអស់អាសវៈទាំង-ឡាយ ។ ពិតហើយ បុគ្គលដែលអស់អាសវៈទាំងឡាយនោះ លោកហៅថា ព្រះអរហន្ត ព្រោះកម្ចាត់កាំនៃកិលេសជាដើមនិងកាំនៃសង្សារចក្ក ព្រោះជាអ្នកឆ្ងាយចាកកិលេសជាដើមនោះឯង ព្រោះជាបុគ្គល គួរដល់ទេយ្យធម៌ដែលមានបច្ច័យជាដើមនិងព្រោះមិនមានទីកំបាំងក្នុងការធ្វើបាប ។

ពិតហើយ ក្នុងសេចក្តីនេះ សន្តានរបស់ព្រះខីណាស្រព វៀរចាកទោសមានលោភៈជាដើម ប្រកបដោយបច្ច័យដទៃ មានកាលជាដើម ក្នុងកាលបុគ្គលសាបព្រោះនូវពូជ គឺទេយ្យធម៌ដែលគាត់តែងល្អហើយ រមែងមានផលច្រើនដល់ទាយក ប្រៀបដូចស្រែវៀរចាកទោស មានស្មៅជាដើម ប្រកបដោយបច្ច័យដទៃ មានឧតុនិងទឹកជាដើម ក្នុងកាលព្រោះនូវពូជ ដែលគេសម្រិតសម្រាំងយ៉ាងល្អ រមែងមានផលច្រើនដល់អ្នកស្រែ ដូច្នោះ ។ ដោយហេតុ

នោះ ទើបព្រះមានព្រះភាគត្រាស់ថា **ខេត្តូបមា អរហន្តោ** ដូច្នេះជាដើម នេះជានិទ្ទេសយ៉ាងឧក្រិដ្ឋ ព្រោះមិនបដិសេធថា សូម្បីព្រះអរិយបុគ្គល មានព្រះសេក្ខៈជាដើមថា ជាខេត្តរបស់ទាយកនោះ ។

បទថា **ទាយកា** បានដល់ អ្នកឲ្យ គឺអ្នកបរិច្ចាគបច្ច័យ មានចីវរជាដើម ។ អធិប្បាយថា បុគ្គលលះបង់ គឺកាត់កិលេស មានលោភៈជាដើមក្នុងសន្តានរបស់ខ្លួន ដោយបរិច្ចាគបច្ច័យ មានចីវរជាដើមនោះម្យ៉ាងទៀត បុគ្គលជម្រះនិងបុគ្គលរក្សាសន្តានរបស់ខ្លួនចាកកិលេស មានលោភៈជាដើមនោះ ។ បទថា **កស្សកូបមា** បានដល់ ដូចអ្នកស្រែ ។ អ្នកស្រែក្នុងស្រែស្រូវសាលីជាដើម កាលមិនប្រមាទដោយកិច្ច មានការព្រោះ ការបង្ហូរទឹកចូល ការបើកទឹកចេញ ការស្ទួងនិងការរក្សាជាដើម តាមគួរដល់ពេល រមែងបានទទួលផលនៃស្រូវដ៏ឧឡារនិងបរិបូណ៌ យ៉ាងណា ទាយកក៏ដូច្នោះ កាលមិនប្រមាទ ដោយបរិច្ចាគទេយ្យធម៌ និងការបដិបត្តិក្នុងព្រះអរហន្តទាំងឡាយ រមែងបានទទួលផលនៃទានដ៏ឧឡារ និងបរិបូណ៌ ។ ដោយហេតុនោះ ទើបលោកពោលថា ទាយកដូចអ្នកក្នុរាស់ ដូច្នេះជាដើម ។

បទថា **តីជូបមំ ទេយ្យធម្មំ** លោកពោលដោយលិង្គវិបល្លាស ។ អធិប្បាយថា ទេយ្យធម៌ដូចជាពូជ ។ ពិតហើយ ពាក្យថា **ទេយ្យធម្មំ** នេះជាឈ្មោះនៃវត្ថុដែលគប្បីឲ្យ ១០ យ៉ាង មានបាយនិងទឹកជាដើម ។ បទថា **ឯត្តោ និព្វត្តតេ ផលំ** សេចក្តីថា ផលនៃទាន រមែងកើតឡើងនិងកើតឡើងអំពីបរិច្ចាគទេយ្យធម៌របស់ទាយក ដល់បដិគ្គាហកៈនោះ និងរមែងប្រព្រឹត្ត

*ទៅដោយអំណាចការបន្តអស់កាលយូរ ។*

*ក្នុងទីនេះ ព្រោះហេតុដែលវត្ថុ មានបាយនិងទឹកជាដើម ដែលរៀបចំដោយចេតនាជាគ្រឿងបរិច្ចាគ មិនមែនភាវៈនៃវត្ថុក្រៅអំពីនេះ ព្រោះហេតុនោះ ទើបលោកចាត់ទេយ្យធម៌ដោយសព្ទថា* **ពីជូបមំ ទេយ្យធម្មំ** *ដូច្នេះ ។ ព្រោះហេតុនោះ គប្បីឃើញចេតនាជាគ្រឿងបរិច្ចាគ ដែលមានទេយ្យធម្មវត្ថុជាអារម្មណ៍នោះឯងថាជាពូជ ដោយអាងដល់ទេយ្យធម៌ ។ ពិតហើយចេតនាជាគ្រឿងបរិច្ចាគនោះ ឲ្យសម្រេចផល ផ្សេងដោយបដិសន្ធិជាដើម និងផ្សេងដោយអារម្មណ៍ដែលជានិស្សយប្បច្ច័យនៃបដិសន្ធិជាដើមនោះ មិនមែនទេយ្យធម៌ឡើយ ។*

*បទថា* **ឯតំ ពីជំ កសី ខេត្តំ** *បានដល់ ពូជតាមដែលពោលហើយ និងស្រែតាមដែលពោលហើយ ។ អធិប្បាយថា* **កសិ** *ពោលគឺបយោគក្នុងការសាបព្រោះពូជនោះក្នុងស្រែនោះ ។ ការគ្រប់ទាំង ៣ យ៉ាងនោះ ចាំបាច់ព្រោះដូច្នោះ ទើបលោកពោលថា* **បេតានំ ទាយកស្ស ច** *ជាដើម ។ បើទាយកឲ្យទានឧទ្ទិសឲ្យប្រេតទាំងឡាយ រមែងឲ្យកើតផលដល់ពួកប្រេត និងទាយក ។ បើមិនឲ្យទាន ឧទ្ទិសឲ្យពួកប្រេត រមែងមិនកើតផល អធិប្បាយថា ពូជនោះ ការសាបព្រោះនោះ និងស្រែនោះ តែងមានដើម្បីឧបការៈដល់ទាយកប៉ុណ្ណោះ ។ ឥឡូវនេះ ដើម្បីសម្តែងដល់ឧបការៈ ទើបលោកពោលថា ប្រេតទាំងឡាយ តែងបរិភោគនូវផលនៃទាននោះ ទាយកអ្នកឲ្យទាន តែងចម្រើនដោយបុណ្យ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **តំ បេតា បរិភុញ្ជន្តិ** សេចក្ដីថា កាលទាយកថ្វាយទានឧទ្ទិសដល់ពួកប្រេត បើស្រែ ការសោបព្រោះ និងពូជតាមដែលពោលហើយសម្បូរ និងមានការអនុមោទនា ពួកប្រេតរមែងបរិភោគផលទានដែលសម្រេចដល់ប្រេត ។ បទថា **ទាតា បុញ្ញេន វឌ្ឍតិ** សេចក្ដីថា បុគ្គលអ្នកឲ្យរមែងចម្រើនដោយផលនៃបុណ្យ មានភោគសម្បត្តិជាដើម ក្នុងទេវតានិងមនុស្សដែលមានបុណ្យសម្រេចអំពីទានរបស់ខ្លួនជានិមិត្ត ។ ពិតហើយ សូម្បីផលនៃបុណ្យ លោកក៏ហៅថា បុណ្យ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចម្រើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយយ៉ាងនេះ ។ បទថា **ឥទេវ កុសលំ កតំ** សេចក្ដីថា សន្សំបុណ្យដែលសម្រេចដោយទាន ដោយអំណាចការឧទ្ទិសដល់ពួកប្រេតឈ្មោះថា កុសល ព្រោះអត្ថថា មិនមានទោស និងមានសុខជាផល ក្នុងអត្តភាពនេះឯង ។ បទថា **បេតេ ច បដិបូជិយ** សេចក្ដីថា ទទួលដោយទានឧទ្ទិសប្រេត ឲ្យប្រេតទាំងនោះផុតចាកទុក្ខដែលសោយ ។ ពិតហើយ ទានដែលឲ្យឧទ្ទិសប្រេត ឈ្មោះថា បូជាប្រេតទាំងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ការបូជា ឈ្មោះថាញាតិទាំងឡាយបានធ្វើហើយដល់ពួកយើង និងថា ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ មហារាជបានធ្វើហើយ ។ ដោយ ច សព្ទ ក្នុងបទថា **បេតេ ច** នេះ ចាត់ចូលក្នុងអានិសង្សនៃទានដែលជាបច្ចុប្បន្ន មានយ៉ាងនេះថា បុគ្គលអ្នកឲ្យរមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីទុកចិត្ត ជាអ្នកលើកតម្កើង ជាអ្នកដែលគួរគោរព ជាអ្នក

ដែលវិញ្ញូជនគួរសរសើរ គួរប្រារព្ធដល់ ។ បទថា **សគ្គញ្ច កមតិ ឋានំ កម្មំ កត្វាន ភទ្ទកំ** សេចក្ដីថា ធ្វើកល្យាណធម៌ គឺកុសលកម្ម រមែងឈានដល់ គឺចូលដល់ ដោយអំណាច ការចូលដល់ទេវលោក ដែលជាទីកើតនៃពួកមនុស្សដែលបានធ្វើបុណ្យទុក ដែលបានឈ្មោះថា **សគ្គ** ព្រោះមាន អារម្មណ៍ល្អដោយឋានៈ ១០ ប្រការ មានអាយុទិព្វជាដើម ។

ក្នុងបទទាំងនេះ លោកពោលថា **កុសលំ កត្វា** ( បុគ្គលធ្វើកុសលហើយ ) ពោលដដែលថា **កម្មំ កត្វាន ភទ្ទកំ** ( បុគ្គលធ្វើកុសលកម្ម ) គប្បីឃើញថា ដើម្បីសម្ដែងថា សូម្បីបរិច្ចាគធម៌ជាទាន ដោយការឲ្យចំណែកបុណ្យ ដូចបរិច្ចាគទេយ្យធម៌ ចាត់ជាកុសលកម្មដែលសម្រេចដោយទានដូចគ្នា ។ ក្នុងទីនេះ អាចារ្យពួកខ្លះពោលថា ព្រះអរហន្ត លោកបំណងយកថា **បេត** ពាក្យនោះ ត្រឹមតែជាមតិរបស់កេចិអាចារ្យទាំងនោះ ព្រោះថា ព្រះខីណាស្រពជាប្រេតមិនមានឡើយ ព្រោះព្រះខីណាស្រពទាំងនោះ មិនប្រកបការៈ មានពូជជាដើម ដូចទាយក និងព្រោះអ្នកកើតក្នុងកំណើតប្រេតមានការៈ មានពូជជាដើមប្រកបទុក ។

ក្នុងកាលចប់ទេសនា សត្វ ៨៤០០០ រាប់ទាំងទេវបុត្តនិងនាងសុលសា បានត្រាស់ដឹងធម៌ហើយ ដូច្នេះ ។

### អដ្ឋកថា ខេត្តូបមាប្រេតចប់

## រឿង សូករប្រេត ទី ២

[ ២ ] ( ព្រះនារទត្ថេរសួរថា ) កាយទាំងមូលរបស់អ្នក មានសម្បុរដូចជាមាស មានរស្មីភ្លឺស្វាង សព្វទិស តែមាត់របស់អ្នកដូចមាត់ជ្រូក តើអំពីភពមុន អ្នកបានធ្វើអំពើដូចម្ដេច ។

( ប្រេតតបថា ) បពិត្រព្រះនារទៈ ខ្ញុំជាបុគ្គលបានសង្រួមកាយ តែមិនបានសង្រួមវាចា ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ដូចលោកម្ចាស់បានឃើញស្រាប់ហើយ បពិត្រព្រះនារទៈ ខ្ញុំសូមទូលរឿងនោះ ដល់លោកម្ចាស់ រឿងនេះលោកម្ចាស់បានឃើញ ដោយខ្លួនឯងស្រាប់ហើយលោកកុំធ្វើបាបដោយមាត់ កុំមានមាត់ដូចមាត់ជ្រូកឡើយ ។

**ចប់ រឿងសូករប្រេត ទី ២ ។**

## អដ្ឋកថា សូករប្រេត

[ ២ ] កាលព្រះសាស្ដាទ្រង់អាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ទ្រង់ប្រារព្ធប្រេត មានមុខដូចជ្រូកមួយរូប ទើបត្រាស់ពាក្យផ្ដើមថា **កាយោ តេ សព្វសោ វណ្ណោ** ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាកស្សបៈ មានភិក្ខុមួយរូប ជាអ្នកសង្រួមកាយ តែមិនសង្រួមវាចា ជេរបរិភាសភិក្ខុទាំងឡាយ ស្លាប់ហើយទៅកើតក្នុងនរក ឆេះក្នុងនរកនោះអស់មួយពុទ្ធន្តរចុតិអំពីនរកនោះហើយ ក្នុងពុទ្ធុប្បាទកាលនេះ ដោយសេសសល់ផលកម្មនោះឯង កើតជាប្រេត ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ត្រង់ជើងភ្នំគិជ្ឈ

កូដ ក្បែរក្រុងរាជគ្រឹះ ។ សរីរៈរបស់ប្រេតនោះ មានពណ៌ដូចមាស តែមុខមាត់របស់ប្រេតនោះដូចមុខជ្រូក លំដាប់នោះ ព្រះនារទៈនៅត្រង់ភ្នំគិជ្ឈកូដ សម្អាតរាងកាយអំពីព្រលឹម កាន់បាត្រនិងចីវរ កំពុងត្រាច់បិណ្ឌបាត ទៅកាន់ក្រុងរាជគ្រឹះ ជួបប្រេតនោះត្រង់កណ្ដាលផ្លូវ កាលសួរដល់កម្មដែលប្រេតនោះធ្វើ ទើបពោលថា

កាយទាំងមូលរបស់អ្នក មានសម្បុរដូចជាមាស មានរស្មីភ្លឺ
ស្វាងសព្វទិស តែមាត់របស់អ្នកដូចមាត់ជ្រូក តើអំពីកពមុន
អ្នកបានធ្វើអំពើដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **កាយោ តេ សព្វសោ វណ្ណោ** សេចក្ដីថា កាយ គឺសរីរៈរបស់អ្នក មានពណ៌ដូចមាស គឺដូចមាសទឹកដប់ ។ បទថា **សព្វា ឱភាសតេ ទិសា** សេចក្ដីថា ពន្លឺកាយរបស់អ្នកភ្លឺរុងរឿងសព្វទិស ដោយជុំវិញ ។ ម្យ៉ាងទៀត ក្នុងពាក្យថា **ឱភាសតេ** នេះ មានហេតុជាគ្រឿង ឈមចុះខាងក្នុងជាអត្ថ គប្បីឃើញសេចក្ដីថា កាយរបស់អ្នកមានពណ៌ដូចមាស ភ្លឺស្វាង រុងរឿងសព្វទិស ។ បទថា **មុខំ តេ សូករស្សេវ** បានដល់ មុខមាត់របស់អ្នក ដូចមុខជ្រូក អធិប្បាយថា មុខមាត់របស់អ្នកដូចមុខរបស់សត្វជ្រូក ។ ដោយបទថា **កឹ កម្មមកាសិ បុរេ** សេចក្ដីថា ព្រះនារទៈសួរថា កាលមុន គឺក្នុងអតីតជាតិ អ្នកធ្វើកម្មអ្វី ។ ប្រេតនោះ ត្រូវព្រះថេរៈសួរដល់កម្មដែលខ្លួនធ្វើយ៉ាងនេះ កាលនឹងឆ្លើយដោយគាថា ទើបពោលថា

បពិត្រព្រះនារទៈ ខ្ញុំជាបុគ្គលបានសង្រួមកាយ តែមិនបាន
សង្រួមវាចា ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនេះ
ដូចលោកម្ចាស់បានឃើញស្រាប់ហើយ ។

ក្នុងបទទាំងនោះ បទថា **កាយេន សញ្ញតោ អាសឹ** សេចក្តីថា ខ្ញុំសង្រួមដោយការសង្រួមកាយ គឺបានជាអ្នកសង្រួមដោយល្អ ដោយការសង្រួមកាយទ្វារ ។ បទថា **វាចាយាសិមសញ្ញតោ** សេចក្តីថា តែខ្ញុំមិនបានសង្រួមវាចា គឺជាបុគ្គលប្រកបដោយការមិនសង្រួមផ្លូវវាចា ។ បទថា **តេន** បានដល់ ព្រោះការសង្រួមនិងការមិនសង្រួមទាំង ២ យ៉ាងនោះ ។ បទថា **មេ** ប្រែថា របស់ខ្ញុំ ។ បទថា **ឯតាទិសោ វណ្ណោ** បានដល់ រស្មីកាយនៃខ្ញុំបែបនេះ គឺដូចលោកម្ចាស់ឃើញច្បាស់ហើយនេះឯង ។ មានវាចាប្រកបសេចក្តីថា ខ្ញុំមានកាយមានទ្រង់ទ្រាយដូចមនុស្ស មានពណ៌ដូចមាសតែមានមាត់ដូចមាត់ជ្រូក ។ **វណ្ណ** សព្ទ ក្នុងគាថានេះ គប្បីឃើញថា ប្រើក្នុងអត្ថថា ពណ៌សម្បុរនិងទ្រង់ទ្រាយ ។

ប្រេតត្រូវព្រះថេរៈសួរយ៉ាងនេះ កាលឆ្លើយតាមពាក្យលោកហើយកាលធ្វើសេចក្តីនោះឯងឲ្យជាហេតុ ហើយដាស់តឿនព្រះថេរៈ ទើបពោលថា

បពិត្រព្រះនារទៈ ខ្ញុំជាបុគ្គលបានសង្រួមកាយ តែមិនបាន
សង្រួមវាចា ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ
ដូចលោក ម្ចាស់បានឃើញស្រាប់ហើយ ។

ក្នុងបទទាំងនោះ បទថា **កាយេន សញ្ញតោ អាសឹ** សេចក្តីថា ខ្ញុំ

សង្រួមដោយការសង្រួមកាយ គឺបានជាអ្នកសង្រួមដោយល្អ ដោយការសង្រួមកាយទ្វារ បទថា **វាចាយាសិមសញ្ញតោ** សេចក្តីថា ខ្ញុំមិនបានសង្រួមវាចា គឺបានជាអ្នកប្រកបដោយការមិនសង្រួមវាចា ។ បទថា **តេន** បានដល់ ព្រោះការសង្រួមនិងការមិនសង្រួមទាំងពីរយ៉ាងនោះ ។ បទថា **មេ** ប្រែថា របស់ខ្ញុំ ។ បទថា **តាទិសោ វណ្ណោ** បានដល់ បពិត្រព្រះនារទៈ រស្មីកាយរបស់ខ្ញុំ មានសភាពបែបនេះ គឺដូចលោកម្ចាស់ឃើញប្រចក្សនោះឯង ។ មានវាចាប្រកបសេចក្តីថា ខ្ញុំមានកាយ មានទ្រង់ទ្រាយ ដូចមនុស្សមានពណ៌ដូចមាស តែមានមាត់ដូចមាត់ជ្រូក ។ **វណ្ណ** សព្ទ ក្នុងគាថានេះគប្បី ឃើញថា ប្រើក្នុងអត្ថថា ពណ៌សម្បុរនិងទ្រង់ទ្រាយ ។

ប្រេតត្រូវព្រះថេរៈសួរយ៉ាងនេះ កាលឆ្លើយសំណួរនេះហើយ និងកាលធ្វើសេចក្តីនោះឯងឲ្យជាហេតុ ហើយដាស់តឿនព្រះថេរៈ ទើបពោលគាថាថា

បពិត្រព្រះនារទៈ ខ្ញុំសូមទូលរឿងនោះដល់លោកម្ចាស់ រឿងនេះលោកម្ចាស់បានឃើញដោយខ្លួនឯងស្រាប់ហើយ លោកកុំធ្វើបាបដោយមាត់ កុំមានមាត់ដូចមាត់ជ្រូកឡើយ ។

បណ្តាបទទាំងនោះ បទថា **តំ** កែជា **តស្មា** ប្រែថា ព្រោះហេតុនោះ ។ បទថា **ត្យាហំ** កាត់បទជា **តេ អហំ** ។ ប្រេតហៅព្រះថេរៈដោយពាក្យថា បពិត្រព្រះនារទៈ ។ បទថា **ព្រូមិ** ប្រែថា ខ្ញុំនឹងប្រាប់ ។ បទថា **សាមំ** បានដល់ ចំពោះដោយខ្លួនឯង ។ ដោយបទថា **ឥទំ** ប្រេតពោលសំដៅដល់រាងកាយរបស់ខ្លួន ។ ក្នុងពាក្យនេះ មានអធិប្បាយដូច្នេះថា បពិត្រព្រះ

នារទៈ ព្រោះហេតុដែលរាងកាយរបស់ខ្ញុំ ចាប់ពីកដល់កាយខាងក្រោម មានទ្រង់ទ្រាយដូចមនុស្ស កាយកំណាត់ខាងលើ មានទ្រង់ទ្រាយដូចជ្រូក ដូចលោកម្ចាស់ឃើញស្រាប់ហើយ ព្រោះហេតុនោះ ខ្ញុំសូមដាស់តឿនលោក ដើម្បីចៀសវាងពាក្យសួរថា អ្នកពោលដូចម្តេច ទើបប្រេតពោលថា លោកកុំធ្វើបាបដោយមាត់ កុំមានមាត់ដូចមាត់ជ្រូកឡើយ ។

ក្នុងបទទាំងនោះ សព្ទថា **មា** ជានិបាត ប្រើក្នុងអត្ថបដិសេធ ។ បទថា **មុខសា** ប្រែថា ដោយមាត់ ។ សព្ទថា **ខោ** ប្រើក្នុងអវធារណៈ គឺឃាត់នូវអត្ថដទៃ អធិប្បាយថា លោកកុំធ្វើ គឺកុំធ្វើអំពើអាក្រក់ដោយវាចាឡើយ ។ ដោយបទថា **មា ខោ សូករមុខោ អហុ** នេះ ប្រេតបដិសេធចំពោះហេតុ ដោយសំដៅដល់ការបដិសេធផលថា មាត់ជ្រូកដូចខ្ញុំកុំបីមានឡើយ បើលោកជាមនុស្សមាត់រឹង ធ្វើអំពើអាក្រក់ដោយវាចាសោត លោកគប្បីមានមាត់ដូចជ្រូកដោយចំណែកមួយ ព្រោះហេតុនោះ លោកកុំធ្វើអាក្រក់ដោយមាត់ឡើយ ។

លំដាប់នោះ ព្រះនារទៈនិមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់មកអំពីបិណ្ឌបាត ខាងក្រោយអាហារ ក្រាបទូលសេចក្តីនោះដល់ព្រះសាស្តាដែលគង់ត្រង់កណ្តាលបរិស័ទ ៤ ។ ព្រះសាស្តាត្រាស់ថា ម្នាលនារទៈ តថាគតបានឃើញសត្វនោះយូរហើយ កាលទ្រង់ប្រកាសទោស ដ៏លាមកជាអនេកដែលអាស្រ័យវចីទុច្ចរិត និងអានិសង្សដែលទាក់ទងដោយវចីសុចរិត ទើបទ្រង់សម្តែងធម៌ ។ ទេសនានោះ មានប្រយោជន៍ដល់បរិស័ទដែលដល់ព្រម

ហើយនោះឯង ។

## អដ្ឋកថា សូករប្រេត ចប់

# រឿង បូតិមុខប្រេត ទី៣

[ ៣ ] ( ព្រះនារទត្ថេរសួរថា ) អ្នកទ្រទ្រង់នូវវណ្ណធាតុ គឺរាងកាយជាទិព្វដ៏ល្អ ឋិតនៅព្ធដ៏អាកាសវេហាស៍ ទាស់តែដង្កូវទាំងឡាយ ទំពាស៊ីនូវមាត់របស់អ្នកដែលមានក្លិនស្អុយ តើអំពីភពមុន អ្នកបានធ្វើអំពើដូចម្តេច ។

( ប្រេតតបថា ) ខ្ញុំជាសមណៈលាមក មានវាចាអាក្រក់ ប្រព្រឹត្តតបធម៌ មិនសង្រួមមាត់ ឯវណ្ណធាតុខ្ញុំបានហើយ ដោយតបធម៌ មាត់របស់ខ្ញុំមានក្លិនស្អុយព្រោះតែពោលពាក្យញុះញង់ ។ បពិត្រព្រះនារទៈ អំពើនោះលោកម្ចាស់បានឃើញខ្លួនឯងស្រាប់ហើយ អ្នកឈ្លាសទាំងឡាយ ជាអ្នកអនុគ្រោះ គប្បីពោលថា អ្នកកុំពោលពាក្យញុះញង់ កុំពោលពាក្យកុហក ទើបអ្នកនឹងបានជាទេវបុត្ត មានកាមតាមសេចក្តីប្រាថ្នា ។

ចប់ រឿងបូតិមុខប្រេត ទី ៣ ។

# អដ្ឋកថា បូតិមុខប្រេត

[ ៣ ] ព្រះសាស្តា កាលគង់ក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន ទ្រង់ប្រារព្ធប្រេតមានមាត់ស្អុយទើបត្រាស់ពាក្យផ្តើមថា **ទិព្វំ សុភំ ធារេសិ វណ្ណធាតុំ** ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថា កស្សបៈ មានកុលបុត្រ ២ រូប បួសក្នុងសាសនានៃព្រះមានព្រះភាគអង្គនោះ សម្បូរដោយសីលនិងអាចារ មានការប្រព្រឹត្តដុសខាត់ នៅដោយការព្រមព្រៀងគ្នា ក្នុងអាវាសជិតតំបន់មួយ ។ សម័យនោះ ភិក្ខុមួយរូបមានអធ្យាស្រ័យអាក្រក់ ចូលចិត្តញុះញង់ ចូលទៅកាន់លំនៅរបស់ភិក្ខុ ២ រូបនោះ ព្រះថេរៈធ្វើបដិសណ្ឋារៈជាមួយលោក ឲ្យទីសម្រាក ក្នុងថ្ងៃទី ២ ទើបនាំភិក្ខុនោះចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ពួកមនុស្សឃើញភិក្ខុទាំងនោះហើយ ធ្វើនូវសេចក្តីគោរពក្រៃលែង ក្នុងព្រះថេរៈទាំងនោះ ទទួលដោយអាហារ មានបបរនិងភត្តជាដើម ។ លោកចូលទៅកាន់វិហារគិតថា គោចរគាមនេះល្អហ្ន៎ ពួកមនុស្សក៏មានសទ្ធាជ្រះថ្លា ប្រគេនបិណ្ឌបាតនិងសេនាសនៈប្រណីត ។ វិហារនេះសម្បូរដោយម្លប់និងទឹក អញអាចនៅក្នុងទីនេះ បានយ៉ាងសប្បាយ តែកាលភិក្ខុទាំងនេះនៅក្នុងទីនេះ អញនឹងមិនសប្បាយ នឹងនៅដូចជាអន្តេវាសិក ណ្ហើយចុះ អញនឹងធ្វើឲ្យភិក្ខុទាំងនេះបែកគ្នា ហើយនៅក្នុងទីនេះ ។

ថ្ងៃមួយ កាលព្រះមហាថេរៈឲ្យឱវាទ ដល់ភិក្ខុទាំង ២ រូបហើយចូលទៅកាន់ទីសម្រាករបស់ខ្លួន ភិក្ខុដែលចូលចិត្តញុះញង់ នៅសម្ងំអស់មួយពេល ទើបចូលទៅរកព្រះមហាថេរៈ ថ្វាយបង្គំហើយ កាលព្រះថេរៈសួរថា ហេតុ

អ្វីលោកមកខុសកាល ទើបឆ្លើយថា ខ្ញុំមានរឿងមួយចង់និយាយ ព្រះថេរៈក៏អនុញ្ញាតថា និយាយចុះលោក ក៏ប្រាប់ថា បពិត្រលោកម្ចាស់ ព្រះថេរៈជាសម្លាញ់របស់លោកម្ចាស់ ក្នុងទីចំពោះមុខសម្តែងខ្លួនដូចជាមិត្ត លុះក្រោយខ្នង ក៏និយាយដើមដូចសត្រូវ ។ ព្រះថេរៈសួរថា គេនិយាយដូចម្តេចខ្លះ ក៏ប្រាប់ថា សូមលោកម្ចាស់ស្តាប់ ព្រះមហាថេរៈនោះ ពោលនូវទោសលោកម្ចាស់ថា ជាអ្នកអួត មានមាយា លាក់ពុត ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រះថេរៈឆ្លើយថា លោកកុំនិយាយយ៉ាងនេះឡើយ ភិក្ខុរូបនោះនឹងមិនពោលដល់ខ្ញុំយ៉ាងនោះទេ យើងស្គាល់លោកតាំងពីគ្រហស្ថមក លោកដឹងថា ខ្ញុំមានសីលជាទីស្រឡាញ់ មានកល្យាណធម៌ ។ ភិក្ខុនោះពោលថា លោកម្ចាស់គិតយ៉ាងនោះព្រោះលោកម្ចាស់មានចិត្តបរិសុទ្ធ សេចក្តីនោះ សមគួរដល់លោកម្ចាស់នោះឯង តែខ្ញុំមិនមានពៀរជាមួយព្រះមហាថេរៈនោះ រឿងអ្វីទើបខ្ញុំពោលពាក្យដែលព្រះមហាថេរៈមិនពោល ណ្ហើយចុះ លោកម្ចាស់នឹងដឹងក្នុងពេលក្រោយ ។ ឯព្រះថេរៈមានចិត្តគិតជាពីរ ព្រោះខ្លួនជាបុថុជ្ជន កើតសេចក្តីរង្កៀសថា ប្រហែលជាយ៉ាងនោះ ទើបរំសាយការទុកចិត្តបន្តិច ។ ភិក្ខុនោះជាបុគ្គលពាល ញុះញង់ព្រះមហាថេរៈ មុនហើយ ទៅញុះញង់ព្រះថេរៈមួយរូបទៀត ដោយន័យដូចពោលហើយនោះឯង ។ លំដាប់នោះ ព្រះថេរៈទាំង ២ ក្នុងថ្ងៃទី ២ មិននិយាយរកគ្នា កាន់បាត្រនិងចីវររៀងៗខ្លួន ចូលទៅបិណ្ឌបាតក្នុងស្រុក កាន់បិណ្ឌបាត មកធាន់ក្នុងទីសម្រាករៀងៗខ្លួន មិនបានធ្វើត្រឹមតែសាមីចិកម្មអស់មួយថ្ងៃ ក្នុងទីនោះឯង លុះរាត្រីអស់ហើយ ក៏មិន

ប្រាប់គ្នានឹងគ្នាឡើយ បែកគ្នា ទៅតាមទីប្រាថ្នា ។

ភិក្ខុដែលច្រើនដោយការញុះញង់ មានមនោរថពេញ ចូលទៅបិណ្ឌបាត ក្នុងស្រុកពួកមនុស្សឃើញនាំគ្នាពោលថាព្រះថេរៈទាំងឡាយនាំគ្នាទៅណា ។ ភិក្ខុនោះពោលថា ព្រះថេរៈទាំង ២ ទាស់គ្នាមួយយប់ទល់ភ្លឺ ទោះបីអាត្មាឃាត់ថា លោកកុំទាស់ទែងគ្នា ចូរសាមគ្គីគ្នាចុះ ព្រោះថា ការវិវាទនាំមកតែសេចក្ដីវិនាសញុំាងទុក្ខឲ្យកើតក្នុងអនាគត ជាផ្លូវនៃអកុសល មនុស្សសម័យមុន ក៏ធ្លាប់ឃ្លាតចាកប្រយោជន៍ធំ ព្រោះការឈ្លោះគ្នា ដូច្នេះជាដើម ក៏មិនស្ដាប់ពាក្យរបស់អាត្មា នាំគ្នាចៀសចេញទៅ ។ លំដាប់នោះ ពួកមនុស្សអង្វរថា សូមព្រះថេរៈទៅចុះ តែលោកម្ចាស់កុំរំខានចិត្ត នៅក្នុងទីនេះឯងដើម្បីអនុគ្រោះពួកខ្ញុំ ។ លោកទទួលពាក្យថា សាធុ ហើយនៅក្នុងទីនោះឯង បាន ២-៣ ថ្ងៃ គិតថា អញញុះញង់ភិក្ខុទាំងឡាយ ដែលមានសីល មានទូវកល្យាណធម៌ ដោយចង់ធ្វើជាចៅអាវាស អញខ្ទះខ្ទែងតែក្នុងកម្មអាក្រក់ហ្ន៎ ទើបត្រូវសេចក្ដីក្ដៅក្រហាយដ៏ខ្លាំងក្លាគ្របសង្កត់ កើតអាពាធ ព្រោះកម្លាំងសេចក្ដីសោក មិនយូរប៉ុន្មានធ្វើកាលកិរិយា កើតក្នុងអវិចីមហានរក ។

ឯព្រះថេរៈជាសម្លាញ់ទាំង ២ រូប ចារិកទៅក្នុងជនបទ ជួបគ្នាត្រង់អាវាសមួយកន្លែង ក៏ប្រាស្រ័យគ្នានឹងគ្នា ប្រាប់ពាក្យញុះញង់ដែលភិក្ខុនោះនិយាយដល់គ្នានឹងគ្នា ដឹងថា រឿងនោះមិនពិត ទើបព្រមព្រៀងគ្នាត្រឡប់មកកាន់អាវាសនោះឯង ដោយលំដាប់ ។ ពួកមនុស្សឃើញព្រះថេរៈទាំង ២ រូប ហើយ នាំគ្នាត្រេកអរ ឧបដ្ឋាកដោយបច្ច័យ ៤ ។ ព្រះថេរៈទាំង ២ រូប

កាលនៅក្នុងទីនោះឯង មានចិត្តជាសមាធិ ព្រោះបានអាហារជាទីសប្បាយ ចម្រើនវិបស្សនាហើយ មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។

ភិក្ខុដែលច្រើនដោយការញុះញង់ ឆេះក្នុងនរក អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតជាប្រេតមាត់ស្អុយ នៅមិនឆ្ងាយអំពីក្រុងរាជគ្រឹះ ។ កាយរបស់ប្រេតនោះ មានពណ៌ដូចមាស តែដង្កូវហូរចេញអំពីមាត់ នាំគ្នារូងជញ្ជក់ក្នុងទីផ្សេងៗ ក្លិនមាត់របស់ប្រេតនោះស្អុយផ្សាយទៅ សូម្បីក្នុងទីឆ្ងាយ ។

លំដាប់នោះ ព្រះនារទៈ ខណៈចុះអំពីភ្នំគិជ្ឈកូដបានជួបប្រេតនោះ ក៏សួរដល់កម្មដែលប្រេតធ្វើដោយគាថានេះថា

> អ្នកទ្រទ្រង់នូវវណ្ណធាតុ គឺរាងកាយ ជាទិព្វដ៏ល្អ ឋិតនៅក្នុងអាកាសវេហាស៍ ទាស់តែដង្កូវទាំងឡាយ ទំពាស៊ីនូវមាត់របស់អ្នកដែលមានក្លិនស្អុយ តើអំពីកពមុន អ្នកបានធ្វើអំពើដូចម្តេច ។

ក្នុងបទទាំងនោះ បទថា **ទិព្វំ** បានដល់ ជាទិព្វ គឺទាក់ទងដោយអត្តភាពរបស់ទេវតា តែក្នុងទីនេះ ឈ្មោះថា ទិព្វ ព្រោះដូចជារបស់ទិព្វ ។ បទថា **សុភំ** បានដល់ ស្អាត ឬការស្អាត ។ បទថា **វណ្ណធាតុំ** បានដល់ ពណ៌សម្បុរ ។ បទថា **ធារេសិ** បានដល់ នាំទៅ ។ បទថា **វេហាសយំ តិដ្ឋសិ អន្តលិក្ខេ** បានដល់ ឈរនៅកណ្តាលអាកាស ដែលតែងហៅថា អាកាស តែអាចារ្យពួកខ្លះ ពោលបាឋៈថា **វិហាយសំ តិដ្ឋសិ អន្តលិក្ខេ** ដូច្នេះក៏មាន

ហើយពោលអត្ថនៃបាទនោះ ដោយពាក្យដ៏សេសថា អ្នកឈរនៅលើអាកាស ធ្វើអាកាសឲ្យក្លិ ។ បទថា **បូតិគន្ធំ** ប្រែថា មានក្លិនដូចសាកសព អធិប្បាយថា មានក្លិនស្អុយ ។ បទថា **កឹ កម្មមកាសិ បុព្វេ** នេះ ព្រះថេរៈសួរថា ពួកដង្កូវរួងជញ្ជក់មាត់ ដែលមានក្លិនស្អុយក្រៃលែងរបស់អ្នក តែកាយរបស់អ្នក មានពណ៌ដូចមាស ក្នុងកាលមុន អ្នកធ្វើកម្មអ្វី ដែលជាហេតុបានអត្តភាពបែបនេះ ។

ប្រេតនោះ ត្រូវព្រះថេរៈសួរដល់កម្មដែលខ្លួនធ្វើយ៉ាងនេះ កាលនឹងឆ្លើយបញ្ហានោះ ទើបពោលគាថានេះថា

ខ្ញុំជាសមណៈលាមក មានវាចាអាក្រក់ ប្រព្រឹត្តតបធម៌ មិនសង្រួមមាត់ ឯវណ្ណធាតុខ្ញុំបានហើយដោយតបធម៌ មាត់របស់ខ្ញុំមានក្លិនស្អុយ ព្រោះតែពោលពាក្យញុះញង់ ។

ក្នុងបទទាំងនោះ បទថា **សមណោ អហំ បាបោ** បានដល់ ខ្ញុំជាសមណៈលាមក គឺជាភិក្ខុអាក្រក់ ។ បទថា **អតិទុដ្ឋវាចោ** សេចក្តីថា ជាអ្នកនិយាយពាក្យអាក្រក់ក្រៃលែង គឺជាអ្នកពោលកន្ទង់អ្នកដទៃ អធិប្បាយថា ជាអ្នកពោលកម្ចាត់គុណរបស់អ្នកដទៃ ។ម្យ៉ាងទៀត បាលីថា **អតិទុក្ខវាចោ** ដូច្នេះក៏មាន អធិប្បាយថា ជាអ្នកមានវាចាគ្រោតគ្រាតក្រៃលែង គឺត្រេកអរតែក្នុងវចីទុច្ចរិត មានការពោលកុហកនិងពោលញុះញង់ជាដើម ។ បទថា **តបស្សិរូបោ** បានដល់ ជាសមណៈក្លែងក្លាយ ។ បទថា **មុខសា** បានដល់ ដោយមាត់ ។ បទថា **លទ្ធា** បានដល់ បានចំពោះហើយ ។ ច អក្ខរៈ

ជា សម្បិណ្ឌនត្ថៈ ប្រែថា ម្យ៉ាងទៀត ។ បទថា **មេ** កែជា **មយា** ប្រែថា ដែលខ្ញុំ ។ បទថា **តបសា** បានដល់ ព្រោះព្រហ្មចរិយៈ ។ បទថា **មេ-សុណភិយេន** បានដល់ ព្រោះបិសុណវាចា ។ បទថា **បូតិ** បានដល់ មានក្លិនស្អុយ ។

ប្រេតនោះ កាលប្រាប់កម្មដែលខ្លួនបានធ្វើទុកយ៉ាងនេះហើយ ឥឡូវនេះកាលនឹងជាស់តឿនព្រះថេរៈ ទើបពោលគាថាចុងក្រោយថា

បពិត្រព្រះនារទៈ អំពើនោះ លោកម្ចាស់បានឃើញខ្លួនឯង
ស្រាប់ហើយ អ្នកឈ្លាសទាំងឡាយ ជាអ្នកអនុគ្រោះ គប្បី
ពោលថា អ្នកកុំពោលពាក្យញុះញង់ កុំពោលពាក្យកុហកទើប
អ្នកនឹងបានជាទេវបុត្ត មានកាមតាមសេចក្តីប្រាថ្នា ។

ក្នុងបទទាំងនោះ បទថា **យមិទំ** បានដល់ រូបរាងរបស់ខ្ញុំនេះ ។ បទថា **អនុកម្បកា យេ កុសលា វទេយ្យុំ** សេចក្តីថា ជាអ្នកឈ្លាសក្នុងបដិបទាដែលជាប្រយោជន៍ដល់អ្នកដទៃ គឺជាអ្នកល្អិតល្អន់ មានព្រះពុទ្ធ ជាដើម ជាអ្នកមានការអនុគ្រោះជាប្រក្រតី គឺជាអ្នកប្រកបដោយព្រះករុណា ពោលពាក្យឯណាទុក អធិប្បាយថា ខ្ញុំនឹងពោលពាក្យនោះឯង ឥឡូវនេះប្រេតនោះ កាលនឹងជាស់តឿន ទើបពោលថា អ្នកកុំពោលពាក្យញុះញង់ កុំពោលពាក្យកុហក ទើបអ្នកនឹងបានជាទេវបុត្ត មានកាមតាមសេចក្តីប្រាថ្នា ដូច្នេះ ។

ពាក្យនោះ មានអធិប្បាយដូច្នេះថា លោកកុំពោល គឺកុំពោលពាក្យញុះញង់ ពាក្យស៊កសៀតនិងពាក្យមិនពិត ។ បើលោកលះពាក្យកុហកនិងពាក្យ

ញុះញង់បាន ហើយសង្រួមដោយវាចា លោកនឹងជាបុគ្គលដែលគេបូជា ឬកើតជាទេវតាអង្គណាមួយដែលបានទិព្វសម្បត្តិដ៏ឧឡារ ដែលគួរប្រាថ្នា គួរពេញចិត្ត ត្រេកអរក្នុងទិព្វសម្បត្តិ គឺអភិរម្យដោយការបម្រើឥន្ទ្រិយតាមសប្បាយ ។

ព្រះថេរៈបានស្តាប់ដូច្នោះ ទើបទៅកាន់ក្រុងរាជគ្រឹះ ត្រាច់បិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយអាហារ ទើបក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ព្រះសាស្តាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយសម្តែងធម៌ព្រះធម្មទេសនានោះ មានប្រយោជន៍ដល់បរិស័ទដែលដល់ព្រមហើយ ។

## អដ្ឋកថា បូតិមុខប្រេត ចប់

# រឿង បិដ្ឋធីតលិកប្រេត ទី៤

[ ៤ ] ( ព្រះសម្ពុទ្ធទ្រង់សម្ដែងថា ) បុគ្គលមិនមានសេចក្ដីកំណាញ់ គួរធ្វើនូវហេតុណានីមួយឲ្យជាអារម្មណ៍ ហើយគប្បីឲ្យទាន គឺប្រារព្ធនូវបុព្វបុរសទាំងឡាយ មានមាតាបិតាជាដើម ដែលរំលាងខន្ធទៅកាន់បរលោកហើយ ឬនូវទេវតាទាំងឡាយដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានទីផ្ទះ ជាដើម នូវស្ដេចធំទាំង ៤ ដែលរក្សាលោក ជាអ្នកមានយសបរិវារ គឺព្រះបាទកុវេរៈ ១ ធតរដ្ឋៈ ១ វិរូបក្ខៈ ១ វិរុឡ្ហកៈ ១ ហើយឲ្យនូវទានចុះ ជនទាំងឡាយមានស្ដេចធំជាដើមនោះ ឈ្មោះថាជាបុគ្គលគឺទាយកនោះបានបូជាហើយឯអ្នកឲ្យមិនមែនជាមិនមានផលឡើយ ។ ការយំក្ដី សោកសៅក្ដី ខ្សឹកខ្សួលណាដទៃក្ដី បុគ្គលមិនគប្បីធ្វើទេ កិច្ចមានយំសោកជាដើមនោះ មិនជាប្រយោជន៍ដល់អ្នកដែលទៅកាន់បរលោកឡើយ ញាតិទាំងឡាយ ( ដែលទៅកាន់បរ-លោកនោះ ) ក៏ឋិតនៅយ៉ាងនោះដដែល ( ឥតបានដឹងបានឮឡើយ ) ។ ចំណែកទក្ខិណាទាន ដែលបុគ្គលបានឲ្យហើយនេះឯង ជាទានតម្កល់នៅល្អ ហើយក្នុងសង្ឃ រមែងសម្រេចផលដើម្បីជាប្រយោជន៍ដល់ញាតិ ដែលទៅកាន់លោកខាងនាយនោះ អស់កាលជាយូរអង្វែង តាមឋានៈ គឺទីដែលគួរសម្រេចបាន ។

**ចប់ រឿងបិដ្ឋធីតលិកប្រេត ទី ៤ ។**

# អដ្ឋកថា បិដ្ឋធីតលិកាប្រេត

[ ៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន មហាវិហារក្រុងសាវត្ថី ទ្រង់ប្រារព្ធទានរបស់អនាថបិណ្ឌិកគហបតី បានត្រាស់ពាក្យនេះ មានពាក្យផ្តើមថា **យំ កិញ្ចារម្មណំ កត្វា** ដូច្នេះ ។

បានឮថា គីលៀងរបស់ទារិកា ដែលជាកូនរបស់កូនស្រីអនាថបិណ្ឌិក-សេដ្ឋី បានឲ្យតុក្កតាម្យ៉ាង ប្រាប់ថា នេះជាកូនស្រីរបស់នាង ចូរនាងពរវាទៅលេងចុះ ។ ទារិកានោះសម្គាល់តុក្កតាម្យ៉ាងនោះថាជាកូនស្រី ។ ថ្ងៃមួយកាលទារិកាពតុក្កតានោះលេង តុក្កតាក៏ធ្លាក់បែក ព្រោះការធ្វេសប្រហែស ។ បន្ទាប់អំពីនោះ ក្មេងស្រីនោះ ក៏យំខ្សឹកខ្សួល ពោលថា កូនស្រីខ្ញុំស្លាប់ហើយ កាលនាងកំពុងយំ មនុស្សក្នុងផ្ទះ មិនអាចប្រាប់ហេតុឲ្យនាងយល់បាន ។ សម័យនោះ ព្រះសាស្តាគង់លើអាសនៈដែលគេក្រាលហើយ ក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី លោកមហាសេដ្ឋី ក៏អង្គុយជិតព្រះមានព្រះភាគ ។ ស្រីគីលៀងបាននាំទារិកានោះ ទៅរកលោកសេដ្ឋី ។ សេដ្ឋីឃើញហើយក៏ ពោលថា ទារិកានេះយំអ្វី ។ គីលៀងបានប្រាប់រឿងនោះដល់លោកសេដ្ឋីហើយ ។ សេដ្ឋីបានឲ្យទារិកានោះ អង្គុយលើភ្លៅ ហើយប្រាប់ឲ្យយល់ថា តានឹងឲ្យទានឧទ្ទិសដល់កូនស្រីរបស់ចៅ ដូច្នេះហើយ ទើបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នានឹងឲ្យទានឧទ្ទិសដល់តុក្កតាម្យ៉ាង ដែលជាកូនស្រីរបស់ចៅខ្ញុំព្រះអង្គ សូមទ្រង់មួយអន្លើដោយភិក្ខុ ៥០០ ទទួលទាននោះរបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ព្រះមានព្រះភាគទទួលដោយតុណ្ហីភាព ។

ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុ ៥០០ យាងទៅកាន់ផ្ទះលោកសេដ្ឋី សោយព្រះក្រយាហារហើយ កាលនឹងធ្វើអនុមោទនា ក៏បានភាសិតគាថាទាំងនេះថា

បុគ្គលមិនមានសេចក្តីកំណាញ់ គួរធ្វើនូវហេតុណានីមួយ ឲ្យជាអារម្មណ៍ ហើយគប្បីឲ្យទាន គឺប្រារព្ធនូវបុព្វបុរសទាំងឡាយ មានមាតាបិតាជាដើម ដែលរំលាងខន្ធទៅកាន់បរលោកហើយ ឬនូវទេវតាទាំងឡាយ ដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានទីផ្ទះ ជាដើម នូវស្តេចធំទាំង ៤ ដែលរក្សាលោកជាអ្នកមានយសបរិវារ គឺព្រះបាទកុវេរៈ ១ ធតរដ្ឋៈ ១ វិរូបក្ខៈ ១ វិរុឡ្ហកៈ ១ ហើយឲ្យនូវទានចុះ ជនទាំងឡាយមានស្តេចធំជាដើមនោះ ឈ្មោះថាជាបុគ្គលគឺទាយកនោះបានបូជាហើយ ឯអ្នកឲ្យមិនមែនជាមិនមានផលឡើយ ។ ការយំក្តី សោកសៅក្តី ខ្សឹកខ្សួលណាដទៃក្តី បុគ្គលមិនគប្បីធ្វើទេ កិច្ចមានយំសោក ជាដើមនោះ មិនជាប្រយោជន៍ដល់អ្នកដែលទៅកាន់បរលោកឡើយ ញាតិទាំងឡាយ ( ដែលទៅកាន់បរលោកនោះ ) ក៏ឋិតនៅយ៉ាងនោះដដែល ( ឥតបានដឹងបានឮឡើយ ) ។ ចំណែកទក្ខិណាទានដែលបុគ្គលបានឲ្យហើយនេះឯង ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ រមែងសម្រេចផលដើម្បីជាប្រយោជន៍ ដល់ញាតិ ដែលទៅកាន់លោកខាងនាយ

នោះ អស់កាលជាយូរអង្វែង តាមឋានៈ គឺទីដែលគួរសម្រេចបាន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យំ កិញ្ចារម្មណំ កត្វា** សេចក្ដីថា ប្រារព្ធ គឺឧទ្ទិសហេតុណាមួយ ក្នុងបណ្ដាហេតុដែលជាមង្គលជាដើម ។ បទថា **ទជ្ជា** ប្រែថា គប្បីឲ្យ ។ បទថា **អមច្ឆរី** សេចក្ដីថា ឈ្មោះថា **អមច្ឆរី** ព្រោះមិនមានសេចក្ដីកំណាញ់ ដែលមានលក្ខណៈមិនអត់ធន់ ចំពោះសម្បត្តិរបស់ខ្លួនដែលជាសាធារណៈដល់អ្នកដទៃ ។ អធិប្បាយថា ជាអ្នកមានប្រក្រតីបរិច្ចាគធ្វើមន្ទិលនៃចិត្ត មានមច្ឆរិយៈនិងលោភៈជាដើមឲ្យឆ្ងាយ ហើយគប្បីឲ្យទាន ។ បទថា **បុព្វេបេតេ ច អារព្ភ** បានដល់ ឧទ្ទិសបុព្វេបេតជន មានវាចាប្រកប-សេចក្ដីថា បទថា **វត្ថុទេវតា** ប្រារព្ធទេវតាដែលស្ថិតនៅក្នុងទីផ្សេងៗមានផ្ទះជាដើម ដោយពាក្យថា **អថ វា** នេះ ទ្រង់សម្ដែងថា ប្រារព្ធបេតជនពួកណានីមួយ មានទេវតានិងមនុស្សជាដើមដទៃហើយ គប្បីឲ្យទាន ។

ក្នុងពាក្យទាំងនោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងទេវតាប្រាកដពួកខ្លះ ក្នុងទេវតាទាំងនោះមុន ទើបត្រាស់ថា **ចត្តារោ ច មហារាជេ** កាលប្រារព្ធទេវតាទាំងនោះដោយឈ្មោះទៀត ទើបត្រាស់ពាក្យថា **កុវេរំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **កុវេរំ** បានដល់ ព្រះបាទវេស្សវ័ណ ។ បទថា **ធតរដ្ឋំ** ជាដើម ជាឈ្មោះនៃទេវតារក្សាលោក ៣ អង្គដ៏សេស ។ បទថា **តេ ចេវ បូជិតា ហោន្តិ** សេចក្ដីថា មហារាជទាំងនោះនិងបុព្វេបេតជននិងវត្ថុទេវតាដែលគេរាប់អាន ដោយការធ្វើឧទ្ទិស ។ បទថា **ទាយកា ច**

**អផលា** *សេចក្តីថា ទាយកអ្នកឲ្យទាន មិនឥតផលឡើយ ព្រោះហេតុត្រឹមតែការឧទ្ទិសដល់បេតជនដទៃ ទាំងជាអ្នកមានចំណែកនៃផលទានរបស់ខ្លួនដូចគ្នា ។*

*ឥឡូវនេះ ដើម្បីសម្តែងថា ការយំជាដើមនោះ របស់ជនទាំងនោះ ដែលយំកន្ទក់កន្ទេញ សោកខ្សឹកខ្សួល ព្រោះញាតិរបស់ខ្លួនដែលស្លាប់ទៅ មិនមានប្រយោជន៍ ត្រឹមតែធ្វើខ□ឲ្យក្តៅក្រហាយប៉ុណ្ណោះ ទើបត្រាស់គាថាថា* **ន ហិ រុណ្ណំ វា** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **រុណ្ណំ** *ប្រែថា យំ គឺបង្ហូរទឹកភ្នែក ។ បាលីដ៏សេសគប្បីនាំមកភ្ជាប់ដោយបទថា* **ន ហិ ការតព្វំ** *។ បទថា* **សោកោ** *បានដល់ សេចក្តីសោក គឺការក្តៅក្រហាយខាងក្នុង ។ អធិប្បាយថា ការក្តៅខាងក្នុង ។ បទថា* **យា ចញ្ញា បរិទេវនា** *បានដល់ ការយំរៀបរាប់ដទៃចាកការយំនិងសេចក្តីសោក បានដល់ ការរវើរវាយដោយវាចា មានពាក្យថា កូនតែមួយ កូនទៅឯណា ជាដើម អធិប្បាយថា ការរវើរវាយដោយវាចានោះ ក៏មិនគួរធ្វើ ។* **វា** *សព្ទ ក្នុងបទទាំងពួង ជាវិកប្បត្ថៈ ប្រែថា ខ្លះ ឬ ក្តី ។ បទថា* **ន តំ បេតស្ស អត្ថាយ** *សេចក្តីថា ហេតុជាដើមថា ការយំក្តី ការសោកក្តី ការកន្ទក់កន្ទេញក្តី ទាំងអស់នោះមិនមានប្រយោជន៍ មិនមានឧបការៈដល់អ្នកលះលោកទៅហើយ គឺស្លាប់ទៅហើយ ដូច្នោះទើបហេតុមានការយំជាដើមនោះ មិនគួរធ្វើ អធិប្បាយថា ទោះជាយ៉ាងនោះ ពួកញាតិក៏មិនដឹងរឿង ដោយតាំងនៅយ៉ាងនោះ ។*

*ព្រះសាស្តា កាលទ្រង់សម្តែងដល់ហេតុនៃទុក្ខធម៌ មានការយំជាដើម*

ឥឡូវនេះ កាលទ្រង់សម្តែងទក្ខិណាដែលទាយកប្រារព្ធបុព្វបេតជាដើម ហើយ ថ្វាយដល់សង្ឃថាជាវត្ថុមានប្រយោជន៍ ទើបត្រាស់គាថាថា **អយញ្ច ខោ ទក្ខិណា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ ដោយបទថា **អយំ** នេះ ព្រះមានព្រះភាគ កាលសម្តែងដល់ទានដែលទាយកឲ្យហើយនោះដោយប្រចក្ស ទើបត្រាស់ ។ **ច** សព្ទជា ព្យតិរេកត្ថៈ ប្រែថា ផង ។ ដោយ **ច** សព្ទនោះ រមែងធ្វះបញ្ចាំងអត្ថដែលពិសេស ព្រោះកំពុងនឹងពោលថា ទក្ខិណានេះ មិនដូចហេតុ មានការយំជាដើមដែលមិនជាប្រយោជន៍ដល់អ្នកស្លាប់ទៅហើយឡើយ ទក្ខិណានេះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់អ្នកស្លាប់ទៅហើយនោះអស់កាលយូរ ។ សព្ទថា **ខោ** ប្រើក្នុងអត្ថថា អវធារណៈ ប្រែថា ហាមនូវអត្ថដទៃ ។ បទថា **ទក្ខិណា** បានដល់ ទាន ។ បទថា **សង្ឃម្ហិ សុបតិដ្ឋិតា** បានដល់ តម្កល់ល្អហើយក្នុងសង្ឃ ដែលជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ បទថា **ទីឃរត្តំ ហិតាយស្ស** បានដល់ ដើម្បីជាប្រយោជន៍ដល់ប្រេតនោះ អស់កាលយូរ ។ បទថា **ឋានសោ ឧបកប្បតិ** បានដល់ រមែងសម្រេចក្នុងខណៈនោះឯង អធិប្បាយថា មិនមែនក្នុងកាលដទៃ ។ ពិតហើយ នេះជាធម្មតាក្នុងសេចក្តីនោះថា បើប្រេតអនុមោទនាទានក្នុងកាលទាយកថ្វាយឧទ្ទិសដល់ប្រេត ប្រេតក៏រួចផុតទៅ ដោយអំណាចនៃផលទាននោះក្នុងខណៈនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌យ៉ាងនេះហើយ ទ្រង់ធ្វើឲ្យមហាជនត្រេកអរក្រៃលែងក្នុងទានដែលឧទ្ទិសដល់ប្រេតហើយទ្រង់ក្រោកចាកអា-

សនៈចៀសចេញទៅ ។ ក្នុងថ្ងៃរះឡើង ភរិយាសេដ្ឋីនិងពួកញាតិដ៏សេសកាល អនុលោមតាមសេដ្ឋី ទើបឲ្យមហាទានប្រព្រឹត្តទៅប្រមាណ ៣ ខែ ដោយអាការយ៉ាងនេះ ។

សម័យនោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វីទើបភិក្ខុទាំងឡាយ មិនទៅកាន់រាជវាំងរបស់ខ្ញុំព្រះអង្គប្រមាណមួយខែហើយ កាលព្រះសាស្ដាត្រាស់ប្រាប់ហេតុនោះហើយ ព្រះរាជាកាលទ្រង់យកតម្រាប់តាមសេដ្ឋី ទើបឲ្យមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អ្នកនគរ ឃើញដូច្នោះ កាលអនុវត្តតាមព្រះរាជា ទើបឲ្យមហាទានប្រព្រឹត្តទៅប្រមាណមួយខែ អ្នកនគរឲ្យមហាទានដែលមានតុក្កតាម្សៅជាហេតុប្រព្រឹត្តទៅអស់ ២ ខែដោយប្រការដូច្នេះ ។

## អដ្ឋកថា បិដ្ឋធីតលិកប្រេតចប់

# រឿង តិរោកុឌ្ឌប្រេត ទី៥

[ ៥ ] ( ព្រះសម្ពុទ្ធទ្រង់សម្តែងថា ) ប្រេតទាំងឡាយ មកកាន់ផ្ទះរបស់ខ្លួន ឋិតនៅខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ នឹងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង នឹងទ្វារផ្ទះទាំងឡាយខ្លះ ។ កាលបើបាយ ទឹក បង្អែម ចំអាបដ៏ច្រើនដែលពួកញាតិចូលទៅតាំងទុកហើយ ញាតិណាមួយមិននឹករឭកដល់ប្រេតទាំងឡាយនោះ ព្រោះបច្ច័យ គឺកម្មរបស់សត្វទាំងឡាយ ។ ជនទាំងឡាយណា ជាអ្នកអនុគ្រោះ ជនទាំងនោះរមែងឲ្យនូវទឹកនឹងភោជនដ៏ហ្មត់ចត់ប្រសើរ ជារបស់គួរតាមកាល ដើម្បីញាតិទាំងឡាយយ៉ាងនេះថា ទាននេះចូរសម្រេចដល់ញាតិទាំងឡាយ សូមឲ្យញាតិទាំងឡាយដល់នូវសេចក្តីសុខចុះ ។ ឯប្រេតជាញាតិទាំងនោះ មកប្រជុំគ្នាក្នុងទីដែលឲ្យទាននោះ ជាអ្នកមកល្អហើយ កាលបើបាយនឹងទឹកដ៏ច្រើន ( ដែលគេឧទ្ទិសដល់ខ្លួន ) គប្បីអនុមោទនាដោយគោរពថា យើងទាំងឡាយបាន ( ទទួលផល ) ព្រោះហេតុនៃពួកញាតិណា សូមញាតិទាំងនោះរបស់យើងរស់នៅអស់កាលយូរចុះ ការបូជា ឈ្មោះថាញាតិទាំងឡាយបានធ្វើហើយដល់ពួកយើង ឯអ្នកឲ្យទាន មិនមែនជាមិនមានផលឡើយ ។ កសិកម្ម គឺការភ្ជួររាស់ ក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្ម គឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ វណិជ្ជកម្ម គឺការជួញប្រែដែលជាហេតុបាននូវសម្បត្តិដូច្នោះ ក៏មិនមានការលក់ចេញទិញចូលដោយប្រាក់ ក៏មិនមាន ។ បុគ្គលទាំងឡាយធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយសារតែផលទានដែលញាតិឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះក្នុងទី

ទូលរមែងហូរទៅកាន់ទីទាបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះរមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។ ផ្លូវទឹកទាំងឡាយដ៏ពេញរមែងញុំាងសាគរឲ្យពេញប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះរមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរឭកឃើញនូវឧបការគុណដែលញាតិនិងមិត្តជាដើម បានធ្វើដល់ខ្លួនក្នុងកាលមុនថា អ្នកឯណោះបានឲ្យ ( របស់នេះ ) ដល់អាត្មាអញ អ្នកឯណោះបានធ្វើ ( គុណនេះ ) ដល់អាត្មាអញ ជនទាំងនោះ ជាញាតិមិត្ត ជាសំឡាញ់របស់អាត្មាអញ ដូច្នេះហើយ គួរឲ្យទក្ខិណាទានដល់ប្រេតទាំងឡាយ ។ ការយំក្តី ការសោកក្តី ឬសេចក្តីខ្សឹកខ្សួលណាដទៃក្តី បុគ្គលមិនគប្បីធ្វើឡើយ ព្រោះកិច្ចមានយំសោកជាដើម មិនជាប្រយោជន៍ ដល់អ្នកដែលទៅកាន់បរលោកឡើយ ញាតិទាំងឡាយ ( ដែលទៅកាន់បរលោកនោះ ) ក៏ឋិតនៅយ៉ាងនោះដដែល ( ឥតបានដឹងឮឡើយ ) ។ ចំណែកទក្ខិណាទានដែលបុគ្គលបានឲ្យហើយនេះឯង ជាទានតម្កល់ទុកនៅល្អហើយ ក្នុងព្រះសង្ឃ រមែងសម្រេចផល ដើម្បីជាប្រយោជន៍ដល់ញាតិនោះ អស់កាលដ៏យូរអង្វែងតាមឋានៈ គឺទីដែលគួរសម្រេចបាន ។

ក៏ញាតិធម៌នោះ មហារាជបានសម្តែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លា ចំពោះប្រេតទាំងឡាយ មហារាជបានធ្វើហើយ កម្លាំងកាយរបស់ភិក្ខុទាំងឡាយ មហារាជបានបំពេញហើយ បុណ្យដ៏ច្រើនមហារាជ ក៏បានសន្សំហើយ ។

**ចប់ រឿងតិរោកុឌ្ឌប្រេត ទី ៥ ។**

# អដ្ឋកថា តិរោកុឌ្ឌប្រេត

[ ៥ ] ព្រះសាស្ដា កាលទ្រង់គង់នៅក្នុងនគររាជគ្រឹះ ទ្រង់ប្រារព្ធពួកប្រេតជាច្រើន ទើបត្រាស់ព្រះគាថានេះ មានពាក្យផ្ដើមថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ដូច្នេះ ។

ក្នុងសេចក្ដីនោះ មានកថាពិស្ដារដូចតទៅនេះថា ក្នុងកប្បទី ៩២ បន្ទាប់អំពីកប្បនេះ មាននគរមួយឈ្មោះថា កាសី ព្រះរាជាព្រះនាមថា ជយសេន ទ្រង់គ្រងរាជសម្បត្តិក្នុងនគរនោះ ។ ព្រះអង្គមានព្រះរាជទេវី ព្រះនាមថា សិរិមា ព្រះពោធិសត្វព្រះនាមថា ផុស្សៈ កើតក្នុងគភ៌របស់ព្រះនាង ហើយត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដោយលំដាប់ ។ ព្រះបាទជយសេនកើតនូវការយើញតែប្រយោជន៍ខ្លួនថា កូនរបស់អញចេញមហាភិនេស្រ្កមណ៍ បានត្រាស់ដឹងជាព្រះពុទ្ធ ព្រះពុទ្ធជារបស់អញ ព្រះធម៌ជារបស់អញ ព្រះសង្ឃ ក៏ជារបស់អញ ដូច្នេះហើយ ទ្រង់ឧបដ្ឋាកដោយព្រះអង្គឯងសព្វៗកាល មិនឲ្យឱកាសដល់ជនដទៃឡើយ ។

បងប្អូន ៣ អង្គ មាតាដទៃដែលជាប្អូនប្រុសរបស់ព្រះមានព្រះភាគ គិតគ្នាថា ធម្មតាព្រះពុទ្ធទាំងឡាយ កើតឡើងដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងអស់ មិនមែនដើម្បីជាប្រយោជន៍ចំពោះបុគ្គលណាមួយ បិតារបស់ពួកយើង មិនឲ្យឱកាសដល់ជនដទៃឡើយ ធ្វើដូចម្ដេចហ្ន៎ពួកយើងគប្បីបានឧបដ្ឋាកព្រះមានព្រះភាគនិងភិក្ខុសង្ឃ ។ បងប្អូនទាំង ៣ អង្គនោះ មានគំនិតយ៉ាងនេះថា ណ្ហើយចុះ ពួកយើងធ្វើឧបាយណាមួយ ។ បងប្អូន ៣ អង្គនោះ បានសាងស្ថានការណ៍ឯជាយដែន ហាក់ដូចជាមានចោរប្លន់ស្រុក ។ បន្ទាប់អំពី

នោះព្រះរាជាទ្រង់ឮថា នៅឯជាយដែនមានការបះបោរ ទើបទ្រង់បញ្ជូនព្រះរាជឱរសទាំង ៣ ចេញទៅបង្ក្រាបជនបទ ។ បងប្អូនទាំង ៣ អង្គនោះ ទៅបង្ក្រាបបច្ចន្តជនបទរាបទាបហើយត្រឡប់មក ។ ព្រះរាជាទ្រង់ពេញព្រះទ័យ បានប្រទានពរថា ពួកកូនប្រាថ្នារបស់ណា ក៏ចូរកាន់យករបស់នោះចុះ ។ បងប្អូនទាំង ៣ អង្គនោះ ក្រាបទូលថា ទូលបង្គំប្រាថ្នានឹងឧបដ្ឋាកព្រះមានព្រះភាគ ។ ព្រះរាជាទ្រង់ត្រាស់ថា វៀរព្រះមានព្រះភាគចេញ ចូរអ្នកកាន់យករបស់ដទៃតាមចិត្តចុះ ។ បងប្អូន ៣ អង្គនោះក្រាបទូលថា ពួកទូលបង្គំមិនត្រូវការវត្ថុដទៃ ព្រះរាជាត្រាស់ថា បើដូច្នោះ ពួកអ្នកចូរកំណត់ពេល ហើយកាន់យកចុះ ។ បងប្អូន ៣ អង្គនោះទូលសូម ៧ ឆ្នាំ ព្រះរាជាមិនអនុញ្ញាត ។ បងប្អូន ៣ អង្គក្រាបទូលថា សូម ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ រហូតសល់ត្រឹម ៣ ខែ ដោយប្រការដូច្នេះ ។ ក្នុងកាលនោះ ព្រះរាជាទ្រង់អនុញ្ញាតថា ចូរកាន់យកចុះ ។

បងប្អូនទាំង ៣ អង្គនោះ ចូលគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកទ្រង់អស់កាល ៣ ខែ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលការនៅចាំវស្សាអស់ ៣ ខែ ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ បងប្អូន ៣ អង្គ នោះក៏បញ្ជូនសំបុត្រទៅនាយស្មៀន ក្នុងជនបទរបស់ខ្លួនថា ពួកយើងនឹងឧបដ្ឋាកព្រះមានព្រះភាគអស់ ៣ ខែ សូមអ្នកចាត់ចែងសម្ភារសម្រាប់ឧបដ្ឋាកព្រះមានព្រះភាគសព្វយ៉ាង រាប់តាំងពីព្រះវិហារឡើងទៅ ។ នាយស្មៀននោះបានចាត់

ថែងសព្វយ៉ាង ហើយបញ្ជូនលិខិតតបទៅវិញ ។ បងប្អូន ៣ អង្គនោះ នាំគ្នាស្លៀកសំពត់កាសាយៈ មួយអន្លើដោយបុរស ១០០០ នាក់ ធ្វើនូវការខ្វល់ខ្វាយបាននាំគ្នាឧបដ្ឋាកព្រះមានព្រះភាគនិងភិក្ខុសង្ឃដោយគោរព នាំទៅកាន់ជនបទ វេរវិហារថ្វាយចាំវស្សា ។

គហបតីម្នាក់ជានាយឃ្លាំងរបស់ព្រះរាជបុត្ត ៣ អង្គនោះ មួយអន្លើដោយភរិយា ជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា ។ បានថ្វាយទានវត្តដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយគោរព ។ នាយស្មៀនក្នុងជនបទ នាំអ្នកជនបទប្រមាណ ១១០០០ នាក់ បានឲ្យទានប្រព្រឹត្តទៅដោយគោរពនោះឯង ក្នុងអ្នកទាំងនោះ អ្នកជនបទពួកខ្លះ កើតការអាក់អន់ចិត្តឡើង ជនទាំងនោះនាំគ្នាធ្វើអន្តរាយដល់ទាន នាំគ្នាបរិភោគទេយ្យធម៌ដោយខ្លួនឯង និងយកភ្លើងមកដុតផ្ទះបាយ ។ រាជបុរសប្រាថ្នាហើយ នាំគ្នាធ្វើសក្ការៈដល់ព្រះមានព្រះភាគ ធ្វើព្រះមានព្រះភាគទុកខាងមុខ ហើយត្រឡប់មករកបិតាវិញ ។ បណ្ដាជនទាំងនោះ ព្រះមានព្រះភាគយាងទៅហើយ ក៏បរិនិព្វាន ឯរាជបុត្ត ស្មៀនក្នុងជនបទ និងនាយឃ្លាំង មួយអន្លើដោយបរិស័ទ ធ្វើកាលកិរិយា ហើយទៅកើតក្នុងស្ថានសួគ៌ដោយលំដាប់ ឯពួកជនដែលអាក់អន់ ក៏នាំគ្នាកើតក្នុងនរក ។ កាលជនទាំង ២ ពួកនោះ ចុតិអំពីស្ថានសួគ៌ ក៏ចូលដល់ស្ថានសួគ៌ ចុតិអំពីនរកក៏ចូលដល់នរក ដោយអាការយ៉ាងនេះអស់ ៩២ កប្ប ។

លុះដល់ភទ្ទកប្បនេះ ក្នុងកាលព្រះមានព្រះភាគព្រះនាមកស្សបៈ ពួកជនដែលអាក់អន់ទាំងនោះ កើតក្នុងពួកប្រេត ។ ក្នុងកាលនោះ ពួកមនុស្សនាំគ្នា

ឲ្យទានឧទ្ទិសដើម្បីជាប្រយោជន៍ដល់ពួកប្រេតដែលជាញាតិរបស់ខ្លួនថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំចុះ ។ ប្រេតទាំងនោះបានសោយសម្បត្តិលំដាប់នោះ ប្រេតទាំងនោះបានឃើញដូច្នោះ ទើបចូលគាល់ព្រះកស្សបសម្មាសម្ពុទ្ធ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំគប្បីបានសម្បត្តិបែបនេះដែរឬហ្ន៎ ព្រះសាស្ដាត្រាស់ថា ឥឡូវនេះ ពួកអ្នកមិនបានទេ តែក្នុងអនាគតមានព្រះសម្មាសម្ពុទ្ធព្រះនាមថាគោតម ក្នុងកាលនៃព្រះមានព្រះភាគអង្គនោះនឹងមានព្រះរាជាមួយអង្គ ព្រះនាមពិម្ពិសារដែលជាញាតិរបស់ពួកអ្នកកាលពី ៩២ កប្បមុននេះ ទ្រង់បានថ្វាយទានដល់ព្រះពុទ្ធ ហើយនឹងឧទ្ទិសដល់ពួកអ្នក អ្នកនឹងបានក្នុងកាលនោះ ។ បានឮថា កាលព្រះកស្សបសម្មាសម្ពុទ្ធត្រាស់យ៉ាងនេះហើយ ព្រះតម្រាស់នោះបានប្រាកដដល់ពួកប្រេតទាំងនោះថាពួកអ្នកនឹងបានក្នុងថ្ងៃស្អែក ។

ពុទ្ធន្តរមួយកន្លងទៅ ព្រះមានព្រះភាគនៃយើងកើតឡើងក្នុងលោក ។ ព្រះរាជបុត្តទាំង ៣ អង្គនោះ មួយអន្លើដោយបុរស ១០០០ ចុតិអំពីទេវលោកហើយ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងមគធរដ្ឋ នាំគ្នាបួសជាឥសីតាមលំដាប់ជាជដិល ៣ នាក់បងប្អូន ត្រង់គយាសីសប្បទេស នាយស្មៀនក្នុងជនបទបានមកកើតជាព្រះបាទពិម្ពិសារ គហបតីបុត្តដែលជានាយឃ្លាំង កើតជាសេដ្ឋីឈ្មោះវិសាខ ។ ភរិយារបស់គហបតីបុត្តនោះ បានជាធីតារបស់សេដ្ឋី ឈ្មោះធម្មទិន្នា ឯមនុស្សក្រៅពីនោះ កើតជាបរិវាររបស់ព្រះរាជានោះឯង ។

ព្រះមានព្រះភាគ ទ្រង់កើតឡើងក្នុងលោកបាន ៧ សប្ដាហ៍ ក៏យាងទៅ

កាន់ក្រុងពារាណសីតាមលំដាប់ ទ្រង់ប្រកាសធម្មចក្ក ទ្រង់ទូន្មានតាំងអំពីបញ្ចវគ្គិយ រហូតដល់ជដិល ៣ នាក់បងប្អូន មួយអន្លើដោយបរិវារ ១០០០ នាក់ ហើយយាងទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងបណ្តាជនទាំងនោះ ទ្រង់ឲ្យព្រះបាទពិម្ពិសារដែលចូលទៅគាល់ក្នុងថ្ងៃនោះឯង មួយអន្លើដោយព្រាហ្មណ៍និងគហបតីអ្នកអង្គៈនិងអ្នកមគធៈ ១១០០០០ នាក់ ឲ្យតាំងនៅក្នុងសោតាបត្តិផលហើយ ។ សម័យនោះ ព្រះរាជាទ្រង់និមន្តដោយកត្តដើម្បីសោយក្នុងថ្ងៃស្អែក ទ្រង់ទទួលហើយ ក្នុងថ្ងៃទី ២ ដែលសក្កទេវរាជកាឡាខ្លួនជាមាណពនាំទ្រង់ទៅ សរសើរដោយព្រះគាថា ( វិនយបិដកមហាវគ្គ ) ថា

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ ( នូវឥន្ទ្រិយ ) មានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលជាអ្នកទូន្មានហើយ ( នូវឥន្ទ្រិយ ) ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ដូច្នេះ ជាដើម ។

ទើបយាងចូលទៅកាន់ក្រុងរាជគ្រឹះ ទ្រង់ទទួលមហាទាន ក្នុងព្រះរាជនិវេសន៍ ។ ឯពួកប្រេតទាំងនោះបាននាំគ្នាឈរចោមរោមដោយទន្ទឹងថា ឥឡូវនេះព្រះរាជានឹងឧទ្ទិសផលទានដល់ពួកយើង ឥឡូវនេះព្រះរាជានឹងឧទ្ទិស ។ ព្រះរាជាទ្រង់ថ្វាយទានហើយ ទ្រង់ត្រិះរិះចំពោះទីគង់របស់ព្រះមានព្រះភាគថា ព្រះមានព្រះភាគគប្បីគង់នៅក្នុងទីណាហ្ន៎ ដូច្នេះ ទើបមិនបានឧទ្ទិសទាននោះ

ដល់បុគ្គលណាមួយឡើយ ។ ពួកប្រេតកាលមិនបានទាននោះយ៉ាងនោះក៏អស់សង្ឃឹម ក្នុងពេលយប់ ក៏នាំគ្នាបញ្ចេញសំឡេងគួរខ្លាចក្រៃលែងក្បែរព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ដល់នូវសេចក្តីសង្វេគនិងតក់ស្លុតស្រៀវខ្លាច កាលរាត្រីអស់ហើយ បានចូលទៅក្រាបទូលដល់ព្រះមានព្រះភាគថា ខ្ញុំព្រះអង្គបានឮសំឡេងបែបនេះ នឹងមានហេតុអ្វីហ្ន៎ ព្រះសាស្តាត្រាស់ថា កុំភ័យខ្លាចឡើយមហាបពិត្រ អន្តរាយលាមកឯណានីមួយ មិនមានដល់ព្រះអង្គទេ ម្យ៉ាងទៀតបុរាណញាតិរបស់ទ្រង់កើតក្នុងពួកប្រេតមាន ញាតិទាំងនោះ ទន្ទឹងជួបទ្រង់រហូតមួយពុទ្ធន្តរ គ្រាច់ទៅដោយសង្ឃឹមថា ទ្រង់ថ្វាយទានដល់ព្រះពុទ្ធហើយនឹងឧទ្ទិសដល់ពួកយើងខ្លះ ព្រោះទ្រង់ថ្វាយទានកាលអំពីម្សិលមិញហើយមិនបានឧទ្ទិស ទើបនាំគ្នាអស់សង្ឃឹម បញ្ចេញសំឡេងបែបនោះ ។ ព្រះរាជាត្រាស់សួរថា បើខ្ញុំព្រះអង្គថ្វាយទានក្នុងកាលឥឡូវនេះ ប្រេតទាំងនោះ គប្បីបានទទួលឬ ព្រះសាស្តាត្រាស់ថា បាន មហាបពិត្រ ។ ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមទ្រង់ទទួលទានរបស់ខ្ញុំព្រះអង្គ ដើម្បីសោយក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គនឹងឧទ្ទិសដល់ពួកប្រេតទាំងនោះ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។

ព្រះរាជាយាងទៅកាន់ព្រះរាជនិវេសន៍ ទ្រង់រៀបចំមហាទាន ហើយក្រាបទូលកាលដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ យាងទៅកាន់ព្រះរាជនិវេសន៍ មួយអន្លើដោយភិក្ខុសង្ឃ គង់លើអាសនៈដែលគេក្រាលទុក ប្រេតទាំងនោះបានទៅដោយសង្ឃឹមថា ថ្ងៃនេះ ពួកយើងនឹងបានអ្វីពិត ដូច្នេះ ទើប

នាំគ្នាឈរក្នុងទីផ្សេងៗ មានខាងក្រៅជញ្ជាំងជាដើម ។ ព្រះមានព្រះភាគទ្រង់បានធ្វើដោយភាពដែលពួកប្រេតទាំងនោះ មកប្រាកដដល់ព្រះរាជា ។ ព្រះរាជាកាលទ្រង់ប្រួចទឹកទក្ខិណោទក ទើបឧទ្ទិសថា ទាននេះចូរសម្រេចដល់ញាតិទាំងឡាយ ។ ក្នុងវេលានោះឯង ស្រះបោក្ខរណីដែលដេរដាសដោយផ្កាកុមុទកើតឡើងដល់ពួកប្រេត ។ ប្រេតទាំងនោះនាំគ្នាងូតនិងផឹកក្នុងស្រះបោក្ខរណីនោះ បានស្ងប់រម្ងាប់សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាកនិងសេចក្តីស្រេកឃ្លាន ជាអ្នកមានពណ៌សម្បុរដូចមាស ។ ព្រះរាជាទ្រង់ថ្វាយបបរ ខាទនីយាហារនិងភោជនីយាហារហើយឧទ្ទិសឲ្យ ខណៈនោះឯង បបរ របស់ទំពានិងរបស់បរិភោគដែលជាទិព្វ កើតឡើងដល់ប្រេតទាំងនោះ ។ ប្រេតទាំងនោះនាំគ្នាបរិភោគបបរជាដើមនោះហើយ ក៏បានជាអ្នកមានឥន្ទ្រិយផូរផង់ ។ លំដាប់នោះទ្រង់បានថ្វាយសំពត់ ទីដេកនិងទីអង្គុយ ហើយឧទ្ទិសឲ្យ ។ គ្រឿងប្រដាប់មានប្រភេទផ្សេងៗ ដូចជាសំពត់ ប្រាសាទ កម្រាលនិងទីដេកជាដើមដែលជាទិព្វបានកើតដល់ប្រេតទាំងនោះ ។ សម្បត្តិរបស់ប្រេតទាំងអស់នោះបានប្រាកដដល់ព្រះរាជាដោយប្រការដែលព្រះមានព្រះភាគទ្រង់អធិដ្ឋាន ។ ព្រះរាជាទ្រង់ទតឃើញដូច្នោះ ទ្រង់ពេញព្រះរាជហឫទ័យពន់ពេក ។ គ្រានោះ ព្រះមានព្រះភាគសោយព្រះក្រយាហារហើយ ទ្រង់ហាមកត្តហើយ ដើម្បីអនុមោទនាដល់ព្រះបាទពិម្ពិសារ ទើបត្រាស់អនុមោទនា តិរោកុឌ្ឍបេតវត្ថុថា

ប្រេតទាំងឡាយ មកកាន់ផ្ទះរបស់ខ្លួន ឋិតនៅខាងក្រៅជញ្ជាំង
ទាំងឡាយខ្លះ នាផ្លូវបែកជា ៤ នឹងផ្លូវបែកជា ៣ ទាំងឡាយ

ខ្លះ ជិតទ្វារក្រុងនិងទ្វារផ្ទះទាំងឡាយខ្លះ ។ កាលបើបាយ ទឹក បង្អែម ចំអាបដ៏ច្រើនដែលពួកញាតិ ចូលទៅតាំងទុកហើយ ញាតិណាមួយ មិនទឹករឭកដល់ប្រេតទាំងឡាយនោះ ព្រោះ បច្ច័យ គឺកម្មរបស់សត្វទាំងឡាយ ។ ជនទាំងឡាយណា ជា អ្នកអនុគ្រោះ ជនទាំងនោះរមែងឲ្យនូវទឹកនឹងភោជនដ៏ហ្មត់ចត់ ប្រសើរ ជារបស់គួរតាមកាល ដើម្បីញាតិទាំងឡាយយ៉ាងនេះ ថា ទាននេះ ចូរសម្រេចដល់ញាតិទាំងឡាយ សូមឲ្យញាតិទាំង ឡាយ ដល់នូវសេចក្តីសុខចុះ ។ ឯប្រេតជាញាតិទាំងនោះ មកប្រជុំគ្នាក្នុងទីដែលឲ្យទាននោះ ជាអ្នកមកល្អហើយ កាល បើបាយនឹងទឹកដ៏ច្រើន ( ដែលគេឧទ្ទិសដល់ខ្លួន ) គប្បីអនុ- មោទនា ដោយគោរពថា យើងទាំងឡាយបាន ( ទទួលផល ) ព្រោះហេតុនៃពួកញាតិណា សូមញាតិទាំងនោះ របស់យើង រស់នៅអស់កាលយូរចុះ ការបូជា ឈ្មោះថាញាតិទាំងឡាយ បានធ្វើហើយដល់ពួកយើង ឯអ្នកឲ្យទាន មិនមែនជាមិនមាន ផលឡើយ ។ កសិកម្ម គឺការភ្ជួររាស់ ក៏មិនមានក្នុងភូមិនៃ ប្រេតនោះ គោរក្ខកម្ម គឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេត នោះ វណិជ្ជកម្ម គឺការជួញប្រែដែលជាហេតុបាននូវសម្បត្តិ ដូច្នោះ ក៏មិនមាន ការលក់ចេញទិញចូលដោយប្រាក់ ក៏មិន មាន ។ បុគ្គលទាំងឡាយធ្វើកាលកិរិយាទៅកើតជាប្រេតរមែង

ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយសារតែផលទានដែលញាតិឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះក្នុងទីទួលរមែងហូរទៅកាន់ទីទាបដូចម្តេចមិញទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ ប្រេតទាំង-ឡាយ ដូច្នោះដែរ ។ ផ្លូវទឹកទាំងឡាយដ៏ពេញ រមែងញុំាងសាគរឲ្យពេញប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះរមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរឭកឃើញនូវឧបការគុណដែលញាតិនិងមិត្តជាដើមបានធ្វើដល់ខ្លួនក្នុងកាលមុនថា អ្នកឯណោះបានឲ្យ ( របស់នេះ ) ដល់អាត្មាអញ អ្នកឯណោះបានធ្វើ ( គុណនេះ ) ដល់អាត្មាអញ ជនទាំងនោះជាញាតិមិត្ត ជាសំឡាញ់របស់អាត្មាអញដូច្នេះហើយ គួរឲ្យទក្ខិណាទានដល់ប្រេតទាំងឡាយ ។ ការយំក្តី ការសោកក្តី ឬសេចក្តីខ្សឹកខ្សួលណាដទៃក្តី បុគ្គលមិនគប្បីធ្វើឡើយ ព្រោះកិច្ច មានយំសោកជាដើមមិនជាប្រយោជន៍ដល់អ្នកដែលទៅកាន់បរលោកឡើយ ញាតិទាំងឡាយ ( ដែលទៅកាន់បរលោកនោះ ) ក៏ឋិតនៅយ៉ាងនោះដដែល ( ឥតបានដឹងឮឡើយ ) ។ ចំណែកទក្ខិណាទានដែលបុគ្គលបានឲ្យហើយនេះឯង ជាទានតម្កល់ទុកនៅល្អហើយក្នុងព្រះសង្ឃ រមែងសម្រេចផល ដើម្បីជាប្រយោជន៍

ដល់ញាតិនោះអស់កាលដ៏យូរអង្វែង តាមឋានៈ គឺទីដែលគួរ សម្រេចបាន ។ ក៏ញាតិធម៌នោះ មហារាជបានសម្តែងជាបែប យ៉ាងហើយ ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ មហារាជ បានធ្វើហើយ កម្លាំងកាយរបស់ភិក្ខុទាំងឡាយ មហារាជបាន បំពេញហើយ បុណ្យដ៏ច្រើនមហារាជ ក៏បានសន្សំហើយ ។

ក្នុងបទទាំងនោះ បទថា **តិរោកុឌ្ឌេសុ** បានដល់ ត្រង់ចំណែកដទៃនៃ ជញ្ជាំង ( ផ្ទះ ) ។ ពាក្យថា **តិដ្ឋន្តិ** នេះ ជាពាក្យកំណត់ការឈរ ដោយ បដិសេធការអង្គុយជាដើម អធិប្បាយថា ឈរខាងក្រៅទ្វារផ្ទះ ទ្វារកំពែង និងជញ្ជាំងផ្ទះ ។ បទថា **សន្ធិសិង្ឃាដកេសុ** ច បានដល់ ត្រង់ប្រកដែល មានផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ។ បទថា **សន្ធិ** បានដល់ ប្រកដែល មានមុំ ៤ ។ ហៅថា ទីតផ្ទះ ទីតជញ្ជាំង ទីតបង្អួចក៏មាន ។ បទថា **សិង្ឃាដកា** បានដល់ ប្រកដែលបែកជា ៣ ។ បទថា **ទ្វារពាហាសុ តិដ្ឋន្តិ** បានដល់ ឈរផ្អែកទ្វារនគរនិងទ្វារផ្ទះ ។ បទថា **អាគន្ត្វាន សកំ ឃរំ** សេច ក្តីថា ផ្ទះរបស់ញាតិក្នុងកាលមុនក្តី ផ្ទះរបស់ខ្លួនគ្រប់គ្រងដោយភាពជាម្ចាស់ក្តី ឈ្មោះថា ផ្ទះរបស់ខ្លួន ព្រោះពួកប្រេតទាំងនោះ អាស្រ័យផ្ទះទាំង ២ ប្រភេទ នោះ ដោយយល់ថាជាផ្ទះរបស់ខ្លួន ដូច្នោះទើបត្រាស់ថា មកកាន់ផ្ទះរបស់ ខ្លួន ។

ព្រះមានព្រះភាគ ទ្រង់បង្ហាញដល់ព្រះរាជានូវពួកប្រេតជាច្រើនដែលមាន រូបចម្លែកៗមិនគួរមើល ទាំងគួរគប្ញើខ្លាចយ៉ាងក្រៃលែងដែលសោយផលនៃ

ការប្រណៃន និងការកំណាញ់ ដែលមកកាន់ព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារដែលខ្លួនមិនធ្លាប់គ្រប់គ្រងក្នុងកាលមុន ដោយសម្គាល់ថាជាផ្ទះរបស់ខ្លួន ព្រោះជាផ្ទះរបស់ពួកញាតិក្នុងកាលមុន ហើយឈរខាងក្រៅជញ្ជាំងជាដើមដោយប្រការដូច្នេះទើបត្រាស់គាថាថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ជាដើម កាលទ្រង់សម្តែងដដែលថា កម្មដែលពួកប្រេតទាំងនោះធ្វើ ជាកម្មអាក្រក់ក្រៃលែង ទើបត្រាស់គាថាទី ២ ថា **បហូតេ អន្នបានម្ហិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បហូតេ** បានដល់ មិនតិច គឺច្រើន អធិប្បាយថា ល្មមសមគួរដល់សេចក្តីត្រូវការ ។ ពិតហើយ ផ្លាស់ ៣ អក្ខរៈជា ប អក្ខរៈក៏បាន ដូចក្នុងប្រយោគជាដើមថា **បហុ សន្តោ ន ភរតិ** បុគ្គលណាជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹម ( មាតាឬបិតា ) ។ ឯអាចារ្យពួកខ្លះពោលថា **ពហុកេ** ដូច្នេះក៏មាន តែនោះជាការពោលដោយការភ្លាំងភ្លាត់ ។ បទថា **អន្នបានម្ហិ** បានដល់ របស់គួរបរិភោគនិងគួរផឹក ។ បទថា **ខជ្ជភោជ្ជេ** ប្រែថា កាលរបស់ទំពានិងរបស់បរិភោគ ។ ដោយពាក្យនេះ ទ្រង់សម្តែងអាហារទាំង ៤ ប្រភេទ គឺរបស់បរិភោគ របស់ផឹក របស់ទំពានិងរបស់លិទ្ធភក្ស ។ បទថា **ឧបដ្ឋិតេ** បានដល់ ចូលទៅតាំងទុក គឺត្រៀមទុក អធិប្បាយថា រៀបចំទុក ។ បទថា **ន តេសំ កោចិ សរតិ សត្តានំ** សេចក្តីថា បុគ្គលណាមួយទោះជាម្តាយ ឪពុក កូនឬចៅក៏ដោយរបស់សត្វទាំងនោះ គឺដែលកើតក្នុងបេតវិស័យ រឭកមិនបាន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកម្មជាបច្ច័យ អធិប្បាយថា ព្រោះកម្ម គឺសេចក្តីកំណាញ់មានការមិនឲ្យ និងការ

បដិសេធការឲ្យជាដើមដែលខ្លួនធ្វើទុកជាហេតុ កម្មនោះឯងធ្វើឲ្យពួកញាតិទាំងនោះរឭកមិនបាន ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការមិនមាន សូម្បីតែការរឭករបស់ពួកញាតិ ព្រោះផលកម្មរបស់ពួកប្រេតដែលសង្ឃឹមចំពោះពួកញាតិ ក្នុងកាលបាយនិងទឹកជាដើម មានប្រមាណច្រើន មានយ៉ាងនេះហើយ ឥឡូវនេះកាលទ្រង់សរសើរទាន ដែលព្រះរាជាថ្វាយឧទ្ទិសពួកញាតិ ដែលកើតក្នុងបេតវិស័យ ទើបត្រាស់គាថាទី ៣ ថា **ឯវំ ទទន្តិ ញាតីនំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឯវំ** ជាពាក្យឧបមា ។ បទថា **ឯវំ** នោះ ភ្ជាប់សេចក្តីបាន ២ ប្រការ គឺបណ្តាញាតិពួកខ្លះដែលរឭកមិនបាន ព្រោះកម្មរបស់សត្វទាំងនោះជាបច្ច័យ ញាតិពួកខ្លះជាអ្នកអនុគ្រោះយ៉ាងនោះ ក៏តែងឲ្យដល់ពួកញាតិ គឺពួកញាតិដែលអនុគ្រោះ រមែងឲ្យទឹកនិងបាយដ៏ស្អាត ប្រណីតដែលសមគួរតាមកាល ដល់ញាតិទាំងឡាយ ដូចទានដែលមហាបពិត្រថ្វាយហើយដូច្នោះ ។ ក្នុងបទទាំងនោះ បទថា **ទទន្តិ** បានដល់ រមែងឲ្យ គឺឧទ្ទិសឲ្យ ប្រគល់ឲ្យ ។ បទថា **ញាតីនំ** បានដល់ ជនដែលទាក់ទងគ្នាខាងមាតានិងបិតា ។ បទថា **យេ** បានដល់ ជនពួកណានីមួយ មានបុត្តជាដើម ។ បទថា **ហោន្តិ** ប្រែថា រមែងឲ្យ ។ បទថា **អនុកម្បកា** បានដល់ ជាអ្នកត្រូវការប្រយោជន៍ គឺជាអ្នកស្វែងរកប្រយោជន៍ ។ បទថា **សុចឹ** បានដល់ បរិសុទ្ធ ផូរផង់ និងប្រកបដោយធម៌ ។ បទថា **បណីតំ** បានដល់ ឧឡារ ។ បទថា **កាលេន** បានដល់ ដោយកាលដ៏សមគួរដល់ការបរិភោគនៃទក្ខិ-

ណោយបុគ្គលទាំងឡាយឬដោយកាលដែលប្រេតជាញាតិ មកឈរខាងក្រៅជញ្ជាំងផ្ទះជាដើម ។ បទថា **កប្បិយំ** សេចក្តីថា គួរ គឺសមគួរ បានដល់សមគួរដើម្បីការបរិភោគរបស់ព្រះអរិយៈទាំងឡាយ ។ បទថា **ខាទនីយភោជនំ** បានដល់ ទឹកនិងបាយ ។ ក្នុងទីនេះ ដោយការសម្តែងអាងដល់បទថា បានភោជននោះ ទ្រង់ត្រាស់ដល់ទេយ្យធម៌គ្រប់យ៉ាង ។

ឥឡូវនេះ ដើម្បីសម្តែងប្រការដែលជាហេតុ ឈ្មោះថាដែលញាតិឲ្យហើយដល់ប្រេតទាំងនោះ ទើបត្រាស់កន្លះគាថាខាងដើម ដោយគាថាទី ៤ ថា **ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** ដូច្នេះជាដើម ។ កន្លះគាថាខាងដើមនៃគាថាទី ៤ គប្បីភ្ជាប់នឹងកន្លះគាថាខាងដើមនៃគាថាទី ៣ ថា **ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។**

ដោយ **ឯវំ** សព្ទនោះ ដែលមានអាការជាអត្ថថា ញាតិទាំងឡាយរមែងឲ្យដោយប្រការយ៉ាងនេះថា ទាននេះ ចូរសម្រេចដល់ញាតិទាំងឡាយ មិនឲ្យដោយប្រការដទៃ ដែលឈ្មោះថាធ្វើនូវការសម្តែងចេញដល់អាការដែលគប្បីឲ្យ ។

ក្នុងបទទាំងនោះ បទថា **ឥទំ** ជាបទសម្តែងចេញដល់ទេយ្យធម៌ ។ បទថា **វោ** ត្រឹមតែជានិបាត ដូច **វោ** អក្ខរៈក្នុងប្រយោគជាដើមថា **យេហិ វោ អរិយា** តថាគតជាព្រះអរិយៈមួយដែរ ។ បទថា **ញាតីនំ ហោតុ** សេចក្តីថា ចូរសម្រេចដល់ញាតិទាំងឡាយដែលកើតក្នុងបេតវិស័យ ។ តែអាចារ្យពួកខ្លះ

ពោលថា **នោ ញាតីនំ** អធិប្បាយថា ដល់ញាតិទាំងឡាយរបស់ពួកយើង ។ បទថា **សុខិតា ហោន្តុ ញាតយោ** សេចក្តីថា ពួកញាតិដែលចូលដល់បេតវិស័យទាំងនោះ កាលសោយផលនេះ ចូរមានសេចក្តីសុខ គឺបានទទួលសេចក្តីសុខ ។

ព្រោះកម្មដែលបុគ្គលដទៃធ្វើ ក្នុងកាលពួកញាតិពោលថា សូមទាននេះសម្រេចដល់ញាតិទាំងឡាយ ដូច្នេះ រមែងមិនឲ្យផលដល់បុគ្គលដទៃ របស់នោះដែលគេឧទ្ទិសយ៉ាងនោះ សុទ្ធតែជាបច្ច័យដល់កុសលកម្ម ដល់ពួកប្រេតជាញាតិ ដូច្នោះ កាលទ្រង់សម្តែងប្រការដែលកុសលកម្ម ដែលបង្កើតផលដល់ប្រេតទាំងនោះក្នុងទីនោះ គឺក្នុងខណៈនោះឯង ទើបត្រាស់ពាក្យថា **តេ ច តត្ថ** ដូច្នេះ ជាដើម ។

ក្នុងបទទាំងនោះ បទថា **តេ** បានដល់ ប្រេតដែលជាញាតិ ។ បទថា **តត្ថ** បានដល់ ក្នុងទីដែលពួកញាតិឲ្យទាន ។ បទថា **សមាគន្ត្វា** សេចក្តីថា ជាអ្នកនាំគ្នាមកក្នុងទីនោះ ដើម្បីអនុមោទនាថា ពួកញាតិទាំងនេះរបស់ពួកយើង ឧទ្ទិសទានដើម្បីជាប្រយោជន៍ដល់ពួកយើង ។ បទថា **បហូតេ អន្នបានម្ហិ** បានដល់ កាលវត្ថុនោះដែលពួកញាតិឧទ្ទិសឲ្យខ្ជួន ។ បទថា **សក្កច្ចំ អនុមោទរេ** សេចក្តីថា ជឿកម្មនិងផលនៃកម្ម មិនលះនូវការកោតក្រែង ជាអ្នកមានចិត្តមិនរាយមាយរមែងត្រេកអររមែងរីករាយ កើតនូវបីតិសោមនស្សថា ទានរបស់ពួកយើងនេះ ចូរប្រព្រឹត្តទៅដើម្បីជាប្រយោជន៍និងសេចក្តីសុខចុះ ។

*បទថា* **ចិរំ ជីវន្តុ** *បានដល់ ចូរមានជីវិតយឺនយូរ គឺមានអាយុយឺនយូរ បទថា* **នោ ញាតី** *បានដល់ ញាតិទាំងឡាយរបស់ពួកយើង ។ បទថា* **យេ-សំ ហេតុ** *បានដល់ ព្រោះហេតុនៃញាតិពួកណា គឺព្រោះអាស្រ័យញាតិពួកណា ។ បទថា* **លភាមសេ** *សេចក្តីថា រមែងបាននូវសម្បត្តិបែបនេះ ។ ពិតហើយ បទនេះជាបទសម្តែងអាការៈ ដែលពួកប្រេតអ្នកសោយសម្បត្តិដែលបានដោយការឧទ្ទិសដល់ពួកញាតិរបស់ខ្លួន ។ ពិតហើយ ទក្ខិណាតែងកើតផលដល់ពួកប្រេតក្នុងខណៈនោះ ដោយអង្គ ៣ គឺ ដោយខ□នអនុមោទនា ១ ដោយទាយកឧទ្ទិសឲ្យ ១ ដោយការដល់ព្រមដោយទក្ខិណេយ្យបុគ្គល ១ ។ ក្នុងអង្គទាំង ៣ នោះ ទាយកជាហេតុពិសេស ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **យេសំ ហេតុ លភាមសេ** *ដូច្នេះ ជាដើម ។*

*បទថា* **អម្ហាកញ្ច កតា បូជា** *សេចក្តីថា ការបូជា គឺទាយកឧទ្ទិសឲ្យយ៉ាងនេះថា សូមទាននេះសម្រេចដល់ញាតិទាំងឡាយចុះ ធ្វើដល់ពួកយើងហើយទាយកទាំងនោះ ក៏ឈ្មោះថាជាអ្នកមិនឥតផល ព្រោះឲ្យផលក្នុងសន្តានដែលជាទីកើតនៃកម្មដែលសម្រេចដោយកិរិយាបរិច្ចាគនោះឯង ។*

*ក្នុងសេចក្តីនេះ មានអ្នកចោទសួរថា ចំពោះពួកញាតិដែលចូលដល់បេតវិស័យរមែងបានហេតុសម្បត្តិប៉ុណ្ណោះឬ ឬថាអ្នកដទៃក៏បាន ។ ក្នុងសេចក្តីនេះពួកយើងមិនចាំបាច់ពោល ព្រោះព្រះមានព្រះភាគ ទ្រង់បានព្យាករហើយសមដូចព្រះតម្រាស់ ដែលមានព្រះមានព្រះភាគត្រាស់ក្នុង អង្គុត្តរនិកាយ ទសកនិបាតថា*

បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍តែងឲ្យទានតែងធ្វើអំពើដែលគេគប្បីធ្វើដោយសទ្ធា ហើយឧទ្ទិសថា ទាននេះសូមឲ្យសម្រេចផល ដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយជាញាតិសាលោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចម្រើនចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយជាញាតិសាលោហិត ដែរឬទេ ប្រេតទាំងឡាយ ជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះបានដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននេះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។ បពិត្រ ព្រះគោតមដ៏ចម្រើន ទីដែលគួរ តើដូចម្តេច ទីដែលមិនគួរ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងនរក អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយកើតក្នុងនរក សត្វនរកនោះតែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះ ឋិតនៅក្នុងនរក

នោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថាទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតនៃតិរច្ឆាន អាហារណាជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះឋិតនៅក្នុងទីនោះដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាក អ-ទិន្នាទាន វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្ប-លាបៈ ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស អាហារណាជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះដោយអាហារនោះបុគ្គលនោះ ឋិតនៅក្នុងទីនោះដោយសារអាហារនោះ

ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិត នៅក្នុងទីណា ទីនេះឯងហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាក បាណាតិបាត ។បេ។ មានសេចក្ដីយល់ត្រូវ បុគ្គលនោះលុះបែក ធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណា ជាអាហារសម្រាប់ពួកទេវតា ទេវតានោះ ក៏ញ៉ាំងអត្តភាពឲ្យ ប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះឋិតនៅ ក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅ ថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជា អ្នកសម្លាប់សត្វ ។បេ។ មានសេចក្ដីយល់ខុស បុគ្គលនោះលុះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងបិត្តិវិស័យ អាហារ ណាជាអាហារសម្រាប់សត្វទាំងឡាយដែលកើតក្នុងបិត្តិវិស័យ ប្រេតនោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះដោយអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះដោយសារអាហារនោះ ឬក៏ពួកមិត្តអាមាត្យក្ដី ជនជាញាតិសាលោហិតក្ដី ឧទ្ទិសឲ្យនូវ ទានណាដល់ប្រេតនោះអំពីលោកនេះ ប្រេតនោះក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះដោយអាហារនោះ ប្រេតនោះឋិត នៅក្នុងទីនោះដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាន

នោះសម្រេចផលដល់សត្វ ដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថាទីគួរ ។ ជាណុស្សោណិព្រាហ្មណ៍ក្រាបទូលសួរថាបពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិ សាលោហិតនោះមិនបានទៅកើតក្នុងទីនោះទេ តើអ្នកណាបរិភោគទាននោះ ។ អើព្រាហ្មណ៍ ពួកប្រេត ដែលជាញាតិសាលោហិតដទៃទៀតរបស់គេគង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯងបរិ-ភោគទាននោះ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិត ដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណាបរិភោគទាននោះ ។ នែព្រាហ្មណ៍ ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយ ជាញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផលទេ ដូច្នេះ ។

ឥឡូវនេះ កាលទ្រង់សម្តែងការមិនមានហេតុដែលពួកអ្នកកើតក្នុងបេតវិស័យបានទទួលសម្បត្តិ មានកសិកម្មនិងគោរក្ខកម្មជាដើម ក្នុងបេតវិស័យនោះ និងការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលពួកញាតិឲ្យហើយអំពីមនុស្សលោកនេះ ទើបត្រាស់ពាក្យជាដើមថា **ន ហិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ន ហិ តត្ថ កសិ អត្ថិ** សេចក្តីថា ក្នុងបេតវិស័យនោះ កសិកម្មដែលពួកប្រេតអាស្រ័យចិញ្ចឹមជីវិតយ៉ាងសប្បាយ មិនមានឡើយ ។ បទថា **គោរក្ខេត្ថ ន វិជ្ជតិ** សេចក្តីថា ក្នុងបេតវិស័យនោះ មិនមែនមិនមានតែកសិកម្មតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីគោរក្ខកម្មដែលពួកប្រេតទាំងនោះអាស្រ័យចិញ្ចឹមជីវិតជាសុខ ក៏មិនមានដូចគ្នា ។ បទថា **វណិជ្ជា តាទិសី នត្ថិ** សេចក្តីថា សូម្បីពាណិជ្ជកម្មដែលជាហេតុឲ្យប្រេតទាំងនោះបានទទួលសម្បត្តិ ក៏មិនមានដូចគ្នា ។ បទថា **ហិរញ្ញេន កយាកយំ** សេចក្តីថា ក្នុងបេតវិស័យនោះ សូម្បីការដោះដូរដោយប្រាក់ ដែលជាហេតុឲ្យប្រេតទាំងនោះបានទទួលសម្បត្តិ ក៏មិនមានដូចគ្នា ។ បទថា **ឥតោ ទិន្នេន យាបេន្តិ បេតា កាលគតា តហឹ** សេចក្តីថា ម្យ៉ាងទៀត ប្រេតទាំងនោះរមែងចិញ្ចឹមជីវិត គឺញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលញាតិ ឬមិត្តអាមាត្យឲ្យហើយអំពីមនុស្សលោកនេះតែម្យ៉ាង ។ បទថា **បេតា** បានដល់ ពួកសត្វដែលកើតក្នុងបេតវិស័យ ។ បទថា **កាលគតា** បានដល់ អ្នកទៅតាមកាលរបស់ខ្លួន គឺស្លាប់ ។ បាឋៈថា **កាលកតា** ដូច្នេះក៏មាន សេចក្តីថា អ្នកធ្វើកាលហើយ គឺដែលស្លាប់ទៅហើយ បានដល់ ដល់នូវមរណៈ ។ បទថា **តហឹ** បានដល់ ក្នុងបេតវិស័យនោះ ។

ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្តីតាមដែលពោលហើយដោយឧបមា ទើបព្រះមានព្រះភាគត្រាស់ ២ គាថាថា **ឧន្នមេ ឧទកំ វុដ្ឋំ** ដូច្នេះជាដើម ។ ២ គាថានោះ មានអធិប្បាយដូចតទៅថា ភ្លៀងធ្លាក់ក្នុងទីទួល គឺ បទេស

ដែលខ្ពស់រមែងហូរទៅតាមរណ្ដៅ គឺហូរទៅតាមទីទំនាប យ៉ាងណា ទានដែលពួកញាតិឲ្យអំពីមនុស្សលោកនេះក៏ដូច្នោះដូចគ្នា រមែងសម្រេចដល់ពួកប្រេតគឺរមែងមិនផុតអំពីការកើតផល ។ ពិតហើយ បេតលោកជាឋានៈដែលសមគួរដើម្បីការសម្រេចនៃទាន ដូចទីទាបជាឋានៈ ដែលសមគួរដល់ការហូរទៅនៃទឹក ។ សមដូចទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននោះសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថាទីគួរ ដូច្នេះ ។ មួយវិញទៀត ទានដែលពួកមនុស្សឲ្យហើយអំពីមនុស្សលោកនេះ រមែងសម្រេចដល់ពួកប្រេតដោយន័យដូចពោលហើយក្នុងកាលមុន ដូចអន្លង់ទឹក គឺស្ទឹងធំពេញទៅដោយទឹកដែលហូរមកអំពីភ្នំ ពេញជ្រោះ ស្ទឹង អូរ ប្រឡាយ ត្រពាំង ហូរទៅពេញសមុទ្ទ ដូច្នោះ ។

ព្រោះហេតុដែលប្រេតទាំងឡាយ ត្រូវសេចក្ដីសង្ឃឹមគ្របសង្កត់ថា ពួកយើងនឹងបានអ្វីមួយអំពីទីនេះ ទើបនាំគ្នាមកកាន់ផ្ទះរបស់ញាតិ ក៏មិនអាចសូមថា អ្នកទាំងឡាយចូរឲ្យវត្ថុឈ្មោះនេះមកខ្ញុំ ដូច្នោះ កាលទ្រង់សម្ដែងថា កុលបុត្តកាលរឭកដល់វត្ថុដែលជាទីរឭកទាំងនេះរបស់ពួកញាតិទាំងនោះ ទើបគួរឲ្យទក្ខិណា ទើបត្រាស់គាថាថា **អទាសិ មេ** ដូច្នេះជាដើម ។

ពាក្យនៃគាថានោះ មានអធិប្បាយដូច្នេះថា កុលបុត្តកាលរឭកដល់វត្ថុទាំងអស់នេះថា បុគ្គលនោះឲ្យទ្រព្យ ឬធញ្ញាហារឈ្មោះនេះដល់អញ អ្នកនោះដល់នូវការព្យាយាមដោយខ្លួនឯង ធ្វើកិច្ចនេះដល់អញ បុគ្គលនោះឈ្មោះថា ជាញាតិ ព្រោះទាក់ទងខាងមាតាឬបិតារបស់អញ ។ បុគ្គលនោះឈ្មោះ

ថា ជាមិត្ត ព្រោះអាចរក្សាដោយអំណាចសេចក្ដីស្នេហា ។ បុគ្គលនោះឈ្មោះ ថា ជាសម្លាញ់លេងដីជាមួយគ្នារបស់អញ ទើបឲ្យនូវទក្ខិណា គឺគប្បីប្រគល់ ឲ្យនូវទានដល់ប្រេតទាំងឡាយ ។ បាលីថា **ទក្ខិណា ទជ្ជា** ប្រែថា គប្បីឲ្យ ទក្ខិណាដល់ប្រេតទាំងឡាយ ដូច្នេះក៏មាន ។ ដោយបទថា **ទក្ខិណា ទជ្ជា** នោះ លោកអធិប្បាយថា កុលបុត្តកាលរឭក គឺអនុស្សរណៈដល់ឧបការៈ ដែលញាតិធ្វើក្នុងកាលមុនដោយន័យជាដើមថា បុគ្គលនេះ បានឲ្យអញ ពិត ហើយ បទថា **អនុស្សរំ** នេះ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។

កាលទ្រង់សម្ដែងថា សត្វពួកណាជាអ្នកមានទុក្ខធម៌ មានការយំនិងសេច ក្ដីសោកជាដើមជាខាងមុខ ព្រោះការស្លាប់របស់ញាតិនោះឯង គង់តាំងនៅ មិនឲ្យអ្វីមួយដើម្បីប្រយោជន៍ដល់ញាតិ ដែលស្លាប់ទៅហើយនោះ ទុក្ខធម៌ មានការយំនិងការសោកជាដើមនៃសត្វទាំងនោះ ត្រឹមតែធ្វើខ្លួនឲ្យក្ដៅតែម្យ៉ាង ប៉ុណ្ណោះ ទុក្ខធម៌ មានការយំនិងសេចក្ដីសោកជាដើម រមែងមិនញុំាងប្រ- យោជន៍ណាមួយឲ្យសម្រេចដល់ប្រេតទាំងឡាយ ទើបត្រាស់គាថាថា **ន ហិ រុណ្ណំ វា** ដូច្នេះ ដើម្បីសម្ដែងដល់ទក្ខិណាដែលព្រះបាទមគធៈថ្វាយថា មាន ប្រយោជន៍ ទើបត្រាស់សេចក្ដីនៃពាក្យទាំងនោះ មានពាក្យជាដើមថា **អយញ្ច ខោ** ដូច្នេះក្នុងកាលជាខាងក្រោយទៀត ។

ព្រោះហេតុដែលព្រះរាជា កាលទ្រង់ថ្វាយទក្ខិណានេះក្នុងឥឡូវនេះឈ្មោះ ថា សម្ដែងចេញដល់ញាតិធម៌ ដោយធ្វើកិច្ចដែលពួកញាតិគប្បីធ្វើដល់ពួក ញាតិឲ្យប្រាកដដល់ជនជាច្រើន គឺទ្រង់ធ្វើការសម្ដែងចេញឲ្យប្រាកដថា ទាន

ទាំងឡាយក៏គប្បីបំពេញញាតិធម៌ក្នុងញាតិទាំងឡាយឲ្យបរិបូណ៌ ដោយអាការយ៉ាងនេះឯង ។ ម្យ៉ាងទៀត កាលព្រះរាជាធ្វើឲ្យពួកប្រេតទាំងនោះបានទទួលសម្បត្តិ ឈ្មោះថា ធ្វើនូវការបូជាដល់ប្រេតទាំងឡាយឲ្យក្រៃលែង កាលឲ្យភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យស្កប់ស្កល់ដោយបាយនិងទឹកជាដើម ឈ្មោះថា តាមឲ្យនូវកម្លាំងដល់ភិក្ខុទាំងឡាយ កាលធ្វើចាគចេតនាដែលមានគុណ មានការអនុគ្រោះជាដើម ជាគ្រឿងប្រកបឲ្យកើត ឈ្មោះថា ទ្រង់ខ្វល់ខ្វាយក្នុងបុណ្យមិនមានប្រមាណ ដូច្នោះ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើព្រះរាជាឲ្យត្រេកអរដោយគុណតាមសេចក្ដីពិត ទើបត្រាស់គាថាចុងក្រោយថា **សោ ញាតិធម្មោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ញាតិធម្មោ** សេចក្ដីថា ការធ្វើកិច្ចដែលពួកញាតិគប្បីធ្វើដល់ពួកញាតិ ។ បទថា **ឧឡារា** បានដល់ ឲ្យធំទូលំទូលាយ ។ បទថា **ពលំ** បានដល់ កម្លាំងកាយ ។ បទថា **បសុតំ** បានដល់ កសាង ។ ក្នុងពាក្យទាំងនេះ ដោយពាក្យថា **សោ ញាតិធម្មោ ច អយំ និទស្សិតោ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងអាងធម្មីកថានឹងព្រះរាជា ។ ពិតហើយ ការសម្ដែងអាងក្នុងទីនេះ សំដៅដល់ការសម្ដែងញាតិធម៌ ។ ព្រះអង្គទ្រង់ទូន្មានដោយពាក្យនេះថា ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ មហារាជបានធ្វើហើយ ។ ការសរសើរ ក្នុងពាក្យថា ថ្លៃថ្លា នេះ ជាការទូន្មានឲ្យធ្វើនូវការបូជារឿយៗ ។ ទ្រង់ឲ្យអាចហ៊ានដោយពាក្យនេះថា កម្លាំងកាយរបស់ភិក្ខុទាំងឡាយ មហារាជបានបំពេញហើយ ។ ពិតហើយ ក្នុងទីនេះ ការបន្ថែមឲ្យកម្លាំងដល់ភិក្ខុទាំងឡាយ ជាការឲ្យអាច

ហាន ដោយការបន្ថែមឧស្សាហ៍ ក្នុងការបន្ថែមឲ្យនូវកម្លាំងដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ ទ្រង់ឲ្យត្រេកអរដោយពាក្យនេះថា បុណ្យដ៏ច្រើនមហារាជក៏បានសន្សំហើយ ។ ក្នុងទីនេះ គប្បីជ្រាបយោជនាយ៉ាងនេះថា ក្នុងទីនេះ ការសម្រេចដល់ការ ជួបនូវបុណ្យ គឺការធ្វើឲ្យត្រេកអរ ដោយការសរសើរគុណតាមសេចក្តីពិត របស់បុណ្យនោះ ។

ក្នុងពេលចប់ទេសនា ធម្មាភិសម័យមានដល់សត្វ ៨៤០០០ ដែលមានចិត្តសង្វេគ ដោយការពណ៌នាទោសនៃការកើតក្នុងបេតវិស័យដែលផ្តើមព្យាយាមដោយឧបាយប្រាជ្ញា ក្នុងថ្ងៃទី ២ ទ្រង់ក៏សម្តែងតិរោកុឌ្ឌទេសនាកណ្ឌនេះឯងដល់ទេវតានិងមនុស្សទាំងឡាយ ធម្មាភិសម័យបែបនោះ មានដោយអាការយ៉ាងនេះអស់ ៧ ថ្ងៃ ។

## អដ្ឋកថា តិរោកុឌ្ឌប្រេតចប់

# រឿង បញ្ចបុត្តខាទិកាប្រេត ទី៦

[ ៦ ] ( ព្រះថេរៈទាំងឡាយសួរថា ) នាងជាស្ត្រីអាក្រាត មានរូប មានសម្បុរអាក្រក់ មានក្លិនអាក្រក់ ស្អុយ តែងបក់ចេញទៅ នាងមានហ្វូងរុយចោមរោមហើយ តើនាងជាស្រីអ្វី មកឋិតនៅក្នុងទីនេះ ។

( ប្រេតស្រីតបថា ) បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំជាស្រីប្រេតដល់នូវសេចក្ដីទុក្ខជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ព្រោះធ្វើអំពើអាក្រក់ ។ ក្នុងពេលព្រឹក ខ្ញុំសម្រាលកូន ៥ នាក់ ក្នុងពេលល្ងាច សម្រាលកូន ៥ នាក់ទៀត រួចហើយទំពាស៊ីកូនទាំងអស់នោះ ក៏មិនគ្រាន់ដល់ខ្ញុំឡើយ ។ ហឫទ័យរបស់ខ្ញុំ ក្ដៅក្រហាយហុយផ្សែង ព្រោះតែសេចក្ដីស្រេកឃ្លាន ខ្ញុំផឹកទឹកក៏មិនបាន លោកម្ចាស់ចូរមើលខ្ញុំដែលជាអ្នកដល់នូវសេចក្ដីវិនាសចុះ ។

( ព្រះថេរៈទាំងឡាយសួរថា ) ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត តើដូចម្ដេច នាងទំពាស៊ីសាច់កូន តើព្រោះវិបាករបស់កម្មដូចម្ដេច ។

( ប្រេតស្រីតបថា ) ស្រីរួមប្ដីរបស់ខ្ញុំ ជាស្រីមានគភ៌ ខ្ញុំបានគិតនូវអំពើដ៏អាក្រក់ដល់ស្រីរួមប្ដីនោះ ខ្ញុំនោះមានចិត្តប្រទូស្តបានធ្វើនូវការញុំាងគភ៌ឲ្យធ្លាក់ចុះ ។ គភ៌របស់ស្រីរួមប្ដីនោះ បានតែត្រឹម ២ ខែ ឈាមក៏ហូរចេញមក ឯមាតារបស់ស្រីរួមប្ដីនោះ ក៏ក្រេវក្រោធនឹងខ្ញុំ ហើយបានបបួលញាតិទាំងឡាយ ញុំាងខ្ញុំឲ្យធ្វើសម្បថផង ឲ្យផ្ដាសាខ្លួនឯងផង ។ ខ្ញុំនោះ ក៏បានពោលនូវសម្បថដ៏ឃោរឃៅផង នូវពាក្យមុសាវាទផងថា បើខ្ញុំបានធ្វើអំពើ

អាក្រក់នេះមែន សូមឲ្យខ្ញុំទំពាស៊ីនូវសាច់នៃកូន ។ ដោយផលនៃកម្មនោះផង ដោយផលនៃមុសាវាទផង ទាំង ២ នេះ ខ្ញុំទើបបានទំពាស៊ីសាច់កូនខ្លួនប្រឡាក់ដោយខ្ទុះនិងឈាមដូច្នេះ ។

**ចប់ រឿងបញ្ចបុត្តខាទិកប្រេត ទី ៦ ។**

## អដ្ឋកថា បញ្ចបុត្តខាទិកប្រេត

[ ៦ ] កាលព្រះសាស្តាគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធដល់ស្រីប្រេតទំពាស៊ីកូនម្តង ៥ ទើបត្រាស់ពាក្យថា **នគ្គា ទុព្វណ្ណរូបាសិ** ដូច្នេះជាដើម ។

បានឮថា មានភរិយារបស់កុដុម្ពិកៈម្នាក់ នៅក្នុងភូមិមិនឆ្ងាយអំពីក្រុងសាវត្ថី ជាស្រីអារ ។ ពួកញាតិរបស់កុដុម្ពិកៈនោះ បាននាំគ្នាពោលដូច្នេះថា ប្រពន្ធរបស់ឯងជាស្រីអារ ពួកយើងនឹងនាំស្រីដទៃមកឲ្យ ។ ព្រោះសេចក្តីស្នេហាក្នុងភរិយានោះ កុដុម្ពិកៈនោះក៏មិនប្រាថ្នាភរិយាដទៃ ។ លំដាប់នោះ ភរិយារបស់កុដុម្ពិកៈដឹងរឿងនោះហើយ ទើបពោលនឹងស្វាមីនោះថា នៃអ្នក ខ្ញុំជាស្រីអារ គួរតែនាំស្រីដទៃមក កុំឲ្យវង្សត្រកូលរបស់អ្នកដាច់សូន្យអី ។ កុដុម្ពិកៈកាលត្រូវភរិយារំអុកទើបរៀបការជាមួយស្រីដទៃ ។ ក្នុងកាលតមកភរិយាក្រោយក៏មានទម្ងន់ ។ ស្រីអារមានចិត្តប្រណែនជាប្រក្រតី គិតថា ស្រីនេះបានកូនហើយ នឹងជាធំក្នុងផ្ទះនេះ ទើបរកឧបាយធ្វើឲ្យគភ៌ស្រីនោះរលូត ទើបទំនុកបម្រុងបរិព្វាជិកាម្នាក់ ដោយបាយនិងទឹក ជាដើម ឲ្យធ្វើគភ៌របស់នាងឲ្យធ្លាក់ ។ ស្ត្រីនោះកាលគភ៌រលូតក៏បានប្រាប់ឲ្យមាតារបស់ខ្លួនជ្រាបមាតា

ឲ្យប្រជុំពួកញាតិហើយ ប្រាប់សេចក្ដីនោះ ញាតិទាំងនោះ បានពោលនឹងស្រីអារដូច្នេះថា ហងធ្វើគភ៌របស់ស្រីនេះឲ្យធ្លាក់ ស្រីអារឆ្លើយថា ខ្ញុំមិនបានធ្វើឲ្យធ្លាក់ទេ ពួកញាតិពោលថា បើនាងមិនបានធ្វើគភ៌ឲ្យធ្លាក់ចូរស្បថ ។ ស្រីអារក៏ពោលកុហកធ្វើនូវសម្បថថា បើខ្ញុំធ្វើគភ៌ឲ្យធ្លាក់ ទុគ្គតិសូមមានដល់ខ្ញុំទៅខាងមុខ ត្រូវសេចក្ដីឃ្លានគ្របសង្កត់ សូមឲ្យខ្ញុំកើតកូន ព្រឹក ៥ ល្ងាច ៥ ហើយទំពាស៊ីទាំងអស់ក៏នៅតែមិនឆ្អែត សូមឲ្យខ្ញុំមានក្លិនស្អុយជានិច្ច ត្រូវរុយចោមរោមចុះ ។ មិនយូរប៉ុន្មាននាងក៏ធ្វើកាលកិរិយា ទៅកើតជាស្រីប្រេតមានរូបអាក្រក់ក្រៃពេក ក្នុងទីមិនឆ្ងាយអំពីស្រុកនោះឯង ។

ក្នុងកាលនោះ ព្រះថេរៈ ៨ រូប ចេញវស្សាក្នុងជនបទ មកកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះសាស្ដា ទើបចូលទៅសម្រាក ក្នុងដងព្រៃដែលសម្បូរដោយម្លប់និងទឹក មិនឆ្ងាយអំពីស្រុកនោះ ។ លំដាប់នោះ ស្រីប្រេតនោះបានបង្ហាញខ្លួនដល់ព្រះថេរៈទាំងឡាយ ។ ក្នុងព្រះថេរៈទាំងនោះ ព្រះសង្ឃត្ថេរបានសាកសួរស្រីប្រេតនោះដោយគាថាថា

នាងជាស្ត្រីអាក្រាត មានរូបមានសម្បុរអាក្រក់ មានក្លិនអា
ក្រក់ស្អុយតែងបក់ចេញទៅ នាងមានហ្វូងរុយចោមរោមហើយ
តើនាងជាស្រីអ្វី មកឋិតនៅក្នុងទីនេះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **នគ្គា** បានដល់ ជាអ្នកមិនមានសំពត់ ។ បទថា **ទុព្វណ្ណរូបាសិ** សេចក្ដីថា នាងមានរូបអាក្រក់ គឺប្រកបដោយរូបគួរខ្ពើមក្រៃពេក ។ បទថា **ទុគ្គន្ធា** គឺមានក្លិនមិនគួរប្រាថ្នា ។ បទថា **បូតិ វាយសិ**

សេចក្តីថា មានក្លិនដូចសាកសព ស្អុយចេញអំពីកាយ ។ បទថា **មក្ខិកាហិ បរិកិណ្ណា** បានដល់ ពួករុយខៀវចោមរោមដោយជុំវិញ ។ បទថា **កា នុ ត្វំ ឥធ តិដ្ឋសិ** សេចក្តីថា នាងជានរណា មានរូបបែបនេះ មកឈរក្នុងទីនេះ អធិប្បាយថា ត្រាច់ទៅក្នុងទីផ្សេងៗ ។

លំដាប់នោះ ស្រីប្រេតនោះត្រូវព្រះមហាថេរៈសួរយ៉ាងនោះ កាលប្រកាសខ្លួន និងឲ្យពួកសត្វកើតនូវសេចក្តីសង្វេគ ទើបពោល ៣ គាថាថា

បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្តីទុក្ខ ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ព្រោះធ្វើអំពើអាក្រក់ ។ ក្នុងពេលព្រឹក ខ្ញុំសម្រាលកូន ៥ នាក់ ក្នុងពេលល្ងាច សម្រាលកូន ៥ នាក់ទៀត រួចហើយទំពាស៊ីកូនទាំងអស់នោះ ក៏មិនគ្រាន់ដល់ខ្ញុំឡើយ ។ ហឫទ័យរបស់ខ្ញុំក្តៅក្រហាយ ហុយផ្សែង ព្រោះតែសេចក្តីស្រេកឃ្លាន ខ្ញុំផឹកទឹកក៏មិនបាន លោកម្ចាស់ចូរមើលខ្ញុំដែលជាអ្នកដល់នូវសេចក្តីវិនាសចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ ស្រីប្រេតហៅព្រះថេរៈដោយសេចក្តីគោរពថា **ភទន្តេ** ។ បទថា **ទុគ្គតា** ប្រែថា ដល់ទុគ្គតិ ។ បទថា **យមលោកិកា** បានដល់ ដឹងច្បាស់នូវបេតលោក ដែលហៅថា យមលោក ព្រោះភាវៈដែលធ្លាក់ទងក្នុងបេតលោកនោះ ។ បទថា **ឥតោ គតា** សេចក្តីថា ចាកមនុស្សលោកនេះហើយទៅ ដោយការចូលដល់បេតលោក អធិប្បាយថា កើតឡើង ។

*បទថា* **កាលេន** *បានដល់ ក្នុងកាលរាត្រីអស់ហើយ ។ ពិតហើយ បទថា* **កាលេន** *នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ បទថា* **បញ្ច បុត្តានិ** *ប្រែថា នូវបុត្ត ៥ នាក់ ។ ពិតហើយ បទថា* **បុត្តានិ** *នេះ លោកពោលដោយលិង្គវិបល្លាស ។ បទថា* **សាយំ បញ្ច បុនាបរេ** *បានដល់ប្រសូតបុត្តដទៃទៀតក្នុងវេលាល្ងាច ។ មានវាចាប្រកបសេចក្តីថា ខ្ញុំស៊ីកូនទាំង ៥ នាក់ ។ បទថា* **វិជាយិត្វាន** *សេចក្តីថា ប្រសូតបុត្ត មួយថ្ងៃ ១០ នាក់ ។ បទថា* **តេបិ ន ហោន្តិ មេ អលំ** *សេចក្តីថា កូន ១០ នាក់នោះមិនគ្រប់គ្រាន់ ដើម្បីបន្ទោបង់ការឃ្លានរបស់ខ្ញុំត្រឹមតែមួយថ្ងៃ ។ ក្នុងទីនេះដើម្បីងាយស្រួលដល់គាថា ទើបលោកពោលឲ្យជាទីឃៈថា* **ន** *។ បទថា* **បរិឌយ្ហតិ ធូមាយតិ ខុធាយ ហទយំ មម** *សេចក្តីថា ចំណែកនៃហទយៈរបស់ខ្ញុំ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ រមែងឆេះ ក្តៅក្រហាយ គឺក្តៅសព្វអន្ទើដោយភ្លើងក្នុងផ្ទៃ ។ បទថា* **ទានីយំ ន លភេ ទាតុំ** *សេចក្តីថា ខ្ញុំត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ កាលត្រាច់ទៅក្នុងទីនោះៗ មិនបានផឹកទឹក ។ បទថា* **បស្ស មំ ព្យសនំ គតំ** *សេចក្តីថា ប្រេតបានប្រកាសទុក្ខដែលខ្លួនសោយដល់ព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មើលខ្ញុំដែលដល់នូវការវិកវរបែបនេះចុះដែលទូទៅ និងមិនទូទៅដល់ការចូលដល់ភាពជាប្រេតចុះ ។ ព្រះថេរៈបានស្តាប់ដូច្នោះ កាលនឹងសួរដល់កម្មដែលស្រីប្រេតនោះធ្វើ ទើបពោលគាថាថា*

*ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត*

តើដូចម្តេច នាងទំពាស៊ីសាច់កូន តើព្រោះវិបាករបស់កម្មដូចម្តេច ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទុក្កដំ** បានដល់ ទុច្ចរិត ។ បទថា **កិស្សកម្ម-វិបាកេន** បានដល់ ដោយវិបាកកម្មដូចម្តេច អធិប្បាយថា ដោយវិបាកនៃបាណាតិបាតឬអទិន្នាទានជាដើមណាមួយ ។ អាចារ្យពួកខ្លះពោលថា **កេន កម្មវិបាកេន** ដោយវិបាកនៃកម្មដូចម្តេច ។

លំដាប់នោះ ស្រីប្រេតកាលប្រកាសភាពដែលខ្លួនធ្វើដល់ព្រះថេរៈ ក៏បានពោលគាថាទាំងឡាយថា

ស្រីរួមប្តីរបស់ខ្ញុំ ជាស្រីមានគភ៌ ខ្ញុំបានគិតនូវអំពើដ៏អាក្រក់ដល់ស្រីរួមប្តីនោះ ខ្ញុំនោះ មានចិត្តប្រទូស្តបានធ្វើនូវការញ៉ាំងគភ៌ឲ្យធ្លាក់ចុះ ។ គភ៌របស់ស្រីរួមប្តីនោះ បានតែត្រឹម ២ ខែ ឈាមក៏ហូរចេញមក ឯមាតារបស់ស្រីរួមប្តីនោះក៏ក្រេវក្រោធនឹងខ្ញុំ ហើយបានបបួលញាតិទាំងឡាយ ញ៉ាំងខ្ញុំឲ្យធ្វើសម្បថផង ឲ្យផ្តាសាខ្លួនឯងផង ។ ខ្ញុំនោះ ក៏បានពោលនូវសម្បថដ៏ឃោរឃៅផង នូវពាក្យមុសាវាទផងថា បើខ្ញុំបានធ្វើអំពើអាក្រក់នេះមែន សូមឲ្យខ្ញុំទំពាស៊ីនូវសាច់នៃកូន ។ ដោយផលនៃកម្មនោះផង ដោយផលនៃមុសាវាទផង ទាំង ២ នេះ ខ្ញុំទើបបានទំពាស៊ីសាច់កូន ខ្លួនប្រឡាក់ដោយខ្ទុះ និងឈាម ដូច្នេះ ។

ស្រីរួមប្តី លោកហៅថា **សបតី** ក្នុងគាថានោះ ។ បទថា **តស្សា ចាបំ អចេតយឹ** បានដល់ បានគិតដល់កម្មអាក្រក់គ្រោតគ្រាតដល់ស្រីរួមប្តីនោះ ។ បទថា **បទុដ្ឋមនសា** ប្រែថា មានចិត្តគិតប្រទូស្ត ឬមានចិត្តគិតអាក្រក់ ។ បទថា **ទ្វេមាសិកោ** បានដល់ ស្រីនោះតាំងគភ៌ត្រឹមតែ ២ ខែ ឈ្មោះថា **ទ្វេមាសិក** គឺមានគភ៌ត្រឹម ២ ខែ ។ បទថា **លោហិតញ្ញោវ បគ្ឃរិ** សេចក្តីថា គភ៌វិបត្តិ ហូរចេញជាលោហិត ។ បទថា **តឆស្សា មាតា កុបិតា មយ្ហំ ញាតី សមានយិ** សេចក្តីថា ក្នុងកាលនោះ មាតាបិតារបស់ស្រីរួមប្តីនោះក្រោធខ្ញុំ ទើបប្រជុំពួកញាតិរបស់ខ្លួន ។ បាឋៈថា **តតស្សា** ដូច្នេះក៏មាន ។ បទថា **តតស្សា** នោះ ចែកបទជា **តតោ អស្សា** ។

បទថា **សបថំ** បានដល់ ការផ្តាសា ។ បទថា **បរិភាសាបយិ** បានដល់ សម្លុតឲ្យខ្លាច ។ បទថា **សបថំ មុសាវាធំ អភាសិសំ** សេចក្តីថា កាលខ្ញុំសម្តែងដល់កម្មអាក្រក់ដែលខ្លួនធ្វើនោះឯងថាមិនបានធ្វើ ពោលមុសាវាទ គឺពាក្យដែលមិនពិត បានដល់ ពាក្យស្បថថា បើកម្មអាក្រក់នោះខ្ញុំបានធ្វើហើយ សូមឲ្យខ្ញុំមានសភាពបែបនេះ ។ បទថា **បុត្តមំសានិ ខាទាមិ សចេ តំ បកតំ មយា** នេះជាបទសម្តែងអាការដែលធ្វើសម្បថក្នុងពេលនោះ អធិប្បាយថា បើខ្ញុំបានធ្វើអាក្រក់ គឺការធ្វើគភ៌ឲ្យធ្លាក់ទៅនោះក្នុងអនាគត គឺក្នុងការដែលខ្ញុំកើតក្នុងភពថ្មី សូមឲ្យខ្ញុំស៊ីសាច់កូនខ្លួនឯងប៉ុណ្ណោះ ។ បទថា **តស្ស កម្មស្ស** បានដល់ បាណាតិបាតកម្មដែលស្រីអារនោះធ្វើដោយធ្វើឲ្យគភ៌ធ្លាក់នោះ ។ បទថា **មុសាវាទស្ស ច** បានដល់ មុសាវាទកម្មផង ។

បទថា **ឧភយំ** បានដល់ ដោយវិបាកនៃកម្មទាំង ២ ។ ពិតហើយ បទថា **ឧភយំ** នេះ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថតតិយាវិភត្តិ ។ មានវាចាប្រកបសេចក្តីថា បទថា **បុត្តលោហិតមក្ខិតា** សេចក្តីថា ខ្ញុំប្រឡាក់ខ្ទុះនិងឈាមដោយអំណាចការហូរចេញនិងដោយអំណាចការបែក ទំពាស៊ីនូវសាច់កូន ។ ស្រីប្រេតនោះ កាលប្រកាសវិបាកនៃកម្មរបស់ខ្លួនយ៉ាងនេះហើយ ទើបពោលនឹងព្រះថេរៈយ៉ាងនេះទៀតថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំជាកិរិយានៃកុដុម្ពិកៈឈ្មោះនោះ ក្នុងស្រុកនោះឯង ជាស្រីមានសេចក្តីប្រណែនជាប្រក្រតី ធ្វើនូវកម្មអាក្រក់ ទើបកើតក្នុងកំណើតប្រេតយ៉ាងនេះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំសូមឱកាស សូមលោកទាំងឡាយទៅកាន់ផ្ទះរបស់កុដុម្ពិកៈនោះចុះ កុដុម្ពិកៈនោះនឹងថ្វាយទានដល់លោកទាំងឡាយ លោកទាំងឡាយគប្បីឲ្យគេឧទ្ទិសទក្ខិណានោះដល់ខ្ញុំកាលបើដូច្នោះ ខ្ញុំនឹងរួចផុតចាកបេតលោកនេះ ។ ព្រះថេរៈទាំងឡាយស្តាប់ដូច្នោះហើយ កាលអនុគ្រោះស្រីនោះ តាំងនៅក្នុងសភាវៈលើកឡើង ( មានបំណងនឹងជួយ ) ចូលទៅបិណ្ឌបាតក្នុងផ្ទះកុដុម្ពិកៈនោះ ។ កុដុម្ពិកៈឃើញព្រះថេរៈទាំងឡាយហើយ កើតសេចក្តីជ្រះថ្លាស្វាគមន៍ហើយទទួលបាត្រ និមន្តឲ្យគង់លើអាសនៈ និមន្តឲ្យឆាន់ដោយអាហារដ៏ប្រណីត ។ ព្រះថេរៈទាំងឡាយ ប្រាប់រឿងនោះដល់កុដុម្ពិកៈ ទើបឲ្យកុដុម្ពិកៈឧទ្ទិសទាននោះដល់ស្រីប្រេតនោះ ។ ខណៈនោះឯង ស្រីប្រេតនោះប្រាសចាកទុក្ខហើយ បានទទួលសម្បត្តិដ៏ក្រៃលែង បង្ហាញខ្លួនដល់កុដុម្ពិកៈក្នុងវេលារាត្រី ។ លំដាប់នោះ ព្រះថេរៈទាំងឡាយក៏ទៅកាន់ក្រុងសាវត្ថីដោយ

លំដាប់ ក្រាបទូលសេចក្ដីនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់បរិស័ទ ដែលដល់ព្រមហើយ ដោយលើករឿងនោះឡើងជាអត្ថុប្បត្តិហេតុ ។ ក្នុងកាលចប់ទេសនា មហាជនដល់នូវសេចក្ដីសង្វេគ វៀរចាកសេចក្ដីប្រណែននិងសេចក្ដីកំណាញ់ ទេសនានោះបានជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះឯង ។

## អដ្ឋកថា បញ្ចបុត្តខាទិកប្រេតចប់

# រឿង សត្តបុត្តខាទិកាប្រេត ទី ៧

[ ៧ ] ( ព្រះថេរៈទាំងឡាយសួរថា ) នាងជាស្រីអាក្រាត មានរូបសម្បុរអាក្រក់ មានក្លិនអាក្រក់ ស្អុយ តែងបក់ចេញទៅ នាងមានហ្វូងរុយចោមរោមហើយ តើជាស្រីអ្វី បានជាមកឋិតនៅក្នុងទីនេះ ។

( ប្រេតស្រីតបថា ) បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្តីទុក្ខ ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ព្រោះធ្វើអំពើអាក្រក់ ។ ក្នុងពេលព្រឹក ខ្ញុំសម្រាលកូន ៧ នាក់ ក្នុងពេលល្ងាច សម្រាលកូន ៧ នាក់ទៀត ហើយទំពាស៊ីកូនទាំងអស់នោះ ក៏មិនគ្រាន់ដល់ខ្ញុំឡើយ ។ ហឫទ័យរបស់ខ្ញុំក្តៅក្រហាយហុយផ្សែង ព្រោះសេចក្តីស្រេកឃ្លាន ខ្ញុំមិនបានសេចក្តីស្ងប់ទុក្ខ តែងក្តៅក្រហាយ ដូចជាបុគ្គលត្រូវភ្លើងឆេះ ។

( ព្រះថេរៈទាំងឡាយសួរថា ) អំពើអាក្រក់ដែលនាងធ្វើហើយដោយកាយ វាចា ចិត្ត ដូចម្តេចខ្លះ នាងទំពាស៊ីសាច់កូនព្រោះផលកម្មអ្វី ។

( នាងប្រេតតបថា ) ខ្ញុំមានកូន ២ នាក់ កូនទាំង ២ នាក់នោះ ពេញវ័យហើយ ខ្ញុំនោះអាស្រ័យកម្លាំងកូននោះ ក៏មើលងាយប្តី ។ តអំពីនោះមក ប្តីរបស់ខ្ញុំ ក្រេវក្រោធនឹងខ្ញុំហើយ បាននាំយកស្រីរួមប្តីដទៃទៀត ស្រីរួមប្តីបានតាំងគភ៌ហើយ ខ្ញុំបានគិតនូវអំពើដ៏អាក្រក់ដល់ស្រីនោះ ខ្ញុំនោះ មានចិត្តប្រទូស្ត បានធ្វើនូវការញុំាងគភ៌ឲ្យធ្លាក់ចុះ គភ៌នៃស្រីរួមប្តីបានតែត្រឹម ៣ ខែ មានខ្ទុះនិងឈាមធ្លាក់ចុះ មាតានៃស្រីរួមប្តីនោះ ក្រេវក្រោធនឹងខ្ញុំ បានបបួលពួកញាតិមក ឲ្យខ្ញុំធ្វើសម្បថផង ឲ្យខ្ញុំផ្តាសាខ្លួនឯងផង ។ ខ្ញុំនោះបានពោល

នូវសម្បថដ៏ឃោរឃៅផង នូវពាក្យមុសាវាទផងថា បើខ្ញុំបានធ្វើអំពើអាក្រក់នេះហើយ សូមឲ្យខ្ញុំទំពាស៊ីសាច់កូន ដោយផលកម្មនោះផង ដោយផលមុសាវាទផងទាំង ២ នេះ ទើបខ្ញុំទំពាស៊ីសាច់កូន ប្រឡាក់ដោយខ្ទុះនិងឈាមដូច្នេះ ។

## ចប់ រឿងសត្តបុត្តខាទិកប្រេតទី ៧ ។

# អដ្ឋកថា សត្តបុត្តខាទិកប្រេត

[ ៧ ] កាលព្រះសាស្តាគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធដល់ស្រីប្រេតស៊ីកូន ៧ នាក់ ទើបត្រាស់ពាក្យថា **នគ្គា ទុព្វណ្ណរូបាសិ** ដូច្នេះ ជាដើម ។

បានឮថា ឧបាសកម្នាក់នៅក្នុងតំបន់មួយ មិនឆ្ងាយអំពីក្រុងសាវត្ថី មានកូនប្រុស ២ នាក់ តាំងនៅក្នុងបឋមវ័យ សម្បូរដោយរូបឆោម ប្រកបដោយសីលនិងអាចារ មាតារបស់កូនទាំង ២ នោះគិតថា អញជាអ្នកមានកូន ទើបមើលងាយប្តីដោយកម្លាំងគឺបុត្ត ។ ស្វាមីនោះ ត្រូវភរិយាមើលងាយ មានចិត្តនឿយណាយ ទើបនាំស្រីដទៃមកគ្រប់គ្រង មិនយូរប៉ុន្មានស្រីនោះក៏តាំងគភ៌ ។ លំដាប់នោះ ភរិយាដើមជាស្រីមានសេចក្តីច្រណែនជាប្រក្រតី បានយកអាមិសទៅលួងលោមគ្រូម្នាក់ ឲ្យគ្រូនោះ ធ្វើគភ៌របស់ស្រីនោះដែលបាន ៣ ខែឲ្យធ្លាក់ ។ សម័យនោះ ស្រីនោះដែលពួកញាតិនិងបងប្អូនប្រុសសួរថា នាងធ្វើគភ៌របស់ស្រីនេះឲ្យធ្លាក់ឬ ក៏ពោលមុសាថា មិនបានធ្វើឲ្យធ្លាក់ឡើយ មនុស្សទាំងនោះមិនជឿទើបពោលថា ចូរនាងស្បថ ហើយបានធ្វើ

សម្បថថា សូមឲ្យខ្ញុំកើតកូនព្រឹក ៧ ល្ងាច ៧ ទំពាស៊ីសាច់កូន សូមឲ្យខ្ញុំមានក្លិនស្អុយ រុយចោមរោមជានិច្ច ។

ក្នុងកាលតមក នាងធ្វើកាលកិរិយា ទៅកើតក្នុងកំណើតប្រេត ដោយវិបាកនៃការធ្វើគភ៌ឲ្យធ្លាក់និងពោលមុសានោះឯង ទើបទំពាស៊ីសាច់កូនដោយន័យដូចពោលហើយ ត្រាច់ទៅមិនឆ្ងាយអំពីស្រុកនោះ ។ គ្រានោះ ព្រះថេរៈច្រើនរូបចេញវស្សាក្នុងស្រុក មកកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះមានព្រះភាគ សម្រាកនៅក្នុងចំណែកមួយមិនឆ្ងាយអំពីស្រុកនោះ ។ កាលនោះ ស្រីប្រេតនោះបង្ហាញខ្លួនដល់ព្រះថេរៈទាំងនោះ ព្រះថេរៈសួរដោយគាថាថា

នាងជាស្រីអាក្រាត មានរូប សម្បុរអាក្រក់ មានក្លិនអាក្រក់ស្អុយ តែងបក់ចេញទៅ នាងមានហ្វូងរុយចោមរោមហើយ តើជាស្រីអ្វី បានជាមកឋិតនៅក្នុងទីនេះ ដូច្នេះ ។

ស្រីប្រេតត្រូវព្រះថេរៈសួរ បានឆ្លើយដោយគាថា ៣ ថា

បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន ខ្ញុំជាស្រីប្រេតដល់នូវសេចក្តីទុក្ខ ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយបានទៅកាន់បេតលោក ព្រោះធ្វើអំពើអាក្រក់ ។ ក្នុងពេលព្រឹក ខ្ញុំសម្រាលកូន ៧ នាក់ ក្នុងពេលល្ងាចសម្រាលកូន ៧ នាក់ទៀត ហើយទំពាស៊ីកូនទាំងអស់នោះ ក៏មិនគ្រាន់ដល់ខ្ញុំឡើយ ។ ហឫទ័យរបស់ខ្ញុំក្តៅក្រហាយ ហុយផ្សែងព្រោះសេចក្តីស្រេកឃ្លាន ខ្ញុំមិនបានសេចក្តីស្ងប់ទុក្ខ តែងក្តៅក្រហាយ

ដូចជាបុគ្គលត្រូវភ្លើងឆេះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឆិញ្ញតី** បានដល់ ស្ងប់រម្ងាប់ទុក្ខដែលកើតអំពីសេចក្តីស្រេកឃ្លាន ។ បទថា **ឆាធិគច្ឆាមិ** បានដល់ មិនបានទទួល ។ ដោយបទថា **អគ្គិទឌ្ឍាវ អាតបេ** នេះជាវាចាប្រកបសេចក្តីថា ខ្ញុំដូចត្រូវភ្លើងឆេះក្នុងទីកណ្តាលថ្ងៃ មិនបានទទួលសេចក្តីត្រជាក់ ។

ព្រះមហាថេរៈបានស្តាប់ដូច្នោះ កាលនឹងសួរដល់កម្មដែលស្រីប្រេតនោះធ្វើ ទើបពោលគាថាថា

អំពើអាក្រក់ដែលនាងធ្វើហើយដោយកាយ វាចា ចិត្ត ដូចម្តេចខ្លះ នាងទំពាស៊ីសាច់កូនព្រោះផលកម្មអ្វី ។

គ្រានោះ ស្រីប្រេតកាលប្រាប់ដល់ភាពដែលខ្លួនកើតក្នុងបេតលោក និងហេតុដែលទំពាស៊ីសាច់កូន ទើបពោលគាថានេះថា

ខ្ញុំមានកូន ២ នាក់ កូនទាំង ២ នាក់នោះពេញវ័យហើយ ខ្ញុំនោះអាស្រ័យកម្លាំងកូននោះ ក៏មើលងាយប្តី ។ តអំពីនោះមកប្តីរបស់ខ្ញុំក្រេវក្រោធនឹងខ្ញុំហើយ បាននាំយកស្រីរួមប្តីដទៃទៀត ស្រីរួមប្តីបានតាំងគភ៌ហើយ ខ្ញុំបានគិតនូវអំពើដ៏អាក្រក់ ដល់ស្រីនោះ ខ្ញុំនោះ មានចិត្តប្រទូស្ត បានធ្វើនូវការញុំាងគភ៌ឲ្យធ្លាក់ចុះ គភ៌នៃស្រីរួមប្តី បានតែត្រឹម ៣ ខែ មានខ្ទុះនិងឈាមធ្លាក់ចុះ មាតានៃស្រីរួមប្តីនោះ ក្រេវក្រោធនឹងខ្ញុំ បានបបួលពួកញាតិមក ឲ្យខ្ញុំធ្វើសម្បថផង ឲ្យខ្ញុំផ្តាសាខ្លួនឯងផង ។ ខ្ញុំ

នោះបានពោលនូវសម្បថ ដ៏ឃោរឃៅផង នូវពាក្យមុសាវាទផងថា បើខ្ញុំបានធ្វើអំពើអាក្រក់នេះហើយ សូមឲ្យខ្ញុំទំពាស៊ីសាច់កូន ដោយផលកម្មនោះផង ដោយផលមុសាវាទផងទាំង ២ នេះ ទើបខ្ញុំទំពាស៊ីសាច់កូន ប្រឡាក់ដោយខ្ទុះនិងឈាម ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុត្តពល្លូបេតា** បានដល់ អាស្រ័យកម្លាំង គឺកូន គឺបានកម្លាំងដោយអំណាចកូន ។ បទថា **អតិមញ្ញិស្សំ** បានដល់ មើលងាយពន់ពេក ។ បទថា **បូតិលោហិតកោ បតិ** បានដល់ គគ្រិហូរចេញជាលោហិតដែលមានក្លិនស្អុយ ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលជាលំដាប់មកនោះឯង ។ ក្នុងរឿងនោះ មានព្រះថេរៈ ៨ រូប តែក្នុងរឿងនេះ មានព្រះថេរៈច្រើន ។ ក្នុងរឿងនោះមានកូន ៥ តែក្នុងរឿងនេះមានកូន ៧ នេះជាការខុសប្លែកគ្នា ។

## អដ្ឋកថា សត្តបុត្តខាទិកប្រេតចប់

# រឿង គោណាប្រេតទី៨

[ ៨ ] ( បិតាសួរថា ) អ្នកមានសភាពជាបុគ្គលឆ្កួតទេដឹង បានជាអ្នកប្រូតស្មៅខ្ចីយកមកនិយាយនឹងគោចាស់ ដែលជាសត្វប្រាសចាកជីវិតថា ចូរស៊ីចុះៗដូច្នេះ ។ ធម្មតាគោដែលស្លាប់ហើយ មិនដែលក្រោកឡើងបានដោយស្មៅនិងទឹកទេ អ្នកជាបុគ្គលពាលអប្បបញ្ញា ប្រហែលនឹងបុគ្គលល្ងង់ខ្លៅដទៃដែរ ។

( កូនតបថា ) នេះជាជើង នេះជាក្បាល នេះជាខ្លួន ព្រមទាំងកន្ទុយនេះក្អែករបស់គោ ឋិតនៅក្នុងទីដូចដែល គោនេះគប្បីក្រោកឡើងបាន ដៃជើងខ្លួននិងក្បាលរបស់ជីតាមិនប្រាកដ ក្រែងអ្នកដែលយំលើផ្នូរដីទេដឹងជាបុគ្គលល្ងង់ ។

( បិតាពោលថា ) អ្នកស្រោចស្រពយើង ដែលភ្លើងឆេះហើយ ញុំាងសេចក្ដីក្ដៅក្រហាយទាំងពួងឲ្យរម្ងាប់ ដូចបុគ្គលយកទឹកស្រោចលត់ភ្លើងដែលឆេះឆ្នាំងខ្លាញ់ សរគឺសេចក្ដីសោកដែលអាស្រ័យនៅក្នុងហឫទ័យយើង អ្នកបានដកចោលហើយ កាលយើងត្រូវសេចក្ដីសោកចំពោះបិតាគ្របសង្កត់ អ្នកដែលចេះបន្ទោបង់សេចក្ដីសោកបាន យើងនោះឈ្មោះថា មានសរគឺសេចក្ដីសោកដែលអ្នកដកចោលហើយ មានសេចក្ដីត្រជាក់កើតហើយ មានទុក្ខរលត់ហើយ ម្នាលមាណព យើងលែងសោយសោក លែងយំហើយ ព្រោះបានស្ដាប់វាចារបស់អ្នក ជនទាំងឡាយណា ប្រកបដោយបញ្ញា ជាអ្នកអនុគ្រោះជនទាំងនោះ តែងធ្វើយ៉ាងនេះ ដូចជាសុជាតមាណព បានញុំាងបិតាឲ្យត្រឡប់ចាកសេចក្ដីសោកដូច្នោះ ។

ចប់ រឿងគោណាប្រេតទី ៨ ។

# អដ្ឋកថា គោឈាប្រេត

[ ៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ដែលមានឪពុកស្លាប់ ទើបត្រាស់ពាក្យថា **កឹ នុ ឧម្មត្តរូបោវ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី បិតារបស់កុដុម្ពិកៈម្នាក់បានស្លាប់ទៅ ព្រោះបិតាស្លាប់ទៅ បុរសនោះក៏សោយសោក ដល់នូវសេចក្តីទុក្ខ ដើរយំដូចជាមនុស្សឆ្កួត សួរមនុស្សដែលខ្លួនឃើញថា លោកឃើញឪពុករបស់ខ្ញុំដែរឬទេ បុគ្គលណាមួយ មិនអាចបន្ទោបង់សេចក្តីសោករបស់គាត់បាន ។ តែឧបនិស្ស័យនៃសោតាបត្តិផល ឆេះសន្ធោសន្ធៅក្នុងហទយៈរបស់គាត់ ដូចប្រទីបដែលឆេះក្នុងថ្នាំង ។ ក្នុងវេលាទៀបភ្លឺ ព្រះសាស្តាប្រមើលមើលសត្វ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផល ទ្រង់ត្រិះរិះថា តថាគតគួរនាំហេតុជាអតីតរបស់កុដុម្ពិកៈនេះមក ហើយរម្ងាប់សេចក្តីសោក ឲ្យសោតាបត្តិផលដល់គេ ដូច្នេះហើយ ភ្លឺឡើង ទើបត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្តមិនបាននាំបុគ្គលណាទៅជាបច្ឆាសមណៈ ទៅកាន់ទ្វារផ្ទះរបស់កុដុម្ពិកៈនោះ ។ បុរសនោះបានឮថា ព្រះសាស្តាយាងមក ទើបទទួល និមន្តព្រះសាស្តាឲ្យយាងចូលទៅកាន់ផ្ទះ កាលព្រះសាស្តាគង់លើអាសនៈដែលរៀបចំទុក ខ្លួនឯងក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជ្រាបទីដែលបិតារបស់ខ្ញុំព្រះអង្គទៅដែរឬ លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក អ្នកសួរដល់បិតាក្នុងអត្តភាពនេះឬ ឬសួរដល់អត្តភាពដែលកន្លងទៅហើយ បុរសនោះបាន

ស្លាប់ដូច្នោះក៏គិតថា អញមានបិតាច្រើន ដូច្នេះ ទើបប្រាសចាកសេចក្តីសោក ទទួលសេចក្តីសោកត្រឹមតែពាក់កណ្តាល ។ គ្រានោះ ព្រះសាស្តាត្រាស់ធម្មកថាដែលជាគ្រឿងបន្ទោបង់សេចក្តីសោកដល់បុរសនោះ ទ្រង់ជ្រាបថា បុរសនោះប្រាសចាកសេចក្តីសោក មានចិត្តសមគួរ ទើបឲ្យតាំងនៅក្នុងសោតាបត្តិផល ដោយសាមុក្កំសិកធម្មទេសនា បានយាងទៅកាន់ព្រះវិហារ ។

សម័យនោះ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ លោកទាំងឡាយចូរមើលពុទ្ធានុភាពចុះ ឧបាសកដែលដល់ព្រមដោយសេចក្តីសោកខ្សឹកខ្សួលយ៉ាងនោះ ព្រះមានព្រះភាគ ក៏គង់ទូន្មានឲ្យនូវសោតាបត្តិផលក្នុងខណៈនោះឯងបាន ។ ព្រះសាស្តាយាងទៅក្នុងទីនោះ គង់លើបវរពុទ្ធាសនៈដែលគេក្រាលទុកហើយ ទើបត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយក៏ទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះទេ ដែលតថាគតកម្ចាត់សេចក្តីសោក របស់កុដុម្ពិកៈនេះ សូម្បីក្នុងកាលមុន ក៏បានកម្ចាត់ដូចគ្នា ដូច្នេះហើយ កាលភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ក្នុងក្រុងពារាណសី ឪពុករបស់កុដុម្ពិកៈម្នាក់បានស្លាប់ទៅ ។ ព្រោះបិតាស្លាប់ កុដុម្ពិកៈនោះក៏ដល់ព្រមដោយសេចក្តីសោក មានមុខជោកដោយទឹកភ្នែក មានភ្នែកក្រហម កន្ទក់កន្ទេញ ដើរប្រទក្សិណជើងថ្ករ ។ កូនរបស់កុដុម្ពិកៈនោះ ឈ្មោះសុជាត នៅក្មេង តែជាអ្នកឈ្លាសវៃ

បរិបូណ៌ដោយបញ្ញា ទើបគិតរកឧបាយកម្ចាត់សេចក្តីសោករបស់ឪពុក ។ ថ្ងៃមួយ ឃើញគោស្លាប់ ខាងក្រៅក្រុង ក៏នាំយកស្មៅនិងទឹកមកដាក់ខាងមុខរបស់គោដែលស្លាប់ហើយនោះ ឈរពោលថា ចូរស៊ី ចូរស៊ី ចូរផឹក ចូរផឹកចុះ ។ អ្នកដែលដើរច្លងកាត់ទៅមកឃើញ ក៏ពោលថា អើសម្លាញ់សុជាតឯងឆ្កួតទៅហើយឬដែលឯងរកស្មៅនិងទឹកទៅឲ្យគោស្លាប់ ។ សុជាតមិនបានឆ្លើយឆ្លងជាមួយបុគ្គលណាមួយឡើយ ពួកមនុស្ស ក៏នាំគ្នាទៅរកបិតារបស់សុជាតហើយពោលថា កូនរបស់អ្នកឆ្កួតហើយ យកស្មៅនិងទឹកឲ្យគោស្លាប់ស៊ី ។ ព្រោះបានស្តាប់ដូច្នោះ កុដុម្ពិកៈប្រាសចាកសេចក្តីសោកដែលកើតឡើងព្រោះប្រារព្ធដល់បិតា ។ គាត់ដល់នូវសេចក្តីសង្វេគថា បានឮថា កូនរបស់អញឆ្កួត ទើបប្រញាប់ទៅ សួរថា នែសុជាត បាជាអ្នកឈ្លាសវៃ សម្បូរដោយបញ្ញាមិនមែនឬ តែហេតុអ្វី ទើបយកស្មៅនិងទឹកឲ្យគោដែលស្លាប់ស៊ី ទើបពោល ២ គាថាថា

> អ្នកមានសភាពជាបុគ្គលឆ្កួតទេដឹង បានជាអ្នកប្រូតស្មៅខ្ចីយកមកនិយាយនឹងគោចាស់ ដែលជាសត្វប្រាសចាកជីវិតថា ចូរស៊ីចុះ ៗ ដូច្នេះ ។ ធម្មតាគោដែលស្លាប់ហើយ មិនដែលក្រោកឡើងបាន ដោយស្មៅនឹងទឹកទេ អ្នកជាបុគ្គលពាលអប្បបញ្ញា ប្រហែលនឹងបុគ្គលល្ងង់ខ្លៅដទៃដែរ ។

ក្នុងបទទាំងនោះ បទថា **កឹ នុ** ជាពាក្យសួរ ។ បទថា **ឧម្មត្តរូបោវ** បានដល់ អ្នកដូចជាមនុស្សឆ្កួត គឺដល់នូវការវាយមាយនៃចិត្ត ។ បទថា **លា-**

**យិត្វា** ប្រែថា ប្រូត ។ បទថា **ហរិតំ តិណំ** បានដល់ ស្មៅស្រស់ ។ បទថា **លបសិ** បានដល់ និយាយផ្ដេសផ្ដាស ។ បទថា **គតសត្តំ** បានដល់ ប្រាសចាកជីវិត ។ បទថា **ជរគ្គវំ** បានដល់ គោឈ្មោលដែលជាគោចាស់ ។ បទថា **អន្នេន ចានេន** បានដល់ ស្មៅដែលខៀវស្រស់និងទឹកផឹកដែលអ្នកឲ្យ ។ បទថា **មតោ គោណោ សមុដ្ឋហេ** បានដល់ គោដែលស្លាប់ហើយមិនមានជីវិត ក្រោកឡើងមិនបាន ។ បទថា **ត្វំសិ ពាលោ ច ទុម្មេធោ** សេចក្ដីថា អ្នកឈ្មោះថា ជាបុគ្គលពាល ព្រោះប្រកបដោយភាពជាបុគ្គលពាល ឈ្មោះថា ជាអ្នកមានបញ្ញាថោកថយ ព្រោះមិនមានបញ្ញា ពោលគឺមេធា ។ បទថា **យថា តញ្ញោវ ទុម្មតិ** សេចក្ដីថា សូម្បីបុគ្គលដទៃដែលឥតបញ្ញាក៏គប្បីរវើរវាយយ៉ាងណា ខ្លួនអ្នកក៏រវើរវាយដល់វត្ថុឥតប្រយោជន៍យ៉ាងនោះ ។ បទថា **យថា តំ** ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត បទថា **ទុម្មតិ** សេចក្ដីថា អ្នកសូម្បីជាបុគ្គលមានបញ្ញា ក៏ងើយមុខរវើរវាយដូចមនុស្សឆ្កួតដទៃៗ ។

សុជាតកុមារបានស្ដាប់ដូច្នោះ កាលប្រកាសបំណងរបស់ខ្លួន ដើម្បីឲ្យបិតាយល់ព្រម ទើបពោល ២ គាថាថា

> នេះជាជើង នេះជាក្បាល នេះជាខ្លួន ព្រមទាំងកន្ទុយ នេះភ្នែករបស់គោ ឋិតនៅក្នុងទីដូចដែល គោនេះគប្បីក្រោកឡើងបាន ដៃជើងខ្លួននិងក្បាលរបស់ជីតាមិនប្រាកដ គ្រែងអ្នកដែលយំលើផ្នូរដីទេដឹង ជាបុគ្គលល្ងង់ ដូច្នេះ ។

អត្ថនៃគាថានោះ មានអធិប្បាយដូច្នេះថា គោនេះមានជើង ៤ មាន

ក្បាល មានកាយមួយអន្ទើដោយកន្ទុយ ព្រោះប្រព្រឹត្តទៅដោយកន្ទុយនិង មានភ្នែក គឺនេត្រា មានទ្រង់ទ្រាយមិនបែកធ្លាយ តាំងនៅដូចមុនពេលស្លាប់ ។ បទថា **អយំ គោណោ សមុដ្ឋហេ** សេចក្តីថា ព្រោះហេតុនេះ ទើបខ្ញុំគិតថា គោនេះគប្បីក្រោកឡើង គឺគប្បីឈរបានឯង ។ អាចារ្យពួកខ្លះពោលថា គោប្រហែលជាក្រោកឡើងបាន ។ ព្រោះហេតុនោះ ទើបខ្ញុំយល់ថា គោនេះគប្បីគ្រាហ៍ឲ្យក្រោកឡើងបានដោយរួសរាន់ អធិប្បាយថា ខ្ញុំយល់យ៉ាងនេះ ។ សុជាតកុមារពោលធម៌ដល់បិតាថា ដៃ ជើង កាយ ក្បាលរបស់ជីតាខ្ញុំមិនប្រាកដ តែលោកឪពុកយំត្រង់ផ្នូរដីដែលសាងបញ្ចុះធ្អឹងរបស់ជីតាតែម្យ៉ាង ជាអ្នកមានបញ្ញាថោកថយ គឺមិនមានបញ្ញារាប់រយជង រាប់ពាន់ជង សង្ខារទាំងឡាយ មានការបែកធ្លាយទៅជាធម្មតា រមែងបែកទៅ បុគ្គលដឹងច្បាស់ក្នុងសេចក្តីនោះ តើមានការកន្ទក់កន្ទេញធ្វើអ្វី ។

បិតារបស់ព្រះពោធិសត្វ ស្តាប់ដូច្នោះហើយ គិតថា កូនរបស់អញជាបណ្ឌិត បានធ្វើកម្មនេះដើម្បីឲ្យអញយល់ កាលសរសើរបុត្តថា នែបាសុជាត យើងបានដឹងហើយថា សត្វទាំងពួងមានការស្លាប់ជាធម្មតា ចាប់អំពីនេះទៅ យើងមិនសោកស្តាយ បុរសមានបញ្ញាដែលឈ្មោះថា អាចកម្ចាត់សេចក្តីសោកបានគប្បីដូចគ្នានឹងអ្នកនេះឯង ទើបពោល ៤ គាថាថា

អ្នកស្រោចស្រពយើងដែលភ្លើងឆេះហើយ ញុំាងសេចក្តីក្តៅ
ក្រហាយទាំងពួងឲ្យរម្ងាប់ ដូចបុគ្គលយកទឹកស្រោចលត់ភ្លើង
ដែលឆេះធ្លាំងខ្លាញ់ សរគឺសេចក្តីសោកដែលអាស្រ័យនៅក្នុង

ហឫទ័យយើង អ្នកបានដកចោលហើយ កាលយើងត្រូវសេចក្តីសោកចំពោះបិតាគ្របសង្កត់ អ្នកដែលចេះបន្ទោបង់សេចក្តីសោកបាន យើងនោះ ឈ្មោះថា មានសរគឺសេចក្តីសោកដែលអ្នកដកចោលហើយ មានសេចក្តីត្រជាក់កើតហើយមានទុក្ខរលត់ហើយ ម្នាលមាណព យើងលែងសោយសោក លែងយំហើយ ព្រោះបានស្តាប់វាចារបស់អ្នក ជនទាំងឡាយណាប្រកបដោយបញ្ញា ជាអ្នកអនុគ្រោះ ជនទាំងនោះតែងធ្វើយ៉ាងនេះ ដូចជាសុជាតមាណព បានញុំាងបិតាឲ្យត្រឡប់ចាកសេចក្តីសោកដូច្នោះ ។

ក្នុងបទទាំងនោះ បទថា **អាទិត្តំ** បានដល់ ដែលក្តៅ គឺសេចក្តីសោកឆេះទូទៅហើយ គឺឆេះហើយ ។ បទថា **សន្តំ** ប្រែថា មាន ។ បទថា **ចាវកំ** ប្រែថា ក្តៅ ។ បទថា **វារិនា វិយ ឱសិញ្ចំ** ប្រែថា ដូចយកទឹកស្រោច ។ បទថា **សព្វំ និព្វាបយេ ទរំ** សេចក្តីថា ឲ្យនូវការក្រវល់ក្រវាយនៃចិត្តរបស់យើងរលត់ ។ បទថា **អព្វហី វត** ប្រែថា ដកឡើងហើយ ។ បទថា **សល្លំ** បានដល់ ព្រួញ គឺសេចក្តីសោក ។ បទថា **ហទយនិស្សិតំ** បានដល់ ដូចព្រួញដែលទម្លុះហទយៈ ។ បទថា **សោកបរេតស្ស** បានដល់ត្រូវសេចក្តីសោកគ្របសង្កត់ ។ បទថា **បិតុសោកំ** បានដល់ នូវសេចក្តីសោកដែលកើតឡើងព្រោះប្រារព្ធបិតា ។ បទថា **អបានុទិ** បានដល់ បានកម្ចាត់ហើយ ។ បទថា **តវ សុត្វាន មាណវ** សេចក្តីថា នៃកុមារ ព្រោះ

បានស្តាប់ពាក្យរបស់អ្នកហើយ ចាប់ពីនេះតទៅ ឪពុកមិនសោយសោក មិនយំឡើយ ។ បទថា **សុជាតោ បិតរំ យថា** សេចក្តីថា សុជាតកុមារនេះឲ្យបិតារបស់ខ្លួនផុតចាកសេចក្តីសោក យ៉ាងណា សូម្បីជនដទៃក៏យ៉ាងនោះ ជាអ្នកអនុគ្រោះ មានការអនុគ្រោះជាប្រក្រតី មានបញ្ញាធ្វើយ៉ាងនោះ គឺធ្វើឧបការៈដល់បិតានិងជនដទៃ ។

បិតាស្តាប់ពាក្យរបស់មាណពហើយ ជាអ្នកប្រាសចាកសេចក្តីសោកទើបកក់សក់ បរិភោគអាហារ ប្រកបការងារ ធ្វើកាលកិរិយាហើយ ជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ។ ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយទើបប្រកាសសច្ចៈដល់ភិក្ខុទាំងនោះ កាលចប់សច្ចៈ មហាជនសម្រេចសោតាបត្តិផលជាដើម ។ សុជាតកុមារក្នុងកាលនោះ គឺព្រះលោកនាថក្នុងកាលឥឡូវនេះឯង ។

## អដ្ឋកថា គោណប្រេតចប់

## រឿង មហាបេសការប្រេត ទី ៩

[ ៩ ] ( ភិក្ខុសួរថា ) នារីណា មានខ្ទុះនិងឈាមជាអាហារ សព្វកាល នារីនេះតែងបរិភោគលាមកផង មូត្រផង ឈាមផង ខ្ទុះផង នេះជាវិបាកនៃកម្មអ្វី នារីនោះបានធ្វើអំពើដូចម្តេចហ្ន៎ សំពត់ទាំងឡាយថ្មីៗផង ល្អៗផង មានសាច់ទន់ផង បរិសុទ្ធផង ប្រកបដោយរោមផង គេបានឲ្យដល់នារីនោះហើយ ក៏ប្រាកដដូចជាលោហៈទៅវិញ ចុះនារីនេះបានធ្វើអំពើដូចម្តេច ។

( ទេវតាប្រាប់ថា ) បពិត្រលោកដ៏ចម្រើន នារីនេះ ជាភរិយារបស់ខ្ញុំ ជាស្រីមិនដែលឲ្យវត្ថុអ្វីដល់អ្នកណាមួយឡើយ ជាស្រីកំណាញ់ស្វិតស្វាញតែងជេរប្រទេចផ្តាសានូវខ្ញុំ ដែលកំពុងឲ្យទានដល់សមណព្រាហ្មណ៍ទាំងឡាយថា អ្នកចូរស៊ីលាមកផង មូត្រផង ឈាមផង ខ្ទុះផង ដែលជារបស់មិនស្អាតសព្វកាលចុះ ផលនេះចូរកើតមានដល់អ្នកក្នុងបរលោកចុះ សំពត់មានផែនដូចលោហៈ ចូរមានដល់អ្នកចុះ លុះនារីនោះ ប្រព្រឹត្តអំពើទុច្ចរិត ប្រាកដដូច្នេះហើយ មកកាន់ទីនេះ ទើបបានទទួលផល ( ដ៏ក្រហល់ក្រហាយ ) អស់រាត្រីដ៏យូរអង្វែង ។

**ចប់ រឿងមហាបេសការប្រេតទី ៩ ។**

## អដ្ឋកថា មហាបេសការប្រេត

[ ៩ ] កាលព្រះសាស្តាគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធដល់ស្រីប្រេតដែលជាកូនជាងតម្បាញម្នាក់ ទើបត្រាស់ពាក្យនេះមានពាក្យផ្តើមថា **គូថញ្ច មុត្តំ រុធិរញ្ច បុព្វំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុប្រមាណ ១២ រូប រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ពិចារណាដល់ទីសមគួរសម្រាប់នៅ កាលទៀបចូលវស្សា ឃើញដងព្រៃគួរជាទីត្រេកអរ សម្បូរដោយម្ហូបនិងទឹកមួយកន្លែង និងគោចរគាមនៅមិនឆ្ងាយមិនជិតអំពីដងព្រៃនោះ ទើបនៅក្នុងទីនោះមួយរាត្រី ស្អែកឡើងត្រាច់បិណ្ឌបាតក្នុងស្រុក ។

ក្នុងស្រុកនោះ មានជាងតម្បាញ ១១ នាក់នៅអាស្រ័យ ឃើញពួកភិក្ខុទាំងនោះ ក៏កើតសោមនស្ស ទើបនាំមកកាន់ផ្ទះរៀងៗខ្លួន អង្គាសដោយអាហារដ៏ប្រណីត ហើយសាកសួរថា លោកម្ចាស់គិតនិមន្តទៅណា ភិក្ខុទាំងនោះពោលថា អាត្មានឹងទៅក្នុងទីដែលជាសប្បាយ ។ ពួកជាងតម្បាញទាំងនោះពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់នៅក្នុងទីនេះឯងដូច្នេះហើយ ទើបនិមន្តឲ្យនៅចាំវស្សា ។ ភិក្ខុទាំងឡាយក៏ទទួលពាក្យ ។ ឧបាសក ឧបាសិកាទាំងឡាយនាំគ្នាសាងតូបក្នុងព្រៃ ក្នុងទីនោះ ហើយវេរប្រគេនដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយចាំវស្សាក្នុងទីនោះឯង ។

បណ្តាជាងតម្បាញទាំងនោះ ជាងតម្បាញដែលជាប្រធានឧបដ្ឋាកភិក្ខុ ២ រូប ដោយបច្ច័យ ៤ ដោយគោរព ក្រៅអំពីនោះបានឧបដ្ឋាកភិក្ខុម្នាក់មួយរូប ។ ភរិយារបស់ជាងតម្បាញដែលជាប្រធាន មិនមានសទ្ធា មិនមានការ

ជ្រះថ្លា ជាមនុស្សមិច្ឆាទិដ្ឋិ មានសេចក្តីកំណាញ់ មិនឧបដ្ឋាកភិក្ខុទាំងឡាយដោយគោរព ។ ជាងតម្បាញជាប្រធានឃើញដូច្នោះ ក៏នាំយកប្អូនស្រីរបស់ភរិយានោះឯងមក ហើយប្រគល់ភាពជាធំក្នុងផ្ទះរបស់ខ្លួន ។ ប្អូនស្រីនោះជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា ប្រណិប័តន៍ភិក្ខុទាំងឡាយដោយគោរព ជាងតម្បាញទាំងអស់នោះ បានប្រគេនសំពត់សាដកដល់ភិក្ខុដែលចាំវស្សា មួយរូបមួយផ្ទាំង ។ ក្នុងបណ្តាភរិយានោះ ភរិយារបស់ជាងតម្បាញដែលជាប្រធាន ជាអ្នកមានសេចក្តីកំណាញ់ មានចិត្តគិតប្រទូស្ត ជេរបរិភាសប្តីរបស់ខ្លួនថា ទាន គឺបាយនិងទឹកដែលលោកឲ្យដល់សមណសក្យបុត្តនោះ ចូរកើតជាលាមក មូត្រ ជាខ្ទុះនិងឈាមដល់លោកក្នុងបរលោក សំពត់សាដកចូរក្លាយជាបន្ទះដែកឆេះប្រាលឆ្អៅ ។

សម័យក្រោយមក បណ្តាមនុស្សទាំងនោះ ជាងតម្បាញដែលជាប្រធានធ្វើកាលកិរិយាហើយ កើតជារុក្ខទេវតា ដល់ព្រមដោយអានុភាពក្នុងព្រៃវិញ្ឈៈ ( ព្រៃដែលមានផ្លូវកន្តារច្ឆងកាត់ ) តែភរិយាដើមរបស់គាត់ ធ្វើកាលកិរិយាហើយ កើតជាស្រីប្រេត ក្នុងទីមិនឆ្ងាយអំពីលំនៅរបស់រុក្ខទេវតានោះឯង នាងជាស្រីអាក្រាត មានរូបអាក្រក់ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ ទៅកាន់សម្នាក់របស់ភុម្មទេវតានោះហើយ ពោលថា លោក ខ្ញុំមិនមានសំពត់ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ពន់ពេកត្រាច់ទៅ ចូរលោកឲ្យសំពត់ បាយនិងទឹកដល់ខ្ញុំចុះ ។ ភុម្មទេវតាក៏បង្អោនបាយទឹកដែលជាទិព្វដល់ស្រីប្រេតនោះ ។ លុះស្រីប្រេតទទួលប៉ុណ្ណោះ ក៏ក្លាយជាលាមក មូត្រ ខ្ទុះនិងឈាម សំពត់

សាដកដែលឲ្យគ្រាន់តែនាងដណ្តប់ ក៏ក្លាយជាបន្ទះដែក ឆេះសន្ធោសន្ធៅ នាងសោយទុក្ខយ៉ាងមហន្ត នាងគ្រវាត់សំពត់នោះចោល ហើយដើរទៅ ។

សម័យនោះ ភិក្ខុមួយរូបចេញវស្សាហើយ ធ្វើដំណើរទៅគាល់ព្រះសាស្តា ដើរទៅដល់ព្រៃវិញ្ឈៈ មួយអន្លើដោយក្រុមអ្នករទេះ ។ ពួកអ្នករទេះធ្វើដំណើរក្នុងពេលយប់ ក្នុងពេលថ្ងៃ ឃើញប្រទេសមួយកន្លែង សម្បូរដោយម្លប់ត្រជាក់និងទឹកក្នុងព្រៃ ទើបដាក់រទេះ ហើយសម្រាកមួយស្របក់ ។ ឯភិក្ខុចៀសចេញទៅបន្តិច ព្រោះប្រាថ្នាវិវេក ក្រាលសង្ឃាដីត្រង់គល់ឈើដែលបិទបាំងដោយគុម្ពោតព្រៃដែលមានម្លប់ត្រជាក់មួយដើម ហើយសិង មានរាងកាយទន់ខ្សោយ ព្រោះអស់កម្លាំងក្នុងការដើរពេលរាត្រី ក៏សិងលក់ទៅ ។ ពួករទេះកាលសម្រាកហើយ ក៏ចេញដំណើរទៅទៀត ។ ភិក្ខុនោះក៏មិនទាន់ភ្ញាក់ លុះដល់ពេលល្ងាច ក៏ក្រោកឡើង មិនឃើញពួករទេះទាំងនោះ ក៏ធ្វើដំណើរ ទៅតាមផ្លូវមួយ ដល់ទីលំនៅរបស់ទេវតានោះដោយលំដាប់ ។ លំដាប់នោះ ទេវបុត្តឃើញភិក្ខុនោះហើយ កាឡាខ្លួនជាមនុស្សចូលទៅរក ធ្វើបដិសណ្ឋារៈ និមន្តឲ្យចូលទៅកាន់វិមានរបស់ខ្លួន ប្រគេនភេសជ្ជៈ មានថ្នាំលាបជើងជាដើម ហើយចូលទៅអង្គុយជិត ។ សម័យនោះ ស្រីប្រេតមកពោលថា សូមលោកឲ្យបាយ ទឹកនិងសំពត់ សាដកដល់ខ្ញុំចុះ ។ ទេវបុត្តនោះបានឲ្យរបស់ទាំងនោះ ដល់ស្រីប្រេតនោះ របស់ទាំងនោះគ្រាន់តែនាងទទួល ក៏ក្លាយជាលាមក មូត្រ ខ្ទុះ ឈាមនិងបន្ទះដែក ឆេះសន្ធោសន្ធៅនោះឯង ។ ភិក្ខុនោះឃើញដូច្នោះ ក៏កើតសេចក្តីសង្វេគ ទើបសាកសួរទេវ

បុត្តនោះដោយគាថា ២ ថា

នារីណា មានខ្ទុះនិងឈាមជាអាហារសព្វកាល នារីនេះតែង បរិភោគលាមកផង មូត្រផង ឈាមផង ខ្ទុះផង នេះជា វិបាកនៃកម្មអ្វី នារីនោះបានធ្វើអំពើដូចម្ដេចហ្ន៎ សំពត់ទាំងឡាយ ថ្មីៗផង ល្អៗផង មានសាច់ទន់ផង បរិសុទ្ធផង ប្រកបដោយ រោមផង គេបានឲ្យដល់នារីនោះហើយ ក៏ប្រែកដូចជាលោហៈ ទៅវិញ ចុះនារីនេះបានធ្វើអំពើដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **កិស្ស អយំ វិបាកោ** សេចក្ដីថា នេះជាវិបាក នៃកម្មដូចម្ដេច ដែលស្រីប្រេតសោយក្នុងឥឡូវនេះ ។ បទថា **អយំ នុ កឹ កម្មមកាសិ នារី** សេចក្ដីថា កាលមុនស្រីនេះ បានធ្វើកម្មអ្វីទុកហ្ន៎ ។ បទថា **យា សព្វទា លោហិតបុព្វភក្ខា** សេចក្ដីថា ស្រីនេះរមែងស៊ី គឺបរិភោគខ្ទុះ និងឈាមប៉ុណ្ណោះសព្វកាលនោះឯង ។ បទថា **នវានិ** បានដល់ នៅមាន តម្លៃ ( ថ្មី ) គឺប្រែកដក្នុងខណៈនោះឯង ។ បទថា **សុភានិ** ប្រែថា ស្អាត គឺគួរមើល ។ បទថា **មុទូនិ** បានដល់ មានសម្ផស្សជាសុខ ។ បទថា **សុទ្ធានិ** បានដល់ មានពណ៌បរិសុទ្ធ ។ បទថា **លោមសានិ** ប្រែថា មាន រោមទន់ គឺមានសម្ផស្សជាសុខ អធិប្បាយថា ល្អ ។ បទថា **ឥដ្ឋានិ មិស្សា កិតកា ភវន្តិ** សេចក្ដីថា ដូចគ្នានឹងបន្ទាដែលគ្រោតគ្រាត គឺដូចគ្នានឹងបន្ទះ លោហៈ ម្យ៉ាងទៀត បាឋៈថា **កីដកា ភវន្តិ** ដូច្នេះក៏មាន អធិប្បាយថា មាន ស្បែកដូចសត្វកកេរស៊ី ។ ទេវបុត្តនោះ ត្រូវភិក្ខុនោះសួរយ៉ាងនេះ កាលនឹង

ប្រកាសកម្មដែលស្រីប្រេតធ្វើក្នុងកាលមុន ទើបពោលគាថា ២ ថា

បពិត្រលោកដ៏ចម្រើន នារីនេះ ជាភរិយារបស់ខ្ញុំ ជាស្រីមិនដែលឲ្យវត្ថុអ្វី ដល់អ្នកណាមួយឡើយ ជាស្រីកំណាញ់ស្វិតស្វាញ តែងជេរប្រទេចផ្ដាសានូវខ្ញុំដែលកំពុងឲ្យទានដល់សមណព្រាហ្មណ៍ទាំងឡាយថា អ្នកចូរស៊ីលាមកផង មូត្រផង ឈាមផង ខ្ទុះផង ដែលជារបស់មិនស្អាតសព្វកាលចុះ ផលនេះចូរកើតមាន ដល់អ្នកក្នុងបរលោកចុះ សំពត់មានផែនដូចលោហៈ ចូរមានដល់អ្នកចុះ លុះនារីនោះ ប្រព្រឹត្តអំពើទុច្ចរិតប្រាកដដូច្នេះហើយ មកកាន់ទីនេះ ទើបបានទទួលផល ( ដ៏ក្រហល់ក្រហាយ ) អស់រាត្រីដ៏យូរអង្វែង ។

ក្នុងបទទាំងនោះ បទថា **អទាយិកា** បានដល់ មានប្រក្រតីមិនឲ្យទានណាមួយដល់បុគ្គលណាឡើយ ។ បទថា **មច្ឆរិនី កទរិយា** សេចក្ដីថា ឈ្មោះថា **មច្ឆរិនី** ព្រោះដំបូងមានមន្ទិល គឺសេចក្ដីកំណាញ់ ជាសភាវៈ និងឈ្មោះថា **កទរិយា** ព្រោះមានការសេពរឿយៗនូវសេចក្ដីកំណាញ់នោះ ។ មានវាចាប្រកបសេចក្ដីថា នាងបានជាបុគ្គលមានសេចក្ដីកំណាញ់ ដោយសេចក្ដីកំណាញ់ស្វិតស្វាញនោះ ឥឡូវនេះ ទេវបុត្តកាលនឹងសម្ដែងភាពដែលនាងជាបុគ្គលមានសេចក្ដីកំណាញ់នោះឯង ទើបពោលពាក្យជាដើមថា **សាមំ ទទន្តំ** ( តែងប្រទេចផ្ដាសា ) នូវខ្ញុំដែលកំពុងឲ្យទាន ។ ក្នុងបទទាំងនោះ បទថា **ឃសាធិសំ** បានដល់ ប្រព្រឹត្តវចីទុច្ចរិតជាដើមតាមដែលពោលហើយ បែប

នោះ ។ បទថា **ឥធាគតា** បានដល់ មកកាន់បេតលោកនេះ គឺចូលដល់អត្តភាពនៃប្រេត ។ បទថា **ចិររត្តាយ ឲាឥតិ** បានដល់ ទំពាស៊ីតែលាមកប៉ុណ្ណោះអស់កាលយូរ ។ ពិតហើយ នាងជេរដោយអាការណា ផលក៏កើតដោយអាការនោះដូចគ្នា នាងជេរចំពោះបុគ្គលណា ពាក្យជេរនោះធ្លាក់ទៅក្នុងទីដទៃចាកបុគ្គលនោះ គឺធ្លាក់លើខ្លួនឯង ដូចអសនីបាតធ្លាក់លើផែនដីគឺលើទីបំផុត ពោលគឺអំបែងក្បាល ។

ទេវបុត្តនោះ កាលសម្តែងកម្មដែលស្រីប្រេតធ្វើទុកក្នុងជាតិមុនយ៉ាងនេះហើយ ទើបបានពោលនឹងភិក្ខុនោះទៀតថា បពិត្រលោកម្ចាស់ ឧបាយណាមួយដែលធ្វើឲ្យស្រីប្រេតនេះផុតចាកបេតលោកមានដែរឬកាលភិក្ខុនោះ ពោលថា មាន ទើបពោលថា សូមលោកម្ចាស់សម្តែងចុះ ។ ភិក្ខុនោះពោលថា បើអ្នកថ្វាយទានដល់ព្រះមានព្រះភាគនិងដល់ព្រះអរិយសង្ឃ ឬដល់ភិក្ខុមួយរូបប៉ុណ្ណោះ ហើយឧទ្ទិសឲ្យស្រីប្រេតនេះផង ស្រីប្រេតនេះបានអនុមោទនាទាននោះផង ដោយអាការយ៉ាងនេះ នាងក៏នឹងផុតចាកសេចក្តីទុក្ខនេះទៅបាន ។ ទេវបុត្តបានស្តាប់ដូច្នោះ ទើបបានប្រគេនបាយនិងទឹកដ៏ប្រណីតដល់ភិក្ខុនោះហើយឲ្យទក្ខិណានោះ ឧទ្ទិសដល់ស្រីប្រេតនោះ ។ រំពេចនោះឯង ស្រីប្រេតនោះមានចិត្តត្រេកអរ មានឥន្ទ្រិយស្រស់ថ្លា បានជាអ្នកឆ្អែតដោយអាហារដែលជាទិព្វ ទេវបុត្តនោះ បានថ្វាយគូសំពត់ដែលជាទិព្វក្នុងដៃរបស់ភិក្ខុនោះឧទ្ទិសព្រះមានព្រះភាគ ហើយឧទ្ទិសទក្ខិណានោះដល់ស្រីប្រេត ក្នុងខណៈនោះឯង ស្រីប្រេតស្លៀកសំពត់ទិព្វ ប្រដាប់ដោយគ្រឿងអលង្ការដែលជាទិព្វដល់ព្រម

ដោយវត្ថុ ដែលគួរប្រាថ្នាទាំងពួង បានជាអ្នកមានចំណែកប្រៀបដោយទេពអប្សរ ។ ភិក្ខុនោះដល់ក្រុងសាវត្ថីក្នុងថ្ងៃនោះឯង ដោយឫទ្ធិរបស់ទេវបុត្តនោះ ចូលទៅកាន់វត្តជេតពន ហើយចូលគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ បានថ្វាយគូសំពត់សាដកនោះ ហើយក្រាបទូលរឿងនោះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ សម្ដែងធម៌ដល់បរិស័ទដែលប្រជុំព្រមគ្នាហើយ ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា មហាបេសការប្រេតចប់

# រឿង ខល្លាតប្រេត ទី ១០

[ ១០ ] ( នាយពាណិជ្ជសួរថា ) នាងជាស្ត្រីអ្វីហ្ន៎ ឋិតនៅខាងក្នុងវិមាន មិនចេញអំពីវិមាន ម្នាលនាងដ៏ចម្រើន ចូរនាងចេញមក យើងនឹងឃើញនាង ដែលមានឫទ្ធិច្រើន ។

( នាងប្រេតតបថា ) ខ្ញុំជាស្ត្រីអាក្រាត មានសេចក្តីអៀនខ្មាស ដល់នូវសេចក្តីទុក្ខលំបាក មិនអាចចេញមកខាងក្រៅបានទេ ខ្ញុំជាស្ត្រីមានសរីរៈបិទបាំងដោយសក់ទាំងឡាយ ( ព្រោះថា ) កុសលកម្មមានប្រមាណតិចខ្ញុំបានធ្វើមកហើយ ។

( នាយពាណិជ្ជពោលថា ) បើដូច្នោះ យើងនឹងឲ្យសំពត់សាដកសម្រាប់ដណ្តប់ដល់នាង ចូរនាងស្លៀកសំពត់សាកដនេះចុះ ម្នាលនាងមានកក្រ្តដ៏ល្អ លុះនាងស្លៀកពាក់សំពត់សាកដនេះរួចហើយ ចូរចេញមកខាងក្រៅ ម្នាលនាងដ៏ចម្រើន នាងចូរចេញមក យើងនឹងឃើញនាងដែលមានឫទ្ធិច្រើន ។

( នាងប្រេតតបថា ) ទានដែលអ្នកឲ្យផ្ទាល់ដៃ មិនបានសម្រេចដល់ខ្ញុំទេ ក្នុងប្រជុំជននេះមានឧបាសកទុ៎ះ អ្នកមានសទ្ធា ជាសាវ័កនៃព្រះសម្មាសម្ពុទ្ធ អ្នកចូរញុំាងឧបាសកនេះឲ្យស្លៀកពាក់ ហើយចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំ ទើបខ្ញុំនឹងបានសេចក្តីសុខ សម្រេចនូវសេចក្តីប្រាថ្នាទាំងពួង ។

ពួកពាណិជ្ជទាំងនោះ ក៏ឲ្យឧបាសកនោះងូតទឹក ប្រដាប់តាក់តែងដោយគ្រឿងប្រអប់ ឲ្យស្លៀកពាក់សំពត់ទាំងឡាយរួចហើយ ទើបឧទ្ទិសទក្ខិណាទានដល់ប្រេតនោះថា ផលគប្បីកើតឡើងក្នុងលំដាប់ដែលយើងឧទ្ទិសហើយ ភោជនីយាហារនិងសំពត់ស្លៀកពាក់និងទឹកក៏កើតឡើង នេះជាផលនៃទក្ខិណា

ទាន ។

លំដាប់នោះ ស្រីប្រេតនោះ ជាស្រីបរិសុទ្ធ មានសំពត់ស្លៀកស្អាត ជាស្រីទ្រទ្រង់សំពត់ដ៏ឧត្តម ជាងសំពត់ដែលកើតក្នុងដែនកាសី ហើយក៏សើចចេញអំពីវិមានមក នេះជាផលនៃទក្ខិណាទាន ។

( ពួកពាណិជ្ជសួរថា ) ម្នាលទេវធីតា វិមានរបស់នាង វិចិត្រដោយរូបល្អ ស្អាតរុងរឿង ភ្លឺ នាងដែលយើងសួរហើយចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( នាងប្រេតតបថា ) ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនម្សៅល្ងកិន ប្រមាណ ១ ទោណៈ ដល់ភិក្ខុដែលកំពុងត្រាច់ទៅ មានចិត្តត្រង់ ខ្ញុំក៏បានទទួលវិបាកនៃកុសលកម្មនោះក្នុងវិមាន អស់ចន្លោះកាលដ៏យូរ តែឥឡូវនេះ កុសលនោះ តិចពេកណាស់ ។ កាលកិរិយានឹងមានក្នុងខាងលើអំពី ៤ ខែ ខ្ញុំនឹងចូលទៅកាន់នរកដ៏ខ្លាំងក្លា ខ្លោចផ្សាដោយពិត នរកមានជ្រុង ៤ មានទ្វារ ៤ រាប់ដោយចំណែកដែលចែកហើយ មានដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃផែនដីនៃមហានរកនោះ សុទ្ធតែដែក មានភ្លើងឆេះប្រាលរន្ទាលផ្សាយទៅបាន ១០០ យោជន៍ដោយជុំវិញ តាំងនៅសព្វកាល ខ្ញុំនឹងរងទុក្ខវេទនាអស់កាលជាអង្វែងក្នុងនរកនោះ ព្រោះហេតុនោះ ខ្ញុំទើបទទួលផលនៃបាបកម្មដែលក្តៅក្រហាយក្រៃពេកណាស់ ។

**ចប់ រឿង ខល្លាតប្រេតទី ១០ ។**

# អដ្ឋកថា ខល្វាតប្រេត

[ ១០ ] កាលព្រះសាស្តាគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធស្រីប្រេតខល្វាតម្នាក់ ទើបត្រាស់ពាក្យថា **កា នុ អន្តោ វិមានស្មឹ** ដូច្នេះជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានស្រីម្នាក់អាស្រ័យរូបចិញ្ចឹមជីវិត នាងមានរូបស្អាត គួរមើល គួរសរសើរ ប្រកបដោយពណ៌សម្បុរល្អក្រៃលែង មានសក់សក់គួរជាទីត្រេកអរនៃចិត្ត ។ ពិតហើយសក់របស់នាងខ្មៅ វែង ល្អិត ទន់ ក្រាស់ មានចុងងឡើង សំយុងចុះរហូតដល់ចង្កេះ ។ ពួកកំលោះៗឃើញលម្អសក់របស់នាង ដោយច្រើនក៏មានចិត្តប្រតិព័ទ្ធ ។ លំដាប់នោះ ស្រី ២-៣ នាក់ ត្រូវសេចក្តីច្រណែនគ្របសង្កត់ អត់ធន់នឹងសម្រស់សក់របស់នាងមិនបាន ទើបនាំគ្នាប្រឹក្សា យករបស់បន្តិចបន្តួចទំនុកបម្រុងស្រីបម្រើរបស់នាងនោះឯង ឲ្យស្រីបម្រើដាក់ថ្នាំដែលជាហេតុធ្វើសរសៃសក់ឲ្យជ្រុះ បានឮថា ស្រីបម្រើនោះ យកថ្នាំនោះលាយនឹងលម្អិតសម្រាប់កក់សក់ ក្នុងពេលដែលនាងទៅងូតទឹកក្នុងស្ទឹងគង្គាក៏ឲ្យដល់នាង ។ ស្រីនោះយកលម្អិតនោះកក់សក់ហើយ មុជចុះទៅក្នុងទឹក ។ គ្រាន់តែមុជប៉ុណ្ណោះ សរសៃសក់ទាំងឫសទាំងគល់ក៏ជ្រុះអស់ទៅ ។ ក្បាលរបស់នាង ដូចគ្នានឹងសម្បកឃ្លោក ។ ស្រីនោះអស់សក់ដោយប្រការទាំងពួង ដូចសត្វព្រាបដែលជករោមត្រង់ក្បាល ដូច្នោះ គួរស្អប់ក្រៃលែង ។ ព្រោះខ្មាសគេ នាងមិនអាចចូលក្នុងនគរបាន ក៏យកសំពត់ទទូរក្បាល សម្រេចការនៅក្នុងទីមួយកន្លែងខាងក្រៅនគរ លុះកន្លងទៅពីរបីថ្ងៃ នាងអស់ការខ្មាសត្រឡប់អំពីទីនោះ ប្រេបាច់គ្រាប់ល្ង ធ្វើជាអ្នកលក់ប្រេងល្អនិងធ្វើជាអ្នកលក់

ស្រាចិញ្ចឹមជីវិត ។ ថ្ងៃមួយ កាលមនុស្ស ២-៣ នាក់ស្រវឹងស្រា ដេក លក់ស៊ប់ ទើបនាងលួចសំពត់ដែលមនុស្សទាំងនោះស្លៀកជូរៗ ។ ថ្ងៃមួយ នាងឃើញព្រះថេរៈខីណាស្រពមួយរូប កំពុងត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា ទើបនាំទៅកាន់ផ្ទះរបស់ខ្លួន ឲ្យគង់លើអាសនៈដែលតាក់តែងទុក បានប្រគេន ម្សៅដែលប្រឡាក់ក្នុងស្នូក ផ្សំនឹងប្រេងល្ង ។ ដើម្បីអនុគ្រោះនាង ព្រះថេរៈ ក៏ទទួលម្សៅផ្សំដោយប្រេងល្ងនោះឆាន់ នាងមានចិត្តជ្រះថ្លាបានឈរបាំងឆត្រ ។ ព្រះថេរៈនោះ កាលធ្វើឲ្យនាងមានចិត្តត្រេកអរ ទើបធ្វើអនុមោទនា ហើយ ចៀសចេញទៅ ក្នុងកាលដែលអនុមោទនានោះឯង ស្រីនោះបានតាំងសេចក្តី ប្រាថ្នាថា សូមសក់ខ្ញុំវែង ល្អិត ទន់ មានចុងង ។

ក្នុងកាលតមក នាងក៏ធ្វើកាលកិរិយា ព្រោះផលនៃកម្មដែលលាយគ្នា ក៏កើតជាស្រីឯកោក្នុងវិមានមាស កណ្តាលមហាសមុទ្ទ ។ សរសៃសក់របស់ នាងសម្រេចតាមអាការដែលនាងប្រាថ្នានោះឯង តែព្រោះនាងស្រោតយកសំ-ពត់របស់ពួកមនុស្ស ទើបជាស្រីអាក្រាត នាងកើតរឿយៗក្នុងវិមានមាសនោះ ជាស្រីអាក្រាតអស់មួយពុទ្ធន្តរ ។

លំដាប់នោះ កាលព្រះមានព្រះភាគនៃយើងកើតឡើងក្នុងលោក ទ្រង់ ប្រកាសធម្មចក្កដ៏បវរ គង់នៅក្នុងក្រុងសាវត្ថីដោយលំដាប់ ឈ្មួញអ្នកក្រុង សាវត្ថី ៧០០ ចេញសំពៅទៅកាន់មហាសមុទ្រ ឆ្ពោះទៅកាន់សុវណ្ណភូមិ នាវា ដែលពួកឈ្មួញនោះចេញដំណើរទៅត្រូវកម្លាំងខ្យល់បោកបក់ ទើបរសាត់ទៅ ក្នុងទិសផ្សេងៗរហូតដល់ប្រទេសដែលវិមានិកប្រេតនោះនៅ ។ សម័យនោះ

វិមានិកប្រេតនោះក៏បង្ហាញខ្លួនដល់ពួកឈ្មួញទាំងនោះ មួយអន្លើដោយវិមាន មេឈ្មួញឃើញដូច្នោះ ទើបពោលថា

នាងជាស្ត្រីអ្វីហ្ន៎ ឋិតនៅខាងក្នុងវិមាន មិនចេញអំពីវិមានម្នាល
នាងដ៏ចម្រើន ចូរនាងចេញមក យើងនឹងឃើញនាងដែលមាន
ឫទ្ធិច្រើន ។

ក្នុងបទទាំងនោះ បទថា **កា នុ អន្តោ វិមានស្មឹ តិដ្ឋន្តិ** សេចក្តីថា មេឈ្មួញសួរថា នាងនៅក្នុងវិមានជានរណាហ្ន៎ ជាស្រីមនុស្ស ឬអមនុស្ស ។ បទថា **នូបនិក្ខមិ** សេចក្តីថា នាងមិនចេញអំពីវិមានឡើយ ។ បទថា **ឧប-និក្ខមស្សុ ភទ្ទេ បស្សាម តំ ពហិដ្ឋិតំ** សេចក្តីថា នែប្អូនស្រី ពួកយើងប្រាថ្នានឹងឃើញនាងចេញមកនៅខាងក្រៅ ព្រោះហេតុនោះ ចូរនាងចេញអំពីវិមានចុះ ។ បាលីថា **ឧបនិក្ខមស្សុ ភទ្ទន្តេ** ដូច្នេះក៏មាន អធិប្បាយថា សេចក្តីចម្រើន ចូរមានដល់ប្អូនស្រី ។

លំដាប់នោះ នាងវិមានិកប្រេត កាលប្រកាសភាពដែលខ្លួនមិនអាចចេញទៅខាងក្រៅដល់ឈ្មួញនោះ ទើបពោលគាថាថា

ខ្ញុំជាស្ត្រីអាក្រាត មានសេចក្តីអៀនខ្មាស ដល់នូវសេចក្តីទុក្ខ
លំបាក មិនអាចចេញមកខាងក្រៅបានទេ ខ្ញុំជាស្ត្រីមានសរីរៈ
បិទបាំងដោយសក់ទាំងឡាយ ( ព្រោះថា ) កុសលកម្មមាន
ប្រមាណតិច ខ្ញុំបានធ្វើមកហើយ ។

ក្នុងបទទាំងនោះ បទថា **អដ្ដិយាមិ** សេចក្តីថា ខ្ញុំជាស្រីអាក្រាតកាយ

គានតឹងចិត្ត លំបាកចេញទៅខាងក្រៅ ។ បទថា **ហិរាយាមិ** ប្រែថា ខ្មាស ។ បទថា **កេសេហម្ហិ បដិច្ឆន្នា** សេចក្តីថា ខ្ញុំមានសរសៃសក់បិទបាំង គឺមានសក់គ្របបណ្តប់រាងកាយ ។ បទថា **បុញ្ញំ មេ អប្បកំ កតំ** សេចក្តីថា ខ្ញុំធ្វើកុសលកម្មតិច គឺតិចតួច អធិប្បាយថា ត្រឹមតែប្រគេនម្សៅលាយដោយប្រេងប៉ុណ្ណោះ ។

លំដាប់នោះ ឈ្មួញបំណាងឲ្យសំពត់របស់ខ្លួនដល់នាងវិមានិកប្រេតនោះ ទើបពោលគាថាថា

បើដូច្នោះ យើងនឹងឲ្យសំពត់សាដក សម្រាប់ដណ្តប់ដល់នាង
ចូរនាងស្លៀកសំពត់សាដកនេះចុះ ម្នាលនាងមានភក្ត្រដ៏ល្អលុះ
នាងស្លៀកពាក់សំពត់សាដកនេះរួចហើយ ចូរចេញមកខាង
ក្រៅ ម្នាលនាងដ៏ចម្រើន នាងចូរចេញមក យើងនឹងឃើញ
នាងដែលមានឫទ្ធិច្រើន ។

ក្នុងបទទាំងនោះ បទថា **ហន្ទ** ប្រែថា អញ្ជើញចុះ ។ បទថា **ឧត្តរិយំ** ប្រែថា សំពត់ដណ្តប់កាយ អធិប្បាយថា សំពត់ដណ្តប់ ។ បទថា **ទទាមិ តេ** ប្រែថា យើងនឹងឲ្យដល់នាង ។ បទថា **ឥទំ ទុស្សំ និវាសយ** បានដល់ចូរនាងដណ្តប់សំពត់នេះរបស់យើងចុះ ។ បទថា **សោភណេ** ប្រែថា នៃនាងមានរូបស្អាត ។

កាលឈ្មួញពោលយ៉ាងនេះហើយ ទើបនាំយកសំពត់ដណ្តប់របស់ខ្លួនទៅឲ្យដល់នាង នាងវិមានិកប្រេត កាលនឹងសម្តែងភាពដែលឈ្មួញប្រគល់

សំពត់ឲ្យយ៉ាងនេះ ជាការអនុគ្រោះដល់ខ្លួននិងការដែលឈ្មួញឲ្យសំពត់យ៉ាង នោះមិនសម្រេចប្រយោជន៍ ទើបពោលគាថា ២ ថា

ទានដែលអ្នកឲ្យផ្ទាល់ដៃ មិនបានសម្រេចដល់ខ្ញុំទេ ក្នុងប្រជុំជននេះ មានឧបាសកនុ៎ះអ្នកមានសទ្ធា ជាសាវកនៃព្រះសម្មាសម្ពុទ្ធ អ្នកចូរញុំាងឧបាសកនេះឲ្យស្លៀកពាក់ហើយចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំ ទើបខ្ញុំនឹងបានសេចក្តីសុខ សម្រេចនូវសេចក្តីប្រាថ្នាទាំងពួង ។

ក្នុងបទទាំងនោះ បទថា **ហត្ថេន ហត្ថំ តេ ទិន្នំ ន មយ្ហំ ឧបកប្បតិ** សេចក្តីថា នៃលោកនិគ្រន្ថ សំពត់ដែលអ្នកឲ្យក្នុងដៃរបស់ខ្ញុំ មិនសម្រេច គឺមិនឲ្យផល បានដល់ មិនគួរជាគ្រឿងឧបភោគដល់ខ្ញុំទេ ។ បទថា **ឯសេត្ថុ-បាសកោ សទ្ធោ** សេចក្តីថា បុគ្គលនេះឈ្មោះថា ឧបាសក ព្រោះដល់ព្រះរតនត្រ័យជាសរណៈ និងឈ្មោះថាជាអ្នកមានសទ្ធា ព្រោះប្រកបដោយការជឿកម្មនិងផលនៃកម្ម មាននៅក្នុងទីនេះ គឺក្នុងពួកប្រជុំជននេះ ។ បទថា **ឯតំ អច្ឆាទយិត្វាន មម ទក្ខិណមាទិស** សេចក្តីថា មេឈ្មួញឲ្យឧបាសកនោះស្លៀកដណ្តប់សំពត់ដែលឲ្យដល់ខ្ញុំ ហើយឧទ្ទិសទក្ខិណានោះ គឺធ្វើបត្តិ-ទានមយៈឧទ្ទិសដល់ខ្ញុំ ។ បទថា **តថាហំ សុខិតា ហេស្សំ** សេចក្តីថា កាលធ្វើយ៉ាងនោះ ខ្ញុំនឹងមានសេចក្តីសុខ ស្លៀកដណ្តប់សំពត់ទិព្វ និងបានទទួលសេចក្តីសុខ ។

ពួកឈ្មួញបានស្តាប់ដូច្នោះ ទើបឲ្យឧបាសកនោះងូត និងលាបហើយឲ្យ

ស្បៀកសំពត់មួយផ្ទាំង ដណ្តប់មួយផ្ទាំង ។ ព្រះសង្គីតិកាចារ្យទាំងឡាយកាល ប្រកាសសេចក្តីនោះ ទើបពោលគាថា ៣ ថា

ពួកពាណិជ្ជទាំងនោះក៏ឲ្យឧបាសកនោះងូតទឹក ប្រដាប់តាក់តែងដោយគ្រឿងប្រអប់ ឲ្យស្លៀកពាក់សំពត់ទាំងឡាយ រួចហើយទើបឧទ្ទិសទក្ខិណាទានដល់ប្រេតនោះថា ផលគប្បីកើតឡើងក្នុងលំដាប់ ដែលយើងឧទ្ទិសហើយ ភោជនីយាហារនិងសំពត់ស្លៀកពាក់និងទឹក ក៏កើតឡើង នេះជាផលនៃទក្ខិណាទាន ។

លំដាប់នោះ ស្រីប្រេតនោះជាស្រីបរិសុទ្ធមានសំពត់ស្លៀកស្អាត ជាស្រីទ្រទ្រង់សំពត់ដ៏ឧត្តម ជាងសំពត់ដែលកើតក្នុងដែនកាសី ហើយក៏សើច ចេញអំពីវិមានមក នេះជាផលនៃទក្ខិណាទាន ។

ក្នុងបទទាំងនោះ បទថា **តំ** បានដល់ ញ៉ាំងឧបាសកនោះ ។ **ច** សព្ទគ្រាន់តែជានិបាត ។ មានវាចាប្រកបសេចក្តីថា បទថា **តេ** បានដល់ ឈ្មួញទាំងនោះ ។ បទថា **វិលិម្បេត្វាន** បានដល់ លាបដោយគ្រឿងក្រអូបដ៏ល្អ ។ បទថា **វត្ថេហច្ឆាទយិត្វាន** សេចក្តីថា ឲ្យបរិភោគភោជន មួយអន្ទើដោយសម្លដែលសម្បូរដោយពណ៌ ក្លិន រស ឲ្យស្លៀកសំពត់ គឺឲ្យស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង បានដល់ឲ្យសំពត់ ២ ផ្ទាំង ។ បទថា **តស្សា ទក្ខិ-ណាមាទិសុំ** បានដល់ ឧទ្ទិសចំណែកបុណ្យដល់វិមានិកប្រេតនោះ ។

បទថា **អនុ** ក្នុងបទថា **សមនន្តរានុទ្ទិដ្ឋេ** នេះ ត្រឹមតែជានិបាត អធិប្បាយថា ក្នុងរំពេចនោះ ក៏បានឃើញផលនៃទក្ខិណាទាននោះឯង ។ បទថា **វិបា-កោ ឧបបជ្ជថ** សេចក្តីថា វិបាក គឺផលនៃទក្ខិណាបានកើតឡើងដល់នាងវិមានិកប្រេតនោះ ។ ដើម្បីចៀសវាងនូវពាក្យសួរថា វិបាកដូចម្តេច ទើបនាងវិមានិកប្រេតពោលថា ភោជន គ្រឿងស្លៀកដណ្តប់ និងទឹកកើតឡើងហើយ មានវាចាប្រកបសេចក្តីថា ភោជន ដូចគ្នានឹងភោជនទិព្វ មានប្រការផ្សេងៗ សំពត់ដែលដូចជាសំពត់ទិព្វដែលរុងរឿងដោយពណ៌ចម្រុះ និងទឹកផឹក មានច្រើនប្រភេទ ផលបែបនេះរមែងកើតព្រោះទក្ខិណា ។ បទថា **តតោ** បានដល់ ខាងក្រោយអំពីការបានទទួលវត្ថុ មានភោជនជាដើមតាមដែលបានពោលហើយ ។ បទថា **សុទ្ធា** បានដល់ មានរាងកាយស្អាតដោយការងូតទឹក ។ បទថា **សុចិវសនា** បានដល់ ស្លៀកដណ្តប់សំពត់ដ៏ស្អាត ។ បទថា **កាសិ-កុត្តមធារិនី** បានដល់ ស្លៀកដណ្តប់សំពត់ល្អជាងសំពត់របស់អ្នកកាសី ។ បទថា **ហសន្តី** សេចក្តីថា នាងវិមានិកប្រេតញញឹមញញែមចេញអំពីវិមានមួយអន្លើដោយការប្រកាសថា លោកទាំងឡាយមើលចុះ នេះជាផលវិសេសនៃទក្ខិណារបស់ពួកលោក ជាលំដាប់ដំបូង ។

លំដាប់នោះ ពួកឈ្មួញនោះ បានឃើញផលបុណ្យដោយប្រចក្សយ៉ាងនេះ ទើបកើតអស្ចារ្យដែលមិនធ្លាប់មានអំពីមុន កើតនូវសេចក្តីគោរពរាប់អានច្រើនក្នុងឧបាសកនោះ នាំគ្នាធ្វើអញ្ជលីកម្ម ចូលទៅអង្គុយជិតឧបាសកនោះ ឯឧបាសកឲ្យឈ្មួញទាំងនោះជ្រះថ្លាក្នុងធម្មកថា ដោយប្រមាណក្រៃលែង និង

ឲ្យតាំងនៅក្នុងសរណៈនិងសីល ។ ទើបពួកឈ្មួញទាំងនោះសួរដល់កម្មដែលនាងវិមានិកប្រេតនោះធ្វើទុកដោយគាថានេះថា

ម្នាលទេវធីតា វិមានរបស់នាង វិចិត្រដោយរូបល្អ ស្អាតរុងរឿង ក្តី នាងដែលយើងសួរហើយចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

ក្នុងបទទាំងនោះ បទថា **សុចិត្តរូបំ** បានដល់ មានរូបដ៏វិចិត្រដែលចាត់ចែងល្អហើយ ជារូបដំរី សេះ ស្រ្តីនិងបុរសជាដើមនិងដោយមាលាកម្មនិងលតាកម្មជាដើម ។ បទថា **រុចិរំ** បានដល់ គួរត្រេកអរ គួរសរសើរ ។ បទថា **កិស្ស កម្មស្សិទំ ផលំ** សេចក្តីថា នេះជាផលនៃកម្មដូចម្តេច គឺជាផលរបស់ទានមយៈ ឬរបស់សីលមយៈ ។

ទេពធីតានោះ ត្រូវពួកឈ្មួញសួរយ៉ាងនេះហើយ កាលនឹងប្រាប់ផលកម្មទាំង ២ យ៉ាងនេះថា នេះជាផលរបស់កុសលកម្មតិចតួចដែលខ្ញុំធ្វើ ជាលំដាប់ដំបូង តែសម្រាប់អកុសលកម្មនឹងប្រាកដដូច្នេះក្នុងនរកតទៅ ដូច្នេះ ទើបបានពោលគាថាទាំងឡាយថា

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនម្សៅល្ងកិន ប្រមាណ ១ ទោណៈ ដល់ភិក្ខុដែលកំពុងត្រាច់ទៅ មានចិត្តត្រង់ ខ្ញុំក៏បានទទួលវិបាកនៃកុសលកម្មនោះក្នុងវិមាន អស់ចន្លោះកាលដ៏យូរ តែឥឡូវនេះ កុសលនោះ តិចពេកណាស់ ។ កាលកិរិយា នឹងមានក្នុងខាងលើអំពី ៤ ខែ ខ្ញុំនឹងចូលទៅកាន់នរកដ៏ខ្លាំងក្លាខ្លោច-

ផ្សាដោយពិត នរកមានជ្រុង ៤ មានទ្វារ ៤ រាប់ដោយចំណែកដែលចែកហើយ មានដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃផែនដីនៃមហានរកនោះ សុទ្ធតែដែក មានភ្លើងឆេះប្រាលរន្ទាល ផ្សាយទៅបាន ១០០ យោជន៍ដោយជុំវិញតាំងនៅសព្វកាល ខ្ញុំនឹងរងទុក្ខវេទនា អស់កាលជាអង្វែងក្នុងនរកនោះ ព្រោះហេតុនោះ ខ្ញុំទើបទទួលផលនៃបាបកម្មដែលក្តៅក្រហាយក្រៃពេកណាស់ ។

ក្នុងបទទាំងនោះ បទថា **ភិក្ខុនោ ចរមានស្ស** បានដល់ ដល់ភិក្ខុដែលទម្លាយកិលេសមួយរូបកំពុងត្រាច់បិណ្ឌបាត ។ បទថា **គោណភិនិម្មជ្ជនី** បានដល់ នូវម្សៅដែលមានប្រេងល្ងផ្សើម ។ បទថា **ឧជុភូតស្ស** សេចក្តីថា ឈ្មោះថាដល់នូវភាពជាអ្នកត្រង់ ព្រោះមិនមានកិលេសធ្វើនូវការវៀចនៃចិត្ត ។ បទថា **វិប្បសន្នេន ចេតសា** សេចក្តីថា មានចិត្តជ្រះថ្លាល្អដោយការជឿកម្មនិងផលនៃកម្ម ។

ម អក្ខរៈ ក្នុងបទថា **ទីឃមន្តរំ** នេះ ធ្វើនូវការតបទ អធិប្បាយថា រយៈកាលយូរ គឺអស់កាលយូរ ។ បទថា **តញ្ច ទានិ បរិត្តកំ** សេចក្តីថា ផលបុណ្យ ៥ យ៉ាង ឥឡូវនេះ មានបន្តិចបន្តួច គឺសល់តិចតួច ព្រោះវិបាកនៃកម្មមានផលឆ្អិនហើយ មិនយូរប៉ុន្មានអំពីនេះទៅ ។ ដោយហេតុនោះ ទើបលោកពោលថា កាលកិរិយានឹងមានក្នុងខាងលើអំពី ៤ ខែ ដូច្នេះ ជាដើមស្រីប្រេតចង្អុលបង្ហាញថា ផុតអំពី ៤ ខែ គឺក្នុងខែទី ៥ បន្ទាប់អំពី ៤ ខែ

ទៅ ខ្ញុំនឹងចុតិអំពីវិមាននេះ ។ បទថា **ឃោរាកដុកំ** សេចក្តីថា នឹងមានទុក្ខពិតប្រាកដ ព្រោះត្រូវទទួលផលដែលមិនគួរប្រាថ្នា ដោយចំណែកមួយនោះឯង ។ បទថា **ឃោរំ** ប្រែថា ដ៏ពន្លឹក ។ បទថា **និរយំ** សេចក្តីថា នរកដែលបានឈ្មោះថា និរយៈ ព្រោះធ្វើវិគ្គហៈថា ជាទីមិនមានសេចក្តីចម្រើនគឺសេចក្តីសុខ ។ បទថា **បបតិស្សហំ** កាត់បទជា **បបតិស្សាមិ អហំ** ខ្ញុំនឹងធ្លាក់នរក ។ លោកពោលថា **ចតុក្កណ្ណំ** ដូច្នេះជាដើម ដើម្បីនឹងសម្តែងនរកនោះដោយសរុប ព្រោះលោកសម្តែងដល់អវិចីមហានរក ក្នុងពាក្យថា **និរយំ** នេះ ។ ក្នុងបទទាំងនោះ បទថា **ចតុក្កណ្ណំ** ប្រែថា មានជ្រុង ៤ ។ បទថា **ចតុទ្វារំ** បានដល់ ប្រកបដោយទ្វារ ៤ ក្នុងទិសទាំង ៤ ។ បទថា **វិភត្តំ** ប្រែថា ចែកដោយល្អ ។ បទថា **ភាគសោ** ប្រែថា ដោយការចែក ។ បទថា **មិតំ** បានដល់ ស្មើគ្នា ។ បទថា **អយោបាការបរិយន្តំ** ប្រែថា ព័ទ្ធដោយកំពែងដែលធ្វើដោយដែក ។ បទថា **អយសា បដិកុជ្ជិតំ** បានដល់ ខាងលើបិទដោយគម្របដែកសុទ្ធៗ ។

បទថា **តេជសា យុត្តា** បានដល់ មានអណ្តាតភ្លើងឆេះមិនដាច់ដោយគំនរភ្លើងធំជុំទិស ។ បទថា **សមន្តា យោជនសតំ** បានដល់ ផ្សាយទៅ ១០០ យោជន៍ គឺអស់ចម្ងាយ ១០០ យោជន៍ គ្រប់ទិសខាងក្រៅដោយជុំវិញយ៉ាងនេះ ។ បទថា **សព្វទា** ប្រែថា សព្វកាល ។ បទថា **ផរិត្វា តិដ្ឋតិ** បានដល់ ផ្សាយទៅតាំងនៅ ។ បទថា **តត្ថ** បានដល់ ក្នុងមហានរកនោះ ។ បទថា **វេទិស្សំ** បានដល់ នឹងបានទទួល គឺ នឹងបានសោយ ។

បទថា **ផលញ្ច បាបកម្មស្ស** សេចក្ដីថា ការសោយទុក្ខបែបនេះជាផលនៃកម្មអាក្រក់ដែលខ្ញុំបានធ្វើទុក ។

កាលទេពធីតានោះ ប្រកាសផលនៃកម្មដែលខ្លួនបានធ្វើ និងភ័យដែលធ្លាក់នរកក្នុងអនាគតយ៉ាងនេះហើយ ឧបាសកនោះ មានសេចក្ដីករុណាជាស់តឿនឲ្យគិតថា ណ្ហើយចុះ អញនឹងជាទីពឹងរបស់នាង ហើយពោលថា នែនាងទេពធីតា នាងសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង ក្លាយជាអ្នកប្រកបដោយសម្បត្តិដ៏ក្រៃលែង ដោយអំណាចទានរបស់យើងតែម្យ៉ាងប៉ុណ្ណោះ តែឥឡូវនេះនាងឲ្យទានដល់ឧបាសកទាំងនេះហើយ រឭកដល់គុណនៃព្រះសាស្ដា នឹងផុតចាកការកើតក្នុងនរកបាន ។ ស្រីប្រេតនោះ មានចិត្តត្រេកអរពោលថា សាធុហើយឲ្យឧបាសកទាំងនោះ ឆ្អែតស្កប់ស្កល់ដោយបាយ និងទឹកដែលជារបស់ទិព្វ បានឲ្យសំពត់ទិព្វ និងកែវច្រើនប្រភេទ នាងបានថ្វាយគូសំពត់ទិព្វឧទ្ទិសព្រះមានព្រះភាគក្នុងដៃឧបាសកទាំងនោះ ហើយពោលថា បពិត្រព្រះអង្គដ៏ចម្រើន នាងវិមានិកប្រេតម្នាក់ សូមផ្ញើនូវការថ្វាយបង្គំដោយសិរសា គឺត្បូងទៀបព្រះបាទារបស់ព្រះមានព្រះភាគ ដូច្នេះហើយ ក៏ដល់ក្រុងសាវត្ថី ហើយបញ្ជូនការថ្វាយបង្គំដល់ព្រះសាស្ដាថា សូមលោកទាំងឡាយ ថ្វាយបង្គំព្រះសាស្ដាតាមពាក្យរបស់ខ្ញុំចុះ ។ ថ្ងៃនោះឯង នាងបាននាំទូកនោះ ទៅដល់ត្រើយដែលឧបាសកទាំងនោះប្រាថ្នាដោយឥទ្ធានុភាពរបស់ខ្លួន ។

លំដាប់នោះ ឈ្មួញទាំងនោះ ចេញអំពីកំពង់នោះហើយ ដល់ក្រុងសាវត្ថីដោយលំដាប់ ចូលទៅកាន់វត្តជេតពន ថ្វាយគូសំពត់នោះដល់ព្រះមុនីនិង

បានឲ្យព្រះអង្គ ទ្រង់ជ្រាបដល់ការថ្វាយបង្គំរបស់នាង ហើយក្រាបទូលរឿងនោះ តាំងអំពីដើមដល់ចប់ដល់ព្រះមានព្រះភាគ ។ ព្រះសាស្ដាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយទ្រង់សម្ដែងធម៌ដោយពិស្ដារដល់បរិស័ទ ដែលដល់ព្រមហើយ ។ ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់មហាជន ។ ក្នុងថ្ងៃទី ២ ឧបាសកទាំងនោះ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយឧទ្ទិសចំណែកបុណ្យឲ្យដល់ស្រីប្រេតនោះ នាងបានចុតិអំពីបេតលោកនោះហើយ កើតក្នុងវិមានមាសក្នុងឋានតាវត្តិង្សដែលរុងរឿងដោយរតនៈផ្សេងៗ មានទេពអប្សរ ១០០០ ជាបរិវារ ។

## អដ្ឋកថា ខល្លាតប្រេតចប់

# រឿង ឆាតប្រេត ទី១១

[ ១១ ] ( សាមណេរសួរថា ) អ្នកទៅមុនគេបង្អស់ ជិះដំរីស ឯអ្នកទៅកណ្តាលគេ ជិះរថទឹមសេះអស្សតរ ចំណែកកញ្ញាមកខាងក្រោយគេ ទៅដោយវគ្គិស្វាងរុងរឿងសព្វទិសទាំង ១០ ។ ឯអ្នកទាំងឡាយ ( ដែលមកក្រោយគេបង្អស់ ) មានដៃកាន់ដំបង មានមុខជោកដោយទឹកភ្នែក មានខ្លួនបែកធ្លាយ ហើយផឹកនូវខ្ទុះនិងឈាមនៃគ្នានឹងគ្នាជាអាហារ អ្នកទាំងឡាយកាលកើតជាមនុស្ស តើបានធ្វើអំពើដូចម្តេចខ្លះ ។

( នាងប្រេតតបថា ) បុគ្គលណាទៅដោយដំរីសដ៏ប្រសើរ មានជើង ៤ មុនគេ បុគ្គលនោះជាបុត្តច្បងរបស់ខ្ញុំ បានថ្វាយទានហើយ ក៏បានជួបសេចក្តីសុខ ។ បុគ្គលណាទៅដោយរថទឹមសេះ ៤ មានដំណើរល្អក្នុងទីកណ្តាល បុគ្គលនោះជាបុត្តកណ្តាលរបស់ខ្ញុំ ជាអ្នកមិនកំណាញ់ ជាម្ចាស់ទានដ៏រុងរឿង ។ នារីណា ប្រកបដោយបញ្ញា មានភ្នែកថ្លាដូចម្រឹគ ទៅដោយវគ្គក្រោយគេ នារីនោះ ជាធីតាពៅអង្អស់របស់ខ្ញុំ ជាអ្នកមានសេចក្តីសុខ តែងរីករាយ តាមចំណែកផលទានពាក់កណ្តាល ។ អំពីជាតិមុនជនទាំងនុ៎ះ ជាអ្នកមានចិត្តជ្រះថ្លា បានឲ្យទានដល់ពួកសមណៈនិងព្រាហ្មណ៍ ចំណែកយើងខ្ញុំទាំងឡាយវិញជាអ្នកកំណាញ់ ជេរប្រទេចផ្តាសាសមណព្រាហ្មណ៍ទាំងឡាយ ឯជនទាំងនេះលុះឲ្យហើយទើបគេបម្រើ ( ដោយកាមគុណ ) ចំណែកពួកយើងទើបក្រៀមស្ងួត ដូចដើមបបុសដែលហាលថ្ងៃដូច្នោះ ។

( សាមណេរសួរថា ) ភោជនាហាររបស់អ្នកទាំងឡាយដូចម្តេចទៅ ទីដេករបស់អ្នកដូចម្តេចទៅ ចុះអ្នកទាំងឡាយមានបាបធម៌ដ៏ក្រៃលែងញុំាងអត្ត

ភាពឲ្យប្រព្រឹត្តទៅដូចម្តេច ភោជនាហារទាំងឡាយដ៏ច្រើន មិនមែនជារបស់តិចតួចឡើយ ឥឡូវនេះអ្នកដល់នូវសេចក្តីទុក្ខព្រោះប្រាសចាកសេចក្តីសុខ ។

( នាងប្រេតតបថា ) យើងខ្ញុំទាំងឡាយ សម្លាប់នូវគ្នានឹងគ្នា ហើយក្រេបផឹកនូវខ្ទុះនិងឈាម ទុកជាផឹកច្រើន ក៏មិនបាត់ស្រេកឃ្លាន យើងខ្ញុំទាំងឡាយក៏នៅតែស្រេកឃ្លានដដែល ។ ជនទាំងឡាយណា ជាអ្នកមិនចែកចាយឲ្យទាន ជនទាំងនោះ លុះលះលោកនេះទៅហើយរមែងទៅកើតក្នុងឋានយមលោក តែងខ្សឹកខ្សួលដូចយើងខ្ញុំទាំងឡាយ ជនទាំងឡាយណាបាននូវសម្បត្តិទាំងឡាយហើយ តែជាអ្នកកំណាញ់ មិនបរិភោគផង មិនធ្វើបុណ្យផង ។ ជនទាំងនោះ ជាអ្នកមានសេចក្តីស្រេកឃ្លានគ្របសង្កត់ក្នុងលោកខាងមុខក្នុងកាលជាខាងក្រោយមក ជនទាំងនោះរមែងឆេះរោលរាលក្តៅក្រហាយ អស់កាលជាយូរអង្វែង ព្រោះបានធ្វើនូវកម្មមានផលជាទុក្ខ តែងទទួលផលជាទុក្ខមានផលដ៏ក្តៅក្រហាយ ។ ទ្រព្យសម្បត្តិជារបស់មិនទៀង ជីវិតក្នុងលោកនេះជារបស់មិនទៀង បណ្ឌិតដឹងនូវរបស់មិនទៀង តាមសភាពជារបស់មិនទៀងហើយ គប្បីធ្វើនូវទីពឹង ។ ជនទាំងឡាយណា អ្នកឈ្លាសក្នុងព្រះសទ្ធម្មដឹងច្បាស់យ៉ាងនេះ ជនទាំងនោះឈ្មោះថា ជាអ្នកមិនធ្វេសប្រហែសក្នុងទានព្រោះបានស្តាប់ពាក្យនៃព្រះអរហន្តទាំងឡាយ ។

**ចប់ រឿងនាគប្រេតទី ១១ ។**

# អដ្ឋកថា ឆាតប្រេត

[ ១១ ] ព្រះសាស្តា កាលគង់នៅក្នុងវិហារឈ្មោះជេតពន ទ្រង់ប្រារព្ធព្រាហ្មណប្រេត ២ នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បុរតោ វ សេតេន បលេតិ ហត្ថិនា** ដូច្នេះ ។

បានឮថា ព្រះសង្កិច្ចៈមានអាយុ ៧ ឆ្នាំពីកំណើត សម្រេចអរហត្តក្នុងខណៈដាក់កាំបិតកោរដល់ចុងសក់នោះឯង តាំងនៅក្នុងសាមណេរភូមិ នៅក្នុងដងព្រៃ មួយអន្លើដោយភិក្ខុប្រមាណ ៣០ រូប ឃាត់ការស្លាប់ដែលមកដល់ភិក្ខុទាំងនោះអំពីដៃរបស់ពួកចោរ ៥០០ នាក់ ហើយទូន្មានចោរទាំងនោះឲ្យចោរបព្វជ្ជា នាំទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងនោះ ។ ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុទាំងនោះក៏បានសម្រេចអរហត្ត ។ សម័យនោះ សង្កិច្ចៈមានវស្សាគ្រប់ បានឧបសម្បទាហើយ មួយអន្លើដោយភិក្ខុ ៥០០ រូបនោះ នាំគ្នាទៅកាន់ក្រុងពារាណសី ស្នាក់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ។ ពួកមនុស្សនាំគ្នាទៅរកព្រះថេរៈ បានស្តាប់ធម៌ហើយ មានចិត្តជ្រះថ្លា បានថ្វាយអាគន្តុកទានជាពួកៗ តាមលំដាប់វិថី ។ ក្នុងមនុស្សទាំងនោះ មានឧបាសកម្នាក់ បានបបួលពួកមនុស្សឲ្យធ្វើនិច្ចភត្ត មនុស្សទាំងនោះបានធ្វើនិច្ចភត្តតាមកម្លាំង ។

សម័យនោះ ក្នុងក្រុងពារាណសីមានព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់ មានកូនប្រុស ២ នាក់ កូនស្រីម្នាក់ ។ ក្នុងកូនទាំងនោះ កូនច្បងមានឧបាសកជាសម្លាញ់ ។ ឧបាសកនោះនាំកូនច្បងរបស់ព្រាហ្មណ៍នោះទៅរកព្រះសង្កិច្ចៈ ។ ព្រះសង្កិច្ចៈ សម្តែងធម៌ដល់បុរសនោះ គេក៏មានចិត្តទន់ភ្លន់ ។ លំដាប់នោះ

ឧបាសកនោះ ពោលនឹងបុរសនោះថា ចូរឯងឲ្យនិច្ចភត្តដល់ភិក្ខុមួយរូបចុះ ។ ព្រាហ្មណបុត្តពោលថា ពួកយើងជាព្រាហ្មណ៍ មិនធ្លាប់ឲ្យនិច្ចភត្តដល់សមណសក្យបុត្តឡើយ ព្រោះហេតុនោះ យើងមិនព្រមឲ្យ ។ ឧបាសកពោលថា ទោះបីយើង ក៏ឯងមិនឲ្យភត្តខ្លះឬ ព្រាហ្មណបុត្តពោលថា រឿងអ្វីដែលខ្ញុំមិនឲ្យ ។ ឧបាសកពោលថា បើដូច្នោះ របស់ដែលឯងឲ្យខ្ញុំ ចូរប្រគេនដល់ភិក្ខុមួយរូបចុះ ។ បុរសនោះទទួលពាក្យថា សាធុ ក្នុងថ្ងៃទី ២ បានទៅកាន់វិហារ អំពីព្រលឹមនិមន្តភិក្ខុមកមួយរូបឲ្យឆាន់ហើយ ។

ពេលវេលាកន្លងទៅយ៉ាងនេះ ប្អូនប្រុសនិងប្អូនស្រីរបស់គេ ឃើញការបដិបត្តិរបស់ភិក្ខុទាំងឡាយ និងបានស្តាប់ធម៌ហើយ មានសេចក្តីជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា និងមានសេចក្តីត្រេកអរក្នុងបុញ្ញកម្ម ជនទាំង ៣ នាក់នោះកាលឲ្យទានតាមកម្លាំងទ្រព្យយ៉ាងនេះ បានធ្វើសក្ការៈ គោរពរាប់អានបូជាសមណព្រាហ្មណ៍ទាំងឡាយ ។ ចំណែកមាតានិងបិតារបស់ពួកជនទាំងនោះជាអ្នកមិនមានសទ្ធា មិនមានការជ្រះថ្លា មិនគោរពក្នុងសមណព្រាហ្មណ៍ មិនអើពើ មិនពេញចិត្តក្នុងការបំពេញបុណ្យ ។ ពួកញាតិក៏បានសូមក្មេងស្រីដែលជាធីតានៃមាតាបិតាទាំងនោះមក ដើម្បីជាប្រយោជន៍ដល់កូនរបស់ឪពុកមា ។ បុត្តរបស់ឪពុកមានោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសង្ឃិច្ចៈហើយកើតសេចក្តីសង្វេគ បព្វជ្ជាហើយ ទៅកាន់ផ្ទះរបស់មាតាខ្លួនដើម្បីឆាន់ជានិច្ច ។ មាតាលួងលោមលោកដោយកូនស្រីបងប្រុសរបស់ខ្លួន ។ ដោយហេតុនោះ លោកក៏អផ្សុក ចូលទៅរកឧបជ្ឈាយ៍ប្រាប់ថា បពិត្រលោកម្ចាស់ខ្ញុំនឹងសឹក

សូមលោកម្ចាស់អនុញ្ញាតឲ្យខ្ញុំសឹកចុះ ។ ព្រះឧបជ្ឈាយ៍ឃើញលោកដល់ព្រម ដោយឧបនិស្ស័យទើបពោលថា នែសាមណេរ ចូរអ្នកបន្ទន់មួយខែសិនចុះ សាមណេរទទួលពាក្យថា សាធុ កន្ទងទៅបានមួយខែ ក៏ប្រាប់ឲ្យជ្រាបយ៉ាង នោះដូចគ្នា ។ ព្រះឧបជ្ឈាយ៍ក៏ពោលទៀតថា ចូរបន្ទង់កន្លះខែទៀតចុះ លុះ កន្លងទៅកន្លះខែ កាលសាមណេរពោលយ៉ាងនោះ ព្រះថេរៈក៏ពោលទៀតថា ចូរបន្អង់ ៧ ថ្ងៃសិនចុះ សាមណេរទទួលពាក្យថា សាធុ ខាងក្នុង ៧ ថ្ងៃ នោះផ្ទះអំស្រីរបស់សាមណេរផ្ទុះធ្លាយទ្រុឌទ្រោម ជញ្ជាំងស្រុត ត្រូវខ្យល់និង ភ្លៀងសាចចូលក៏បាក់ ។ ក្នុងមនុស្សទាំងនោះ ព្រាហ្មណ៍ ព្រាហ្មណី កូន ប្រុស ២ កូនស្រី ១ ត្រូវផ្ទះបាក់សង្កត់ស្លាប់ទាំងអស់ ។ ក្នុងជនដែលស្លាប់ ទាំងនោះ ព្រាហ្មណ៍និងព្រាហ្មណីកើតក្នុងកំណើតប្រេត កូនប្រុស ២ នាក់ កូនស្រី ១ កើតក្នុងកុម្មទេវតា ។ ក្នុងកូនទាំងនោះ កូនច្បងមានដំរីជាពាហនៈ កូនពៅមានរថទឹមដោយសេះអស្សតរ កូនស្រីមានវិមាសជាជំនិះ ព្រាហ្មណ៍ និងព្រាហ្មណីកាន់ដំបងដែកយ៉ាងធំវាយគ្នាទៅវិញទៅមក ។ ទីដែលត្រូវវាយ ហើយបូសមានប្រមាណប៉ុនក្អមផុសឡើង មួយរំពេចប៉ុណ្ណោះ បូសក៏ទុំពេញ ទំហឹង ហើយបែក ។ ព្រាហ្មណ៍ ២ នាក់ប្តីប្រពន្ធនោះ ក៏នាំគ្នាថែទាំបូស ដល់គ្នានឹងគ្នា ត្រូវសេចក្តីក្រោធគ្របសង្កត់ ឥតសេចក្តីករុណា គំហកគ្នា ដោយវាចាគ្រោតគ្រាត នាំគ្នាផឹកខ្ទុះនិងឈាម ក៏មិនឆ្អែត ។

លំដាប់នោះ សាមណេរត្រូវសេចក្តីអផ្សុកវិតរុំចិត្ត ចូលទៅរកឧបជ្ឈាយ៍ ប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំធួនថ្ងៃប្លេជ្ញាហើយនឹងត្រឡប់ទៅផ្ទះសូមលោក

ម្ចាស់អនុញ្ញាតចុះ ។ គ្រានោះ ព្រះឧបជ្ឈាយ៍ក៏ពោលនឹងសាមណេរថា ក្នុងថ្ងៃ ១៤ រោច ពេលព្រះអាទិត្យលិច ចូរត្រឡប់មក ។ ដូច្នេះហើយ បានដើរទៅបន្តិច ឈរត្រង់ឥសិបតនវិហារ ។ សម័យនោះ ទេវបុត្ត ២ អង្គនោះ មួយអន្ទើដោយប្អូនស្រីដើរច្នូងកាត់ទីនោះឯង ដើម្បីទៅកាន់សមាគមយក្ខ ។ ឯមាតាបិតារបស់ជនទាំងនោះ នាំគ្នាកាន់ដំបង និយាយវាចាគ្រោតគ្រាត មានសម្បុរខ្មៅ មានសរសៃសក់កន្ទ្រើង ដូចគ្នានឹងដើមត្នោតដែលត្រូវភ្លើងឆេះ មានខ្ទុះនិងលោហិតហូរ មានខ្លួនក្រៀមស្វិត ឃើញគួរខ្ពើម គួរកិតភ័យដើរតាមទេវតានោះទៅ ។

សម័យនោះ ព្រះសង្ឃិច្ចៈសម្តែងឫទ្ធិឲ្យសាមណេរនោះបានឃើញជនទាំងនោះដែលកំពុងដើរទៅទាំងអស់ ហើយពោលនឹងសាមណេរថា តើអ្នកឃើញដែរឬទេ ជនទាំងនេះកំពុងដើរទៅ សាមណេរប្រាប់ថា ឃើញលោកម្ចាស់ ។ ព្រះសង្ឃិច្ចៈពោលថា បើដូច្នោះ ចូរអ្នកសាកសួរដល់កម្មដែលជនទាំងនេះធ្វើចុះ ។ សាមណេរសួរទេវតាដែលទៅដោយដំរីជាដើមតាមលំដាប់ ជនទាំងនោះពោលថា សូមលោកម្ចាស់សាកសួរ អ្នកមកខាងក្រោយចុះ សាមណេរពោលនឹងប្រេតទាំងនោះដោយគាថាទាំងឡាយថា

អ្នកទៅមុនគេបង្អស់ ជិះដំរីស ឯអ្នកទៅកណ្តាលគេ ជិះរថទឹមសេះអស្សតរ ចំណែកកញ្ញាមកខាងក្រោយគេ ទៅដោយវក្លីស្វាងរុងរឿងសព្វទិសទាំង ១០ ។ ឯអ្នកទាំងឡាយ ( ដែលមកក្រោយគេបង្អស់ ) មានដៃកាន់ដំបង មានមុខជោកដោយ

ទឹកភ្នែក មានខ្លួនបែកធ្លាយ ហើយផឹកនូវខ្ទុះនឹងឈាម នៃគ្នានឹងគ្នាជាអាហារ អ្នកទាំងឡាយ កាលកើតជាមនុស្ស តើបានធ្វើអំពើដូចម្តេចខ្លះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុរតោ** បានដល់ មុនគេបង្អស់ ។ បទថា **សេតេន** បានដល់ ពណ៌ស ។ បទថា **បលេតិ** ប្រែថា ដើរទៅ ។ បទថា **មជ្ឈេ បន** បានដល់ ក្នុងរវាងទេវបុត្តដែលជិះដ៏រនិងទេពធីតាដែលអង្គុយលើរ ។ មានវាចាប្រកបសេចក្តីថា បទថា **អស្សតរីរថេន** សេចក្តីថា ទៅដោយរថទឹមដោយមេសេះអស្សតរ ។ បទថា **នីយតិ** ប្រែថា នាំទៅ ។ បទថា **ឱភាសយន្តិ ឯស សព្វសោ ទិសា** សេចក្តីថា បញ្ចេញរស្មី សព្វទិសទាំង ១០ ដោយជុំវិញដោយរស្មីនៃសរីរៈរបស់ខ្លួននិងដោយរស្មីនៃសំពត់និងគ្រឿងអាភរណៈជាដើម ។ បទថា **មុគ្គរហត្ថបាណិនោ** បានដល់ ចំណែកអ្នកទាំងឡាយមានដៃកាន់ដំបងព្រោះមានដំបងក្នុងដៃដែលហៅថា **មុគ្គរំ** ( ដំបង ) ។ បាតដៃនោះឯង មានអត្ថបែកចេញអំពីសព្ទថា **ហត្ថ** ( ដៃ ) ព្រោះបានវោហារថា បាតដៃ ក្នុងកិច្ចដែលគប្បីធ្វើផែនដីឲ្យល្អិតជាដើម ។ បទថា **ឆិន្នបភិន្នគត្តា** បានដល់ មានខ្លួនជាមុខដំបៅក្នុងទីនោះៗ ដោយការប្រើដំបងវាយ ។ បទថា **បិវាថ** ប្រែថា សូមអ្នកទាំងឡាយផឹកស៊ីចុះ ។

ប្រេតទាំងនោះ ត្រូវសាមណេរសួរយ៉ាងនេះ ទើបឆ្លើយរឿងទាំងអស់នោះដោយគាថា ៤ ថា

បុគ្គលណាទៅដោយដ៏រសេះដ៏ប្រសើរ មានជើង ៤ មុនគេ បុគ្គល

*នោះជាបុត្តច្បងរបស់ខ្ញុំ បានថ្វាយទានហើយក៏បានជួបសេចក្ដីសុខ ។ បុគ្គលណា ទៅដោយរថទឹមសេះ ៤ មានដំណើរល្អក្នុងទីកណ្ដាល បុគ្គលនោះជាបុត្តកណ្ដាលរបស់ខ្ញុំ ជាអ្នកមិនកំណាញ់ ជាម្ចាស់ទានដ៏រុងរឿង ។ នារីណា ប្រកបដោយបញ្ញា មានភ្នែកថ្លាដូចម្រឹគ ទៅដោយវ ក្រោយគេ នារីនោះជាធីតាពៅអង្គស់របស់ខ្ញុំ ជាអ្នកមានសេចក្ដីសុខតែងរីករាយតាមចំណែកផលទានពាក់កណ្ដាល ។ អំពីជាតិមុនជនទាំងនុ៎ះជាអ្នកមានចិត្តជ្រះថ្លា បានឲ្យទានដល់ពួកសមណៈ និងព្រាហ្មណ៍ ចំណែកយើងខ្ញុំទាំងឡាយវិញ ជាអ្នកកំណាញ់ ជេរប្រទេចផ្ដាសា សមណព្រាហ្មណ៍ទាំងឡាយ ឯជនទាំងនេះលុះឲ្យហើយទើបគេបម្រើ ( ដោយកាមគុណ ) ចំណែកពួកយើងទើបក្រៀមស្ងួតដូចដើមបបុសដែលហាលថ្ងៃដូច្នោះ ដូច្នេះ ។*

*ក្នុងបទទាំងនោះ បទថា* **បុរតោ វ យោ គច្ឆតិ** *សេចក្ដីថា បណ្ដាបុគ្គលដែលដើរទៅទាំងនេះ អ្នកដែលទៅខាងមុខ... ។ បាលីថា* **យោ សោ បុរតោ គច្ឆតិ** *ដូច្នេះក៏មាន អធិប្បាយថា បុគ្គលដែលទៅខាងមុខនោះ ។ បទថា* **កុញ្ជរេន** *បានដល់ ដំរីដែលបានឈ្មោះថា កុញ្ជរ ព្រោះអត្ថថា ញ៉ាំងផ្ទៃប្រឹថពី គឺផែនដីឲ្យវិនាស ឬព្រោះត្រេកអរ គឺត្រាច់ទៅកាន់ជើងភ្នំដែលសម្បូរដោយស្មៅនិងវល្លិជាដើម ។ បទថា* **នាគេន** *បានដល់ ឈ្មោះថា នាគ ព្រោះជាសត្វមិនគួរកន្លងល្មើស មិនគួរមើលងាយ ។ ដោយដំរីដ៏ប្រសើរនោះ ។*

បទថា **ចតុក្កមេន** បានដល់ មានជើង ៤ ។ បទថា **ជេដ្ឋកោ** ប្រែថា ដែល កើតមុន ។

បទថា **ចតុត្ថិ** បានដល់ ដោយមេសេះអស្សតរ ៤ ។ បទថា **សុវគ្គិតេន** បានដល់ ដែលមានការស្ទុះទៅស្មើ គឺរត់ទៅយ៉ាងល្អ ។ បទថា **មិគមន្ទ-លោចនា** បានដល់ មានភ្នែកដូចភ្នែកម្រឹគ ។ បទថា **ភាគឌ្ឍភាគេន** បាន ដល់ ព្រោះចំណែកទានពាក់កណ្ដាល គឺព្រោះទានពាក់កណ្ដាលចំណែកអំពី ចំណែកនៃទានដែលខ្លួនបានហើយជាហេតុ ។ បទថា **សុខី** ប្រែថា បានទទួល សេចក្ដីសុខ ។ ពិតហើយ ពាក្យថា **សុខី** នេះ លោកពោលជាលិង្គវិ-បល្លាស ។ បទថា **បរិភាសកា** ប្រែថា អ្នកជេរ ។ បទថា **បរិចារយន្តិ** សេចក្ដីថា ជនទាំងនោះ រមែងញុំាងឥន្ទ្រិយរបស់ខ្លួនឲ្យត្រាច់ទៅក្នុងកាមគុណ ដែលជាទិព្វ តាមសេចក្ដីសុខក្នុងទីផ្សេងៗ ឬញុំាងជនជាបរិវារ ឲ្យធ្វើការ បម្រើខ្លួន ដោយវិបាកជាគ្រឿងហូរចេញនៃបុញ្ញានុភាពរបស់ខ្លួន ។

បទថា **មយញ្ច សុស្សាម នឡោវ ឆិន្នោ** សេចក្ដីថា ឯខ្ញុំទាំង ២ ស្គម ស្គាំង សុបសៅ ដូចដើមបបុសដែលគេកាត់ គឺដែលគេបោះទៅកណ្ដាលថ្ងៃ ដូច្នោះ បានដល់ ជាអ្នកក្រៀមស្ងួតហួតហែង ដោយការឃ្លាននិងស្រេកនិង ដោយការប្រើដំបងប្រទូស[illegible] ។

ប្រេតទាំងនោះ កាលប្រកាសសេចក្ដីអាក្រក់របស់ខ្លួន យ៉ាងនេះហើយ ទើបប្រាប់ថា ពួកយើងជាអ៊ំប្រុសនិងអ៊ំស្រីរបស់លោក ។ សាមណេរបាន ស្ដាប់ដូច្នោះហើយ កើតសេចក្ដីសង្វេគ កាលនឹងសួរថា ធ្វើដូចម្ដេចហ្ន៎ ទើប

ភោជនសម្រេចដល់ពួកអ្នកធ្វើអំពើអាក្រក់បែបនេះបាន ទើបពោលគាថានេះថា

ភោជនាហាររបស់អ្នកទាំងឡាយដូចម្តេចទៅ ទីដេករបស់អ្នកដូចម្តេចទៅ ចុះអ្នកទាំងឡាយមានបាបធម៌ដ៏ក្រៃលែង ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដូចម្តេច ភោជនាហារទាំងឡាយដ៏ច្រើនមិនមែនជារបស់តិចតួចឡើយ ឥឡូវនេះ អ្នកដល់នូវសេចក្តីទុក្ខ ព្រោះប្រាសចាកសេចក្តីសុខ ។

ក្នុងបទទាំងនោះ បទថា **កឹ តុម្ហាកំ ភោជនំ** សេចក្តីថា វត្ថុដូចម្តេចជាភោជនរបស់ពួកអ្នក ។ បទថា **កឹ សយានំ** សេចក្តីថា វត្ថុដូចម្តេចជាទីដេករបស់អ្នក ។ អាចារ្យពួកខ្លះពោលថា **កឹសយានា** ដូច្នេះក៏មាន អធិប្បាយថា របស់ដូចម្តេចដែលជាទីដេករបស់អ្នក គឺអ្នកដេកក្នុងទីដេកដូចម្តេច ។ បទថា **កថញ្ច យាបេថ** សេចក្តីថា អ្នកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយប្រការដូចម្តេច ។ បាលីថា **កថំ វោ យាបេថ** ដូច្នេះក៏មាន អធិប្បាយថា អ្នកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាការដូចម្តេច ។ បទថា **សុបាបធម្មិនោ** បានដល់ បុគ្គលមានបាបធម៌ដោយល្អ គឺយ៉ាងក្រៃលែង ។ បទថា **បហូតភោគេសុ** សេចក្តីថា កាលភោគៈមិនមានទីបំផុត គឺយ៉ាងក្រៃលែងមាន ។ បទថា **អនប្បកេសុ** ប្រែថា មិនតិច គឺច្រើន ។ បទថា **សុខំ វិរាធាយ** បានដល់ ទៀយណាយ គឺមិនត្រេកអរនឹងសេចក្តីសុខ ព្រោះមិនធ្វើបុណ្យដែលជាហេតុឲ្យកើត សេចក្តីសុខ ។ អាចារ្យពួកខ្លះពោលថា **សុខស្ស វិរាធេន**

ក៏មាន ។ បទថា **ទុក្ខជ្ជ បត្តា** សេចក្ដីថា ថ្ងៃនេះ គឺឥឡូវនេះ អ្នកបានទទួលសេចក្ដីទុក្ខដែលទាក់ទងក្នុងកំណើតប្រេតនោះ ។

ប្រេតទាំងឡាយ ត្រូវសាមណេរសួរយ៉ាងនោះហើយ កាលនឹងឆ្លើយពាក្យសាមណេរសួរទើបបានភាសិតគាថា ៥ ថា

យើងខ្ញុំទាំងឡាយ សម្លាប់នូវគ្នានឹងគ្នា ហើយក្រេបផឹកនូវខ្ទុះ និងឈាម ទុកជាផឹកច្រើន ក៏មិនបាត់ស្រេកឃ្លាន យើងខ្ញុំទាំងឡាយ ក៏នៅតែស្រេកឃ្លានដដែល ។ ជនទាំងឡាយណា ជាអ្នកមិនចែកចាយឲ្យទាន ជនទាំងនោះ លុះលះលោកនេះទៅហើយ រមែងទៅកើតក្នុងឋានយមលោក តែងខ្សឹកខ្សួល ដូចយើងខ្ញុំទាំងឡាយ ជនទាំងឡាយណា បាននូវសម្បត្តិទាំងឡាយហើយ តែជាអ្នកកំណាញ់ មិនបរិភោគផង មិនធ្វើបុណ្យផង ។ ជនទាំងនោះជាអ្នកមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ក្នុងលោកខាងមុខ ក្នុងកាលជាខាងក្រោយមក ជនទាំងនោះរមែងឆេះរោលរាលក្ដៅក្រហាយ អស់កាលជាយូរអង្វែងព្រោះបានធ្វើនូវកម្មមានផលជាទុក្ខ តែងទទួលផលជាទុក្ខ មានផលដ៏ក្ដៅក្រហាយ ។ ទ្រព្យសម្បត្តិជារបស់មិនទៀង ជីវិតក្នុងលោកនេះជារបស់មិនទៀង បណ្ឌិតដឹងនូវរបស់មិនទៀងតាមសភាពជារបស់មិនទៀងហើយ គប្បីធ្វើនូវទីពឹង ។ ជនទាំងឡាយណាអ្នកឈ្លាសក្នុងព្រះសទ្ធម្ម ដឹងច្បាស់យ៉ាងនេះ ជន

ទាំងនោះឈ្មោះថា ជាអ្នកមិនថ្កើសប្រហែសក្នុងទាន ព្រោះ
បានស្តាប់ពាក្យនៃព្រះអរហន្តទាំងឡាយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ន ធាតា ហោម** សេចក្តីថា ខ្ញុំមិនបាត់ស្រេកឃ្លាន គឺមិនឆ្អែត ។ បទថា **នច្ចាធិម្ហសេ** បានដល់ មិនទាន់ឆ្អែត គឺមិនញុំាងការពេញចិត្តឲ្យកើតឡើង អធិប្បាយថា ពួកយើងមិនបានផឹកខ្ទះនិងឈាមតាមសេចក្តីត្រូវការរបស់ខ្លួន ។ បទថា **ឥច្ចេវ** កែជា **ឯវមេវ** ប្រែថា ដូច្នោះនោះឯង ។ បទថា **មច្ចា បរិទេវយន្តិ** សេចក្តីថា ពួកមនុស្សដទៃដែលធ្វើបាប រមែងកន្ទក់កន្ទេញ រមែងខ្សឹកខ្សួល ដូចពួកយើង ។ បទថា **អធាយកា** បានដល់ ជាអ្នកមិនឲ្យជាប្រក្រតី គឺជាអ្នកកំណាញ់ ។ បទថា **យមស្ស ឋាយិនោ** បានដល់ ជាអ្នកមានប្រក្រតីតាំងនៅក្នុងស្ថាននៃស្តេចយម ដែលគេស្គាល់ថា ជាយមលោក គឺក្នុងបេតវិស័យ ។ បទថា **យេ តេ វិន្ទន្តិ អធិគច្ឆ ភោគេ** សេចក្តីថា ជនទាំងនោះពួកណាបានជួប គឺបានទទួលនូវភោគៈផ្សេងៗដែលជាសេចក្តីសុខវិសេស ក្នុងឥឡូវនេះនិងក្នុងកាលតទៅ ។ បទថា **ន កុព្វរេ ធាបិ ករោន្តិ បុញ្ញំ** សេចក្តីថា រមែងមិនបរិភោគដោយខ្លួនឯងដូចពួកយើង កាលនឹងឲ្យដល់ជនដទៃ ក៏មិនធ្វើបុណ្យ ដែលសម្រេចដោយទាន ។

បទថា **តេ ខុប្បិបាសូបគតា បរត្ថ** សេចក្តីថា សត្វទាំងនោះ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ក្នុងលោកខាងមុខ គឺក្នុងបរលោក បានដល់ ក្នុងបេតវិស័យ ។ បទថា **ចិរំ ឈាយរេ ឧយ្ហមានា** សេចក្តីថា ត្រូវភ្លើង គឺទុក្ខ

*ដែលមានការស្រេកឃ្លានជាដើមជាហេតុ គឺត្រូវភ្លើងក្តៅក្រហាយ ប្រព្រឹត្តទៅ ដោយន័យជាដើមថា ពួកយើងមិនបានធ្វើកុសលឡើយ ធ្វើតែអំពើអាក្រក់ ដូច្នេះដុតពេល គឺក្តៅពេលពល ។ បទថា* **ទុខុទ្រានិ** *បានដល់ មានទុក្ខជាវិបាក ។ បទថា* **អនុភោន្តិ ទុក្ខំ កដុកប្ផលានិ** *សេចក្តីថា មនុស្សទាំងនោះកាលធ្វើនូវបាបកម្មដែលមានផលមិនគួរប្រាថ្នាហើយ រមែងសោយទុក្ខ គឺទុក្ខដែលប្រព្រឹត្តទៅក្នុងអបាយអស់កាលយូរ ។*

*បទថា* **ឥត្តរំ** *សេចក្តីថា មិនតាំងនៅអស់កាលយូរ គឺមិនទៀង មានការប្រែប្រួលជាធម្មតា ។ បទថា* **ឥត្តរំ ឥធ ជីវិតំ** *សេចក្តីថា សូម្បីជីវិតនៃសត្វទាំងឡាយ ក្នុងមនុស្សលោកនេះបន្តិចបន្តួច គឺមានប្រមាណតិចតួច ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ទុកក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលរស់នៅយ៉ាងយូរ ត្រឹមមួយរយឆ្នាំ ឬថយចុះមកក៏មាន លើសជាង បន្តិចក៏មាន ដូច្នេះ ។*

*បទថា* **ឥត្តរំ ឥត្តរតោ ញត្វា** *សេចក្តីថា ពិចារណាដោយបញ្ញាថា គ្រឿងឧបភោគបរិភោគ មានទ្រព្យនិងធញ្ញាហារជាដើមនិងជីវិតរបស់មនុស្សទាំងឡាយ មានបន្តិចបន្តួច គឺមានមួយជួរខណៈ បានដល់ មិនយូរ ។ បទថា* **ទីបំ កយិរាថ បណ្ឌិតោ** *សេចក្តីថា បុរសដែលមានបញ្ញាគប្បីធ្វើនូវកោះ គឺទីពឹងរបស់ខ្លួនឲ្យជាទីតាំងអាស្រ័យនៃហិតសុខ ក្នុងបរលោក ។ បទថា* **យេ តេ ឯវំ បជានន្ត** *សេចក្តីថា ជនទាំងនោះ ពួកណារមែងដឹងតាមសេចក្តីពិតថាភោគៈនិងជីវិតនៃមនុស្សទាំងឡាយ ជារបស់បន្តិចបន្តួច ជនទាំងនោះ*

រមែងមិនប្រមាទក្នុងទានសព្វកាល ។ បទថា **សុត្វា អរហតំ វចោ** សេចក្តីថា បានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះអរហន្តទាំងឡាយគឺរបស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម អធិប្បាយថា ព្រោះស្តាប់ ។ ពាក្យដ៏សេសប្រាកដច្បាស់ហើយនោះឯង ។

ប្រេតទាំងនោះ ត្រូវសាមណេរសួរហើយយ៉ាងនេះ ទើបប្រាប់សេចក្តីនោះហើយប្រកាសថា ពួកយើងជាអ៊ំប្រុសនិងអ៊ំស្រីរបស់លោក ។ សាមណេរបានស្តាប់ដូច្នោះហើយ កើតនូវសេចក្តីសង្វេគ បន្ទាបង់សេចក្តីអផ្សុកបានឱនក្បាលចុះត្រង់ជើងទាំង ២ របស់ឧបជ្ឈាយ៍ ហើយពោលយ៉ាងនេះថាបពិត្រលោកម្ចាស់ កាលដែលលោកម្ចាស់អនុគ្រោះ អាស្រ័យសេចក្តីករុណាគប្បីធ្វើនោះ ឈ្មោះថាធ្វើហើយដល់ខ្ញុំ ខ្ញុំនឹងរក្សាដោយមិនឲ្យធ្លាក់ទៅកាន់សេចក្តីវិនាសដ៏ខ្លាំងក្លា ឥឡូវនេះ ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះ ត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈប៉ុណ្ណោះ លំដាប់នោះ ព្រះសង្កិច្ចៈបានប្រាប់កម្មដ្ឋានដែលសមគួរដល់អធ្យាស្រ័យរបស់សាមណេរនោះ សាមណេរប្រកបព្យាយាមកម្មដ្ឋានមិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ ឯព្រះសង្កិច្ចៈបានក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តា ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ដោយពិស្តារដល់បរិស័ទ ដែលដល់ព្រមហើយ ទេសនានោះមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា នាគប្រេតចប់

# រឿង ឧរគប្រេត ទី ១២

[ ១២ ] ( ពោធិសត្វនិយាយថា ) ពស់តែងសកសំណកចាស់របស់ខ្លួនចោលហើយលូនទៅ យ៉ាងណាមិញ ( សត្វ ) កាលបើសរីរៈប្រើការមិនកើតហើយ ធ្វើនូវមរណកាលទៅកាន់បរលោក ក៏យ៉ាងនោះ ( ឯសរីរៈដែលនៅសល់ខាងអាយនោះ ) កាលគេដុត ក៏មិនបានដឹង ( ធ្វើម្ដេចនឹងដឹង ) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយបាន ហេតុនោះ ខ្ញុំមិនសោកស្ដាយសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

( មាតានិយាយថា ) បុត្ររបស់ខ្ញុំនេះ ខ្ញុំមិនបានហៅគេមកអំពីលោកនោះ ខ្ញុំមិនបានអនុញ្ញាត គេក៏ទៅអំពីមនុស្សលោកនេះ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការទួញយំធ្វើអ្វីព្រោះកិរិយាទៅនោះ ( ឯសរីរៈដែលនៅសល់ខាងអាយនោះ ) គេដុតក៏មិនបានដឹង ( ធ្វើម្ដេចនឹងដឹង ) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនទួញយំនឹងសរីរៈនុ៎ះឡើយស្រេចតែគតិរបស់គេ ។

( ប្អូនស្រីនិយាយថា ) បើខ្ញុំយំ ខ្ញុំនឹងទៅជាស្គមក្នុងការយំនោះ នឹងគប្បីមានផលដូចម្ដេចដល់ខ្ញុំ សេចក្ដីមិនត្រេកអរដ៏លើសលុប នឹងគប្បីមានដល់ពួកញាតិមិត្ត និងអ្នកមានចិត្តល្អរបស់យើងទាំងឡាយ ( ឯសរីរៈដែលសល់នៅខាងអាយនោះ ) កាលគេដុតក៏មិនបានដឹង ( ធ្វើម្ដេចនឹងដឹង ) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយស្រេចតែគតិរបស់គេ ។

( ភរិយានិយាយថា ) បុគ្គលណាសោកស្ដាយ នូវបុគ្គលដែលធ្វើមរណ

កាលទៅកាន់បរលោកហើយ បុគ្គលនោះ ប្រៀបដូចជាទារកយំទារនូវព្រះចន្ទ ដែលកំពុងចរទៅ ( ឯសរីរៈដែលសល់នៅខាងអាយនោះ ) កាលគេដុតក៏មិនបានដឹង ( ធ្វើម្ដេចនឹងដឹង ) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

( ទាសីនិយាយថា ) បពិត្រព្រាហ្មណ៍ ក្អមទឹកដែលបែកហើយ តភ្ជាប់វិញមិនបាន យ៉ាងណា សរីរៈអ្នកស្លាប់នេះក៏យ៉ាងនោះដែរ បុគ្គលណា សោកស្ដាយនូវបុគ្គលដែលទៅកាន់បរលោកហើយ ( បុគ្គលនោះក៏ដូចជាអ្នកសោកស្ដាយនូវក្អមទឹកដែលបែកហើយ ) ( ឯសរីរៈដែលសល់នៅខាងអាយនោះ ) កាលគេដុតក៏មិនបានដឹង ( ធ្វើម្ដេចនឹងដឹង ) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ។

## ចប់ រឿងឧរគប្រេតទី ១២ ។

## ឧទ្ទាន

រឿងខេត្តូបមាប្រេត ( ព្រះអរហន្តប្រៀបដូចស្រែ ) ១ រឿង ( សូករប្រេត ) ប្រេតមានសម្បុរកាយល្អ ១ ជា ២ លើករឿង ( បូតិមុខប្រេត ) ១ រឿងបិដ្ឋធីតលិកប្រេត ១ រឿងតិរោកុឌ្ឌប្រេត ១ រឿងបុត្តខាទិកប្រេត ( ស្រីប្រេតស៊ីកូនឯង ) ២ លើក រឿងគោណប្រេត ១ រឿងមហាបេសការប្រេតស៊ីនូវគូថ ១ រឿងខលាត

ប្រេតនៅក្នុងវិមាន ១ រឿងនាគប្រេត ១ រឿងឧរគប្រេត ១ ឧទ្ទានក្នុងវគ្គជាបឋម មានរឿង ១២ យ៉ាងនេះឯង ៗ

## ចប់ ឧរគវគ្គទី ១ ៗ

# អដ្ឋកថា ឧរគប្រេត

[ ១២ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ ទើបត្រាស់ថា **ឧរគោវ តចំ ជិណ្ណំ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី មានកូនប្រុសរបស់ឧបាសកម្នាក់ បានធ្វើកាលកិរិយា ។ ព្រោះកូននោះស្លាប់ ឧបាសកនោះក៏ដល់នូវសេចក្តីសោកខ្សឹកខ្សួល ចេញទៅខាងក្រៅ មិនអាចធ្វើការងារណាមួយបានទើបនៅតែក្នុងផ្ទះប៉ុណ្ណោះ ។ ក្នុងវេលាជិតភ្លឺ ព្រះសាស្តាយាងចេញអំពីព្រះមហាករុណាសមាបត្តិទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញឧបាសកនោះ ក្នុងពេលព្រឹកទ្រង់ស្លៀកដណ្តប់ហើយ ទ្រង់កាន់បាត្រនិងចីវរ បានយាងទៅកាន់ផ្ទះរបស់ឧបាសកនោះហើយ ប្រថាប់ឈរត្រង់ទ្វារ ឯឧបាសកដឹងថា ព្រះសាស្តាយាងមកទើបក្រោកឡើងទៅទទួល ហើយទទួលបាត្រអំពីព្រះហស្តហើយយាងឲ្យចូលក្នុងផ្ទះ ក្រាលអាសនៈថ្វាយ ។ ព្រះមានព្រះភាគ គង់លើអាសនៈដែលគេក្រាលហើយ ចំណែកឧបាសក ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងចំណែកម្ខាង ព្រះមានព្រះភាគត្រាស់នឹងឧបាសកនោះថា ម្នាលឧបាសក ហេតុអ្វីទើបប្រាកដដូចជាសោយសោក ឧបាសកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កូនជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គស្លាប់ទៅ ព្រោះហេតុនោះទើបខ្ញុំព្រះអង្គសោយសោក ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់បន្ទោបង់សេចក្តីសោករបស់បុរសនោះ ទើបត្រាស់ឧរគជាតកថា

បានឮថា ក្នុងអតីតកាល ក្នុងនគរពារាណសី ដែនកាសី មានត្រកូលព្រាហ្មណ៍ ឈ្មោះធម្មបាល ក្នុងត្រកូលព្រាហ្មណ៍នោះ មានបុគ្គលទាំងនេះគឺ

ព្រាហ្មណ៍ ព្រាហ្មណី កូនប្រុស កូនស្រី កូនប្រសាស្រីនិងទាសី ។ ជនទាំង អស់មានសេចក្ដីត្រេកអរក្នុងការចម្រើនមរណានុស្សតិ ។ បណ្ដាជនទាំងនោះ អ្នកដែលចេញទៅអំពីផ្ទះ ឲ្យឱវាទជនដ៏សេសហើយ មិនអាឡោះអាល័យ ចេញទៅ ។ ថ្ងៃមួយ ព្រាហ្មណ៍និងបុត្តចេញអំពីផ្ទះទៅភ្ជួរស្រែ កូនប្រុសដុត ស្មៅស្ងួតឈើនិងមែកឈើងាប់ៗ ។ ពស់មួយនៅក្នុងទីនោះ លូនចេញអំពី ព្រង់ឈើ ព្រោះខ្លាចឆេះ ទើបចឹកកូនប្រុសរបស់ព្រាហ្មណ៍ ។ បុរសនោះ សន្លប់ព្រោះកម្លាំងពិស ដួលចុះត្រង់ទីនោះឯង ស្លាប់ហើយកើតជាសក្កទេវ រាជ ។ ព្រាហ្មណ៍ឃើញកូនស្លាប់ហើយ ក៏និយាយនឹងបុរសម្នាក់ដែលដើរ ក្បែរទីធ្វើការយ៉ាងនេះថា នែសម្លាញ់ ចូរអ្នកទៅផ្ទះរបស់ខ្ញុំ ហើយប្រាប់ ព្រាហ្មណីយ៉ាងនេះថា ចូរងូតទឹក ស្លៀកសំពត់ស កាន់យកកត្តនិងផ្កាគ្រឿង ក្រអូបជាដើមសម្រាប់បុគ្គលម្នាក់ ហើយចូរប្រញាប់មក ។ បុរសនោះទៅ ផ្ទះនោះហើយ ប្រាប់ឲ្យដឹងយ៉ាងនោះ ។ ឯជនក្នុងផ្ទះ ក៏បានធ្វើតាមនោះ ត្រៀម ងូតទឹក បរិភោគអាហារ ហើយលាបគ្រឿងក្រអូប មានបរិវារជនចោមរោម លើកសរីរៈរបស់បុត្តដាក់លើជើងថ្ករ ដុតភ្លើង បូជាសព មិនសោយសោក មិនក្ដៅក្រហាយ ឈរមនសិការដោយអនិច្ចសញ្ញា ដូចដុតគល់ឈើ ។

លំដាប់នោះ បុត្តរបស់ព្រាហ្មណ៍កើតជាសក្កទេវរាជ ។ សក្កទេវរាជនោះ ជាព្រះពោធិសត្វនៃយើងទាំងឡាយ ទ្រង់ពិចារណាមើលជាតិមុន របស់ព្រះ អង្គនិងបុណ្យដែលបានធ្វើ កាលអនុគ្រោះបិតានិងពួកញាតិ ទើបកាឡាខ្លួន ជាព្រាហ្មណ៍មកក្នុងទីនោះ ឃើញពួកញាតិមិនសោយសោកក៏ពោលថាលោក

ដ៏ចម្រើនដុតម្រឹគឬ ចូរឲ្យសាច់ដល់ខ្ញុំខ្លះ ខ្ញុំកំពុងឃ្លាន ព្រាហ្មណ៍ពោលថា មិនមែនម្រឹគ តែជាមនុស្ស ។ សក្កទេវរាជពោលថា បុគ្គលនេះ ជាសត្រូវរបស់ពួកអ្នកឬ ព្រាហ្មណ៍ពោលថា មិនមែនសត្រូវទេ ជាកូនប្រុស មានគុណច្រើន ជាឱរសកើតក្នុងទ្រូង សក្កទេវរាជពោលថា កាលកូនមានគុណបែបនេះស្លាប់ ហេតុអ្វីពួកអ្នកមិនសោយសោក ។ ព្រាហ្មណ៍បានស្តាប់ដូច្នោះ កាលនឹងប្រាប់ហេតុដែលមិនសោក ទើបពោលគាថា ២ ថា

*ពស់តែងសកសំណកចាស់ របស់ខ្លួនចោល ហើយលូនទៅ*
*យ៉ាងណាមិញ ( សត្វ ) កាលបើសរីរៈប្រើការមិនកើតហើយ*
*ធ្វើនូវមរណកាលទៅកាន់បរលោកក៏យ៉ាងនោះ (ឯសរីរៈដែល*
*នៅសល់ខាងអាយនោះ ) កាលគេដុតក៏មិនបានដឹង ( ធ្វើម្តេច*
*នឹងដឹង ) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយបាន ហេតុ*
*នោះ ខ្ញុំមិនសោកស្តាយសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ*
*ដូច្នេះ ។*

ក្នុងបទទាំងនោះ បទថា **ឧរគោ** សេចក្តីថា ឈ្មោះថា **ឧរគ** ព្រោះទៅដោយទ្រូង ។ ពាក្យថា **ឧរគោ** នេះ ជាឈ្មោះរបស់ពស់ ។ បទថា **តចំ ជិណ្ណំ** បានដល់ ស្បែក គឺស្រការបស់ខ្លួនដែលគ្រាំគ្រា គឺចាស់ព្រោះភាពទ្រុឌទ្រោម ។ បទថា **ហិត្វា គច្ឆតិ សន្តនុំ** សេចក្តីថា ពស់លះបង់សំណកចាស់របស់ខ្លួនចាកសរីរៈ ត្រង់ចន្លោះដើមឈើនិងក្នុងចន្លោះឈើដែលជាឧសក្នុងរវាងគល់ឈើឬក្នុងរវាងផែនដី ដូចបុគ្គលដោះអាវ ហើយទៅតាមសេច-

ក្តីត្រូវការ យ៉ាងណា សត្វដែលវិលវល់ទៅក្នុងសង្សារ ក៏ដូច្នោះដូចគ្នា លះរាងកាយរបស់ខ្លួន គឺសរីរៈរបស់ខ្លួនដែលឈ្មោះថាជារបស់គ្រាំគ្រាព្រោះកម្មចាស់អស់ទៅគឺទៅតាមកម្ម អធិប្បាយថា កើតឡើងក្នុងភពថ្មី ។ ព្រាហ្មណ៍កាលសម្តែងដល់រាងកាយរបស់កូនដែលកំពុងនាំគ្នាដុត ទើបពោលថា **ឯវំ** ដូច្នេះជាដើម ។ បទថា **សរីរេ និព្ភោគេ** បានដល់ កាលរាងកាយរបស់បុគ្គលដទៃដែលប្រើប្រាស់មិនបានយ៉ាងនេះក៏មិនកើតប្រយោជន៍ ដូចរាងកាយរបស់កូននេះ ។ បទថា **បេតេ** បានដល់ ប្រាសចាកអាយុ ភ្លើងធាតុនិងវិញ្ញាណ ។ បទថា **កាលកតេ សតិ** បានដល់ ស្លាប់ទៅហើយ ។ បទថា **តស្មា** សេចក្តីថា ព្រោះរាងកាយដែលត្រូវដុតរមែងមិនដឹងដល់ការយំ និងការខ្សឹកខ្សួលរបស់ពួកញាតិ ដូចកូនរបស់ខ្ញុំ មិនដឹងនូវសេចក្តីទុក្ខ ដែលកើតអំពីការដុតព្រោះប្រាសចាកវិញ្ញាណ ដូច្នោះ ខ្ញុំធ្វើកូននេះឲ្យជាហេតុ ទើបមិនយំ ។ បទថា **គតោ សោ តស្ស យា គតិ** សេចក្តីថា បើសត្វដែលស្លាប់ទៅហើយមិនដាច់សូន្យសោត ទោះជាដូច្នោះ អ្នកស្លាប់គប្បីប្រាថ្នានូវគតិណាដោយអំណាច កម្មដែលមានឱកាសបានធ្វើទុក បុគ្គលនោះក៏ទៅកាន់គតិនោះ បន្ទាប់អំពីចុតិនោះឯង អធិប្បាយថា បុគ្គលនោះ រមែងមិនដឹងនូវការយំ ឬការខ្សឹកខ្សួលរបស់ពួកញាតិក្នុងជាតិមុននិងការយំរបស់ពួកញាតិក្នុងជាតិមុន ក៏មិនអាចសម្រេចប្រយោជន៍ណាមួយដោយច្រើន ។

កាលព្រាហ្មណ៍បានពោលដល់ហេតុ ដែលខ្លួនមិនសោយសោក កាលបានប្រកាសដល់ភាពឈ្លាសវៃក្នុងមនសិការ ដោយបរិយាយយ៉ាងនេះហើយ

សក្កទេវរាជដែលមកក្នុងរូបរាងជាព្រាហ្មណ៍ ក៏ត្រាស់នឹងព្រាហ្មណីថា នែនាង អ្នកដែលស្លាប់នោះ ជាអ្វីនឹងនាង ព្រាហ្មណីពោលថា ជាកូនរបស់ខ្ញុំ ខ្ញុំបរិហារគភ៌អស់ ១០ ខែ ឲ្យជៀសផុតបីបាច់រក្សារហូតធំ ។ សក្កទេវរាជពោលថា បើដូច្នេះ ជាជំបូងឪពុកមិនយំ ព្រោះគេជាមនុស្សប្រុស តែជម្មតាម្ដាយតែងមានទូវហឫទ័យទន់ ព្រោះហេតុអ្វី ទើបនាងមិនយំ នាងបានស្ដាប់ដូច្នោះ កាលប្រាប់នូវហេតុដែលមិនយំ ទើបពោលគាថា ២ ថា

> បុត្តរបស់ខ្ញុំនេះ ខ្ញុំមិនបានហៅគេមកអំពីលោកនោះ ខ្ញុំមិនបានអនុញ្ញាត គេក៏ទៅអំពីមនុស្សលោកនេះ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការទួញយំធ្វើអ្វី ព្រោះកិរិយាទៅនោះ ( ឯសរីរៈដែលនៅសល់ខាងអាយនោះ ) គេដុតក៏មិនបានដឹង ( ធ្វើម្ដេចនឹងដឹង ) នូវសេចក្ដីខ្សឹកខ្សួលរបស់ញាតិទាំងឡាយព្រោះហេតុនោះ ខ្ញុំមិនទួញយំនឹងសរីរៈនុ៎ះឡើយស្រេចតែគតិរបស់គេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អនព្ភិតោ** ប្រែថា មិនបានហៅមក គឺមិនបានហៅយ៉ាងនេះថា អ្នកចូរមកជាកូនរបស់យើងចុះ ។ បទថា **តតោ** បានដល់ចាកបរលោកដែលគេធ្លាប់នៅអំពីមុន ។ បទថា **អាគា** ប្រែថា មកហើយ ។ បទថា **អននុញ្ញាតោ** ប្រែថា មិនបានអនុមតិ គឺពួកយើងមិនបានបណ្ដោយយ៉ាងនេះថា ចូរទៅបរលោកចុះ ។ បទថា **ឥតោ** យោគថា **ឥធលោកតោ** ប្រែថា ចាកលោកនេះ ។ បទថា **គតោ** ប្រែថា ទៅប្រាសហើយ ។ បទ

ថា **យថាគតោ** បានដល់ មកហើយដោយអាការណា អធិប្បាយថា ពួកយើងមិនបានហៅក៏មក ។ បទថា **តថា គតោ** បានដល់ ទៅហើយដោយអាការនោះដូចគ្នា ។ ព្រាហ្មណីសម្តែងដល់កម្មដែលកូននោះធ្វើថា គេមកដោយកម្មរបស់ខ្លួនឯង យ៉ាងណា គេក៏ទៅដោយកម្មរបស់ខ្លួនឯង យ៉ាងនោះ ។ បទថា **តត្ថ កា បរិទេវនា** សេចក្តីថា ចាំបាច់បរិទេវនាធ្វើអ្វី ព្រោះការស្លាប់វិលវល់ក្នុងសង្សារដែលមិនទៅក្នុងអំណាចយ៉ាងនេះ ។ ព្រាហ្មណីសម្តែងថា ការកន្ទក់កន្ទេញនោះមិនសមគួរ បុគ្គលមានបញ្ញាមិនគប្បីធ្វើ ។

សក្កទេវរាជ កាលបានស្តាប់ពាក្យរបស់ព្រាហ្មណីយ៉ាងនេះហើយ ទើបសួរប្អូនស្រីរបស់គេថា នែនាង នាងជាអ្វីនឹងបុគ្គលដែលស្លាប់ នាងឆ្លើយថា គាត់ជា បងប្រុសរបស់ខ្ញុំ សក្កទេវរាជសួរថា នែនាង ធម្មតាប្អូនស្រី ត្រូវស្រឡាញ់បងប្រុស ព្រោះហេតុអ្វី ទើបនាងមិនយំ ឯនាងកាលប្រាប់ហេតុដែលមិនយំទើបពោលគាថា ២ ថា

> បើខ្ញុំយំ ខ្ញុំនឹងទៅជាស្គមក្នុងការយំនោះ នឹងគប្បីមានផលដូចម្តេចដល់ខ្ញុំ សេចក្តីមិនត្រេកអរដ៏លើសលុបនឹងគប្បីមានដល់ពួកញាតិមិត្តនិងអ្នកមានចិត្តល្អ របស់យើងទាំងឡាយ ( ឯសរីរៈដែលសល់នៅខាងអាយនោះ ) កាលគេដុតក៏មិនបានដឹង ( ធ្វើម្តេចនឹងដឹង ) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សចេ រោទេ កិសា អស្សំ** សេចក្តីថា បើខ្ញុំគប្បីយំ គឺខ្ញុំក៏នឹងស្គម មានរាងកាយរីងស្ងួត ។ បទថា **តត្ថ មេ កឹ ផលំ សិយា** សេចក្តីថា នឹងមានផលដូចម្តេច មានអានិសង្សដូចម្តេច ក្នុងការយំដែលមានការស្លាប់របស់បងប្រុសខ្ញុំជាហេតុនោះ អធិប្បាយថា បងប្រុសនៃខ្ញុំ នឹងមិនមកព្រោះការយំនោះ គាត់ក៏មិនទៅកាន់សុគតិព្រោះការយំនោះ ។ បទថា **ញាតិមិត្តសុហជ្ជានំ ភិយ្យោ នោ អរតី សិយា** សេចក្តីថា ការមិនសប្បាយចិត្ត គឺសេចក្តីលំបាកទាំងនោះ សូម្បីក្រៃលែងជាងទុក្ខព្រោះការស្លាប់របស់បងប្រុស គប្បីមានដល់ញាតិមិត្ត សម្លាញ់របស់ពួកយើង ព្រោះការសោយសោករបស់ខ្ញុំ ។

សក្កទេវរាជបានស្តាប់ពាក្យប្អូនស្រីយ៉ាងនេះហើយ ទើបពោលនឹងភរិយារបស់គេថា នាងជាអ្វីនឹងអ្នកស្លាប់ ស្រីនោះឆ្លើយថា បុរសនេះ ជាប្តីរបស់ខ្ញុំ សក្កទេវរាជពោលថា នែនាង ធម្មតាស្ត្រីរមែងមានសេចក្តីស្នេហាក្នុងប្តី ស្រីមេម៉ាយរមែងជាអ្នកឥតទីពឹង ព្រោះហេតុអ្វីទើបនាងមិនយំ ឯស្រីនោះ លុះប្រាប់ហេតុដែលខ្លួនមិនយំ ទើបពោលគាថា ២ ថា

បុគ្គលណាសោកស្តាយនូវបុគ្គលដែលធ្វើមរណកាលទៅកាន់
បរលោកហើយ បុគ្គលនោះ ប្រៀបដូចជាទារកយំទារនូវព្រះ
ចន្ទដែលកំពុងចរទៅ ( ឯសរីរៈដែលសល់នៅខាងអាយនោះ )
កាលគេដុតក៏មិនបានដឹង ( ធ្វើម្តេចនឹងដឹង ) នូវសេចក្តីខ្សឹក
ខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹង

សរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទារកោ** បានដល់ កុមារដែលនៅតូច ។ បទថា **ចន្ទំ** បានដល់ ព្រះចន្ទ ។ បទថា **គច្ឆន្តំ** បានដល់ អណ្តែតឡើងកាន់អាកាស ។ បទថា **អនុរោទតិ** សេចក្តីថា រមែងយំថា ចូរចាប់កង់រថឲ្យខ្ញុំចុះ ។ បទថា **ឯវំ សម្បទមេវេតំ** សេចក្តីថា បុគ្គលណា រមែងសោយសោកដល់បុគ្គលដែលអនិច្ចកម្មទៅហើយ គឺស្លាប់ទៅហើយ ។ សេចក្តីសោករបស់បុគ្គលនោះ ក៏មានសេចក្តីយ៉ាងនោះ គឺបែបនោះ អធិប្បាយថា ដូចមានសេចក្តីត្រូវការនឹងចាប់ព្រះចន្ទដែលអណ្តែតកណ្តាលអាកាស ព្រោះការចង់បានក្នុងវត្ថុដែលមិនគួរបាន ។

សក្កទេវរាជកាលស្តាប់ពាក្យកិរិយា របស់គេយ៉ាងនោះហើយ ទើបសួរទាសីថា នាងជាអ្វីនឹងបុរសនេះ ទាសីឆ្លើយថា គាត់ជាចៅហ្វាយរបស់ខ្ញុំ សក្កទេវរាជសួរថា បើដូច្នោះ នាងប្រហែលជាត្រូវបុរសនេះវាយ ហើយប្រើឲ្យធ្វើការងារ ព្រោះដូច្នេះ ទើបនាងមិនយំ ដោយគិតថា អញផុតល្អហើយអំពីបុរសនេះ ។ ទាសីពោលថា លោកកុំពោលយ៉ាងនោះជាមួយខ្ញុំឡើយ ទាំងសេចក្តីនោះ ក៏មិនសមគួរដល់ខ្ញុំ កូនរបស់ចៅហ្វាយខ្ញុំដល់ព្រមដោយខន្តី មេត្តានិងករុណា យ៉ាងក្រៃលែង ចូលចិត្តពោលត្រឹមត្រូវ ដូចជាកូនដែលកើតក្នុងទ្រូង ។ សក្កទេវរាជពោលថា កាលបើដូច្នោះ ព្រោះហេតុអ្វីទើបនាងមិនយំ ចំណែកទាសី កាលប្រាប់ហេតុដែលខ្លួនមិនយំ ទើបពោលគាថា ២ ថា

បពិត្រព្រាហ្មណ៍ ក្អមទឹកដែលបែកហើយ តភ្ជាប់វិញមិនបាន យ៉ាងណា សរីរៈអ្នកស្លាប់នេះ ក៏យ៉ាងនោះដែរ បុគ្គលណា សោកស្តាយនូវបុគ្គលដែលទៅកាន់បរលោកហើយ ( បុគ្គលនោះក៏ដូចជាអ្នកសោកស្តាយនូវក្អមទឹកដែលបែកហើយ ) ( ឯសរីរៈដែលសល់នៅខាងអាយនោះ ) កាលគេដុត ក៏មិនបានដឹង ( ធ្វើម្តេចនឹងដឹង ) នូវសេចក្តីខ្សឹកខ្សួលរបស់ញាតិទាំងឡាយ ព្រោះហេតុនោះ ខ្ញុំមិនយំនឹងសរីរៈនុ៎ះឡើយ ស្រេចតែគតិរបស់គេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យថាបិ ព្រហ្មេ ឧទកុម្ភោ ភិន្នោ អប្បដិសន្ធិយោ** សេចក្តីថា នែព្រាហ្មណ៍ ក្អមទឹកដែលបែកទៅដោយការវាយដោយដំបងជាដើម ផ្សារឲ្យជាប់គ្នាទៀតមិនបាន គឺនឹងឲ្យជាប្រក្រតីដូចដើមមិនបាន ។ ពាក្យដ៏សេសក្នុងគាថានេះមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលទុកហើយ ។

សក្កទេវរាជ កាលស្តាប់ពាក្យរបស់មនុស្សទាំងនោះហើយ មានចិត្តជ្រះថ្លាទើបត្រាស់ថា អ្នកទាំងឡាយ ចូរចម្រើនមរណស្សតិដោយប្រពៃនោះឯងតាំងអំពីនេះទៅ អ្នកទាំងឡាយ មិនមានកិច្ចដែលត្រូវធ្វើ មានការភ្ជួររាស់ជាដើមឡើយ ដូច្នេះហើយ ទើបធ្វើផ្ទះរបស់ជនទាំងនោះឲ្យពេញទៅដោយរតនៈ ៧ ប្រការ ទូន្មានថា អ្នកទាំងឡាយកុំប្រមាទ ចូរឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម និងប្រាប់ឲ្យមនុស្សទាំងនោះស្គាល់ព្រះអង្គ ហើយយាងទៅ

កាន់លំនៅរបស់ព្រះអង្គនោះឯង សូម្បីជនទាំងនោះ មានព្រាហ្មណ៍ជាដើម ធ្វើបុណ្យនិងទានជាដើម តាំងនៅអស់អាយុហើយ កើតក្នុងទេវលោក ។

ព្រះសាស្តា កាលទ្រង់នាំជាតកនេះមកហើយ ទ្រង់ដកនូវព្រួញគឺសេចក្តីសោករបស់ឧបាសកនោះហើយ ទ្រង់ប្រកាសសច្ចៈឲ្យក្រៃលែងឡើង ក្នុងកាលចប់សច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផល ។

អដ្ឋកថា ឧរគប្រេតចប់

ឧរគវគ្គចប់

# ឧព្វរីវគ្គ ទី២

## រឿង សំសារមោចកាប្រេត ទី ១

[ ១៣ ] ( ព្រះសារីបុត្តសួរថា ) ម្នាលស្រីស្អុម មានធ្មេញជំនីរគោម នាងជាស្រីអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមដោយសរសៃ នាងជាអ្វី មកឋិតនៅទីនេះ ។

( នាងប្រេតតបថា ) បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្តីទុក្ខ ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ព្រោះធ្វើបាបកម្ម ។

ចុះអំពើអាក្រក់ដែលនាងបានធ្វើដោយកាយ វាចា ចិត្ត តើដូចម្តេច នាងទៅកាន់បេតលោកអំពីមនុស្សលោកនេះ ព្រោះវិបាកនៃកម្មដូចម្តេច ។

បពិត្រលោកដ៏ចម្រើន បិតាមាតា ឬពួកញាតិជាអ្នកអនុគ្រោះ
ដល់ខ្ញុំ គប្បីដឹកនាំខ្ញុំថា នាងចូរមានចិត្តជ្រះថ្លា ឲ្យទានដល់ពួក
សមណព្រាហ្មណ៍ ( ដូច្នេះ ) ពុំមានឡើយ ។ ខ្ញុំទើបបាន
ជាស្រីអាក្រាតមានសភាពយ៉ាងនេះ តែងត្រាច់ទៅអស់ ៥០០
ឆ្នាំ ចាប់ដើមអំពីឆ្នាំនេះទៅ ទំពាស៊ីដោយសេចក្តីស្រេកឃ្លាន
ផង ដោយចំណង់ផង នេះជាផលនៃបាបកម្មរបស់ខ្ញុំ ។ បពិត្រ
លោកម្ចាស់ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់បពិត្រ
លោកម្ចាស់អ្នកមានព្យាយាម មានអានុភាពធំ សូមលោក
អនុគ្រោះខ្ញុំ សូមលោកឲ្យទេយ្យធម៌ណានីមួយ ឧទ្ទិសដល់ខ្ញុំ

ផង បពិត្រលោកម្ចាស់ដ៏ចម្រើនសូមលោកម្ចាស់ដោះខ្ញុំឲ្យរួច
អំពីទុគ្គតិផងចុះ ។

ព្រះសារីបុត្តនោះ ជាអ្នកអនុគ្រោះ ទទួលស្ដាប់ពាក្យស្រីប្រេតនោះថា សាធុ ដូច្នេះហើយ បានប្រគេននូវពំនូតបាយ នូវសំពត់ប្រមាណប៉ុនបាតដៃផង និងទឹកដែលគួរក្រេបផឹក ១ ផ្ដិលដល់ភិក្ខុទាំងឡាយ រួចហើយឧទ្ទិសទក្ខិណាទានដល់ស្រីប្រេតនោះ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ ភោជនាហារនិងសំពត់ស្លៀកពាក់ និងទឹកដែលគួរក្រេបផឹក ក៏កើតឡើងនេះជាផលនៃទក្ខិណា លំដាប់នោះ ស្រីប្រេតនោះ ជាស្រីស្អាត ស្លៀកពាក់សំពត់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្ដមជាងសំពត់ដែលកើតក្នុងដែនកាសីមានគ្រឿងវត្ថាករណៈដ៏វិចិត្រ ចូលទៅរកព្រះសារីបុត្ត ។

( ព្រះសារីសួរថា ) ម្នាលទេវធីតា នាងមានសម្បុរល្អ ភ្លឺសព្វទិសដូចជាផ្កាយព្រឹក ។ សម្បុរបស់នាងប្រាកដដូច្នោះ ដោយហេតុអ្វី ផលនៃសេចក្ដីសុចរិត សម្រេចដល់នាងក្នុងពេលនេះ ដោយហេតុអ្វី បានជាភោគៈទាំងឡាយណានីមួយដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលទេវធីតាដ៏មានអានុភាពច្រើន យើងសូមសួរនាង នាង
កាលកើតជាមនុស្សបានធ្វើបុណ្យដូចម្ដេច នាងមានអានុភាព
ភ្លឺផ្លេក ទាំងសម្បុររបស់នាងក៏ភ្លឺសព្វទិស យ៉ាងនេះ ដោយ
បុញ្ញកម្មដូចម្ដេច ។

( ប្រេតតបថា ) ព្រះអគ្គសាវកជាអ្នកប្រាជ្ញក្នុងលោក ប្រកបដោយ

សេចក្តីករុណា បានឃើញនូវខ្ញុំជាស្រីស្គម មានសម្បុរលឿង មានសេចក្តីស្រេកឃ្លាន ជាស្រីអាក្រាត មានសម្បុរស្បែកគ្រោតគ្រាត ដល់នូវសេចក្តីទុក្ខលំបាក ហើយបានប្រគេនពំនូតបាយផង សំពត់ប្រមាណប៉ុនបាតដៃផង ទឹកគួរផឹកប្រមាណមួយផ្តិលផង ដល់ភិក្ខុទាំងឡាយហើយបានឧទ្ទិស ( នូវទក្ខិណាទានដល់ខ្ញុំ ) ។ សូមលោកឃើញផលពំនូតបាយចុះ ខ្ញុំជាស្រីបាននូវកាមតាមចំណង់ បរិភោគនូវភត្តអស់ ១ ពាន់ឆ្នាំ ប្រកបដោយម្ហូបមានរសជាអនេក សូមលោកឃើញនូវវិបាកនៃសំពត់ប្រមាណប៉ុនបាតដៃ ប្រាកដដូចម្តេច បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់សម្រាប់ស្លៀកពាក់ក្នុងដែននៃស្តេចនន្ទអម្បាលមាណ សំពត់ស្លៀកនិងសំពត់ដណ្តប់ផង សំពត់កោសេយ្យៈនិងសំពត់កម្ពលផង សំពត់ត្បាញអំពីសម្បកឈើនិងសំពត់ដែលត្បាញអំពីកប្បាសផង ដ៏ធំទូលាយ មានតម្លៃច្រើនរបស់ខ្ញុំ ច្រើនជាងសំពត់ក្នុងដែននន្ទរាជនោះ សំពត់ទាំងអស់នោះ តែងសំយុងចុះមកអំពីអាកាសសំពត់ណាដែលជាទីពេញចិត្ត ខ្ញុំក៏ស្លៀកពាក់នូវសំពត់នោះ សូមលោកឃើញនូវវិបាកនៃទឹកផឹកប្រមាណ ១ ផ្តិល ប្រាកដដូចម្តេច ។ ស្រះបោក្ខរណីដ៏ជ្រៅ មានជ្រុង ៤ ដែលបុញ្ញកម្មនិម្មិតល្អហើយ មានទឹកថ្លា មានកំពង់រាបស្មើ មានទឹកត្រជាក់ មានក្លិនក្រអូប ដេរដាសដោយផ្កាបទុមនិងឧប្បល ពេញដោយទឹកដ៏ដេរដាសដោយកេសរ ។ ខ្ញុំនោះរីករាយលេងសប្បាយ ឥតមានភ័យពីទីណាៗឡើយ បពិត្រលោកដ៏ចម្រើន ខ្ញុំមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញប្រកបដោយសេចក្តីករុណាក្នុងលោក ។

**ចប់ រឿងសំសារមោចកប្រេតទី ១ ។**

# ឧព្វរីវគ្គ ទី២

## អដ្ឋកថា សំសារមោចកប្រេត

[ ១៣ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធស្រីប្រេតម្នាក់ ក្នុងស្រុកឈ្មោះឥដ្ឋកវតី ដែនមគធ: ទើបត្រាស់ពាក្យផ្ដើមថា **នគ្គា ទុព្វណ្ណរូបាសិ** ដូច្នេះជាដើម ។

បានឮថា ក្នុងដែនមគធ: មានស្រុក ២ គឺស្រុកឥដ្ឋកវតីនិងស្រុក ទីឃរាជី ។ ក្នុងស្រុក ២ នោះ ពួកសង្សារមោចក: ដោយច្រើន ជាមនុស្សមិច្ឆាទិដ្ឋិរស់នៅប្រចាំ ក្នុងអតីតកាល ក្នុងទីបំផុត ៥០០ ឆ្នាំ មានស្រីម្នាក់កើតក្នុងត្រកូលសង្សារមោចក:មួយ ក្នុងស្រុកឥដ្ឋកវតីនោះឯង ដោយអំណាចមិច្ឆាទិដ្ឋិ សម្លាប់សត្វល្អិត មានកណ្ដូបជាដើមជាច្រើន ហើយកើតជាប្រេតនាងសោយទុក្ខ មានការស្រេកឃ្លានជាដើម អស់ ៥០០ ឆ្នាំ កាលព្រះមានព្រះភាគនៃយើងទ្រង់កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្កដ៏បវរយាងទៅអាស្រ័យនគររាជគ្រឹះ គង់នៅក្នុងវេឡុវ័ន ដោយលំដាប់ នាងត្រឡប់មកកើតក្នុងត្រកូលសង្សារមោចក:នោះឯង ក្នុងស្រុកឥដ្ឋកវតី ។ ក្នុងពេលដែលនាងមានអាយុ ៧-៨ ឆ្នាំ អាចលេងរថជាមួយពួកក្មេងស្រីដទៃៗបាន ។ ក្នុងកាលនោះ ព្រះសារីបុត្តត្ថេរ អាស្រ័យស្រុកនោះឯង នៅក្នុងអរុណវតីវិហារ ។ ថ្ងៃមួយ ព្រះសារីបុត្តមួយអន្លើដោយភិក្ខុ ១២ រូប ធ្វើដំណើរទៅតាមទ្វារស្រុកនោះ ។ ក្នុងខណៈនោះ ក្មេងស្រីជាច្រើន ចេញអំពីស្រុកទៅលេងក្បែរទ្វារ មានចិត្តជ្រះថ្លា ក៏រត់មកថ្វាយបង្គំព្រះថេរៈនិងភិក្ខុទាំងនោះដោយបញ្ចង្គប្រតិស្ឋាន តាមដែលឃើញមាតាបិតាបដិបត្តិ ឯកុមារីនោះជាធីតានៃត្រកូលមិន

មានសទ្ធា ដាច់អាចារបស់សប្បុរស ព្រោះមិនបានសន្សំកុសលអស់កាលយូរ ទើបមិនអើពើ ឈរដូចបុគ្គលមិនមានជោគ ។ ព្រះថេរៈឃើញការប្រព្រឹត្តក្នុងកាលមុនរបស់នាង ការដែលនាងមកកើតក្នុងត្រកូលសង្គ្រាមោ-ចកៈក្នុងឥឡូវនេះនិងការដែលនាងសមគួរដល់ការកើតក្នុងនរកតទៅ ដឹងថាបើទារិកានេះ ថ្វាយបង្គំអញសោត នឹងមិនកើតក្នុងនរក ឬទោះបីកើតជាប្រេត ក៏គង់បានទូវសម្បត្តិ ព្រោះអាស្រ័យអាត្មាអញដូចគ្នា ដូច្នេះ មានចិត្តត្រូវសេចក្តីករុណាដាស់តឿន ទើបពោលនឹងទារិកាទាំងនោះថា ពួកនាងថ្វាយបង្គំភិក្ខុទាំងឡាយ តែក្មេងស្រីនេះ ឈរដូចមនុស្សមិនមានជោគ ។ លំដាប់នោះ ក្មេងស្រីទាំងឡាយ ក៏នាំគ្នាចាប់ដៃអូសមកឲ្យថ្វាយបង្គំព្រះថេរៈដោយកម្លាំងបាយ ។

សម័យតមក នាងចម្រើនវ័យ មាតាបិតាលើកឲ្យដល់កុមារម្នាក់ក្នុងត្រ-កូលសង្គ្រាមោចកៈក្នុងស្រុកទីឃរាជី លុះមានគភ៌ចាស់ ក៏ស្លាប់ទៅកើតជាប្រេតអាក្រាតកាយ មានរូបរាងគួរខ្ពើម ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់មានរូបគួរខ្ពើមក្រៃលែង ត្រាច់ទៅក្នុងពេលយប់ បង្ហាញខ្លួនដល់សារីបុត្តត្ថេរហើយឈរក្នុងចំណែកម្ខាង ព្រះថេរៈឃើញស្រីប្រេតនោះ ទើបសួរដោយគាថាថា

> ម្នាលស្រីស្គម មានធ្មេញជំនីរគោម នាងជាស្រីអាក្រាត មាន
> រូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមដោយ
> សរសៃ នាងជាអ្វី មកឋិតនៅទីនេះ ដូច្នេះ ។

*ក្នុងបទទាំងនោះ បទថា* **ធមនិសន្ថតា** *បានដល់ មានខ្នងពោរពេញដោយសរសៃ ព្រោះមិនមានសាច់និងឈាម ។ បទថា* **ឧប្ផាសុលិកេ** *បានដល់ មានឆ្អឹងជំនីរផុសឡើង ។ បទថា* **កិសិកេ** *បានដល់ មានរាងកាយស្គម ។ ជាដំបូងព្រះថេរៈពោលថា* **កិសា** *ហើយត្រូតថា* **កិសិកេ** *ទៀតដើម្បីសម្តែងថា នាងជាស្រីស្គមក្រៃលែង ព្រោះជាបុគ្គលមានរាងកាយសល់ត្រឹមតែឆ្អឹង ស្បែកនិងសរសៃ ។ ស្រីប្រេតបានស្តាប់ដូច្នោះហើយ កាលនឹងប្រកាសខ្លួនទើបពោលគាថាថា*

*បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំជាស្រីប្រេតដល់នូវសេចក្តីទុក្ខ*
*ជាយមលោកសត្វ ស្លាប់អំពីមនុស្សលោកនេះហើយ បានទៅ*
*កាន់បេតលោកព្រោះធ្វើបាបកម្ម ដូច្នេះ ។*

*ព្រះថេរៈសួរដល់កម្មដែលធ្វើទុកទៀតថា*

*ចុះអំពើអាក្រក់ដែលនាងបានធ្វើដោយកាយ វាចា ចិត្ត តើ*
*ដូចម្តេច នាងទៅកាន់បេតលោកអំពីមនុស្សលោកនេះ ព្រោះ*
*វិបាកនៃកម្មដូចម្តេច ដូច្នេះ ។*

*កាលនាងសម្តែងថា ខ្ញុំមិនធ្លាប់ឲ្យទាន ជាមនុស្សកំណាញ់ទើបកើតក្នុងកំណើតប្រេត សោយទុក្ខមហន្តយ៉ាងនេះ ទើបពោលគាថា ៣ ថា*

*បពិត្រលោកដ៏ចម្រើន បិតាមាតា ឬពួកញាតិជាអ្នកអនុគ្រោះ*
*ដល់ខ្ញុំ គប្បីដឹកនាំខ្ញុំថា នាងចូរមានចិត្តជ្រះថ្លា ឲ្យទានដល់ពួក*
*សមណព្រាហ្មណ៍ ( ដូច្នេះ ) ពុំមានឡើយ ។ ខ្ញុំទើបបានជា*

ស្រីអាក្រាតមានសភាពយ៉ាងនេះ តែងត្រាច់ទៅអស់ ៥០០ ឆ្នាំ ចាប់ដើមអំពីឆ្នាំនេះទៅ ទំពាស៊ីដោយសេចក្តីស្រេកឃ្លានផងដោយចំណង់ផង នេះជាផលនៃបាបកម្មរបស់ខ្ញុំ ។ បពិត្រលោកម្ចាស់ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់បពិត្រលោកម្ចាស់ អ្នកមានព្យាយាម មានអានុភាពធំ សូមលោកអនុគ្រោះខ្ញុំ សូមលោកឲ្យទេយ្យធម៌ណានីមួយ ឧទ្ទិសដល់ខ្ញុំផង បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ដោះខ្ញុំឲ្យរួចអំពីទុគ្គតិផងចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អនុកម្បកា** បានដល់ ជាអ្នកអនុគ្រោះដោយប្រយោជន៍ដែលប្រព្រឹត្តទៅ ក្នុងភពខាងមុខ ។ ទើបនាងហៅព្រះថេរៈថា **ភន្តេ** ។ មានវាចាប្រកបសេចក្តីថា **យេ មំ និយោជេយ្យុំ** សេចក្តីថា ជនពួកណា ជាមាតាក្តី បិតាក្តី ញាតិក្តី ជាអ្នកមានចិត្តជ្រះថា□ូបេះ□តប្បីដឹកនាំខ្ញុំថា ចូរឲ្យទានដល់សមណព្រាហ្មណ៍ចុះ ជនអ្នកអនុគ្រោះបែបនោះ មិនមានដល់ខ្ញុំឡើយ ។

បទថា **ឥតោ អហំ វស្សសតានិ បញ្ច យំ ឯវរូបា វិចរាមិ នគ្គា** នេះ ស្រីប្រេតនោះរឭកដល់អត្តភាពប្រេតរបស់ខ្លួនដោយជាតិទី ៣ អំពីជាតិនេះ ទើបពោលដោយបំណងថា សូម្បីខណៈនេះ ខ្ញុំក៏ត្រាច់ទៅដល់ ៥០០ ឆ្នាំ យ៉ាងនោះ ។ ក្នុងបទទាំងនោះ បទថា **យំ** ប្រែថា ព្រោះហេតុណា ។ មានវាចាប្រកបសេចក្តីថា ខ្ញុំជាប្រេតអាក្រាតបែបនេះ ព្រោះមិនបានធ្វើនូវ

បុណ្យមានទានជាដើម តាំងអំពីនេះទៅ ក៏នឹងត្រាច់ទៅអស់ ៥០០ ឆ្នាំ ។ បទថា **តណ្ហាយ** បានដល់ សេចក្ដីត្រូវការ ។ បទថា **១ជ្ឈមានា** បានដល់ ត្រូវទំពាស៊ី អធិប្បាយថា ត្រូវបៀតបៀន ។

បទថា **វន្ទាមិ តំ អយ្យ បសន្នចិត្តា** សេចក្ដីថា បពិត្រលោកម្ចាស់ ខ្ញុំជាអ្នកមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់ ស្រីប្រេតសម្ដែងថា ឥឡូវនេះ ខ្ញុំអាចធ្វើបុណ្យបានប្រមាណប៉ុណ្ណោះឯង ។ បទថា **អនុកម្ប មំ** សេចក្ដីថា សូមលោកម្ចាស់អនុគ្រោះ គឺសូមធ្វើករុណាចំពោះខ្ញុំ ។ បទថា **ទត្វា ច មេ អាទិស យំ ហិ កិញ្ចិ** សេចក្ដីថា ចូរឲ្យនូវទេយ្យធម៌ណាមួយក៏បាន ដល់សមណព្រាហ្មណ៍ ហើយឧទ្ទិសទក្ខិណានោះដល់ខ្ញុំចុះ ។ នាងពោលដោយបំណងថា អញនឹងផុតចាកកំណើតប្រេតនេះ ដោយការឲ្យនូវទក្ខិណានោះ ។ ព្រោះហេតុនោះឯង ទើបនាងពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ដោះខ្ញុំ ឲ្យរួចអំពីទុគ្គតិផងចុះ ។

កាលស្រីប្រេតពោលអង្វរយ៉ាងនោះ ដើម្បីសម្ដែងប្រការដែលព្រះថេរៈបដិបត្តិ ព្រះសង្គីតិកាចារ្យក៏ពោលគាថា ៣ ថា

ព្រះសារីបុត្តនោះ ជាអ្នកអនុគ្រោះទទួលស្ដាប់ពាក្យស្រីប្រេត
នោះថា សាធុ ដូច្នេះហើយ បានប្រគេននូវពំនូតបាយ នូវ
សំពត់ ប្រមាណប៉ុនបាតដៃផង និងទឹកដែលគួរក្រេបផឹក ១
ផ្តិលដល់ភិក្ខុទាំងឡាយ រួចហើយឧទ្ទិសទក្ខិណាទានដល់ស្រី
ប្រេតនោះ វិបាកក៏កើតឡើង ក្នុងលំដាប់ដែលឧទ្ទិសហើយ

ភោជនាហារនិងសំពត់ស្លៀកពាក់និងទឹកដែលគួរក្រេបផឹក ក៏កើតឡើង នេះជាផលនៃទក្ខិណា លំដាប់នោះ ស្រីប្រេតនោះជាស្រីស្អាត ស្លៀកពាក់សំពត់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ចូលទៅរកព្រះសារីបុត្ត ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភិក្ខុនំ** បានដល់ ភិក្ខុមួយរូប ពិតហើយពាក្យថា **ភិក្ខុនំ** នេះ លោកពោលដោយវចនវិបល្លាស ។ អាចារ្យពួកខ្លះពោលថា **អាលោបំ ភិក្ខុនោ ទត្វា** ប្រគេនបាយមួយពំនូតដល់ភិក្ខុ ។ បទថា **អាលោបំ** បានដល់ ដុំបាយ អធិប្បាយថា ភោជនប្រមាណមួយពំនូត ។ បទថា **ចាណិមត្តញ្ច ចោឡកំ** សេចក្ដីថា កំណាត់សំពត់ ប្រមាណ ប៉ុនបាតដៃមួយផ្ទាំង ។ បទថា **ថាលកស្ស ច បានីយំ** បានដល់ ទឹកប្រមាណពេញផ្ដិលមួយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងខល្លាដិយបេតវត្ថុនោះឯង ។

លំដាប់នោះ ព្រះសារីបុត្តឃើញស្រីប្រេតនោះមានឥន្ទ្រិយផូរផង់ មានពណ៌សម្បុរស្រស់ថ្លា មានសំពត់និងអាភរណៈ គ្រឿងប្រដាប់ដែលជាទិព្វភ្លឺទៅដោយជុំវិញ ដោយរស្មីរបស់ខ្លួន ចូលទៅរក ហើយឈរ បំណងនឹងឲ្យស្រីប្រេតនោះប្រកាសផលកម្មដោយប្រចក្ស ទើបពោលគាថា ៣ ថា

ម្នាលទេវធីតា នាងមានសម្បុរល្អ ភ្លឺសព្វទិស ដូចជាផ្កាយព្រឹក ។ សម្បុររបស់នាងប្រាកដដូច្នោះដោយហេតុអ្វី ផលនៃសេចក្ដីសុចរិត សម្រេច

ដល់នាងក្នុងពេលនេះ ដោយហេតុអ្វី បានជាភោគៈទាំងឡាយណានីមួយដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលទេវធីតាដ៏មានអានុភាពច្រើន យើងសូមសួរនាង នាងកាលកើតជាមនុស្សបានធ្វើបុណ្យដូចម្ដេច នាងមានអានុភាពភ្លឺផ្លេក ទាំងសម្បុររបស់នាង ក៏ភ្លឺសព្វទិសយ៉ាងនេះ ដោយបុញ្ញកម្មដូចម្ដេច ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អភិក្កន្តេន** បានដល់ ធ្វើចិត្តឲ្យត្រេកអរក្រៃលែង អធិប្បាយថា មានរូបស្អាត ។ បទថា **វណ្ណេន** បានដល់ មានពណ៌សម្បុរ ។ បទថា **ឱភាសេន្តី ទិសា សព្វា** បានដល់ រុងរឿងទូទៅទាំង ១០ ទិស គឺធ្វើឲ្យមានពន្លឺតែមួយ កាលចៀសវាងពាក្យសួរថា ប្រៀបដូចអ្វីទើបព្រះសារីបុត្តពោលថា ដូចផ្កាយព្រឹក អធិប្បាយថា នាងបំភ្លឺទិសទាំងពួងឲ្យភ្លឺស្វាងដូចផ្កាយឈ្មោះ ឱសធី ព្រោះជាគ្រឿងទ្រទ្រង់នូវរស្មីដ៏សន្ធោសន្ធៅ ឬព្រោះបន្ថែមឲ្យកម្លាំងដល់ឱសថទាំងឡាយ ធ្វើឲ្យមានពន្លឺជុំទិស តាំងនៅដូច្នោះ ។

**កឹ** សព្ទ ក្នុងបទថា **កេន** នេះ ប្រើក្នុងពាក្យសួរ ។ បទថា **កេន** នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃហេតុ អធិប្បាយថា ព្រោះហេតុអ្វី ។ បទថា **តេ** ប្រែថា របស់នាង ។ បទថា **ឯតាទិសោ** ប្រែថា ដូច្នេះ ។ លោកពោលអធិប្បាយថា តាមដែលប្រាកដក្នុងឥឡូវនេះ ។ បទថា **កេន តេ ឥធ-មិជ្ឈតិ** សេចក្ដីថា ផលនៃសុចរិតដែលនាងបានក្នុងឥឡូវនេះ រមែងសម្រេច

*គឺឲ្យផលក្នុងទីនេះ ព្រោះបុញ្ញវិសេសដូចម្ដេច ។ បទថា* **ឧប្បជ្ជន្តិ** *ប្រែថា កើតឡើង ។ បទថា* **ភោគា** *សេចក្ដីថា ឧបករណ៍វិសេសនៃទ្រព្យជាគ្រឿងត្រេកអរ មានសំពត់និងអាភរណៈជាដើមដែលបានឈ្មោះថា ភោគៈ ព្រោះអត្ថថា ត្រូវប្រើប្រាស់ ។ ដោយបទថា* **យេ កេចិ** *នេះ ព្រះសារីបុត្តត្ថេរសង្គ្រោះយកភោគៈគ្រប់យ៉ាង មិនសេសសល់ ។ ដូចនិទ្ទេសដែលបង្រួបបង្រួមទាំងអស់ នេះឈ្មោះថា សង្គ្រហគ្រប់យ៉ាង ដូច្នេះ ជាដើម ។ បទថា* **មនសោ បិយា** *បានដល់ ភាពដែលចិត្តគប្បីស្រឡាញ់ អធិប្បាយថា ជាទីពេញចិត្ត ។*

*បទថា* **បុច្ឆាមិ** *ប្រែថា អាត្មាសុំសួរ អធិប្បាយថា អាត្មាចង់ដឹង ។ បទថា* **តំ** *បានដល់* **ត្វំ** *ប្រែថា នូវនាង ។ បទថា* **ទេវិ** *សេចក្ដីថា ឈ្មោះថា ទេពធីតា ព្រោះជាអ្នកដល់ព្រមដោយអានុភាពដែលជាទិព្វ ។ ដោយហេតុនោះព្រះសារីបុត្រក៏ពោលថា ម្នាលទេពធីតា ដ៏មានអានុភាពច្រើន ។ បទថា* **មនុស្សភូតា** *បានដល់ កើតក្នុងពួកមនុស្ស គឺបាននូវភាពជាមនុស្ស ។ ពាក្យថា* **មនុស្សភូតា** *នេះ លោកពោល ព្រោះបំណងថា ដោយច្រើនសត្វដែលតាំងនៅក្នុងអត្តភាពមនុស្សទើបធ្វើបុណ្យបាន ។ គាថាទាំងនេះមានសេចក្ដីសង្ខេបប្រមាណប៉ុណ្ណេះ ។ ឯសេចក្ដីពិស្ដារគប្បីជ្រាបតាមន័យដែលពោលក្នុងអដ្ឋកថាវិមានវត្ថុ ឈ្មោះ បរមត្ថទីបនី ឯណោះ ។*

*ស្រីប្រេត ត្រូវព្រះថេរៈសួរបន្ថែមយ៉ាងនេះ កាលប្រកាសហេតុដែលខ្លួនបានសម្បត្តិនោះទើបពោលគាថាដ៏សេសថា*

ព្រះអគ្គសាវកជាអ្នកប្រាជ្ញក្នុងលោក ប្រកបដោយសេចក្ដីករុ-
ណា បានឃើញនូវខ្ញុំជាស្រីស្គមមានសម្បុរលឿងមានសេចក្ដី
ស្រេកឃ្លាន ជាស្រីអាក្រាត មានសម្បុរស្បែកគ្រោតគ្រាត
ដល់នូវសេចក្ដីទុក្ខលំបាក ហើយបានប្រគេនពំនូតបាយផង
សំពត់ប្រមាណប៉ុនបាតដៃផងទឹកគួរផឹកប្រមាណមួយផ្តិលផង
ដល់ភិក្ខុទាំងឡាយ ហើយបានឧទ្ទិស ( នូវទក្ខិណាទានដល់
ខ្ញុំ ) ។ សូមលោកឃើញផលពំនូតបាយចុះ ខ្ញុំជាស្រីបាននូវ
កាមតាមចំណង់ បរិភោគនូវភត្តអស់ ១ ពាន់ឆ្នាំ ប្រកប
ដោយម្ហូបមានរសជាអនេក សូមលោកឃើញនូវវិបាកនៃសំ
ពត់ប្រមាណប៉ុនបាតដៃ ប្រាកដដូចម្ដេច បពិត្រលោកម្ចាស់ដ៏
ចម្រើន សំពត់សម្រាប់ស្លៀកពាក់ក្នុងដែននៃស្ដេចនន្ទអម្បាល
មាណ សំពត់ស្លៀកនិងសំពត់ដណ្ដប់ផង សំពត់កោសេយ្យៈ
និងសំពត់កម្ពលផង សំពត់ត្បាញអំពីសម្បកឈើនិងសំពត់
ដែលត្បាញអំពីកប្បាសផង ដ៏ធំទូលាយ មានតម្លៃច្រើនរបស់
ខ្ញុំ ច្រើនជាងសំពត់ក្នុងដែននន្ទរាជនោះ សំពត់ទាំងអស់នោះ
តែងសំយុងចុះមកអំពីអាកាស សំពត់ណាដែលជាទីពេញចិត្ត
ខ្ញុំក៏ស្លៀកពាក់នូវសំពត់នោះ សូមលោកឃើញនូវវិបាកនៃទឹក
ផឹកប្រមាណ ១ ផ្តិល ប្រាកដដូចម្ដេច ។ ស្រះបោក្ខរណីដ៏
ជ្រៅ មានជ្រុង ៤ ដែលបុញ្ញកម្មនិម្មិតល្អហើយ មានទឹកថ្លា

មានកំពង់រាបស្មើ មានទឹកត្រជាក់ មានក្លិនក្រអូប ដេរដាស
ដោយផ្កាបទុមនិងឧប្បល ពេញដោយទឹក ដ៏ដេរដាសដោយ
កេសរ ។ ខ្ញុំនោះរីករាយ លេងសប្បាយ ឥតមានភ័យពីទី
ណាៗឡើយ បពិត្រលោកដ៏ចម្រើនខ្ញុំមកដើម្បីថ្វាយបង្គំលោក
ជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណាក្នុងលោក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧប្បណ្ឌុកី** បានដល់ មានខ្លួនលឿង ។ បទថា **ឆាតំ** បានដល់ ជាអ្នកស្រេកឃ្លាន គឺត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ។ បទថា **សម្បតិច្ឆវី** បានដល់ មានស្បែកនៃរាងកាយបែកចេញជាចង្អូរ ។ បទថា **លោកេ** នេះ ជាបទសម្ដែងអារម្មណ៍នៃករុណាដែលពោលទុកក្នុងបទថា **ការុណិកោ** នេះ ។ បទថា **តំ មំ** បានដល់ ខ្ញុំជាបុគ្គលបែបនោះ គឺខ្ញុំតាំងនៅក្នុងឋានៈគួរករុណាដោយចំណែកមួយ តាមន័យដែលពោលហើយ ។ បទថា **ទុគ្គតំ** បានដល់ ដល់នូវទុគ្គតិ ។

បទថា **ភិក្ខុនំ អាលោបំ ទត្វា** ដូច្នេះជាដើម ជាគ្រឿងសម្ដែងអាការដែលព្រះថេរៈធ្វើសេចក្ដីករុណាដល់ខ្លួន ។ ក្នុងបទទាំងនោះ បទថា **ភត្តំ** បានដល់ បាយ អធិប្បាយថា កោជនដែលជាទិព្វ ។ បទថា **វស្សសតំ ទស** បានដល់ ១០០ ឆ្នាំ ១០ ដង អធិប្បាយថា ១០០០ ឆ្នាំ ។ ពាក្យនេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃអច្ចន្តសំយោគ ប្រែថា រហូត ។ មានវាចាប្រកបសេចក្ដីថា បទថា **ភុញ្ជាមិ កាមកាមិនី អនេករសព្យញ្ជនំ** សេចក្ដីថា ខ្ញុំប្រកបដោយវត្ថុដែលគួរត្រូវការផ្សេងៗ ទើបបរិភោគអាហារ មានម្ហូប

មានរសផ្សេងៗ ។

ដោយពាក្យថា **ចោឡស្ស** នេះ ស្រីប្រេតសម្តែងចំពោះបុណ្យដែលសម្រេចដោយទានដែលមានសំពត់នោះជាអារម្មណ៍ ដោយបំណងយកទេយ្យធម៌ជាគោល ។ បទថា **វិបាកំ បស្ស យាទិសំ** បានដល់ សូមលោកម្ចាស់មើលផល ពោលគឺវិបាកនៃការថ្វាយសំពត់ជាទាននេះចុះ ។ ដើម្បីចៀសវាងពាក្យសួរថា ផលនោះដូចម្តេច ស្រីប្រេតក៏ពោលពាក្យថា **យាវតា នន្ទរាជស្ស** ដូច្នេះជាដើម ។

ក្នុងពាក្យនោះ អ្នកណាឈ្មោះ នន្ទរាជា អង្គនេះ បានឮថា ក្នុងអតីតកាល ក្នុងពួកមនុស្សមានអាយុមួយម៉ឺនឆ្នាំ មានកុដុម្ពិកៈអ្នកក្រុងពារាណសីម្នាក់ដើរលេងក្នុងព្រៃ បានឃើញព្រះបច្ចេកពុទ្ធមួយរូបត្រង់ព្រៃនោះ ។ ព្រះបច្ចេកពុទ្ធអង្គនោះ កំពុងធ្វើចីវរក្នុងព្រៃនោះ កាលសំពត់អនុវាតមិនគ្រប់គ្រាន់ក៏បត់រក្សាទុក កុដុម្ពិកៈឃើញដូច្នោះ ទើបពោលថា លោកម្ចាស់ធ្វើអ្វី ព្រះបច្ចេកពុទ្ធមិនពោលពាក្យណាមួយ ព្រោះលោកជាអ្នកប្រាថ្នាតិច ក៏ដឹងថាចីវរមិនគ្រប់គ្រាន់ ទើបដាក់សំពត់ដណ្តប់របស់ខ្លួនក្បែរជើងរបស់ព្រះបច្ចេកពុទ្ធ ហើយចៀសចេញទៅ ព្រះបច្ចេកពុទ្ធ កាន់យកសំពត់ឧត្តរាសង្គៈនោះមកធ្វើជាអនុវាតចីវរ ។ ក្នុងកាលអស់ជីវិត កុដុម្ពិកៈនោះ ស្លាប់ទៅកើតក្នុងស្ថានតាវត្តិង្ស សោយទិព្វសម្បត្តិក្នុងស្ថានតាវត្តិង្សនោះដរាបដល់អស់អាយុ ចុតិអំពីតាវត្តិង្សនោះ ទៅកើតក្នុងត្រកូលអាមាត្យ ត្រង់ស្រុកមួយ ក្នុងទីប្រមាណមួយយោជន៍អំពីនគរពារាណសី ។

ក្នុងកាលដែលបុរសនោះចម្រើនវ័យ មានការប្រកាសនក្ខត្តឫក្សក្នុងស្រុកនោះ បុរសនោះនិយាយនឹងមាតាថា បពិត្រអ្នកម៉ែ សូមឲ្យសំពត់សាដកដល់ខ្ញុំ ខ្ញុំនឹងលេងនក្ខត្តឫក្ស ។ មាតាបាននាំយកសំពត់ដែលបោកទុកយ៉ាងស្អាតមកឲ្យ ។ បុរសនោះពោលថា សំពត់នេះសាច់គ្រោតគ្រាត មាតាក៏នាំសំពត់ដទៃមកឲ្យ គេក៏បដិសេធទៀត ។ លំដាប់នោះ មាតាក៏ពោលនឹងបុរសនោះថា នែបា ពួកយើងកើតក្នុងផ្ទះដែលមិនមានបុណ្យ នឹងបានសំពត់សាច់ម៉ដ្ឋជាងនេះមកអំពីណា បុរសនោះពោលថា ខ្ញុំនឹងទៅកាន់ទីដែលបាន ម្ដាយពោលថា ទៅចុះកូន ម៉ែប្រាថ្នាឲ្យកូនបានរាជសម្បត្តិក្នុងក្រុងពារាណសីនាថ្ងៃនេះឯង ។ បុរសនោះទទួលពរ ហើយថ្វាយបង្គំមាតា ធ្វើប្រទក្សិណហើយពោលថា ខ្ញុំលាហើយម៉ែ មាតាពោលថា ទៅចុះកូន ។ បានឮថា ម្ដាយនោះ គិតយ៉ាងនេះថា កូនអញនឹងទៅឯណា គេមុខជាអង្គុយក្នុងផ្ទះនេះឬផ្ទះនោះ ។ ឯបុរសនោះត្រូវបុព្វនិយាមដាស់តឿន ក៏ចេញអំពីស្រុក ទៅកាន់នគរពារាណសី ហើយដេកទទូរក្បាលលើផ្ទាំងថ្មដែលជាមង្គល ។ ក្នុងថ្ងៃនោះជាថ្ងៃដែលព្រះបាទពារាណសីសោយទិវង្គតមកអស់ ៧ ថ្ងៃហើយ ។

ពួកអាមាត្យនិងបុរោហិត នាំគ្នាថ្វាយព្រះភ្លើងព្រះបរមសពហើយក៏អង្គុយប្រឹក្សាគ្នាក្នុងលានព្រះរាជវាំងថា ព្រះរាជាមានព្រះរាជធីតាមួយអង្គ ព្រះរាជឱរសមិនមាន រាជសម្បត្តិមិនមានព្រះរាជាគ្រប់គ្រងរមែងតាំងនៅមិនបាន ពួកយើងនឹងផ្សងបុស្សរថ ។ ពួកអាមាត្យនិងបុរោហិត ទឹមសេះសិន្ធព ៤ ដែលមានពណ៌ដូចផ្កាកុមុទ ដាក់គ្រឿងរាជកកុធភណ្ឌ ៥ យ៉ាង មានស្វេតច្ឆត្រ

ជាប្រធានទុកក្នុងរថនោះឯង ហើយលែងរថទៅ ប្រគំតន្ត្រីតាមក្រោយ រថចេញអំពីទ្វារទិសខាងកើត បានបែរមុខទៅកាន់ព្រះរាជឧទ្យាន អាមាត្យពួកខ្លះពោលថា រថបែរមុខទៅកាន់ផ្លូវឧទ្យាន ព្រោះសេះធ្លាប់ទៅ ពួកយើងនឹងឲ្យត្រឡប់ បុរោហិតពោលជំទាស់ថា កុំឲ្យត្រឡប់ឡើយ រថធ្វើប្រទក្សិណកុមារហើយ ធ្វើអាកប្បកិរិយានឹងឡើងហើយក៏ឈប់ ។ បុរោហិត ទាញជាយសំពត់ចេញ ពិនិត្យមើលបាតជើងទាំង ២ ពោលថា ទីនេះចូរស្ទេះទុកកុមារនេះសមគួរគ្រងរាជ្យក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារដូច្នេះហើយទើបឲ្យប្រគំតន្ត្រី ៣ ដងថា ចូរប្រគំតន្ត្រី ចូរប្រគំទៀត ។

លំដាប់នោះ កុមារបើកមុខសម្លឹងមើលហើយ ពោលថា នែអ្នកទាំងឡាយ ពួកអ្នកនាំគ្នាមកដោយការងារអ្វី ។ ពួកអាមាត្យពោលថា បពិត្រសម្មតិទេព រាជសម្បត្តិធ្លាក់ដល់ទ្រង់ហើយ ។ កុមារសួរថា ព្រះរាជារបស់ពួកអ្នកទៅណា ពួកអាមាត្យពោលថា ទ្រង់សោយទិវង្គតហើយ ។ កុមារសួរថា កន្លងទៅបានប៉ុន្មានថ្ងៃហើយ ពួកអាមាត្យពោលថា ថ្ងៃនេះជាថ្ងៃទី ៧ កុមារសួរថា ព្រះរាជឱរស ព្រះរាជធីតារបស់ទ្រង់មិនមានទេឬ អាមាត្យពោលថា មានតែព្រះរាជធីតា ព្រះរាជឱរសមិនមាន ។ កុមារពោលថា បើយ៉ាងនោះ យើងនឹងគ្រងរាជសម្បត្តិ ។ ពួកអាមាត្យទាំងនោះ នាំគ្នាធ្វើមណ្ឌបសម្រាប់អភិសេកក្នុងវេលានោះឯង ហើយតាក់តែងព្រះរាជធីតាដោយគ្រឿងអលង្ការទាំងពួង នាំមកកាន់ព្រះរាជឧទ្យាន អភិសេកកុមារ ។

សម័យនោះ ពួកអាមាត្យបង្អោនសំពត់មានតម្លៃមួយសែនចូលទៅថ្វាយ

ព្រះរាជកុមារដែលអភិសេកហើយនោះ ។ ព្រះរាជាអង្គថ្មីនោះត្រាស់សួរថា នែបា នេះជាអ្វី ពួកអាមាត្យក្រាបទូលថា បពិត្រព្រះអង្គ សំពត់សម្រាប់ស្លៀក ។ ព្រះរាជាត្រាស់ថា សំពត់នេះសាច់គ្រោតគ្រាតមិនមែនឬ ពួកអាមាត្យទូលថា បពិត្រព្រះសម្មតិទេព បណ្ដាសំពត់ដែលពួកមនុស្សប្រើប្រាស់ សំពត់ដែលល្អជាងនេះមិនមាន ។ ព្រះរាជាត្រាស់សួរថា ព្រះរាជាអង្គមុនរបស់ពួកអ្នក ទ្រង់ប្រើសំពត់បែបនេះឬ ពួកអាមាត្យទូលថា ករុណាថ្លៃ□ សេស ។ ព្រះរាជាត្រាស់ថា ព្រះរាជារបស់ពួកអ្នកប្រហែល ជាមិនមានបុណ្យ ពួកអ្នកចូរនាំយកកុណ្ឌីមាសមក យើងនឹងបានសំពត់ ។ ពួកអាមាត្យក៏យកទឹកក្នុងកុណ្ឌីមាសមកថ្វាយ ។ ព្រះរាជាទ្រង់ក្រោកឡើង យកទឹកលុបព្រះភក្ត្រដោយព្រះអង្គឯង ខ្ពុរព្រះឱស្ឋ យកព្រះហស្តក្បង់ទឹក ប្រោះទៅទិសខាងកើត ពេលនោះ ដើមកប្បព្រឹក្ស ៨ ដើម ទម្លាយផែនដីផុសឡើង ទ្រង់ដាក់ទឹកក្នុងព្រះហស្តប្រោះទៅទិសខាងត្បូង ខាងលិច ខាងជើង ទាំង ៤ ទិស យ៉ាងនេះ ដោយប្រការដូច្នេះ ។ ដើមកប្បព្រឹក្ស ៨ ដើមៗ គ្រប់ទិស រួមជា ៣២ ដើមផុសឡើង ។ អាចារ្យពួកខ្លះពោលថា ដើមកប្បព្រឹកដុះឡើង ៦៤ ដើម គឺមួយទិស ១៦ ដើម ។ ព្រះរាជា ទ្រង់ស្លៀកសំពត់ទិព្វមួយផ្ទាំងដណ្ដប់មួយផ្ទាំងហើយត្រាស់ ពួកអ្នកចូរត្រាច់ប្រកាសថា ក្នុងដែនរបស់ព្រះបាទនន្ទរាជ ពួកស្រីអ្នកត្បាញរវៃមិនចាំបាច់ធ្វើទៀតឡើយ ដូច្នេះហើយ ឲ្យលើកនូវស្វេតច្ឆត្រឡើង ទ្រង់តាក់តែងគ្រឿងអលង្ការ ឡើងកាន់ដំរីដ៏ប្រសើរចូលព្រះនគរ ឡើងកាន់ប្រាសាទ ហើយសោយមហាសម្បត្តិ ។

ពេលវេលាកន្លងទៅយ៉ាងនេះ ថ្ងៃមួយ ព្រះទេវីឃើញសម្បត្តិរបស់ព្រះរាជាហើយ ព្រះនាងសម្តែងអាការនៃសេចក្តីករុណាថា ឱ ! អ្នកមានតបៈ ត្រូវព្រះស្វាមីសួរថា តើមានរឿងអ្វី ក៏ទូលថា បពិត្រព្រះសម្មតិទេព សម្បត្តិរបស់ទ្រង់ធំក្រៃលែង ទ្រង់បានធ្វើកល្យាណកម្មទុកក្នុងអតីតកាល ឥឡូវនេះទ្រង់មិនធ្វើកុសលទុកដើម្បីជាប្រយោជន៍ដល់អនាគតកាល ។ ព្រះរាជាត្រាស់ថា យើងនឹងឲ្យដល់អ្នកណា បើមិនមានអ្នកមានសីលនោះ ព្រះទេវីក្រាបទូលថា បពិត្រព្រះសម្មតិទេព ជម្ពូទ្វីបមិនសាបសូន្យចាក ព្រះអរហន្តទាំងឡាយឡើយ សូមទ្រង់រៀបចំទេយ្យទាន ខ្ញុំម្ចាស់នឹងបានព្រះអរហន្ត ។ ស្អែកឡើង ព្រះរាជាត្រាស់ឲ្យត្រៀមទានដែលគួរដល់តម្លៃច្រើន ។ ព្រះទេវីអធិដ្ឋានថា បើទិសនេះមានព្រះអរហន្តសោត សូមនិមន្តមកទទួលភិក្ខារបស់យើងខ្ញុំក្នុងទីនេះចុះ ហើយព្រះនាងថ្វាយបង្គំបែរមុខទៅទិសខាងជើង ។ កាលព្រះទេវីក្រាបចុះប៉ុណ្ណោះ ព្រះបច្ចេកពុទ្ធ ៥០០ អង្គដែលជារាជឱរសរបស់នាងបទុមវតី ដែលនៅក្នុងព្រៃហិមពាន្ត ព្រះមហាបទុមជាបងប្រុស ហៅព្រះបច្ចេកពុទ្ធជាប្អូនមកថា លោកនិទ្ទុក្ខ ស្តេចនន្ទរាជនិមន្តពួកលោក ពួកលោកចូរទទួលនិមន្តន៍របស់ព្រះអង្គចុះ ។ ព្រះបច្ចេកពុទ្ធទាំងឡាយនោះទទួលនិមន្តន៍ហើយ មកតាមអាកាសមួយរំពេច ចុះត្រង់ទ្វារទិសខាងជើង ។ ពួកមនុស្សក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះបច្ចេកពុទ្ធ ៥០០ អង្គនិមន្តមកហើយ ព្រះរាជាមួយអន្លើដោយព្រះទេវីចេញមកថ្វាយបង្គំ ទទួលបាត្រហើយនិមន្តឲ្យព្រះបច្ចេកពុទ្ធទាំងឡាយឡើងកាន់ប្រាសាទ ថ្វាយទានដល់

ព្រះបច្ចេកពុទ្ធទាំងនោះ លើប្រាសាទនោះ ក្នុងវេលាស្រេចភត្តកិច្ច ព្រះរាជាក្រាបទៀបបាទារបស់ព្រះបច្ចេកពុទ្ធដែលជាសង្ឃត្ថេរ ព្រះទេវីក្រាបទៀបបាទារបស់ព្រះបច្ចេកពុទ្ធដែលជាសង្ឃនវកៈទ្រង់ឲ្យប្តេជ្ញាថា សូមលោកម្ចាស់ទាំងឡាយកុំលំបាកដោយបច្ច័យ កុំឲ្យយើងខ្ញុំទាំងឡាយសាបសូន្យចាកបុណ្យសូមលោកម្ចាស់ទាំងឡាយ ឲ្យប្តេជ្ញាដល់យើងខ្ញុំទាំងឡាយ ដើម្បីនៅក្នុងទីនេះឯងដូច្នេះហើយ ឲ្យសាងអាស្រមក្នុងព្រះរាជឧទ្យាន ទំនុកបម្រុងព្រះបច្ចេកពុទ្ធទាំងឡាយដរាបដល់អស់អាយុ ។ កាលព្រះបច្ចេកពុទ្ធទាំងនោះបរិនិព្វានហើយ ឲ្យលេងសាធុកីឡា ធ្វើឈាបនកិច្ចដោយឈើក្រអូបជាដើម ហើយឲ្យរក្សាធាតុសាងព្រះចេតិយ កើតសេចក្តីសង្វេគថាការស្លាប់គង់មានដល់លោកអ្នកមានអានុភាពច្រើនដល់ម៉្លេះ នឹងពោលទៅថ្វីដល់មនុស្សអម្បាលពួកយើង ទើបទ្រង់អភិសេកឱរសច្បងក្នុងរាជសម្បត្តិ ឯព្រះអង្គក៏បួសជាតាបស ។ ព្រះទេវីគិតថា ព្រះរាជាបួសហើយ អញនៅធ្វើអ្វី ដូច្នេះហើយ ព្រះនាងក៏បួស ។ ជនទាំង ២ ក៏បួសក្នុងព្រះរាជឧទ្យាន ធ្វើឈានឲ្យកើតហើយ នៅដោយសុខក្នុងឈាន ក្នុងកាលអស់អាយុ កើតក្នុងព្រហ្មលោក ។ បានឮថា ព្រះបាទនន្ទរាជនោះ ជាមហាកស្សបត្ថេរ ជាព្រះថេរៈចាស់ទុំនៃព្រះសាស្តារបស់យើងទាំងឡាយ ។ អគ្គមហេសីរបស់ព្រះបាទនន្ទរាជ បានមកជាភិក្ខុនីឈ្មោះកបិលានី ។

ព្រះបាទនន្ទរាជនេះ ស្លៀកសំពត់ទិព្វអស់មួយម៉ឺនឆ្នាំ ទ្រង់ធ្វើដែនរបស់ព្រះអង្គឲ្យដូចឧត្តរកុរុទ្វីប បានឲ្យសំពត់ទិព្វដល់ពួកមនុស្សដែលមកដល់ ។

ស្រីប្រេតសំដៅយកការសម្រេចសំពត់ទិព្វនោះ និងការសម្រេចនៃសំពត់ទាំងពួងទើបពោលថា **យាវតា នន្ទរាជស្ស វិជិតស្មឹ បដិច្ឆនា** ប្រែថា សំពត់សម្រាប់ស្លៀកពាក់ក្នុងដែននៃស្តេចនន្ទៈអម្បាលមាណ ។ ក្នុងបទទាំងនោះបទថា **វិជិតស្មឹ** ប្រែថា ក្នុងដែន ។ បទថា **បដិច្ឆនា** បានដល់ សំពត់ទាំងឡាយ ។ ពិតហើយ សំពត់ទាំងនោះ លោកហៅថា **បដិច្ឆនា** ព្រោះជាគ្រឿងបិទបាំង ។

ឥឡូវនេះ ស្រីប្រេតនោះ កាលសម្តែងថា ឥឡូវនេះ ការសម្រេចនៃអាត្មាអញបរិបូណ៌ជាងការសម្រេចរបស់ព្រះបាទនន្ទរាជ ទើបពោលពាក្យជាដើមថា **តតោ ពហុតរា ភន្តេ វត្ថានច្ឆាទនានិ មេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តតោ** សេចក្តីថា សំពត់ជាគ្រឿងបិទបាំងរបស់ខ្ញុំ គង់ច្រើនជាងសំពត់ដែលមានក្នុងការគ្រប់គ្រងរបស់ព្រះបាទនន្ទរាជ ។ បទថា **វត្ថានច្ឆាទនានិ** បានដល់ សំពត់សម្រាប់ស្លៀកនិងសំពត់សម្រាប់ដណ្តប់ ។ បទថា **កោសេយ្យកម្ពលីយានិ** បានដល់ សំពត់សូត្រនិងសំពត់កម្ពល ។ បទថា **ខោមកប្បាសិកានិ** បានដល់ សំពត់សម្បកឈើនិងសំពត់ដែលសម្រេចដោយកប្បាស ។

បទថា **វិបុលា** បានដល់ ធំទាំងចំណែកបណ្តោយនិងចំណែកទទឹង ។ បទថា **មហគ្ឃា** បានដល់ ច្រើនដោយមានតម្លៃច្រើន គឺគួរដល់តម្លៃច្រើន ។ បទថា **អាកាសេវលម្ពរេ** បានដល់ សំយុងលើអាកាសនោះឯង ។ បទថា **យំ យំ ហិ មនសោ បិយំ** មានវាចាប្រកបសេចក្តីថា ខ្ញុំកាន់យកសំពត់

ដែលខ្ញុំពេញចិត្ត ហើយស្លៀកដណ្តប់ ។

បទថា **ថាលកស្ស ច ចានីយំ ទិធាកំ បស្ស យាធិសំ** បានដល់ ទឹកផឹកពេញផ្តិលដែលលោកឲ្យ ដែលខ្ញុំអនុមោទនា ។ ស្រីប្រេតកាលសម្តែងថា សូមលោកម្ចាស់មើលវិបាករបស់ទឹកផឹកនោះ យ៉ាងណា គឺមានច្រើនដរាបណា ទើបពោលពាក្យជាដើមថា **គម្ភីរា ចតុរស្សា ច** ។ ក្នុងបទទាំងនោះ បទថា **គម្ភីរា** បានដល់ ស្ទង់មិនដល់ ។ បទថា **ចតុរស្សា** ប្រែថា មានរាង ៤ ជ្រុង ។ បទថា **ចោក្ខរញ្ញោ** បានដល់ ស្រះបោក្ខរណី ។ បទថា **សុនិម្មិតា** បានដល់ និម្មិតដោយល្អ ដោយអានុភាពកម្មនោះឯង ។

បទថា **សេតោទកា** បានដល់ មានទឹកថ្លាជេរជាសដោយខ្សាច់ពណ៌ស ។ បទថា **សុប្បតិត្ថា** បានដល់ មានកំពង់ល្អ ។ បទថា **សីតា** បានដល់ មានទឹកត្រជាក់ ។ បទថា **អប្បដិគន្ធិយា** បានដល់ មានក្លិនក្រអូបឈ្ងុយឈ្ងប់ វៀរចាកក្លិនដែលជាបដិកូល ។ បទថា **វារិកិញ្ជក្ខបូរិតា** សេចក្តីថាពេញទៅដោយទឹកដែលជេរជាសដោយកេសរឈូកនិងព្រលិតជាដើម ។

បទថា **សាហំ** កាត់បទជា **សា អហំ** ប្រែថា ខ្ញុំនោះ ។ បទថា **រមាមិ** ប្រែថា ជួបនូវការត្រេកអរ ។ បទថា **កីឡាមិ** បានដល់ បម្រើឥន្ទ្រិយ ។ បទថា **មោទាមិ** បានដល់ ជាអ្នកត្រេកអរដោយភោគសម្បត្តិ ។ បទថា **អកុតោភយា** សេចក្តីថា មិនមានភ័យអំពីទីណាឡើយ គឺខ្ញុំជាអ្នកមានសិរីនៅជាសុខ ។ បទថា **ភន្តេ វន្ទិតុមាគតា** សេចក្តីថា បពិត្រលោកម្ចាស់ ខ្ញុំមក គឺចូលមករកដើម្បីថ្វាយបង្គំលោកម្ចាស់ ដែលជាហេតុឲ្យបាននូវទិព្វ

សម្បត្តិនេះ ។ ក្នុងទីនេះ ពាក្យណាដែលខ្ញុំមិនបានចែកដោយអត្ថ ពាក្យនោះខ្ញុំបានពោលហើយក្នុងទីនោះៗឯង ។

កាលស្រីប្រេតពោលយ៉ាងនោះ ព្រះសារីបុត្តសម្តែងសេចក្តីនោះដោយពិស្តារក្នុងកាលពួកអ្នកស្រុកទាំង ២ គឺស្រុកឥដ្ឋកវតីនិងស្រុកទីឃរាជីដែលមកកាន់សម្នាក់របស់ខ្លួន ឲ្យពួកជនទាំងនោះសង្វេគ ឲ្យផុតចាកសង្សារនិងកម្មអាក្រក់ ឲ្យតាំងនៅក្នុងភាវៈជាឧបាសក ។ រឿងនោះប្រាកដហើយក្នុងពួកភិក្ខុ ។ ភិក្ខុទាំងឡាយទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយទេសនានោះមានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

## អដ្ឋកថា សំសារមោចកប្រេតចប់

# រឿង ប្រេតជាមាតានៃព្រះសារីបុត្ត ទី២

[ ១៤ ] ( ព្រះសារីបុត្តសួរថា ) ម្នាលស្រីស្គម មានផ្អឹងជំនីរគោម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមទៅដោយសរសៃ នាងជាអ្វីមកឈរនៅទីនេះ ។

( នាងប្រេតតបថា ) អំពីមុន ខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្ដីស្រេកឃ្លាន បរិភោគទឹកមាត់ដែលគេស្ដោះចោល ទឹកសម្បោរ ស្លេស្ម ខ្ទាញ់រាវ ( នៃសាកសព ) ដែលគេដុតនិងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន និងឈាមនៃដំបៅនឹងច្រមុះនឹងក្បាលដាច់ មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគនូវខ្ទុះនិងឈាមដែលជាប់នឹងសរីរៈនៃស្រីនិងបុរស នូវខ្ទុះនិងឈាមនៃបសុសត្វនិងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំនៅ ដេកតែលើទីស្មសានដូចគ្រែ លោកម្ចាស់ជាបុត្ត សូមលោកម្ចាស់ឲ្យទានដើម្បីខ្ញុំ លុះឲ្យហើយ ចូរឧទ្ទិសផលដល់ខ្ញុំ គិតធ្វើដូចម្ដេចហ្ន៎ ឲ្យខ្ញុំគប្បីបានរួចអំពីការបរិភោគនូវខ្ទុះនិងឈាម ។

ព្រះអគ្គសាវក មាននាមថា ឧបតិស្សៈ លុះបានស្ដាប់ពាក្យនៃនាងប្រេតជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិន ១ ឲ្យធ្វើនូវកុដិទាំងឡាយ ៤ ខ្នង ហើយវេរកុដិផងឲ្យបាយនិងទឹកផង ចំពោះសង្ឃដែលមកអំពីទិសទាំង ៤ ហើយឧទ្ទិសទក្ខិណាទានដល់មាតា ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយភោជនាហារគឺទឹកផឹកនិងសំពត់ ( ក៏កើតឡើង ) នេះជាផលនៃទក្ខិណាទាន លំដាប់នោះ

( ស្រីនោះ ) ស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្របានចូលទៅរកព្រះកោលិតៈ ។

( ព្រះកោលិតៈសួរថា ) ម្នាលនាងទេវធីតា នាងមានសម្បុរល្អ មកឈរនៅ ( ទីនេះ ) ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយដូចជាផ្កាយព្រឹក ឯសម្បុរប្រាកដដូច្នោះកើតឡើងដល់នាងដោយហេតុដូចម្តេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេចបានជាភោគៈណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង
នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច នាងជាទេវ
ធីតាមានអានុភាពភ្លឺផ្ទេកយ៉ាងនេះ ទាំងសម្បុរនាង ក៏ភ្លឺសព្វ
ទិស ដោយបុញ្ញកម្មដូចម្តេច ។

( ប្រេតតបថា ) អំពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ក្នុងជាតិទាំង-ឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លាន បរិភោគតែទឹកមាត់ដែលគេស្តោះចោល ទឹកសម្បោរ ស្លេស្មទិងខ្ទាញ់រាវ ( នៃសាកសព ) ដែលគេដុតនិងឈាមនៃស្រីទាំងឡាយដែលសម្រាលកូននិងឈាមនៃដំបៅនឹងច្រមុះនឹងក្បាលដាច់ ខ្ញុំមានសេចក្តីស្រេកឃ្លានគ្របសង្កត់ បរិភោគនូវខ្ទុះនិងឈាមដែលជាប់នឹងសរីរៈនៃស្ត្រីនិងបុរស នូវខ្ទុះនិងឈាមនៃបសុសត្វនិងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីពំនាក់អា

ស្រ័យ ដេកតែលើទីស្មសានដូចគ្រែ ។ ខ្ញុំត្រេកអរដោយទាននៃព្រះសារីបុត្ត ទើបមិនមានភ័យក្នុងទីណាៗ បពិត្រលោកដ៏ចម្រើន ខ្ញុំមកដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញប្រកបដោយសេចក្តីករុណាក្នុងលោក ។

ចប់ រឿងប្រេតជាមាតានៃព្រះសារីបុត្តទី ២ ។

# អដ្ឋកថា សារីបុត្តត្ថេរមាតុប្រេត

[ ១៤ ] ព្រះសាស្តាកាលគង់នៅក្នុងវេឡុវនវិហារ ទ្រង់ប្រារព្ធប្រេតមាតាព្រះសារីបុត្តត្ថេរ ក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **នគ្គា ទុព្ពណ្ណរូបាសិ** ដូច្នេះជាដើម ។

ថ្ងៃមួយ ព្រះសារីបុត្ត ព្រះមហាមោគ្គល្លាន ព្រះអនុរុទ្ធនិងព្រះកប្បិនបាន នៅក្នុងជង្រៃមួយកន្លែងជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ក្នុងក្រុងពារាណសី មានព្រាហ្មណ៍ម្នាក់ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ដូចជាអណ្តូងទឹកជាទីផឹករបស់សមណព្រាហ្មណ៍ មនុស្សកំព្រា អ្នកដំណើរ វនិព្វកៈ យាចក បានឲ្យរបស់ មានបាយ ទឹក សំពត់និងទីដេក ជាដើម កាលឲ្យ រមែងបដិបត្តិតាមការពេញចិត្តគ្រប់យ៉ាង តាមលំដាប់នៃការឲ្យមាន ទឹកលាងជើងនិងសំពត់ជូតជើងជាដើម តាមកាល និងតាមសមគួរដល់អ្នក មកដល់ក្នុងពេលមុនអាហារបានអង្គាសភិក្ខុទាំងឡាយដោយបាយ និងទឹកជា ដើមដោយគោរព ។ កាលទៅទឹកដីដទៃ ក៏ផ្តាំផ្ញើនឹងភរិយាថា នៃនាងដ៏

ចម្រើន នាងកុំធ្វើទានវត្តនេះឲ្យវិនាស ចូរប្រឹងប្រែងរក្សាដោយគោរព ។ ភរិយាទទួលថា សាធុ លុះប្តីចៀសចេញទៅប៉ុណ្ណោះ ក៏កាត់ផ្តាច់ទំនៀមដែលបញ្ញត្តទុកដើម្បីភិក្ខុទាំងឡាយជាដំបូង លុះអ្នកដំណើរ ចូលទៅដើម្បីនៅអាស្រ័យ ក៏ប្រាប់សាលាចាស់ដែលបោះបង់ចោលដោយពាក្យថា ពួកលោកចូរនៅក្នុងសាលានេះ កាលអ្នកដំណើរមកក្នុងទីនោះដើម្បីបាយនិងទឹក ជាដើមនាងក៏ពោលប្រារព្ធឈ្មោះវត្តមិនស្អាត គួរខ្ពើមថា ចូរបរិភោគលាមក ផឹកទឹកនោម ផឹកឈាម ស៊ីខួរក្បាលរបស់ម្តាយពួកឯងចុះ ហើយស្តោះទឹកមាត់ ។

សម័យតមក នាងធ្វើកាលកិរិយាហើយ ដែលអានុភាពនៃកម្មបន្សាត់ទៅ កើតក្នុងកំណើតប្រេត សោយទុក្ខសមគួរដល់វិបាកទុច្ចរិតរបស់ខ្លួន រឭកដល់សម្ពន្ធភាពគ្នាក្នុងជាតិមុន មានបំណងមកកាន់សម្នាក់របស់ព្រះសារីបុត្តទើបមកដល់ទ្វារវិហារ ។ ទេវតាដែលស្ថិតនៅត្រង់ទ្វារវិហារ របស់ព្រះសារីបុត្តនោះ ក៏មិនឲ្យចូល ។ បានឮថា ស្រីប្រេតនោះធ្លាប់ជាមាតារបស់ព្រះថេរៈក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ។ ព្រោះហេតុនោះទើបពោលយ៉ាងនេះថា ខ្ញុំជាមាតារបស់ លោកម្ចាស់សារីបុត្តត្រេក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ សូមលោកឲ្យខ្ញុំចូលដើម្បីជួបព្រះថេរៈ ។ ទេវតាបានស្តាប់ដូច្នោះក៏អនុញ្ញាត ។ កាលចូលទៅហើយ បានឈរនៅក្នុងទីបំផុតនៃទីចង្ក្រម បង្ហាញខ្លួនដល់ព្រះថេរៈ ព្រះថេរលុះបានឃើញស្រីប្រេតនោះ ជាអ្នកមានចិត្តដែលសេចក្តីករុណាជាស់តឿនទើបសួរដោយគាថាថា

ម្នាលស្រីស្គម មានធ្មឹងជំនីរគោម នាងជាស្រីអាក្រាតមានរូប

មានសម្បុរអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាម
ទៅដោយសរសៃ នាងជាអ្វីមកឈរនៅទីនេះ ដូច្នេះ ។

ស្រីប្រេតនោះ ត្រូវព្រះថេរៈសួរ កាលនឹងឲ្យចម្លើយ ទើបពោល ៥ គាថាថា

អំពីមុន ខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃ
មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្ដីស្រេក
ឃ្លានបរិភោគទឹកមាត់ដែលគេស្ដោះចោល ទឹកសម្បោរស្ទេស្ទ
ខ្ទាញ់រាវ ( នៃសាកសព ) ដែលគេដុតនិងឈាមនៃស្រីទាំង
ឡាយដែលសម្រាលកូន និងឈាមនៃដំបៅនឹងច្រមុះនឹងក្បាល
ដាច់ មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគនូវខ្ទុះនិង
ឈាមដែលជាប់នឹងសរីរៈនៃស្រីនិងបុរស នូវខ្ទុះនិងឈាមនៃ
បសុសត្វនិងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំ
នៅ ដេកតែលើទីស្មសានដូចគ្រែ លោកម្ចាស់ជាបុត្ត សូម
លោកម្ចាស់ឲ្យទានដើម្បីខ្ញុំ លុះឲ្យហើយចូរឧទ្ទិសផលដល់ខ្ញុំ
គិតធ្វើដូចម្ដេចហ្ន៎ ឲ្យខ្ញុំគប្បីបានរួចអំពីការបរិភោគ នូវខ្ទុះនិង
ឈាម ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អហំ តេ សកិយា មាតា** សេចក្ដីថា ខ្ញុំឯងជាមាតារបស់លោកដោយកំណើត ។ ដោយពាក្យថា **បុព្វេ អញ្ញាសុ ជាតីសុ** នេះ គប្បីឃើញថា ខ្ញុំមិនមែនជាមាតាតែក្នុងជាតិនេះ ដោយពិតក្នុងជាតិ

មុន គឺក្នុងជាតិដទៃ ខ្ញុំក៏បានជាមាតាក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ។ បទថា **ឧបបន្នា បេត្តិវិសយំ** សេចក្តីថា ចូលដល់បេតលោកដោយបដិសន្ធិ ។ បទថា **ខុប្បិបាសា សមប្បិតា** បានដល់ ត្រូវសេចក្តីឃ្លាននិងសេចក្តីស្រេក គ្របសង្កត់ អធិប្បាយថា ត្រូវសេចក្តីឃ្លាននិងសេចក្តីស្រេក គ្របសង្កត់មិនដាច់ ។

បទថា **ឆឌ្ឌិតំ** បានដល់ ជាសំណល់ អធិប្បាយថា ដែលគេខ្ជាក់ហើយ ។ បទថា **ខិបិតំ** បានដល់ មន្ទិលដែលចេញអំពីមាត់មួយអន្លើដោយទឹកមាត់ដែលគេស្តោះចោល ។ បទថា **ខេឡំ** បានដល់ ស្តោះទឹកមាត់ ។ បទថា **សិង្ឃាណិកំ** បានដល់ មន្ទិលដែលហូរចេញអំពីខួរក្បាល ហើយហូរចេញតាមច្រមុះ ។ បទថា **សិលេសុមំ** បានដល់ ស្លេស្ម ។ បទថា **វសញ្ច ឌយ្ហមានានំ** បានដល់ ខ្លាញ់រាវនៃសាកសពដែលគេដុតលើជើងថ្ករ។ បទថា **វិជាតានញ្ច លោហិតំ** បានដល់ ឈាមរបស់ស្រីសម្រាលកូន មន្ទិលគភ៌ លោកសង្គ្រោះចូលដោយ ច សព្ទ ។ បទថា **វណិកានំ** បានដល់ ដំបៅដែលកើតឡើង ។ បទថា **យំ** ភ្ជាប់នឹងបទថា **យំ លោហិតំ** ។ បទថា **ឃានសីសច្ឆិន្នានំ** បានដល់ លោហិតណារបស់បុគ្គលដែលកាត់ច្រមុះនិងត្រូវកាត់ក្បាល ។ មានវាចាប្រកបសេចក្តីថា ខ្ញុំបរិភោគនូវលោហិតនោះ ។ បទថា **ឃានសីសច្ឆិន្នានំ** នេះ ជាមាតិកានៃទេសនា ដោយបទថា **ឃាន-សីសច្ឆិន្នានំ** នេះ គប្បីឃើញថា ព្រោះហេតុដែល លោហិតរបស់បុគ្គលដែលត្រូវកាត់ដៃនិងជើងជាដើមក៏ប្រេតនោះបរិភោគដូចគ្នា ម្យ៉ាងទៀតដោយ

បទថា **វណភិក្កានំ** នេះ គប្បីឃើញថា លោក សង្គ្រោះយកលោហិតរបស់បុគ្គលដែលត្រូវកាត់ដៃនិងជើងជាដើមនោះផងដែរ ។ បទថា **ខុធាបរេតា** បានដល់ ជាអ្នកត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ។ ដោយបទថា **ឥត្ថី-បុរិសធិស្សិតំ** នេះ ប្រេតសម្ដែងថា ខ្ញុំនឹងស៊ីស្បែក សាច់ សរសៃ និងខ្ទុះជាដើម ដែលអាស្រ័យរាងកាយរបស់ស្ត្រី និងបុរសជទៃតាមដែលពោលហើយ ។

បទថា **បសូនំ** បានដល់ នៃពពែ គោនិងក្របីជាដើម ។ បទថា **អ-លេណា** ប្រែថា មិនមានទីពឹង ។ បទថា **អនគារា** ប្រែថា មិនមានលំនៅ ។ បទថា **នីលមញ្ចបរាយនា** បានដល់ ដេកលើគ្រែដែលស្មោកគ្រោកដែលគេចោលក្នុងព្រៃស្មសាន ។ម្យ៉ាងទៀត ផែនដីត្រង់ព្រៃស្មសាន ច្រើនទៅដោយផេះនិងរងើកភ្លើង លោកបំណងយកថា **នីល** អធិប្បាយថា ដេកសង្កត់លើផែនដីត្រង់ព្រៃខ្មោចនោះឯង ដូចដេកលើគ្រែ ។ បទថា **អទ្ធា-ទិសាហិ មេ** សេចក្ដីថា សូមលោកម្ចាស់ឧទ្ទិសបត្តិទានដោយប្រការដែលចំណែកបុណ្យដែលឲ្យហើយសម្រេចដល់ខ្ញុំបាន ។ បទថា **អប្បេវ នាម មុញ្ចេយ្យាំ បុព្វលោហិតភោជនា** សេចក្ដីថា ធ្វើម្ដេចហ្ន៎ ខ្ញុំផុតពីជីវិតជាប្រេតដែលមានខ្ទុះនិងឈាមជាអាហារនោះ ព្រោះការឧទ្ទិសរបស់លោកម្ចាស់ ។

ព្រះសារីបុត្តត្ថេរបានស្ដាប់ដូច្នោះហើយ ក្នុងថ្ងៃទី ២ ក៏ហៅព្រះថេរៈ ៣ រូប មានព្រះមហាមោគ្គល្លានត្ថេរជាដើមមកមួយអន្លើដោយព្រះថេរៈទាំងនោះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បានទៅដល់ព្រះរាជនិវេសន៍របស់ព្រះបាទ

ពិម្ពិសារ ព្រះរាជាឃើញព្រះថេរៈហើយ ទើបសួរដល់ហេតុនៃការមកថា បពិត្រលោកម្ចាស់ លោកម្ចាស់មកធ្វើអ្វី ព្រះមហាមោគ្គល្លានក៏ទូលរឿងនោះដល់ព្រះរាជា ព្រះរាជាត្រាស់ថា ញោមដឹងហើយ ទើបលាព្រះថេរៈ ត្រាស់ឲ្យហៅអាមាត្យអ្នកសម្រេចរាជការ ទ្រង់បញ្ជាថា ចូរអ្នកសាងកុដិ ៤ ខ្នង ក្នុងទីដែលសម្បូរដោយម្លប់និងទឹកដ៏វិចិត្រ មិនឆ្ងាយអំពីនគរ និងខាងក្នុងរាជវាំង ឲ្យចែកមនុស្សជា ៣ ពួក ដោយជ្រើសរើសមនុស្សដែលមានជំនាញគ្រប់គ្រាន់ ហើយឲ្យទទួលខុសត្រូវក្នុងការធ្វើកុដិ ៤ ខ្នង ។ ឯខ្លួនព្រះអង្គក៏បានយាងទៅកាន់ទីនោះ ទ្រង់បានធ្វើព្រះរាជករណីយកិច្ចដែលគួរធ្វើ ។ កាលកុដិសម្រេចហើយ ទើបឲ្យត្រៀមពលីកម្មទាំងអស់ចូលទៅតម្កល់ បាយ ទឹក និងសំពត់ជាដើម មួយអន្លើដោយគ្រឿងបរិក្ខារគ្រប់យ៉ាង ដែលសមគួរដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ហើយថ្វាយវត្ថុទាំងអស់នោះដល់ព្រះសារីបុត្តត្ថេរ ។ គ្រានោះ ព្រះថេរៈបានថ្វាយវត្ថុទាំងអស់នោះដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធានឧទ្ទិសដល់ស្រីប្រេតនោះ ។ ស្រីប្រេតនោះ បានអនុមោទនាចំណែកបុណ្យនោះហើយ កើតក្នុងទេវលោក ជាអ្នកដល់ព្រមដោយវត្ថុដែលគួរប្រាថ្នាសព្វយ៉ាង ។ ក្នុងថ្ងៃបន្ទាប់មកក៏បានចូលទៅរកព្រះមហាមោគ្គល្លានត្ថេរថ្វាយបង្គំហើយឈរ ។ ព្រះថេរៈសាកសួរស្រីប្រេតនោះ ស្រីប្រេតនោះ បានប្រាប់ហេតុដែលខ្លួនចូលដល់ភាពជាប្រេត និងចូលដល់ភាពជាទេវតាទៀតដោយពិស្ដារ ព្រោះហេតុនោះទើបលោកពោលថា

ព្រះអគ្គសាវក មាននាមថា ឧបតិស្សៈ លុះបានស្តាប់ពាក្យនៃនាងប្រេតជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិន ១ ឲ្យធ្វើនូវកុដិទាំងឡាយ ៤ ខ្នង ហើយវេរកុដិផង ឲ្យបាយនិងទឹកផង ចំពោះសង្ឃដែលមកអំពីទិសទាំង ៤ ហើយឧទ្ទិសទក្ខិណាទានដល់មាតា ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ ភោជនាហារ គឺទឹកផឹក និងសំពត់ ( ក៏កើតឡើង ) នេះជាផលនៃទក្ខិណាទាន លំដាប់នោះ ( ស្រីនោះ ) ស្អាតមានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្របានចូលទៅរកព្រះកោលិតៈ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សង្ឃេ ចាតុទ្ទិសេ អទា** សេចក្តីថា បានប្រគេន គឺបានវេរប្រគេនដល់សង្ឃដែលមកអំពីទិសទាំង ៤ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ លំដាប់នោះ ព្រះមហាមោគ្គល្លានសួរស្រីប្រេតនោះថា

ម្នាលនាងទេវធីតា នាងមានសម្បុរល្អ មកឈរនៅ ( ទីនេះ ) ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក ឯសម្បុរប្រាកដដូច្នោះ កើតឡើងដល់នាង ដោយហេតុដូចម្តេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេច បានជាភោគៈណា

នីមួយដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច នាងជាទេវធីតាមានអានុភាពភ្លឺផ្លេកយ៉ាងនេះ ទាំងសម្បុរនាង ក៏ភ្លឺសព្វទិស ដោយបុញ្ញកម្មដូចម្តេច ដូច្នេះ ។

លំដាប់នោះ ស្រីប្រេតក៏ឆ្លើយដោយន័យថា ពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ដូច្នេះជាដើម ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

គ្រានោះ ព្រះមហាមោគ្គល្លានត្ថេរ បានក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ ទេសនានោះមានប្រយោជន៍ដល់មហាជន ដូច្នេះ ។

## អដ្ឋកថា សារីបុត្តត្ថេរមាតុប្រេតចប់

# រឿង នាងមត្តាប្រេត ទី ៣

[ ១៥ ] ( នាងតិស្សាសួរថា ) ម្នាលស្រីស្គម មានផ្អឹងជំនីរគោម នាងជាស្រីមានកាយអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមដោយសរសៃ នាងជាអ្វី បានជាមកឈរនៅក្នុងទីនេះ ។

( នាងមត្តាប្រេតប្រាប់ថា ) កាលពីមុន នាងឯងឈ្មោះតិស្សា ខ្ញុំឈ្មោះមត្តា ជាស្រីរួមប្តីរបស់នាង បានធ្វើអំពើបាប ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត នោះតើដូចម្តេច នាងឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះវិបាកនៃកម្ម ដូចម្តេច ។

ខ្ញុំជាស្រីកាច ( ឆ្នាស ) បានពោលផ្ទុសវាទ ជាស្រីឫស្យា កំណាញ់អួតអាង ខ្ញុំនោះបានពោលពាក្យអាក្រក់ ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

ពិតមែនហើយ យើងបានដឹងថា នាងជាស្រីឆ្នាស យើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងមានខ្លួនប្រាណប្រឡាក់ដោយអាចម៍ដី ព្រោះកម្មដូចម្តេច ។

នាងបានលុបលាងក្បាលរួចហើយ មានសំពត់ដ៏ស្អាតប្រដាប់ហើយ ខ្លួនយើងសោត ក៏ប្រដាប់តាក់តែងដោយគ្រឿងអលង្ការ ដ៏ក្រៃលែងជាងនាង កាលខ្ញុំនោះកំពុងសំឡឹងមើល នាងក៏ពោលចរចានឹងស្វាមី ក្នុងលំដាប់នោះខ្ញុំមានសេចក្តីឫស្យាពេកណាស់ ខ្ញុំមានសេចក្តីក្រោធកើតឡើង តអំពីនោះ

ខ្ញុំក៏ប្រវ៉ាយកអាចម៍ដី ទៅរោយដាក់នាងដោយអាចម៍ដី ព្រោះហេតុនោះ ខ្ញុំទើបមានខ្លួនប្រឡាក់ដោយអាចម៍ដី ព្រោះវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងដឹងថា នាងបានរោយអាចម៍ដីដាក់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងត្រូវរោគកមរមាស់បៀតបៀនដោយកម្មអ្វី ។

យើងទាំងពីរនាក់ បានចូលទៅកាន់ព្រៃដើម្បីរកថ្នាំ ចំណែកនាងបានយកថ្នាំមក ឯខ្ញុំបាននាំយកខ្ញែមកវិញ កាលបើនាងមិនដឹង ខ្ញុំក៏រោយខ្ញែលើដំណេករបស់នាង ព្រោះហេតុនោះ រាងកាយរបស់ខ្ញុំទើបត្រូវរោគកមរមាស់បៀតបៀន ព្រោះវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងបានដឹងថា នាងបានរោយ ( ខ្ញែ ) លើដំណេករបស់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងមានកាយអាក្រាតដោយកម្មអ្វី ។

មានការប្រជុំមិត្តសំឡាញ់ និងជួបជុំពួកញាតិ គេបានហៅនាងព្រមទាំងស្វាមី តែខ្ញុំគេមិនហៅ កាលបើនាងមិនបានដឹង ខ្ញុំក៏លួចយកសំពត់នាងទៅលាក់ ហេតុនោះ ខ្ញុំទើបមានរាងកាយអាក្រាត ព្រោះវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងដឹងថា នាងបានលួចសំពត់របស់យើងទៅលាក់ យើងសួរនាងអំពីហេតុដទៃទៀត ចុះរាងកាយរបស់នាងមានក្លិនស្អុយដូចក្លិនលាមក ព្រោះកម្មអ្វី ។

ខ្ញុំបានលួចយកនូវគ្រឿងក្រអូប ផ្កាកម្រងនិងគ្រឿងលាបដ៏មានតម្លៃរបស់

នាងទៅចោលក្នុងរណ្ដៅលាមក ខ្ញុំបានធ្វើអំពើអាក្រក់នោះ ហេតុនោះ បានជាខ្ញុំមានក្លិនស្អុយដូចក្លិនលាមក ព្រោះហេតុវិបាកនៃកម្មនោះឯង ។

ពិតមែនហើយ យើងបានដឹងហើយថា នាងបានធ្វើអំពើអាក្រក់នោះ យើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងជាស្រីទុគ៌ត ព្រោះវិបាកនៃកម្មអ្វី ។

កាលយើងទាំងពីរនាក់ មានទ្រព្យសម្បត្តិក្នុងផ្ទះស្មើគ្នា កាលទេយ្យធម៌មាន ខ្ញុំក៏មិនបានធ្វើទីពឹងដើម្បីខ្លួន ព្រោះហេតុនោះ បានជាខ្ញុំជាស្រីទុគ៌តដោយវិបាកនៃកម្មនោះឯង ។

នាងឯងបានស្ដីឲ្យខ្ញុំថា នាងកុំសេពអំពើអាក្រក់ ដ្បិតថាសុគតិមិនមែនបានដោយងាយ ព្រោះបាបកម្មឡើយ ។ នាងបានកំហែងយើងដោយផ្លូវខុស ទាំងបានឫស្យាយើង នាងចូរមើលចុះ វិបាកនៃអំពើអាក្រក់ប្រាកដយ៉ាងណា ( អំពីមុន ) ខ្ញុំស្រីទាំងឡាយក្នុងផ្ទះនោះនិងគ្រឿងប្រដាប់ប្រដានោះឯងជារបស់ខ្ញុំក៏មាន ( ឥឡូវនេះ ) របស់អស់នោះ ក៏បានទៅអ្នកដទៃប្រើប្រាស់ទ្រព្យទាំងឡាយ ក៏ជារបស់មិនទៀង ឥឡូវនេះ ( កុដុម្ពិក៍ ) ជា បិតារបស់ខ្ញុំ[១] ត្រឡប់អំពីផ្សារមកផ្ទះ ធ្វើដូចម្ដេច កុដុម្ពិក៍នឹងឲ្យទេយ្យធម៌តិចតួចដល់នាង នាងកុំអាលទៅអំពីទីនេះឡើយ ។

ខ្លួនខ្ញុំជាស្រីអាក្រាត មានរូបរាងអាក្រក់ក្រៃពេក ជាស្រីស្គម មានខ្លួនវៀមទៅដោយសរសៃ នេះជាកេរ្តិ៍ខ្មាសរបស់ស្រីទាំងឡាយ កុំឲ្យកុដុម្ពិក៍ជា

---

១-កូតស្ស បិតា គួរប្រែថា បិតារបស់កូតកុមារ ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

បិតានាង[២]មកឃើញខ្ញុំឡើយ ។

បើដូច្នោះ ខ្ញុំគួរឲ្យអ្វីដល់នាង ម្យ៉ាងទៀត ខ្ញុំនឹងធ្វើឧបការៈអ្វីដល់នាង ដ៏ជាហេតុឲ្យនាងសម្រេចដោយសេចក្តីប្រាថ្នាទាំងពួងដល់នូវសេចក្តីសុខ ។

នាងចូរនិមន្តភិក្ខុ ៨ រូប គឺ ភិក្ខុ ៤ រូបអំពីសង្ឃ ភិក្ខុ ៤ រូបទៀតអំពីបុគ្គលឲ្យឆាន់ ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំ នោះជាហេតុឲ្យខ្ញុំសម្រេចសេចក្តីប្រាថ្នាទាំងពួង ដល់នូវសេចក្តីសុខ ។

នាងតិស្សា បានទទួលពាក្យនាងមត្តាប្រេតថា សាធុ ហើយទើបនិមន្តភិក្ខុ ៨ រូបឲ្យឆាន់ រួចហើយឲ្យស្លៀកដណ្តប់ ដោយសំពត់ទាំងឡាយហើយឧទ្ទិសទក្ខិណាទានដល់នាងមត្តាប្រេតនោះ ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ ភោជនាហារ សំពត់ស្លៀកដណ្តប់និងទឹកផឹក ក៏កើតឡើងនេះជាផលនៃទក្ខិណាទាន លំដាប់នោះ នាងប្រេតជាស្រីស្អាត មានគ្រឿងស្លៀកពាក់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ជាងសំពត់ដែលកើតក្នុងដែនកាសីមានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ទើបបានចូលទៅរកនាងតិស្សា ជាស្រីរួមប្តី ។

( នាងតិស្សាសួរថា ) ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿងដោយរស្មី មកឋិតនៅ ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ ដោយហេតុដូចម្តេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេចបានជាភោគទាំងឡាយណានីមួយដែលជាទីពេញចិត្ត កើតឡើងដល់នាង

---

២- គួរប្រែថា ជាបិតារបស់ភូតកុមារ ។

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង នាងកើតជាមនុស្ស បានធ្វើបុញ្ញកម្មដូចម្ដេច នាងជាទេវធីតា មានអានុភាពភ្លឺផ្លេកយ៉ាងនេះ ដោយបុញ្ញកម្មដូចម្ដេច បានជានាងមានអានុភាពដ៏រុងរឿង ទាំងសម្បុររបស់នាង ក៏ភ្លឺសព្វទិស ។

( នាងមត្តាប្រេតតបថា ) កាលអំពីមុន នាងឈ្មោះតិស្សា ខ្ញុំឈ្មោះមត្តា ជាស្រីរួមប្ដីរបស់នាង បានធ្វើនូវអំពើអាក្រក់ទើបបានឃ្លាតអំពីមនុស្សលោកនេះទៅកាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់នាង ដែលបានឲ្យហើយទើបមិនមានភ័យក្នុងទីណាឡើយ ។ ម្នាលប្អូនចូរនាងរស់នៅអស់កាលយូរព្រមដោយពួកញាតិទាំងអស់ចុះ ម្នាលនាងល្អ ចូរនាងឲ្យប្រព្រឹត្តធម៌ឲ្យទានក្នុងលោកនេះនឹង ( ចូលទៅកាន់ឋានសួគ៌ ) ដែលមិនមានសោក មិនមានធូលី ជាទីនៅនៃវសវត្តីទេវរាជទាំងឡាយ ។

នាងចូរបន្ទោបង់នូវមន្ទិល គឺសេចក្ដីកំណាញ់ ព្រមទាំងឫសគល់ចេញ ដែលគេនិន្ទាមិនបាន ចូរទៅកាន់ស្ថានសួគ៌ ។

## ចប់ រឿងនាងមត្តាប្រេតទី ៣ ។

# អដ្ឋកថា ឆាតមត្តាប្រេត

[ ១៥ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធស្រីប្រេតឈ្មោះមត្តា ទើបត្រាស់ព្រះគាថានេះ មានពាក្យផ្តើមថា **ឆត្តា ឧព្វណ្ណរូបាសិ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិកៈម្នាក់ ជាអ្នកមានសទ្ធា មានការជ្រះថ្លា តែភរិយារបស់គាត់ មិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ច្រើនដោយសេចក្តីក្រោធ ជាស្រីអារ ដោយឈ្មោះ មានឈ្មោះថា មត្តា ។ គ្រានោះ កុដុម្ពិកៈនោះ ព្រោះខ្លាចដាច់វង្សត្រកូល ក៏បាននាំស្រីដទៃ ឈ្មោះថា តិស្សា មកអំពីត្រកូលស្មើគ្នា នាងជាស្រីមានសទ្ធា មានសេចក្តីជ្រះថ្លា និងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ស្វាមី ។ មិនយូរប៉ុន្មាននាងក៏មានទម្ងន់ ដោយកន្លងទៅ ១០ ខែ ក៏ប្រសូតកូនម្នាក់ កូននោះឈ្មោះថា ភូតៈ ។ នាងជាស្រីមេផ្ទះ ឧបដ្ឋាកភិក្ខុ ៤ រូប ដោយគោរព ឯស្រីអារក៏ច្រណែននឹងនាង ។

ថ្ងៃមួយ ស្រីទាំង ២ នោះ កក់សក់ បានឈរសំងិលសក់ ។ កុដុម្ពិកៈមានសេចក្តីស្នេហាក្នុងនាងតិស្សាដោយអំណាចគុណ មានចិត្តត្រេកអរ បានឈរចរចាជាមួយនឹងនាងតិស្សានោះយ៉ាងច្រើន នាងមត្តាអត់ធន់ចំពោះហេតុការណ៍នោះមិនបាន ត្រូវសេចក្តីឫស្យាគ្របសង្កត់ទើបយកសំរាមដែលបោសគរទុកក្នុងផ្ទះមកបាចលើក្បាលរបស់នាងតិស្សា ។ សម័យតមក នាងមត្តាធ្វើកាលកិរិយាហើយ កើតក្នុងកំណើតប្រេត សោយទុក ៥ ប្រការ ព្រោះកម្លាំងនៃកម្មរបស់ខ្លួន ។ ទុក្ខនោះ ដឹងបានតាមបាលីនោះឯង ។ ថ្ងៃមួយ

ស្រីប្រេតនោះក៏បង្ហាញខ្លួនដល់នាងតិស្សាដែលកំពុងងូតទឹកខាងក្រោយផ្ទះ ។ នាងតិស្សាឃើញស្រីនោះទើបសាកសួរដោយគាថាថា

ម្នាលស្រីស្គម មានធ្មេញដំនីរគោម នាងជាស្រីមានកាយអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមដោយសរសៃ នាងជាអ្វី បានជាមកឈរនៅក្នុងទីនេះ ដូច្នេះ ។

ឯស្រីប្រេតបានឲ្យចម្លើយដោយគាថាថា

កាលពីមុន នាងឯងឈ្មោះតិស្សា ខ្ញុំឈ្មោះមត្តា ជាស្រីរួមប្តីរបស់នាង បានធ្វើអំពើបាប ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អហំ មត្តា តុវំ តិស្សា** សេចក្តីថា ខ្ញុំឈ្មោះមត្តា នាងឈ្មោះតិស្សា ។ បទថា **បុរេ** ប្រែថា ក្នុងអត្តភាពមុន ។ បទថា **តេ** សេចក្តីថា ខ្ញុំបានជាអ្នករួមប្តីជាមួយនាង ។ អធិប្បាយថា បានកើតហើយ ។ នាងតិស្សាក៏សួរដល់កម្មដែលនាងធ្វើដោយគាថាទៀតថា

ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្តនោះ តើដូចម្តេច នាងឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះវិបាកនៃកម្ម ដូចម្តេច ដូច្នេះ ។

ឯស្រីប្រេត ក៏ប្រាប់កម្មដែលខ្លួនធ្វើដោយគាថាបន្តថា

ខ្ញុំជាស្រីកាច ( ឆ្នាស ) បានពោលផរុសវាចា ជាស្រីប្រស្សា

កំណាញ់ អួតអាង ខ្ញុំនោះបានពោលពាក្យអាក្រក់ ទើបបាន ឃ្លាត អំពីមនុស្សលោកនេះ ទៅកាន់បេតលោក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ចណ្ឌី** ប្រែថា ជាអ្នកច្រើនដោយសេចក្តីក្រោធ ។ បទថា **ផរុសា** ប្រែថា ច្រើនដោយពាក្យគ្រោតគ្រាត ។ បទថា **អាសឹ** ប្រែថា បានកើតហើយ ។ បទថា **តាហំ** កាត់បទជា **តំ អហំ** ។ បទថា **ទុរុត្តំ** ប្រែថា ពោលពាក្យអាក្រក់ គឺពាក្យដែលមិនមានប្រយោជន៍ ។ ខាងមុខអំពីនោះទៅ ស្រីទាំង ២ នាក់នោះ បានប្រកាសគាថាដោយការ ពោលឆ្លើយឆ្លងគ្នាប៉ុណ្ណោះ ។

នាងតិស្សាពោលថា

ពិតមែនហើយ យើងបានដឹងថា នាងជាស្រីឆ្នាស យើងសូមសួរនាង អំពីហេតុដទៃទៀត ចុះនាងមានខ្លួនប្រឡាក់ប្រឡាក់ ដោយអាចម៍ដី ព្រោះកម្មដូចម្តេច ។

នាងមត្តាពោលថា

នាងបានលុបលាងក្បាលរួចហើយ មានសំពត់ដ៏ស្អាតប្រដាប់ហើយ ខ្លួនយើងសោត ក៏ប្រដាប់តាត់តែងដោយគ្រឿងអលង្ការដ៏ក្រៃលែងជាងនាង កាលខ្ញុំនោះកំពុងសំឡឹងមើល នាងក៏ពោលចរចានឹងស្វាមី ក្នុងលំដាប់នោះ ខ្ញុំមានសេចក្តីឫស្យាពេកណាស់ ខ្ញុំមានសេចក្តីក្រោធកើតឡើង តអំពីនោះ ខ្ញុំក៏ប្រវាយកអាចម៍ដីទៅរោយដាក់នាងដោយអាចម៍ដី ព្រោះហេតុ

នោះ ខ្ញុំទើបមានខ្លួនប្រឡាក់ដោយអាចម៍ដី ព្រោះវិបាកនៃកម្ម នោះឯង ។

នាងតិស្សាពោលថា

ពិតមែនហើយ យើងដឹងថា នាងបានរោយអាចម៍ដីដាក់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងត្រូវរោគកមរមាស់បៀតបៀន ដោយកម្មអ្វី ។

នាងមត្តាពោលថា

យើងទាំងពីរនាក់ បានចូលទៅកាន់ព្រៃដើម្បីរកថ្នាំ ចំណែកនាងបានយកថ្នាំមក ឯខ្ញុំបាននាំយកខ្ញែមកវិញ កាលបើនាងមិនដឹង ខ្ញុំក៏រោយខ្ញែលើដំណេករបស់នាង ព្រោះហេតុនោះ រាងកាយរបស់ខ្ញុំ ទើបត្រូវរោគកមរមាស់បៀតបៀន ព្រោះវិបាកនៃកម្មនោះឯង ។

នាងតិស្សាពោលថា

ពិតមែនហើយ យើងបានដឹងថា នាងបានរោយ ( ខ្ញែ ) លើដំណេករបស់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងមានកាយអាក្រាតដោយកម្មអ្វី ។

នាងមត្តាពោលថា

មានការប្រជុំមិត្តសំឡាញ់និងជួបជុំពួកញាតិ គេបានហៅនាងព្រមទាំងស្វាមី តែខ្ញុំគេមិនហៅ កាលបើនាងមិនបានដឹង ខ្ញុំក៏

លួចយកសំពត់នាងទៅលាក់ ហេតុនោះ ខ្ញុំទើបមានរាងកាយអាក្រាត ព្រោះវិបាកនៃកម្មនោះឯង ។

នាងតិស្សាពោលថា

ពិតមែនហើយ យើងដឹងថា នាងបានលួចសំពត់របស់យើងទៅលាក់ យើងសួរនាងអំពីហេតុដទៃទៀត ចុះរាងកាយរបស់នាងមានក្លិនស្អុយដូចក្លិនលាមក ព្រោះកម្មអ្វី ។

នាងមត្តាពោលថា

ខ្ញុំបានលួចយកនូវគ្រឿងក្រអូប ផ្កាកម្រង និងគ្រឿងលាបដ៏មានតម្លៃរបស់នាងទៅចោលក្នុងរណ្ដៅលាមក ខ្ញុំបានធ្វើអំពើអាក្រក់នោះ ហេតុនោះ បានជាខ្ញុំមានក្លិនស្អុយដូចក្លិនលាមក ព្រោះហេតុវិបាកនៃកម្មនោះឯង ។

នាងតិស្សាពោលថា

ពិតមែនហើយ យើងបានដឹងហើយថា នាងបានធ្វើអំពើអាក្រក់នោះ យើងសូមសួរនាងអំពីហេតុដទៃទៀតចុះនាងជាស្រីទុរគត ព្រោះវិបាកនៃកម្មអ្វី ។

នាងមត្តាពោលថា

កាលយើងទាំងពីរនាក់ មានទ្រព្យសម្បត្តិក្នុងផ្ទះស្មើគ្នាកាលទេយ្យធម៌មាន ខ្ញុំក៏មិនបានធ្វើទីពឹងដើម្បីខ្លួន ព្រោះហេតុនោះបានជាខ្ញុំជាស្រីទុរគត ដោយវិបាកនៃកម្មនោះឯង ។

នាងឯងបានស្តីឲ្យខ្ញុំថា នាងកុំសេពអំពើអាក្រក់ ដ្បិតថា សុគតិមិនមែនបានដោយងាយព្រោះបាបកម្មឡើយ ។

នាងតិស្សាពោលថា

នាងបានកំហែងយើងដោយផ្លូវខុស ទាំងបានប្រស្យាយើងនាង ចូរមើលចុះ វិបាកនៃអំពើអាក្រក់ ប្រាកដយ៉ាងណា ( អំពីមុន ) ខ្ញុំស្រីទាំងឡាយក្នុងផ្ទះនោះនិងគ្រឿងប្រដាប់ប្រដានោះឯង ជារបស់ខ្ញុំ[១]ក៏មាន ( ឥឡូវនេះ ) របស់អស់នោះក៏បានទៅអ្នកដទៃប្រើប្រាស់ ទ្រព្យទាំងឡាយក៏ជារបស់មិនទៀង ឥឡូវនេះ ( កុដុម្ពិក៍ ) ជាបិតារបស់ខ្ញុំ ត្រឡប់អំពីផ្សារមកផ្ទះ ធ្វើដូចម្តេច កុដុម្ពិក៍នឹងឲ្យទេយ្យធម៌តិចតួចដល់នាង នាងកុំអាលទៅអំពីទីនេះឡើយ ។

នាងមត្តាពោលថា

ខ្លួនខ្ញុំជាស្រីអាក្រាត មានរូបរាងអាក្រក់ក្រៃពេក ជាស្រីស្គម មានខ្លួនរាំមទៅដោយសរសៃ នេះជាកេរ្តិ៍ខ្មាសរបស់ស្រីទាំងឡាយ កុំឲ្យកុដុម្ពិក៍ជាបិតានាងមកឃើញខ្ញុំឡើយ ។

នាងតិស្សាពោលថា

បើដូច្នោះ ខ្ញុំគួរឲ្យអ្វីដល់នាង ម្យ៉ាងទៀត ខ្ញុំនឹងធ្វើឧបការៈ

---

១-ពាក្យថា មេ ប្រែដោយត្រង់ថារបស់ខ្ញុំ ក៏ពិត តែគួរប្រែថា របស់នាង ទើបត្រូវតាមន័យអដ្ឋកថា ។

អ្វីដល់នាង ដ៏ជាហេតុឲ្យនាង សម្រេចដោយសេចក្តីប្រាថ្នា ទាំងពួងដល់នូវសេចក្តីសុខ ។

នាងមត្តាពោលថា

នាងចូរនិមន្តភិក្ខុ ៨ រូប គឺភិក្ខុ ៤ រូបអំពីសង្ឃ ភិក្ខុ ៤ រូប ទៀតអំពីបុគ្គលឲ្យឆាន់ ហើយឧទ្ទិសនូវទក្ខិណាទាន ដល់ខ្ញុំ នោះ ជាហេតុឲ្យខ្ញុំ សម្រេចសេចក្តីប្រាថ្នាទាំងពួង ដល់នូវ សេចក្តីសុខ ។

ព្រះសង្គីតិកាចារ្យពោលថា

នាងតិស្សាបានទទួលពាក្យនាងមត្តាប្រេតថា សាធុហើយទើប និមន្តភិក្ខុ ៨ រូបឲ្យឆាន់ រួចហើយឲ្យស្លៀកដណ្តប់ដោយ សំពត់ទាំងឡាយ ហើយឧទ្ទិសទក្ខិណាទានដល់នាងមត្តាប្រេត នោះ ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ ភោជ នាហារ សំពត់ស្លៀកដណ្តប់និងទឹកផឹក ក៏កើតឡើង នេះជា ផលនៃទក្ខិណាទាន លំដាប់នោះ នាងប្រេតជាស្រីស្អាត មាន គ្រឿងស្លៀកពាក់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ជាងសំពត់ ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ទើប បានចូលទៅរកនាងតិស្សាជាស្រីរួមប្តី ។

នាងតិស្សាពោលថា

ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿងដោយរស្មី មកឋិតនៅ

ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះដោយហេតុដូចម្តេច ផលនៃសុចរិតសម្រេចដល់នាង ក្នុងទីនេះ ដោយហេតុដូចម្តេច បានជាភោគទាំងឡាយណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលនាងទេវធីតាមានអានុភាពច្រើន យើងសូមសួរនាងនាង កើតជាមនុស្ស បានធ្វើបុញ្ញកម្មដូចម្តេច នាងជាទេវធីតាមាន អានុភាពភ្លឺផ្លេកយ៉ាងនេះ ដោយបុញ្ញកម្មដូចម្តេច បានជានាង មានអានុភាពដ៏រុងរឿង ទាំងសម្បុររបស់នាងក៏ភ្លឺសព្វទិស ។ នាងមត្តាប្រេតពោលថា

កាលអំពីមុន នាងឈ្មោះតិស្សា ខ្ញុំឈ្មោះមត្តា ជាស្រីរួម ប្តីរបស់នាង បានធ្វើនូវអំពើអាក្រក់ ទើបបានឃ្លាតអំពីមនុស្ស លោកនេះ ទៅកាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់ នាង ដែលបានឲ្យហើយ ទើបមិនមានភ័យក្នុងទីណាឡើយ ។ ម្នាលប្អូន ចូរនាងរស់នៅអស់កាលយូរ ព្រមដោយពួកញាតិ ទាំងអស់ចុះ ម្នាលនាងល្អ ចូរនាងខំប្រព្រឹត្តធម៌ ខំឲ្យទានក្នុង លោកនេះនឹង ( ចូលទៅកាន់ឋានសួគ៌ ) ដែលមិនមាន សោកមិនមានធូលីជាទីនៅនៃវសវត្តីទេវរាជទាំងឡាយ ។

នាងចូរបន្ទោបង់នូវមន្ទិលគឺសេចក្តីកំណាញ់ ព្រមទាំងឫស គល់ចេញដែលគេនិន្ទាមិនបានចូរទៅកាន់ស្ថានសួគ៌ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សព្វំ អហម្បិ ជានាមិ យថា ត្វំ ចណ្ឌិកា អហុ** សេចក្តីថា ពាក្យដែលនាងពោលថា នាងជាស្រីកាចនិងមានវាចាគ្រោតគ្រាត ទាំងអស់នោះ ខ្ញុំក៏ដឹងថា នាងជាស្រីកាច ច្រើនទៅដោយសេចក្តីក្រោធ មានវាចាគ្រោតគ្រាត ច្រើនដោយសេចក្តីឫស្យា កំណាញ់និងអួតអាង ។ បទថា **អញ្ញញ្ច ខោ តំ បុច្ឆាមិ** សេចក្តីថា ឥឡូវនេះ ខ្ញុំសូមសួរនាងមួយទៀត ។ បទថា **កេនាសិ បំសុកុន្ថិតា** សេចក្តីថា នាងជាបុគ្គលប្រឡាក់ដោយសំរាមនិងធូលី ជាអ្នកមានរាងកាយប្រឡាក់ប្រឡូស ដោយប្រការទាំងពួង ព្រោះកម្មអ្វី ។

បទថា **សីសំ ន្ហាតា** បានដល់ ងូតទឹកទាំងក្បាល ។ បទថា **អធិមត្តំ** បានដល់ មានប្រមាណក្រៃលែងជាង ។ បទថា **សមលង្កតតរា** បានដល់ ប្រដាប់ដោយល្អ គឺល្អក្រៃលែង ។ បាលីថា **អធិមត្តា** ដូច្នេះក៏មាន អធិប្បាយថា ជាអ្នកស្រវឹង គឺជាអ្នកស្រវឹងដោយមានះយ៉ាងក្រៃលែង គឺអាស្រ័យមានះ ។ បទថា **តយា** ប្រែថា នាងដ៏ចម្រើន ។ បទថា **សាមិកេន សមន្តយិ** សេចក្តីថា នាងពោលចរចាប្រាស្រ័យនឹងប្តី ។

បទថា **ខជ្ជសិ កច្ចុយា** សេចក្តីថា នាងត្រូវរោគកមរមាស់ គឺបៀតបៀន ។ បទថា **ភេសជ្ជហារី** បានដល់ នាងរកថ្នាំ គឺនាំឱសថមក ។ បទថា **ឧភយោ** ប្រែថា ទាំង ២ នាក់ អធិប្បាយថា នាងនិងខ្ញុំ ។ បទថា **វនន្តំ** ប្រែថា ចូលកាន់ព្រៃ ។ បទថា **ត្វញ្ច ភេសជ្ជមាហរិ** សេចក្តីថា ឯនាងរកថ្នាំដែលនាំឧបការៈដល់ខ្លួន តាមដែលគ្រូប្រាប់ ។ បទថា **អហាញ្ច**

**កបិកច្ឆុនោ** សេចក្ដីថា តែខ្ញុំបាននាំយកផ្លែខ្វៃ គឺផ្លែដែលមានផស្សៈអាក្រក់មកឲ្យ ម្យ៉ាងទៀត សេចក្ដីថា វល្លិដែលកើតឯង លោកហៅថា **កបិកច្ឆុ** ព្រោះហេតុនោះទើបខ្ញុំនាំយកស្លឹកនិងផ្លែរបស់វល្លិដែលកើតឯងមក ។ បទថា **សេយ្យំ ត្យាហំ សមោកិរឹ** សេចក្ដីថា ខ្ញុំយកផ្លែ និងស្លឹកខ្វៃរោយលើទីដេករបស់នាង ។

បទថា **សហាយានំ** បានដល់ មិត្ត ។ បទថា **សមយោ** ប្រែថា ការប្រជុំ ។ បទថា **ញាតីនំ** បានដល់ ផៅពង្ស ។ បទថា **សមិតី** ប្រែថា ការប្រប្រជុំ ។ បទថា **អាមន្តិតា** សេចក្ដីថា នាងដែលគេអញ្ជើញដោយការធ្វើមង្គល ។ បទថា **សសាមិនី** សេចក្ដីថា ស្រីរួមប្ដី គឺអ្នករួមប្ដី ។ មានវាចាប្រកបសេចក្ដីថា បទថា **នោ ច ខោហំ** សេចក្ដីថា ចំណែកខ្ញុំគេមិនបានអញ្ជើញ ។ បទថា **ឧស្សំ ត្យាហំ** កាត់បទជា **ឧស្សំ តេ អហំ** ។ បទថា **អចានុធឹ** បានដល់ ខ្ញុំបានលួច គឺបានកាន់យកដោយអាការលួច ។ បទថា **បច្ចគ្ឃំ** បានដល់ ជារបស់ថ្មី ឬមានតម្លៃច្រើន ។ បទថា **អតារេសឹ** បានដល់ បោះចោល ។ បទថា **គូថគន្ធិនី** បានដល់ មានក្លិនដូចក្លិនលាមក គឺផ្សាយទៅដោយក្លិនឧច្ចារៈ ។

បទថា **យំ គេហេ វិជ្ជតេ ធនំ** សេចក្ដីថា យើងទាំង ២ គឺនាងនិងខ្ញុំមានទ្រព្យកើតឡើងក្នុងផ្ទះស្មើគ្នា គឺប្រមាណប៉ុនគ្នា ។ បទថា **សន្តេសុ** ប្រែថា មាន ។ បទថា **ទីបំ** បានដល់ ទីពឹង លោកពោលសំដៅយកបុញ្ញកម្ម ។

ស្រីប្រេតនោះ ប្រាប់សេចក្ដីដែលនាងតិស្សាសួរយ៉ាងនេះហើយ កាល

នឹងប្រកាសកំហុសដែលខ្ញុំមិនធ្វើតាមពាក្យរបស់នាងតិស្សានោះ ក្នុងកាលមុនទៀតទើបពោលពាក្យជាដើមថា នាងឯងបានស្តី ( ដាស់តឿន ) ឲ្យខ្ញុំ ។

ក្នុងបទទាំងនោះ បទថា **តទេវ** ប្រែថា ក្នុងកាលនោះឯង គឺក្នុងកាលដែលខ្ញុំតាំងនៅក្នុងអត្តភាពមនុស្សនោះឯង ។ បាលីថា **តថេវ** ដូច្នេះ ក៏មានអធិប្បាយថា កម្មដែលកើតឡើងក្នុងឥឡូវនេះ យ៉ាងណា កម្មនោះក៏ដូច្នោះដូចគ្នា ។ ស្រីប្រេតសម្តែងយកខ្លួនជាបន្ទាល់ថា **មំ** ។ បទថា **ត្វំ** បានដល់នាងតិស្សា ។ បទថា **អវច** ប្រែថា បានពោលហើយ ។ ដើម្បីសម្តែងដល់អាការដែលនាងតិស្សាពោលទើបលោកពោលពាក្យជាដើមថា **ទាបកម្មំ** ប្រែថា អំពើអាក្រក់ ។ បាលីថា **ទាបកម្មានិ** ដូច្នេះក៏មាន ។ នាងតិស្សាពោលថាជ្បិតថាសុគតិមិនមែនបានដោយងាយព្រោះបាបកម្មឡើយ ។ ដោយពិតបានតែទុគ្គតិប៉ុណ្ណោះ ។ នាងមត្តាពោលថា នាងបានពោលគឺដាស់តឿនខ្ញុំក្នុងកាលមុនដោយអាការៈណា កម្មនោះរមែងមានដោយអាការៈនោះឯង ។

នាងតិស្សាបានស្តាប់ដូច្នោះហើយ ទើបពោល ៣ គាថា ដោយន័យជាដើមថា **វាមតោ មំ ត្វំ បច្ចេសិ** នាងបានកំហែងយើងដោយផ្លូវខុស ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **វាមតោ មំ ត្វំ បច្ចេសិ** សេចក្តីថា នាងកំហែងយើងដោយផ្លូវខុស គឺនាងប្រកាន់ខ្ញុំដែលជាអ្នកស្វែងរកប្រយោជន៍ ដើម្បីនាងថាធ្វើខ្លួនជាសត្រូវ ( របស់នាង ) ។ បទថា **មំ ឧសូយសិ** ប្រែថា នាងប្រណែននឹងខ្ញុំ ធ្វើនូវការប្រណែននឹងខ្ញុំ ។ បទថា **បស្ស ទាទានំ កម្មានំ វិទាកោ ហោតិ យាទិសោ** នេះ នាងតិស្សា សម្តែងថា ចូរនាងមើលវិបាក

នៃកម្មអាក្រក់ដ៏ខ្លាំងក្លានោះដោយប្រចក្ស ។

បទថា **តេ អញ្ញេ បរិចារេន្តិ** សេចក្តីថា ទាសីក្នុងផ្ទះរបស់នាង និងគ្រឿងអាភារណៈទាំងនេះដែលនាងហួងហែងក្នុងកាលមុន ឥឡូវនេះ បម្រើអ្នកដទៃ គឺអ្នកដទៃប្រើប្រាស់ ។ ពិតហើយ បទថា **ឥមេ** នេះ លោកពោលដោយលិង្គវិបល្លាស ។ បទថា **ន ភោគា ហោន្តិ សស្សតា** សេចក្តីថា ធម្មតាភោគៈទាំងនេះមិនពិតប្រាកដ គឺមិនស្ថិតស្ថេរ ជារបស់មួងម្កាល ត្រូវលះបង់ចោលទៅ អធិប្បាយថា ព្រោះដូច្នោះ មិនគួរធ្វើសេចក្តីប្រណែននិងសេចក្តីកំណាញ់ជាដើមដើម្បីប្រយោជន៍ដល់ភោគៈនោះ ។

បទថា **ឥទានិ ភូតស្ស បិតា** សេចក្តីថា ឥឡូវនេះ កុដុម្ពិកៈជាឪពុករបស់ភូតកុមារដែលជាកូនរបស់យើង ។ បទថា **អាបណា** សេចក្តីថា គាត់នឹងមក គឺត្រឡប់មកអំពីផ្សារមកកាន់ផ្ទះ ។ បទថា **អប្បេវ តេ ទទេ កិញ្ចិ** សេចក្តីថា កុដុម្ពិកៈមកដល់ផ្ទះហើយ នឹងឲ្យទេយ្យធម៌ណាមួយដែលគួរឲ្យដល់នាង ។ បទថា **មា សុ តាវ ឥតោ អគា** សេចក្តីថា នាងតិស្សា កាលអនុគ្រោះស្រីប្រេតនោះ ទើបពោលថា ជាបឋម នាងកុំទៅអំពីនេះ គឺអំពីទីខាងក្រោយផ្ទះនេះ ។

ស្រីប្រេតបានស្តាប់ដូច្នោះ កាលនឹងប្រកាសអធ្យាស្រ័យរបស់ខ្លួន ក៏បានពោលគាថាជាដើមថា ខ្លួនខ្ញុំជាស្រីអាក្រាត មានរូបរាងអាក្រក់ក្រៃពេកដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **កោបីនមេតំ ឥត្ថីនំ** សេចក្តីថា ភាពជាមនុស្សអាក្រាតកាយនិងមានរូបរាងគួរខ្ពើមជាដើមយ៉ាងនេះ ជារបស់គួរខ្មាស

គឺគួរបិទបាំងសម្រាប់ស្រីទាំងឡាយ ព្រោះជាអវយវៈគួរបិទបាំង ។ បទថា **មា មំ ភូតបិតាទ្ទស** សេចក្តីថា ស្រីប្រេតខ្មាសបណ្តើរ ពោលបណ្តើរថា ព្រោះហេតុនោះ កុំឲ្យកុដុម្ពីក៏ជាបិតារបស់ភូតកុមារមកឃើញខ្ញុំឡើយ ។

នាងតិស្សា កាលបានស្តាប់ដូច្នោះ ក៏កើតករុណា ពោលថា ខ្ញុំនឹងធ្វើឧបការៈអ្វីដល់នាង ។ ក្នុងបទទាំងនោះ សព្ទថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថថា ដាស់តឿន ។ បទថា **កឹ វា ត្យាហំ ទម្មិ** សេចក្តីថា ខ្ញុំនឹងឲ្យអ្វីដល់នាង គឺនឹងឲ្យសំពត់ ឬអាហារ ។ បទថា **កឹ វា តេធ ករោមហំ** សេចក្តីថា ខ្ញុំនឹងធ្វើឧបការៈណាមួយក្នុងទីនេះ គឺក្នុងពេលនេះ ។

ស្រីប្រេត បានស្តាប់ដូច្នោះហើយ ទើបពោលគាថាថា **ចត្តារោ ភិក្ខូ សង្ឃតោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ចត្តារោ ភិក្ខូ សង្ឃតោ ចត្តារោ បន បុគ្គលេ** សេចក្តីថា នាងចូរឲ្យភិក្ខុ ៨ រូប បរិភោគតាមគាប់ចិត្ត យ៉ាងនេះ គឺចាកភិក្ខុសង្ឃ គឺអំពីសង្ឃ ៤ រូប អំពីបុគ្គល ៤ រូប ដូច្នេះហើយ ឧទ្ទិសចំណែកបុណ្យនោះដល់ខ្ញុំ គឺចូរឲ្យបត្តិទានដល់ខ្ញុំចុះ ។ បទថា **តទាហំ សុខិតា ហេស្សំ** សេចក្តីថា ក្នុងពេលដែលនាងឧទ្ទិសចំណែកបុណ្យដល់ខ្ញុំ ខ្ញុំនឹងបានទទួលសេចក្តីសុខ គឺដល់នូវសេចក្តីសុខ ជាអ្នកសម្រេចនូវវត្ថុដែលប្រាថ្នាគ្រប់យ៉ាង ។

នាងតិស្សា កាលបានស្តាប់ដូច្នោះ ទើបប្រាប់សេចក្តីនោះដល់ស្វាមីនៃខ្លួន ក្នុងថ្ងៃទី ២ ទើបឲ្យភិក្ខុ ៨ រូបឆាន់ ហើយឧទ្ទិសចំណែកបុណ្យដល់ស្រីប្រេត ភ្លាមនោះឯង ស្រីប្រេតក៏បានទទួលទិព្វសម្បត្តិ ទើបត្រឡប់ទៅរក

នាងតិស្សា ។ ដើម្បីសម្តែងសេចក្តីនោះទើបព្រះសង្គីតិកាចារ្យទាំងឡាយបាន តាំងគាថា ៣ ថា នាងតិស្សា បានទទួលពាក្យនាងមត្តាប្រេតថា សាធុ ដូច្នេះ ជាដើម ។

ឯនាងតិស្សា បានសាកសួរទេពធីតាដែលចូលទៅឈរហើយដោយគាថា ៣ ថា **អភិក្កន្តេន វណ្ណេន** ដូច្នេះ ជាដើម ។ ឯទេពធីតាក៏ប្រាប់រឿងរបស់ ខ្លួនដោយគាថាថា ខ្ញុំឈ្មោះមត្តា ហើយបានឲ្យអនុមោទនា ដល់នាង តិស្សាដោយគាថាថា **ចិរំ ជីវាហិ ភគិនិ** ដូច្នេះ ជាដើម យ៉ាងនេះហើយ បានឲ្យឱវាទដោយគាថាថា **ឥធ ធម្មំ ចរិត្វាន** ដូច្នេះជាដើម ។ ក្នុងបទទាំង នោះ បទថា **តវ ទិន្នេន** បានដល់ ទានដែលនាងឲ្យហើយ ។ បទថា **អសោកំ វិរជំ ឋានំ** សេចក្តីថា ឈ្មោះថា **អសោកំ** ព្រោះមិនមានសេចក្តី សោក ។ ម្យ៉ាងទៀត ឋានៈដែលជាទិព្វ ឈ្មោះថា **វិរជំ** ព្រោះមិនមាន ធូលី គឺញើសក្អែលទាំងអស់នោះ ទេពធីតាពោលសំដៅយកទេវលោក ។ បទថា **អាវាសំ** បានដល់ ទីកន្លែង ។ បទថា **វសវត្តិនំ** បានដល់ ទេវតា ទាំងឡាយដែលផ្សាយអំណាចរបស់ខ្លួន ដោយភាពជាអធិបតី ដ៏ជាទិព្វ ។ បទថា **សម្ពលំ** បានដល់ ប្រព្រឹត្តទៅមួយអន្លើដោយ លោភៈនិងទោសៈ ។ ពិតហើយ លោភៈនិងទោសៈ ឈ្មោះថា ជាមូលរបស់សេចក្តីកំណាញ់ ។ បទថា **អនិន្ទិតា** បានដល់ បុគ្គលណាមួយក៏មិនតិះដៀល គឺគួរសរសើរ ។ បទថា **សគ្គមុបេហិ ឋានំ** សេចក្តីថា ចូរតម្កល់ឋានៈដែលជាទិព្វដែលបាន ឈ្មោះថា **សគ្គ** ព្រោះប្រសើរដោយល្អដោយអារម្មណ៍ទាំងឡាយ មានរូប

ជាដើម អធិប្បាយថា មានសុគតិជាទីទៅខាងមុខ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

លំដាប់នោះ នាងតិស្សាប្រាប់រឿងរ៉ាវនោះដល់កុដុម្ពិកៈ ។ ទើបកុដុម្ពិកៈពិតដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក៏ក្រាបទូលដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់សម្ដែងធម៌ ដល់បរិស័ទដែលដល់ព្រមហើយ ។ មហាជនបានស្ដាប់ធម៌នោះ បាននូវសេចក្ដីសង្វេគទើបកម្ចាត់មន្ទិលមានសេចក្ដីកំណាញ់ជាដើម ជាអ្នកត្រេកអរក្នុងទាន និងសីលជាដើម មានសុគតិជាទីទៅខាងមុខ ដូច្នេះ ។

## អដ្ឋកថា នាងមត្តាប្រេតចប់

# រឿង ឆន្ទាប្រេត ទី៤

[ ១៦ ] ( នន្ទសេនជាស្វាមីសួរថា ) នាងជាស្រីមានខ្លួនខ្មៅ មានរូបអាក្រក់គ្រោតគ្រាតមើលគួរខ្លាច មានភ្នែកលឿង មានធ្មេញរង្វើលយើងមិនសំគាល់ថា នាងជាស្រីមនុស្សទេ ។

( នាងប្រេតតបថា ) ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ។

ចុះអំពើអាក្រក់ដែលនាងបានធ្វើដោយ កាយ វាចា ចិត្តនោះ តើដូចម្ដេចខ្លះ នាងទៅអំពីមនុស្សលោកនេះ កាន់បេតលោកដោយវិបាកនៃកម្មដូចម្ដេចខ្លះ ។

ខ្ញុំជាស្រីកំណាចផង មានវាចាអាក្រក់ផង ឥតមានសេចក្ដីគោរពចំពោះអ្នកផង ខ្ញុំពោលពាក្យអាក្រក់ចំពោះអ្នក ទើបបានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ។

បើដូច្នោះ យើងនឹងឲ្យសំពត់បង់កដល់នាង ចូរនាងស្លៀកសំពត់នេះចុះ លុះនាងស្លៀកសំពត់នេះហើយ ចូរចូលមកយើងនឹងនាំនាងទៅផ្ទះ នាងទៅដល់ផ្ទះហើយ នឹងបានសំពត់ បាយ ទឹក បានឃើញនូវបុត្តទាំងឡាយរបស់នាងផង បានឃើញកូនប្រសារស្រីរបស់នាងផង ។

វត្ថុដែលអ្នកបានឲ្យផ្ទាល់ដៃដោយដៃ មិនសម្រេចដល់ខ្ញុំទេ អ្នកចូរញ៉ាំងភិក្ខុទាំងឡាយដែលបរិបូណ៌ដោយសីល ជាអ្នកប្រាសចាករាគៈ ជាពហុស្សូតឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំ ក្នុង

វេលានោះ ទើបខ្ញុំនឹងដល់នូវសេចក្ដីសុខ សម្រេចនូវសេចក្ដីប្រាថ្នាទាំងពួងបាន ។

លំដាប់នោះ នន្ទសេន ឧបាសកនោះ ទទួលថា សាធុ ដូច្នេះហើយ បានចាត់ចែងនូវទានដ៏បរិបូណ៌ គឺបាយ ទឹក បង្អែម សំពត់ សេនាសនៈ ឆត្រ គ្រឿងក្រអូប ផ្កាកម្រង ស្បែកជើងផ្សេងៗ ។ នន្ទសេនឧបាសក ក៏បានញ៉ាំងភិក្ខុទាំងឡាយដែលបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ហើយឧទ្ទិសទក្ខិណាទានដល់នាងនន្ទាប្រេត ។

វិបាកក៏កើតឡើងក្នុងលំដាប់ដែលបានឧទ្ទិស ភោជនាហារ សំពត់ស្លៀកទាំងទឹកផឹកក៏កើត នេះជាផលនៃទក្ខិណាទាន លំដាប់នោះ នាងនន្ទាប្រេតនោះ ជាស្រីស្អាត មានសំពត់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ចូលទៅរកស្វាមី ។

( នន្ទសេនឧបាសកសួរថា ) ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿង ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក សម្បុរបស់នាងប្រាកដដូច្នោះដោយហេតុដូចម្ដេច ផលនៃសុចរិតសម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេច ភោគទាំងឡាយណានីមួយដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវធីតាមានអានុភាពច្រើន យើងសូមសួរនាង នាង
កាលកើតជាមនុស្សបានធ្វើបុញ្ញកម្មដូចម្ដេច នាងជាទេវធីតា

មានអានុភាពរុងរឿងយ៉ាងនេះ ដោយបុញ្ញកម្មដូចម្តេច ទាំង
សម្បុររបស់នាងក៏ភ្លឺសព្វទិស ។

( នាងប្រេតតបថា ) ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ទើបបានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់អ្នកដែលបានឲ្យហើយទើបឥតមានភ័យក្នុងទីណាៗឡើយ ។ ម្នាលគហបតី អ្នកព្រមទាំងពួកញាតិទាំងអស់គ្នា ចូររស់នៅអស់កាលយូរ ម្នាលគហបតី អ្នកខំប្រព្រឹត្តធម៌ ខំឲ្យទានក្នុងលោកនេះ នឹងចូលទៅកាន់ទិព្វស្ថានដែលមិនមានសោក មិនមានធូលី ជាទីនៅនៃវសវត្តីទេវរាជទាំងឡាយ ។

អ្នកចូរបន្ទោបង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫសគល់ចេញប្រាសចាកនិន្ទា ចូលទៅកាន់ស្ថានសួគ៌ ។

## ចប់ រឿងនន្ទាប្រេត ទី ៤ ។

## អដ្ឋកថា នន្ទាប្រេត

[ ១៦ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធប្រេតឈ្មោះនន្ទា ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **កាឡី ទុព្វណ្ណរូបាសិ** ដូច្នេះជាដើម ។

បានឮថា ក្នុងតំបន់មួយ មិនឆ្ងាយអំពីក្រុងសាវត្ថី មានឧបាសកម្នាក់ឈ្មោះនន្ទិសេន ជាអ្នកមានសទ្ធា មានការជ្រះថ្លា ។ ឯភរិយារបស់គាត់ឈ្មោះនន្ទា មិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ជាបុគ្គលកំណាញ់ កាចពោលវាចាគ្រោតគ្រាត មិនគោរពកោតក្រែងប្តី ជេរបរិភាសប្តី ដោយវាចាជាចោរ ។ សម័យតមក នាងនន្ទានោះ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងកំណើតប្រេត មិនឆ្ងាយអំពីស្រុកនោះឯង ក៏មកបង្ហាញខ្លួនដល់ប្តី ។ នន្ទិសេនឧបាសកឃើញស្រីប្រេតនោះ ទើបពោលគាថាថា

> នាងជាស្រីមានខ្លួនខ្មៅ មានរូបអាក្រក់គ្រោតគ្រាតមើលគួរខ្លាច
> មានភ្នែកលឿង មានធ្មេញរង្គើល យើងមិនសំគាល់ថា នាង
> ជាស្រីមនុស្សទេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កាឡី** បានដល់ មានសម្បុរខ្មៅ ។ ពិតហើយពណ៌សម្បុររបស់ប្រេតនោះ ដូចជាធ្យូងដែលគេដុត ។ បទថា **ផរុសា** បានដល់ មានខ្លួនពុំរាបស្មើ ។ បទថា **ភីរុទស្សនា** បានដល់ មើលគួរខ្លាច គឺមានអាការគួរខ្លាច ។ បាលីថា **ភារុទស្សនា** ដូច្នេះក៏មាន អធិប្បាយថាឃើញគួរខ្លាចក្រៃពេក គឺមិនគួរមើលព្រោះមានពណ៌សម្បុរគួរខ្ពើមជាដើម ។ បទថា **បិង្គលា** ប្រែថា មានភ្នែកលឿង ។ បទថា **កឡារា** ប្រែថា ជា

អ្នកចង្កូមដូចជ្រូក ។ បទថា **ន តំ មញ្ញាមិ មានុសឹ** សេចក្តីថា ខ្ញុំមិនសម្គាល់នាងជាស្រីមនុស្ស អធិប្បាយថា តែខ្ញុំសម្គាល់នាងថាជាស្រីប្រេត ។ ស្រីប្រេតបានស្តាប់ដូច្នោះ កាលនឹងប្រកាសខ្លួន ទើបពោលគាថាថា

ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អហំ នន្ទា នន្ទិសេន** សេចក្តីថា នែនន្ទិសេន ខ្ញុំឈ្មោះនន្ទា ។ បទថា **ភរិយា តេ បុរេ អហុំ** សេចក្តីថា ក្នុងជាតិមុន ខ្ញុំជាភរិយារបស់លោក ។ ខាងមុខអំពីនេះទៅ ឧបាសកក៏សួរថា

ចុះអំពើអាក្រក់ដែលនាងបានធ្វើដោយ កាយ វាចា ចិត្តនោះ តើដូចម្តេចខ្លះ នាងទៅអំពីមនុស្សលោកនេះ កាន់បេតលោក ដោយវិបាកនៃកម្មដូចម្តេចខ្លះ ដូច្នេះ ។

លំដាប់នោះស្រីប្រេតក៏បានឆ្លើយនឹងនន្ទិសេនឧបាសកថា

ខ្ញុំជាស្រីកំណាចផង មានវាចាអាក្រក់ផង ឥតមានសេចក្តីគោរពចំពោះអ្នកផង ខ្ញុំពោលពាក្យអាក្រក់ចំពោះលោក ទើបបានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ។

នន្ទិសេនឧបាសកក៏សួរទៀតថា

បើដូច្នោះ យើងនឹងឲ្យសំពត់បង់កដល់នាង ចូរនាងស្លៀកសំពត់នេះចុះ លុះនាងស្លៀកសំពត់នេះហើយ ចូរមករកយើង

យើងនឹងនាំនាងទៅផ្ទះ នាងទៅដល់ផ្ទះហើយ នឹងបានសំពត់ បាយទឹក បានឃើញនូវបុត្តទាំងឡាយរបស់នាងផងបានឃើញ កូនប្រសាស្រីរបស់នាងផង ។

លំដាប់នោះ ស្រីប្រេតក៏បានពោល ២ គាថាដល់នន្ទិសេនថា

វត្ថុដែលអ្នកបានឲ្យផ្ទាល់ដៃដោយដៃ មិនសម្រេចដល់ខ្ញុំទេ អ្នក ចូរញ៉ាំងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ជាអ្នកប្រាស ចាករាគៈ ជាពហុស្សូត ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំ ក្នុងវេលានោះទើបខ្ញុំនឹងដល់នូវ សេចក្ដីសុខ សម្រេចនូវសេចក្ដីប្រាថ្នាទាំងពួងបាន ដូច្នេះ ។

លំដាប់នោះ ព្រះសង្គីតិកាចារ្យបានពោលគាថា ៤ ថា

លំដាប់នោះ នន្ទសេនឧបាសកនោះ ទទួលថា សាធុ ដូច្នេះ ហើយ បានចាត់ចែងនូវទានដ៏បរិបូណ៌ គឺបាយ ទឹក បង្អែម សំពត់ សេនាសនៈ ឆត្រ គ្រឿងក្រអូប ផ្កាកម្រង ស្បែក ជើងផ្សេងៗ ។ នន្ទសេនឧបាសក ក៏បានញ៉ាំងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូតឲ្យ ឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ហើយឧទ្ទិសទក្ខិណាទាន ដល់នាងនន្ទាប្រេត ។

វិបាកក៏កើតឡើងក្នុងលំដាប់ដែលបានឧទ្ទិស ភោជនាហារ សំពត់ស្លៀក ទាំងទឹកផឹកក៏កើត នេះជាផលនៃទក្ខិណាទាន

លំដាប់នោះ នាងនន្ទាប្រេតនោះ ជាស្រីស្អាតមានសំពត់ស្អាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តម ជាងសំពត់ ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ចូលទៅរកស្វាមី ដូច្នេះ ។

បន្ទាប់អំពីនេះ ជាគាថាពោលឆ្លើយឆ្លងរវាងឧបាសកនិងស្រីប្រេតដូចតទៅនេះថា

ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿង ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក សម្បុរបស់នាងប្រាកដដូច្នោះ ដោយហេតុដូចម្តេច ផលនៃសុចរិតសម្រេចដល់នាង ក្នុងទីនេះ ដោយហេតុដូចម្តេច ភោគទាំងឡាយណានីមួយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវធីតាមានអានុភាពច្រើន យើងសូមសួរនាង នាងកាលកើតជាមនុស្ស បានធ្វើបុញ្ញកម្មដូចម្តេច នាងជាទេវធីតាមានអានុភាពរុងរឿងយ៉ាងនេះ ដោយបុញ្ញកម្មដូចម្តេច ទាំងសម្បុររបស់នាង ក៏ភ្លឺសព្វទិស ។

ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់អ្នកដែលបានឲ្យហើយ ទើបឥតមានភ័យក្នុងទីណាៗឡើយ ។ ម្នាលគហបតីអ្នកព្រមទាំងពួកញាតិទាំងអស់គ្នា ចូររស់នៅអស់កាលយូរ ម្នាល

គហបតី អ្នកខំប្រព្រឹត្តធម៌ ខំឲ្យទានក្នុងលោកនេះ នឹងចូល
ទៅកាន់ទិព្វស្ថានដែលមិនមានសោក មិនមានធូលី ជាទីនៅ
នៃវសវត្តីទេវរាជទាំងឡាយ ។

អ្នកចូរបន្ទោបង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំង
ឫសគល់ចេញ ប្រាសចាកនិន្ទា ចូលទៅកាន់ស្ថានសួគ៌
ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ធានំ វិបុលមាគិរី** សេចក្តីថា អ្នកគប្បីញ៉ាំង
មហាទានឲ្យប្រព្រឹត្តទៅក្នុងខេត្តនៃទក្ខិណេយ្យបុគ្គល ដូចព្រោះពូជ គឺទេយ្យ
ធម៌ ។ ពាក្យដ៏សេស ដូចរឿងបន្ទាប់គ្នាមកនោះឯង ។

ទេពធីតានោះ កាលប្រកាសទិព្វសម្បត្តិរបស់ខ្លួននិងហេតុនៃទិព្វសម្បត្តិ
នោះដល់នន្ទិសេនឧបាសកយ៉ាងនេះហើយ ទើបទៅកាន់លំនៅរបស់ខ្លួនវិញ ។
ឧបាសកប្រាប់រឿងនោះដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក៏ក្រាបទូលដល់
ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុទ្រង់
សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ ទេសនានោះមានប្រយោជន៍
ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា នន្ទាប្រេតចប់

# រឿង មដ្ឋកុណ្ឌលិប្រេត ទី៥

[ ១៧ ] អ្នកមានគ្រឿងប្រដាប់ហើយ មានកុណ្ឌលដ៏រលើង ។បេ។

( ត្រូវមើលក្នុងរឿងទី ៩ នៃសុនិក្ខិត្តវគ្គទី ៧ ក្នុងវិមានវត្ថុចុះ )

ចប់ រឿងមដ្ឋកុណ្ឌលិប្រេតទី ៥ ។

# អដ្ឋកថា មដ្ឋកុណ្ឌលិប្រេត

[ ១៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមដ្ឋកុណ្ឌលីទេវបុត្ត ទើបត្រាស់ពាក្យជាដើមថា **អលង្កតោ មដ្ឋកុណ្ឌលី** ដូច្នេះ ជាដើម ។ ពាក្យដែលគប្បីពោលក្នុងរឿងមដ្ឋកុណ្ឌលីនោះ លោកបានពោលទុកហើយ ក្នុងអដ្ឋកថាមដ្ឋកុណ្ឌលីវិមានវត្ថុ ក្នុងអដ្ឋកថាវិមានវត្ថុ ឈ្មោះបរមត្ថទីបនី ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដូចពោលក្នុងអដ្ឋកថាវិមានវត្ថុនោះឯង ។

ក្នុងទីនេះ រឿងរបស់មដ្ឋកុណ្ឌលីនោះ លោកលើកឡើងទុកក្នុងបាលីវិមានវត្ថុ ព្រោះមដ្ឋកុណ្ឌលីទេវបុត្តជាទេវតាក្នុងវិមានក៏ពិតតែព្រោះ ទេវបុត្រនោះ ដើម្បីកម្ចាត់សេចក្តីសោករបស់អទិន្នបុព្វកព្រាហ្មណ៍ដែលទៅកាន់ឈាបនដ្ឋាន ដើរវិលជុំវិញឈាបនដ្ឋាន ទ្រហោយំ ព្រោះសេចក្តីសោកដល់បុត្ត ទើបកាឡាខ្លួនជាមនុស្ស មានរាងកាយប្រោះព្រំដោយចន្ទន៍លឿង ផ្គងដើមដៃទាំង ២ កន្ទក់កន្ទេញ បង្ហាញខ្លួនដោយអាការដែលត្រូវសេចក្តីទុក្ខគ្របសង្កត់ដូចប្រេត ។ ទោះហៅថាប្រេតដោយអមក៏ហៅបាន ព្រោះប្រាស

ចាកអត្តភាពមនុស្ស ដូច្នោះ គប្បីឃើញថា រឿងរបស់មដ្ឋកុណ្ឌលីនោះលោក
លើកឡើងទុកក្នុងបាលីបេតវត្ថុ ។

## អដ្ឋកថា មដ្ឋកុណ្ឌលីប្រេតចប់

# រឿង កណ្ហាប្រេត ទី៦

[ ១៨ ] ( រោហិណេយ្យអាមាត្យក្រាបទូលថា ) បពិត្រព្រះកណ្ហៈ ព្រះអង្គផ្ទំធ្វើអ្វី សូមព្រះអង្គក្រោកឡើង ប្រយោជន៍អ្វីដល់ព្រះអង្គដោយការផ្ទំ ឥឡូវនេះខ្យល់កំពុងតែកម្រើកឡើងដល់ព្រះរាជកនិដ្ឋដែលដូចជាហឫទ័យនឹងចក្ខុខាងស្តាំរបស់ព្រះអង្គ បពិត្រព្រះអង្គមានព្រះកេសាល្អ ឃដបណ្ឌិតកំពុងតែរវើរវាយ ។

ព្រះបាទកេសវៈ ទ្រង់បានស្តាប់ពាក្យនោះ របស់រោហិណេយ្យអាមាត្យនោះហើយក៏ស្ទុតព្រះហឫទ័យ ទ្រង់ក្រោកចាកក្រឡាព្រះបន្ទំហើយ ទ្រង់ទន្ទឹះខ្សឹកខ្សួល ព្រោះសេចក្តីសោកចំពោះព្រះកនិដ្ឋ ។

អ្នកមានសភាពជាមនុស្សឆ្កួតទេដឹង បានជាត្រាច់ទៅសព្វស្រុកទ្វារកនេះហើយស្រែកថាទន្សាយៗដូច្នេះ អ្នកចង់បានទន្សាយអ្វី ទន្សាយមាស ទន្សាយកែវមណី ទន្សាយទង់ដែង ឬមួយទន្សាយប្រាក់ ទន្សាយស័ង្ខ សិលា កែវ-ប្រពាឡ យើងនឹងប្រើគេឲ្យធ្វើទន្សាយឲ្យអ្នក ពុំនោះសោតទេ ពួកទន្សាយដទៃដែលត្រាច់ស៊ីស្មៅក្នុងព្រៃក៏មាន យើងនឹងនាំយកទន្សាយទាំងនោះមកឲ្យអ្នក តើអ្នកចង់បានទន្សាយដូចម្តេច ។

ទន្សាយទាំងឡាយណាដែលអាស្រ័យនៅលើផែនដី ខ្ញុំព្រះអង្គមិនប្រាថ្នាចង់បានទន្សាយទាំងនុ៎ះទេ ខ្ញុំព្រះអង្គប្រាថ្នាចង់បានតែទន្សាយអំពីដួងព្រះចន្ទ បពិត្រព្រះអង្គមានព្រះកេសាខ្មៅ សូមព្រះអង្គនាំយកទន្សាយនោះមកឲ្យខ្ញុំ ។

ម្នាលកនិដ្ឋជាញាតិ អ្នកនោះនឹងក្ស័យជីវិតដ៏ថ្លៃថ្លា អ្នកប្រាថ្នារបស់ដែលមិនគួរប្រាថ្នា ព្រោះអ្នកប្រាថ្នាទន្សាយអំពីដួងព្រះចន្ទ ។

បពិត្រព្រះអង្គមានព្រះកេសាខ្មៅ បើព្រះអង្គ ទ្រង់ជ្រាបយ៉ាងនេះហើយ គួរតែព្រះអង្គប្រៀនប្រដៅអ្នកដទៃបាន ចុះក្នុងថ្ងៃនេះ ហេតុដូចម្តេចបានជាព្រះអង្គ ទ្រង់ព្រះកន្សែងនឹងបុត្តដែលធ្វើមរណកាលក្នុងកាលមុន ។ ( ពាក្យថា ) បុត្តរបស់យើង កើតមកហើយកុំស្លាប់ទៅវិញ ពាក្យនោះ មនុស្សនឹងទេវតាមិនដែលបានឮ បានស្តាប់ឡើយ ព្រះអង្គគប្បីបាននូវរបស់ដែលមិនត្រូវបានអំពីទីណា បពិត្រព្រះអង្គមានព្រះកេសាខ្មៅ ព្រះអង្គទ្រង់សោយសោកចំពោះបុគ្គលដែលទៅកាន់បរលោកហើយធ្វើអ្វី ព្រះអង្គមិនអាចដើម្បីនឹងនាំយកមកវិញបានដោយមន្តដោយមូលភេសជ្ជៈ ដោយឱសថ ឬដោយទ្រព្យឡើយ ។ ពួកជនអ្នកមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើនក្តី ពួកក្សត្រដែលនៅក្នុងរដ្ឋមណ្ឌល មានទ្រព្យនិងស្រូវដ៏ច្រើនក្តី ជនទាំងនោះក៏គង់មិនរួចអំពីជរានិងមរណៈឡើយ ។ ក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រក្តី ចណ្ឌាលក្តី បុក្កុសៈក្តី ជនទាំងនុ៎ះ ផ្សេងគ្នាដោយជាតិ ជនទាំងនោះឯងក៏មិនរួចអំពីជរានិងមរណៈ ។ ជនទាំងឡាយណា ប្រព្រឹត្តគឺស្វាធ្យាយមន្តប្រកបដោយអង្គ ៦ ដែលព្រហ្មបានគិតហើយ ជនទាំងនុ៎ះផ្សេងគ្នាដោយវិជ្ជា ជនទាំងនោះឯង ក៏មិនរួចអំពីមរណៈដែរ ។ ម្យ៉ាងទៀត ពួកឥសីណាជាអ្នករម្ងាប់ ជាអ្នកសង្រួមកាយនិងវាចា មានព្យាយាមដុតកម្តៅកិលេស ពួកឥសី ដែលមានព្យាយាមដុតកម្តៅកិលេសនោះឯង ក៏រមែងលះបង់សរីរៈទៅតាមកាល ។ ព្រះអរហន្តទាំងឡាយ អ្នកមានខ្លួនចម្រើនហើយមានកិច្ចបានធ្វើស្រេចហើយ មានអាសវៈអស់ហើយ រមែងដាក់ចុះនូវរាងកាយនេះព្រោះ

អស់បុណ្យនិងបាប ។

ប្អូនញុំាងសេចក្តីក្រវល់ក្រវាយទាំងពួងរបស់យើង ដែលក្តៅដោយភ្លើង គឺសេចក្តីសោកឲ្យរលត់ ដូចបុគ្គលយកទឹកទៅស្រោចស្រពភ្លើង ដែលឆេះផ្ទាំងខ្លាញ់ ។ សរគឺសេចក្តីសោកដែលអាស្រ័យនៅក្នុងហឫទ័យរបស់យើង អ្នកក៏បានដកចេញហើយ អ្នកបានបន្ទោបង់នូវសេចក្តីសោកព្រោះកូន របស់យើងដែលមានសេចក្តីសោកគ្របសង្កត់ហើយ យើងនោះមានសរ គឺសេចក្តីសោកបានដកចេញហើយជាអ្នកត្រជាក់ហើយ មានទុក្ខរំលត់ហើយ ។ យើងលែងសោក លែងយំហើយ ព្រោះបានស្តាប់ភាសិតរបស់អ្នក ជនទាំងឡាយណាប្រកបដោយបញ្ញា ជាអ្នកអនុគ្រោះ ជនទាំងនោះធ្វើយ៉ាងនេះ ឃដបណ្ឌិតបានញុំាងបងច្បង ឲ្យត្រឡប់ចាកសេចក្តីសោក អាមាត្យទាំងឡាយដែលជាអ្នកបម្រើរបស់ព្រះរាជាអង្គណា ក៏រមែងប្រាកដដូច្នោះ ដូចជាឃដបណ្ឌិតបានញុំាងបងច្បងឲ្យប្រព្រឹត្តទៅតាមសុភាសិត ។

## ចប់ រឿងកណ្ហប្រេតទី ៦ ។

# អដ្ឋកថា កណ្ហាប្រេត

[ ១៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ដែលកូនស្លាប់ ទើបត្រាស់ព្រះគាថានេះមានពាក្យផ្តើមថា **ឧដ្ឋេហិ កណ្ហ កឹ សេសិ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី មានបុត្តរបស់ឧបាសកម្នាក់ ធ្វើកាលកិរិយាហើយ ។ ឧបាសកនោះ ដល់ព្រមដោយសរ គឺសេចក្តីសោក ព្រោះការស្លាប់របស់កូននោះ មិនងូតទឹក មិនបរិភោគអាហារ មិនចាត់ចែងការងារ មិនទៅកាន់ទីឧបដ្ឋាករបស់ព្រះពុទ្ធ រវើរវាយតែម្យ៉ាង ពោលថា បាជាកូនសម្លាញ់ បាលះបង់ឪពុកទៅណាហើយ ។ ក្នុងវេលាទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់ឧបាសកនោះ ស្អែកឡើង ចោមរោមដោយភិក្ខុសង្ឃ ទ្រង់ចារិកបិណ្ឌបាត កាន់ក្រុងសាវត្ថី ទ្រង់សោយព្រះក្រយាហារស្រេចហើយ ទើបទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ។ ចំណែកព្រះអង្គមានព្រះអានន្ទត្ថេរជាបច្ឆាសមណៈ បានយាងទៅកាន់ទ្វារផ្ទះរបស់ឧបាសកនោះ ។ មនុស្សទាំងឡាយក៏ប្រាប់ដល់ឧបាសកថា ព្រះសាស្តាយាងមកដល់ហើយ ។ លំដាប់នោះ មនុស្សក្នុងផ្ទះរបស់ឧបាសកនោះ ក៏នាំគ្នាតាក់តែងសេនាសនៈ ត្រង់ទ្វារផ្ទះ ហើយនិមន្តឲ្យព្រះសាស្តាប្រថាប់គង់ គ្រាហ៍ឧបាសកចូលទៅគាល់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ឃើញឧបាសកនោះអង្គុយក្នុងចំណែកម្ខាង ទើបត្រាស់សួរថា ម្នាលឧបាសក អ្នកមានសេចក្តីសោកឬ្វ កាលឧបាសកក្រាបទូលឲ្យទ្រង់ជ្រាប ទើបត្រាស់ថា ម្នាលឧបាសក បុរាណកបណ្ឌិតទាំងឡាយស្តាប់ពាក្យរបស់បណ្ឌិតទាំងឡាយហើយ

មិនសោយសោកដល់បុត្តដែលស្លាប់ទៅ ដូច្នេះហើយ កាលឧបាសកនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ក្នុងក្រុងទ្វារវតី មានព្រះរាជាជាបងប្អូននឹងគ្នា ១០ អង្គ គឺព្រះបាទវាសុទេព ១ ពលទេព ១ ចន្ទទេព ១ សុរិយទេព ១ អគ្គិទេព ១ វរុណទេព ១ អជ្ជុន ១ បជ្ជុន ១ ឃដបណ្ឌិត ១ និងអង្កុរ ១ ។ ក្នុងស្តេចទាំងនោះ ឱរសជាទីស្រឡាញ់របស់ព្រះបាទវាសុទេពមហារាជ បានសោយទិវង្គត ព្រោះហេតុនោះ ព្រះរាជាក៏ត្រូវសេចក្តីសោកគ្របសង្កត់ ទ្រង់លះព្រះរាជករណីយកិច្ចគ្រប់យ៉ាង ឱបមែគ្រែ ទ្រង់ផ្តូរផ្តើរវាយ ។ ក្នុងកាលនោះ ឃដបណ្ឌិត ទ្រង់ត្រិះរិះថា វៀរអាត្មាអញហើយ អ្នកដទៃដែលឈ្មោះថា អាចដោះនូវសេចក្តីសោកបងប្រុសរបស់អញ រមែងមិនមាន អញនឹងកម្ចាត់សេចក្តីសោករបស់បងប្រុសអញដោយឧបាយ ។ ឃដបណ្ឌិតក៏ក្លែងធ្វើឆ្កួតសម្លឹងមើលអាកាស ត្រាច់ទៅពេញព្រះនគរ ពោលថា ចូរលោកឲ្យទន្សាយដល់យើង ចូរលោកឲ្យទន្សាយដល់យើង ។ អ្នកនគរទាំងមូល នាំគ្នាភ្ញាក់ផ្អើលថា ឃដបណ្ឌិតឆ្កួតហើយ ។

ពេលនោះ អាមាត្យឈ្មោះថា រោហិណេយ្យទៅគាល់ព្រះបាទវាសុទេព កាលនឹងសន្ទនាជាមួយព្រះបាទវាសុទេព ក៏ពោលគាថានេះថា

បពិត្រព្រះកណ្ហៈ ព្រះអង្គផ្ទំធ្វើអ្វី សូមព្រះអង្គក្រោកឡើង
ប្រយោជន៍អ្វីដល់ព្រះអង្គដោយការផ្ទំ ឥឡូវនេះ ខ្យល់កំពុង
តែកម្រើកឡើងដល់ព្រះរាជកនិដ្ឋដែលដូចជាហឫទ័យ និងចក្ខុ

ខាងស្តាំរបស់ព្រះអង្គ បពិត្រព្រះអង្គមានព្រះកេសាល្អ យើង
បណ្ឌិតកំពុងតែរវើរវាយ ដូច្នេះ ។

ក្នុងបទទាំងនោះអាមាត្យហៅព្រះបាទវាសុទេពដោយគោត្តថា កណ្ហៈ ។ បទថា **កោ អត្ថោ សុបនេន តេ** សេចក្តីថា ការចម្រើនអ្វីនឹងមានដល់ព្រះអង្គដោយការផ្ទំ ។ បទថា **សកោ ភាតា** បានដល់ ប្អូនប្រុសរួមឧទរ ។ បទថា **ហទយំ ចក្ខុ ច ទក្ខិណំ** សេចក្តីថា ដូចដួងហទយៈនិងព្រះនេត្រខាងស្តាំ ។ បទថា **តស្ស វាតា ពលីយន្តិ** សេចក្តីថា ខ្យល់ គឺរោគឆ្កួតកើតឡើងដល់ព្រះភាតា ដើររវើរវាយ មានកម្លាំងដ៏ខ្លាំងក្លាកម្រើក គឺគ្របសង្កត់ ។ បទថា **សសំ ជប្បតិ** សេចក្តីថា រវើរវាយថា ចូរឲ្យទន្សាយដល់យើង ។ បទថា **កេសវ** បានឮថា ព្រះបាទវាសុទេពនោះ គេហៅថា **កេសវ** ព្រោះមានសក់ល្អ ព្រោះហេតុនោះ ទើបគេហៅព្រះអង្គដោយព្រះនាម ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទ្រង់សម្តែងនូវភាពដែលព្រះបាទវាសុទេពបានស្តាប់ពាក្យរបស់អាមាត្យនោះហើយ ទ្រង់ក្រោកឡើងចាកទីបន្ទំ ទើបត្រាស់គាថានេះថា

ព្រះបាទកេសវៈ ទ្រង់បានស្តាប់ពាក្យនោះរបស់រោហិណេយ្យ
អាមាត្យនោះហើយក៏ស្ទុតព្រះហឫទ័យ ទ្រង់ក្រោកចាកក្រឡា
ព្រះបន្ទំហើយ ទ្រង់ទង្គឹះខ្សឹកខ្សួល ព្រោះសេចក្តីសោកចំពោះ
ព្រះកនិដ្ឋ ដូច្នេះ ។

ព្រះរាជាក្រោកឡើងហើយ ប្រញាប់ចុះអំពីប្រាសាទ ហើយយាងទៅរកយជបណ្ឌិត ចាប់ដៃទាំង ២ របស់យជបណ្ឌិតយ៉ាងមាំ កាលនឹងចរចា ក៏ពោលគាថា ៣ ថា

អ្នកមានសភាពជាមនុស្សឆ្កួតទេដឹង បានជាត្រាច់ទៅសព្វស្រុក ទ្វារកនេះ ហើយស្រែកថាទន្សាយៗដូច្នេះ អ្នកចង់បានទន្សាយអ្វី ទន្សាយមាស ទន្សាយកែវមណី ទន្សាយទង់ដែង ឬមួយទន្សាយប្រាក់ ទន្សាយសង្ខ សិលា កែវប្រពាឡ យើងនឹងប្រើគេឲ្យធ្វើទន្សាយឲ្យអ្នក ពុំនោះសោតទេ ពួកទន្សាយដទៃដែលត្រាច់ស៊ីស្មៅក្នុងព្រៃក៏មាន យើងនឹងនាំយកទន្សាយទាំងនោះមកឲ្យអ្នក តើអ្នកចង់បានទន្សាយដូចម្តេច ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧម្មត្តករូបោវ** ប្រែថា ដូចមនុស្សឆ្កួត ។ បទថា **កេវលំ** ប្រែថា ទាំងមូល ។ បទថា **ទ្វារកំ** បានដល់ ត្រាច់ទៅពេញទ្វារវតីនគរ ។ បទថា **សសោ សសោតិ លបសិ** សេចក្តីថា រវើរវាយថាទន្សាយ ទន្សាយ ។ បទថា **សោវណ្ណមយំ** ប្រែថា សម្រេចដោយមាស ។ បទថា **លោហមយំ** ប្រែថា សម្រេចដោយលោហៈ គឺទង់ដែង ។ បទថា **រូបិយមយំ** ប្រែថា សម្រេចដោយប្រាក់ ។ អ្នកប្រាថ្នាវត្ថុណា ក៏ចូរប្រាប់មកចុះ ។ កាលបើដូច្នោះ អ្នកសោយសោកព្រោះអ្វី ។ ព្រះបាទវាសុទេពអញ្ជើញយជបណ្ឌិតដោយទន្សាយថា ទន្សាយសូម្បីដទៃដែលត្រាច់រកស៊ីក្នុងព្រៃ ក៏មានក្នុងព្រៃ យើងនឹងនាំទន្សាយនោះមកឲ្យដល់អ្នក ។ នែអ្នកមាន

មុខដ៏ចម្រើន អ្នកប្រាថ្នាទ្រព្យដូចម្តេច ក៏ចូរប្រាប់មកចុះ ដូច្នេះ ដោយបំណងថា យជបណ្ឌិតត្រូវការទ្រព្យ យជបណ្ឌិតបានស្តាប់ដូច្នោះ ទើបពោលគាថាថា

ទ្រព្យទាំងឡាយណាដែលអាស្រ័យនៅលើផែនដី ខ្ញុំព្រះអង្គមិនប្រាថ្នាចង់បានទ្រព្យទាំងនុ៎ះទេ ខ្ញុំព្រះអង្គប្រាថ្នាចង់បានតែទ្រព្យអំពីដួងព្រះចន្ទ បពិត្រព្រះអង្គមានព្រះកេសាខ្មៅសូមព្រះអង្គនាំយកទ្រព្យនោះមកឲ្យខ្ញុំ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឱហារ** បានដល់ ទ្រង់ឲ្យនាំចុះមក ។ ព្រះរាជាកាលទ្រង់ស្តាប់ដូច្នោះ ទើបដល់នូវទោមនស្សថា ព្រះភាតារបស់អញឆ្កួតទៅហើយដោយឥតសង្ស័យ ទើបត្រាស់គាថាថា

ម្នាលកនិដ្ឋជាញាតិ អ្នកនោះនឹងក្ស័យជីវិតដ៏ថ្លៃថ្លា អ្នកប្រាថ្នារបស់ដែលមិនគួរប្រាថ្នា ព្រោះអ្នកប្រាថ្នាទ្រព្យអំពីដួងព្រះចន្ទ ដូច្នេះ ។

ព្រះបាទកេសវៈ ហៅប្អូនប្រុសថា ជាញាតិក្នុងព្រះគាថានេះ ។ ក្នុងព្រះគាថាមានអធិប្បាយដូច្នេះថា ញាតិជាទីស្រឡាញ់របស់យើង ដែលប្រាថ្នាវត្ថុមិនគប្បីប្រាថ្នាប្រហែលជាលះបង់ជីវិតដែលគួរត្រេកអររបស់ខ្លួនដោយពិត ។

យជបណ្ឌិតបានស្តាប់ព្រះតម្រាស់របស់ព្រះរាជា ក៏ឈរស្ងៀម កាលនឹងសម្តែងសេចក្តីនេះថា បពិត្របងប្រុស ទ្រង់កាលដឹងថា ខ្ញុំប្រាថ្នាទ្រព្យអំពីព្រះចន្ទ កាលមិនបានទ្រព្យនោះនឹងអស់ជីវិត ព្រោះហេតុអ្វី ទ្រង់មិន

បានឱរសដែលស្លាប់ទៅហើយ ក៏នៅតែសោយសោក ទើបពោលគាថាថា

បពិត្រព្រះអង្គមានព្រះកេសាខ្មៅ បើព្រះអង្គ ទ្រង់ជ្រាបយ៉ាង
នេះហើយ គួរតែព្រះអង្គប្រៀនប្រដៅអ្នកដទៃបាន ចុះក្នុងថ្ងៃ
នេះ ហេតុដូចម្តេច បានជាព្រះអង្គ ទ្រង់ព្រះកន្សែងនឹងបុត្ត
ដែលធ្វើមរណកាលក្នុងកាលមុន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឯវញ្ចេ កណ្ហ ជានាសិ** សេចក្តីថា បពិត្រ
កណ្ហមហារាជបងប្រុស បើទ្រង់ជ្រាបយ៉ាងនេះថា ឈ្មោះថាវត្ថុដែលមិនគប្បី
បាន ក៏មិនគប្បីប្រាថ្នា ។ បទថា **យថញ្ញំ** សេចក្តីថា ព្រះជេដ្ឋាជីងយ៉ាង
នេះ កុំធ្វើជំទាស់នឹងវត្ថុដែលទ្រង់ប្រៀនប្រដៅអ្នកដទៃ ។ បទថា **កស្មា បុរេ
មតំ បុត្តំ** សេចក្តីថា កាលបើដូច្នេះ ព្រោះហេតុអ្វី ក្នុងថ្ងៃនេះ ទ្រង់នៅតែ
សោយសោកដល់បុត្តដែលស្លាប់ទៅក្នុងទីបំផុត ៤ ខែ រាប់ទាំងខែនេះ ។

ឃដបណ្ឌិត ឈរក្នុងវាងផ្លូវនោះទូលថា ជំបូងខ្ញុំប្រាថ្នាវត្ថុដែលប្រាកដ
យ៉ាងនេះ ឯទ្រង់សោយសោកដើម្បីវត្ថុដែលមិនប្រាកដ កាលសម្តែងធម៌
ដល់ព្រះរាជា ទើបពោលគាថា ២ ថា

( ពាក្យថា ) បុត្តរបស់យើង កើតមកហើយកុំស្លាប់ទៅវិញ
ពាក្យនោះ មនុស្សនិងទេវតាមិនដែលបានឮបានស្តាប់ឡើយ
ព្រះអង្គគប្បីបានទូវរបស់ដែលមិនត្រូវបាន អំពីទីណា បពិត្រ
ព្រះអង្គមានព្រះកេសាខ្មៅ ព្រះអង្គទ្រង់សោយសោក ចំពោះ
បុគ្គលដែលទៅកាន់បរលោកហើយធ្វើអ្វី ព្រះអង្គមិនអាចដើម្បី

នឹងនាំយកមកវិញបានដោយមន្ត ដោយមូលភេសជ្ជៈ ដោយ
ឱសថ ឬដោយទ្រព្យឡើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យំ** សេចក្តីថា នែបងប្រុស មនុស្សនិងទេវតា មិនគប្បីបាន គឺមិនអាចបានតាមដែលទ្រង់ប្រាថ្នាថា សូមបុត្តរបស់អញកើតមកយ៉ាងនេះហើយកុំស្លាប់ទៅឡើយ អធិប្បាយថា សេចក្តីប្រាថ្នានោះ ទ្រង់នឹងបានអំពីទីណា គឺទ្រង់អាចបានដោយហេតុអ្វី ព្រោះហេតុដែលឈ្មោះថា វត្ថុដែលមិនគួរបាននេះ ជាវត្ថុដែលមិនគួរនឹងបាន ។

បទថា **មន្តា** ប្រែថា ដោយការប្រកបមន្ត ។ បទថា **មូលភេសជ្ជា** ប្រែថា ដោយឫសថ្នាំ ។ បទថា **ឱសធេហិ** បានដល់ ឱសថច្រើនប្រភេទ ។ បទថា **ធនេន វា** បានដល់ ដោយទ្រព្យដែលរាប់បាន ១០០ កោដិ លោកពោលអធិប្បាយដូច្នេះថា បុគ្គលណាមួយ មិនអាចនាំឱរសដែលលះលោកទៅហើយ ដែលទ្រង់សោយសោកនោះមកវិញ ដោយការប្រកបមន្តជាដើមយ៉ាងនោះ ។

យជបណ្ឌិត កាលនឹងសម្តែងទៀតថា បពិត្របងប្រុស ឈ្មោះថា ការស្លាប់នេះ បុគ្គលណាក៏មិនអាចហាមបានដោយទ្រព្យ ដោយជាតិ ដោយវិជ្ជា ដោយសីល ឬដោយការវនាបានឡើយ ទើបសម្តែងធម៌ដល់ព្រះរាជាដោយគាថា ៥ ថា

ពួកជនអ្នកមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើនក្តី ពួក
ក្សត្រដែលនៅក្នុងរដ្ឋមណ្ឌល មានទ្រព្យនិងស្រូវដ៏ច្រើនក្តីជន

ទាំងនោះ ក៏គង់មិនរួចអំពីជរានិងមរណៈឡើយ ។ ក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រក្តី ចណ្ឌាលក្តី បុក្កុសៈក្តី ជនទាំងនុ៎ះផ្សេងគ្នាដោយជាតិ ជនទាំងនោះឯង ក៏មិនរួចអំពីជរានិងមរណៈ ។ ជនទាំងឡាយណា ប្រព្រឹត្តគឺស្វាធ្យាយមន្តប្រកបដោយអង្គ ៦ ដែលព្រហ្មបានគិតហើយ ជនទាំងនុ៎ះផ្សេងគ្នាដោយវិជ្ជា ជនទាំងនោះឯងក៏មិនរួចអំពីមរណៈដែរ ។ម្យ៉ាងទៀត ពួកឥសីណា ជាអ្នករម្ងាប់ ជាអ្នកសង្រួមកាយនិងវាចា មានព្យាយាមដុតកម្តៅកិលេស ពួកឥសីដែលមានព្យាយាមដុតកម្តៅកិលេសនោះឯង ក៏រមែងលះបង់សរីរៈទៅតាមកាល ។ ព្រះអរហន្តទាំងឡាយ អ្នកមានខ្លួនចម្រើនហើយ មានកិច្ចបានធ្វើស្រេចហើយ មានអាសវៈអស់ហើយ រមែងដាក់ចុះនូវរាងកាយនេះ ព្រោះអស់បុណ្យនិងបាប ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មហទ្ធនា** បានដល់ ឈ្មោះថា ជាអ្នកមានទ្រព្យច្រើន ព្រោះមានទ្រព្យកប់ទុកនោះឯងច្រើន ។ បទថា **មហាភោគា** បានដល់ ប្រកបដោយភោគសម្បត្តិច្រើន ដូចគ្នានឹងភោគសម្បត្តិរបស់ទេវតា បទថា **រដ្ឋវន្តោ** បានដល់ មានដែនច្រើន ។ បទថា **បហូតធនធញ្ញាសេ** បានដល់ មានទ្រព្យនិងធញ្ញាហាររាប់មិនអស់ ដោយទ្រព្យនិងធញ្ញាហារដែលត្រូវប្រើប្រាស់ជាប្រចាំ ដែលកប់ទុកដើម្បីប្រើប្រាស់ដល់ទៅ ៣ ឆ្នាំ ឬ ៤ ឆ្នាំ ។ បទថា **តេបិ នោ អជរាមរា** សេចក្តីថា ក្សត្រ មានព្រះបាទមន្ធាតុ

និងព្រះបាទមហាសុទស្សនៈជាដើម ជាអ្នកមានសម្បត្តិច្រើនយ៉ាងនោះជាអ្នក មិនចាស់ មិនស្លាប់ មិនមានឡើយ គឺតាំងនៅក្នុងមាត់មរណៈដោយពិតនោះ ឯង ។

បទថា **ឃតេ** បានដល់ ក្សត្រតាមដែលពោលហើយជាដើម ។ បទថា **អញ្ញោ** បានដល់ ជនឯណានីមួយ មានអម្ពដ្ឋមាណពជាដើម ជាអ្នករស់នៅ យ៉ាងនោះ ។ បទថា **ជាតិយា** បានដល់ ជាអ្នកមិនចាស់ មិនស្លាប់ ព្រោះ ជាតិរបស់ខ្លួនជាហេតុ មិនមានឡើយ ។

បទថា **មន្តំ** បានដល់ វេទ ។ បទថា **បរិវត្តេន្តិ** បានដល់ រមែងស្វា-ធ្យាយនិងរមែងប្រាប់ ម្យ៉ាងទៀត បទថា **បរិវត្តេន្តិ** បានដល់ រាយវេទ ធ្វើ នូវការបូជាភ្លើងនិងប្រកបមន្ត ។ បទថា **ឆឡង្គំ** សេចក្តីថា ប្រកបដោយអង្គ ៦ ពោលគឺសិក្ខា ( បញ្ចេញសំឡេងអានត្រូវបង្វាក់ ស្ទាត់និងពីរោះ ) ១ **កប្ប** ( បានដល់ ស្គាល់បែបផែននៃកិច្ចពិធីផ្សេងៗ ) ១ **និរុត្តិ** ( បាន ដល់ ស្គាល់មូលសព្ទនិងពាក្យប្រែសព្ទ ) ១ **វេយ្យាករណា** ( បានដល់ ចេះតម្រាភាសា ) ១ **ជោតិសាស្ត្រ** ( បានដល់ ស្គាល់ផ្កាយ ស្គាល់ឫក្ស និងចងដួងជតា ) ១ **ចន្ទោវិចិតិ** ( បានដល់ ចេះគណៈឆន្ទនិងចងគាថា បាន ) ១ ។ បទថា **ព្រហ្មចិន្តិតំ** បានដល់ ព្រហ្មជាអ្នកគិត គឺពោលដើម្បី ប្រយោជន៍ដល់ពួកព្រាហ្មណ៍ ។ បទថា **វិជ្ជាយ** បានដល់ ដែលប្រកបដោយ វិជ្ជាដូចព្រហ្ម អធិប្បាយថា សូម្បីលោកទាំងនោះនឹងមិនចាស់ មិនស្លាប់មិន មានឡើយ ។

បទថា **ឥសយោ** សេចក្តីថា ឈ្មោះថា ឥសី ព្រោះអត្ថថា ស្វែងរកវត្តដែលប្រព្រឹត្តប្រចាំនិងវត្ត ដែលប្រព្រឹត្តតាមកាលកំណត់ជាដើម និងបដិកូលសញ្ញាជាដើម ។ បទថា **សន្តា** បានដល់ ស្ងប់កាយវាចាជាសភាវៈ ។ បទថា **សញ្ញតត្តា** បានដល់ មានចិត្តសង្រួមដោយការសង្រួមកិលេស មានរាគៈជាដើម ។ ឈ្មោះថា **តបស្សិនោ** ព្រោះមានតបៈ ពោលគឺធ្វើកាយឲ្យក្តៅក្រហាយ ។ម្យ៉ាងទៀត បទថា **តបស្សិនោ** បានដល់ ជាអ្នកសង្រួម ។ ដោយពាក្យថា **តបស្សិនោ** នោះ លោកសម្តែងថា ជាអ្នកអាស្រ័យតបៈយ៉ាងនោះ និងអ្នកប្រាថ្នាដើម្បីនឹងរួចផុតចាកសរីរៈ ជាអ្នកសង្រួម រមែងលះសរីរៈបាននោះឯង ។ ម្យ៉ាងទៀត បទថា **ឥសយោ** ឈ្មោះថា **ឥសយ** ព្រោះអត្ថថា ស្វែងរកអធិសីលសិក្ខាជាដើម ឈ្មោះថា **សន្តា** ព្រោះចូលទៅស្ងប់បាបធម៌ដែលជាបដិបក្ខចំពោះអធិសីលសិក្ខានោះ ក៏ដើម្បីជាប្រយោជន៍ដល់អធិសីលសិក្ខានោះ ឈ្មោះថា **សញ្ញតត្តា** ព្រោះសង្រួមចិត្ត ក្នុងអារម្មណ៍តែមួយ ឈ្មោះថា **តបស្សិនោ** ព្រោះមានសេចក្តីព្យាយាមជាគ្រឿងដុតនូវបាបដោយប្រកបសេចក្តីព្យាយាមប្រពៃ ។ បណ្ឌិតគប្បីប្រកបសេចក្តីថា អ្នកមានសេចក្តីព្យាយាម ជាគ្រឿងប្រកប ឈ្មោះថា **តបស្សិនោ** ព្រោះធ្វើកិលេសមានរាគៈជាដើមឲ្យក្តៅក្រហាយ ។ បទថា **ភាវិតត្តា** បានដល់ ដែលមានចិត្តអប់រំហើយដោយកម្មដ្ឋានភាវនាដែលមានសច្ចៈ ៤ ជាអារម្មណ៍ ។

កាលយជបណ្ឌិតសម្តែងធម៌យ៉ាងនេះ ព្រះរាជាបានស្តាប់ដូច្នោះ ជាអ្នកប្រាសចាកសរ គឺសេចក្តីសោក មានចិត្តជ្រះថ្លា កាលទឹងសរសើរយជបណ្ឌិតទើបពោលគាថាដ៏សេសថា

អ្នកញុំាងសេចក្តីក្រវល់ក្រវាយទាំងពួងរបស់យើង ដែលក្តៅដោយភ្លើង គឺសេចក្តីសោកឲ្យរលត់ ដូចបុគ្គលយកទឹកទៅស្រោចស្រពភ្លើងដែលឆេះឆ្នាំងខ្លាញ់ ។ សរគឺសេចក្តីសោកដែលអាស្រ័យនៅក្នុងហឫទ័យរបស់យើងអ្នកក៏បានដកចេញហើយ អ្នកបានបន្ទោបង់នូវសេចក្តីសោក ព្រោះកូនរបស់យើង ដែលមានសេចក្តីសោកគ្របសង្កត់ហើយ យើងនោះមានសរ គឺសេចក្តីសោកបានដកចេញហើយ ជាអ្នកត្រជាក់ហើយមានទុក្ខរំលត់ហើយ ។ យើងលែងសោកលែងយំហើយ ព្រោះបានស្តាប់ភាសិតរបស់អ្នក ជនទាំងឡាយណា ប្រកបដោយបញ្ញាជាអ្នកអនុគ្រោះ ជនទាំងនោះធ្វើយ៉ាងនេះ យជ-បណ្ឌិត បានញុំាងបងច្បងឲ្យត្រឡប់ចាកសេចក្តីសោក អា-មាត្យទាំងឡាយ ដែលជាអ្នកបម្រើរបស់ព្រះរាជាអង្គណា ក៏រមែងប្រាកដដូច្នោះ ដូចជាយជបណ្ឌិត បានញុំាងបងច្បងឲ្យប្រព្រឹត្តទៅតាមសុភាសិត ។

ក្នុងបទទាំងនោះ បទថា **យថោ ជេដ្ឋំវ ភាតរំ** សេចក្តីថា ដូចយជ-បណ្ឌិតធ្វើព្រះជេដ្ឋារបស់ខ្លួនដែលត្រូវសេចក្តីសោក ព្រោះបុត្តស្លាប់ទៅគ្រប

សង្កត់ ឲ្យផុតចាកសេចក្ដីសោកព្រោះបុត្តនោះ ដោយភាពដែលខ្លួនជាអ្នកឈ្លាសក្នុងឧបាយនិងដោយធម្មកថា យ៉ាងណា សូម្បីជនដទៃអ្នកមានបញ្ញា មានការអនុគ្រោះក៏ដូច្នោះ រមែងធ្វើឧបការៈដល់ញាតិទាំងឡាយ ។

បទថា **យស្ស ឯតាទិសា ហោន្តិ** នេះជាគាថានៃព្រះសព្វញ្ញូ ។ អត្ថនៃគាថានោះ មានអធិប្បាយដូចតទៅនេះថា យជបណ្ឌិតរមែងជួយស្រោចស្រង់ គឺទូន្មានព្រះបាទវាសុទេពដែលសេចក្ដីសោកព្រោះបុត្តគ្របសង្កត់ដោយពាក្យដែលជាសុភាសិត ដើម្បីកម្ចាត់សេចក្ដីសោកដោយប្រការណា គឺដោយហេតុណា ។ អាមាត្យជាបណ្ឌិតក៏ដូច្នោះ ដែលបុគ្គលណាមួយ គប្បីបាន ។ ការសោករបស់ទ្រង់នឹងមានអំពីណា ដូច្នេះឯង ។ គាថាដ៏សេសមានអត្ថដូចពោលហើយខាងដើមនោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបត្រាស់ថា យ៉ាងនោះឯងឧបាសក បុរាណបណ្ឌិតទាំងឡាយ ស្ដាប់ពាក្យរបស់បណ្ឌិតទាំងឡាយហើយ កម្ចាត់សេចក្ដីសោក ព្រោះបុត្តបាន ដូច្នេះហើយ ទើបប្រកាសសច្ចៈ ប្រជុំជាតក ។ ក្នុងទីបំផុតនៃសច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផលនោះឯង ។

## អដ្ឋកថា កណ្ហប្រេតចប់

# រឿង ធនបាលប្រេត ទី៧

[ ១៩ ] ( ពួកពាណិជ្ជសួរថា ) អ្នកជាបុគ្គលអាក្រាត មានរូបមានសម្បុរអាក្រក់ ស្គាំងស្គម រវាមដោយសរសៃ មានឆ្អឹងជំនីរគោម ស្គម ម្នាលអ្នកនិរទុក្ខ ចុះអ្នកជាអ្វី ។

( ប្រេតតបថា ) បពិត្រអ្នកទាំងឡាយដ៏ចម្រើនខ្ញុំជាប្រេតដល់នូវសេចក្តីទុក្ខ ជាយមលោកសត្វ ព្រោះធ្វើអំពើអាក្រក់ ទើបទៅអំពីមនុស្សលោកនេះកាន់បេតលោក ។

ចុះអំពើអាក្រក់ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត ដូចម្តេច អ្នកទៅអំពីមនុស្សលោកនេះ កាន់បេតលោក ព្រោះវិបាកនៃកម្មដូចម្តេច ។

មាននគរមួយ ឈ្មោះឯរកច្ចៈ ក្នុងដែនទសន្នៈ ក្នុងជាតិមុនខ្ញុំកើតជាសេដ្ឋីក្នុងនគរនោះ គេស្គាល់ខ្ញុំថាធនបាល ។ ខ្ញុំមានទ្រព្យ ៨០ រទេះ មានមាសច្រើន មានកែវមុក្តានិងកែវពិទូរ្យច្រើន ។ ការឲ្យនូវទានមិនជាទីពេញចិត្តរបស់ខ្ញុំអ្នកមានទ្រព្យច្រើនដល់ម្លោះ ខ្ញុំក៏បិទទ្វារផ្ទះបរិភោគ មិនឲ្យពួកយាចកឃើញខ្ញុំឡើយ ។ ខ្ញុំជាអ្នកមិនមានសទ្ធា កំណាញ់ស្វិតស្វាញ ជេរប្រទេចពួកជនអ្នកឲ្យ អ្នកធ្វើ បានហាមឃាត់នូវជនដ៏ច្រើន ។ ផលនៃទានមិនមានផលនៃការសង្រួមនឹងមានមកអំពីណា ខ្ញុំបានទម្លាយស្រះបោក្ខរណីនិងអណ្តូងទឹកផង របស់ដែលគេដាំក្នុងអារាមផង រោងទឹកផង នូវស្ពានក្នុងទីទៅបានដោយលំបាកផង ។ ខ្ញុំនោះមិនបានធ្វើល្អ ធ្វើតែអាក្រក់ ច្យុតអំពីមនុស្សលោកនោះ ទៅកើតក្នុងកំណើតប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លានអស់ ៥៥ ឆ្នាំ តាំងអំពីខ្ញុំធ្វើមរណកាលអំពីអត្តភាពនោះ ។ ខ្ញុំមិនបាន

បរិភោគបាយឬផឹកទឹកឡើយ សេចក្តីសំចៃ ( មិនឲ្យទាន ) ណា នោះជាសេចក្តីវិនាស សេចក្តីវិនាសណា នោះជាសេចក្តីសំចៃ បានឮថា ប្រេតទាំងឡាយរមែងដឹងថា សេចក្តីសំចៃណា នោះជាសេចក្តីវិនាស ។ អំពីជាតិមុនខ្ញុំបានសំចៃ គឺមិនបានឲ្យទ្រព្យទាំងឡាយដ៏ច្រើន កាលទេយ្យធម៌ទាំងឡាយមាននៅ ខ្ញុំមិនបានធ្វើទីពឹងដល់ខ្លួនឡើយ ។ ខ្ញុំនោះក្តៅក្រហាយក្នុងកាលខាងក្រោយ អន្ទោលទៅតាមផលកម្មរបស់ខ្លួន កាលកិរិយាក៏មានដោយកាលកន្លងទៅខាងលើ ៤ ខែ ។ ខ្ញុំធ្លាក់ទៅរងទុក្ខ ក្នុងនរកដ៏ខ្លាំងក្លា ខ្លោចផ្សា ជានរកមានជ្រុង ៤ មានទ្វារ ៤ វាស់ដោយចំណែកដែលគេចែកស្មើគ្នា មានរបងដែកព័ទ្ធជុំវិញ គ្របដោយដែក ។ ផ្ទៃផែនដីខាងក្រោមនៃមហានរកនោះសុទ្ធតែដែកមានភ្លើងឆេះរន្ទាលប្រាលផ្សាយទៅបាន ១០០ យោជន៍ជុំវិញ តាំងនៅសព្វកាល ។ ខ្ញុំបានរងទុក្ខវេទនា អស់កាលយូរអង្វែងក្នុងនរកនោះ ដោយផលនៃបាបកម្ម ព្រោះហេតុនោះ ខ្ញុំទើបសោកស្តាយក្រៃពេកណាស់ ។ ខ្ញុំប្រាប់សេចក្តីនុ៎ះដល់អ្នកទាំងឡាយ អ្នកទាំងឡាយមកកាន់ទីប្រជុំនេះ មានប្រមាណប៉ុន្មាន សេចក្តីចម្រើនចូរមានដល់អ្នកទាំងឡាយអ្នកទាំងឡាយកុំធ្វើកម្មលាមក ទោះក្នុងទីវាល ឬក្នុងទីស្ងាត់ឡើយ ។ បើអ្នកទាំងឡាយនឹងធ្វើ ឬធ្វើឥឡូវនេះនូវកម្មលាមកនោះ ទោះបីអ្នកទាំងឡាយហោះរត់ទៅលើអាកាស ក៏មិនផុតអំពីសេចក្តីទុក្ខ អ្នកទាំងឡាយគប្បីប្រតិបត្តិមាតាបិតា កោតក្រែងដល់បុគ្គលជាធំក្នុងត្រកូល គប្បីធ្វើការបូជាដល់សមណព្រាហ្មណ៍ អ្នកទាំងឡាយនឹងទៅឋានសួគ៌ ដោយបុញ្ញកម្មយ៉ាងនេះ ។ ហោះ

ទៅក្នុងអាកាសក៏មិនរួច ( អំពីបាបកម្ម ) ចូលទៅក្នុងកណ្ដាលសមុទ្រក៏មិនរួច ចូលទៅក្នុងចន្លោះភ្នំក៏មិនរួច បុគ្គលឋិតនៅក្នុងប្រទេសនៃផែនដីណាហើយ រួចចាកបាបកម្មបាន ប្រទេសនៃផែនដីនោះមិនមានឡើយ ។

**ចប់ រឿង ធនបាលប្រេតទី ៧ ។**

# អដ្ឋកថា ធនបាលសេដ្ឋិប្រេត

[ ១៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធនបាលប្រេត ទើបត្រាស់ពាក្យជាដើមថា **នគ្គោ ទុព្វណ្ណរូបោសិ** ដូច្នេះជាដើម ។

បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើងក្នុងលោក ក្នុងនគរឯរកច្ឆបណ្ណរដ្ឋ មានសេដ្ឋីម្នាក់ឈ្មោះធនបាលកៈ ជាអ្នកមិនមានសទ្ធា មិនមានការជ្រះថ្លា ជាមនុស្សកំណាញ់ ជានត្ថិកទិដ្ឋិបុគ្គល កិរិយារបស់សេដ្ឋីនោះប្រាកដតាមព្រះបាលីនោះឯង ។ គាត់ធ្វើកាលកិរិយាហើយ កើតជាប្រេតក្នុងកន្តារ គឺត្រង់វាលខ្សាច់ គាត់មានរាងកាយប៉ុនដើមត្នោត មានស្បែកគគ្រាត មានសក់វែងចាក់ស្រែះ គួរខ្លាច មានពណ៌សម្បុរគួរខ្ពើម មានរូបអាក្រក់ក្រៃលែង ឃើញគួរស្បើម ប្រេតនោះមិនបានបាយសូម្បីតែមួយគ្រាប់ ឬទឹកសូម្បីមួយតំណក់ អស់កាល ៥៥ ឆ្នាំ មានបំពង់ក បបូរមាត់ និងអណ្ដាតក្រៀមស្ងួត ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ស្ទុះស្ទាទៅកាន់ទិសផ្សេងៗ ។

កាលព្រះមានព្រះភាគនៃយើងកើតឡើងក្នុងលោក ទ្រង់ប្រកាសព្រះធម្មចក្រដ៏បវរ គង់នៅក្នុងក្រុងសាវត្ថីដោយលំដាប់ ។ ឈ្មួញអ្នកក្រុងសាវត្ថី

ដាក់ទំនិញពេញរទេះ ៥០០ ទៅកាន់ឧត្តរាបថជនបទ លក់ដូរទំនិញហើយ យករទេះដាក់ទំនិញដែលបាន ត្រឡប់មកក្នុងវេលាល្ងាចដល់ស្ទឹងមួយ ទើបដាក់រទេះក្នុងទីនោះ សម្រាកមួយរាត្រី ។ សម័យនោះ ប្រេតនោះត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ មកដើម្បីទឹក មិនបានទឹកសូម្បីមួយតំណក់ក្នុងទីនោះ ក៏អស់សង្ឃឹម ទន់ក្បាលជង្គង់ដួលចុះក្នុងទីនោះឯង ដូចដើមត្នោតដាច់ឫសដូច្នោះ ។ ពួកឈ្មួញឃើញដូច្នោះ ក៏នាំគ្នាសួរដោយគាថានេះថា

អ្នកជាបុគ្គលអាក្រាត មានរូបមានសម្បុរអាក្រក់ ស្គាំងស្គម
រវាមដោយសរសៃ មានឆ្អឹងជំនីរគោម ស្គម ម្នាលអ្នកនិរទុក្ខ
ចុះអ្នកជាអ្វី ដូច្នេះ ។

លំដាប់នោះប្រេត ក៏ឆ្លើយថា

បពិត្រអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំជាប្រេត ដល់នូវសេចក្តីទុក្ខ
ជាយមលោកសត្វ ព្រោះធ្វើអំពើអាក្រក់ ទើបទៅអំពីមនុស្ស
លោកនេះ កាន់បេតលោក ដូច្នេះ ។

កាលអាង្ខនដូច្នេះហើយ ត្រូវឈ្មួញសួរដល់កម្មដែលគេធ្វើទៀតថា

ចុះអំពើអាក្រក់ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត ដូច
ម្តេច អ្នកទៅអំពីមនុស្សលោកនេះ កាន់បេតលោក ព្រោះ
វិបាកនៃកម្មដូចម្តេច ដូច្នេះ ។

កាលនឹងសម្តែងប្រវត្តិរបស់ខ្លួនក្នុងអតីតផង ក្នុងបច្ចុប្បន្នផង អនាគតផង តាំងពីទីដែលខ្លួនកើតក្នុងកាលមុន កាលឲ្យឱវាទដល់ពួកឈ្មួញ បាន

ពោលគាថាទាំងនេះថា

មាននគរមួយ ឈ្មោះឯរកច្ឆៈ ក្នុងដែនទសន្នៈ ក្នុងជាតិមុនខ្ញុំកើតជាសេដ្ឋីក្នុងនគរនោះ គេស្គាល់ខ្ញុំថាធនបាល ។ ខ្ញុំមានទ្រព្យ ៨០ រទេះ មានមាសច្រើន មានកែវមុក្តា និងកែវពិទូរ្យច្រើន ។ ការឲ្យនូវទានមិនជាទីពេញចិត្តរបស់ខ្ញុំអ្នកមានទ្រព្យច្រើនដល់ម៉្លោះ ខ្ញុំក៏បិទទ្វារផ្ទះបរិភោគ មិនឲ្យពួកយាចកឃើញខ្ញុំឡើយ ។ ខ្ញុំជាអ្នកមិនមានសទ្ធា កំណាញ់ស្វិតស្វាញជេរប្រទេចពួកជនអ្នកឲ្យ អ្នកធ្វើ បានហាមឃាត់ នូវជនដ៏ច្រើន ។ ផលនៃទាន មិនមាន ផលនៃការសង្រួមនឹងមានមកអំពីណា ខ្ញុំបានទម្លាយស្រះបោក្ខរណីនិងអណ្តូងទឹក ផងរបស់ដែលគេដាំក្នុងអារាមផង រោងទឹកផង នូវស្ពានក្នុងទីទៅបានដោយលំបាកផង ។ ខ្ញុំនោះមិនបានធ្វើល្អ ធ្វើតែអាក្រក់ច្យុតអំពីមនុស្សលោកនោះ ទៅកើតក្នុងកំណើតប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លាន អស់ ៥៥ ឆ្នាំ តាំងអំពីខ្ញុំធ្វើមរណកាល អំពីអត្តភាពនោះ ។ ខ្ញុំមិនបានបរិភោគបាយឬផឹកទឹកឡើយ សេចក្តីសំចៃ ( មិនឲ្យទាន ) ណា នោះជាសេចក្តីវិនាស សេចក្តីវិនាសណា នោះជាសេចក្តីសំចៃ បានឮថា ប្រេតទាំងឡាយរមែងដឹងថា សេចក្តីសំចៃណា នោះជាសេចក្តីវិនាស ។ អំពីជាតិមុន ខ្ញុំបានសំចៃ គឺមិនបានឲ្យទ្រព្យ

ទាំងឡាយដ៏ច្រើន កាលទេយ្យធម៌ទាំងឡាយមាននៅ ខ្ញុំមិនបានធ្វើទីពឹងដល់ខ្លួនឡើយ ។ ខ្ញុំនោះក្តៅក្រហាយក្នុងកាលខាងក្រោយ អន្ទោលទៅតាមផលកម្មរបស់ខ្លួន កាលកិរិយាក៏មានដោយកាលកន្លងទៅខាងលើ ៤ ខែ ។ ខ្ញុំធ្លាក់ទៅវេទនាក្នុងនរកដ៏ខ្លាំងក្លា ខ្លោចផ្សា ជានរកមានជ្រុង ៤ មានទ្វារ ៤ វាស់ដោយចំណែកដែលគេចែកស្មើគ្នា មានរបងដែកព័ទ្ធជុំវិញគ្របដោយដែក ។ ផ្ទៃផែនដីខាងក្រោមនៃមហានរកនោះ សុទ្ធតែដែកមានភ្លើងឆេះរន្ទាលប្រាលផ្សាយទៅបាន ១០០ យោជន៍ ជុំវិញ តាំងនៅសព្វកាល ។ ខ្ញុំបានវេទនាវេទនាអស់កាលយូរអង្វែងក្នុងនរកនោះដោយផលនៃបាបកម្ម ព្រោះហេតុនោះ ខ្ញុំទើបសោកស្តាយក្រៃពេកណាស់ ។ ខ្ញុំប្រាប់សេចក្តីនុ៎ះ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយមកកាន់ទីប្រជុំនេះមានប្រមាណប៉ុន្មាន សេចក្តីចម្រើន ចូរមានដល់អ្នកទាំងឡាយ អ្នកទាំងឡាយកុំធ្វើកម្មលាមក ទោះក្នុងទីវាល ឬក្នុងទីស្ងាត់ឡើយ ។ បើអ្នកទាំងឡាយនឹងធ្វើ ឬធ្វើឥឡូវនេះនូវកម្មលាមកនោះ ទោះបីអ្នកទាំងឡាយ ហោះរត់ទៅលើអាកាស ក៏មិនផុតអំពីសេចក្តីទុក្ខ អ្នកទាំងឡាយគប្បីប្រតិបត្តិមាតាបិតាកោតក្រែង ដល់បុគ្គលជាធំក្នុងត្រកូល គប្បីធ្វើការបូជាដល់សមណព្រាហ្មណ៍ អ្នកទាំងឡាយនឹងទៅឋានសួគ៌ដោយបុញ្ញ

កម្មយ៉ាងនេះ ។ ហោះទៅក្នុងអាកាសក៏មិនរួច ( អំពីបាប កម្ម ) ចូលទៅក្នុងកណ្ដាលសមុទ្រក៏មិនរួច ចូលទៅក្នុងចន្លោះភ្នំក៏មិនរួច បុគ្គលឋិតនៅក្នុងប្រទេសនៃផែនដីណា ហើយរួចចាកបាបកម្មបានប្រទេសនៃផែនដីនោះមិនមានឡើយដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧសន្នានំ** បានដល់ ព្រះរាជារបស់រដ្ឋឈ្មោះថា **ឧសន្ន** ដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ឃរកច្ចំ** បានដល់ ជាឈ្មោះរបស់ព្រះនគរនោះ ។ បទថា **តត្ថ** បានដល់ ក្នុងនគរនោះ ។ បទថា **បុរេ** បានដល់ ក្នុងកាលមុន គឺក្នុងអត្តភាពដែលជាអតីត ។ បទថា **ធនបាលោតិ មំ វិទូ** សេចក្ដីថា ពួកជនហៅខ្ញុំថា ធនបាលសេដ្ឋី ។ ប្រេតកាលសម្ដែងថា ឈ្មោះថាទ្រព្យបែបនេះរមែងជាប់តាមជាប្រយោជន៍ដល់ខ្ញុំក្នុងកាលនោះ ឯងទើបពោលគាថាថា **អសីតិ** ដូច្នេះជាដើម ។ មានយោជនាថា ក្នុងបទទាំងនោះ បទថា **អសីតិ សកដវាហានំ** សេចក្ដីថា ២០ ខារិកៈ ( អម្រែក ) ជា ១ វាហៈ ដែលលោកហៅថា ១ រទេះ ខ្ញុំមានប្រាក់និងកហាបណៈ ៨០ រទេះ ។ បទថា **បហូតំ មេ ជាតរូបំ** ក្លាប់សេចក្ដីថា មាសក៏មានច្រើន គឺមានប្រមាណច្រើនអម្រែក ។

បទថា **ន មេ ទាតុំ បិយំ អហុ** សេចក្ដីថា ខ្ញុំមិនស្រឡាញ់ក្នុងការឲ្យទាន ។ បទថា **មា មំ យាចនកាទ្ទសុំ** សេចក្ដីថា បិទទ្វារផ្ទះបរិភោគដោយបំណងថា ពួកយាចកកុំបីឃើញអញឡើយ ។ បទថា **កទរិយោ** បានដល់ មានសេចក្ដីកំណាញ់ស្វិតស្វាញ ។ បទថា **បរិភាសកោ** សេចក្ដីថា ឃើញ

អ្នកដទៃឲ្យទានក៏សម្គុតឲ្យខ្ទាច ។ បទថា **ឧឧត្តានំ ករោត្តានំ** ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ ប្រែថា ដែលឲ្យទាន ដែលធ្វើបុណ្យ ។ បទថា **ពហូ ជនេ** បានដល់ សត្វជាច្រើន ។ ខ្ញុំឃាត់ គឺរារាំងជនជាច្រើនដែលជាក្រុមនៃអ្នកឲ្យទាន ឬធ្វើបុណ្យចាកបុញ្ញកម្មនោះៗ ។

បទថា **វិបាកោ នត្ថិ ទានស្ស** ជាដើម ជាបទសម្តែងហេតុនៃការហាមនៃការឲ្យទានជាដើម ។ ក្នុងបណ្តាបទទាំងនោះ បទថា **វិបាកោ នត្ថិ ទា-នស្ស** សេចក្តីថា ប្រេតសម្តែងថា ឈ្មោះថា ផលនៃការធ្វើទានមិនមាន មានតែការវិនាសនៃទ្រព្យតែម្យ៉ាង ដោយពាក្យថា បុណ្យ បុណ្យ ប៉ុណ្ណោះ ។ បទថា **សំយមស្ស** បានដល់ ការសង្រួមសីល ។ បទថា **កុតោ ផលំ** សេចក្តីថា នឹងបានផលអំពីណា អធិប្បាយថា ការរក្សាសីល មិនមានប្រយោជន៍ឡើយ ។ បទថា **អារាមានិ** បានដល់ សួនផ្កានិងសួនផ្លែឈើ ។ បទថា **បបាយោ** បានដល់ សាលាតម្កល់ទឹក ។ បទថា **ទុគ្គេ** បានដល់ ទីដែលទៅលំបាក ព្រោះមានទឹកនិងមានភក់ ។ បទថា **សង្កមនានិ** ប្រែថា ស្ពាន ។ បទថា **តតោ ចុតោ** បានដល់ ចុតិអំពីមនុស្សលោកនោះ ។ បទថា **បញ្ច-បញ្ញាស** ប្រែថា ៥៥ ឆ្នាំ ។ បទថា **យតោ កាលង្កតោ អហំ** កែជា **យទា កាលកតោ អហំ** ប្រែថា តាំងអំពីខ្ញុំស្លាប់ទៅ ។ បទថា **នាភិ-ជានាមិ** សេចក្តីថា ខ្ញុំមិនបានស្គាល់អ្វីទោះជាបាយឬទឹកអស់កាលមានប្រ-មាណប៉ុណ្ណោះ ។

បទថា **យោ សំយមោ សោ វិនាសោ** សេចក្តីថា ការសំចៃ គឺការ

*មិនឲ្យទាន ដល់បុគ្គលណាមួយដោយអំណាចលោភៈជាដើមនោះ ឈ្មោះថា ជាការវិនាសរបស់សត្វទាំងនេះ ព្រោះប្រេតដែលកើតក្នុងកំណើតប្រេត ជាហេតុនៃការរីករាយយ៉ាងធំកន្លង ។ ដោយបទថា* **យោ វិឃាសោ សោ សំ-យមោ** *នេះ ប្រេតពោលដល់ ប្រយោជន៍តាមដែលពោលហើយ ជាប្រ-យោជន៍យ៉ាងពិតប្រាកដ ។* **ហិ** *សព្ទ ក្នុងពាក្យថា* **បេតា ហិ កិរ ជានន្តិ** *នេះ ជានិបាត ប្រើក្នុងអវធារណៈ ។* **កិរ** *សព្ទ ជានិបាត ប្រើក្នុងអរុចិ-សូចនត្ថៈ ( ទោះជាយ៉ាងនោះ ) ។ បានឮថា ពួកប្រេតប៉ុណ្ណោះ ទើបដឹងសេចក្តីនេះថា ការសំចៃ គឺការមិនបរិច្ចាគទេយ្យធម៌ ជាហេតុនៃសេចក្តីវិនាស ព្រោះខ្លួន ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ដោយឃើញបានច្បាស់ មិនមែនពួកមនុស្ស ។ សេចក្តីនេះមិនសមគួរឡើយ ព្រោះសូម្បីពួកមនុស្សក៏គង់ត្រូវសេចក្តីស្រេកឃ្លានជាដើម គ្របសង្កត់ប្រាកដដូចពួកប្រេត តែពួកប្រេតដឹងរឿងនោះល្អជាងព្រោះកម្មដែលខ្លួនធ្វើក្នុងអត្តភាពមុនប្រាកដច្បាស់ ។ ដោយហេតុនោះ ទើបប្រេតនោះពោលថា អំពីជាតិមុន ខ្ញុំបានសំចៃដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **សំយមិស្សំ** *សេចក្តីថា ខ្លួនឯងក៏បានធ្វើការសំចៃ គឺការមិនធ្វើបុញ្ញកិរិយា មានការឲ្យទានជាដើម ។ បទថា* **ពហុកេ ធនេ** *បានដល់ កាលទ្រព្យជាច្រើនមាន ។*

*បទថា* **តំ** *ប្រែថា ព្រោះហេតុនោះ ។ បទថា* **វោ** *ប្រែថា លោកទាំងឡាយ ។ បាលីដ៏សេសថា* **កតំ វោ** *គប្បីនាំមកភ្ជាប់ដោយពាក្យថា* **កតំ កល្យាណំ** *កម្មដ៏ចម្រើន គឺកម្មល្អ បានដល់ សុចរិតកម្មចូរមានដល់ពួក*

លោក ។ បទថា **យាវន្តេត្ថ សមាគតា** មានអធិប្បាយថា ពួកអ្នកមានប្រមាណប៉ុនណា គឺមានប្រមាណត្រឹមណា មកប្រជុំគ្នាក្នុងទីនេះ ទាំងអស់នោះ ចូរស្តាប់ពាក្យរបស់ខ្ញុំ ។ បទថា **អាវិ** បានដល់ ពាក្យប្រកាសដោយប្រាកដ ដល់បុគ្គលដទៃ ។ បទថា **រហោ** បានដល់ ពាក្យអាថ៌កំបាំង ព្រោះជាពាក្យមិនប្រាកដដល់ជនដទៃ អធិប្បាយថា លោកទាំងឡាយកុំធ្វើ គឺកុំធ្វើនូវកម្មអាក្រក់លាមក បានដល់ អកុសលកម្ម ក្នុងទីវាល ដោយអំណាចកាយប្បយោគ មានបាណាតិបាតជាដើម និងវចីបយោគ មានមុសាវាទជាដើម ឬក្នុងទីកំបាំង ដោយអំណាច អកុសលកម្ម មានអភិជ្ឈាជាដើម ។

បទថា **សចេ តំ បាបកំ កម្មំ** សេចក្តីថា បើពួកលោកនឹងធ្វើបាបកម្មនោះក្នុងអនាគត ឬកំពុងធ្វើក្នុងបច្ចុប្បន្ន ឈ្មោះថា ការរួចផុត គឺការរួចផុតចាកទុក្ខដែលជាផលរបស់បាបកម្មនោះក្នុងអបាយទាំង ៤ មាននរកជាដើម និងក្នុងពួកមនុស្ស ដោយអំណាចភាពជាអ្នកមានអាយុតិចជាដើម រមែងមិនមាន ។ បទថា **ឧប្បច្ចាបិ បលាយតំ** សេចក្តីថា កាលពួកអ្នកហោះទៅក្តី ក៏រួចផុតមិនបាន ។ បាលីថា **ឧបេច្ច** ដូច្នេះក៏មាន អធិប្បាយថា កាលពួកអ្នកផ្គងចិត្តក្លែងគេចទៅដោយបំណងថា សេចក្តីទុក្ខកុំបីជាប់តាមអញឡើយ គេចទៅក្នុងទីផ្សេងៗ ការរួចផុតនោះរមែងមិនមាន តែកាលការប្រជុំនៃបច្ច័យដទៃមានគតិនិងកាលជាដើមនៅមាន កម្មអាក្រក់នោះគង់ឲ្យផលបានដូចគ្នា ។ សេចក្តីនេះ គប្បីសម្តែងដោយគាថានេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**

**ន បព្វតានំ វិវរំ បវិសំ**

**ន វិជ្ជតី សោ ជគតិប្បទេសោ**

**យត្រដ្ឋិតោ មុញ្ចេយ្យ បាបកម្មា ។**

*បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្ទ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយគប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ដូច្នេះ ។*

*ក្នុងបទទាំងនោះ បទថា* **មត្តេយ្យា** *បានដល់ ឧបការៈដល់មាតាបិតា ។ បទថា* **ហោថ** *សេចក្តីថា ចូរឧបដ្ឋាក ជាដើម ដល់មាតាបិតាទាំងនោះ ។ បទថា* **បេត្តេយ្យា** *ក៏គប្បីជ្រាបយ៉ាងនោះ ។ បទថា* **កុលេ ជេដ្ឋាបចាយិកា** *បានដល់ ជាអ្នកធ្វើការឱនលំទោនដល់បុគ្គលជាធំក្នុងត្រកូល ។ បទថា* **សាមញ្ញា** *បានដល់ ជាបុគ្គលដែលបូជាសមណៈ ។ បទថា* **ព្រហ្មញ្ញា** *ក៏ដូចគ្នា អធិប្បាយថា ដែលបូជាដល់លោកអ្នកដែលបន្សាត់បាប ។ ដោយបទថា* **ឯវំ សគ្គំ គមិស្សថ** *នេះ មានអធិប្បាយថា លោកទាំងឡាយធ្វើបុណ្យដោយន័យដែលខ្ញុំបានពោលហើយនឹងចូលដល់ទេវលោក ។ ក្នុងរឿងនេះ បទដែលមិនបានចែកទុកដោយអត្ថ គប្បីជ្រាបដោយន័យដែលពោលក្នុងខល្លាដិយបេតវត្ថុ ជាដើម ខាងដើម ។*

*ពួកពាណិជទាំងនោះ បានស្តាប់ពាក្យរបស់ប្រេតទាំងឡាយ កើតនូវសេចក្តីសង្វេគ កាលនឹងអនុគ្រោះប្រេតនោះ ទើបយកកាជនៈជងទឹកមក ឲ្យ*

ប្រេតដេកហើយ បញ្ច្រកចូលតាមមាត់ តែទឹកដែលមហាជនចាក់សូម្បីច្រើនជន ក៏មិនហូរចូលកាន់បំពង់ក ព្រោះកម្លាំងនៃបាបកម្មរបស់ប្រេតនោះ ។ ទឹកនោះកម្ចាត់សេចក្តីស្រេកបានអំពីណា ។ ឈ្មួញទាំងនោះក៏សួរប្រេតថា អ្នកបានស្រាកស្រាន្តចិត្តខ្លះដែរឬទេ ប្រេតឆ្លើយថា បើទឹកដែលជនមានប្រមាណប៉ុណ្ណោះ បញ្ច្រកចូលទៅអស់កាលប្រមាណប៉ុណ្ណោះ សូម្បីត្រឹមមួយតំណក់ ចូលទៅកាន់បំពង់កខ្ញុំ ដូចចូលកាន់បំពង់កអ្នកដទៃសោត ការរួចផុតពីកំណើតប្រេតនេះ កុំបីមានឡើយ ។ លំដាប់នោះ ឈ្មួញទាំងនោះបានស្តាប់ដូច្នោះ ក៏កើតសេចក្តីសង្វេគក្រៃលែង ទើបនាំគ្នាពោលថា ឧបាយណាមួយដើម្បីរម្ងាប់ការស្រេកឃ្លានមានខ្លះដែរឬទេ ប្រេតឆ្លើយថា កាលកម្មអាក្រក់នេះអស់ទៅ កាលពួកញាតិថ្វាយទានដល់ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ឧទ្ទិសទានឲ្យដល់ខ្ញុំ ខ្ញុំនឹងផុតចាកភាពជាប្រេតនេះទៅបាន ។ ពួកឈ្មួញបានស្តាប់ដូច្នោះ ទើបនាំគ្នាទៅកាន់ក្រុងសាវត្ថី ចូលគាល់ព្រះមានព្រះភាគ ក្រាបទូលរឿងនោះ ទទួលសរណគមន៍និងសីល ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ហើយឧទ្ទិសចំណែកបុណ្យដល់ប្រេតនោះ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ សម្តែងធម៌ដល់បរិស័ទ ៤ មហាជនលះមន្ទិល គឺសេចក្តីកំណាញ់ មានលោភៈជាដើម បានជាអ្នកត្រេកអរក្នុងបុណ្យ មានទានជាដើម ដូច្នេះឯង ។

**អដ្ឋកថា ធនបាលសេដ្ឋិប្រេតចប់**

# រឿង ចូឡសេដ្ឋិប្រេត ទី៨

[ ២០ ] ( *ព្រះបាទអជាតសត្រូវទ្រង់សួរថា* ) *បពិត្រលោកដ៏ចម្រើន លោកជាបព្វជិត មានកាយអាក្រាត ស្គាំងស្គម ហេតុអ្វីបានជាលោកទៅកាន់ទីណាតែក្នុងវេលារាត្រី សូមលោកប្រាប់ហេតុនោះដល់ខ្ញុំ ខ្ញុំនឹងអាចចាត់ចែងទ្រព្យទាំងពួង តាមអធ្យាស្រ័យនៃលោក ។*

*( ប្រេតតបថា ) ក្រុងពារាណសី មានកិត្តិសព្ទល្បីទៅក្នុងទីឆ្ងាយ ខ្ញុំជាគហបតី មានទ្រព្យច្រើនក្នុងក្រុងពារាណសីនោះ ជាអ្នកកំណាញ់មិនឲ្យទាន មានចិត្តជាប់នូវក្នុងអាមិសៈដល់នូវយមវិស័យ ( បេតលោក ) ដោយភាវៈទ្រុស្តសីល ។ ខ្ញុំជាបុគ្គលលំបាកដោយសេចក្តីស្រេកឃ្លាន ប្រាកដដូចជាម្ជុលចាក់នៅជានិច្ច ព្រោះអំពើអាក្រក់នោះទើបទៅរកញាតិ ជាហេតុនឹងបានអាមិសៈតិចតួច ( ពួកមនុស្សណា ) មិនឲ្យទាន មិនជឿថា ផលទានមានក្នុងបរលោក ( មនុស្សទាំងនោះតែងទៅកើតជាប្រេតរងទុក្ខធ្ងន់ដូចជាខ្លួនខ្ញុំ ) ។ ចំណែកធីតារបស់ខ្ញុំ ពោលរឿយៗថា អាត្មាអញនឹងឲ្យទានដល់បិតាដល់ជីតា ក៏បានឲ្យព្រាហ្មណ៍ទាំងឡាយបរិភោគភោជនដែលខ្លួនតាក់តែង ខ្ញុំទៅកាន់អន្ធកវិន្ទនគរដើម្បីបរិភោគនូវផលទាននោះ ។*

*ព្រះបាទអជាតសត្រូវ បានត្រាស់សួរទៅប្រេតនោះថា អ្នកបានទទួលផលទាន ( ដែលធីតារបស់អ្នកបានតាក់តែងឲ្យហើយ ) នោះ គប្បីត្រឡប់វិលវិញឆាប់ យើងនឹងធ្វើការបូជា ( ដល់អ្នក ) បើមានហេតុ អ្នកចូរប្រាប់ហេតុនោះដល់យើង យើងនឹងស្តាប់ពាក្យប្រកបដោយហេតុដែលគួរជឿ ។*

*ប្រេតនោះ ពោលដូច្នោះហើយ បានទៅកាន់ អន្ធកវិន្ទនគរនោះ ពួក*

ព្រាហ្មណ៍បរិភោគកត្ត តែជាអ្នកមិនគួរដល់បទក្ខិណា ( ព្រោះជាព្រាហ្មណ៍ទ្រុស្តសីល ) ខាងក្រោយមក ប្រេតនោះ ក៏ទៅនគររាជគ្រឹះវិញ ក៏ប្រាកដចំពោះព្រះភក្ត្រព្រះបាទអជាតសត្រូវជាធំជាងជន ។

ព្រះរាជាបានទតឃើញប្រេតមកហើយ ត្រាស់សួរថា យើងនឹងឲ្យនូវអ្វី អ្នកជាបុគ្គលឆ្អែតអស់កាលយូរដោយហេតុណា បើហេតុនោះមាន អ្នកចូរប្រាប់ដល់យើង ។

បពិត្រមហារាជ សូមព្រះអង្គអង្គាសព្រះពុទ្ធផង ព្រះសង្ឃផង ដោយបាយ ទឹក និងចីវរ ហើយសូមឧទ្ទិសនូវទក្ខិណាទាននោះដើម្បីប្រយោជន៍ដល់ខ្ញុំ ខ្ញុំគប្បីជាបុគ្គលឆ្អែតឆ្អន់អស់កាលយូរ ដោយប្រការយ៉ាងនេះ ។

ក្នុងកាលនោះ ព្រះរាជាស្តេចចុះចាកប្រាសាទនោះ ហើយថ្វាយនូវទានមានឱជារសរកប្រមាណមិនបាន ដោយព្រះហស្តព្រះអង្គឯង ដល់ព្រះសង្ឃ ហើយក្រាបទូលអំពីទានដែលបានធ្វើចំពោះព្រះតថាគត ហើយឧទ្ទិសនូវទក្ខិ-ណាទានដល់ប្រេត ។

ប្រេតនោះ ដែលព្រះរាជាបូជាហើយ ក៏រុងរឿងក្រៃពេក ប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជាជាធំជាងជន ពោលថា ខ្ញុំព្រះអង្គជាយក្សសម្រេចនូវឫទ្ធិដ៏ឧត្តម រកមនុស្សមានឫទ្ធិប្រាកដស្មើនឹងខ្ញុំគ្មាន ។ សូមព្រះអង្គទ្រង់ទតមើលនូវអានុភាពរបស់ខ្ញុំ រកប្រមាណមិនបាននេះ ទានដ៏ឧត្តមដែលព្រះអង្គឧទ្ទិសហើយឲ្យចំពោះសង្ឃ បពិត្រមនុស្សទេព ខ្ញុំព្រះអង្គជាបុគ្គលឆ្អែតស្កប់ស្កល់ដោយវត្ថុទាំងឡាយច្រើនរឿយៗ សព្វកាល ក៏បាននូវសេចក្ដីសុខ

ឥឡូវសូមលាទៅ ។

### ចប់ រឿងចូឡសេដ្ឋិប្រេតទី ៨ ។

## អដ្ឋកថា ចូឡសេដ្ឋិប្រេត

[ ២០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធ ចូឡសេដ្ឋីប្រេត ត្រាស់គាថានេះ មានពាក្យផ្ដើមថា **នគ្គោ កិសោ បព្វជិតោសិ ភន្តេ** ដូច្នេះ ជាដើម ។

បានឮថា ក្នុងក្រុងពារាណសី មានគហបតីម្នាក់ជាបុគ្គលមិនមានសទ្ធា មិនមានសេចក្ដីជ្រះថ្លា ជាបុគ្គលកំណាញ់ស្វិតស្វាញ មិនអើពើចំពោះការបំពេញបុណ្យ គាត់មានឈ្មោះថា ចូឡសេដ្ឋី ។ គាត់ធ្វើកាលកិរិយាហើយកើតក្នុងពួកប្រេត ។ រាងកាយរបស់ប្រេតនោះ ប្រាសចាកសាច់និងឈាម មានត្រឹមតែរាងឆ្អឹង សរសៃនិងស្បែក មានក្បាលត្រងោល ប្រាសចាកសំពត់ តែធីតារបស់សេដ្ឋីនោះ ឈ្មោះអនុលា នៅក្នុងផ្ទះរបស់ស្វាមីក្នុងអន្ធកវិន្ទនគរ មានបំណងនឹងឲ្យព្រាហ្មណ៍បរិភោគអាហារឧទ្ទិសដល់ឪពុក ទើបរៀបចំគ្រឿងឧបភោគបរិភោគនៃទានមានអង្ករជាដើម ។ ប្រេតដឹងដូច្នោះ ទៅក្នុងទីនោះតាមអាកាសដោយសេចក្ដីសង្ឃឹមដល់ក្រុងរាជគ្រឹះ ។ សម័យនោះព្រះបាទអជាតសត្តុត្រូវទេវទត្តបញ្ចុះទៅឲ្យផ្ដាច់ព្រះជន្មព្រះបិតា មិនចូលដល់ការនិទ្រា ព្រោះការក្ដៅក្រហាយ និងព្រោះយល់សប្តិអាក្រក់នោះ ទើបឡើងទៅលើប្រាសាទ ចង្ក្រម ឃើញប្រេតនោះហោះទៅ ទើបសួរដោយគាថានេះថា

បពិត្រលោកដ៏ចម្រើន លោកជាបព្វជិត មានកាយអាក្រាត ស្គាំងស្គម ហេតុអ្វីបានជាលោកទៅកាន់ទីណាតែក្នុងវេលារាត្រី សូមលោកប្រាប់ហេតុនោះដល់ខ្ញុំ ខ្ញុំនឹងអាចចាត់ចែងទ្រព្យទាំងពួងតាមអធ្យាស្រ័យនៃលោក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បព្វជិតោ** បានដល់ សមណៈ ។ បានឮថា ព្រះរាជាពោលនឹងប្រេតថា លោកជាបព្វជិត មានកាយអាក្រាត ស្គាំងស្គម ជាដើម ដោយសម្គាល់ថា ប្រេតនេះជាសមណៈអាក្រាត ព្រោះប្រេតជាអ្នកអាក្រាត និងមានក្បាលត្រងោល ។ បទថា **កិស្ស ហេតុ** បានដល់ មានអ្វីជាហេតុ ។ បទថា **សព្វេន វិត្តំ បដិបាទយេ តុវំ** សេចក្ដីថា ខ្ញុំនឹងប្រគល់ទ្រព្យ ជាគ្រឿងត្រេកអរនៃចិត្ត ដែលជាគ្រឿងឧបករណ៍នៃទ្រព្យជាគ្រឿងត្រេកអរនៃចិត្តមួយអន្លើដោយកោគៈគ្រប់យ៉ាង ឬដោយឧស្សាហៈគ្រប់យ៉ាង តាមសមគួរដល់អធ្យាស្រ័យ របស់អ្នក ធ្វើម្ដេចខ្ញុំអាចធ្វើដូច្នោះបាន ព្រោះហេតុនោះ ចូរអ្នកប្រាប់សេចក្ដីនោះដល់ខ្ញុំ គឺចូរប្រាប់ហេតុនៃការមករបស់អ្នកនោះដល់ខ្ញុំ ។

ប្រេតកាលព្រះរាជាសួរយ៉ាងនោះហើយ កាលនឹងប្រាប់ប្រវត្តិរបស់ខ្លួន ទើបពោលគាថា ៣ ថា

ក្រុងពារាណសី មានកិត្តិសព្ទល្បីទៅក្នុងទីឆ្ងាយ ខ្ញុំជាគហបតីមានទ្រព្យច្រើន ក្នុងក្រុងពារាណសីនោះ ជាអ្នកកំណាញ់មិនឲ្យទានមានចិត្តជាប់នូវក្នុងអាមិសៈ ដល់នូវយមវិស័យ ( បេត

លោក ) ដោយការៈទ្រុស្តសីល ។ ខ្ញុំជាបុគ្គលលំបាកដោយសេចក្តីស្រេកឃ្លាន ប្រាកដដូចជាម្លូលចាក់នៅជានិច្ច ព្រោះអំពើអាក្រក់នោះ ទើបទៅរកញាតិ ជាហេតុនឹងបានអាមិសៈតិចតួច ( ពួកមនុស្សណា ) មិនឲ្យទាន មិនជឿថា ផលទានមានក្នុងបរលោក ( មនុស្សទាំងនោះតែងទៅកើតជាប្រេតរងទុក្ខធ្ងន់ដូចជាខ្ញុំ ) ។ ចំណែកជីតារបស់ខ្ញុំ ពោលរឿយៗថា អាត្មាអញនឹងឲ្យទានដល់បិតាដល់ជីតាក៏បានឲ្យព្រាហ្មណ៍ទាំងឡាយបរិភោគភោជនដែលខ្លួនតាក់តែង ខ្ញុំទៅកាន់អន្ធកវិន្ទនគរដើម្បីបរិភោគនូវផលទាននោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទូរឃុដ្ឋោ** បានដល់ ល្បី ដោយអំណាចកិត្តិគុណទៅកាន់ទីឆ្ងាយ អធិប្បាយថា ល្បីខ្ចរខ្ចាយទៅគឺប្រាកដក្នុងទីគ្រប់ស្ថាន ។ បទថា **អឌ្ឍកោ** បានដល់ ជាអ្នកស្តុកស្តម្ភ គឺមានសម្បត្តិច្រើន ។ បទថា **ឥនោ** បានដល់ មានចិត្តកំណាញ់ គឺមានអធ្យាស្រ័យក្នុងការមិនឲ្យ ។ ដោយហេតុនេះ ទើបប្រេតពោលថា **អទាតា** គឺដែលមិនឲ្យ ។ បទថា **គេធិតមនោ អាមិសស្មឹ** បានដល់ ដែលមានចិត្តជាប់ជំពាក់ គឺដល់នូវការជាប់ក្នុងអាមិសៈ គឺកាម ។ បទថា **ទុស្សីល្យេន យមវិសយម្ហិ បត្តោ** សេចក្តីថា ខ្ញុំបានដល់វិស័យនៃស្តេចយម គឺបេតលោក ដោយកម្ម គឺភាពជាអ្នកទ្រុស្តសីលដែលខ្លួនធ្វើទុក ។

បទថា **សោ សូចិកាយ កិលមិតោ** សេចក្តីថា ខ្ញុំនោះលំបាក ព្រោះ

ការឃ្លានដែលបានឈ្មោះថា **សូចិកា** ព្រោះដូចម្ជុល ព្រោះអត្ថថា ចាក់ដោត គឺចាក់មិនដាច់រយៈ ។ម្យ៉ាងទៀត បាលីថា **កិលមថោ** ដូច្នេះក៏មាន ។ បទថា **តេហិ** សេចក្ដីថា ដោយបាបកម្មជាហេតុដែលពោលហើយ ដោយន័យជាដើមថា **ឥណោ** ជាអ្នកកំណាញ់ ដូច្នេះ ។ ពិតហើយ កាលប្រេតនោះ រឭកដល់កម្មអាក្រក់នោះ ទោមនស្សខ្លាំងក្លា កើតឡើងហើយ ព្រោះហេតុនោះ ទើបប្រេតពោលយ៉ាងនោះ ។ បទថា **តេនេវ** បានដល់ ព្រោះសេចក្ដីទុក្ខដែលកើតអំពីការឃ្លាននោះឯង ។ បទថា **ញាតីសុ យាមិ** សេចក្ដីថា ខ្ញុំក៏ចូលទៅ គឺចូលទៅដល់ទីជិតនៃពួកញាតិ ។ បទថា **អាមិសកិញ្ចិក្ខ-ហេតុ** បានដល់ ព្រោះហេតុនៃខ្ញុំព្រះអង្គប្រាថ្នាអាមិសជានិមិត្ត អធិប្បាយថា ប្រាថ្នាអាមិសណាមួយ ។ បទថា **អទានសីលា ន ច សទ្ទហន្តិ ទានផលំ ហោតិ បរម្ហិ លោកេ** សេចក្ដីថា ខ្ញុំជាអ្នកមានប្រក្រតីមិនឲ្យទានយ៉ាងណា សូម្បីជនដទៃ ក៏មានប្រក្រតីមិនឲ្យទានយ៉ាងនោះដូចគ្នា និងមិនជឿថាផលនៃទាននឹងមានក្នុងបរលោកយ៉ាងពិត អធិប្បាយថា សូម្បីពួកជនទាំងនោះ ជាប្រេតសោយទុក្ខយ៉ាងធំ ដូចខ្ញុំ ។

បទថា **លបតេ** ប្រែថា រមែងពោល ។ បទថា **អភិក្ខណំ** ប្រែថា រឿយៗ គឺដោយចំណែកច្រើន ។ ដើម្បីចៀសវាងពាក្យសួរថា ប្រេតពោលដូចម្ដេច ទើបពោលថា ខ្ញុំនឹងឲ្យទានដើម្បីមាតាបិតា ជីដូន ជីតា ។

ក្នុងបទទាំងនោះ បទថា **បិតូនំ** បានដល់ មាតានិងបិតា ឬមា អ៊ំ ។ បទថា **បិតាមហានំ** បានដល់ ជីដូន ជីតា ។ បទថា **ឧបក្ខដំ** បានដល់

ដែលធីតាចាត់ចែងហើយ ។ បទថា **បរិវិសយន្តិ** បានដល់ ឲ្យបរិភោគ ។ បទថា **អន្ធកាវិន្ទំ** បានដល់ នគរដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ភុត្តុំ** បានដល់ ដើម្បីបរិភោគ ។ ខាងមុខអំពីនោះ ព្រះសង្គីតិកាចារ្យបានពោលទុកថា

ព្រះបាទអជាតសត្រូវបានត្រាស់សួរទៅប្រេតនោះថា អ្នកបានទទួលផលទាន ( ដែលធីតារបស់អ្នកបានតាក់តែងឲ្យហើយ ) នោះ គប្បីត្រឡប់វិលវិញចាប់ យើងនឹងធ្វើការបូជា ( ដល់អ្នក ) បើមានហេតុ អ្នកចូរប្រាប់ហេតុនោះដល់យើង យើងនឹងស្ដាប់ពាក្យប្រកបដោយហេតុដែលគួរជឿ ។

ប្រេតនោះ ពោលដូច្នោះហើយ បានទៅកាន់អន្ធកវិន្ទនគរនោះ ពួកព្រាហ្មណ៍បរិភោគភត្តតែជាអ្នកមិនគួរដល់បទក្ខិណា ( ព្រោះជាព្រាហ្មណ៍ទុស្សសីល ) ខាងក្រោយមកប្រេតនោះក៏ទៅនគររាជគ្រឹះវិញ ក៏ប្រាកដចំពោះព្រះភក្ត្រព្រះបាទអជាតសត្រូវជាធំជាងជន ។

ព្រះរាជាបានទតឃើញប្រេតមកហើយ ត្រាស់សួរថាយើងនឹងឲ្យនូវអ្វី អ្នកជាបុគ្គលឆ្អែតអស់កាលយូរដោយហេតុណា បើហេតុនោះមាន អ្នកចូរប្រាប់ដល់យើង ដូច្នេះ ។

ចូឡសេដ្ឋីប្រេតក្រាបទូលថា

បពិត្រមហារាជ សូមព្រះអង្គអង្គាសព្រះពុទ្ធផង ព្រះសង្ឃ

ផង ដោយបាយ ទឹក និងចីវរ ហើយសូមឧទ្ទិសនូវទក្ខិណា-ទាននោះ ដើម្បីប្រយោជន៍ដល់ខ្ញុំ ខ្ញុំគប្បីជាបុគ្គលឆ្អែតឆ្អន់អស់កាលយូរ ដោយប្រការយ៉ាងនេះ ។

ក្នុងកាលនោះ ព្រះរាជាស្តេចចុះចាកប្រាសាទនោះ ហើយថ្វាយនូវទាន មានឱជារសរកប្រមាណមិនបានដោយព្រះហស្ត ព្រះអង្គឯងដល់ព្រះសង្ឃ ហើយក្រាបទូលអំពីទានដែលបានធ្វើ ចំពោះព្រះតថាគត ហើយឧទ្ទិសនូវទក្ខិណាទាន ដល់ប្រេត ។

ប្រេតនោះ ដែលព្រះរាជាបូជាហើយ ក៏រុងរឿងក្រៃពេក ប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ជាធំជាងជន ពោលថា ខ្ញុំព្រះអង្គជាយក្ស សម្រេចនូវឫទ្ធិដ៏ឧត្តម រកមនុស្សមានឫទ្ធិប្រាកដស្មើនឹងខ្ញុំគ្មាន ។ សូមព្រះអង្គ ទ្រង់ទតមើលនូវអានុភាពរបស់ខ្ញុំរកប្រមាណមិនបាននេះ ទានដ៏ឧត្តមដែលព្រះអង្គឧទ្ទិសហើយឲ្យចំពោះសង្ឃ បពិត្រមនុស្សទេព ខ្ញុំព្រះអង្គជាបុគ្គល ឆ្អែតស្កប់ស្កល់ ដោយវត្ថុទាំងឡាយច្រើនរឿយៗ សព្វកាល ក៏បាននូវសេចក្តីសុខ ឥឡូវសូមលាទៅ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តមវោច រាជា** សេចក្តីថា ព្រះបាទអជាតសត្តុបានប្រាប់ប្រេតនោះដែលឈរពោលយ៉ាងនោះ ។ បទថា **អនុកម្បិយាន តម្បិ** សេចក្តីថា សោយទាននោះដែលកូនស្រីរបស់អ្នកចូលទៅតាំងទុក ។

បទថា **ឯយ្យាសិ** ប្រែថា គប្បីមក ។ បទថា **ករិស្សំ** ប្រែថា នឹងធ្វើ ។ បទថា **អាចិក្ខ មេ តំ យទិ អត្ថិ ហេតុ** សេចក្ដីថា បើពាក្យណាមានហេតុដែលគួរជឿបាន ចូរប្រាប់ដល់យើង ។ បទថា **សទ្ធាយិតំ** ប្រែថា គួរជឿបានហើយ ។ បទថា **ហេតុវចោ** បានដល់ ពាក្យដែលគួរដល់ហេតុ អធិប្បាយថា ចូរពោលពាក្យ ដែលមានហេតុថា កាលបំពេញទានក្នុងទីឈ្មោះនោះ ដោយប្រការនោះ ផលទាននឹងសម្រេចដល់ខ្ញុំ ។

បទថា **តថាតិ វត្វា** សេចក្ដីថា ចូឡសេដ្ឋីប្រេតទទួលព្រះតម្រាស់ហើយ ។ បទថា **តត្ថ** បានដល់ ក្នុងទីដែលជាទីអង្គាសក្នុងអន្ធកវិន្ទនគរនោះ ។ បទថា **ភុញ្ជីសុ ភត្តំ ន ច ទក្ខិណារហា** សេចក្ដីថា ព្រាហ្មណ៍ទុស្សីលបរិភោគភត្តាហារហើយ តែព្រាហ្មណ៍ដែលគួរដល់ទក្ខិណាដែលមានសីលមិនបានបរិភោគ ។ បទថា **បុនាបរំ** សេចក្ដីថា ខាងក្រោយចូឡសេដ្ឋីប្រេតត្រឡប់មកកាន់នគររាជគ្រឹះវិញ ។

បទថា **កឹ ទទាមិ** សេចក្ដីថា ព្រះរាជាត្រាស់សួរប្រេតនោះថា យើងនឹងឲ្យទានដូចម្ដេចដល់អ្នក ។ បទថា **យេន តុវំ** សេចក្ដីថា អ្នកឆ្អែតស្កប់ស្កល់ដោយហេតុណា ។ បទថា **ចិរតំ** ប្រែថា អស់កាលយូរ ។ បទថា **បីណិតោ** សេចក្ដីថា បើអ្នកឆ្អែតស្កប់ស្កល់ហើយ ចូរប្រាប់សេចក្ដីនោះ ។

បទថា **បរិវិសិយាន** ប្រែថា ឲ្យបរិភោគ ។ ចូឡសេដ្ឋីប្រេតហៅព្រះបាទអជាតសត្រូវថា បពិត្រមហារាជ ។ បទថា **មេ ហិតាយ** បានដល់ដើម្បីប្រយោជន៍ដល់ខ្ញុំព្រះអង្គ គឺដើម្បីឲ្យខ្ញុំព្រះអង្គផុតចាកភាពជាប្រេត ។

បទថា **តតោ** ប្រែថា ព្រោះហេតុនោះ គឺព្រោះពាក្យនោះ ។ ម្យ៉ាងទៀត បទថា **តតោ** ប្រែថា ចាកប្រាសាទនោះ ។ បទថា **និបតិត្វា** ប្រែថា ចេញទៅហើយ ។ បទថា **តាវទេ** បានដល់ ក្នុងកាលនោះឯង គឺក្នុងពេលអរុណរះ អធិប្បាយថា ព្រះរាជាបានថ្វាយទានចំពោះក្នុងពេលមុនកត្តដែលប្រេតនោះត្រឡប់មកបង្ហាញខ្លួនដល់ព្រះរាជា ។ បទថា **សហត្ថា** ប្រែថា ដោយដៃរបស់ព្រះអង្គ ។ បទថា **អតុលំ** បានដល់ ប្រមាណមិនបាន គឺប្រណីតក្រៃលែង ។ បទថា **ទត្វា សង្ឃេ** បានដល់ ថ្វាយដល់សង្ឃ ។ បទថា **អារោចេសិ បកតំ តថាគតស្ស** សេចក្តីថា ព្រះរាជាក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ទាននេះ ខ្ញុំព្រះអង្គបានបំពេញបំណងឧទ្ទិសដល់ប្រេតមួយរូប ។ កាលក្រាបទូលហើយ ទាននោះក៏សម្រេចដល់ប្រេតនោះដោយប្រការនោះ ។ ព្រះរាជាឧទ្ទិសចំណែកបុណ្យដល់ប្រេតនោះដោយប្រការដូច្នេះ ។ បទថា **សោ** បានដល់ ប្រេតនោះ ។ បទថា **បូជិតោ** បានដល់ ដែលព្រះរាជាទ្រង់បូជាដោយទក្ខិណា ដែលទ្រង់ឧទ្ទិសឲ្យ ។ បទថា **អតិវិយ សោភមានោ** បានដល់ ជាបុគ្គលរូបល្អក្រៃលែងដោយអានុភាពដែលជាទិព្វ ។ បទថា **ចាតុរហោសិ** បានដល់ ប្រាកដហើយ គឺបង្ហាញខ្លួនចំពោះព្រះភក្ត្ររបស់ព្រះរាជា ។ បទថា **យក្ខោហមស្មិ** សេចក្តីថា ខ្ញុំផុតចាកភាពជាប្រេត ក្លាយជាទេវតា គឺដល់នូវភាពជាទេវតា ។ បទថា **ន មយ្ហមត្ថិ សមា សទិសា មានុសា** សេចក្តីថា មនុស្សទាំងឡាយដែលស្មើដោយអានុភាពសម្បត្តិ ឬដូចភោគសម្បត្តិរបស់ខ្ញុំមិនមាន ។

បទថា **បស្សានុភាវំ អបរិមិតំ មមយិទំ** សេចក្តីថា ចូឡសេដ្ឋីប្រេត ក្រាបទូលសម្តែងសម្បត្តិរបស់ខ្លួនដល់ព្រះរាជាដោយប្រចក្សថា សូមទ្រង់ទត មើលអានុភាពនៃទេវតាដែលរកប្រមាណមិនបាននេះ របស់ខ្ញុំចុះ ។ បទថា **តយានុទិដ្ឋំ អតុលំ ទត្វា សង្ឃេ** សេចក្តីថា ដែលទ្រង់ថ្វាយទានដ៏ឧឡារ រកវត្ថុប្រៀបមិនបាន ដល់ព្រះអរិយសង្ឃ ហើយទ្រង់ឧទ្ទិស ដោយសេចក្តី អនុគ្រោះដល់ខ្ញុំ ។ បទថា **សន្តប្បិតោ សតតំ សទាពហូហិ** សេចក្តីថា ខ្ញុំកាលព្រះអរិយសង្ឃ ឆ្អែតដោយទេយ្យធម៌ដ៏ច្រើន មានបាយ ទឹក និង សំពត់ជាដើមឈ្មោះថាឲ្យឆ្អែតស្កប់ស្កល់ជាប់តគ្នា គឺមិនដាច់រយៈ សូម្បីក្នុង ទីនោះសព្វកាល គឺសព្វវេលាដរាបអស់ជីវិត ។ បទថា **យាមិ អហំ សុខិ-តោ មនុស្សទេវ** សេចក្តីថា ចូឡសេដ្ឋីប្រេតទូលសួរព្រះរាជាថា បពិត្រម-ហារាជជាទេវតានៃមនុស្សព្រោះដូច្នោះ ឥឡូវនេះ ខ្ញុំមានសេចក្តីសុខហើយ សូមលាត្រឡប់ទៅកាន់ទីតាមប្រាថ្នា ។

កាលប្រេតលាត្រឡប់ទៅយ៉ាងនេះ ព្រះបាទអជាតសត្តុត្រាស់ប្រាប់សេច ក្តីនោះដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយចូលទៅគាល់ព្រះមានព្រះភាគហើយ ក្រាបទូលសេចក្តីនោះ ។ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិ-ហេតុសម្តែងធម៌ ដល់បរិស័ទដែលដល់ព្រមហើយ មហាជនស្តាប់ធម៌នោះ ហើយ លះនូវមន្ទិល គឺសេចក្តីកំណាញ់ បានជាអ្នកត្រេកអរក្រៃលែងក្នុង បុណ្យ មានទានជាដើម ដូច្នេះ ។

អដ្ឋកថា ចូឡសេដ្ឋិប្រេតចប់

# រឿង អង្គុរប្រេត ទី ៩

[ ២១ ] ( ព្រាហ្មណ៍និយាយថា ) យើងទាំងឡាយ ជាអ្នកស្វែងរកទ្រព្យ ទៅកាន់ដែនកម្ពុជៈ ព្រោះហេតុនៃទ្រព្យណា យក្សនេះ ជាអ្នកឲ្យទ្រព្យនោះតាមប្រាថ្នា យើងនឹងនាំយកយក្សនេះទៅ ឬថា យើងចាប់យកយក្សនេះទាំងអំណាចឲ្យបានដោយងាយ លើកឡើងកាន់យាន ហើយទៅកាន់ទ្វារកនគរ ដោយឆាប់រហ័ស ។

( អង្កុរៈតបថា ) បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា មិនគួរកាច់មែកឈើនោះឡើយ ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលលាមក ។

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា គប្បីកាត់ឈើនោះបានខ្លះ បើមានប្រយោជន៍ប្រាកដដោយការកាត់នោះ ។

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា មិនគប្បីក្តិចស្លឹកឈើនោះឡើយ ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលលាមក ។

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា គប្បីដកឈើនោះព្រមទាំងឫសបានខ្លះ បើមានប្រយោជន៍ប្រាកដ ដោយការដកនោះ ។

បុរសគប្បីនៅក្នុងផ្ទះនៃបុគ្គលណា សូម្បីអស់មួយរាត្រី បុរសគប្បីបានបាយទឹកក្នុងសំណាក់នៃបុគ្គលណា មិនគប្បីគិតនូវអំពើអាក្រក់ ដល់បុគ្គលនោះសូម្បីដោយចិត្តឡើយ ពួកសប្បុរស តែងសរសើរនូវភាព នៃបុគ្គលកតញ្ញូ ។ បុរសគប្បីនៅក្នុងផ្ទះនៃបុគ្គលណា សូម្បីអស់មួយរាត្រី ដែលគេទំនុកបំរុងដោយបាយនិងទឹក មិនគប្បីគិតអំពើអាក្រក់ដល់បុគ្គលនោះ សូម្បីដោយចិត្តឡើយ បុគ្គលមានដៃមិនប្រទូស្ត តែងដុតកម្តៅនូវបុគ្គលដែលប្រ-

ទូស្តមិត្ត ។

សត្វណាបៀតបៀននូវបុគ្គល ដែលធ្វើឧបការៈមុន ដោយអំពើអាក្រក់ក្នុងកាលជាខាងក្រោយ សត្វនោះជាអ្នកបៀតបៀននូវបុគ្គលជាអ្នកមានបាតដៃទទឹក រមែងមិនឃើញនូវសេចក្តីចម្រើនទេ ។

បុគ្គលណា ប្រទូស្តដល់នរជនដែលមិនបានប្រទូស្ត ជាបុគ្គលស្អាត មិនមានទីទួលគឺកិលេស បាបរមែងត្រឡប់ទៅរកបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិតដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។ ខ្ញុំទោះបីទេវតាក្តីមនុស្សក្តី កម្ចាត់កម្ចាយដោយឥស្សរិយយសមិនបានឡើយ ខ្លួនខ្ញុំជាយក្ស សម្រេចនូវឫទ្ធិដ៏ឧត្តម ទៅក្នុងទីឆ្ងាយបាន ប្រកបដោយរូបសម្បត្តិនិងកម្លាំង ។

ដៃទាំងអស់របស់អ្នក មានសម្បុរដូចជាមាស ទ្រទ្រង់នូវវត្ថុជាទីប្រាថ្នាដោយអង្គុលីទាំង ៥ បញ្ចេញនូវរសផ្អែម រសទាំងឡាយផ្សេងៗរមែងហូរចេញ ខ្ញុំសម្គាល់ថាជាសក្កទេវរាជឈ្មោះបុរិន្ទទៈ ។

ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាព្រះឥន្ទ្រ ឈ្មោះបុរិន្ទទៈទេ ម្នាលអង្កុរៈ អ្នកចូរដឹងនូវខ្លួនខ្ញុំថាជាប្រេតច្យុតអំពីភេរុវនគរ ( មកកើត ) ក្នុងទីនេះទេតើ ។

អំពីជាតិមុន កាលអ្នកនៅក្នុងភេរុវនគរ មានសីលដូចម្តេច មានសមាចារដូចម្តេច ផលបុណ្យសម្រេចក្នុងដៃរបស់អ្នក ដោយការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដូចម្តេច ។

អំពីជាតិមុន កាលនោះខ្លួនខ្ញុំជាអ្នកតម្បាញ នៅក្នុងភេរុវនគរ ជាអ្នក

ប្រព្រឹត្តចិញ្ចឹមជីវិតដោយលំបាក ជាមនុស្សកំព្រា វត្ថុដែលគួរឲ្យទានមិនមាន ដល់ខ្ញុំទេ តែទីលំនៅរបស់ខ្ញុំនៅជិត ( ផ្ទះ ) នៃអសយ្ហមហាសេដ្ឋីដែលជាអ្នកប្រកបដោយសទ្ធា ជាម្ចាស់នៃទាន បានធ្វើបុណ្យ ជាអ្នកខ្មាសបាប ។ ពួកយាចកនិងពួកវណិព្វកៈ មានគោត្តផ្សេងៗគ្នា តែងទៅក្នុងទីនោះ ជនទាំងនោះ តែងសួររកទីលំនៅនៃអសយ្ហមហាសេដ្ឋីនឹងខ្ញុំក្នុងទីនោះ ។ សេចក្ដីចម្រើន ចូរមានដល់អ្នកចុះ ពួកយើងទៅក្នុងទីណា អសយ្ហមហាសេដ្ឋីតែងឲ្យទានក្នុងទីណា ខ្ញុំកាលដែលជនទាំងនោះសួរហើយ បានប្រាប់នូវលំនៅនៃអសយ្ហមហាសេដ្ឋីដល់ជនទាំងនោះ ។ ខ្ញុំបានលើកដើមដៃខាងស្ដាំ ( បង្ហាញលំនៅនៃអសយ្ហមហាសេដ្ឋីដល់ជនទាំងនោះ ) ថា សេចក្ដីចម្រើន ចូរមានដល់អ្នកទាំងឡាយចុះ អ្នកទាំងឡាយចូរនាំគ្នាទៅក្នុងទីនោះចុះ អសយ្ហមហាសេដ្ឋីតែងឲ្យទានក្នុងទីនុ៎ះ ដៃរបស់ខ្ញុំអាចឲ្យសម្រេចសេចក្ដីប្រាថ្នាបាន ដោយហេតុនោះដៃរបស់ខ្ញុំទើបបញ្ចេញនូវរសផ្អែមបាន ដោយហេតុនោះ បុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយការប្រព្រឹត្តដ៏ប្រសើរនោះ ។

បានឮថា អ្នកមិនដែលឲ្យទានដល់ជនណាមួយដោយដៃទាំងឡាយរបស់ខ្លួនទេ គ្រាន់តែអនុមោទនាទានរបស់បុគ្គលដទៃ ហើយលើកដៃចង្អុល ប្រាប់ផ្លូវប៉ុណ្ណោះ ។

ដៃរបស់ខ្ញុំ អាចឲ្យសម្រេចសេចក្ដីប្រាថ្នា ដោយហេតុនោះ ដៃរបស់ខ្ញុំទើបបញ្ចេញ នូវរសផ្អែមបាន ដោយហេតុនោះ បុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយការប្រព្រឹត្តដ៏ប្រសើរនោះ ។

បពិត្រលោកដ៏ចម្រើន អសយ្ហមហាសេដ្ឋីនោះ ជាអ្នកមានចិត្តជ្រះថ្លា ហើយបានឲ្យនូវទានដោយដៃខ្លួនឯង លុះសេដ្ឋីនោះ លះបង់នូវអត្តភាពជាមនុស្ស ហើយទៅទិសណា ។

ខ្ញុំក៏មិនដឹងនូវដំណើរទៅ ឬមក នៃអសយ្ហមហាសេដ្ឋី ជាអ្នកអត់ធន់ ដែលមានរស្មីផ្សាយចេញអំពីកាយឡើយ តែខ្ញុំឮថា អសយ្ហមហាសេដ្ឋី ទៅកើតជាមួយនឹងព្រះឥន្ទ្រក្នុងសំណាក់នៃស្តេចវេស្សវណ ។

បុគ្គលគួរធ្វើកុសល គួរឲ្យទានតាមសមគួរ បុគ្គលណាឃើញដៃដែលឲ្យតាមបំណងហើយនឹងមិនធ្វើបុណ្យកើត ។ ខ្ញុំទៅអំពីទីនេះ ដល់ទៅទ្វារកនគរនឹងតម្កល់ទុកនូវទាន ជាទីនាំមកនូវសេចក្តីសុខដល់ខ្ញុំដោយពិត ។ ខ្ញុំនឹងឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្តូងទឹក ពាងទឹកសម្រាប់ផឹក និងស្ពានក្នុងផ្លូវដែលលំបាកទៅ ។

ម្រាមដៃម្រាមជើងរបស់អ្នកក្ងែងកូង់ មុខរបស់អ្នកក្រញេវក្រញូវ ភ្នែករបស់អ្នកចេះតែហូរចេញនូវទឹកភ្នែក ព្រោះហេតុអ្វី បាបកម្មដូចម្តេច ដែលអ្នកបានធ្វើហើយ ។

កាលអសយ្ហគហបតី ដែលមានរស្មីចេញអំពីកាយ មានសទ្ធាគ្រប់គ្រងផ្ទះ ខ្ញុំជាអ្នកចាត់ចែងនូវទានទាំងឡាយក្នុងរោងទានរបស់គហបតីនោះ ។ ខ្ញុំបានឃើញពួកស្មូមដែលត្រូវការភោជនមកក្នុងទីនោះ ចៀសចេញទៅក្នុងទីដ៏សមគួរ ហើយបានធ្វើមុខក្រញេវក្រញូវ ។ ព្រោះហេតុនោះ បានជាម្រាមដៃម្រាមជើងរបស់ខ្ញុំក្ងែងកូង់ មុខរបស់ខ្ញុំក្រញេវក្រញូវ ភ្នែកទាំងឡាយរបស់

ខ្ញុំចេះតែហូរចេញនូវទឹកភ្នែក មានក្លិនស្អុយ បាបកម្មនោះ ខ្ញុំបានធ្វើហើយ ។

ម្នាលបុរសលាមក មុខរបស់អ្នកក្រញៀវក្រញូវផង ភ្នែករបស់អ្នកចេះតែហូរចេញនូវ ( ទឹកភ្នែកមានក្លិនស្អុយ ) ផង ( សមគួរ ) តាមហេតុ ព្រោះអ្នកបានធ្វើមុខក្រញៀវក្រញូវចំពោះទានបុគ្គលដទៃ ។

បុរសកាលឲ្យទាន បាយ ទឹក ខាទនីយៈ សំពត់និងសេនាសនៈ តើគប្បីធ្វើ ( ទាននោះ ) ឲ្យសម្រេចដល់បុគ្គលដទៃ ដូចម្ដេច ។

ខ្ញុំទៅអំពីទីនេះ ដល់ទៅទ្វារកនគរហើយ នឹងតម្កល់នូវទាន ជាទីនាំមកនូវសេចក្ដីសុខដល់ខ្ញុំដោយពិត ។ ខ្ញុំនឹងឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្ដូងទឹក ទឹកសម្រាប់ផឹក និងសង់ស្ពានក្នុងផ្លូវលំបាកទៅ ។

មែនពិត លុះអង្កុរៈនោះ ត្រឡប់អំពីទីនោះមកដល់ទ្វារកនគរហើយ ក៏បានតម្កល់នូវទាននោះ ជាទីនាំមកនូវសេចក្ដីសុខ ។ បានឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្ដូងទឹក និងពាងទឹកសម្រាប់ផឹក ដោយចិត្តជ្រះថ្លា ។ អ្នកណាឃ្លាន អ្នកណាស្រេក អ្នកណានឹងស្លៀកដណ្ដប់សំពត់ អ្នកណាលំបាកដោយយាន ចូរទឹមពាហនៈបរអំពីទីនេះទៅចុះ ។ អ្នកណាចង់បានឆត្រ ចង់បានគ្រឿងក្រអូប ចង់បានកម្រងផ្កា ចង់បានស្បែកជើង ចូរយកទៅចុះ ពួកជាងកាត់សក់ ពួកអ្នកធ្វើបាយ និងពួកអ្នកក្រងផ្កា តែងស្រែកឃោសនាក្នុងលំនៅនៃអង្កុរៈ ទាំងពេលព្រឹក ទាំងពេលល្ងាច សព្វៗកាលក្នុងទីនោះដូច្នេះ ។

ជនតែងដឹងនូវខ្ញុំថា អង្កុរៈដេកជាសុខ ម្នាលសិន្ធុកមាណព តែខ្ញុំដេក

ជាទុក្ខ ព្រោះមិនឃើញពួកយាចក ។ ជនតែងដឹងនូវខ្ញុំថា អង្គុរៈតែងដេក លក់ជាសុខ ម្នាលសិន្ធកមាណព តែខ្ញុំដេកជាទុក្ខព្រោះឃើញនូវពួកវណិព្វក ជនតិច ។ ប្រសិនបើព្រះឥន្ទ្រជាធំជាងទេវតាក្នុងជាន់តាវត្តិង្ស គប្បីឲ្យពរ ដល់អ្នក តើអ្នកគប្បីប្រាថ្នានូវពរ ដល់លោកទាំងពួងដូចម្ដេច ។

បើព្រះឥន្ទ្រជាធំជាងទេវតាក្នុងជាន់តាវត្តិង្ស គប្បីឲ្យនូវពរដល់ខ្ញុំ កាល ខ្ញុំក្រោកឡើងអំពីព្រឹក ក្នុងវេលាជាទីរះឡើងនៃព្រះអាទិត្យ ភិក្ខាទាំងឡាយដ៏ ជាទិព្វ គប្បីកើតប្រាកដពួកអ្នកមានសីលនិងយាចកគប្បីមានប្រាជក កាល ខ្ញុំឲ្យនូវទានកុំគប្បីអស់ទៅឡើយ លុះខ្ញុំឲ្យរួចហើយកុំគប្បីក្ដៅក្រហាយ កាល ខ្ញុំកំពុងឲ្យគប្បីញុំាងចិត្តឲ្យជ្រះថ្លា បពិត្រសក្កៈ ខ្ញុំចង់បាននូវពរយ៉ាងនេះ ។

បុគ្គលកុំគប្បីឲ្យនូវទ្រព្យគាប់ចិត្តទាំងអស់ដល់បុគ្គលដទៃឡើយ បុគ្គល គប្បីឲ្យនូវទានផង គប្បីរក្សានូវទ្រព្យផង ព្រោះថា ទ្រព្យនោះឯងប្រសើរ ជាងទាន ត្រកូលទាំងឡាយមិនចម្រើន ព្រោះឲ្យទានខ្លាំងពេកទេ ។ អ្នក ប្រាជ្ញទាំងឡាយ រមែងមិនសរសើរនូវការមិនឲ្យទានផង នូវការឲ្យទានច្រើន ពេកផង ព្រោះថា ទ្រព្យនោះឯងប្រសើរជាងទាន បុគ្គលគួរប្រព្រឹត្តឲ្យស្មើ នោះជាធម៌របស់អ្នកប្រាជ្ញ ។

ឱហ្ន៎ អាត្មាអញគប្បីឲ្យនូវទាន ព្រោះថា សប្បុរសទាំងឡាយអ្នកមាន ចិត្តស្ងប់រម្ងាប់ហើយគប្បីគប់រកនូវអាត្មាអញ អាត្មាអញ ញុំាងពួកវណិព្វកៈ ទាំងពួងឲ្យឆ្អែតស្កប់ស្កល់ ដូចមហាមេឃញុំាងទីទាបឲ្យពេញដូច្នោះ ។

សម្បុរមុខ របស់បុគ្គលណាជ្រះថ្លា ព្រោះឃើញនូវយាចកទាំងឡាយ

បុគ្គលនោះលុះឲ្យហើយ រមែងមានចិត្តត្រេកអរ នោះជាសុខរបស់បុគ្គលអ្នកគ្រប់គ្រងផ្ទះ ។ សម្បុរមុខរបស់បុគ្គលណាជ្រះថ្លា ព្រោះឃើញនូវយាចកទាំងឡាយ បុគ្គលនោះ លុះឲ្យរួចហើយ រមែងមានចិត្តត្រេកអរនេះជាការបរិបូណ៌នៃយញ្ញ ។ បុគ្គលមុននឹងឲ្យទាន ក៏មានចិត្តស្អាត កំពុងឲ្យ ក៏ញុំាងចិត្តឲ្យជ្រះថ្លា លុះឲ្យរួចហើយ មានចិត្តត្រេកអរ នេះជាការបរិបូណ៌នៃយញ្ញ ។

បុគ្គលតែងឲ្យភោជនជានិច្ចដល់ជនអ្នកប្រាថ្នាបុណ្យ ក្នុងលំនៅនៃអង្កុរៈអស់ ៦០០០០ ដឹក ។ ពួកអ្នកធ្វើបាយចំនួន ៣ ពាន់ ( ៣០០០ ) នាក់ប្រដាប់នូវកុណ្ឌលដ៏វិចិត្រដោយកែវមណី ជាអ្នកខ្វល់ខ្វាយនូវបុណ្យក្នុងការឲ្យទានតែងអាស្រ័យចិញ្ចឹមជីវិតនឹងអង្កុរៈ ។ ពួកបុរសចំនួន ប្រាំមួយម៉ឺន ( ៦០០០០ ) នាក់ ប្រដាប់នូវកុណ្ឌលដ៏វិចិត្រដោយកែវមណី ជាមាណពតែងពុះឧសក្នុងមហាទាននៃអង្កុរៈ ។ ពួកស្ត្រីចំនួន មួយម៉ឺនប្រាំមួយពាន់ ( ១៦០០០ ) នាក់ ប្រដាប់នូវគ្រឿងអលង្ការទាំងពួង ជានារីអ្នកចាត់ចែងប្រមូលនូវកណ្ឌៈក្នុងមហាទាននៃអង្កុរៈ ។ ពួកស្ត្រីចំនួនមួយម៉ឺនប្រាំមួយពាន់ ( ១៦០០០ ) នាក់ ប្រដាប់នូវគ្រឿងអលង្ការទាំងពួង ជាអ្នកកាន់នូវវែកហើយចូលទៅឈរនៅ ( នាបរិវេណ ) ក្នុងមហាទាននៃអង្កុរៈ ។ អ្នកចូរឲ្យទានច្រើនដល់ជនច្រើន ម្នាលនាងក្សត្រី នាងចូរឲ្យទានអស់កាលដ៏យូរចុះ ធ្វើនូវសេចក្តីកោតក្រែងដោយគោរពផង ដោយដៃផង ឲ្យរឿយៗចុះ ។ អង្កុរៈបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ អស់ខែទាំងឡាយជាច្រើនផង អស់

បក្ខទាំងឡាយជាច្រើនផង អស់ជូវនឹងឆ្នាំទាំងឡាយជាច្រើនផង ក្នុងចន្លោះនៃកាលដ៏វែងឆ្ងាយ ។ អង្កុរៈបានឲ្យទានយ៉ាងនេះផង បូជាយ៉ាងនេះផង អស់ចន្លោះនៃកាលដ៏វែង អង្កុរៈនោះ លុះលះបង់រាងកាយជាមនុស្សនេះទៅ ក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្ស ។ ឥន្ទកៈបានឲ្យនូវចង្ហាន់មួយវែកដល់ព្រះអនុរុទ្ធ ឥន្ទកៈនោះលុះលះបង់រាងកាយជាមនុស្សនេះទៅ ក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្សដែរ ។ ឥន្ទកៈជាអ្នករុងរឿងជាងអង្កុរៈដោយឋានៈ ១០ យ៉ាង គឺរូប ១ សំឡេង ១ រស ១ ក្លិន ១ ផោដ្ឋព្វដ៏ជាទីតម្រេកនៃចិត្ត ១ អាយុ ១ យស ១ សម្បុរ ១ សេចក្ដីសុខ ១ ភាវៈជាធំ ១ ឥន្ទកៈទេវបុត្តរុងរឿងជាងអង្កុរៈទេវបុត្តដោយភាពជាធំ ( យ៉ាងនេះ ) ។

( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលអង្កុរៈ មហាទានដែលអ្នកបានឲ្យហើយក្នុងចន្លោះនៃកាលដ៏វែង ឥឡូវអ្នកទៅអង្គុយនៅក្នុងទីឆ្ងាយ ចូរអ្នកមកក្នុងទីជិតនៃតថាគត ។

កាលណា ព្រះពុទ្ធឧត្តមជាងបុរស គង់នៅលើថ្មបណ្ឌុកម្ពលជិតគល់នៃបារិច្ឆត្តកព្រឹក្សក្នុងជាន់ត្រៃត្រិង្ស ។ ទេវតាទាំងឡាយក្នុងលោកធាតុទាំង ១០ បានប្រជុំគ្នា ចូលទៅអង្គុយជិតព្រះសម្ពុទ្ធ ដែលគង់នៅលើកំពូលភ្នំ ( សុមេរុ ) ។ ទេវតាណាមួយ រុងរឿងជាងព្រះសម្ពុទ្ធដោយវណ្ណៈមិនមានឡើយ ។ មានតែព្រះសម្ពុទ្ធមួយព្រះអង្គឯងប៉ុណ្ណោះ រុងរឿងកន្លងនូវទេវតាទាំងអស់ ។ ក្នុងកាលនោះ អង្កុរៈទេវបុត្តនៅក្នុងទីប្រមាណ ១២ យោជន៍ ឥន្ទកទេវបុត្តរុងរឿងក្រៃពេក ក្នុងទីជិតនៃព្រះសម្ពុទ្ធ ។ ព្រះសម្ពុទ្ធទ្រង់រមិល

មើលនូវអង្កុរទេវបុត្ត និងឥន្ទកទេវបុត្ត កាលទ្រង់សរសើរនូវទក្ខិណេយ្យបុគ្គល បានត្រាស់សម្តែងនូវពាក្យនេះថា ម្នាលអង្កុរៈ មហាទាន ដែលអ្នកឲ្យហើយអស់ចន្លោះនៃកាលដ៏វែង អ្នកអង្គុយក្នុងទីឆ្ងាយពេកណាស់ ចូរមកជិតតថាគតមក ។

អង្កុរទេវបុត្ត ដែលព្រះសម្ពុទ្ធមានព្រះអង្គអប់រំហើយ ទ្រង់ដាស់តឿនហើយ ក៏បានក្រាបបង្គំទូលដូច្នេះថា ប្រយោជន៍អ្វីដោយទាននោះ របស់ខ្ញុំព្រះអង្គព្រោះ ( ទាននោះ ) សូន្យចាកទក្ខិណេយ្យបុគ្គល ។ ឥន្ទកយក្សនេះឯង ឲ្យទានតិចតួចទេ រុងរឿងជាងពួកខ្ញុំព្រះអង្គ ដូចជាព្រះចន្ទក្នុងពួកផ្កាយ ។

( ព្រះសម្ពុទ្ធត្រាស់ថា ) ពូជដែលបុគ្គលព្រោះហើយ សូម្បីមានប្រមាណច្រើនក្នុងស្រែទួល ផលរមែងមិនបរិបូណ៌ ទាំងមិនញុំាងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ ទានដែលបុគ្គលតម្កល់ទុកហើយ មានប្រមាណច្រើន ក្នុងបុគ្គលទ្រុស្តសីលទាំងឡាយ ផលរមែងមិនបរិបូណ៌ ទាំងមិនបានញុំាងទាយកឲ្យត្រេកអរបាន ក៏ដូច្នោះឯង ។ ពូជដែលបុគ្គលព្រោះហើយ សូម្បីតិចក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញុំាងអ្នកស្រែឲ្យត្រេកអរបាន ដូចម្តេចមិញ សក្ការៈដែលបុគ្គលធ្វើហើយ សូម្បីតិចតួចក្នុងតាទិបុគ្គលទាំងឡាយ មានសីល មានគុណ បុណ្យរមែងមានផលច្រើន ក៏ដូច្នោះឯង ។ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលណារមែងមានផលច្រើន បុគ្គលគួរពិចារណាហើយសឹមឲ្យទាន ទាយកទាំងឡាយ ពិចារណាហើយ

ឲ្យនូវទាន តែងទៅកាន់ឋានសួគ៌

ទានដែលបុគ្គលពិចារណាហើយទើបឲ្យ ព្រះសុគតទ្រង់សរ-សើរហើយ ទក្ខិណេយ្យបុគ្គលណាដែលមាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមានផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ។

**ចប់ រឿង អង្កុរប្រេតទី ៩ ។**

# អដ្ឋកថា អង្កុរប្រេត

[ ២១ ] ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអង្កុរប្រេត ទើបត្រាស់គាថានេះ មានពាក្យជាដើមថា **យស្ស អត្ថាយ គច្ឆាម** ។ ក្នុងទីនេះមិនមានអង្កុរប្រេតក៏ពិត តែព្រោះការប្រព្រឹត្តរបស់អង្កុរនោះ ទាក់ទងដោយប្រេត ដូច្នោះ ការប្រព្រឹត្តរបស់អង្កុរដែលទាក់ទងដោយប្រេតនោះទើបលោកពោលថា អង្កុរបេតវត្ថុ ។

ក្នុងសេចក្តីនោះ មានសង្ខេបកថា ដូចតទៅនេះថា មានក្សត្រ ១១ អង្គ គឺព្រះនាមអញ្ជនទេវីនិងប្អូនប្រុស ១០ អង្គគឺ វាសុទេព ១ ពលទេព ១ ចន្ទទេព ១ សុរិយទេព ១ អគ្គិទេព ១ វរុណទេព ១ អជ្ជុន ១ បជ្ជុន ១ ឃតបណ្ឌិត ១ អង្កុរ ១ ។ អាស្រ័យគភ៌របស់ព្រះនាងទេវគព្ភាដែលជាធីតារបស់ព្រះបាទមហាកំសៈក្នុងអសិតញ្ជនទគរ ដែលព្រះបាទកំសៈ គ្រប់

គ្រងក្នុងឧត្តរាបថជនបទ ព្រោះអាស្រ័យឧបសាគរ ដែលជាឱរសរបស់ព្រះបាទមហាសាគរ ជាធំក្នុងឧត្តរមធុរជនបទ ។ បណ្តាក្សត្រទាំងនោះ ក្សត្របងប្អូន មានវាសុទេពជាដើម ប្រើកងចក្កផ្តាច់ព្រះជន្មរបស់ព្រះរាជាទាំងអស់ ៦៣០០០ នគរ ពេញជម្ពូទ្វីប តាំងពីអសិតញ្ជននគរ រហូតដល់ ទ្វារវតីនគរ ជាទីបំផុត ហើយប្រថាប់នៅក្នុងទ្វារវតីនគរ ចែករដ្ឋជា ១០ ចំណែក តែមិនបានគិតដល់ព្រះនាងអញ្ជនទេវី ដែលជាព្រះជេដ្ឋកគិនី តែកាលរឭកបាន ទើបពោលថា យើងចែកជា ១១ ចំណែក ។ ព្រះបាទអង្កុរដែលជាប្អូនពៅរបស់ក្សត្រទាំងនោះពោលថា សូមឲ្យចំណែករបស់ខ្ញុំដល់បងស្រីចុះ ខ្ញុំនឹងធ្វើជំនួញចិញ្ចឹមជីវិត សូមទ្រង់ទាំងឡាយឲ្យសួយក្នុងជនបទរៀងៗខ្លួនដល់ខ្ញុំ ។ ក្សត្រទាំងនោះទទួលព្រះតម្រាស់ហើយ យកចំណែករបស់អង្កុរឲ្យព្រះជេដ្ឋកគិនី ព្រះរាជាទាំង ៩ អង្គ ប្រថាប់នៅក្នុងនគរទ្វារវតី ។

ឯអង្កុរប្រកបនូវការជួញដូរ បំពេញមហាទានជានិច្ចកាល ។ អង្កុរនោះមានទាសៈម្នាក់ ជានាយឃ្លាំងប្រាថ្នាប្រយោជន៍ អង្កុរគាប់ចិត្ត ក៏បានសូមកុលធីតាម្នាក់ ឲ្យដល់បុរសនោះ កាលនាងតាំងគភ៌ប៉ុណ្ណោះ បុរសនោះក៏ស្លាប់ កាលកូនកើតហើយ អង្កុរបានយកថ្លៃឈ្នួលដែលឲ្យដល់ឪពុកទារកនោះឲ្យដល់ទារក កាលក្មេងនោះចម្រើនវ័យ ក៏កើតការវិនិច្ឆ័យក្នុងរាជត្រកូលថា កុមារនេះជាទាសៈ ឬមិនមែន ព្រះនាងអញ្ជនទេវីបានស្តាប់ដូច្នោះ ក៏ត្រាស់ប្រៀបដោយមេគោទឹកដោះ ហើយត្រាស់ថា កូនរបស់មាតាដែលជាអ្នកជា ក៏ជាអ្នកជាប៉ុណ្ណោះ ដូច្នេះហើយ ទើបឲ្យផុតចាកភាពជាទាសៈ ។

តែព្រោះការខ្មាសអៀន កុមារនោះមិនអាចនៅក្នុងទីនោះបាន ទើបទៅកាន់ពោរុវនគរ នាំធីតារបស់ជាងតម្បាញម្នាក់ទៅផង ចិញ្ចឹមជីវិតដោយការត្បាញ ។ សម័យនោះ មានមហាសេដ្ឋី ឈ្មោះអសយ្ហៈ ក្នុងពោរុវនគរ គាត់បានឲ្យមហាទានដល់សមណព្រាហ្មណ៍ មនុស្សកំព្រា អ្នកដំណើរ វណិព្វកៈ និងយាចកទាំងឡាយ ។ ជាងតម្បាញនោះ កើតបីតិសោមនស្ស លាដៃចង្អុលឲ្យមើលនិវេសន៍របស់អសយ្ហសេដ្ឋី ដល់ជនដែលមិនស្គាល់ផ្ទះរបស់សេដ្ឋីថា សូមអ្នកទាំងឡាយទៅក្នុងទីនោះ ហើយនឹងបានវត្ថុដែលគួរបាន កម្មរបស់បុរសនោះមកហើយក្នុងបាលីនោះឯង ។

សម័យតមក គាត់បានធ្វើកាលកិរិយា កើតជាភុម្មទេវតាត្រង់ដើមជ្រៃមួយដើមក្នុងមរុភូមិ ( វាលខ្សាច់ ) ដៃស្តាំរបស់ទេវតានោះ បានឲ្យនូវវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាង ។ ក្នុងពោរុវនគរនោះឯង មានបុរសម្នាក់ ជាអ្នកខ្នះខ្នែងក្នុងទានរបស់អសយ្ហសេដ្ឋី តែមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លាជាមិច្ឆាទិដ្ឋិ មិនអើពើក្នុងការបំពេញបុណ្យ ធ្វើកាលកិរិយាហើយ កើតជាប្រេតមិនឆ្ងាយអំពីលំនៅរបស់ទេវតានោះ ។ កម្មដែលបុរសនោះធ្វើមកហើយក្នុងព្រះបាលីនោះឯង ។ ចំណែកអសយ្ហសេដ្ឋីធ្វើកាលកិរិយាហើយ ចូលដល់ភាពជាសម្លាញ់របស់សក្កទេវរាជក្នុងស្ថានតាវត្តិង្ស ។

ក្នុងកាលតមក ព្រះបាទអង្កុរផ្ទុកទំនិញ ៥០០ រទេះ ឯព្រាហ្មណ៍ម្នាក់ទៀតផ្ទុកទំនិញ ៥០០ រទេះ សេចក្តីថា ជនទាំង ២ ផ្ទុកទំនិញដោយរទេះ ១០០០ បរទៅតាមផ្លូវមរុកន្តារ នាំគ្នាវង្វេងផ្លូវដល់ទីនោះឯង ក្នុងពេលច្រើន

ថ្ងៃ របូតអស់ស្បៀងនិងទឹកមួយអន្លើដោយអាហារ ។ ស្តេចអង្កុរបញ្ជូនទូតសេះមកស្វែងរកទឹកទាំង ៤ ទិស ។ លំដាប់នោះ ទេវតាដៃទិព្វឃើញជនទាំងនោះបានទទួលនូវការវឹកវរនោះ នឹកដល់ឧបការៈដែលព្រះបាទអង្កុរ បានធ្វើដល់ខ្លួនក្នុងកាលមុន ទើបគិតថា ណ្ហើយចុះ ឥឡូវនេះ អញនឹងជាទីពឹងរបស់ស្តេចអង្កុរនេះ ដូច្នេះហើយ ទើបចង្អុលឲ្យមើលដើមជ្រៃ ដែលជាលំនៅរបស់ខ្លួន ។ បានឮថា ដើមជ្រៃនោះសម្បូរដោយមែកនិងប្រគាប មានស្លឹកក្រាស់ មានម្លប់ត្រឈឹងត្រឈៃ មានពួរច្រើនពាន់ពួរ ពោលដោយទំហំនិងកម្ពស់ប្រមាណ ១ យោជន៍ ។ ស្តេចអង្កុរឃើញដូច្នោះហើយ កើតនូវអស្ចារ្យ បានបោះជំរំខាងក្រោមដើមជ្រៃនោះ ។ ទេវតាលាដៃស្តាំរបស់ខ្លួនឲ្យមនុស្សទាំងអស់ផឹកទឹកជាដំបូង បន្ទាប់មកបានឲ្យវត្ថុដែលមនុស្សទាំងនោះត្រូវការ ។

កាលមហាជននោះ ឆ្អែតស្កប់ស្កល់តាមត្រូវការដោយបាយនិងទឹកជាដើមច្រើនប្រភេទយ៉ាងនេះ ក្រោយមក កាលអន្តរាយក្នុងផ្លូវស្ងប់ ព្រាហ្មណ៍ដែលជាឈ្លួញនោះ ដាក់ចិត្តដោយអយោនិសោមនសិការថា អញទៅអំពីទីនេះកាន់ដែនកម្ពោជៈហើយ នឹងធ្វើអ្វីដើម្បីឲ្យបានទ្រព្យ អញនឹងនាំទេវតានេះឯងទៅដោយឧបាយណាមួយ ឡើងកាន់យានទៅកាន់នគររបស់អញ កាលគិតយ៉ាងនេះហើយ កាលប្រាប់សេចក្តីនោះដល់ព្រះបាទអង្កុរ បានពោលគាថា ២ ថា

យើងទាំងឡាយ ជាអ្នកស្វែងរកទ្រព្យ ទៅកាន់ដែនកម្ពុជៈ

ព្រោះហេតុនៃទ្រព្យណា យក្សនេះជាអ្នកឲ្យទ្រព្យនោះតាមប្រាថ្នា យើងនឹងនាំយកយក្សនេះទៅ ឬថាយើងចាប់យកយក្សនេះទាំងអំណាចឲ្យបានដោយងាយ លើកឡើងកាន់យានហើយទៅកាន់ទ្វារកនគរដោយឆាប់រហ័ស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យស្ស អត្ថាយ** ប្រែថា ព្រោះហេតុនៃប្រយោជន៍ណា ។ បទថា **កម្ពោជំ** បានដល់ ដែនកម្ពោជៈ ។ បទថា **ធនហារកា** បានដល់ រកទ្រព្យដែលបានមកដោយការលក់ ។ បទថា **កាមទទោ** បានដល់ ដែលឲ្យវត្ថុតាមត្រូវការ ។ បទថា **យក្ខោ** បានដល់ ទេវបុត្ត ។ បទថា **ឥយាមសេ** បានដល់ នឹងនាំទៅ ។ បទថា **សាធុកេន** បានដល់ ដោយការអង្វរ ។ បទថា **បសយ្ហ** បានដល់ កំហែងដោយកម្លាំងបាយ ។ បទថា **យានំ** បានដល់ យានដែលនាំមកនូវសេចក្តីសុខ ។ បទថា **ទ្វារកំ** បានដល់ ទ្វារវតីនគរ អធិប្បាយថា ក្នុងវេលាក្រោយ មានដូចតទៅនេះ ពួកយើងប្រាថ្នាទៅអំពីនេះកាន់ដែនកម្ពោជៈ ដើម្បីប្រយោជន៍ណា ប្រយោជន៍ដែលគប្បីឲ្យសម្រេចដោយការទៅនោះ រមែងសម្រេចក្នុងទីនេះឯងព្រោះទេវបុត្តនេះ ជាអ្នកឲ្យសម្បត្តិដែលគួរប្រាថ្នា ព្រោះហេតុនោះ យើងសូមអង្វរទេវបុត្តនេះ ហើយនាំទៅតាមអនុមតិរបស់ទេវបុត្តនោះ ឬបើមិនទៅតាម នឹងបីទេវបុត្តនេះឡើងកាន់យានដោយកម្លាំងបាយ ហើយចាប់ទេវបុត្តនោះចងដៃទៅក្រោយទុកក្នុងយាន ចេញអំពីទីនេះឯង ប្រញាប់ទៅកាន់ទ្វារវតីនគរ ។

ចំណែកព្រះបាទអង្កុរ ត្រូវព្រាហ្មណ៍ដឹកនាំយ៉ាងនេះហើយ តាំងនៅក្នុង

សប្បុរសធម៌ កាលបដិសេធនូវពាក្យរបស់ព្រាហ្មណ៍ ទើបពោលគាថានេះថា

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា មិនគួរកាច់មែកឈើនោះឡើយ ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលលាមកដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ន ភញ្ជេយ្យ** ប្រែថា មិនគប្បីកាច់ ។ បទថា **មិត្តទុព្ភោ** បានដល់ ទ្រុស្តមិត្ត គឺនាំសេចក្តីវិនាសឲ្យដល់មិត្តទាំងនោះ ។ បទថា **ចាបកោ** បានដល់ មនុស្សមិនល្អ គឺមនុស្សច្រើនដោយការប្រទូស្តចំពោះមិត្ត ។ ពិតហើយ ដើមឈើដែលមានម្លប់ត្រជាក់ យ៉ាងណា រមែងបន្ទោបង់នូវការក្រវល់ក្រវាយ របស់បុគ្គលដែលត្រូវកម្តៅដុតរោល បុគ្គលណាមួយ មិនគួរគិតប្រទូស្តចំពោះដើមឈើនោះ នឹងពោលទៅថ្វីដល់ពួកសត្វនោះ ។ អង្កុរពោណិជសម្តែងថា ទេវបុត្តនេះជាសប្បុរស ជាបុព្វការីបុគ្គល ជាអ្នកបន្ទោបង់នូវសេចក្តីទុក្ខ ជាអ្នកមានឧបការៈច្រើនដល់យើងទាំងឡាយ យើងមិនគួរគិតប្រទូស្តដោយហេតុណាមួយ ចំពោះទេវបុត្តនោះ ដោយពិត ទេវបុត្តនោះ យើងគួរបូជានោះឯង ។

ព្រាហ្មណ៍បានស្តាប់ដូច្នោះ គិតថា អញនឹងប្រាប់មូលហេតុនៃសេចក្តីត្រូវការ ដូច្នេះហើយ អាស្រ័យផ្លូវដែលជាលំនាំតាំងនៅក្នុងចំណែកជំទាស់នឹងព្រះបាទអង្កុរ ទើបពោលគាថាថា

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា គប្បីកាត់

ឈើនោះបានខ្លះ បើមានប្រយោជន៍ប្រាកដដោយការកាត់នោះ

ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អត្ថោ ចេ តាទិសោ សិយា** សេចក្ដីថា បើមានសេចក្ដីត្រូវការដោយទព្វសម្ភារៈ ដូច្នោះ អធិប្បាយថា សូម្បីដើមរបស់ដើមឈើនោះក៏គួរកាត់ នឹងពោលទៅថ្វីដល់មែកជាដើមនោះ ។

កាលព្រាហ្មណ៍ពោលយ៉ាងនេះហើយ ព្រះបាទអង្កុរកាលនឹងផ្គងចំពោះសប្បុរសធម៌ ទើបពោលគាថានេះថា

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណា មិនគប្បីក្តិចស្លឹកឈើនោះឡើយ ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលលាមក

ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ន តស្ស បត្តំ ភិន្ទេយ្យ** សេចក្ដីថា មិនគប្បីធ្វើត្រឹមតែស្លឹកមួយរបស់ដើមឈើនោះឲ្យធ្លាក់ នឹងពោលថ្វីដល់ការកាប់មែកជាដើមនោះ ។

ព្រាហ្មណ៍កាលនឹងផ្គងវាទៈរបស់ខ្លួនទៀត ទើបពោលគាថាថា

បុគ្គលគប្បីអង្គុយ ឬដេកនៅក្រោមម្លប់ឈើណាគប្បីដកឈើនោះព្រមទាំងឫសបានខ្លះ បើមានប្រយោជន៍ប្រាកដដោយការដកនោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សមូលម្បិ តំ អព្វុហេ** សេចក្ដីថា គប្បីដក គឺគប្បីផ្តាច់ផ្តិលឡើងនូវដើមឈើនោះ ព្រមទាំងឫស គឺព្រមដោយឫសក្នុង

ទីនោះឯង ។

កាលព្រាហ្មណ៍ពោលយ៉ាងនេះហើយ ព្រះបាទអង្កុរ មានបំណងនឹងធ្វើបែបផែនទោះឲ្យឥតប្រយោជន៍ទៀត ទើបពោលគាថា ៣ ថា

បុរសគប្បីនៅក្នុងផ្ទះនៃបុគ្គលណា សូម្បីអស់មួយរាត្រី បុរសគប្បីបានបាយទឹក ក្នុងសំណាក់នៃបុគ្គលណា មិនគប្បីគិតនូវអំពើអាក្រក់ ដល់បុគ្គលនោះ សូម្បីដោយចិត្តឡើយ ពួកសប្បុរសតែងសរសើរនូវភាពនៃបុគ្គលកតញ្ញូ ។

បុរសគប្បី នៅក្នុងផ្ទះនៃបុគ្គលណា សូម្បីអស់មួយរាត្រី ដែលគេទំនុកបំរុងដោយបាយនឹងទឹក មិនគប្បីគិតអំពើអាក្រក់ដល់បុគ្គលនោះ សូម្បីដោយចិត្តឡើយ បុគ្គលមានដៃមិនប្រទូស្តតែងដុតកម្តៅនូវបុគ្គលដែលប្រទូស្តមិត្ត ។

សត្វណាបៀតបៀននូវបុគ្គល ដែលធ្វើឧបការៈមុន ដោយអំពើអាក្រក់ក្នុងកាលជាខាងក្រោយ សត្វនោះជាអ្នកបៀតបៀននូវបុគ្គលជាអ្នកមានបាតដៃទទឹក រមែងមិនឃើញនូវសេចក្តីចម្រើនទេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យស្ស** បានដល់ ចំពោះបុគ្គលណា ។ បទថា **ឯករត្តិម្បិ** សេចក្តីថា គប្បីអាស្រ័យក្នុងផ្ទះតែម្យ៉ាងសូម្បីត្រឹមតែមួយរាត្រី ។ បទថា **យត្ថន្នបានំ បុរិសោ លភេថ** សេចក្តីថា បុរសពួកខ្លះគប្បីបានកោជនណាមួយ ទោះជាបាយឬទឹកក្នុងសម្នាក់នៃបុគ្គលណា ។ បទថា **ន តស្ស**

**ចាបំ មនសាបិ ចិន្តយេ** សេចក្តីថា បុគ្គលមិនគប្បីមានចិត្តប្រទូស្តចំពោះវត្ថុដែលមិនល្អ គឺវត្ថុដែលឥតប្រយោជន៍ចំពោះបុគ្គលនោះ សូម្បីដោយចិត្តនឹងពោលថ្វីដល់កាយនិងវាចានោះ ។ បើមានពាក្យសួរថា សេចក្តីនោះព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពជាបុគ្គលកតញ្ញូដែលសប្បុរសទាំងឡាយសរសើរហើយ អធិប្បាយថា ឈ្មោះថា ភាពជាបុគ្គលកតញ្ញូដែលបុរសដ៏ឧត្តម មានព្រះពុទ្ធជាដើម សរសើរហើយ ។

បទថា **ឧបដ្ឋិតោ** សេចក្តីថា គប្បីចូលទៅអង្គុយជិត គឺគប្បីឧបដ្ឋាកដោយបាយនិងទឹកជាដើមថា សូមលោកទទួលវត្ថុនេះ សូមលោកបរិភោគវត្ថុនេះ ។ បទថា **អទ្ទភាណិ** បានដល់ ជាអ្នកមានបាតដៃមិនបៀតបៀន គឺជាអ្នកសង្រួមដៃ ។ បទថា **ឧហតេ មិត្តទុព្ភី** សេចក្តីថា រមែងជុតពាល គឺរមែងធ្វើបុគ្គលដែលច្រើនដោយការប្រទូស្តមិត្តនោះ ឲ្យវិនាស ។ ពោលដោយអត្ថ ឈ្មោះថា រមែងជុតបុគ្គលដទៃដែលធ្វើខុសក្នុងបុគ្គលមិនប្រទូស្តដែលសម្បូរដោយអធ្យាស្រ័យជាប្រយោជន៍ គឺនាំមកនូវសេចក្តីវិនាស ដល់បុគ្គលប្រទូស្តនោះឯងដោយមិនប្លែកគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> បុគ្គលណា ប្រទូស្តដល់នរជនដែលមិនបានប្រទូស្ត ជាបុគ្គលស្អាត មិនមានទីទួលគឺកិលេស បាបរមែងត្រឡប់ទៅរកបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ដូច្នេះ ។

បទថា **យោ បុព្វេ កតកល្យាណោ** សេចក្ដីថា បុគ្គលណាមានសេចក្ដីល្អដែលបុគ្គលល្អពួកខ្លះធ្វើឲ្យ គឺធ្វើឧបការៈឲ្យ ។ បទថា **បច្ឆា បាបេន ហឹសតិ** សេចក្ដីថា ក្រោយមក បៀតបៀនបុគ្គលនោះដែលធ្វើនូវឧបការៈមុនដោយអំពើអាក្រក់ គឺកម្មមិនល្អ បានដល់ ដោយកម្មដែលឥតប្រយោជន៍ ។ បទថា **អល្លបាណិហតោ បោសោ** សេចក្ដីថា បុគ្គលកម្ចាត់ គឺបៀតបៀនបុគ្គលដែលមានបាតដៃសើម គឺមានបាតដៃដែលទទឹក ព្រោះធ្វើឧបការៈ បានដល់ ធ្វើឧបការៈមុនដោយដៃដែលលាងស្អាតហើយ ដោយន័យដូចពោលហើយខាងដើម ។ ម្យ៉ាងទៀត កម្ចាត់ដោយការ បៀតបៀនបុគ្គលដែលធ្វើឧបការៈមុននោះ ឈ្មោះថា កម្ចាត់បុគ្គលដែលមានបាតដៃទទឹក ។ បានដល់បុគ្គលអកតញ្ញូ ។ បទថា **ន សោ ភទ្រានិ បស្សតិ** សេចក្ដីថា បុគ្គលនោះ គឺបុគ្គលតាមដែលពោលហើយ រមែងមិនឃើញ រមែងមិនជួប គឺរមែងមិនបានក្នុងលោកនេះនិងក្នុងឥឡូវនេះ ។

ព្រាហ្មណ៍នោះ ត្រូវព្រះបាទអង្កុរ ដែលសរសើរសប្បុរសធម៌ ពោលសង្កត់យ៉ាងនេះ ក៏នៅស្ងៀម ។ ឯទេវបុត្តស្ដាប់ពាក្យឆ្លើយឆ្លងរបស់ជនទាំង ២ នោះ ទោះបីក្រោធចំពោះព្រាហ្មណ៍ ក៏គិតថា ណ្ហើយចុះ ក្នុងពេលក្រោយអញនឹងដឹងកម្មដែលគួរធ្វើដល់ព្រាហ្មណ៍អ្នកទ្រុស្តមិត្តនេះ កាលសម្ដែងភាវៈដែលខ្លួនជាបុគ្គលដែលអ្នកដទៃសង្កត់សង្កិនមិនបាន ជាបឋម ទើបពោលគាថាថា

ខ្ញុំទោះបីទេវតាក្ដី មនុស្សក្ដីកម្ចាត់កម្ចាយដោយឥស្សរិយយស

មិនបានឡើយ ខ្លួនខ្ញុំជាយក្ស សម្រេចនូវឫទ្ធិដ៏ឧត្តម ទៅក្នុង
ទីឆ្ងាយបាន ប្រកបដោយរូបសម្បត្តិនិងកម្លាំង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទេវេន វា** បានដល់ ទោះជាទេវតាអង្គណានី មួយក្តី ។ សូម្បីក្នុងបទថា **មនុស្សេន វា** នេះ ក៏ន័យនេះដូចគ្នា ។ បទថា **ឥស្សរិយេន វា** សេចក្តីថា ដែលជាធំក្នុងពួកទេវតាក្តីដែលជាធំក្នុងពួកមនុស្សក្តី ។ ក្នុងភាពជាធំ ២ យ៉ាងនោះ ឈ្មោះថា ជាធំក្នុងពួកទេវតា បានដល់ទេវឫទ្ធិរបស់ស្តេចចាតុម្មហារាជ សក្កទេវរាជ ស្តេចសុយាមជាដើម ។ ឈ្មោះថា ភាពជាធំក្នុងពួកមនុស្ស បានដល់ បុញ្ញឫទ្ធិរបស់ស្តេចចក្កពត្តិជាដើម ។ ព្រោះហេតុនោះ ទើបលោកសង្គ្រោះយកទេវតានិងមនុស្សដែលមានអានុភាពច្រើនដោយឥស្សរិយសក្តិ ។ ពិតហើយ ទេវតាដែលមានអានុភាពច្រើនកាលមិនមានមនុស្សដែលផលនៃបុណ្យឧបត្ថម្ភខ្លួន រមែងមិនអាចគ្របសង្កត់នូវបយោគវិបត្តិ នឹងពោលថ្វីដល់បុគ្គលក្រៅអំពីនេះ ។ សព្ទថា **ហំ** ជានិបាត ប្រើក្នុងអត្ថថា អត់ធន់មិនបាន ។ បទថា **ន សុប្បសយ្ហោ** បានដល់ ដែលបុគ្គលណាមួយកម្ចាត់មិនបាន ។ បទថា **យក្ខោហមស្មិ បរមិទ្ធិបត្តោ** សេចក្តីថា ព្រោះផលនៃបុណ្យរបស់ខ្លួន ទើបខ្ញុំចូលដល់ភាពជាទេវបុត្ត គឺខ្ញុំជាទេវបុត្តពិតៗ មិនមែនទេវបុត្តក្លែងក្លាយ ។ ដោយពិត ខ្ញុំមានឫទ្ធិក្រៃលែង គឺប្រកបដោយឫទ្ធិរបស់ទេវបុត្តដ៏ក្រៃលែង ។ បទថា **ទូរង្គមោ** បានដល់ អាចដើម្បីទៅកាន់ទីឆ្ងាយ ក្នុងកាលមួយរំពេច ។ ដោយបទថា **វណ្ណពលូបបន្នោ** នេះ ទេវបុត្តសម្តែងចំពោះភាវៈដែលខ្លួនមិនត្រូវបុគ្គលណាមួយសង្កត់សង្កិន

ដោយការប្រកបមន្តជាដើម ដោយបទទាំង ៣ ថា ចូលដល់ គឺប្រកបដោយរូបសម្បត្តិនិងដោយកម្លាំងកាយ ។ ពិតហើយ បុគ្គលដែលសម្បូរដោយរូបជាបុគ្គលដែលជនដទៃរាប់អានច្រើន ព្រោះអាស្រ័យរូបសម្បត្តិ ទើបមិនត្រូវវត្ថុដែលជាសត្រូវអូសទាញទៅបានឡើយ ព្រោះហេតុនោះទើបលោកពោលថា វណ្ណសម្បទាជាហេតុដែលបុគ្គលណាមួយកម្ចាត់មិនបាន ដូច្នេះ ។

ខាងមុខអំពីនេះទៅ អង្កុរពាណិជនិងទេវបុត្តបានធ្វើនូវពាក្យឆ្លើយឆ្លងគ្នាទៅវិញទៅមកថា

ដៃទាំងអស់របស់អ្នក មានសម្បុរដូចជាមាស ទ្រទ្រង់នូវវត្ថុជាទីប្រាថ្នា ដោយអង្គុលីទាំង ៥ បញ្ចេញនូវរសផ្អែម រសទាំងឡាយផ្សេងៗរមែងហូរចេញ ខ្ញុំសម្គាល់ថាជាសក្កទេវរាជឈ្មោះបុរិន្ទទៈ ។

រុក្ខទេវតាឆ្លើយថា

ខ្ញុំមិនមែនជាទេវតាមិនមែនជាគន្ធព្វ មិនមែនជាព្រះឥន្ទ្រឈ្មោះបុរិន្ទទៈទេ ម្នាលអង្កុរៈ អ្នកចូរដឹងនូវខ្លួនខ្ញុំថាជាប្រេត ច្យុតអំពីភេរុវនគរ ( មកកើត ) ក្នុងទីនេះទេតើ ។

អង្កុរពាណិជសួរថា

អំពីជាតិមុន កាលអ្នកនៅក្នុងភេរុវនគរ មានសីល ដូចម្តេច មានសមាចារ ដូចម្តេច ផលបុណ្យសម្រេចក្នុងដៃរបស់អ្នកដោយការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដូចម្តេច ។

រុក្ខទេវតាឆ្លើយថា

អំពីជាតិមុន កាលនោះខ្លួនខ្ញុំជាអ្នកតម្បាញ នៅក្នុងភេរុវនគរ ជាអ្នកប្រព្រឹត្តចិញ្ចឹមជីវិតដោយលំបាក ជាមនុស្សកំព្រា វត្ថុដែលគួរឲ្យទាន មិនមានដល់ខ្ញុំទេ តែទីលំនៅរបស់ខ្ញុំនៅជិត ( ផ្ទះ ) នៃអសយ្ហមហាសេដ្ឋីដែលជាអ្នកប្រកបដោយសទ្ធា ជាម្ចាស់នៃទាន បានធ្វើបុណ្យ ជាអ្នកខ្មាសបាប ។ ពួកយាចកនិងពួកវណិព្វកៈ មានគោត្តផ្សេងៗគ្នា តែងទៅក្នុងទីនោះ ជនទាំងនោះ តែងសួររកទីលំនៅនៃអសយ្ហមហាសេដ្ឋី នឹងខ្ញុំក្នុងទីនោះ ។ សេចក្ដីចម្រើន ចូរមានដល់អ្នកចុះ ពួកយើងទៅក្នុងទីណា អសយ្ហមហាសេដ្ឋីតែងឲ្យទានក្នុងទីណា ខ្ញុំកាលដែលជនទាំងនោះសួរហើយ បានប្រាប់នូវលំនៅ នៃអសយ្ហមហាសេដ្ឋី ដល់ជនទាំងនោះ ។ ខ្ញុំបានលើកដើមដៃខាងស្ដាំ ( បង្ហាញលំនៅនៃអសយ្ហមហាសេដ្ឋីដល់ជនទាំងនោះ ) ថា សេចក្ដីចម្រើន ចូរមានដល់អ្នកទាំងឡាយចុះ អ្នកទាំងឡាយចូរនាំគ្នាទៅក្នុងទីនោះចុះ អសយ្ហមហាសេដ្ឋី តែងឲ្យទានក្នុងទីនុ៎ះ ដៃរបស់ខ្ញុំ អាចឲ្យសម្រេចសេចក្ដីប្រាថ្នាបាន ដោយហេតុនោះ ដៃរបស់ខ្ញុំ ទើបបញ្ចេញនូវសេផ្អែមបាន ដោយហេតុនោះបុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយការប្រព្រឹត្តដ៏ប្រសើរនោះ ។

អង្កុរពាណិជសួរថា

បានឮថា អ្នកមិនដែលឲ្យទានដល់ជនណាមួយដោយដៃទាំង-ឡាយរបស់ខ្លួនទេ គ្រាន់តែអនុមោទនាទាន របស់បុគ្គលដទៃ ហើយលើកដៃចង្អុលប្រាប់ផ្លូវប៉ុណ្ណោះ ។

ដៃរបស់ខ្ញុំ[1]អាចឲ្យសម្រេចសេចក្តីប្រាថ្នា ដោយហេតុនោះ ដៃរបស់ខ្ញុំ[1]ទើបបញ្ចេញ នូវរសផ្អែមបាន ដោយហេតុនោះ បុណ្យ ក៏សម្រេចក្នុងដៃរបស់ខ្ញុំ[1]ដោយការប្រព្រឹត្តដ៏ប្រសើរ នោះ ។

បពិត្រលោកដ៏ចម្រើន អសយ្ហមហាសេដ្ឋីនោះ ជាអ្នកមាន ចិត្តជ្រះថ្លា ហើយបានឲ្យនូវទានដោយដៃខ្លួនឯង លុះសេដ្ឋី នោះលះបង់នូវអត្តភាពជាមនុស្សហើយទៅទិសណា ។

រុក្ខទេវតាឆ្លើយថា

ខ្ញុំក៏មិនដឹងនូវដំណើរទៅ ឬមកនៃអសយ្ហមហាសេដ្ឋី ជាអ្នក អត់ធន់ ដែលមានរស្មីផ្សាយចេញអំពីកាយឡើយ តែខ្ញុំឮថា អសយ្ហមហាសេដ្ឋី ទៅកើតជាមួយនឹងព្រះឥន្រ្ទ ក្នុងសំណាក់ នៃស្តេចវេស្សវណ ។

អង្កុរពាណិជពោលថា

បុគ្គលគួរធ្វើកុសលគួរឲ្យទានតាមសមគួរ បុគ្គលណាឃើញ

---

១-គួរតែជា ដៃរបស់អ្នក ព្រោះគាថានេះ អង្កុរពាណិជជាអ្នកពោល ។

ដៃដែលឲ្យតាមបំណងហើយ នឹងមិនធ្វើបុណ្យកើត ។ ខ្ញុំទៅ
អំពីទីនេះ ដល់ទៅទ្វារកនគរ នឹងតម្កល់ទុកនូវទានជាទីនាំមក
នូវសេចក្ដីសុខដល់ខ្ញុំដោយពិត ។ ខ្ញុំនឹងឲ្យបាយ ទឹក សំពត់
គ្រឿងសេនាសនៈ អណ្ដូងទឹក ពាងទឹកសម្រាប់ផឹកនិងស្ពាន
ក្នុងផ្លូវដែលលំបាកទៅ ដូច្នេះ ។

សរុបគាថាដែលពោលឆ្លើយឆ្លងគ្នាមាន ១៥ គាថា

ក្នុងបទទាំងនោះ បទថា **ចាណិ តេ** បានដល់ បាតដៃស្ដាំរបស់អ្នក ។ បទថា **សព្វសោ វណ្ណោ** បានដល់ មានពណ៌សម្បុរដូចមាស ទាំងអស់ ។ បទថា **បញ្ចធារោ** សេចក្ដីថា ឈ្មោះថា **បញ្ចធារ** ព្រោះ មានការទ្រទ្រង់ទុកនូវវត្ថុដែលបុគ្គលដទៃប្រាថ្នាដោយម្រាមទាំង ៥ ។ បទថា **មធុស្សវោ** ប្រែថា ជាទីហូរចេញនូវរសដ៏ឆ្ងាញ់ ដោយហេតុនេះ ទើបអង្គុរពាណិជពោលថា **ឆនាសោ បគ្ឃរន្តិ** សេចក្ដីថា ជាទីហូរចេញនៃរសផ្សេងៗ មានរសផ្អែមរសហឹរ រសចត់ ជាដើម ។ ពិតហើយ លោកពោលទុកថា រស មានរសផ្អែមជាដើមរមែងហូរចេញអំពីដៃដែលហូរនូវរបស់ទំពា និងរបស់បរិភោគផ្សេងៗ ដែលសម្បូរដោយរស មានរសផ្អែមជាដើម ដែលឲ្យដល់នូវសេចក្ដីប្រាថ្នា របស់ទេវបុត្ត ។ បទថា **មញ្ញេហំ តំ បុរិន្ទទំ** សេចក្ដីថា ខ្ញុំយល់ថា លោកជាសក្កបុរិន្ទទៈ អធិប្បាយថា ខ្ញុំយល់ថា លោកជាសក្កទេវរាជ ជាអ្នកមានអានុភាពច្រើនយ៉ាងនេះ ។

បទថា **ឆាម្ហិ ទេវោ** សេចក្ដីថា ខ្ញុំមិនមែនទេវតាដែលប្រាកដ មានស្ដេច

វេស្សវណជាដើមទេ ។ បទថា **ន គន្ធព្វោ** សេចក្តីថា ទាំងខ្ញុំមិនមែនជាគន្ធព្វ ។ បទថា **នាបិ សក្កោ បុរិន្ទទោ** សេចក្តីថា ទាំងខ្ញុំមិនមែនជាសក្កទេវរាជ ឈ្មោះថា **បុរិន្ទទ** ព្រោះបានតម្កល់ទានក្នុងអត្តភាពមុន គឺក្នុងអត្ត-ភាពមុន ។ ដើម្បីចៀសវាងនូវពាក្យសួរថា អ្នកជាអ្វី ទើបរុក្ខទេវតាពោលពាក្យជាដើមថា ម្នាលអង្កុរ អ្នកចូរដឹងនូវខ្លួនខ្ញុំថាជាប្រេត អធិប្បាយថា ម្នាលអង្កុរ អ្នកចូរដឹងថា ខ្ញុំធ្លាក់នៅក្នុងពួកប្រេត គឺចូរចាំខ្ញុំថា ជាប្រេតដែលមានឫទ្ធិច្រើនមួយរូប ។ បទថា **រោរុវម្ហា ឥធាគតំ** សេចក្តីថា ខ្ញុំច្យុតអំពីរោរុវនគរហើយ មកក្នុងទីនេះ គឺត្រង់ដើមជ្រៃនេះ ក្នុងផ្លូវឡាច់កន្តារ ដោយការកើត គឺកើតឡើងក្នុងទីនេះ ។

បទថា **កឹសីលោ កឹ សមាចារោ រោរុវស្មឹ បុរេ តុវំ** សេចក្តីថា កាលមុន គឺក្នុងអត្តភាពមុន លោកកើតត្រង់រោរុវនគរ ជាអ្នកមានប្រក្រតីដូចម្តេច មានការប្រព្រឹត្តដូចម្តេច គឺលោកសមាទានសីលដូចម្តេច ដែលមានលក្ខណៈឲ្យត្រឡប់ចាកបាប មានលក្ខណៈប្រព្រឹត្តដូចម្តេច ដោយការប្រព្រឹត្ត មានលក្ខណៈបំពេញបុណ្យដែលឲ្យប្រព្រឹត្តទៅហើយ អធិប្បាយថា អ្នកជាអ្នកប្រព្រឹត្តដូចម្តេចក្នុងការបំពេញកុសល មានទានជាដើម ។ បទថា **កេន តេ ព្រហ្មចរិយេន បុញ្ញំ បាណិម្ហិ ឥជ្ឈតិ** សេចក្តីថា ផលបុណ្យនេះ គឺបែបនេះរមែងសម្រេច គឺរមែងឲ្យផលត្រង់បាតដៃរបស់អ្នកក្នុងឥឡូវនេះ ព្រោះការប្រព្រឹត្តប្រសើរដូចម្តេច ចូរអ្នកប្រាប់រឿងនោះ ។ ពិតហើយ ផលបុណ្យលោកបំណាងយកថា បុណ្យក្នុងទីនេះ ដោយការលុបបទខាងក្រោយ ។ ពិត

ហើយ បន្ទាប់អំពីនោះ ផលបុណ្យនោះ ព្រះមានព្រះភាគ ត្រាស់ថា បុណ្យ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចម្រើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយយ៉ាងនេះ ដូច្នេះ ។

បទថា **តុន្នវាយោ** បានដល់ ខ្ញុំជាជាងតម្បាញ ។ បទថា **សុកិច្ឆវុត្តិ** បានដល់ ជាអ្នកចិញ្ចឹមជីវិតដោយលំបាកគឺជាអ្នកមានជីវិតលំបាកក្រៃលែង ។ បទថា **កបណោ** ប្រែថា ជាមនុស្សកំព្រា អធិប្បាយថា ជាមនុស្សទុគ៌ត ។ បទថា **ន មេ វិជ្ជតិ ទាតវេ** សេចក្តីថា ខ្ញុំមិនមានអ្វីដែលគប្បីឲ្យដល់សមណព្រាហ្មណ៍ ឬអ្នកដំណើរ តែខ្ញុំមានការគិតនឹងឲ្យទាន ។

បទថា **និវេសនំ** បានដល់ ផ្ទះឬសាលាសម្នាក់ធ្វើការងារ ។ បទថា **អសយ្ហស្ស ឧបន្តិកេ** បានដល់ ក្បែរផ្ទះរបស់មហាសេដ្ឋីឈ្មោះ អសយ្ហៈ ។ បទថា **សទ្ធស្ស** សេចក្តីថា ប្រកបដោយការជឿកម្មនិងផលនៃកម្ម ។ បទថា **ទានបតិនោ** សេចក្តីថា ជាអ្នកធំក្នុងទានដោយសម្បត្តិជាហេតុបរិច្ចាគមិនជាច់រយៈ និងដោយការគ្រប់សង្កត់លោភៈ ។ បទថា **កតបុញ្ញស្ស** បានដល់ ជាអ្នកមានសុចរិតកម្មដែលធ្វើក្នុងកាលមុន ។ បទថា **លជ្ជិនោ** បានដល់ ជាអ្នកខ្មាសចំពោះបាបជាសភាវៈ ។

បទថា **តត្ថ** បានដល់ ក្នុងផ្ទះរបស់ខ្ញុំនោះ ។ បទថា **យាចនកា យន្តិ** សេចក្តីថា យាចកប្រាថ្នានឹងសូមអ្វីមួយនឹងអសយ្ហសេដ្ឋី ទើបនាំគ្នាមក ។ បទថា **នានាគោត្តា** បានដល់ ជាអ្នកសម្តែងអាងដល់គោត្តផ្សេងៗ ។ បទថា **វណិព្វកា** បានដល់ ពួកអ្នកសូមទានដែលសម្តែងពាក្យសរសើរ ។

ជនពួកណាត្រាច់ប្រកាសដល់ផលបុណ្យ ជាដើម របស់ទាយក និងភាពដែលខ្ញុំមានសេចក្តីត្រូវការដោយសំដៅដល់កិត្តិគុណ ជាដើម ។ បទថា **តត្ថ** ក្នុងបទថា **តេ ច មំ តត្ថ បុច្ឆន្តិ** នោះ ជានិបាត ។ យាចកជាដើមនោះនាំគ្នាសួររកផ្ទះរបស់អសយ្ហសេដ្ឋីនឹងខ្ញុំ ។ ពិតហើយ អ្នកអក្ខរសាស្ត្រមែងប្រាថ្នាកម្ម ២ យ៉ាង ក្នុងឋានៈនេះ ។

បទថា **កត្ថ គច្ឆាម ភទ្ទំ វោ កត្ថ ទានំ បទីយតិ** ជាបទសម្តែងដល់អាការសួររបស់យាចកទាំងនោះ ។ ពិតហើយ ក្នុងទីនេះ មានអធិប្បាយដូច្នេះថា សូមសេចក្តីចម្រើនមានដល់អ្នកទាំងឡាយ ពួកយើងបានឮថា អសយ្ហសេដ្ឋីរមែងឲ្យទាន ដូច្នេះ ទើបនាំគ្នាមក គេឲ្យទានក្នុងទីណា ឬខ្ញុំនឹងទៅផ្លូវណា បុគ្គលទៅផ្លូវណា ទើបអាចបានទាន ។ បទថា **តេសាហំ បុដ្ឋោ អក្ខាមិ** សេចក្តីថា ពួកអ្នកដំណើរទាំងនោះសួរដល់ឋានៈដែលនឹងបានយ៉ាងនេះ ទើបកើតសេចក្តីគោរពឡើងថា ខ្ញុំជាបុគ្គលមិនអាចឲ្យអ្វីមួយដល់ជនបែបនេះក្នុងកាលឥឡូវនេះបាន ព្រោះមិនធ្លាប់ធ្វើក្នុងកាលមុន តែខ្ញុំបង្ហាញរោងទាន ដល់អ្នកទាំងនោះ ឲ្យកើតបីតិដោយប្រាប់ឧបាយនៃការបានដោយហេតុប្រមាណប៉ុណ្ណេះ ក៏សន្សំបុណ្យជាច្រើនបាន ទើបលាដៃស្តាំប្រាប់ផ្ទះអសយ្ហសេដ្ឋីដល់មនុស្សទាំងនោះ ។ ដោយហេតុនោះទើបរុក្ខទេវតាពោលថា ចូរលោកផ្គងដើមដៃស្តាំ ដូច្នេះ ជាដើម ។

បទថា **តេន បាណិ កាមទទោ** សេចក្តីថា ដោយហេតុត្រឹមការអនុមោទនាទានដែលអ្នកដទៃធ្វើហើយ ដោយការប្រកាសទានរបស់អ្នកដទៃនោះ

ដោយគោរព ឥឡូវនេះ បាតដៃរបស់ខ្ញុំដូចដើមកប្បព្រឹក្ស និងដូចដើមទិព្វព្រឹក្ស ឲ្យវត្ថុដែលគួរប្រាថ្នា គឺឲ្យវត្ថុដែលត្រូវការដែលប្រាថ្នា ឈ្មោះថា ឲ្យវត្ថុដែលគួរស្រឡាញ់និងគួរប្រាថ្នា ព្រោះហេតុនោះ ទើបបាតដៃរបស់ខ្ញុំឲ្យនូវវត្ថុដែលគួរប្រាថ្នា ជាទីហូរចេញនៃរសដ៏ឆ្ងាញ់ គឺជាទីហូរចេញនូវវត្ថុដែលគួរប្រាថ្នា ។

សព្ទថា **កិរ** ក្នុងបទថា **ន កិរ ត្វំ អទា ទានំ** នេះ ជានិបាត ចុះក្នុងអត្ថនៃអនុស្សវនត្ថៈ ។ បានព្ទថា អ្នកមិនលះបង់ទ្រព្យរបស់ខ្លួន គឺអ្នកមិនបានឲ្យរបស់ណាមួយដល់អ្នកណាម្នាក់ ឬដល់សមណៈ ដោយបាតដៃរបស់ខ្លួន គឺមួយអន្ទើដោយដៃរបស់ខ្លួន ។ បទថា **បរស្ស ទានំ អនុមោទមានោ** សេចក្តីថា អ្នកកាលអនុមោទនាទានរបស់អ្នកដទៃ ដែលអ្នកដទៃធ្វើតែម្យ៉ាងប៉ុណ្ណោះថា ឱ ! ទានអ្នកឲ្យប្រព្រឹត្តទៅហើយ ។

បទថា **តេន បាណិ កាមទទោ** សេចក្តីថា ព្រោះហេតុនោះ ទើបបាតដៃរបស់អ្នកឲ្យនូវវត្ថុដែលគួរប្រាថ្នាយ៉ាងនេះ អធិប្បាយថា ឱ ! អស្ចារ្យពិតហ្ន៎ គតិនៃបុណ្យទាំងឡាយ ។

អង្កុរពាណិជហៅទេវបុត្តដោយគោរពថា បពិត្រលោកដ៏ចម្រើន អសយ្ហមហាសេដ្ឋីនោះជាអ្នកមានចិត្តជ្រះថ្លា ហើយបានឲ្យនូវទានដោយដៃខ្លួនឯង ។ អធិប្បាយថា ជាបឋមផលបែបនេះ គឺអានុភាពបែបនេះរបស់លោក ដែលអនុមោទនាទានដែលបុគ្គលដទៃធ្វើហើយ តែអសយ្ហមហាសេដ្ឋីនោះ បានឲ្យមហាទាន គឺជាអ្នកមានចិត្តជ្រះថ្លាឲ្យមហាទានប្រព្រឹត្តទៅក្នុងកាលនោះដោយ

ទ្រព្យច្រើនពាន់ ។ បទថា **សោ ហិត្វា មានុសំ ទេហំ** សេចក្តីថា លោកលះអត្តភាពមនុស្សក្នុងទីនេះ ។ បទថា **កំ** បានដល់ ក្នុងទិសណា ។ បទថា **នុ** ក្នុងពាក្យថា **នុ សោ** នេះ ត្រឹមតែជានិបាត ។ បទថា **ទិសតំ គតោ** ប្រែថា ទៅកាន់ទិស គឺទីដែលអន្តរពាណិជសួរដល់ អភិសម្បរាយកពរបស់អសយ្ហសេដ្ឋីថា គតិ គឺសេចក្តីសម្រេចរបស់សេដ្ឋីនោះ ដូចម្តេច ។

បទថា **អសយ្ហសាហិនោ** សេចក្តីថា ឈ្មោះថា អសយ្ហមហាសេដ្ឋី ព្រោះអត់សង្កត់នូវធុរៈរបស់សប្បុរស ដែលចែកនូវបរិច្ចាគជាដើម ដែលជនដទៃជាអ្នកមានសេចក្តីកំណាញ់ គឺជាបុគ្គលដែលសេចក្តីលោភគ្របសង្កត់មិនអាចអត់សង្កត់គឺអត់ធន់បាន ។ បទថា **អង្គីរសស្ស** បានដល់ ជាអ្នកមានរស្មីផ្សាយចេញអំពីខ្លួន ។ ពិតហើយ ពាក្យថា **រសោ** ជាឈ្មោះនៃពន្លឺ បានឮថា បីតិនិងសោមនស្សយ៉ាងក្រៃលែងរមែងកើតឡើងដល់អសយ្ហសេដ្ឋីនោះ ព្រោះឃើញនូវពួកយាចកកំពុងដើរមក គឺមុខរមែងផូរផង់ ។ រុក្ខទេវតានោះពោលយ៉ាងនេះ ព្រោះធ្វើបុគ្គលនោះឲ្យប្រចក្សដល់ខ្លួន ។ បទថា **គតឹ អាគតឹ វា** សេចក្តីថា ខ្ញុំមិនដឹងទីទៅរបស់អសយ្ហសេដ្ឋីនោះថា គាត់ទៅអំពីលោកនេះហើយ ទៅកាន់គតិឈ្មោះនោះ ឬមិនដឹងទីមកថា គាត់មកអំពីទីនោះហើយនឹងមកក្នុងទីនេះក្នុងកាលឈ្មោះនោះ នេះមិនមែនវិស័យរបស់ខ្ញុំ ។ បទថា **សុតញ្ច មេ វេស្សវណស្ស សន្តិកេ** សេចក្តីថា តែខ្ញុំទៅកាន់ទីបម្រើបានស្តាប់សេចក្តីនេះមកក្នុងសម្នាក់របស់ព្រះបាទវេស្សវណមហារាជ ។ បទថា **សក្កស្ស សហព្យតំ គតោ អសយ្ហោ** សេចក្តីថា អសយ្ហមហាសេដ្ឋី

ដល់នូវភាពជាសម្លាញ់របស់សក្កទេវរាជអធិប្បាយថាកើតក្នុងឋានតាវត្តិង្ស ។

បទថា **អលមេវ កាតុំ កល្យាណំ** សេចក្តីថា គុណឯណានីមួយ គឺបុណ្យកុសលសមគួរ គឺត្រូវធ្វើនោះឯង ។ ក្នុងគុណនោះ វត្ថុដែលទូទៅដល់មនុស្សទាំងពួង គួរធ្វើល្អជាង ដើម្បីសម្តែងវត្ថុនោះ អង្កុរក៏ពោលថា គួរឲ្យទានតាមសមគួរ ។ គួរតែឲ្យទានសមគួរដល់សម្បត្តិនិងកម្លាំងរបស់ខ្លួន ។ លោកពោលហេតុក្នុងសេចក្តីនោះថា ឃើញបាតដៃដែលឲ្យវត្ថុគួរប្រាថ្នា ព្រោះឃើញដៃនេះថា ឲ្យនូវវត្ថុដែលគួរប្រាថ្នា ដោយហេតុ មានអនុមោទនាបុណ្យដែលអ្នកដទៃធ្វើហើយជាខាងដើម និងដោយហេតុត្រឹមការប្រាប់ផ្លូវដែលចូលទៅកាន់ផ្ទះនៃទានបតី ។ បទថា **កោ បុញ្ញំ ន ករិស្សតិ** សេចក្តីថា ឈ្មោះថា អ្នកណាដូចខ្ញុំនឹងមិនធ្វើបុណ្យដែលជាទីពឹងរបស់ខ្លួននោះ ។

អង្កុរពោណិជកាលសម្តែងនូវការអើពើ ក្នុងការបំពេញបុណ្យ ដោយមិនកំណត់ពិតប្រាកដយ៉ាងនេះ ឥឡូវនេះ កាលសម្តែងកំណត់ពិតប្រាកដដល់ការបំពេញបុណ្យនោះក្នុងខ្លួនទើបពោល ២ គាថា មានពាក្យជាដើមថា **សោ ហិ នូន** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សោ** បានដល់ ខ្ញុំនោះ ។ សព្ទថា **ហិ** ជានិបាត ចុះក្នុងអត្ថនៃអវធារណៈ ។ សព្ទថា **នូន** ជានិបាត ចុះក្នុងអត្ថថា បរិវិតក្ក ។ បទថា **ឥតោ គន្ត្វា** សេចក្តីថា ខ្ញុំទៅអំពីវាលខ្សាច់នេះហើយ ។ បទថា **អនុប្បត្វាន ទ្វារកំ** បានដល់ ដល់ទ្វារវតីនគរដោយលំដាប់ ។ បទថា **បដ្ឋាបយិស្សាមិ** បានដល់ នឹងឲ្យប្រព្រឹត្តទៅ ។

កាលអង្កុរពាណិជធ្វើប្តេជ្ញាថា ខ្ញុំនឹងឲ្យទានយ៉ាងនេះហើយ ទេវបុត្តមានចិត្តត្រេកអរ ពោលថា អ្នកនិទ្ទុក្ខ អ្នកជាអ្នកលះបង់ ចូរឲ្យទានចុះ ឯខ្ញុំនឹងធ្វើនាទីជាសម្លាញ់របស់អ្នក ទេយ្យធម៌របស់អ្នកនឹងមិនដល់នូវការអស់ដោយប្រការណា ខ្ញុំនឹងធ្វើដោយប្រការនោះ ដូច្នេះហើយ ទើបឲ្យអង្កុរពាណិជនោះអាចហ៊ានក្នុងការបំពេញទាន ហើយពោលថា នែពាណិជ បានឮថា អ្នកចង់នាំបុគ្គលដូចយើងទៅដោយកម្លាំង អ្នកមិនស្គាល់ប្រមាណរបស់ខ្លួន ដូច្នេះហើយ ទើបឲ្យទំនិញរបស់ព្រាហ្មណពិណិជនោះ អន្តរធានទៅ ហើយទើបសម្តុតឲ្យព្រាហ្មណពាណិជនោះខ្លាចដោយអាការដែលគួរខ្លាច ជាយក្ស ។ លំដាប់នោះ អង្កុរពាណិជអង្វរទេវបុត្តនោះដោយប្រការផ្សេងៗ ឲ្យព្រាហ្មណ៍ខមាទោស ឲ្យជ្រះថ្លា ទើបធ្វើទំនិញទាំងអស់ឲ្យជាប្រក្រតី ។ លុះពេលព្រលប់ទើបលាទេវបុត្តទៅ ជួបប្រេតមួយដែលគួរខ្លាចក្រៃពេក ក្នុងទីមិនឆ្ងាយអំពីលំនៅទេវបុត្តនោះ កាលនឹងសួរដល់កម្មដែលប្រេតនោះធ្វើ ទើបពោលគាថាថា

> ម្រាមដៃម្រាមជើង របស់អ្នកក្ងែងក្ងង់ មុខរបស់អ្នកក្រញេវ
> ក្រញូវ ភ្នែករបស់អ្នកចេះតែហូរចេញនូវទឹកភ្នែក ព្រោះហេតុ
> អ្វី បាបកម្មដូចម្តេចដែលអ្នកបានធ្វើហើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កុណោ** ប្រែថា ក្ងែងក្ងង់ គឺ ក្ងិកក្ងក់ បានដល់មិនត្រង់ ។ បទថា **កុណាលីកតំ** បានដល់ វៀច គឺវៀចដោយវិការត្រង់មាត់ ។ បទថា **បគ្ឃរន្តិ** បានដល់ ហូរចេញនូវវត្ថុមិនស្អាត ។

លំដាប់នោះ ប្រេតបានពោល ៣ គាថា ដល់អង្កុរពាណិជនោះថា

កាលអសយ្ហគហបតីដែលមានរស្មីចេញអំពីកាយ មានសទ្ធា គ្រប់គ្រងផ្ទះ ខ្ញុំជាអ្នកចាត់ចែងនូវទានទាំងឡាយក្នុងរោងទាន របស់គហបតីនោះ ។ ខ្ញុំបានឃើញពួកស្មូមដែលត្រូវការភោ-ជន មកក្នុងទីនោះ ចៀសចេញទៅក្នុងទីដ៏សមគួរ ហើយ បានធ្វើមុខក្រញៀវក្រញូវ ។ ព្រោះហេតុនោះ បានជាម្រាមដៃ ម្រាមជើងរបស់ខ្ញុំក្ងែងក្ងង់ មុខរបស់ខ្ញុំក្រញៀវក្រញូវ ភ្នែកទាំងឡាយរបស់ខ្ញុំ ចេះតែហូរចេញនូវទឹកភ្នែក មានក្លិនស្អុយ បាបកម្មនោះ ខ្ញុំបានធ្វើហើយ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អង្គីរសស្ស** ជាដើម ប្រេតប្រាប់ដល់អសយ្ហសេដ្ឋី ។ បទថា **ឃរមេសិនោ** បានដល់ គ្រហស្ថដែលនៅគ្រប់គ្រងផ្ទះ ។ បទថា **ទានវិស្សគ្គេ** បានដល់ ក្នុងរោងទាន គឺក្នុងទីជាទីបរិច្ចាគទាន ។ បទថា **ទានេ អធិការោ អហុំ** សេចក្តីថា ផ្តើមតាំងទុក គឺតាំងទុកក្នុងបរិច្ចាគទេយ្យធម៌ គឺការបំពេញទាន ។

បទថា **ឃកមន្តុំ អបក្កម្ម** សេចក្តីថា ជាអ្នកខ្វល់ខ្វាយក្នុងទាន ឃើញនូវយាចកមកដោយត្រូវការភោជនីយាហារ មិនគេចអំពីរោងទាន ហើយឈរក្នុងទីដើមនោះឯង កើតបីតិនិងសោមនស្ស មានមុខផូរផង់ គប្បីឲ្យទានដោយដៃរបស់ខ្លួន ឬប្រើអ្នកដទៃដែលសមគួរ ឲ្យបរិច្ចាគ តែខ្ញុំមិនបានធ្វើយ៉ាងនោះ ឃើញយាចកដើរមកអំពីចម្ងាយ មិនបង្ហាញខ្លួន ចៀសចេញទៅ

ក្នុងចំណែកម្ខាង ៗ បទថា **អក្ខាសិ កុណលិ មុខំ** សេចក្ដីថា ខ្ញុំបានពេបមាត់ ។

បទថា **តេន** សេចក្ដីថា ក្នុងកាលនោះ ខ្ញុំត្រូវចៅហ្វាយតែងតាំងក្នុងនាទីជាអ្នកឲ្យទាន កាលកៀកវេលាឲ្យទាន ខ្ញុំមានសេចក្ដីកំណាញ់គ្របសង្កត់ គេចចេញទៅអំពីរោងទាន ធ្វើជើងវៀច កាលគួរឲ្យទានដោយដៃរបស់ខ្លួនមិនបានធ្វើយ៉ាងនោះ គឺធ្វើដោយដៃវៀច កាលគួរធ្វើមុខថ្លូវផង់ ក៏ធ្វើមុខក្រញូវ កាលគួរសម្លឹងមើលដោយភ្នែកគួរជាទីស្រឡាញ់ ក៏ធ្វើភ្នែកលៀនចេញមក ព្រោះដូច្នោះ ទើបខ្ញុំមានម្រាមដៃ ម្រាមជើងក្ងេងក្ងង់ និងមាត់វៀច អធិប្បាយថា ភ្នែកទាំង ២ ហូរទឹកភ្នែកចេញមកមិនស្អាត មានក្លិនគួរខ្ពើម ព្រោះហេតុនោះ ទើបប្រេតពោលថា

> ព្រោះហេតុនោះ បានជាម្រាមដៃ ម្រាមជើង របស់ខ្ញុំក្ងេងក្ងង់
> មុខរបស់ខ្ញុំក្រញេវក្រញូវ ភ្នែកទាំងឡាយរបស់ខ្ញុំ ចេះតែហូរ
> ចេញនូវទឹកភ្នែកមានក្លិនស្អុយ បាបកម្មនោះ ខ្ញុំបានធ្វើហើយ
> ដូច្នេះ ។

អង្កុរពាណិជបានស្ដាប់ដូច្នោះ កាលនឹងតិះដៀលប្រេត ក៏ពោលគាថាថា

> ម្នាលបុរសលាមក មុខរបស់អ្នក ក្រញេវក្រញូវផង ភ្នែក
> របស់អ្នកចេះតែហូរចេញនូវ ( ទឹកភ្នែកមានក្លិនស្អុយ ) ផង
> ( សមគួរ ) តាមហេតុ ព្រោះអ្នកបានធ្វើមុខក្រញេវក្រញូវ
> ចំពោះទានបុគ្គលដទៃ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ធម្មេន** បានដល់ ដោយហេតុដែលសមគួរនោះឯង ។ បទថា **តេ** កែជា **តវ** ប្រែថា របស់អ្នក ។ បទថា **កាបុរិស** បានដល់ បុរសលាមក ។ បទថា **យំ** កែជា **យស្មា** ប្រែថា ព្រោះហេតុណា ។ បទថា **បរស្ស ទានស្ស** បានដល់ ក្នុងទានរបស់អ្នកដទៃ ។ ម្យ៉ាង ទៀត បាលីក៏យ៉ាងនេះដូចគ្នា ។

អង្កុរពាណិជ កាលតិះដៀលទានបតី គឺសេដ្ឋីនោះទៀត ទើបពោលគាថាថា

> បុរសកាលឲ្យទាន បាយ ទឹក ខាទនីយៈ សំពត់និងសេនាសនៈ តើគប្បីធ្វើ ( ទាននោះ ) ឲ្យសម្រេចដល់បុគ្គលដទៃដូចម្តេច⁽¹⁾ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយដូច្នេះថា បុរសកាលឲ្យទានហេតុអ្វី ក៏ប្រគល់ឲ្យអ្នកដទៃចាត់ចែងទាននោះ គឺធ្វើឲ្យប្រេចក្សដល់ខ្លួននោះឯងហើយគប្បីឲ្យដោយដៃរបស់ខ្លួន ។ ម្យ៉ាងទៀត ខ្លួនឯងគប្បីជាអ្នកខ្វល់ខ្វាយក្នុងទាននោះ កាលពោលដោយប្រការដទៃ ទេយ្យធម៌របស់ខ្លួនត្រូវបំផ្លាញក្នុងឋានៈដែលមិនគួរ ហើយទក្ខិណេយ្យបុគ្គលគប្បីវិនាសចាកទាន ។

អង្កុរពាណិជ កាលតិះដៀលទានបតី គឺលោកសេដ្ឋី យ៉ាងនេះហើយ ឥឡូវនេះកាលនឹងសម្តែងវិធីដែលខ្លួនបដិបត្តិ ទើបពោល ២ គាថាថា

---

១-គាថានេះមានន័យថា ហេតុដូចម្តេច អសយ្ហសេដ្ឋីកាលឲ្យទាន ទើបបានប្រគល់ បាយ ទឹក ខាទនីយៈ សំពត់ នឹងសេនាសនៈ ឲ្យអ្នកដទៃចាត់ចែង ដូច្នេះ ។

ខ្ញុំទៅអំពីទីនេះ ដល់ទៅទ្វារកនគរហើយ នឹងតម្កល់នូវទាន ជាទីនាំមកនូវសេចក្ដីសុខដល់ខ្ញុំដោយពិត ។ ខ្ញុំនឹងឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្ដូងទឹក ទឹកសម្រាប់ផឹក និងសង់ ស្ពានក្នុងផ្លូវលំបាកទៅ ដូច្នេះ ។

ពាក្យនោះ មានអត្ថដូចពោលហើយនោះឯង កាលនឹងសម្ដែងបដិបទា របស់អង្កុរពាណិជ ទើបព្រះសង្គីតិកាចារ្យទាំងឡាយតាំងគាថា ៤ ដោយ សេចក្ដីថា

មែនពិត លុះអង្កុរៈនោះ ត្រឡប់អំពីទីនោះមកដល់ទ្វារកនគរ ហើយ ក៏បានតម្កល់នូវទាននោះ ជាទីនាំមកនូវសេចក្ដីសុខ ។ បានឲ្យបាយ ទឹក សំពត់ គ្រឿងសេនាសនៈ អណ្ដូងទឹក និងពាងទឹកសម្រាប់ផឹកដោយចិត្តជ្រះថ្លា ។ អ្នកណាឃ្លានអ្នក ណាស្រេក អ្នកណានឹងស្លៀកដណ្ដប់សំពត់ អ្នកណាលំបាក ដោយយានចូរទឹមពាហនៈបរអំពីទីនេះទៅចុះ ។ អ្នកណាចង់ បានឆត្រ ចង់បានគ្រឿងក្រអូប ចង់បានកម្រងផ្កា ចង់បាន ស្បែកជើងចូរយកទៅចុះ ពួកជាងកាត់សក់ ពួកអ្នកធ្វើបាយ នឹងពួកអ្នកក្រងផ្កា តែងស្រែកឃោសនា ក្នុងលំនៅនៃអង្កុរៈ ទាំងពេលព្រឹក ទាំងពេលល្ងាចសព្វៗកាលក្នុងទីនោះដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **គតោ** បានដល់ ទៅអំពីសមុទ្រខ្សាច់ ។ បទថា **និវត្តិត្វា** ប្រែថា ត្រឡប់ទៅហើយ ។ បទថា **អនុប្បត្វាន ទ្វារកំ**

សេចក្ដីថា ដល់ទ្វារវត្តីនគរ ។ បទថា **ធានំ បដ្ឋយិ អង្គុរោ** សេចក្ដីថា អង្កុរពាណិជនោះ ជាអ្នកមានឃ្លាំងទាំងអស់ដែលទេវបុត្តធ្វើឲ្យបរិបូណ៌ហើយ ទើបផ្ដើមតាំងមហាទានដែលឧបការៈដល់អ្នកដំណើរសព្វយ៉ាង ។ បទថា **យន្តំ អស្ស សុខាវហំ** សេចក្ដីថា ព្រោះឲ្យកើតសេចក្ដីសុខដល់ខ្លួន ទាំងក្នុងឥឡូវនេះនិងក្នុងអនាគត ។

បទថា **កោ ឆាតោ** អធិប្បាយថា អ្នកណាឃ្លាន ចូរមកបរិភោគតាមគាប់ចិត្ត ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **តសិតោ** ប្រែថា អ្នកស្រេក ។ បទថា **បរិទហិស្សតិ** សេចក្ដីថា នឹងស្លៀក នឹងដណ្ដប់ ។ បទថា **សន្តានិ** បានដល់ ដល់នូវការខ្សោយកម្លាំង ។ បទថា **យោគ្គានិ** បានដល់ ពាហនៈ គឺរថ ។ បទថា **ឥតោ យោជេន្តុ វាហានំ** សេចក្ដីថា ចូរកាន់យកតាមគាប់ចិត្តអំពីពួកវាហនៈ ដែលត្រៀមទុកនេះ ហើយចូរទឹមពាហនៈ ។

បទថា **កោ ឆត្តិច្ឆតិ** សេចក្ដីថា អ្នកណាត្រូវការឆត្រ មានឆត្រកន្ទេលផែងជាដើម អធិប្បាយថា បុគ្គលនោះចូរកាន់យកចុះ សូម្បីក្នុងបទដ៏សេសក៏មានន័យដូចគ្នា ។ បទថា **គន្ធំ** បានដល់ គ្រឿងក្រអូប មានគ្រឿងក្រអូបដែលប្រកបដោយជាតិ ៤ ជាដើម ។ បទថា **មាលំ** បានដល់ ផ្កាដែលក្រងនិងមិនបានក្រង ។ បទថា **ឧបាហានំ** បានដល់ ស្បែកជើង មានស្បែកជើងដែលធ្វើដោយស្បែកបិទកែងជើងជាដើម ។ សព្ទថា **សុ** ក្នុងពាក្យថា **ឥតិសុ** នេះ ត្រឹមតែជានិបាត ។ សេចក្ដីថា ដោយពាក្យជាដើមថា

អ្នកណាឃ្លាន អ្នកណាស្រេក ដោយប្រការដូច្នេះ គឺយ៉ាងនេះ ។ បទថា **កប្បកា** បានដល់ ជាងកោរកាត់ ។ បទថា **សូទ** បានដល់ ចុងភៅ ។ បទថា **មាគធា** បានដល់ អ្នកមគធៈ ។ មានវាចាប្រកបសេចក្តីថា បទថា **សទា** សេចក្តីថា ប្រកាស គឺឃោសនាក្នុងផ្ទះរបស់អង្គុរពាណិជនោះទាំងពេលព្រឹកទាំងពេលល្ងាចសព្វកាល គឺរាល់ថ្ងៃ ។

កាលអង្គុរពាណិជបំពេញមហាទានយ៉ាងនេះ លុះគ្រាកន្លងទៅក្នុងរោងទាន ក៏ស្ងាត់មនុស្សដែលត្រូវការ ព្រោះជាអ្នកគ្រប់គ្រាន់ហើយ ។ អង្គុរ-ពាណិជឃើញដូច្នោះ ក៏មិនសប្បាយចិត្ត ព្រោះជាអ្នកមានអធ្យាស្រ័យទូលំទូលាយក្នុងការឲ្យទាន ទើបហៅមាណពឈ្មោះសិន្ធុកៈដែលជួយខ្នះខ្នែងក្នុងទានរបស់ខ្លួនមក ហើយពោលគាថា ២ ថា

ជនតែងដឹងនូវខ្ញុំថា អង្គុរៈដេកជាសុខ ម្នាលសិន្ធុកមាណព
តែខ្ញុំដេកជាទុក្ខព្រោះមិនឃើញពួកយាចក ។ ជនតែងដឹងនូវ
ខ្ញុំថាអង្គុរៈតែងដេកលក់ជាសុខ ម្នាលសិន្ធុកមាណពតែខ្ញុំដេក
ជាទុក្ខព្រោះឃើញនូវពួកវណិព្វកជនតិច ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សុខំ សុបតិ អង្កុរោ ឥតិ ជានាតិ មំ ជនោ** សេចក្តីថា មហាជនលើកតម្កើងខ្ញុំយ៉ាងនេះថា ស្តេចអង្គុរដល់ព្រមដោយយសនិងភោគៈ ជាទានបតីរមែងផ្ទំជាសុខ គឺចូលដល់នូវការនិទ្រាដោយសេចក្តីសុខនោះឯង ភ្ញាក់ក៏ជាសុខដោយភោគសម្បត្តិ និងទានសម្បត្តិរបស់ព្រះអង្គ ។ បទថា **ទុក្ខំ សុបាមិ សិន្ធុក** សេចក្តីថា នៃសិន្ធុកមាណពខ្ញុំរមែង

ជេកជាទុក្ខតែម្យ៉ាង ។ ដើម្បីចៀសវាងនូវពាក្យសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះខ្ញុំមិនឃើញពួកយាចក អធិប្បាយថា ព្រោះខ្ញុំមិនឃើញពួកយាចកជាច្រើនដែលមកទទួលទេយ្យធម៌ ដែលសមគួរដល់អធ្យាស្រ័យរបស់ខ្ញុំ ។ មានវាចាប្រកបសេចក្ដីថា បទថា **អប្បកេ សុ វណិព្វកេ** សេចក្ដីថា ខ្ញុំដេកជាទុក្ខ កាលពួកវណិព្វកជនមានតិច គឺ ២-៣ នាក់ ។ សព្ទថា **សុ** ត្រឹមតែជានិបាត អធិប្បាយថា កាលវណិព្វកជនមានតិច ។ សិទ្ធកមាណពបានស្ដាប់ដូច្នេះហើយ មានបំណងនឹងធ្វើការបង្អោនទៅក្នុងទានដ៏ក្រៃលែងរបស់អង្កុរពាណិជឲ្យប្រាកដទើបពោលគាថាថា

ប្រសិនបើព្រះឥន្ទ្រជាធំជាងទេវតាក្នុងជាន់តាវត្តិង្ស គប្បីឲ្យពរ
ដល់អ្នក តើអ្នកគប្បីប្រាថ្នានូវពរដល់លោកទាំងពួងដូចម្ដេច
ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយដូច្នេះថា សក្កៈជាអ្នកធំជាងទេវតាជាន់តាវត្តិង្សនិងជាងសត្វលោកទាំងពួង បើគប្បីឲ្យពរដល់អ្នកថាអង្កុរ ចូរអ្នកសូមពរឯណាមួយដែលអ្នកប្រាថ្នា អ្នកកាលនឹងសូមពរ គឺកាលប្រាថ្នា គប្បីសូមពរដូចម្ដេច ។

លំដាប់នោះ អង្កុរពាណិជ កាលប្រកាសអធ្យាស្រ័យរបស់ខ្លួនតាមសេចក្ដីពិត ទើបពោលគាថា ២ ថា

បើព្រះឥន្ទ្រជាធំជាងទេវតាក្នុងជាន់តាវត្តិង្ស គប្បីឲ្យនូវពរដល់
ខ្ញុំ កាលខ្ញុំក្រោកឡើងអំពីព្រឹក ក្នុងវេលាជាទីរះឡើងនៃព្រះ

អាទិត្យកិច្ចាទាំងឡាយដ៏ជាទិព្វ គប្បីកើតប្រាកដ ពួកអ្នកមានសីលនិងយាចកគប្បីមានប្រាជក កាលខ្ញុំឲ្យនូវទានកុំគប្បីអស់ទៅឡើយ លុះខ្ញុំឲ្យរួចហើយកុំគប្បីក្តៅក្រហាយ កាលខ្ញុំកំពុងឲ្យ គប្បីញុំាងចិត្តឲ្យជ្រះថ្លា បពិត្រសក្កៈ ខ្ញុំចង់បាននូវពរយ៉ាងនេះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កាលុដ្ឋិតស្ស មេ សតោ** សេចក្តីថា កាលខ្ញុំក្រោកឡើងក្នុងពេលព្រឹក ជាអ្នកបរិបូណ៌ដោយសេចក្តីព្យាយាម គឺការប្រកបព្យាយាមដោយអំណាចសាមីចិកម្ម មានការបង្អោននិងការប្រណិប័តន៍ជាដើមចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយដែលមានសេចក្តីត្រូវការ ។ បទថា **សុរិយុគ្គមនំ បតិ** ប្រែថា ក្នុងវេលាព្រះអាទិត្យរះឡើង ។ បទថា **ទិព្វា ភក្ខា ចាតុភវេយ្យុំ** សេចក្តីថា អាហារដែលទាក់ទងក្នុងទេវលោកគប្បីកើតឡើង ។ បទថា **សីលវន្តោ ច យាចកា** សេចក្តីថា ពួកយាចកគប្បីជាអ្នកមានសីល មានកល្យាណធម៌ ។

បទថា **ទទតោ មេ ន ខីយេថ** សេចក្តីថា កាលខ្ញុំឲ្យទានដល់អ្នកដែលមកហើយ ទេយ្យធម៌រមែងមិនអស់ទៅ គឺមិនដល់នូវការអស់ ។ បទថា **ទត្វា នានុតបេយ្យហំ** សេចក្តីថា ព្រោះហេតុនោះយើងឲ្យទាននោះហើយ ឃើញបុគ្គលខ្លះមិនមានសេចក្តីជ្រះថ្លា មិនគប្បីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។ បទថា **ទទំ ចិត្តំ បសាទេយ្យំ** សេចក្តីថា កាលខ្ញុំកំពុងឲ្យគប្បីធ្វើចិត្តឲ្យជ្រះថ្លា គឺខ្ញុំជាអ្នកមានចិត្តជ្រះថ្លាហើយនោះឯង គប្បីឲ្យទាន ។

បទថា **ឯតំ សត្ថំ វរំ វរេ** សេចក្តីថា ខ្ញុំគប្បីសូមពរនឹងសក្កទេវរាជ ៥ យ៉ាង គឺការដល់ព្រមដោយការមិនមានរោគ ការដល់ព្រមដោយទេយ្យធម៌ ការដល់ព្រមដោយទក្ខិណេយ្យបុគ្គល ការដល់ព្រមដោយទេយ្យធម៌មិនមានប្រមាណនិងការដល់ព្រមដោយទាយក ។ ក្នុងពរ ៥ ប្រការនេះ ពាក្យថា កាលខ្ញុំក្រោកឡើងអំពីព្រឹកនេះ ឈ្មោះថា ការដល់ព្រមដោយការមិនមានរោគ ។ ដោយពាក្យថា ភិក្ខុទាំងឡាយដ៏ជាទិព្វគប្បីកើតប្រាកដ នេះឈ្មោះថាការដល់ព្រមដោយទេយ្យធម៌ ដោយពាក្យថាយាចកគប្បីជាអ្នកមានសីល នេះឈ្មោះថា ការដល់ព្រមដោយទក្ខិណេយ្យបុគ្គល ពាក្យថា កាលខ្ញុំឲ្យនូវទាន កុំគប្បីអស់ទៅឡើយ នេះឈ្មោះថា ការដល់ព្រមដោយទេយ្យធម៌មិនមានប្រមាណ ដោយពាក្យថា លុះខ្ញុំឲ្យរួចហើយ កុំគប្បីក្តៅក្រហាយ កាលខ្ញុំកំពុងឲ្យគប្បីញុំាងចិត្តឲ្យជ្រះថ្លានេះ ឈ្មោះថា ការដល់ព្រមដោយទាយក សរុបសេចក្តីថា អង្កុរពាណិជ ប្រាថ្នានូវប្រយោជន៍ ៥ ប្រការ ដោយភាពជាពរ ។ ប្រយោជន៍ ៥ ប្រការនោះឯង គប្បីជ្រាបថា មានត្រឹមតែដើម្បីភាពជាជំនៃបុណ្យដែលសម្រេចដោយទាននោះឯង ។

កាលអង្កុរពាណិជ ប្រកាសអធ្យាស្រ័យរបស់ខ្លួនយ៉ាងនេះ បុរសម្នាក់ឈ្មោះសោនកៈ ជាអ្នកមានជំនាញក្នុងនីតិសាស្ត្រ អង្គុយក្នុងទីនោះ មានបំណងនឹងកាត់ទាននោះចាកទានដែលលើសប្រមាណ ទើបបានពោលគាថា ២ ថា

បុគ្គល កុំគប្បីឲ្យនូវទ្រព្យគាប់ចិត្តទាំងអស់ ដល់បុគ្គលដទៃ

ឡើយ បុគ្គលគប្បីឲ្យនូវទានផង គប្បីរក្សានូវទ្រព្យផងព្រោះ
ថា ទ្រព្យនោះឯង ប្រសើរជាងទាន ត្រកូលទាំងឡាយមិន
ចម្រើនព្រោះឲ្យទានខ្លាំងពេកទេ ។ អ្នកប្រាជ្ញទាំងឡាយរមែង
មិនសរសើរនូវការមិនឲ្យទានផង នូវការឲ្យទានច្រើនពេកផង
ព្រោះថា ទ្រព្យនោះឯងប្រសើរជាងទាន បុគ្គលគួរប្រព្រឹត្តឲ្យ
ស្មើ នោះជាធម៌របស់អ្នកប្រាជ្ញ ដូច្នេះ ។

អាចារ្យមួយពួកទៀតពោលថា សិន្ធុកមាណព មានបំណាងនឹងពិសោធ យ៉ាងនេះទៀត ទើបពោលគាថាជាដើមថា បុគ្គលកុំគប្បីឲ្យនូវទ្រព្យគាប់ចិត្តទាំងអស់ ជាដើម ។ ក្នុងបទទាំងនោះ បទថា **សព្វវិត្តានិ** បានដល់ ឧបករណ៍នៃទ្រព្យជាទីត្រេកអរនៃចិត្តទាំងអស់ ទោះជាសវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យក៏ដោយ អធិប្បាយថា ទ្រព្យទាំងឡាយ ។ បទថា **បរេ** កែជា **បរម្ហិ** ប្រែថា ដល់បុគ្គលដទៃ អធិប្បាយថា **បរស្ស** ប្រែថា ដល់បុគ្គលដទៃ ។ បទថា **ន បវេច្ឆេ** ប្រែថា មិនគប្បីឲ្យ អធិប្បាយថា មិនគួរធ្វើការបរិច្ចាគទ្រព្យទាំងអស់ មិនបន្សល់ទុក ដោយគិតថា អញបានទក្ខិណេយ្យបុគ្គល ។ បទថា **ទទេយ្យ ទានញ្ច** សេចក្តីថា មិនគួរធ្វើការឲ្យទានជាធម្មតាដោយប្រការទាំងពួង ដោយពិត គួរដឹងសេចក្តីចម្រើន និងសេចក្តីវិនាសរបស់ខ្លួនហើយគប្បីឲ្យទានដែលសមគួរដល់សម្បត្តិ ។ បទថា **ធនញ្ច រក្ខេ** សេចក្តីថា គប្បីរក្សាទ្រព្យ ដោយអំណាចការស្វែងរកទ្រព្យដែលមិនទាន់បាន រក្សាទ្រព្យដែលបានហើយ ស្វែងរកទ្រព្យដែលបាត់មក

រក្សា ។ ម្យ៉ាងទៀត ព្រោះទាននោះ មានទ្រព្យនោះជាហេតុ បុគ្គលគប្បី រក្សាទ្រព្យតាមដែលពោលទុក ( ក្នុងសិង្គាលកសូត្រ ) ថា

កុលបុត្តដែលចែកភោគៈទាំងឡាយជា ៤ ចំណែកគឺបរិភោគ ភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារ ២ ចំណែក ទាំងតម្កល់ទុកនូវចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំង ឡាយ ( ទៅខាងមុខ ) ដូច្នេះ ។

ពិតហើយ អ្នកច្បាប់គិតថា គប្បីបដិបត្តិផ្លូវទាំង ៣ ដោយធ្វើគ្រប់ៗ ចំណែកឲ្យបរិសុទ្ធ ។ បទថា **តស្មា ហិ** សេចក្តីថា កាលរក្សាទ្រព្យ និង បំពេញទាន ឈ្មោះថា ប្រព្រឹត្តទៅតាមទាន មានទ្រព្យជាហេតុ ដើម្បីជាប្រ-យោជន៍ដល់លោកទាំង ២ ព្រោះហេតុនោះទើបទ្រព្យប៉ុណ្ណោះប្រសើរ គឺល្អ ជាងទាន ព្រោះហេតុនោះទើបអធិប្បាយថា មិនគប្បីធ្វើទានលើសប្រមាណ ដោយហេតុនោះ ទើបលោកពោលថា ត្រកូលទាំងឡាយមិនចម្រើន ព្រោះ ឲ្យទានខ្លាំងពេកទេ អធិប្បាយថា ព្រោះមិនដឹងប្រមាណរបស់ទ្រព្យអាស្រ័យ ទ្រព្យនោះឲ្យទានទើបត្រកូលតាំងនៅមិនបាន គឺប្រព្រឹត្តទៅមិនបាន បានដល់ ដាច់សូន្យ ព្រោះឲ្យលើសប្រមាណ ។

ឥឡូវនេះ សោនកបុរស កាលតាំងប្រយោជន៍ដែលវិញ្ញូជនសរសើរ ទើបពោលគាថាថា អ្នកប្រាជ្ញទាំងឡាយ រមែងមិនសរសើរនូវការមិនឲ្យទាន ផង នូវការឲ្យទានច្រើនពេកផង ជាដើម ។ ក្នុងបទទាំងនោះ បទថា **អ-ធានមតិធានញ្ច** សេចក្តីថា បណ្ឌិតទាំងឡាយ គឺអ្នកប្រាជ្ញ បានដល់

អ្នកមានបញ្ញា រមែងមិនសរសើរ រមែងមិនលើកតម្កើងការមិនឲ្យទាន រមែងមិនសរសើរការមិនឲ្យកិច្ចាមួយរែកក្តី អឌ្ឍរមួយក្តាប់ក្តី ដោយប្រការទាំងពួង និងការឲ្យលើសប្រមាណ ពោលគឺបរិច្ចាគលើសប្រមាណ ពិតហើយបុគ្គលនោះ រមែងជាអ្នកឆ្ងាយចាកនូវប្រយោជន៍ក្នុងសម្បរាយភព ព្រោះមិនឲ្យទានដោយប្រការទាំងពួង ។ បវេណីក្នុងបច្ចុប្បន្នរមែងមិនប្រព្រឹត្តទៅព្រោះការឲ្យទានលើសប្រមាណ ។ បទថា **សមេន វត្តេយ្យ** សេចក្តីថា បុគ្គលជាអ្នកប្រាជ្ញ សម្បូរដោយធម៌ គួរប្រព្រឹត្តដោយញាណជាកណ្តាលដែលមាំទាំសមគួរដល់ផ្លូវលោក ប្រព្រឹត្តទៅស្មើ ។ ដោយពាក្យជា **ស ធីរធម្មោ** នេះលោកសម្តែងថា ការប្រព្រឹត្តទៅនៃការឲ្យ និងការមិនឲ្យ តាមដែលពោលហើយ យ៉ាងណា នុ៎ះចាត់ជាធម៌ គឺជាផ្លូវដែលអ្នកប្រាជ្ញសម្បូរដោយបញ្ញាឈ្លាសក្នុងនីតិន័យ ប្រព្រឹត្តទៅហើយ ។

អង្កុរពាណិជ បានស្តាប់ដូច្នោះហើយ កាលនឹងដោះនូវបំណងរបស់សោនកបុរសនោះទើបប្រកាសវិធីដែលខ្លួនគប្បីបដិបត្តិដោយគាថា ៤ ថា

ឱហ្ន៎ អាត្មាអញគប្បីឲ្យនូវទាន ព្រោះថាសប្បុរសទាំងឡាយ
អ្នកមានចិត្តស្ងប់រម្ងាប់ហើយ គប្បីគប់រកនូវអាត្មាអញ អាត្មា
អញញុំាងពួកវណិព្វកៈទាំងពួង ឲ្យឆ្អែតស្កប់ស្កល់ ដូចមហា
មេឃញុំាងទីទាបឲ្យពេញដូច្នោះ ។

សម្បុរមុខរបស់បុគ្គលណាជ្រះថ្លា ព្រោះឃើញនូវយាចក
ទាំងឡាយ បុគ្គលនោះ លុះឲ្យហើយរមែងមានចិត្តត្រេកអរ

នោះជាសុខរបស់បុគ្គលអ្នកគ្រប់គ្រងផ្ទះ ។ សម្បុរមុខរបស់
បុគ្គលណាជ្រះថ្លា ព្រោះឃើញនូវយាចកទាំងឡាយ បុគ្គល
នោះ លុះឲ្យរួចហើយរមែងមានចិត្តត្រេកអរ នេះជាការបរិ-
បូណ៌នៃយញ្ញ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អហោ វត** ប្រែថា ឱ ! ល្អហ្ន៎ ។ បទថា **រេ** ជាអាលបនៈ ( ពាក្យហៅ ) ។ បទថា **អហាមេវ ឧជ្ជំ** កែជា **អហំ ឧជ្ជ-មេវ** ប្រែថា ខ្ញុំគប្បីឲ្យនោះឯង ។ ពិតហើយ ក្នុងសេចក្ដីនេះ មានសេចក្ដីសង្ខេបដូចតទៅនេះថា នៃមាណព បើភពទ:របស់អ្នកឈ្មោសក្នុងនីតិសាស្ត្រនេះចូរមានដល់អ្នកថា ទ្រព្យប៉ុណ្ណោះល្អជាងទានក៏ពិតតែយើងក៏គប្បីឲ្យដោយពិត ។ បទថា **សន្តោ ច មំ សប្បុរិសា ភជេយ្យុំ** សេចក្ដីថា សប្បុរស គឺមនុស្សល្អទាំងឡាយ ជាអ្នកស្ងប់ គឺអ្នកមានកាយសមាចារ វចីសមាចារ និងមនោសមាចារស្ងប់ គប្បីសេពគប់ គឺគប្បីចូលដល់យើងក្នុងទាននោះ ។ បទថា **មេឃោវ និន្នានិ បរិបូរយន្តោ** សេចក្ដីថា គួរអស្ចារ្យពិត ខ្ញុំកាលញ៉ាំងបំណងរបស់វណិព្វកៈឲ្យពេញ ឈ្មោះថា គប្បីញ៉ាំងវណិព្វកៈទាំងនោះឲ្យឆ្អែតស្កប់ស្កល់ ដូចមហាមេឃ កាលញ៉ាំងភ្លៀងឲ្យធ្លាក់ ឈ្មោះថា ញ៉ាំងរណ្ដៅ គឺទីទាបឲ្យពេញដូច្នោះ ។

បទថា **យស្ស យាចនកេ ទិស្វា** សេចក្ដីថា ទឹកមុខរបស់បុគ្គលណា គឺអ្នកគ្រប់គ្រងផ្ទះដែលកើតសទ្ធាឡើងជាដំបូងថា បុញ្ញក្ខេត្តប្រាកដដល់អញហ្ន៎ ដូច្នេះ រមែងជ្រះថ្លាព្រោះឃើញពួកយាចក បុគ្គលនោះ កាលឲ្យទានដល់

យាចកទាំងនោះតាមសម្បត្តិហើយ រមែងត្រេកអរ គឺរមែងមានចិត្តដែលបីតិនិងសោមនស្សពាល់ត្រូវហើយ ។ បទថា **តំ** សេចក្តីថា ការឃើញយាចកក្នុងកាលណា និងឃើញយាចកទាំងនោះហើយ ចិត្តរមែងជ្រះថ្លា និងកាលឲ្យទានតាមសមគួរហើយរមែងត្រេកអរ ។

បទថា **ឯសា យញ្ញស្ស សម្បទា** សេចក្តីថា នុ៎ះជាការដល់ព្រមគឺការបរិបូណ៌ បានដល់ ការសម្រេចនៃយញ្ញ ។

បទថា **បុព្វេវ ទានា សុមនោ** សេចក្តីថា បុគ្គលគប្បីជាអ្នកមានចិត្តល្អ គឺកើតសោមនស្ស តាំងអំពីរៀបចំទេយ្យទានមុនមុញ្ចនចេតនាថា អញនឹងកប់ទ្រព្យដែលជាហេតុជាប់តាមខ្លួនទៅបានដែលជាហេតុកើតសម្បត្តិទាំងពួង ។ បទថា **ទទំ ចិត្តំ បសាទយេ** សេចក្តីថា កាលឲ្យ គឺកាលញុំាំងទេយ្យធម៌ឲ្យតាំងនៅក្នុងដៃរបស់ទក្ខិណេយ្យបុគ្គល គប្បីញុំាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លាថា អញនឹងកាន់យកវត្ថុដែលជាសារៈអំពីទ្រព្យដែលមិនមានសារៈ ។ បទថា **ទត្វា អត្តមនោ ហោតិ** សេចក្តីថា កាលបរិច្ចាគទេយ្យធម៌ដល់ទក្ខិណេយ្យបុគ្គលហើយរមែងជាអ្នកមានចិត្តល្អ គឺមានការត្រេកអរ បានដល់រមែងកើតបីតិនិងសោមនស្សថា ឈ្មោះថា ទានដែលបណ្ឌិតបញ្ញត្តហើយ ខ្ញុំក៏បានដើរតាមហើយ ។ ឱ ! ល្អពិតហ្ន៎ ។ បទថា **ឯសា យញ្ញស្ស សម្បទា** សេចក្តីថា បរិបូណ៌ដោយចេតនាទាំង ៣ ដែលសោមនស្សពាល់ត្រូវហើយទៅតាមការជឿកម្មនិងផលនៃកម្មនេះ គឺ បុព្វចេតនា មុញ្ចនចេតនា និងអបរចេតនាណា នោះជាសម្បទានៃយញ្ញគឺការដល់ព្រមនៃទានអធិប្បាយ

ថា មិនមែនប្រព្រឹត្តទៅដោយប្រការដទៃចាកសម្បទានេះ ។

អង្កុរទេវបុត្រ កាលប្រកាសវិធីបដិបត្តិរបស់ខ្លួនយ៉ាងនេះហើយ ជាអ្នកមានអធ្យាស្រ័យក្នុងទានក្រៃលែងឡើង បំពេញមហាទានរាល់ៗថ្ងៃឲ្យប្រព្រឹត្តទៅដោយប្រមាណក្រៃលែង ។ ព្រោះហេតុនោះ ក្នុងកាលនោះ កាលធ្វើរាជសម្បត្តិទាំងពួងឲ្យដូចជាទីទួល ហើយឲ្យមហាទានប្រព្រឹត្តទៅ មនុស្សទាំងឡាយបានឧបករណ៍នៃទានទាំងពួងហើយ លះនូវការងាររៀងៗខ្លួន ត្រាច់ទៅតាមសេចក្តីសុខ ។ ព្រោះហេតុនោះ ឃ្លាំងរបស់ព្រះរាជាទាំងឡាយ ក៏ដល់នូវការអស់ទៅ ។ លំដាប់នោះ ព្រះរាជាទាំងឡាយ ក៏បានបញ្ជូនទូតដល់អង្កុរទេវបុត្រថា លោកដ៏ចម្រើន ព្រោះអាស្រ័យទាន សេចក្តីចម្រើនរបស់ពួកយើងក៏បានវិនាសទៅ ឃ្លាំងទាំងឡាយ ក៏ដល់នូវការអស់ទៅ ពួកយើងគួរដឹងហេតុដែលសមគួរក្នុងសេចក្តីនោះ ដូច្នេះ ។

អង្កុរទេវបុត្របានស្តាប់ដូច្នោះហើយ ក៏ទៅកាន់ទក្ខិណាជនបទ ធ្វើរោងទានធំៗជាច្រើន ក្នុងទីមិនឆ្ងាយអំពីមហាសមុទ្រ ក្នុងទីលំនៅរបស់ពួកទមិឡឲ្យមហាទានប្រព្រឹត្តទៅ តាំងនៅដរាបដល់អស់អាយុ ។ ខាងមុខអំពីកាយបែកធ្លាយកើតក្នុងស្ថានតាវត្តិង្ស ។ ព្រះសង្គីតិកាចារ្យទាំងឡាយកាលសម្តែងសម្បត្តិនៃទាននិងការចូលដល់ស្ថានសួគ៌របស់អង្កុរទេវបុត្រនោះ ទើបពោលគាថាទាំងឡាយថា

បុគ្គលតែងឲ្យភោជនជានិច្ច ដល់ជនអ្នកប្រាថ្នាបុណ្យក្នុងលំ-
នៅនៃអង្កុរៈអស់ ៦០០០០ ដឹក ។ ពួកអ្នកធ្វើបាយចំនួន ៣

ពាន់ ( ៣០០០ ) នាក់ ប្រដាប់នូវកុណ្ឌលដ៏វិចិត្រដោយកែវមណី ជាអ្នកខ្វល់ខ្វាយនូវបុណ្យក្នុងការឲ្យទានតែងអាស្រ័យចិញ្ចឹមជីវិតនឹងអង្កុរៈ ។ ពួកបុរសចំនួន ប្រាំមួយម៉ឺន ( ៦០០០០ ) នាក់ ប្រដាប់នូវកុណ្ឌលដ៏វិចិត្រ ដោយកែវមណី ជាមាណពតែងពុះឧសក្នុងមហាទាននៃអង្កុរៈ ។ ពួកស្ត្រីចំនួន មួយម៉ឺនប្រាំមួយពាន់ ( ១៦០០០ ) នាក់ ប្រដាប់នូវគ្រឿងអលង្ការទាំងពួងជានារីអ្នកចាត់ចែងប្រមូលនូវកណ្ឌៈក្នុងមហាទាននៃអង្កុរៈ ។ ពួកស្ត្រីចំនួន មួយម៉ឺនប្រាំមួយពាន់ ( ១៦០០០ ) នាក់ ប្រដាប់នូវគ្រឿងអលង្ការទាំងពួង ជាអ្នកកាន់នូវវែក ហើយចូលទៅឈរនៅ ( នាបរិវេណ ) ក្នុងមហាទាននៃអង្កុរៈ ។ អ្នកចូរឲ្យទានច្រើន ដល់ជនច្រើន ម្នាលនាងក្សត្រីនាងចូរឲ្យទានអស់កាលដ៏យូរចុះ ធ្វើនូវសេចក្តីកោតក្រែងដោយគោរពផង ដោយដៃផង ឲ្យរឿយៗចុះ ។ អង្កុរៈបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ អស់ខែទាំងឡាយជាច្រើនផង អស់បក្ខទាំងឡាយជាច្រើនផង អស់រដូវនិងឆ្នាំទាំងឡាយជាច្រើនផង ក្នុងចន្លោះនៃកាលដ៏វែងឆ្ងាយ ។ អង្កុរៈបានឲ្យទានយ៉ាងនេះផង បូជាយ៉ាងនេះផង អស់ចន្លោះនៃកាលដ៏វែង អង្កុរៈនោះលុះលះបង់រាងកាយជាមនុស្សនេះទៅក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្ស ដូច្នេះ ។

មានវាចាប្រកបសេចក្តីថា ក្នុងបទទាំងនោះ បទថា **សដ្ឋិ វាហស-ហស្សានិ** សេចក្តីថា ក្នុងផ្ទះរបស់អង្កុរពាណិជដែលជាអ្នកប្រាថ្នាបុណ្យ គឺមានអធ្យាស្រ័យក្នុងទាន បានដល់ ជាអ្នកមានចិត្តបង្អោនទៅក្នុងទាន គោជនដែលគេឲ្យដល់ពួកជន គឺពួកសត្វ មួយថ្ងៃ ៦ ម៉ឺនរទេះ គឺ ៦ ម៉ឺនរទេះ ដែលផ្ទុកគ្រឿងក្រអូប ស្រូវសាលីជាដើមជានិច្ច ។

បទថា **តិសហស្សានិ សូទា ហិ** សេចក្តីថា ចុងភៅ គឺអ្នកដាំស្ល ប្រមាណ ៣០០០ នាក់ អ្នកដាំស្លទាំងនោះ លោកបំណងយកថា ជាប្រធាន ។ ក្នុងបណ្តាអ្នកដាំស្លទាំងនោះ បុគ្គលដែលធ្វើតាមពាក្យរបស់មេចុងភៅម្នាក់ៗ គប្បីជ្រាបថា មានច្រើន ។ បាលីថា **តិសហស្សានិ សូទានំ** ដូច្នេះក៏មាន ។ បទថា **អាមុត្តមណិកុណ្ឌលា** បានដល់ ដែលទ្រទ្រង់នូវកុណ្ឌលដ៏វិចិត្រដោយកែវមណីផ្សេងៗ ។ បទថា **អាមុត្តមណិកុណ្ឌលា** នេះ ត្រឹមតែជាឧទាហរណ៍ ។ ចុងភៅទាំងនោះ មានគ្រឿងអាភរណៈដូចជា កងដៃនិងខ្សែក្រវាត់ធ្វើដោយកែវមុក្តាជាដើម ។ បទថា **អង្គំ ឧបជីវន្តិ** សេចក្តីថា ចូលទៅអាស្រ័យអង្កុរពាណិជចិញ្ចឹមជីវិត អធិប្បាយថា មានជីវិតទាក់ទងជាមួយអង្កុរពាណិជនោះ ។ បទថា **ទានេ យញ្ញស្ស វាវដា** សេចក្តីថា ជាអ្នកខ្វល់ខ្វាយ គឺដល់នូវការខ្វល់ខ្វាយក្នុងការប្រកបទាននៃយញ្ញដែលហៅថា ការបូជាធំ ។ បទថា **កដ្ឋំ ផាលេន្តិ មាណវា** សេចក្តីថា ពួកមនុស្សកំលោះៗ ដែលប្រដាប់តាក់តែងហើយនាំគ្នាពុះ គឺនាំគ្នាកាប់ឧសដើម្បីចម្អិន អាហារ-វិសេស មានរបស់ទំពានិងរបស់បរិភោគជាដើមមានប្រការផ្សេងៗ ។ បទថា

**រិជា** បានដល់ គ្រឿងក្តៅ សម្រាប់ផ្សំអាហារដែលគប្បីចាត់ចែង ។ បទថា **បិណ្ឌេន្តិ** បានដល់ ប្រកបដោយការបុក ។

បទថា **ឧត្តិដ្ឋាហរា** ប្រែថា អ្នកកាន់វែក ។ បទថា **ឧបដ្ឋិតា** សេចក្តីថា ចូលទៅឈរចាំបម្រើក្នុងទីសម្រាប់បម្រើ ។

បទថា **ពហុំ** ប្រែថា ច្រើន គឺគ្រប់គ្រាន់ ។ បទថា **ពហូធំ** ប្រែថា សន្ទឹកសន្ធាប់ ។ បទថា **ចាធាសិ** បានដល់ បានឲ្យដោយប្រការទាំងឡាយ ។ បទថា **ចិរំ** ប្រែថា អស់កាលយូរ ។ ពិតហើយ អង្កុរកើតក្នុងសម័យមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ។ កាលអង្កុរឲ្យទានដ៏ច្រើនដល់មហាជនអស់កាលយូរ ដើម្បីសម្តែងប្រការដែលអង្កុរឲ្យទាន ទើបពោលថា **សក្កច្ចញ្ច** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **សក្កច្ចំ** គឺមានការអើពើ បានដល់ មិនបោះឲ្យ គឺមិនមើលងាយ ។ បទថា **សហត្ថា** ប្រែថា ដោយដៃរបស់ខ្លួន មិនមែនប្រើអ្នកដទៃ ។ បទថា **ចិត្តីកត្វា** សេចក្តីថា ធ្វើ គឺបូជាដោយចិត្តដែលប្រកបដោយសេចក្តីគោរពនិងការរាប់អានច្រើន ។ បទថា **បុនប្បុនំ** បានដល់ ដោយចំណែកច្រើន គឺមិនមែនម្តង មានវាចា ប្រកបសេចក្តីថា មិនមែនធ្វើ ២-៣ វារៈឡើយ បានឲ្យច្រើនវារៈ ។

ឥឡូវនេះ ដើម្បីប្រកាសការធ្វើរឿយៗនោះឯង ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថាថា **ពហូ មាសេ ច** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ពហូ មាសេ** បានដល់ ច្រើនខែ មានខែចេត្រជាដើម ។ បទថា **បក្ខេ** បានដល់ អស់បក្ខជាច្រើន មានកណ្ហបក្ខនិងសុក្កបក្ខ ។ បទថា

**ឧតុសំវច្ឆរានិ** ច សេចក្តីថា អស់រដូវនិងឆ្នាំជាច្រើន ដូចជាវស្សន្តរដូវនិង គិម្ហន្តរដូវជាដើម ។ បទថា **ឧតុសំវច្ឆរានិ** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថ អច្ចន្តសំយោគក្នុងទីទាំងពួង ។ បទថា **ទីឃមន្តរំ** ប្រែថា អស់រយៈកាល យូរ ។ ក្នុងសេចក្តីនេះ ដើម្បីពោលដល់ភាពដែលទានប្រព្រឹត្តទៅអស់កាល យូរថា អង្កុរបានឲ្យអស់កាលយូរហើយ ទើបសម្តែងថា ទាននោះប្រព្រឹត្ត ទៅមិនដាច់នោះឯង គប្បីឃើញថា លោកពោលថា **ពហូ មាសេ** ដូច្នេះជា ដើម ។

បទថា **ឯវំ** បានដល់ ដោយប្រការដូចពោលហើយ ។ បទថា **ឧត្វា យជិត្វា** ច ដោយអត្ថក៏ជាបទដូចគ្នានោះឯង អធិប្បាយថា បានឲ្យដោយ អំណាចបរិច្ចាគទេយ្យធម៌ណាមួយដល់ទក្ខិណេយ្យបុគ្គលពួកខ្លះ និងកាលឲ្យ តាមកម្លាំងដល់ជនទាំងពួង ដែលត្រូវការ ដោយន័យដែលពោលហើយថា បានឲ្យទ្រព្យដ៏ច្រើនដល់មហាជន បូជាដោយអំណាចបូជាធំ ។ បទថា **សោ ហិត្វា មានុសំ ទេហំ តាវតឹសូបគោ អហុ** សេចក្តីថា ក្នុងពេលអស់ អាយុ អង្កុរពាណិជនោះ លះអត្តភាពមនុស្សទៅកើតជាទេវតាក្នុងឋានតា- វត្តិង្ស ដោយបដិសន្ធិ ។

កាលអង្កុរទេវបុត្តនោះ កើតក្នុងជាន់តាវត្តិង្សសោយទិព្វសម្បត្តិយ៉ាងនេះ ក្នុងកាលព្រះមានព្រះភាគនៃយើងកើតឡើងក្នុងលោក ឥន្ទកមាណព កាល ព្រះអនុរុទ្ធត្ថេរ ត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា បានប្រគេនបាយមួយវែក សម័យតមក ឥន្ទកបុរសធ្វើកាលកិរិយាហើយកើតជាទេវបុត្ត ដែលមានឫទ្ធិ

ច្រើន មានអានុភាពច្រើន ក្នុងស្ថានតាវត្តិង្ស ដោយអានុភាពនៃបុញ្ញខេត្ត មានពន្លឺរុងរឿងគ្របសង្កត់អង្កុរទេវបុត្តដោយឋានៈ ១០ មានរូបជាដើមដែលជាទិព្វ ។ ដោយហេតុនោះ ទើបលោកពោលថា

ឥន្ទកៈបានឲ្យនូវបច្ឆាន់មួយវែកដល់ព្រះអនុរុទ្ធ ឥន្ទកៈនោះលុះលះបង់រាងកាយជាមនុស្សនេះទៅ ក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្សដែរ ។ ឥន្ទកៈជាអ្នករុងរឿងជាងអង្កុរៈដោយឋានៈ ១០ យ៉ាង គឺ រូប ១ សំឡេង ១ រស ១ ក្លិន ១ ផោដ្ឋព្វដ៏ជាទីតម្រេកនៃចិត្ត ១ អាយុ ១ យស ១ សម្បុរ ១ សេចក្តីសុខ ១ ភាវៈជាធំ ១ ឥន្ទកៈទេវបុត្តរុងរឿងជាងអង្កុរៈទេវបុត្ត ដោយភាពជាធំ ( យ៉ាងនេះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រូបេ** សេចក្តីថា រូបជាហេតុ គឺរូបសម្បត្តិរបស់ខ្លួនជានិមិត្ត ។ សូម្បីក្នុងបទថា **សទ្ទេ** ជាដើមក៏មានន័យដូចគ្នា ។ បទថា **អាយុនា** បានដល់ ដោយជីវិត ។ ជីវិតរបស់ទេវតាទាំងឡាយលោកពោលថា មានកំណត់ជាប្រមាណមិនមែនឬ លោកពោលពិត តែជីវិតនោះ លោកពោលដោយចំណែកច្រើន ។ ពិតហើយ ទេវតាពួកខ្លះរមែងមានការស្លាប់ក្នុងចន្លោះនោះឯងព្រោះវិបត្តិនៃសេចក្តីព្យាយាមជាដើម ។ ឯឥន្ទកទេវបុត្ត ញុំាងឆ្នាំទាំងឡាយ ៣ កោដិ ៦ លាន ឲ្យបរិបូណ៌ ព្រោះហេតុនោះទើបលោកពោលថា រមែងរុងរឿងដោយអាយុ ។ បទថា **យសសា** បានដល់ បរិបូណ៌ដោយបរិវារធំ ។ បទថា **វណ្ណេន** សេចក្តីថា ដោយការ

បរិបូណ៌ដោយសណ្ឋានទ្រង់ទ្រាយ ។ ការបរិបូណ៌ដោយវណ្ណធាតុ លោកពោលដោយបទថា **រូបេ** ដូច្នេះនោះឯង ។ បទថា **អាធិបច្ចេន** បានដល់ដោយភាពជាធំ ( ឥស្សរះ ) ។

កាលអង្កុរទេវបុត្តនិងឥន្ទកទេវបុត្ត កើតក្នុងស្ថានតាវត្តិង្ស សោយទិព្វសម្បត្តិ ព្រះមានព្រះភាគនៃយើង ទ្រង់ធ្វើយមកប្បាដិហារ្យ ត្រង់គល់គណ្ឌម្ពព្រឹក្ស ត្រង់ទ្វារនៃនគរសាវត្ថី ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី នាឆ្នាំទី ៧ បន្ទាប់អំពីត្រាស់ដឹង ទ្រង់យាងទៅកាន់តាវត្តិង្សដោយឈាន ៣ ជំហានតាមលំដាប់ ទ្រង់គ្របសង្កត់នូវភាពរុងរឿងរបស់ទេវតា និងព្រហ្មបរិស័ទ ដែលប្រជុំគ្នាដោយលោកធាតុ ត្រង់បណ្ឌុកម្ពលសិលាអាសនៈ នាមណ្ឌលបារិច្ឆត្តកៈដោយស្មើរបស់ព្រះអង្គ ដូចព្រះសុរិយោទ័យ ជះរស្មីស្រទន់ លើក្ដំយុគន្ធរ រុងរឿងដូច្នោះ គង់សម្ដែងអភិធម្ម ទតឃើញឥន្ទកទេវបុត្តអង្គុយក្នុងទីមិនឆ្ងាយ និងអង្កុរទេវបុត្តដែលអង្គុយចម្ងាយ ១២ យោជន៍ ដើម្បីប្រកាសភាពបរិបូណ៌នៃទក្ខិណេយ្យបុគ្គល ទើបត្រាស់គាថាថា

> ម្នាលអង្កុរៈ មហាទានដែលអ្នកបានឲ្យហើយ ក្នុងចន្លោះនៃ
> កាលដ៏វែង ឥឡូវអ្នកទៅអង្គុយនៅក្នុងទីឆ្ងាយ ចូរអ្នកមកក្នុង
> ទីជិតនៃតថាគត ដូច្នេះ ។

អង្កុរទេវបុត្តបានស្ដាប់ដូច្នោះទើបទូលថា បពិត្រព្រះមានព្រះភាគ មហាទានដែលខ្ញុំព្រះអង្គបរិច្ចាគ ទេយ្យធម៌ជាច្រើនបំពេញមកអស់កាលយូរក៏មិនមានផលល្អ ព្រោះវៀរចាកទក្ខិណេយ្យសម្បត្តិ ដូចពូជដែលព្រោះ ក្នុងស្រែ

មិនល្អ ដូច្នោះ សូម្បីការឲ្យភិក្ខាមួយវែករបស់ឥន្ទកទេវបុត្ត គង់មានផល ច្រើនក្រៃលែង ព្រោះបរិបូណ៌ដោយទក្ខិណេយ្យបុគ្គល ដូចពូជដែលព្រោះក្នុងស្រែល្អ ដូច្នោះ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលសម្តែងសេចក្តីនោះ ទើបពោលគាថាថា

កាលណា ព្រះពុទ្ធឧត្តមជាងបុរស គង់នៅលើថ្មបណ្ឌុកម្ពល ជិតគល់នៃបារិច្ឆត្តកព្រឹក្សក្នុងជាន់តាវត្តិង្ស ។ ទេវតាទាំងឡាយ ក្នុងលោកធាតុទាំង ១០ បានប្រជុំគ្នា ចូលទៅអង្គុយជិតព្រះពុទ្ធដែលគង់នៅលើកំពូលភ្នំសិនេរុ ទេវតាណាមួយ រុងរឿង ជាងព្រះសម្ពុទ្ធដោយវណ្ណៈមិនមានឡើយ មានតែព្រះសម្ពុទ្ធ មួយព្រះអង្គឯងប៉ុណ្ណោះ រុងរឿងកន្លងនូវទេវតាទាំងអស់ ។ ក្នុងកាលនោះ អង្កុរទេវបុត្តនៅក្នុងទីប្រមាណ ១២ យោជន៍ ឥន្ទកទេវបុត្ត រុងរឿងក្រៃពេកក្នុងទីជិតព្រះសម្ពុទ្ធ ។ ព្រះសម្ពុទ្ធទ្រង់រមិលមើលនូវអង្កុរទេវបុត្តនិងឥន្ទកទេវបុត្ត កាលទ្រង់សរសើរនូវទក្ខិណេយ្យបុគ្គល បានត្រាស់សម្តែងនូវពាក្យនេះថា ម្នាលអង្កុរ មហាទានដែលអ្នកឲ្យហើយ អស់ចន្លោះនៃកាលដ៏វែង អ្នកអង្គុយក្នុងទីឆ្ងាយពេកណាស់ ចូរមកជិតតថាគតមក ។

អង្កុរទេវបុត្ត ដែលព្រះសម្ពុទ្ធមានព្រះអង្គអប់រំហើយ ទ្រង់ដាស់តឿនហើយក៏បានក្រាបទូលដូច្នេះថា ប្រយោជន៍អ្វីដោយ

ទាននោះរបស់ខ្ញុំព្រះអង្គ ព្រោះទាននោះសូន្យចាកទក្ខិណេយ្យ
បុគ្គល ។ ឥន្ទកយក្ខនេះឯង ឲ្យទានតិចតួចទេ រុងរឿងជាង
ពួកខ្ញុំព្រះអង្គ ដូចព្រះចន្ទក្នុងពួកផ្កាយ ដូច្នេះ ។

ឥន្ទកទេវបុត្តទូលថា

ពូជដែលបុគ្គលព្រោះហើយ សូម្បីមានប្រមាណច្រើន ក្នុង
ស្រែទួល ផលរមែងមិនបរិបូណ៌ ទាំងមិនញុំាងអ្នកស្រែឲ្យ
ត្រេកអរបាន ដូចម្ដេចមិញ ទានដែលបុគ្គលតម្កល់ទុកហើយ
មានប្រមាណច្រើន ក្នុងបុគ្គលទ្រុស្តសីលទាំងឡាយ ផល
រមែងមិនបរិបូណ៌ទាំងមិនបានញុំាងទាយកឲ្យត្រេកអរបាន ក៏
ដូច្នោះឯង ។ ពូជដែលបុគ្គលព្រោះហើយសូម្បីតិច ក្នុងស្រែ
ដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញុំាងអ្នកស្រែឲ្យត្រេក
អរបាន ដូចម្ដេចមិញ សក្ការៈដែលបុគ្គលធ្វើហើយ សូម្បី
តិចតួចក្នុងតាទិបុគ្គលទាំងឡាយ មានសីល មានគុណបុណ្យ
រមែងមានផលច្រើន ក៏ដូច្នោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តាវតឹសេ** បានដល់ ក្នុងស្ថានតាវត្តិង្សមាន
វាចាប្រកបសេចក្ដីថា បទថា **សិលាយំ បណ្ឌុកម្ពលេ** សេចក្ដីថា ក្នុងគ្រា
ដែលព្រះពុទ្ធជាឧត្តមបុរស គង់ត្រង់បណ្ឌុកម្ពលសិលាអាសនៈ ។

បទថា **ទសសុ លោកធាតូសុ សន្និបតិត្វាន ទេវតា** សេចក្ដីថា
កាមាវចរទេវតានិងព្រហ្មទេវតាក្នុងម៉ឺនចក្កវាឡដែលហៅថាជាតិខេត្ត បាននាំ

គ្នាមកប្រជុំដើម្បីគាល់ព្រះមានព្រះភាគ និងដើម្បីស្តាប់ធម៌ ដោយហេតុនោះ ទើបលោកពោលថា **បយិរុទាសន្តិ សម្ពុទ្ធំ វសន្តំ ឩគមុទ្ធនិ** ដូច្នេះ អធិប្បាយថា លើកំពូលភ្នំសិនេរុ ។

បទថា **យោជនានិ ឩស ទ្វេ ច អត្ថុរោយំ តទា អហុ** សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តា អង្កុរទេវបុត្ត មានចរិតតាមដែលពោលហើយនោះ បាននៅក្នុងទីឆ្ងាយ ១២ យោជន៍ អធិប្បាយថា បានអង្គុយក្នុងទីចម្ងាយ ១២ យោជន៍អំពីព្រះសាស្តា ។

បទថា **ចោធិតោ ភាវិតត្តេន** សេចក្តីថា ព្រះសម្មាសម្ពុទ្ធទ្រង់មានខ្លួនអប់រំហើយ ដោយអរិយមគ្គភាវនា ដែលទ្រង់អប់រំដ៏លើសលុបជាស់តឿនហើយ ។ គាថាជាដើមថា ប្រយោជន៍អ្វីដោយទាននោះរបស់ខ្ញុំព្រះអង្គ ដូច្នេះ ជាគាថាដែលអង្កុរទេវបុត្តទូលដល់ព្រះសាស្តា ដោយជាពាក្យឆ្លើយ ។ បទថា **ឩក្ខិណេយ្យេន សុញ្ញតំ** សេចក្តីថា ព្រោះក្នុងកាលនោះ ទានរបស់ខ្ញុំព្រះអង្គ សោះសូន្យទទេ គឺវៀរចាកទក្ខិណេយ្យបុគ្គល ហេតុនោះទើបអង្កុរទេវបុត្ត ពោលមើលងាយបុណ្យនិងទានរបស់ខ្លួនថា ប្រយោជន៍អ្វីដោយទាននោះរបស់ខ្ញុំព្រះអង្គ ដូច្នេះ ។

បទថា **យក្ខោ** បានដល់ ទេវបុត្ត ។ បទថា **ឩជ្ជា** សេចក្តីថា ឲ្យហើយ ។ បទថា **អតិរោចតិ អម្ហេហិ** សេចក្តីថា រមែងរុងរឿងក្រៃលែងជាងបុគ្គលដូចខ្លួន ។ ម្យ៉ាងទៀត សព្ទថា **ហិ** ត្រឹមតែជានិបាត អធិប្បាយថា រមែងរុងរឿង គឺគ្របសង្កត់ខ្ញុំ ដើម្បីចៀសវាងពាក្យសួរថា ដូចអ្វី ទើប

*អង្កុរទេវបុត្តពោលថា ដូចជាព្រះចន្ទ្រក្នុងពួកផ្កាយ ។*

*បទថា* **ឧជ្ជង្គលេ** *បានដល់ ក្នុងភូមិភាគដែលរីងក្រៃពេក ។ អាចារ្យពួកខ្លះពោលថា ក្នុងភូមិភាគដែលខ្ពស់ ។ បទថា* **រោបិតំ** *ប្រែថា ដែលគេសាបព្រោះហើយ គឺសាបព្រោះ ឬដកហើយស្ទូងវិញ ។ បទថា* **ផលំ តោសេតិ** *សេចក្តីថា រមែងមិនជាទីត្រេកអរ ឬមិនញ៉ាំងសេចក្តីត្រេកអរឲ្យកើតព្រោះមានផលតិច ។ បទថា* **តថេវ** *សេចក្តីថា ពូជជាច្រើនដែលគេព្រោះក្នុងស្រែទួល រមែងមិនឲ្យផលបរិបូណ៌ គឺមិនមានផលច្រើន ទាំងមិនញ៉ាំងអ្នកស្រែឲ្យត្រេកអរ យ៉ាងណា ទានជាច្រើនក៏ដូច្នោះ បុគ្គលតាំងទុកក្នុងបុគ្គលទ្រុស្តសីល គឺវៀរចាកសីល រមែងមិនមានផលបរិបូណ៌ គឺមិនមានផលច្រើន ទាំងមិនធ្វើឲ្យទាយកត្រេកអរ ។*

*ពីរគាថាថា* **យថាបិ ភទ្ទកេ** *ជាដើម គប្បីជ្រាបអត្ថយោជនា ដោយបរិយាយផ្ទុយគ្នាតាមដែលពោលហើយ ។ ក្នុងបទទាំងនោះ បទថា* **សម្មាធារំ បវេច្ឆន្តេ** *សេចក្តីថា កាលភ្លៀងបង្អុរស្មើ គឺភ្លៀងធ្លាក់រៀងរាល់កន្លះខែ ១០ ថ្ងៃ ឬ ៥ ថ្ងៃម្តង ។ បទថា* **គុណវន្តេសុ** *បានដល់ ក្នុងបុគ្គលដែលប្រកបដោយគុណ មានឈានជាដើម ។ បទថា* **តាទិសុ** *បានដល់ ដែលប្រកបដោយលក្ខណៈនៃបុគ្គលដែលមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា* **ការំ** *លោកពោលដោយលិង្គវិបល្លាស អធិប្បាយថា ឧបការៈ ។ ដើម្បីចៀសវាងពាក្យសួរថា ឧបការៈ គឺអ្វី ទើបឥន្ទកទេវបុត្តពោលថា គឺបុណ្យ ។*

*ព្រះសង្គីតិកាចារ្យបានតាំងគាថានេះថា*

ទានដែលបុគ្គលឲ្យហើយដល់បុគ្គលណា រមែងមានផលច្រើន
បុគ្គលគួរពិចារណាហើយសឹមឲ្យទាន ទាយកទាំងឡាយ ពិ-
ចារណាហើយឲ្យនូវទាន តែងទៅកាន់ឋានសួគ៌

ទានដែលបុគ្គលពិចារណាហើយទើបឲ្យ ព្រះសុគតទ្រង់
សរសើរហើយ ទក្ខិណេយ្យបុគ្គលណា ដែលមាននៅ
ក្នុង ជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ទក្ខិ-
ណេយ្យបុគ្គលទាំងនោះ រមែងមានផលច្រើន ដូចពូជ
ដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិចេយ្យ** បានដល់ គប្បីជ្រើសរើសហើយ គឺគប្បីពិចារណាដល់បុញ្ញក្ខេត្តដោយបញ្ញា ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ហើយ ។

រឿងអង្កុរប្រេតនេះ ព្រះសាស្ដាទ្រង់លើកឡើងសម្ដែងដោយព្រះអង្គឯង ដោយន័យជាដើមថា **មហាទានំ តយា ទិន្នំ** មហាទានដែលអ្នកបានឲ្យហើយ ដូច្នេះ ដើម្បីទ្រង់ប្រកាសភាពបរិបូណ៌នៃទក្ខិណេយ្យបុគ្គលខាងមុខ ដល់ទេវតាក្នុងម៉ឺនចក្កវាឡក្នុងស្ថានតាវត្តិង្ស ទ្រង់សម្ដែងអភិធម្មក្នុងស្ថានតាវត្តិង្សនោះអស់ ៣ ខែ ។ ក្នុងថ្ងៃមហាបវារណា ទ្រង់ចោមរោមដោយពួកទេវតា ទ្រង់ជាទេវតាក្រៃលែងជាងទេវតា យាងចុះអំពីទេវលោក កាន់សង្កស្សនគរ យាងដល់ក្រុងសាវត្ថីដោយលំដាប់ គង់នៅក្នុងវត្តជេតពនមហាវិហារ ដើម្បីប្រកាសភាពបរិបូណ៌នៃទក្ខិណេយ្យបុគ្គល ក្នុងកណ្ដាល

បរិស័ទ ៤ ទើបទ្រង់សម្ដែងដោយពិស្ដារ ដោយន័យជាដើមថា **យស្ស អត្ថាយ គច្ឆាម** យើងទាំងឡាយជាអ្នកស្វែងរកទ្រព្យ (ទៅកាន់ដែនកម្ពុជៈ) ព្រោះហេតុនៃទ្រព្យណា ទើបកាន់យកកំពូលទេសនា គឺចតុសច្ចកថា ។ ក្នុងកាលចប់ទេសនា សត្វច្រើនពាន់កោដិត្រាស់ដឹងធម៌ហើយ ។

## អដ្ឋកថា អង្កុរប្រេតចប់

# រឿង ឆាដឧត្តរមាតុប្រេត ទី ១០

[ ២២ ] ស្រីប្រេតដែលមានសម្បុរអាក្រក់ ឃើញគួរខ្លាច បានចូលទៅរកភិក្ខុនោះ ដែលកំពុងសម្រាកនៅក្នុងវេលាថ្ងៃ អង្គុយនៅទៀបឆ្នេរទន្លេគង្គា សក់ទាំងឡាយនៃស្រីប្រេតនោះវែងសំយុងចុះ ដរាបដល់ដី ស្រីប្រេតនោះ បិទបាំងខ្លួនប្រាណដោយសក់ទាំងឡាយ ហើយនិយាយទៅនឹងសមណដូច្នេះថា ចាប់ដើមតាំងអំពីខ្ញុំធ្វើមរណកាលមកបាន ៥៥ ឆ្នាំហើយ មិនដែលបានបរិភោគ ឬក្រេបផឹកនូវទឹកឡើយ បពិត្រលោកដ៏ចម្រើន សូមលោកឲ្យនូវទឹកដល់ខ្ញុំ ដើម្បីបានក្រេបផឹក ព្រោះសេចក្តីស្រេក ។

( ព្រះកង្ខារេវត្តត្ថេរតបថា ) ទន្លេគង្គានេះ មានទឹកត្រជាក់ហូរមកពីភ្នំហិមវន្ត នាងចូរកាន់យកនូវទឹកអំពីទន្លេគង្គានេះ ហើយក្រេបផឹកចុះ ហេតុអ្វីបានជានាងសូមទឹកនឹងយើងដូច្នេះ ។

បពិត្រលោកដ៏ចម្រើន បើខ្ញុំកាន់យកទឹក អំពីទន្លេគង្គាដោយខ្លួនឯង ទឹកនោះក៏ប្រែទៅជាឈាមដល់ខ្ញុំវិញ ព្រោះហេតុនោះ បានជាខ្ញុំសូមទឹកអំពីលោកម្ចាស់វិញ ។

ចុះអំពើអាក្រក់ ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត ដូចម្តេចខ្លះ បានជាទឹកទន្លេគង្គា ប្រែទៅជាឈាមដល់នាង ព្រោះវិបាកនៃកម្មដូចម្តេច ។

បុត្តរបស់ខ្ញុំឈ្មោះឧត្តរៈ ជាឧបាសកអ្នកមានសទ្ធា កាលខ្ញុំមិនប្រាថ្នា ( នឹងឲ្យទាន ) បុត្តរបស់ខ្ញុំនោះឲ្យនូវចីវរ បិណ្ឌបាត គិលានប្បច្ច័យនិងសេនាសនប្បច្ច័យដល់សមណៈទាំងឡាយ ។ ខ្ញុំនោះត្រូវសេចក្តីកំណាញ់

បៀតបៀន ក៏ជេរប្រទេចកូននោះថា កាលអញមិនប្រាថ្នានឹងឲ្យ ឯងបានឲ្យនូវចីវរ បិណ្ឌបាត គិលានប្បច្ច័យនិងសេនាសនប្បច្ច័យណាដល់សមណៈទាំងឡាយ ។ ម្នាលឧត្តរៈ បច្ច័យមានចីវរជាដើមនុ៎ះ ចូរកើតទៅជាឈាមដល់អ្នកឯងក្នុងបរលោកចុះ ព្រោះវិបាកនៃកម្មនោះ បានជាទឹកក្នុងទន្លេគង្គាក្លាយទៅជាឈាមដល់ខ្ញុំ ។

## ចប់ រឿងនាងឧត្តរមាតុប្រេតទី ១០ ។

# អដ្ឋកថា ឧត្តរមាតុប្រេត

[ ២២ ] រឿងរបស់ស្រីប្រេតដែលជាមាតារបស់ឧត្តរមាណពនេះ មានពាក្យផ្តើមថា **ទិវាវិហារគតំ ភិក្ខុំ** ដូច្នេះជាដើម ។ ក្នុងរឿងនោះ មានការបរិយាយសេចក្តីដូចតទៅនេះថា

កាលព្រះសាស្តាបរិនិព្វានហើយ កាលបឋមមហាសង្គីតិ ប្រព្រឹត្តទៅហើយ ព្រះមហាកច្ចាយនៈ មួយអន្លើដោយភិក្ខុ ១២ រូប នៅក្នុងដងព្រៃមួយកន្លែងមិនឆ្ងាយអំពីក្រុងកោសម្ពី សម័យនោះ អាមាត្យម្នាក់របស់ព្រះបាទឧទេន ធ្វើកាលកិរិយាហើយ ។ ក្នុងកាលមុន អាមាត្យនោះជាអ្នកចាត់ចែងការងារក្នុងព្រះនគរ ។ លំដាប់នោះ ទើបព្រះរាជាត្រាស់ឲ្យហៅឧត្តរមាណពដែលជាកូននៃអាមាត្យនោះ មកហើយទ្រង់ស្ថាបនាក្នុងតំណែងដែលបិតាតាំងនៅថា អ្នកចូរទទួលការងារដែលបិតារបស់អ្នកធ្លាប់ធ្វើ ។

ឧត្តរមាណពនោះ ទទួលព្រះតម្រាស់ហើយ ថ្ងៃមួយ បាននាំមេជាងទៅព្រៃដើម្បីរកឈើជួសជុលព្រះនគរ ទើបចូលទៅកាន់លំនៅ របស់ព្រះមហាកច្ចាយនៈ ក្នុងទីនោះ ឃើញព្រះថេរៈទ្រទ្រង់នូវសំពត់បង្សុកូលចីវរ នៅអង្គុយស្ងប់ស្ងាត់ក្នុងទីនោះ ទើបជ្រះថ្លាក្នុងឥរិយាបថ បានធ្វើបដិសណ្ឋារៈហើយអង្គុយក្នុងទីសមគួរទៅចំណែកម្ខាង ព្រះថេរៈសម្ដែងធម៌ ដល់អាមាត្យនោះ ។ អាមាត្យនោះស្ដាប់ធម៌ហើយ កើតសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ ទើបតាំងនៅក្នុងសរណៈ ហើយនិមន្តព្រះថេរៈដោយពាក្យថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ មួយអន្លើដោយភិក្ខុទាំងឡាយ ទទួលភត្តក្នុងថ្ងៃស្អែកដោយសេចក្ដីអនុគ្រោះដល់ខ្ញុំចុះ ។ ព្រះថេរៈទទួលនិមន្តន៍ដោយតុណ្ហីភាព អាមាត្យនោះត្រឡប់អំពីទីនោះ ហើយចូលទៅកាន់ព្រះនគរ ប្រាប់ដល់ឧបាសកដទៃថា ខ្ញុំបាននិមន្តព្រះថេរៈដើម្បីឆាន់ក្នុងថ្ងៃស្អែក អ្នកទាំងឡាយគប្បីមកកាន់រោងទានរបស់ខ្ញុំ ។

ក្នុងថ្ងៃទី ២ ពេលព្រឹក ឧត្តរអាមាត្យរៀបចំខាទនីយនិងភោជនីយាហារដ៏ប្រណីត ហើយប្រាប់ភត្តកាល ធ្វើនូវការទទួលព្រះថេរៈមួយអន្លើដោយភិក្ខុទាំងឡាយ ថ្វាយបង្គំហើយ បែរមុខចូលទៅកាន់ផ្ទះ លំដាប់នោះ កាលព្រះថេរៈនិងភិក្ខុទាំងឡាយ អង្គុយលើអាសនៈដែលក្រាលដោយកម្រាលជាកប្បិយៈមានតម្លៃច្រើន ធ្វើការបូជាដោយគ្រឿងក្រអូប ផ្កានិងធូមគន្ធៈឲ្យព្រះថេរៈនិងភិក្ខុទាំងនោះ ឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកប្រណីត កើតនូវការជ្រះថ្លាធ្វើអញ្ជលី ស្ដាប់អនុមោទនា ។ កាលព្រះថេរៈធ្វើអនុមោទនាភត្ត

ស្រេចហើយ ក៏កាន់បាត្រតាមជូនដំណើរចេញពីព្រះនគរ កាលនឹងត្រឡប់ក៏និមន្តថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ ចូលកាន់ផ្ទះរបស់ខ្ញុំជានិច្ចចុះ ដឹងថាព្រះថេរៈទទួលហើយទើបត្រឡប់ ។ ឧត្តរឧបដ្ឋាកព្រះថេរៈយ៉ាងនេះ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ សម្រេចសោតាបត្តិផលហើយបានសាងវិហារប្រគេន និងធ្វើឲ្យញាតិរបស់ខ្លួនជ្រះថ្លាក្នុងព្រះសាសនា ។

ឯមាតារបស់ឧត្តរៈ ត្រូវមន្ទិល គឺសេចក្តីកំណាញ់គ្របសង្កត់ បានបរិភាសយ៉ាងនេះថា កាលអញមិនប្រាថ្នានឹងឲ្យ ឯងឲ្យវត្ថុអ្វីដល់ពួកសមណៈ វត្ថុនោះចូរសម្រេចជាឈាមដល់ឯងក្នុងបរលោក ។ តែមាតានោះអនុញ្ញាតរោមកន្ទុយក្ងោកមួយក្នុងថ្ងៃធ្វើវិហារ ។ នាងធ្វើកាលកិរិយាហើយ កើតក្នុងកំណើតប្រេត តែព្រោះនាងអនុមោទនាទានដោយរោមកន្ទុយក្ងោក ទើបមានសក់ខ្មៅល្អ សរសៃល្អិត វែង មានចុងងរឡើង ។ ក្នុងពេលដែលនាងចុះផឹកទឹកក្នុងស្ទឹងគង្គា ដោយគិតថា នឹងផឹកទឹក ទឹកនោះក៏ក្លាយទៅជាឈាម ប្រេតនោះត្រូវសេចក្តីឃ្លានគ្របសង្កត់ ត្រាច់ទៅអស់ ៥៥ ឆ្នាំ ថ្ងៃមួយ បានឃើញព្រះកង្ខារេវតត្ថេរអង្គុយសម្រាកពេលថ្ងៃ ត្រង់មាត់ស្ទឹងគង្គា ទើបយកសក់របស់ខ្លួនបិទបាំងរាងកាយ ចូលទៅរកទឹកផឹក ទើបលោកពោលទុកថា

ស្រីប្រេតដែលមានសម្បុរអាក្រក់ ឃើញគួរខ្លាច បានចូលទៅរកភិក្ខុនោះដែលកំពុងសម្រាកនៅក្នុងវេលាថ្ងៃ អង្គុយនៅទៀបឆ្នេរទន្លេគង្គា សក់ទាំងឡាយនៃស្រីប្រេតនោះវែងសំយុងចុះដរាបដល់ដី ស្រីប្រេតនោះ បិទបាំងខ្លួនប្រាណដោយសក់

ទាំងឡាយ ហើយនិយាយទៅនឹងសមណ ដូច្នេះថា ។

គាថា ២ នេះ ព្រះសង្គីតិកាចារ្យបានរចនាទុកខាងដើមក្នុងទីនេះ ។

បណ្តាបទទាំងនោះ បទថា **ភីរុទស្សនា** បានដល់ ឃើញគួរខ្លាច ។ បាលីថា **រុទ្ទទស្សនា** ដូច្នេះក៏មាន អធិប្បាយថា ឃើញគួរខ្លាច ។ បទថា **យាវភូមាវលម្ពរេ** បានដល់ មានសក់សំយុងចុះមកអូសដី ។ កាលមុន ពោលថា ភិក្ខុ កាលក្រោយពោលថា សមណៈ សំដៅដល់ព្រះកង្ខារេវ-តត្ថេរ នោះឯង ។

ស្រីប្រេតនោះ ចូលទៅរកព្រះថេរៈហើយ កាលនឹងសូមទឹកផឹក ទើបពោលគាថានេះថា

ចាប់ដើមតាំងអំពីខ្ញុំ ធ្វើមរណកាលមកបាន ៥៥ ឆ្នាំហើយ
មិនដែលបានបរិភោគ ឬក្រេបផឹកនូវទឹកឡើយ បពិត្រលោក
ដ៏ចម្រើន សូមលោកឲ្យនូវទឹកដល់ខ្ញុំដើម្បីបានក្រេបផឹកព្រោះ
សេចក្តីស្រេក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ណាភិជានាមិ ភុត្តំ វា** សេចក្តីថា ខ្ញុំមិនបានបរិភោគបាយ ឬផឹកទឹកឡើយ អស់កាលយូរយ៉ាងនេះ គឺមិនបានបរិភោគ និងមិនបានផឹក ។ បទថា **តសិតា** ប្រែថា ស្រេក ។ មានវាចាប្រកបសេចក្តីថា បទថា **ទានីយាយ** សេចក្តីថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យទឹកដល់ខ្ញុំដែលត្រាច់ទៅដើម្បីទឹក ។

ខាងមុខអំពីនេះ គប្បីជ្រាបគាថាដែលពោលដោយពាក្យសួរ និងពាក្យ

ឆ្លើយរបស់ព្រះថេរៈ និងស្រីប្រេតដូចតទៅនេះថា

ព្រះថេរៈពោលថា

ទន្លេគង្គានេះ មានទឹកត្រជាក់ហូរមកពីភ្នំហិមវន្ត នាងចូរកាន់យកនូវទឹកអំពីទន្លេគង្គានេះ ហើយក្រេបផឹកចុះ ហេតុអ្វីបានជានាងសូមទឹកនឹងយើង ដូច្នេះ ។

ស្រីប្រេតឆ្លើយថា

បពិត្រលោកដ៏ចម្រើន បើខ្ញុំកាន់យកទឹក អំពីទន្លេគង្គាដោយខ្លួនឯង ទឹកនោះក៏ប្រែទៅជាឈាមដល់ខ្ញុំវិញ ព្រោះហេតុនោះបានជាខ្ញុំសូមទឹកអំពីលោកម្ចាស់វិញ ដូច្នេះ ។

ព្រះថេរៈសួរថា

ចុះអំពើអាក្រក់ដែលនាងបានធ្វើហើយ ដោយកាយ វាចា ចិត្តដូចម្តេចខ្លះ បានជាទឹកទន្លេគង្គា ប្រែទៅជាឈាមដល់នាង ព្រោះវិបាកនៃកម្មដូចម្តេច ដូច្នេះ ។

ប្រេតឆ្លើយថា

បុត្តរបស់ខ្ញុំឈ្មោះឧត្តរៈ ជាឧបាសកអ្នកមានសទ្ធា កាលខ្ញុំមិនប្រាថ្នា ( នឹងឲ្យទាន ) បុត្តរបស់ខ្ញុំនោះឲ្យនូវចីវរ បិណ្ឌបាត គិលានបច្ច័យ និងសេនាសនបច្ច័យ ដល់សមណៈទាំង-ឡាយ ។ ខ្ញុំនោះត្រូវសេចក្តីកំណាញ់បៀតបៀនក៏ជេរប្រទេចកូននោះថា កាលអញមិនប្រាថ្នានឹងឲ្យ ឯងបានឲ្យនូវចីវរ

បិណ្ឌបាត គិលានប្បច្ច័យនិងសេនាសនប្បច្ច័យណា ដល់សមណៈទាំងឡាយ ។ ម្នាលឧត្តរៈ បច្ច័យមានចីវរជាដើមនុ៎ះ ចូរកើតទៅជាឈាមដល់អ្នកឯងក្នុងបរលោកចុះ ព្រោះវិបាកនៃកម្មនោះ បានជាទឹកក្នុងទន្លេគង្គាក្លាយទៅជាឈាម ដល់ខ្ញុំដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិមវន្តតោ** បានដល់ ហូរអំពីភ្នំឈ្មោះហិមពាន្ត ព្រោះមានសន្សើមច្រើន ។ បទថា **សន្ទតិ** ប្រែថា ហូរទៅ ។ បទថា **ឯតោ** បានដល់ ចាកស្ទឹងគង្គានេះ ។ ដោយបទថា **កឹ** លោកសម្តែងថា នាងសូមទឹកផឹកជាមួយអាត្មាធ្វើអ្វី ចូរនាងចុះកាន់ស្ទឹង គង្គាផឹកតាមសប្បាយចុះ ។ បទថា **លោហិតំ មេ បរិវត្តតិ** សេចក្តីថា ទឹកកាលហូរទៅរមែងក្លាយ គឺប្រែជាឈាម ព្រោះផលនៃកម្មអាក្រក់របស់ខ្ញុំ ទឹកកាល ខ្ញុំក្បង់ឡើង ក៏ក្លាយជាឈាម ។

បទថា **មយ្ហំ អកាមាយ** បានដល់ កាលខ្ញុំមិនប្រាថ្នា ។ បទថា **បវេច្ឆតិ** ប្រែថា រមែងឲ្យ ។ បទថា **បច្ចយំ** បានដល់ គិលានប្បច្ច័យ ។ មានវាចាប្រកបសេចក្តីថា បទថា **ឯតំ** ជាដើម សេចក្តីថា ដោយវិបាកនៃកម្មអាក្រក់ដែលខ្ញុំធ្វើទុក ដោយអំណាចការផ្តាសាថា ម្នាលឧត្តរៈ បច្ច័យមានចីវរជាដើមនុ៎ះ ចូរកើតទៅជាឈាមដល់អ្នកឯងក្នុងបរលោកចុះ ដូច្នេះ ។

លំដាប់នោះ ព្រះរេវតៈបានប្រគេនទឹកដល់ភិក្ខុសង្ឃ ឧទ្ទិសដល់ស្រីប្រេតនោះ ត្រាច់ទៅបិណ្ឌបាត ទទួលភត្តហើយ បានប្រគេនដល់ភិក្ខុទាំងឡាយ

កាន់យកសំពត់បង្សុកូលអំពីគំនរសំរាមជាដើម បោកហើយធ្វើជាពូកនិងខ្នើយ ប្រគេនដល់ភិក្ខុទាំងឡាយ ដោយហេតុនោះ ស្រីប្រេតនោះ ក៏បាននូវទិព្វសម្បត្តិ ។ ស្រីប្រេតទៅកាន់សម្នាក់របស់ព្រះថេរៈ បង្ហាញទិព្វសម្បត្តិដែលខ្លួនបាន ដល់ព្រះថេរៈ ។ ព្រះថេរៈប្រកាសប្រវត្តិនោះដល់បរិស័ទ ៤ ដែលមកកាន់សម្នាក់របស់លោក ហើយសម្តែងធម្មកថា ដោយហេតុនោះ ទើបមហាជនកើតនូវសេចក្តីសង្វេគ ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ដែលជាមន្ទិល ត្រេកអរក្រៃលែងក្នុងកុសលធម៌ មានទាននិងសីលជាដើម ។ បេតវត្ថុនេះ គប្បីឃើញថា លោកលើកឡើងកាន់សង្គាយនា ក្នុងទុតិយសង្គីតិ ។

អដ្ឋកថា ឧត្តរមាតុប្រេតចប់

# រឿង សុត្តប្រេត ទី១១

[ ២៣ ] ( ស្រីដែលនៅជាមួយនឹងវិមានប្រេតមានសេចក្តីអផ្សុកបាន ពោលថា ) ក្នុងកាលមុន បព្វជិតភិក្ខុ គឺព្រះបច្ចេកពុទ្ធ បានចូលមកសុំ អំបោះ ខ្ញុំក៏បានប្រគេន ( ឥឡូវនេះ ) ខ្ញុំបានផលនៃការប្រគេនអំបោះនោះ ជាផលចម្រើនលើសលុប ទាំងសំពត់ច្រើនកោដិ ក៏កើតឡើងដល់ខ្ញុំ ។ ខ្ញុំ នោះបានប្រើប្រាស់នូវវិមានជាទីត្រេកអរ ដ៏ដេរដាសដោយផ្កា វិចិត្រដោយ កែវច្រើនយ៉ាងដែលជនប្រុសស្រីសេពហើយផង បានស្លៀកដណ្តប់ ( សំពត់ តាមចំណង់ ) ផង ទាំងទ្រព្យដ៏ច្រើន ក៏មិនចេះអស់ផង ។ ខ្ញុំបានសេចក្តី សុខនិងសេចក្តីស្រួលក្នុងវិមាននេះព្រោះអាស្រ័យផលនៃកម្មនោះឯង ខ្ញុំនោះ នឹងទៅកាន់មនុស្សលោកវិញហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្ត សូមអ្នកនាំខ្ញុំទៅ ( ឯមនុស្សលោកចុះ ) ។

( វិមានប្រេតនិយាយថា ) នាងមកក្នុងវិមាននេះបាន ៧០០ ឆ្នាំហើយ ( បើនាងទៅអំពីទីនេះវិញទៅនៅ ) ក្នុងមនុស្សលោកនោះនឹងគ្រាំគ្រាចាស់ ពួកញាតិរបស់នាងទាំងអស់ស្លាប់អស់ហើយ ( ព្រោះហេតុនោះ ) នាងនឹង ទៅអំពីទេវលោកនេះធ្វើអ្វីក្នុងមនុស្សលោកនោះ ។

( ស្រីនោះនិយាយថា ) ខ្ញុំបានមកក្នុងវិមាននេះ ជាស្រីបរិបូណ៌ដោយ វត្ថុទិព្វនិងសេចក្តីសុខអស់ត្រឹម ៧ ឆ្នាំ ខ្ញុំនោះនឹងទៅកាន់មនុស្សលោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្ត សូមអ្នកនាំខ្ញុំទៅចុះ ។

វិមានប្រេតនោះ ក៏កាំហែងចាប់ស្រីនោះត្រង់ដើមដៃនាំមក ( កាន់ស្រុក ផៅពង្ស ) វិញ ហើយនិយាយនឹងស្រីចាស់មានកម្លាំងទន់ខ្សោយនោះថា នាង

ត្រូវប្រាប់ដល់ជនដទៃទៀត ដែលមកក្នុងទីនេះថា អ្នកទាំងឡាយចូរធ្វើបុណ្យទាំងឡាយ អ្នកទាំងឡាយ នឹងបានសេចក្ដីសុខ ។

ស្រីនោះ ឲ្យឱវាទដល់ពួកជនដែលមកកាន់សំណាក់ខ្លួនថា ពួកប្រេតដែលខ្ញុំបានឃើញហើយ ជាអ្នកមានអំពើល្អមិនបានធ្វើ តែងលំបាក យ៉ាងណាមិញ ពួកមនុស្ស ក៏យ៉ាងនោះដែរ ពួកសត្វគឺទេវតានិងមនុស្សដែលបានធ្វើកម្ម មានសេចក្ដីសុខជាកម្រៃហើយ តែងតាំងនៅក្នុងសេចក្ដីសុខ ។

## ចប់ រឿងសុត្តប្រេតទី ១១ ។

# អដ្ឋកថា សុត្តប្រេត

[ ២៣ ] រឿងសុត្តប្រេតនេះ មានពាក្យផ្ដើមថា **អហំ បុរេ បព្វជិតស្ស ភិក្ខុនោ** ដូច្នេះជាដើម ។ រឿងនេះមានអត្ថុប្បត្តិហេតុដូចម្ដេច ។ បានឮថា ក្នុងស្រុកមួយ មិនឆ្ងាយអំពីក្រុងសាវត្ថី មុនពេលព្រះសាស្ដាកើតឡើង ៧០០ ឆ្នាំ មានទារកម្នាក់ ឧបដ្ឋាកព្រះបច្ចេកពុទ្ធមួយអង្គ កាលចម្រើនវ័យហើយ មាតារបស់ទារកនោះ ក៏ទៅសូមកុលធីតាម្នាក់ មកអំពីត្រកូលដែលស្មើគ្នា ដើម្បីជាប្រយោជន៍ដល់បុត្តនោះ ។ ក្នុងថ្ងៃរៀបការនោះឯង កុមារនោះទៅងូតទឹកជាមួយសម្លាញ់ ត្រូវពស់ចឹកស្លាប់ទៅ ។ អាចារ្យពួកខ្លះពោលថា ត្រូវយក្ខចាប់ក៏មាន ។ កុមារនោះធ្វើកុសលកម្មទុកជាច្រើន ដោយការឧបដ្ឋាកព្រះបច្ចេកពុទ្ធ ទើបកើតជាវេមានិកប្រេត ដោយអំណាចខ្លួនមានចិត្តប្រតិព័ទ្ធ

ក្នុងទារិកានោះ តែជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។

លំដាប់នោះ វេមានិកប្រេតនោះ ប្រាថ្នានឹងនាំទារិកានោះមកកាន់វិមានរបស់ខ្លួនគិតថា ដោយឧបាយដូចម្ដេចហ្ន៎ ទើបនាងអភិរម្យក្នុងទីនេះជាមួយអញ ឲ្យជាកម្មដែលត្រូវឲ្យផលក្នុងបច្ចុប្បន្ន ទើបពិចារណាដល់ហេតុដែលឲ្យបានសោយភោគសម្បត្តិ ដែលជាទិព្វនោះ ឃើញព្រះបច្ចេកពុទ្ធកំពុងធ្វើចីវរកម្ម ទើបកាឡាខ្លួនជាមនុស្ស ទៅថ្វាយបង្គំ ហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការអំបោះឬ ព្រះបច្ចេកពុទ្ធឆ្លើយថា អាត្មាធ្វើចីវរកម្ម ឧបាសក ។ វេមានិកប្រេតនោះក៏ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ស្វែងរកអំបោះក្នុងទីឈ្មោះនោះ ដូច្នេះហើយ ក៏ចង្អុលផ្ទះរបស់ទារិកានោះ ។ ព្រះបច្ចេកពុទ្ធបានទៅក្នុងទីនោះ ឈរត្រង់ទ្វារផ្ទះ ។ លំដាប់នោះ ទារិកាឃើញព្រះបច្ចេកពុទ្ធឈរក្នុងទីនោះ មានចិត្តជ្រះថ្លា ដឹងថា លោកម្ចាស់របស់យើងមានសេចក្ដីត្រូវការអំបោះ ទើបប្រគេនអំបោះមួយដុំ ។ លំដាប់នោះ អមនុស្សនោះបានកាឡាខ្លួនជាមនុស្ស បានទៅកាន់ផ្ទះរបស់ទារិកា អង្វរមាតារបស់នាងហើយ នៅជាមួយនាង ២-៣ ថ្ងៃ ដើម្បីអនុគ្រោះមាតារបស់នាង ទើបធ្វើភាជនៈគ្រប់យ៉ាងក្នុងផ្ទះនោះឲ្យពេញដោយប្រាក់និងមាស ហើយសរសេរឈ្មោះទុកលើភាជនៈទាំងអស់នោះ ដោយសេចក្ដីថា នេះជាទ្រព្យដែលទេវតាឲ្យ អ្នកដទៃមិនគួរដណ្ដើមយក ដូច្នេះ ទើបនាំទារិកានោះទៅកាន់វិមានរបស់ខ្លួន ។ មាតារបស់នាងបានទ្រព្យជាច្រើន ឲ្យដល់ពួកញាតិរបស់ខ្លួន មនុស្សចាស់ជរា មនុស្សកំព្រា និងអ្នកដំណើរជាដើម ឯខ្លួនបរិភោគហើយ

កាលជិតធ្វើកាលកិរិយាបានផ្ដាំដល់ញាតិទាំងឡាយថា បើកូនស្រីរបស់ខ្ញុំមក ចូរឲ្យទ្រព្យនេះ ហើយក៏ស្លាប់ទៅ ។

ក្នុងកាលកន្លងទៅ ៧០០ ឆ្នាំ បន្ទាប់អំពីកាលនោះ ព្រះមានព្រះភាគនៃយើង ទ្រង់កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្រដ៏បវរ គង់នៅក្នុងក្រុងសាវត្ថីដោយលំដាប់ កាលស្រីនោះ នៅរួមជាមួយអមនុស្សនោះ ការអផ្សុកក៏កើតឡើង ។ នាងពោលនឹងអមនុស្សនោះថា អយ្យបុត្ត សូមលោកនាំខ្ញុំត្រឡប់ទៅកាន់ផ្ទះវិញ ដូច្នេះហើយ បានពោលគាថានេះថា

ក្នុងកាលមុន បព្វជិតភិក្ខុ គឺព្រះបច្ចេកពុទ្ធ បានចូលមកសុំអំបោះ ខ្ញុំក៏បានប្រគេន ( ឥឡូវនេះ ) ខ្ញុំបានផលនៃការប្រគេនអំបោះនោះ ជាផលចម្រើនលើសលុប ទាំងសំពត់ច្រើនកោដិ ក៏កើតឡើងដល់ខ្ញុំ ។ ខ្ញុំនោះ បានប្រើប្រាស់នូវវិមានជាទីត្រេកអរ ដ៏ដេរដាសដោយផ្កា វិចិត្រដោយកែវច្រើនយ៉ាងដែលជនប្រុសស្រីសេពហើយផង បានស្លៀកដណ្ដប់ ( សំពត់តាមចំណង់ ) ផង ទាំងទ្រព្យដ៏ច្រើន ក៏មិនចេះអស់ផង ។ ខ្ញុំបានសេចក្ដីសុខនិងសេចក្ដីស្រួល ក្នុងវិមាននេះ ព្រោះអាស្រ័យផល នៃកម្មនោះឯង ខ្ញុំនោះនឹងទៅកាន់មនុស្សលោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្ត សូមអ្នកនាំខ្ញុំទៅ ( ឯមនុស្សលោកចុះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បព្វជិតស្ស ភិក្ខុនោ** នេះ លោកពោល

សំដៅដល់ព្រះបច្ចេកពុទ្ធ ពិតហើយ ព្រះបច្ចេកពុទ្ធនោះ កាលពោលដោយបរមត្ថ គួរពោលបានថា ជាបព្វជិត ព្រោះបណ្តេញ គឺកម្ចាត់កម្ចាំងនៃកាមចេញអំពីខន្ធសន្តានរបស់ខ្លួនជាសមុច្ឆេទ និងគួរពោលថា ភិក្ខុ ព្រោះជាអ្នកទម្លាយកិលេស ។ បទថា **សុត្តំ** បានដល់ អំបោះដែលធ្វើអំពីកប្បាស ។ បទថា **ឧបសង្កម្ម** បានដល់ ចូលមកកាន់ផ្ទះរបស់ខ្ញុំ ។ បទថា **យាចិតា** សេចក្តីថា ព្រះបច្ចេកពុទ្ធសូមដោយការត្រាច់ទៅដើម្បីភិក្ខា ពោលគឺប្រកបដោយកាយវិញ្ញត្តិដែលពោលទុក ( ក្នុងអដ្ឋិសេនកជាតក ) យ៉ាងនេះថា ពួកអរិយៈគ្រាន់តែឈរឧទ្ទិស ស្ងៀមៗប៉ុណ្ណោះ នុ៎ះជាការសូមរបស់ពួកអរិយៈដូច្នេះ ។ បទថា **តស្ស** បានដល់ នៃការប្រគេនអំបោះនោះ ។ បទថា **វិ-បាកោ វិបុលផលូបលព្ភតិ** សេចក្តីថា ឥឡូវនេះ បាន គឺសោយផលដ៏បរិបូណ៌ គឺវិបាកដែលតាំងឡើងយ៉ាងធំ ។ បទថា **ពហុកា** បានដល់ មិនមែនតិច ។ បទថា **វត្ថកោដិយោ** បានដល់ កោដិនៃសំពត់ អធិប្បាយថា សំពត់ច្រើនសែនប្រភេទ ។

បទថា **អនេកចិត្តំ** បានដល់ វិចិត្រដោយរូបភាពផ្សេងៗ ឬមានរូបភាពដែលវិចិត្រដោយរតនៈមានកែវមុក្តានិងកែវមណីជាដើមសន្ធឹកសន្ធាប់ ។ បទថា **នរនារិសេវិតំ** បានដល់ ដល់ព្រមទៅដោយទេវបុត្តនិងទេវធីតាដែលជាបរិវារ ។ បទថា **សាហំ ភុញ្ជាមិ** សេចក្តីថា ខ្ញុំនឹងជ្រើសរើស ប្រើប្រាស់វិមាននោះ ។ បទថា **ធារុធាមិ** សេចក្តីថា ខ្ញុំនឹងស្លៀកដណ្តប់សំពត់តាមដែលប្រាថ្នាត្រូវការ បណ្តាសំពត់ច្រើនកោដិ ។ បទថា **បហូតវិត្តា**

សេចក្តីថា វត្ថុសព្វយ៉ាងជាគ្រឿងឧបករណ៍ដល់ទ្រព្យជាទី ត្រេកអរនៃចិត្ត សន្ទឹកសន្ធាប់ គឺមានទ្រព្យច្រើន បានដល់ មានភោគៈច្រើន ។ បទថា **ឆ ច តាវ ខីយតិ** សេចក្តីថា វត្ថុសព្វយ៉ាងដែលជាគ្រឿងត្រេកអរនៃចិត្តនោះរមែង មិនអស់ទៅ គឺមិនដល់នូវការអស់ទៅ បានដល់ មិនដល់នូវការអស់ ។

បទថា **តស្សេវ កម្មស្ស វិបាកមន្វហំ** សេចក្តីថា ខ្ញុំបានទទួលសេចក្តី សុខដែលជាវិបាកនិងសេចក្តីសុខ ពោលគឺការឆ្ងាញ់ដែលគួរប្រាថ្នាដោយភាព ជាហេតុបច្ច័យ អាស្រ័យបុញ្ញកម្ម ដែលសម្រេចដោយការឲ្យអំបោះនោះឯង ក្នុងវិមាននេះ ។ បទថា **គន្ត្វា បុនទេវ មានុសំ** បានដល់ ខ្ញុំត្រឡប់ទៅ កាន់មនុស្សលោកទៀត ។ បទថា **កាហាមិ បុញ្ញានិ** សេចក្តីថា ខ្ញុំធ្វើបុណ្យ ដែលឲ្យសម្រេចសេចក្តីសុខវិសេសដល់ខ្ញុំ ដែលជាហេតុឲ្យខ្ញុំបានសម្បត្តិនេះ ។ បទថា **នយយ្យបុត្ត មំ** សេចក្តីថា បពិត្រអយ្យបុត្ត សូមនាំ គឺសូមនាំខ្ញុំ ត្រឡប់ទៅកាន់មនុស្សលោក ។

អមនុស្សនោះ កាលបានស្តាប់ដូច្នោះហើយ កាលមិនប្រាថ្នានឹងទៅដោយ សេចក្តីអនុគ្រោះ ព្រោះអំណាចដែលខ្លួនមានចិត្តប្រតិព័ទ្ធក្នុងភរិយា ក៏ពោល គាថាថា

> នាងមកក្នុងវិមាននេះ បាន ៧០០ ឆ្នាំហើយ ( បើនាងទៅ
> អំពីទីនេះវិញទៅនៅ ) ក្នុងមនុស្សលោកនោះ នឹងគ្រាំគ្រា
> ចាស់ ពួកញាតិរបស់នាងទាំងអស់ស្លាប់អស់ហើយ ( ព្រោះ
> ហេតុនោះ ) នាងនឹងទៅអំពីទេវលោកនេះធ្វើអ្វី ក្នុងមនុស្ស

លោកនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្ត** នេះជាការសម្តែងលម្អិតដល់ការលុប វិភត្តិ ។ មួយទៀត បទថា **សត្ត** នេះ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថបញ្ចមីវិភត្តិ ។ បទថា **វស្សសតា** ប្រែថា ជាង ១០០ ឆ្នាំ អធិប្បាយថា នាងមកនៅក្នុងទីនេះគឺមកកាន់វិមាននេះ ៧០០ ឆ្នាំ គឺនាងនៅក្នុងទីនេះ ៧០០ ឆ្នាំ ។ បទថា **ជិណ្ណា ច វុឌ្ឍា ច តហឹ ភវិស្សសិ** សេចក្តីថា នាងមានអត្តភាពដែលឧតុនិងអាហារជាទិព្វឧបត្ថម្ភក្នុងវិមាននេះ តាំងនៅដោយអាការក្មេងខ្ចីនោះឯង អស់កាលមានប្រមាណប៉ុណ្ណេះដោយអានុភាពនៃកម្ម ។ មួយទៀត នាងទៅអំពីទេវលោកនេះ នឹងក្លាយជាមនុស្សជរាតាមវ័យ ក្នុងមនុស្សលោកនោះ ព្រោះកម្មអស់ទៅ និងព្រោះអំណាចនៃឧតុ និងអាហាររបស់មនុស្ស ។ ដើម្បីចៀសវាងនូវពាក្យសួរថា នឹងធ្វើដូចម្តេច ទើបប្រេតពោលថា ពួកញាតិរបស់នាងទាំងអស់ស្លាប់អស់ហើយ អធិប្បាយថា ញាតិរបស់នាងទាំងអស់នោះឯង ស្លាប់ទៅអស់ហើយ ព្រោះកាលកន្លងទៅយូរ ដូច្នោះ នាងទៅអំពីទេវលោកនេះ ទៅកាន់មនុស្សលោកនោះ នឹងធ្វើអ្វីក្នុងមនុស្សលោកនោះ អធិប្បាយថា ចូរនាងញុំាងអាយុឲ្យអស់ទៅក្នុងទីនេះ កុំឲ្យសេសសល់ គឺចូរនៅក្នុងទីនេះ ។

ស្រីនោះ កាលអមនុស្សពោលហើយយ៉ាងនេះ កាលមិនស្តាប់ពាក្យនៃអមនុស្សនោះ ទើបពោលគាថាទៀតថា

ខ្ញុំបានមកក្នុងវិមាននេះ ជាស្រីបរិបូណ៌ដោយវត្ថុទិព្វនិងសេច

ក្តីសុខអស់ត្រឹម ៧ ឆ្នាំ ខ្ញុំនោះនឹងទៅកាន់មនុស្សលោកវិញ ហើយធ្វើបុណ្យទាំងឡាយ បពិត្រព្រះអយ្យបុត្ត សូមអ្នកនាំខ្ញុំទៅចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្តេវ វស្សានិ ឥធាគតាយ មេ** សេចក្តីថា បពិត្រអយ្យបុត្ត កាលខ្ញុំនៅក្នុងទីនេះ ប្រហែលជាកន្លងទៅ ៧ ឆ្នាំនោះឯង នាងកំណត់កាលដែលកន្លងទៅដ៏ច្រើនមិនបាន ទើបបានពោលយ៉ាងនោះ ព្រោះអំណាច ដែលខ្លួនដល់ព្រមដោយទិព្វសម្បត្តិ និងសុខសម្បត្តិដល់ទៅ ៧០០ ឆ្នាំ ។

វិមានប្រេតនោះ កាលនាងរំអុកយ៉ាងនេះហើយ ទើបប្រៀនប្រដៅ មានប្រការផ្សេងៗ ហើយពោលថា ឥឡូវនេះ នាងមិននៅក្នុងទីនោះលើស ៧ ថ្ងៃ ទ្រព្យដែលយើងឲ្យម្តាយរបស់នាងកប់ទុកមាន ចូរនាងឲ្យទ្រព្យនោះដល់សមណព្រាហ្មណ៍ ហើយប្រាថ្នាមកកើតក្នុងទីនេះឯង ។ ទើបចាប់ដើមដៃមកដាក់កណ្តាលស្រុក ពោលថា ចូរនាងប្រាប់ជនដទៃ ដែលមកកាន់ទីនេះថា អ្នកទាំងឡាយ ចូរធ្វើបុណ្យតាមកម្លាំងចុះ ដូច្នេះហើយ ក៏ទៅវិញ ដោយហេតុនោះ ទើបលោកពោលថា

វិមានប្រេតនោះ ក៏កំហែងចាប់ស្រីនោះត្រង់ដើមដៃ នាំមក ( កាន់ស្រុកផៅពង្ស ) វិញ ហើយនិយាយនឹងស្រីចាស់មានកម្លាំងទន់ខ្សោយនោះថា នាងត្រូវប្រាប់ដល់ជនដទៃទៀតដែលមកក្នុងទីនេះថា អ្នកទាំងឡាយ ចូរធ្វើបុណ្យទាំងឡាយ អ្នក

ទាំងឡាយ នឹងបានសេចក្តីសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ** បានដល់ វិមានប្រេតនោះ ។ បទថា **តំ** បានដល់ ស្រីនោះ ។ បទថា **គហេត្វាន បសយ្ហ ពាហាយំ** បានដល់ ចាប់ដើមដៃស្រីនោះ ដូចកំហែងនាំទៅ ។ បទថា **បច្ចានយិត្វាន** បានដល់ នាំត្រឡប់មកកាន់ស្រុកដែលនាងកើតចម្រើនធំធាត់ ។ បទថា **ជើរ** បានដល់ ជាមនុស្សចាស់ អធិប្បាយថា មនុស្សចាស់ មនុស្សជរា ។ បទថា **សុទុព្វលំ** បានដល់ មានកម្លាំងតិចបំផុត ព្រោះខ្លួនជរា ព្រោះជរានោះឯង ។ បានឮថា ដំណាលគ្នានឹងការទៅអំពីវិមាននោះឯង នាងក៏ជាមនុស្សចាស់គ្រាំគ្រាជរាទុព្វល ព្រោះមានវ័យកន្លងទៅ ។ បទថា **វជ្ជេសិ** បានដល់ គប្បីពោល ។ ដើម្បីសម្តែងអាការនៃពាក្យដែលគប្បីពោល ទើបលោកពោលពាក្យជាដើមថា **អញ្ញម្បិ ជនំ** ពាក្យនោះ មានអធិប្បាយដូច្នេះថា នែនាង នាងគប្បីធ្វើបុណ្យ សូម្បីមនុស្សដែលមកក្នុងទីនេះ ដើម្បីសួរសុខទុក្ខ នាងក៏គប្បីពោលទូន្មានថា នែអ្នកមានមុខផូរផង់ ចូរអ្នកសម្លឹងមើលសីសៈ និងកំណាត់សំពត់ដែលត្រូវភ្លើងឆេះ ក៏ចូរបំពេញបុណ្យ មានទាននិងសីលជាដើម និងថា កាលធ្វើបុណ្យហើយ អ្នកនឹងបានទទួលសេចក្តីសុខ ដែលជាផលនៃបុណ្យនោះដោយពិតនោះឯង មិនគួរធ្វើសេចក្តីសង្ស័យក្នុងបុណ្យនោះ ។

កាលវេមានិកប្រេតនោះពោលយ៉ាងនេះហើយទើបទៅ ។ ស្រីនោះទៅកាន់លំនៅរបស់ពួកញាតិខ្លួន ឲ្យញាតិទាំងនោះស្គាល់ខ្លួនហើយ ទើបកាន់យកទ្រព្យ ដែលញាតិទាំងនោះប្រគល់ឲ្យ កាលនឹងឲ្យទានដល់សមណៈនិង

ព្រាហ្មណ៍ ទើបបានឲ្យឱវាទដល់ជនដែលមកហើយកាន់សម្នាក់ខ្លួន ដោយគាថា

ស្រីនោះ ឲ្យឱវាទដល់ពួកជន ដែលមកកាន់សំណាក់ខ្លួនថា
ពួកប្រេតដែលខ្ញុំបានឃើញហើយ ជាអ្នកមានអំពើល្អ មិន
បានធ្វើ តែងលំបាក យ៉ាងណាមិញ ពួកមនុស្ស ក៏យ៉ាងនោះ
ដែរ ពួកសត្វគឺទេវតានិងមនុស្សដែលបានធ្វើកម្ម មានសេច
ក្ដីសុខជាកម្រៃហើយ តែងតាំងនៅក្នុងសេចក្ដីសុខ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អកតេន** បានដល់ មិនសាង គឺខ្លួនមិនបានសន្សំទុក ។ បទថា **សាធុនា** បានដល់ មានកុសលកម្ម ។ បទថា **សាធុនា** នេះ ជាតតិយាវិភត្តិ ប្រើក្នុងលក្ខណៈនៃឥត្ថម្ភូត ។ បទថា **វិហាញ្ញន្តិ** បានដល់ ដល់នូវការចង្អៀតចង្អល់ ។ បទថា **សុខវេទនីយំ** បានដល់ បុញ្ញកម្មដែលមានសុខជាវិបាក ។ បទថា **សុខេ ឋិតា** ប្រែថា តាំងនៅក្នុងសេចក្ដីសុខ ។ បាលីថា **សុខេធិតា** ដូច្នេះក៏មាន អធិប្បាយថា ចម្រើនក្រៃលែង គឺផ្សាយទៅដោយសេចក្ដីសុខ ។ ក្នុងសេចក្ដីនេះ មានអធិប្បាយដូច្នេះថា ខ្ញុំឃើញពួកមនុស្សក្ដៅក្រហាយ ព្រោះមិនបានធ្វើកុសលទុក ធ្វើតែអកុសលដល់នូវការចង្អៀតចង្អល់ ដោយការឃ្លាននិងការស្រេកជាដើម សោយទុក្ខយ៉ាងមហន្តដូចពួកប្រេត ។ម្យ៉ាងទៀត ខ្ញុំបានឃើញពួកជនអ្នកធ្វើកម្មដែលជាហេតុឲ្យនូវសេចក្ដីសុខ ដែលទាក់ទងក្នុងទេវតានិងមនុស្ស ដោយកុសលកម្មដែលខ្លួនធ្វើទុកនោះ និងអកុសលកម្មដែលខ្លួនមិនបានធ្វើ តាំងនៅក្នុង

សេចក្ដីសុខ ។ បទថា **សុខេ ឋិតា** នេះ ជាបទពោលសំដៅដល់ខ្លួន ព្រោះហេតុនោះ អ្នកទាំងឡាយកាលវៀរនូវអំពើអាក្រក់ឲ្យឆ្ងាយហើយ ចូរប្រកបខ្វល់ខ្វាយក្នុងការបំពេញបុណ្យ ។

ស្រីនោះ កាលឲ្យឱវាទយ៉ាងនេះ បានបំពេញមហាទាន អស់ ៧ ថ្ងៃ ដើម្បីសមណៈនិងព្រាហ្មណ៍ជាដើម ក្នុងថ្ងៃទី ៧ ស្លាប់ទៅកើតក្នុងស្ថានតាវត្តិង្ស ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់បានធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទើបសម្ដែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ តែបើពោលដោយការប្លែកគ្នា ទ្រង់ប្រកាសដល់ភាពដែលទាន ដែលបំពេញក្នុងព្រះបច្ចេកពុទ្ធជាមានផលច្រើន មានអានិសង្សច្រើន មហាជនបានស្ដាប់ដូច្នោះហើយ ជាអ្នកប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល ត្រេកអរក្រៃលែងក្នុងបុណ្យ មានទានជាដើមដូច្នេះឯង ។

## អដ្ឋកថា សុត្តប្រេតចប់

# រឿង កណ្ណមុណ្ឌប្រេត ទី ១២

[ ២៤ ] ( ព្រះរាជាសួរស្រីប្រេតថា ) ស្រះបោក្ខរណី មានកាំជណ្ដើរជាវិការៈនៃមាស ក្រាលខ្សាច់ជាវិការៈនៃមាស ( ដោយជុំវិញ ) ពួកផ្កាចន្ទុលណីក្នុងស្រះបោក្ខរណីនោះល្អ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ( ស្រះបោក្ខរណីនោះ ) ដេរដាសដោយឈើផ្សេងៗ ផ្សាយទៅដោយក្លិនផ្សេងៗ ដេរដាសដោយឈូកក្រហមផ្សេងៗធូកធ្លាស់ដោយឈូកសផ្សេងៗ ។ ( ស្រះបោក្ខរណីទាំងឡាយនោះ ) ទ្រហឹងអឹងកងដោយហង្សនិងក្រៀល មានសត្វចាក្រពាកស្រែកគ្រលួច កុះករដោយហ្វូងសត្វស្លាបផ្សេងៗប្រកបដោយពួកបក្សី មានសំឡេងផ្សេងៗផង ឈើទាំងឡាយ ទ្រទ្រង់នូវផ្លែផ្សេងៗផង ព្រៃទាំងឡាយ ទ្រទ្រង់នូវកម្រងផ្កាផ្សេងៗផង មានក្លិនក្រអូបជាទីគាប់ចិត្តដែលខ្យល់បក់មកត្រូវ ក៏ផ្សាយទៅ ។ នគរ ( របស់នាង ) នេះ ប្រាកដយ៉ាងណា នគរប្រាកដយ៉ាងនេះ មិនមានក្នុងពួកមនុស្សទេ ទាំងប្រាសាទរបស់នាង ក៏ច្រើនសុទ្ធសឹងតែមាសនិងប្រាក់ រុងរឿង ញុំាងទិសទាំង ៤ ឲ្យភ្លឺជុំវិញ ។ ទាសី ៥០០ ណា ជាស្រីបម្រើរបស់នាង ពួកទាសីទាំងនោះ ក៏ទ្រទ្រង់នូវស័ង្ខនិងកងកនិងកន្ទ្រុំ ស្អិតស្អាងដោយសំពត់មាស ។ បល្ល័ង្ករបស់នាងដ៏ច្រើន សុទ្ធសឹងតែមាសនិងប្រាក់ ក្រាលកម្រាលស្បែកឈ្មុសដែលបុញ្ញកម្មតាក់តែងហើយ ក្រាលសំពត់គោណកៈ ជាទីចូលទៅនៅអាស្រ័យរបស់នាង អ្នកសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ លុះដល់ពាក់កណ្ដាលអធ្រាត្រ នាងតែងក្រោកអំពីបល្ល័ង្កនោះ ទៅកាន់ឱទ្យានភូមិ ដើរជុំវិញស្រះបោក្ខរណី ។

*( ម្នាលនាងដ៏ចម្រើននាងទៅ ) ឈរក្បែរឆ្នេរស្រះបោក្ខរណីនោះ ជាទីមានស្មៅជុះខៀវខ្ចីដ៏ស្អាត លំដាប់នោះ ស្រាប់តែមានឆ្កែកំបុតត្រចៀក មកខាំអវយវៈតូចធំរបស់នាង ។ នាងក្នុងកាលដែលឆ្កែខាំស៊ីធ្វើឲ្យនៅសល់តែរាងឆ្អឹងហើយ នាងចុះទៅកាន់ស្រះបោក្ខរណី កាយ ( របស់នាង ) ក៏តាំងនៅដូចក្នុងកាលមុន ។ លំដាប់នោះ នាងមានអវយវៈតូចធំពេញលេញ ល្អល្អះ គួរឲ្យរមិលមើល ស្លៀកដណ្តប់សំពត់ហើយមកកាន់សំណាក់នៃអញ ។ អំពើអាក្រក់ដូចម្តេច ដែលនាងបានធ្វើដោយកាយ វាចា ចិត្ត ដោយផលនៃកម្មដូចម្តេច បានជាឆ្កែកំបុតត្រចៀកខាំស៊ីនូវអវយវៈតូចធំ ។*

*( ស្រីប្រេតនោះក្រាបទូលថា ) ក្នុងនគរកិម្ពិលា មានគហបតីជាឧបាសកអ្នកមានសទ្ធា ខ្ញុំជាប្រពន្ធរបស់គាត់ ជាស្រីទ្រុស្តសីល បានប្រព្រឹត្តកន្លងចិត្តប្តី ។ កាលខ្ញុំប្រព្រឹត្តកន្លងចិត្តប្តីយ៉ាងនេះហើយ ប្តីបាននិយាយយ៉ាងនេះថា អំពើនេះមិនប្រពៃ មិនសមគួរទេ ព្រោះនាងប្រព្រឹត្តកន្លងអញ ។ ខ្ញុំនោះ បាននិយាយស្បថយ៉ាងអាក្រក់ផង និយាយពាក្យកុហកផងថា ខ្ញុំមិនប្រព្រឹត្តកន្លងអ្នកដោយកាយ ឬដោយចិត្តទេ ប្រសិនបើខ្ញុំប្រព្រឹត្តកន្លងអ្នកដោយកាយ ឬដោយចិត្ត សូមឲ្យឆ្កែកំបុតត្រចៀកនេះ ខាំស៊ីអវយវៈតូចធំចុះ ។ ឆ្កែកំបុតត្រចៀក ខាំស៊ីអវយវៈតូចធំរបស់ខ្ញុំ ព្រោះបាបកម្មណា ខ្ញុំបានទទួលនូវផលនៃបាបកម្មនោះទាំង ២ យ៉ាងគឺ ទុស្សីលកម្ម ១ មុសាវាទកម្ម ១ អស់ ៧០០ ឆ្នាំ ។*

*( ស្រីប្រេតនោះពោលថា ) បពិត្រព្រះសម្មតិទេព ព្រះអង្គជាក្សត្រ*

មានឧបការៈច្រើន បានយាងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំ ឯខ្ញុំក៏បានរួចស្រឡះចាកភ្លើកំបុតត្រចៀក ជាស្រីលែងមានសោក លែងមានភ័យអំពីអារម្មណ៍ណាមួយ បពិត្រព្រះសម្មតិទេព ខ្ញុំសូមធ្វើអញ្ជលី ថ្វាយបង្គំបង្វែព្រះអង្គ សូមព្រះអង្គសោយកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរជាមួយនឹងខ្ញុំ ។

( ស្តេចពោលថា ) កាមទាំងឡាយមិនមែនជារបស់មនុស្ស អញបានបរិភោគហើយ អញជាអ្នកត្រេកអរជាមួយនឹងនាងហើយ ម្នាលនាងមានជោគល្អ អញសូមអង្វរនាង នាងចូរនាំអញទៅ ( នគរ ) វិញឲ្យឆាប់ ។

## ចប់ រឿងកណ្ណមុណ្ឌប្រេតទី ១២ ។

# អដ្ឋកថា កណ្ណមុណ្ឌប្រេត

[ ២៤ ] ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធកណ្ណមុណ្ឌប្រេត ត្រាស់គាថានេះ មានពាក្យផ្តើមថា **សោណ្ណសោបានផលកា** ដូច្នេះជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ក្នុងកិមិលនគរ មានឧបាសកម្នាក់ ជាព្រះសោតាបន្ន មានធនុះរួមជាមួយឧបាសក ៥ រយ ជាអ្នកខ្វល់ខ្វាយក្នុងបុញ្ញកម្ម មានការដាំឈើផ្កា ធ្វើស្ពាន ធ្វើទីចង្ក្រម ជាដើម សាងវិហារថ្វាយសង្ឃ ទៅកាន់វិហារតាមកាល មួយអន្លើដោយឧបាសកទាំងនោះ ។ ចំណែកភរិយារបស់ឧបាសកទាំងនោះ ជាឧបាសិកា ព្រមព្រៀងគ្នានឹងគ្នាកាន់ផ្កានិងគ្រឿងក្រអូប ជាដើម ទៅកាន់វិហារតាមកាល ទៅសម្រាកក្នុងសាលាដែលជាទីត្រេកអរជាដើម ក្នុងរវាងផ្លូវ ។

ថ្ងៃមួយ អ្នកលេង ២-៣ នាក់ អង្គុយប្រជុំគ្នាត្រង់សាលាមួយកន្លែងកាលឧបាសិកាទាំងនោះ នាំគ្នាទៅសម្រាកក្នុងទីនោះ ឃើញរូបសម្បត្តិរបស់ឧបាសិកាទាំងនោះ មានចិត្តប្រតិព័ទ្ធ ដឹងថា ឧបាសិកាទាំងនោះ ដល់ព្រមដោយសីល អាចារនិងគុណ ទើបសន្ទនាគ្នាថា អ្នកណាអាចទម្លាយសីលរបស់ឧបាសិកាម្នាក់ក្នុងឧបាសិកាទាំងនោះបាន ។ ក្នុងអ្នកលេងទាំងនោះ អ្នកលេងម្នាក់ពោលថា ខ្ញុំអាច ។ អ្នកលេងទាំងនោះ បានធ្វើឧបទ្រពថា ពួកយើងនឹងធ្វើកម្មអាក្រក់ ដោយតម្លៃមួយពាន់ ហើយពោលបន្តថា បើឯងធ្វើបាន យើងនឹងឲ្យទ្រព្យ ១០០០ កហាបណៈ បើធ្វើមិនបាន គប្បីឲ្យទ្រព្យ

ដល់យើង ។ បុរសនោះព្យាយាមដោយឧបាយជាច្រើន កាលឧបាសិកាទាំងនោះមកកាន់សភា ទើបដេញពិណខ្សែ ៧ មានសំឡេងពីរោះក្រៃលែង ច្រៀងចម្រៀងប្រកបដោយកាមគុណ មានសំឡេងពីរោះនោះឯង ឲ្យស្រីម្នាក់ក្នុងឧបាសិកាទាំងនោះដល់នូវសីលវិបត្តិដោយសំឡេងច្រៀង ធ្វើនូវការប្រព្រឹត្តកន្លង ឲ្យអ្នកលេងទាំងនោះចាញ់ដោយទ្រព្យ ១០០០ អ្នកលេងដែលចាញ់ដោយទ្រព្យ ១០០០ ក៏ទៅប្រាប់ដល់ប្តីរបស់នាង ស្វាមីសួរនាងថា បុរសទាំងនោះបានពោលដោយប្រការដែលនាងមានសភាពយ៉ាងនេះឬ នាងបដិសេធថា ខ្ញុំមិនដឹងរឿងបែបនេះ កាលស្វាមីមិនជឿ ទើបបង្ហាញឆ្កែដែលនៅជិត បានធ្វើនូវសម្បថថា បើខ្ញុំធ្វើកម្មអាក្រក់បែបនេះសោត សូមឆ្កែខ្មៅកំបុតត្រចៀកនេះខាំខ្ញុំដែលកើតក្នុងភពនោះៗចុះ ។ ឯស្រី ៥០០ នោះ ដឹងថា ស្រីនោះប្រព្រឹត្តក្រៅចិត្ត ត្រូវបុរសនោះសួរថា ស្រីនេះធ្វើកម្មបែបនេះ ឬមិនបានធ្វើ ក៏ពោលមុសាវាទថា ពួកខ្ញុំមិនដឹងកម្មបែបនេះ ទើបធ្វើសម្បថថា បើពួកខ្ញុំដឹង សូមឲ្យពួកខ្ញុំកើតជាទាសីរបស់ស្រីនោះឯង គ្រប់ៗជាតិទៅចុះ ។

លំដាប់នោះ ស្រីដែលប្រព្រឹត្តក្រៅចិត្តប្តីនោះ មានហទយៈត្រូវសេចក្តីក្តៅក្រហាយនោះឯងដុតរោល ក៏ស្គាំងស្គម មិនយូរប៉ុន្មានក៏ស្លាប់ ទៅកើតជាវេមានិកប្រេត ត្រង់មាត់ស្រះកណ្ណមុណ្ឌមួយកន្លែង បណ្តាស្រះធំទាំង ៧ ក្បែរជើងភ្នំហិមពាន្ត ។ ជុំវិញវិមានរបស់នាង ស្រះបោក្ខរណីមួយ បានកើតឡើងដែលប្រកបដោយការសោយវិបាកនៃកម្មរបស់នាង ឯស្រី ៥០០

ដ៏សេស ធ្វើកាលកិរិយា ហើយកើតជាទាសីរបស់ស្រីនោះឯងដោយអំណាចកម្មដែលស្បថ ។ នាងសោយទិព្វសម្បត្តិពេញមួយថ្ងៃ ព្រោះផលនៃបុញ្ញកម្មដែលខ្លួនធ្វើទុកក្នុងកាលមុននោះ លុះដល់កណ្តាលយប់ ត្រូវកម្លាំងកម្មដាស់តឿន ទើបក្រោកពីដំណេក ទៅកាន់ច្រាំងស្រះបោក្ខរណី ។ ឆ្កែខ្មៅមួយប្រមាណប៉ុនកូនសេះ មានរូបគួរខ្លាច មានស្លឹកត្រចៀកកំបុត មានចង្កូមវែងមុត មានភ្នែកដូចគំនររងើកភ្លើងគគីរដែលឆេះល្អហើយ មានអណ្តាតដូចផ្លេកបន្ទោរដែលលៀនចេញមក មិនដាច់រយៈ មានក្រចកកោងមុត មានរោមរឹងវែងគួរខ្ពើម មកអំពីស្រះកណ្ណមុណ្ឌនោះ ហើយធ្វើស្រីនោះ ដែលទៅក្នុងទីនោះ ឲ្យដួលត្រង់ផែនដី ហាក់ដូចត្រូវសេចក្តីឃ្លានខ្លាំងគ្របសង្កត់ គ្រហឹមគំរាមត្របាក់ស៊ី ឲ្យសល់ត្រឹមតែរាងឆ្អឹង ហើយពាំទៅទម្លាក់ត្រង់ស្រះបោក្ខរណី ក៏បាត់ទៅ ។ ដំណាលគ្នានឹងឆ្កែទម្លាក់ឆ្អឹងក្នុងស្រះបោក្ខរណីនោះឯង នាងក៏មានរូបជាប្រក្រតី ហើយឡើងកាន់វិមាន ដេកលើដំណេក ។ ឯស្រីក្រៅពីនោះ សោយទុក្ខជាទាសៈរបស់ស្រីនោះឯង ។ ពួកស្រីទាំងនោះនៅក្នុងទីនោះ ៥៥០ ឆ្នាំ ដោយប្រការដូច្នេះ ។

លំដាប់នោះ ស្រីទាំងនោះសោយទិព្វសម្បត្តិ មិនមានបុរស ក៏កើតការអផ្សុក ។ មានស្ទឹងមួយខ្សែហូរចេញអំពីស្រះកណ្ណមុណ្ឌៈ បណ្តាស្រះធំ ៧ នោះ ចេញតាមប្រកក្នុំហើយ ចូលទៅកាន់ស្ទឹងគង្គា ។ ក្នុងទីជិតលំនៅរបស់ស្រីទាំងនោះ មានដងព្រៃមួយ ល្អដូចឧទ្យាន ប្រកបដោយដើមស្វាយ ខ្នុរនិងឃ្លោក ជាដើម មានផ្លែជាទិព្វ ។ ស្រីទាំងនោះគិតព្រមគ្នាយ៉ាងនេះថា

ណ្ហើយចុះ ពួកយើងនឹងបេះផ្លែស្វាយទម្លាក់ក្នុងស្ទឹងនេះ គង់មានបុរសណាមួយ ឃើញផ្លែស្វាយនេះ ព្រោះចំណង់ក្នុងផ្លែនឹងមកទីនេះមិនខាន ពួកយើងនឹងអភិរម្យជាមួយបុរសនោះ ។ ស្រីទាំងនោះ បានធ្វើយ៉ាងនោះ ។ ឯផ្លែស្វាយដែលស្រីទាំងនោះនាំគ្នាបោះទៅ ផ្លែខ្លះតាបសរើសបាន ផ្លែខ្លះព្រានព្រៃរើសយក ផ្លែខ្លះក្អែកដណ្តើមគ្នាស៊ី ផ្លែខ្លះជាប់តាមមាត់ច្រាំង ឯផ្លែមួយបានអណ្តែតតាមខ្សែទឹកក្នុងស្ទឹងគង្គា ដល់ក្រុងពារាណសីដោយលំដាប់ ។

សម័យនោះ ព្រះបាទពារាណសីទ្រង់ស្រង់ទឹកក្នុងស្ទឹងគង្គាដែលគេព័ទ្ធដោយសំណាញ់លោហៈ លំដាប់នោះ ផ្លែនោះអណ្តែតទៅតាមខ្សែទឹកដោយលំដាប់ ជាប់ត្រង់សំណាញ់លោហៈ ។ ពួករាជបុរសឃើញផ្លែស្វាយទិព្វដ៏ធំ សម្បូរដោយពណ៌ ក្លិននិងរស ទើបនាំទៅថ្វាយដល់ព្រះរាជា ។ ព្រះរាជាទ្រង់ចាប់យកចំណែកមួយរបស់ផ្លែស្វាយនោះ ដើម្បីពិសោធ ព្រះរាជទានឲ្យដល់ពេជ្ឈឃាតម្នាក់ដែលទ្រង់តាំងទុកក្នុងតំណែងជាអ្នកយាមគុក ឲ្យបរិភោគ ។ បុរសនោះទំពាផ្លែស្វាយនោះហើយពោលថា បពិត្រ ព្រះសម្មតិទេព ផ្លែឈើនេះទូលបង្គំមិនធ្លាប់ទំពាស៊ីឡើយ ផ្លែឈើទិព្វនេះ ប្រហែលជាផ្លែស្វាយ ។ ព្រះរាជាបានប្រទានមួយចំណិតទៀតដល់ពេជ្ឈឃាតនោះ ។ ពេជ្ឈឃាតទំពាស៊ីផ្លែស្វាយនោះហើយ ប្រាសចាកស្បែកជ្រីវជ្រួញ សក់ស្កូវក៏ខ្មៅមកវិញ មានរូបស្អាតគួរជាទីពេញចិត្ត ហាក់ដូចតាំងនៅក្នុងវ័យកំលោះ ព្រះរាជាទតឃើញដូច្នោះ ទ្រង់កើតអស្ចារ្យទើបសោយផ្លែស្វាយនោះដែរ បានទទួលសេចក្តីវិសេសក្នុងព្រះវរកាយទើបត្រាស់សួរពួកមនុស្ស

ថា ផ្លែស្វាយទិព្វបែបនេះមាននៅទីណា ពួកមនុស្សក្រាបទូលយ៉ាងនេះថា បានឮថា មាននៅត្រង់ជើងភ្នំហិមពាន្ត ព្រះរាជាត្រាស់ថា អ្នកណាអាចនាំយកផ្លែស្វាយនេះមកបាន ពួកមនុស្សក្រាបទូលថា ព្រានព្រៃមែងដឹង ។ ព្រះរាជាត្រាស់ឲ្យហៅព្រានព្រៃមក ប្រាប់រឿងនោះដល់ពួកព្រានព្រៃ ប្រទានទ្រព្យ ១០០០ កហាបណៈ ដល់ព្រានព្រៃម្នាក់ ដែលពួកព្រានព្រៃទាំងនោះសន្មតថ្វាយ ទើបបញ្ជូនព្រានព្រៃនោះទៅដោយព្រះតម្រាស់ថា ចូរអ្នកទៅចូរប្រញាប់នាំផ្លែស្វាយនោះមកឲ្យយើង ព្រានព្រៃនោះបានឲ្យទ្រព្យ ១០០០ នោះដល់កូនប្រពន្ធ កាន់យកស្បៀងបែរមុខទៅកាន់ស្រះកណ្ណមុណ្ឌៈ ដើរប្រាសខ្សែទឹកស្ទឹងគង្គា រំលងដែនដីមនុស្ស ជួបតាបសម្នាក់ត្រង់ប្រទេសប្រមាណ ៦០ យោជន៍ អំពីស្រះកណ្ណមុណ្ឌ ធ្វើដំណើរតាមផ្លូវដែលតាបសនោះប្រាប់ ជួបតាបសម្នាក់ទៀតក្នុងប្រទេសប្រមាណ ៣០ យោជន៍ ដើរតាមផ្លូវដែលតាបសនោះប្រាប់ជួបតាបសមួយរូបទៀតក្នុងទីប្រមាណ ១៥ យោជន៍ ទើបប្រាប់ហេតុដែលខ្លួនមកដល់តាបសនោះ ។ តាបសប្រៀនប្រដៅថា ចាប់ពីនេះទៅ អ្នកត្រូវលះបង់ស្ទឹងគង្គានេះ ដើរបញ្ច្រាសខ្សែទឹកតាមស្ទឹងតូចនេះ កាន់យកគប់ភ្លើងក្នុងរាត្រី ក្នុងពេលដែលអ្នកឃើញប្រកភ្នំហើយ គប្បីចូលទៅ ឯស្ទឹងតូចនេះ ក្នុងពេលយប់មិនហូរ ព្រោះហេតុនោះ ទើបស្ទឹងនេះសមគួរដល់ការទៅរបស់អ្នក លុះធ្វើដំណើរទៅបាន ២-៣ យោជន៍ អ្នកនឹងឃើញផ្លែស្វាយទាំងនោះ ។ ព្រានព្រៃបានធ្វើតាមនោះ លុះដល់ព្រះអាទិត្យរះឡើង ក៏ដល់ចម្ការស្វាយដែលជាទីត្រេកអរក្រៃលែង ជាភូមិភាគដែលភ្លឺផ

ដោយបណ្តាញនៃរស្មីរបស់រតនៈផ្សេងៗ លម្អដោយអារាមនៃព្រៃ ដែលមានផ្លែច្រើន មានមែកគ្របដណ្តប់ដូចពិតាន ពួកសត្វបក្សីច្រើនប្រភេទបញ្ចេញសំឡេងល្ងើល្ងើយ ។

លំដាប់នោះ ពួកស្រីអមនុស្សទាំងនោះ ឃើញព្រានព្រៃនោះដើរមកអំពីចម្ងាយ ក៏រត់ទៅដោយគិតថា បុរសនេះជាទីពឹងរបស់យើង បុរសនេះជាទីពឹងរបស់យើង ។ ព្រានព្រៃ គ្រាន់តែឃើញស្រីទាំងនោះ ក៏មានចិត្តខ្ល[illegible] ស្រែកហើយរត់គេចទៅ ព្រោះខ្លួនមិនបានធ្វើបុញ្ញកម្មដែលសមគួរសោយទិព្វសម្បត្តិក្នុងទីនោះរួមជាមួយស្រីទាំងនោះ បានទៅដល់ក្រុងពារាណសីដោយលំដាប់ ក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ មានព្រះបំណងចង់ឃើញស្រីទាំងនោះ និងចង់បរិភោគផ្លែស្វាយទាំងឡាយ ក៏ឲ្យពួកអាមាត្យសម្រេចរាជការជំនួសព្រះអង្គ ទ្រង់រៀបចំព្រួញនិងធ្នូ សៀតព្រះខ័ន យកលេសថា ទៅបាញ់សត្វ មានមនុស្ស ២-៣ នាក់ជាបរិវារ យាងទៅតាមផ្លូវដែលព្រានព្រៃនោះប្រាប់ ទើបឲ្យមនុស្សទាំងនោះវិលត្រឡប់ក្នុងរយៈ ២-៣ យោជន៍ នាំតែព្រានព្រៃទៅដោយលំដាប់ ឲ្យព្រានព្រៃនោះត្រឡប់អំពីទីនោះ លុះព្រះអាទិត្យរះឡើង ក៏ចូលដល់ចម្ការស្វាយ ។ លំដាប់នោះ ពួកស្រីទាំងនោះ ឃើញព្រះរាជានោះដូចទេវបុត្តកើតក្នុងភពថ្មី ទើបនាំគ្នាទទួល ដឹងថា ជាព្រះរាជា ក៏កើតសេចក្តីស្នេហានិងការរាប់អានច្រើន ឲ្យងូតទឹកដោយគោរព ឲ្យប្រដាប់តាក់តែងដោយល្អដោយសំពត់ គ្រឿងអលង្ការ ផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាប លើក

ឡើងកាន់វិមាន ឲ្យបរិភោគភោជនដែលជាទិព្វ មានរសដ៏ប្រសើរផ្សេងៗហើយ ចូលទៅអន្ទាយជិត តាមសមគួរដល់សេចក្តីប្រាថ្នា ។

ក្នុងកាលកន្លងទៅ ១៥០ ឆ្នាំ ព្រះរាជាក្រោកឡើងត្រង់កណ្តាលយប់ ប្រថាប់គង់ ទតឃើញស្រីប្រេត ដែលប្រព្រឹត្តក្រៅចិត្តប្តីនោះដើរទៅកាន់មាត់ស្រះបោក្ខរណី ទ្រង់ចង់ដឹង ទើបយាងតាមពីក្រោយដោយគិតថា ព្រោះហេតុអ្វីហ្ន៎ទើបស្រីនេះទៅក្នុងវេលានេះ ។ លំដាប់នោះ ព្រះរាជាឃើញស្រីនោះ ទៅក្នុងទីនោះ ត្រូវឆ្កែកំពុងខាំ មិនដឹងថា នេះជាអ្វីហ្ន៎ ទើបតាមមើល ២-៣ ថ្ងៃ គិតថា ឆ្កែនេះប្រហែលជាសត្រូវរបស់ស្រីនេះ ទើបពួយលំពែងដែលសំលៀងល្អហើយផ្តាច់ជីវិតឆ្កែនោះ ហើយវាយស្រីនោះឲ្យចុះកាន់ស្រះបោក្ខរណី ឃើញរូបដែលខ្លួនបានឃើញក្នុងកាលមុនហើយ ទើបត្រាស់សួរប្រវត្តិរបស់ស្រីនោះដោយគាថា ១២ ថា

ស្រះបោក្ខរណី មានកម្មជណ្តើរ ជាវិការៈនៃមាស ក្រាលខ្សាច់ជាវិការៈនៃមាស ( ដោយជុំវិញ ) ពួកផ្កាចន្ទលណី ក្នុងស្រះបោក្ខណីនោះល្អ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ( ស្រះបោក្ខរណីនោះ ) ដេរដាសដោយឈើផ្សេងៗផ្សាយទៅដោយក្លិនផ្សេងៗ ដេរដាសដោយឈូកក្រហមផ្សេងៗឆ្លុកឆ្លាស់ដោយឈូកសផ្សេងៗ ។ ( ស្រះបោក្ខរណីទាំងឡាយនោះ ) ទ្រហឹងអឹងកងដោយហង្សនិងក្រៀល មានសត្វចាក្រពាកស្រែកគ្រលួច កុះករដោយហ្វូងសត្វស្លាបផ្សេងៗប្រកប

ដោយពួកបក្សីមានសំឡេងផ្សេងៗផង ឈើទាំងឡាយ ទ្រ-ទ្រង់នូវផ្លែផ្សេងៗផង ព្រៃទាំងឡាយ ទ្រទ្រង់នូវកម្រងផ្កាផ្សេងៗផង មានក្លិនក្រអូបជាទីគាប់ចិត្ត ដែលខ្យល់បក់មកត្រូវ ក៏ផ្សាយទៅ ។ នគរ ( របស់នាង ) នេះ ប្រាកដយ៉ាងណា នគរប្រាកដយ៉ាងនេះ មិនមានក្នុងពួកមនុស្សទេ ទាំងប្រាសាទរបស់នាងក៏ច្រើន សុទ្ធសឹងតែមាសនឹងប្រាក់រុងរឿងញុំាងទិសទាំង ៤ ឲ្យភ្លឺជុំវិញ ។ ទាសី ៥០០ ណា ជាស្រីបម្រើរបស់នាង ពួកទាសីទាំងនោះ ក៏ទ្រទ្រង់នូវស័ង្ខនិងកងកនិងកន្ទ្រុំ ស្អិតស្អាងដោយសំពត់មាស ។ បល្ល័ង្ករបស់នាងដ៏ច្រើន សុទ្ធសឹងតែមាស និងប្រាក់ ក្រាលកម្រាលស្បែកឈ្មុសដែលបុញ្ញកម្មតាក់តែងហើយ ក្រាលសំពត់គោណកៈជាទីចូលទៅនៅអាស្រ័យរបស់នាង អ្នកសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ លុះដល់ពាក់កណ្តាលអធ្រាត្រ នាងតែងក្រោកអំពីបល្ល័ង្កនោះទៅកាន់ឱទ្យានភូមិ ដើរជុំវិញស្រះបោក្ខ-រណី ។ ( ម្នាលនាងដ៏ចម្រើននាងទៅ ) ឈរក្បែរឆ្នេរស្រះបោក្ខរណីនោះ ជាទីមានស្មៅដុះខៀវខ្ចីដ៏ស្អាត លំដាប់នោះស្រាប់តែមានឆ្កែកំបុតត្រចៀក មកខាំអវយវៈ តូចធំរបស់នាង ។ នាងក្នុងកាលដែលឆ្កែខាំស៊ីធ្វើឲ្យនៅសល់តែរាងឆ្អឹងហើយ នាងចុះទៅកាន់ស្រះបោក្ខរណី កាយ ( របស់នាង )

ក៏តាំងនៅដូចក្នុងកាលមុន ។ លំដាប់នោះ នាងមានអវយវៈ តូចធំពេញលេញល្អល្អះ គួរឲ្យរមិលមើល ស្លៀកដណ្តប់ សំពត់ហើយ មកកាន់សំណាក់នៃអញ ។ អំពើអាក្រក់ដូចម្តេចដែលនាងបានធ្វើដោយកាយ វាចា ចិត្ត ដោយផលនៃកម្មដូចម្តេច បានជាខ្ញែកំបុតត្រចៀក ខាំស៊ីនូវអវយវៈតូចធំដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោណសោបានផលកា** ប្រែថា បន្ទះក្តារជណ្តើរសម្រេចហើយដោយមាស ។ បទថា **សោវណ្ណវាលុកសន្ថតា** បានដល់ ក្រាលដោយខ្សាច់មាសដោយជុំវិញ ។ បទថា **តត្ថ** បានដល់ ក្នុងស្រះបោក្ខរណីនោះ ។ បទថា **សោគន្ធិយា** ប្រែថា មានក្លិនក្រអូប ។ បទថា **វគ្គូ** បានដល់ ល្អគួរពេញចិត្ត ។ បទថា **សុចិគន្ធា** បានដល់ មានក្លិនជាទីត្រេកអរនៃចិត្ត ។ បទថា **នានាគន្ធសមេរិតា** បានដល់ មានខ្យល់បក់ក្លិននិងគ្រឿងក្រអូបច្រើនប្រភេទមកដោយជុំវិញ ។ បទថា **នានា បទុមសញ្ឆន្នា** បានដល់ មានផ្ទៃទឹកដេរដាសដោយឈូកផ្សេងៗ ច្រើនប្រភេទ ។ បទថា **បុណ្ឌរីកសមោហតា** បានដល់ ដេរដាសទៅដោយឈូកស ។ បទថា **សុរភី សម្បវាយន្តិ** សេចក្តីថា មានក្លិនក្រអូបគួរជាទីត្រេកអរនៃចិត្ត ត្រូវខ្យល់បក់ផ្សាយទៅ អធិប្បាយថា ស្រះបោក្ខរណី ។ បទថា **ហំស-កោញ្ចាភិរុទា** ប្រែថា សំឡេងរងំដោយហង្សនិងសត្វក្រៀល ។

បទថា **នានាទិជគណាកិណ្ណា** ប្រែថា ដេរដាសទៅដោយហ្វូងបក្សី

ផ្សេងៗ ។ បទថា **នានាសរគណាយុតា** បានដល់ ប្រកបទៅដោយពួកបក្សីផ្សេងៗបន្ទឹសំឡេងយំពីរោះជាប់ចិត្ត ក៏មាន ។ បទថា **នានាផលធរា** សេចក្ដីថា មានរុក្ខជាតិដែលទ្រទ្រង់នូវផ្កានិងផ្លែសព្វរដូវកាល មានមែកទោរទន់ដោយទម្ងន់ផ្លែដ៏ច្រើន ។ បទថា **នានាបុប្ផធរាវនា** សេចក្ដីថា ព្រៃដែលមានពួកឈើចេញផ្កា មានក្លិនក្រអូបច្រើនប្រភេទ ។ ពិតហើយ បទថា **វនា** លោកពោលដោយលិង្គវិបល្លាស ។ បទថា **ន មនុស្សេសុ ឦទិសំ នគរំ** សេចក្ដីថា នៅក្នុងមនុស្សលោក មិនមាននគរណាដែលស្មើដូចនគររបស់នាង អធិប្បាយថា មិនមានក្នុងមនុស្សលោក ។ បទថា **រូបិយាមយា** ប្រែថា សម្រេចហើយដោយប្រាក់ ។ បទថា **ទទ្ទល្លមានា** ប្រែថា រុងរឿងក្រៃលែង ។ បទថា **អាភេន្តិ** ប្រែថា ស្អាត ។ បទថា **សមន្តា ចតុរោ ទិសា** សេចក្ដីថា ទាំង ៤ ទិស ដោយជុំវិញ ។ បទថា **យា តេមា** កាត់បទជា **យា តេ ឥមា** ។ បទថា **បរិចារិកា** បានដល់ ស្រីដែលធ្វើការខ្វល់ខ្វាយ ( បម្រើ ) ។ បទថា **តា** បានដល់ ស្រីបម្រើទាំងនោះ ។ បទថា **កម្ពុកាយូរធរា** បានដល់ ប្រដាប់ដោយកងមាស ។ បទថា **កញ្ចនា-វេឡ្យភូសិតា** បានដល់ មានសក់និងដៃប្រដាប់ដោយផ្កាកម្រងមាស ។ បទថា **កតលិមិគសញ្ឆន្នា** ប្រែថា ក្រាលដោយស្បែកឈ្មុស ។ បទថា **សជ្ជា** ប្រែថា ដែលបុគ្គលរាស់ចែកល្អហើយ គឺសមជាទីដេក ។ បទថា **គោ-ណកសន្ថតា** បានដល់ ក្រាលដោយសំពត់កោជវៈមានរោមវែង ។

បទថា **យត្ថ** គឺក្នុងបល្ល័ង្កណា ។ បទថា **វាសូបគតា** ប្រែថា ចូល

ទៅកាន់លំនៅ អធិប្បាយថា ដេក ។ បទថា **សម្បត្តាយឌ្ឍរត្តាយ** ប្រែថា លុះដល់ពេលកណ្ដាលយប់ ។ បទថា **តតោ** ប្រែថា ចាកបល្ល័ង្ក ។ បទថា **ចោក្ខរញ្ញោ** គឺក្បែរស្រះបោក្ខរណី ។ បទថា **ហរិតេ** ប្រែថា ( ស្មៅ ) ខៀវខ្ចី ។ បទថា **សទ្ទលេ** បានដល់ ដេរដាសដោយស្មៅខ្ចី ។ បទថា **សុភេ** ប្រែថា ស្អាត ។ ម្យ៉ាងទៀត បទថា **សុភេ** ជាពាក្យហៅស្រីប្រេត ។ មានវាចាប្រកបសេចក្ដីថា នែស្រីស្អាត នាងទៅឈរត្រង់មាត់ស្រះបោក្ខរណីនោះ លើស្មៅដែលខៀវស្រស់ដោយជុំវិញ ។

បទថា **កណ្ណមុណ្ឌា** ប្រែថា មានត្រចៀកកំបុត គឺកំបុតត្រចៀក ។ បទថា **ខាយិតា អាសិ** សេចក្ដីថា នាងជាបុគ្គលត្រូវឆ្កែត្រចៀកកំបុតខាំហើយ ។ បទថា **អដ្ឋិសង្ខលិកា កតា** បានដល់ ខាំឲ្យសល់តែរាងឆ្អឹង ។ បទថា **យថា បុរេ** បានដល់ ដូចក្នុងកាលមុនអំពីកាលដែលឆ្កែខាំ ។

បទថា **តតោ** បានដល់ ក្រោយអំពីចុះកាន់ស្រះបោក្ខរណី ។ បទថា **អង្គបច្ចង្គី** បានដល់ មានសព៌ាង្គកាយគ្រប់បរិបូណ៌ ។ បទថា **សុចារុ** បានដល់ គួរជាទីត្រេកអរនៃចិត្តដោយល្អ ។ បទថា **បិយទស្សនា** បានដល់ គួរសរសើរ ។ បទថា **អាយាសិ** ប្រែថា រមែងមក ។

ស្រីប្រេតនោះ ត្រូវព្រះរាជាសួរយ៉ាងនេះហើយ កាលនឹងពោលប្រវត្តិខ្លួនក្នុងកាលមុនដល់ព្រះរាជា ទើបពោលគាថា ៥ ថា

ក្នុងនគរកិម្ពិលា មានគហបតីជាឧបាសកអ្នកមានសទ្ធា ខ្ញុំជា
ប្រពន្ធរបស់គាត់ជាស្រីទុស្តសីល បានប្រព្រឹត្តកន្លងចិត្តប្តី ។

កាលខ្ញុំប្រព្រឹត្តកន្ទងចិត្តប្តីយ៉ាងនេះហើយ ប្តីបាននិយាយយ៉ាង នេះថា អំពើនេះមិនប្រពៃ មិនសមគួរទេ ព្រោះនាងប្រព្រឹត្ត កន្ទងអញ ។ ខ្ញុំនោះ បាននិយាយស្បថ យ៉ាងអាក្រក់ផង និយាយពាក្យកុហកផងថា ខ្ញុំមិនប្រព្រឹត្តកន្ទងអ្នកដោយកាយ ឬដោយចិត្តទេ ប្រសិនបើខ្ញុំប្រព្រឹត្តកន្ទងអ្នកដោយកាយ ឬ ដោយចិត្ត សូមឲ្យឆ្កែកំបុតត្រចៀកនេះ ខាំស៊ីអវយវៈតូចធំ ចុះ ។ ឆ្កែកំបុតត្រចៀក ខាំស៊ីអវយវៈតូចធំរបស់ខ្ញុំ ព្រោះ បាបកម្មណា ខ្ញុំបានទទួលរងផលនៃបាបកម្មនោះទាំង ២ យ៉ាង គឺ ទុស្សីលកម្ម ១ មុសាវាទកម្ម ១ អស់ ៧០០ ឆ្នាំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិមិលាយំ** បានដល់ ក្នុងនគរមានឈ្មោះ យ៉ាងនោះ ។ បទថា **អតិចារិនី** សេចក្តីថា ពិតហើយ ករិយា លោក ហៅថាមានការប្រព្រឹត្តក្រៅចិត្ត ព្រោះប្រព្រឹត្តក្រៅចិត្តប្តី មានវាចាប្រកប សេចក្តីថា កាលខ្ញុំប្រព្រឹត្តក្រៅចិត្ត ប្តីខ្ញុំនោះក៏បានពោលពាក្យនេះនឹងខ្ញុំ ។ បទថា **នេតំ ឆន្នំ** ជាដើម ជាការសម្តែងអាការដែលប្តីពោលហើយ ។ បណ្តា បទទាំងនោះ បទថា **នេតំ ឆន្នំ** សេចក្តីថា ការប្រព្រឹត្តក្រៅចិត្តនោះជាការមិន សមគួរ ។ បទថា **ន បតិរូបំ** ជាវេវចនៈនៃបទថា **នេតំ ឆន្នំ** នោះឯង ។ បទថា **យំ** ជាកិរិយាបរាមាស ។ បទថា **អតិចរាសិ** ប្រែថា ប្រព្រឹត្ត ក្រៅចិត្ត ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា អធិប្បាយថា ការដែលនាង ប្រព្រឹត្តក្រៅចិត្តអញនោះ ជាការមិនសមគួរ ។

បទថា **ឃោរំ** ប្រែថា អាក្រក់ ។ បទថា **សបថំ** ប្រែថា ពាក្យផ្តាសា ។ បទថា **ភាសិសំ** ប្រែថា បានពោលហើយ ។ បទថា **សចាហំ** កាត់បទជា **សចេ អហំ** ។ បទថា **តំ** បានដល់ **តុំ** ប្រែថា អ្នក ។ បទថា **តស្ស កម្មស្ស** បានដល់ កម្មដ៏លាមក គឺកម្មនៃបុគ្គលអ្នកទ្រុស្តសីលនោះ ។ បទថា **មុសាវាទស្ស ច** បានដល់ ពោលមុសាវាទថា ខ្ញុំមិនបានប្រព្រឹត្តក្រៅចិត្តអ្នក ។ បទថា **ឧភយំ** បានដល់ វិបាកនៃកម្មទាំង ២ ។ បទថា **អនុភូតំ** ប្រែថា ដែលខ្ញុំសោយ ។ បទថា **យតោ** បានដល់ ចាកកម្មអាក្រក់ណា ។

ស្រីប្រេតនោះ កាលពោលយ៉ាងនេះហើយ កាលប្រារព្ធឧបការៈដែលព្រះរាជាធ្វើដល់ខ្លួន ទើបពោលគាថា ២ ថា

បពិត្រព្រះសម្មតិទេព ព្រះអង្គជាក្សត្រ មានឧបការៈច្រើន
បានយាងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំ ឯខ្ញុំក៏បានរួច
ស្រឡះចាកឆ្កែកំបុតត្រចៀក ជាស្រីលែងមានសោក លែង
មានភ័យអំពីអារម្មណ៍ណាមួយ បពិត្រព្រះសម្មតិទេព ខ្ញុំសូម
ធ្វើអញ្ជលីថ្វាយបង្គំ បង្វរព្រះអង្គ សូមព្រះអង្គសោយកាម
ទាំងឡាយដែលមិនមែនជារបស់មនុស្ស បពិត្រព្រះសម្មតិទេព
សូមព្រះអង្គត្រេកអរជាមួយនឹងខ្ញុំ ដូច្នេះ ។

ស្រីប្រេតហៅព្រះរាជាដោយពាក្យថា **ទេវ** ក្នុងគាថានោះ ។ បទថា **កណ្ណមុណ្ឌស្ស** បានដល់ ឆ្កែកំបុតត្រចៀក ។ ពិតហើយ ពាក្យថា **កណ្ណ-មុណ្ឌស្ស** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃបញ្ចមីវិភត្តិ ។ លំដាប់នោះ ព្រះ

រាជាទ្រង់មានព្រះទ័យនឿយណាយ ដោយការនៅក្នុងទីនោះ ទើបប្រកាសអធ្យាស្រ័យ ក្នុងការយាងទៅ ។ ប្រេតបានស្តាប់ដូច្នោះ មានចិត្តប្រតិព័ទ្ធចំពោះព្រះរាជា កាលអង្វរព្រះរាជាឲ្យប្រថាប់នៅក្នុងទីនោះឯង ទើបពោលគាថាថា **តាហំ ទេវ ឯមស្សាមិ** ដូច្នេះ ។

ព្រះរាជាមានបំណងនឹងយាងទៅព្រះនគរ ដោយចំណែកមួយ កាលនឹងប្រកាសអធ្យាស្រ័យរបស់ព្រះអង្គទៀត ទើបពោលគាថាចុងក្រោយថា

កាមទាំងឡាយ មិនមែនជារបស់មនុស្ស អញបានបរិភោគ
ហើយ អញជាអ្នកត្រេកអរជាមួយនឹងនាងហើយ ម្នាលនាង
មានជោគល្អ អញសូមអង្វរនាង នាងចូរនាំអញទៅ ( នគរ )
វិញឲ្យឆាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តាហំ** កាត់ជា **តំ អហំ** ។ បទថា **សុភគេ** ប្រែថា ជាអ្នកប្រកបដោយលម្អ ។ បទថា **បដិនយាហិ មំ** ប្រែថា សូមនាងនាំខ្ញុំត្រឡប់ទៅកាន់នគររបស់ខ្ញុំចុះ ។ ពាក្យដ៏សេសក្នុងទីទាំងពួងប្រាកដច្បាស់ហើយ ។

លំដាប់នោះ នាងវេមានិកប្រេតនោះ កាលស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ កាលអត់ធន់នឹងការព្រាត់ប្រាសមិនបានមានហទយៈរញ្ជួយដោយសេចក្តីសោក មានរាងកាយញាប់ញ័រ អង្វរដោយឧបាយមានប្រការផ្សេងៗ កាលមិនអាចឲ្យព្រះរាជាប្រថាប់នៅក្នុងទីនោះបាន ទើបនាំព្រះរាជាមួយអន្លើដោយរតនៈដែលគួរដល់តម្លៃច្រើនសន្ធឹកសន្ធាប់ មកកាន់ព្រះនគរ ឲ្យឡើង

កាន់ប្រាសាទ យំរៀបរាប់ហើយ ទើបទៅកាន់លំនៅខ្លួនវិញ ។ ឯព្រះរាជា កាលឃើញដូច្នោះហើយ ទើបកើតសេចក្តីសង្វេគ បំពេញបុញ្ញកម្មនិងទាន ជាដើមបានជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ។ កាលព្រះមានព្រះភាគនៃយើងកើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្រដ៏បវរ គង់នៅក្នុងក្រុងសាវត្ថីដោយលំដាប់ ថ្ងៃមួយ ព្រះមហាមោគ្គល្លានចារិកទៅកាន់បពិត ឃើញស្រីនោះ មួយអន្លើដោយបរិវារ ទើបសួរដល់កម្មដែលនាងធ្វើ នាងបានតំណាលរឿងទាំងអស់នោះ តាំងពីដើមដល់ចប់ ដល់ព្រះថេរៈ ។ ព្រះថេរៈសម្តែងធម៌ដល់ស្រីទាំងនោះ ។ ព្រះថេរៈក៏ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ មហាជនដល់នូវសេចក្តីសង្វេគ វៀរបាបកម្ម ធ្វើនូវបុញ្ញកម្ម មានទានជាដើម មានស្ថានសួគ៌ជាទីទៅខាងមុខ ដោយប្រការដូច្នេះ ។

## អដ្ឋកថា កណ្ណមុណ្ឌប្រេតចប់

# រឿង ឧព្វរីប្រេត ទី ១៣

[ ២៥ ] ( ព្រះសង្គីតិកាចារ្យទាំងឡាយពោលថា ) ស្តេចរបស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល ទ្រង់ព្រះនាមព្រហ្មទត្ត ព្រះអង្គប្រសើរក្នុងរាជសម្បត្តិលុះដល់ថ្ងៃ និងយប់កន្លងទៅ ស្តេចក៏ទ្រង់សោយទិវង្គត ។ អគ្គមហេសីរបស់ស្តេចនោះ ឈ្មោះនាងឧព្វរី បានទៅកាន់ទីស្មសាន ហើយទ្រង់ព្រះកន្សែង កាលមិនឃើញស្តេចព្រហ្មទត្ត ក៏ទ្រង់ព្រះកន្សែងថា ឱព្រះបាទព្រហ្មទត្ត ។ ឥសីជាអ្នកប្រាជ្ញបរិបូណ៌ដោយចរណៈ បានមកក្នុងទីដែលនាងឧព្វរីឈរនោះ ឥសីនោះបានសួរពួកជនដែលមកជួបជុំក្នុងទីនោះថា ចុះទីស្មសាននេះ ដែលផ្សាយទៅដោយក្លិនក្រអូបផ្សេងៗ តើរបស់នរណា ស្រីនេះជាភរិយារបស់នរណា កំពុងកន្ទក់កន្ទេញរកប្តី ដែលទៅឆ្ងាយអំពីមនុស្សលោកនេះ កាលមិនឃើញព្រះបាទព្រហ្មទត្ត ក៏កន្ទក់កន្ទេញថា ឱព្រះបាទព្រហ្មទត្ត ។

ពួកជនដែលមកជួបជុំគ្នាក្នុងទីនោះ ក៏បានឆ្លើយថា បពិត្រមហាឥសីដ៏ចម្រើន ( ទីស្មសាននេះ ) របស់ព្រះបាទព្រហ្មទត្ត បពិត្រមហាឥសីអ្នកនិរទុក្ខ ( ស្រីនេះជាភរិយា ) របស់ព្រះបាទព្រហ្មទត្ត ទីស្មសាននេះរបស់ ព្រះបាទព្រហ្មទត្តនោះ ដែលផ្សាយទៅដោយក្លិនក្រអូបផ្សេងៗ ស្រីនេះជាភរិយារបស់ព្រះបាទព្រហ្មទត្តនោះ កន្ទក់កន្ទេញរកប្តីដែលទៅឆ្ងាយអំពីមនុស្សលោកនេះហើយ កាលមិនឃើញព្រះបាទព្រហ្មទត្ត ក៏កន្ទក់កន្ទេញថា ឱព្រះបាទព្រហ្មទត្ត ។

( តាបសសួរនាងឧព្វរីថា ) ស្តេចទាំងឡាយ ៨៦.០០០ ព្រះអង្គ សុទ្ធ

តែឈ្មោះព្រះបាទព្រហ្មទត្ត ត្រូវគេដុតក្នុងទីស្មសាននេះដែរ បណ្តាស្តេចព្រហ្មទត្តទាំងនោះ តើនាងសោកស្តាយរកស្តេចព្រហ្មទត្តអង្គណា ។

( នាងឧព្វរីឆ្លើយថា ) បពិត្រលោកដ៏ចម្រើន ស្តេចអង្គណារបស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល ជារាជបុត្តនៃព្រះបាទចូឡនី ព្រះអង្គប្រសើរក្នុងរាជសម្បត្តិ ខ្ញុំសោកស្តាយរកស្តេចអង្គនោះ ជាកស្តា ( របស់ខ្ញុំ ) ជាអ្នកឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ។

( តាបសសួរថា ) ពួកស្តេចទាំងអស់ សុទ្ធតែឈ្មោះព្រហ្មទត្ត ពួកស្តេចទាំងអស់ របស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល សុទ្ធតែជារាជបុត្តនៃព្រះបាទចូឡនី ព្រះអង្គប្រសើរក្នុងរាជសម្បត្តិ នាងបានជាមហេសីរបស់ពួកស្តេចទាំងអស់តាមលំដាប់មក ហេតុអ្វីបានជានាងលះបោលពួកស្តេចជាន់មុន ហើយមកសោកស្តាយតែស្តេចជាន់ក្រោយវិញ ។

( នាងឧព្វរីតបថា ) បពិត្រលោកអ្នកនិរទុក្ខ លោកពោលជាច្រើនដងហើយថា នាងឯងជាមហេសីនៃស្តេច ( ទាំងពួង ) ក្នុងសង្សារចំពោះខ្ញុំ ដែលកើតជាស្រីណា ខ្លួនរបស់ខ្ញុំដែលកើតជាស្រីនោះ ( ធ្លាប់កើតជាស្រី ) អស់កាលដ៏យូរ ( ឬក៏ធ្លាប់កើតជាប្រុសដែរ ) ។

( តាបសពោលថា ) នាងឯង ជួនកាលកើតជាស្រី ជួនកាលកើតជាប្រុស មិនតែប៉ុណ្ណោះ ជួនកាលបានទៅកាន់កំណើតបសុសត្វ កាលបើយ៉ាងនេះ ទីបំផុត ( នៃអត្តភាពទាំងឡាយ ) ដែលកន្លងនូវឥត្ថីភាពនិងបុរិសភាពនុ៎ះ រមែងមិនប្រាកដឡើយ ។

( នាងឧត្តរីពោលថា ) លោកបានស្រោចស្រពខ្ញុំ ដែលភ្លើងគឺសេចក្តីសោកកំពុងឆេះសព្វ ឲ្យស្ងប់រម្ងាប់បាន ហើយញុំាងសេចក្តីក្រវល់ក្រវាយទាំងពួងឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចរលត់ភ្លើងកំពុងឆេះនូវថ្នាំងខ្លាញ់ លោកណា បានបន្ទោបង់នូវសេចក្តីសោក ព្រោះប្តីចំពោះខ្ញុំដែលមានសេចក្តីសោកកំពុងគ្របសង្កត់ លោកនោះឈ្មោះថា បានដកនូវសរ គឺសេចក្តីសោកដែលអាស្រ័យនូវហឫទ័យរបស់ខ្ញុំ ។ ខ្ញុំនោះជាអ្នកមានសរ គឺសេចក្តីសោកដកចោលហើយ ជាអ្នកមានចិត្តត្រជាក់កើតហើយ មានទុក្ខរលត់ហើយបពិត្រព្រះមហាមុនី ខ្ញុំលែងសោកស្តាយ លែងយំទួញហើយ ព្រោះស្តាប់ពាក្យរបស់លោក ។

នាងឧត្តរី បានស្តាប់ពាក្យសុភាសិតនោះ របស់តាបសជាសមណៈនោះហើយ ក៏ប្រដាប់បាត្រនិងចីវរ ចូលកាន់ផ្នួស លុះនាងឧត្តរីនោះ ចេញចាកផ្ទះចូលកាន់ផ្នួសហើយ ក៏ចេញអំពីស្រុក ដើរទៅកាន់ស្រុក កាន់និគមនិងរាជធានីទាំងឡាយ បានចម្រើនមេត្តាចិត្តដើម្បីកើតក្នុងព្រហ្មលោក ។ នាងឧត្តរី បានធ្វើមរណកាលក្នុងស្រុកឈ្មោះឧរុវេលៈ នាងឧត្តរីនោះ បានចម្រើនមេត្តាចិត្តដើម្បីកើតក្នុងព្រហ្មលោក ហើយញុំាងចិត្តឲ្យនឿយណាយ ក្នុងឥត្ថីភាព ក៏បានទៅកើតក្នុងព្រហ្មលោក ។

## ចប់ រឿងឧត្តរីប្រេតទី ១៣ ។

## ឧទ្ទាន

រឿងសង្សារមោចកប្រេត ( ប្រេតស្តមកើតរោគលឿង )

១ រឿងស្រីប្រេតជាមាតានៃព្រះសារីបុត្តត្ថេរ ១ រឿងនាងមត្តាប្រេត ( ដែលនៅរួមប្តីនៃនាងតិស្សា ) ១ រឿងនន្ទាប្រេត ១ រឿងមដ្ឋកុណ្ឌលីប្រេត ១ រឿងកណ្ហាប្រេត ១ រឿងធនបាលប្រេត ១ រឿងចូឡសេដ្ឋីប្រេត ១ រឿងអង្កុរប្រេត ១ រឿងនាងឧត្តរមាតុប្រេត ១ រឿងសុត្តប្រេត ១ រឿងកណ្ណមុណ្ឌប្រេត ១ រឿងឧព្វរីប្រេត ១ ។

**ចប់ ឧព្វរីវគ្គទី ២ ។**

# អដ្ឋកថា ឧព្វរីប្រេត

[ ២៥ ] *រឿងនាងឧព្វរីប្រេតនេះ មានពាក្យផ្តើមថា* **អហុ រាជា ព្រហ្ម-ទត្តោ** *ដូច្នេះជាដើម ។*

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធឧបាសិកាម្នាក់ បានឮមកថា ក្នុងក្រុងសាវត្ថី មានស្វាមីរបស់ឧបាសិកាម្នាក់ស្លាប់ទៅ ។ ឧបាសិកានោះ ក៏ក្តៅព្រោះសេចក្តីទុក្ខក្នុងការព្រាត់ប្រាសចាកប្តី សោយសោក ដើរយំទៅកាន់ព្រៃខ្មោច ។ ព្រះមានព្រះភាគ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិនៃសោតាបត្តិផល ទ្រង់មានព្រះទ័យត្រូវករុណាជាស់តឿន យាងទៅកាន់ផ្ទះរបស់នាង គង់លើអាសនៈដែលគេក្រាលហើយ ។ ឧបាសិកា ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា ឧបាសិកា នាងសោយសោកឬ កាលនាងទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សោយសោក ព្រោះព្រាត់ប្រាសចាកប្តីជាទីស្រឡាញ់ ។ ព្រះសាស្តាបំណាងឲ្យនាងប្រាសចាកសេចក្តីសោក ទើបនាំអតីតនិទានមកថា*

*ក្នុងអតីតកាល ក្នុងកបិលនគរ ដែនបញ្ចាល មានព្រះរាជាមួយអង្គព្រះនាមចូឡនីព្រហ្មទត្ត ទ្រង់លះនូវអគតិ ត្រេកអរក្នុងការធ្វើប្រយោជន៍ដល់មហាជនក្នុងដែនរបស់ព្រះអង្គ ទ្រង់មិនឲ្យរាជធម៌ ១០ វិនាសឡើយ ហើយគ្រងរាជសម្បត្តិ ។ សម័យមួយ ទ្រង់មានបំណាងនឹងស្តាប់ថា ក្នុងដែនរបស់ព្រះអង្គមានមនុស្សនិយាយអ្វីខ្លះ ទើបក្លែងខ្លួនជាជាងតម្បាញ ទ្រង់ត្រាច់ទៅមិនមានសម្មាញ់ ចេញអំពីព្រះនគរ ត្រាច់ទៅអំពីស្រុកដល់ស្រុក អំពីជន*

បទដល់ជនបទ ទ្រង់ឃើញដែនទូទៅ មិនមានចម្រូងចម្រាស មិនមានការបៀតបៀន ពួកមនុស្សរដេកមិនចាំបាច់បិទទ្វារ ទ្រង់កើតសោមនស្ស ទើបយាងត្រឡប់មកកាន់ព្រះនគរ យាងចូលទៅកាន់ផ្ទះ របស់ស្រីមេម៉ាយក្រីក្រម្នាក់ក្នុងភូមិ ១ នាងឃើញព្រះរាជា សួរថា អ្នកជានរណា មកអំពីណា ព្រះរាជាត្រាស់ថា នែនាង ខ្ញុំជាជាងតម្បាញ ដើរស៊ីឈ្នួលធ្វើការត្បាញសំពត់ បើនាងមានកិច្ចក្នុងការត្បាញសំពត់ ចូរនាងឲ្យអាហារនិងថ្លៃឈ្នួល ខ្ញុំនឹងធ្វើការឲ្យនាង ។ ស្រីមេម៉ាយ ពោលថា ខ្ញុំមិនមានការងារ ឬថ្លៃឈ្នួលឡើយ សូមអ្នកធ្វើការឲ្យអ្នកដទៃចុះ ព្រះរាជាគង់នៅក្នុងទីនោះ ២-៣ ថ្ងៃ ទ្រង់ឃើញកូនស្រីរបស់នាង ដល់ព្រមដោយលក្ខណៈរបស់អ្នកមានបុណ្យ មានសិរី ទើបត្រាស់នឹងមាតារបស់នាងថា ស្រីនេះមានអ្នកដទៃហួងហែងឬនៅហ្ន៎ បើមិនទាន់មាននរណាហួងហែង សូមនាងឲ្យស្រីនេះដល់ខ្ញុំ ខ្ញុំអាចធ្វើនូវឧបាយជាគ្រឿងចិញ្ចឹមជីវិតតាមសប្បាយដល់ពួកនាងបាន ស្រីមេម៉ាយនោះទទួលពាក្យថា សាធុ ហើយបានឲ្យធីតាដល់ព្រះរាជា ។

ព្រះរាជាទ្រង់នៅជាមួយនាង ២-៣ ថ្ងៃ ទើបព្រះរាជទានទ្រព្យ ១០០០ កហាបណៈដល់នាង ហើយត្រាស់ថា ២-៣ ថ្ងៃទៀត ខ្ញុំនឹងត្រឡប់មកវិញ នែនាង នាងកុំអផ្សុកថ្វីឡើយ ដូច្នេះហើយ ទើបយាងទៅកាន់ព្រះនគររបស់ព្រះអង្គ ទ្រង់ឲ្យគេធ្វើផ្លូវចន្លោះពីព្រះនគរ មកកាន់ភូមិនោះឲ្យរាបស្មើ ឲ្យតុបតែងលម្អ ហើយយាងទៅទីនោះដោយរាជានុភាពធំ បានតាំងទារិកានោះក្នុងគំនរកហាបណៈ ឲ្យងូតដោយទឹកក្រអូបដែលដាក់ក្នុង ក្អមមាស ក្អមប្រាក់

ហើយតាំងព្រះនាមថ្មីឲ្យថា ឧព្វរី ទ្រង់ស្ថាបនាទុក ក្នុងតំណែងអគ្គមហេសី ហើយបានប្រទានស្រុកនោះ ដល់ពួកញាតិរបស់នាង ហើយនាំនាងមកកាន់ព្រះនគរដោយរាជានុភាពធំ ទ្រង់អភិរម្យជាមួយនាង សោយនូវវជ្ជសុខរហូតអស់ព្រះជន្ម ។ ក្នុងទីបំផុតនៃអាយុ ព្រះរាជាក៏សោយទិវង្គត ។ កាលព្រះរាជាសោយទិវង្គតហើយ ធ្វើការថ្វាយព្រះភ្លើងព្រះសពស្រេចហើយ ព្រះនាងឧព្វរីមានហឫទ័យដល់ព្រមដោយសរ គឺសេចក្ដីសោក ព្រោះព្រាត់ប្រាសចាកព្រះស្វាមី ទៅកាន់ឈាបនដ្ឋាន បូជាសក្ការៈ មានគ្រឿងក្រអូបនិងផ្កា ជាដើម ច្រើនថ្ងៃ ប្រារព្ធដល់ព្រះគុណព្រះរាជា យំរៀបរាប់ដូចមនុស្សឆ្កួត ធ្វើប្រទក្សិណឈាបនដ្ឋាន ។

សម័យនោះ ព្រះមានព្រះភាគនៃយើង ទ្រង់ជាព្រះពោធិសត្វ បួសជាឥសី សម្រេចឈាននិងអភិញ្ញា នៅក្នុងដងព្រៃមួយកន្លែងក្បែរព្រៃហិមពាន្ត ឃើញនាងឧព្វរីដល់ព្រមដោយសរ គឺសេចក្ដីសោកដោយទិព្វចក្ខុ ហោះមកតាមអាកាសប្រាកដរូបឲ្យឃើញ ឈរនៅលើអាកាសនោះឯងសួរពួកមនុស្សក្នុងទីនោះថា នេះជាឈាបនដ្ឋានរបស់អ្នកណា ហើយស្រីនេះ យំទួញថា ព្រហ្មទត្ត ព្រហ្មទត្ត តើត្រូវការព្រហ្មទត្តមួយណា ។ ពួកមនុស្សបានស្ដាប់ដូច្នោះ នាំគ្នាពោលថា ព្រះរាជាដែនបញ្ចាលព្រះនាមថាព្រហ្មទត្ត ទ្រង់សោយទិវង្គត ក្នុងកាលអស់ព្រះជន្មាយុ នេះជាឈាបនដ្ឋានរបស់ទ្រង់ នេះជាអគ្គមហេសីឈ្មោះឧព្វរីរបស់ព្រះអង្គ កំពុងយំសោករៀបរាប់ដល់ព្រះនាមរបស់ព្រះរាជាថា ព្រហ្មទត្ត ព្រហ្មទត្ត ដូច្នេះ ។ ព្រះសង្គីតិកាចារ្យទាំងឡាយកាល

សម្តែងសេចក្តីនោះទើបពោលគាថា ៦ ថា

ស្តេចរបស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល ទ្រង់ព្រះនាមព្រហ្មទត្ត ព្រះអង្គប្រសើរក្នុងរាជសម្បត្តិ លុះដល់ថ្ងៃនិងយប់កន្លងទៅ ស្តេចក៏ទ្រង់សោយទិវង្គត ។ អគ្គមហេសីរបស់ស្តេចនោះ ឈ្មោះនាងឧព្វរី បានទៅកាន់ទីស្មសានហើយទ្រង់ព្រះកន្សែង កាលមិនឃើញស្តេចព្រហ្មទត្ត ក៏ទ្រង់ព្រះកន្សែងថាឱព្រះបាទព្រហ្មទត្ត ។ ឥសីជាអ្នកប្រាជ្ញបរិបូណ៌ដោយចរណៈ បានមកក្នុងទីដែលនាងឧព្វរីឈរនោះ ឥសីនោះបានសួរពួកជន ដែលមកជួបជុំក្នុងទីនោះថា ចុះទីស្មសាននេះដែលផ្សាយទៅដោយក្លិនក្រអូបផ្សេងៗ តើរបស់នរណា ស្រីនេះជាភរិយារបស់នរណាកំពុងកន្ទក់កន្ទេញរកប្តី ដែលទៅឆ្ងាយអំពីមនុស្សលោកនេះ កាលមិនឃើញព្រះបាទព្រហ្មទត្ត ក៏កន្ទក់កន្ទេញថា ឱព្រះបាទព្រហ្មទត្ត ។

ពួកជនដែលមកជួបជុំគ្នាក្នុងទីនោះ ក៏បានឆ្លើយថា បពិត្រមហាឥសីដ៏ចម្រើន ( ទីស្មសាននេះ ) របស់ព្រះបាទព្រហ្មទត្ត បពិត្រមហាឥសីអ្នកនិទុក្ខ ( ស្រីនេះជាភរិយា ) របស់ព្រះបាទព្រហ្មទត្ត ទីស្មសាននេះ របស់ព្រះបាទព្រហ្មទត្តនោះ ដែល ផ្សាយទៅដោយក្លិនក្រអូបផ្សេងៗ ស្រីនេះជាភរិយារបស់ព្រះបាទព្រហ្មទត្តនោះ កន្ទក់កន្ទេញរកប្តីដែលទៅឆ្ងាយ

អំពីមនុស្សលោកនេះហើយ កាលមិនឃើញព្រះបាទព្រហ្មទត្ត
ក៏កន្ទក់កន្ទេញថា ឱព្រះបាទព្រហ្មទត្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហុ** ប្រែថា មានហើយ ។ បទថា **បញ្ចាលានំ** បានដល់ អ្នកដែនបញ្ចាល ឬបានដល់ បញ្ចាលរដ្ឋនោះឯង ។ ពិតហើយ ជនបទមួយ គេសម្ដែងចេញដោយពាក្យជាច្រើនថា **បញ្ចាលានំ** ដោយជាពាក្យគ្រោមភាសា ដោយអំណាចព្រះរាជកុមារអ្នកជនបទ ។ បទថា **រថេសភោ** សេចក្ដីថា ជាធំក្នុងរថ គឺមានរថធំ ។ បទថា **តស្ស អាឡាហនំ** បានដល់ ស្ថានទីដែលថ្វាយព្រះភ្លើងព្រះសរីរៈរបស់ព្រះរាជាអង្គនោះ ។

បទថា **ឥសិ** សេចក្ដីថា ឈ្មោះថា ឥសី ព្រោះអត្ថថា ស្វែងរកគុណមានឈានជាដើម ។ បទថា **តត្ថ** បានដល់ ក្នុងទីជាទីប្រថាប់របស់ព្រះនាងឧត្តរីនោះ គឺក្នុងឈាបនដ្ឋាន ។ បទថា **អាគច្ឆិ** ប្រែថា បានមកហើយ ។ បទថា **សម្បន្នចរណោ** សេចក្ដីថា ដល់ព្រម គឺប្រកបដោយគុណ គឺចរណៈ ១៥ ប្រការ មានសីលសម្បទា ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ជាអ្នកភ្ញាក់រឭករឿយៗ ព្រះសទ្ធម្ម ៧ ប្រការ មានសទ្ធា ជាដើម និងរូបាវចរជ្ឈាន ៤ ប្រការ ។ បទថា **មុនិ** សេចក្ដីថា ឈ្មោះថា **មុនិ** ព្រោះដឹង គឺដឹងច្បាស់នូវប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ។ បទថា **សោ ច តត្ថ អបុច្ឆិត្ថ** សេចក្ដីថា តាបសនោះ បានសាកសួរដល់អ្នកដែលនៅក្នុងទីនោះ ។ បទថា **យេ តត្ថ សុសមាគតា** បានដល់ ពួកមនុស្សមកប្រជុំគ្នាក្នុងឈាបនដ្ឋាននោះ ។ បទថា **សុ** ត្រឹមតែជានិបាត ។

ម្យ៉ាងទៀត បាលីថា **យេ តត្ថាសុំ សមាគតា** ដូច្នេះក៏មាន ។ បទថា **អាសុំ** ប្រែថា មានហើយ ។

បទថា **នានាគន្ធសមេរិតំ** សេចក្ដីថា មានក្លិនក្រអូប ច្រើនប្រភេទផ្សាយទៅដោយជុំវិញ ។ បទថា **ឥតោ** ប្រែថា អំពីមនុស្សលោក ។ ដោយពាក្យថា **ទូរគតំ** ឥសីពោលព្រោះភាពដែលព្រះបាទព្រហ្មទត្តយាងទៅកាន់បរលោក ។ បទថា **ព្រហ្មទត្តាតិ កន្ទតិ** សេចក្ដីថា ព្រះនាងហៅដោយអំណាចការយំរៀបរាប់ដោយប្រារព្ធដល់ឈ្មោះយ៉ាងនេះថា ព្រហ្មទត្ត ព្រហ្មទត្ត ។

បទថា **ព្រហ្មទត្តស្ស កទ្ទន្តេ ព្រហ្មទត្តស្ស មារិស** អធិប្បាយថា បពិត្រមហាមុនីមានកាយ និងចិត្តរបស្រឡះ ជាអ្នកនិទុក្ខ នេះជាព្រះសុវណ្ណមេរុរបស់ព្រះបាទព្រហ្មទត្ត ស្រីនេះជាអគ្គមហេសីរបស់ព្រះបាទព្រហ្មទត្តនោះឯងសូមសេចក្ដីចម្រើនមានដល់លោក និងសូមមានដល់ព្រះបាទព្រហ្មទត្ត ប្រយោជន៍និងសេចក្ដីសុខរមែងមានដល់បុគ្គលជាធំបែបនោះដែលស្ថិត នៅក្នុងបរលោកដោយការគិតដល់ជានិច្ចនូវហិតប្រយោជន៍ ។ លំដាប់នោះ តាបសកាលស្ដាប់ពាក្យរបស់មនុស្សទាំងនោះហើយដោយអាស្រ័យសេចក្ដីអនុគ្រោះទើបទៅកាន់សម្នាក់របស់ព្រះនាងឧព្វរីដើម្បីបន្ទោបង់នូវសេចក្ដី សោករបស់ព្រះនាងទើបពោលគាថាថា

ស្ដេចទាំងឡាយ ៨៦.០០០ ព្រះអង្គ សុទ្ធតែឈ្មោះព្រះបាទ
ព្រហ្មទត្តត្រូវគេដុតក្នុងទីស្មសាននេះដែរ បណ្ដាស្ដេចព្រហ្មទត្ត

ទាំងនោះ តើនាងសោកស្តាយ រកស្តេចព្រហ្មទត្ត អង្គណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆឡាសីតិសហស្សានិ** សេចក្តីថា រាប់បាន ៨៦០០០ អង្គ ។ បទថា **ព្រហ្មទត្តស្សនាមកា** បានដល់ មានឈ្មោះយ៉ាងនេះថា ព្រហ្មទត្ត ។ បទថា **តេសំ កតមន្តុសោចសិ** សេចក្តីថា ព្រះនាងទ្រង់ព្រះកន្សែងដល់ព្រះបាទព្រហ្មទត្តអង្គណា បណ្តាព្រះបាទព្រហ្មទត្តទាំង ៨ ម៉ឺន ៦ ពាន់អង្គនោះ ។ តាបសសួរថា ព្រះនាងកើតសេចក្តីសោកព្រោះអាស្រ័យព្រះបាទព្រហ្មទត្តអង្គណា ។

ព្រះនាងឧព្វរី ត្រូវឥសីសួរហើយយ៉ាងនេះ កាលនឹងប្រាប់ដល់ព្រះបាទព្រហ្មទត្តដែលខ្លួនបំណងទើបពោលថា

បពិត្រលោកដ៏ចម្រើន ស្តេចអង្គណារបស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល ជារាជបុត្តនៃព្រះបាទចូឡនី ព្រះអង្គប្រសើរក្នុងរាជសម្បត្តិ ខ្ញុំសោកស្តាយរកស្តេចអង្គនោះ ជាកស្តា ( របស់ខ្ញុំ ) ជាអ្នកឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចូឡនីបុត្តោ** បានដល់ ព្រះឱរសរបស់ព្រះរាជាដែលមានព្រះនាមយ៉ាងនោះ ។ បទថា **សព្វកាមទំ** បានដល់ ទ្រង់ប្រទានរបស់ទាំងពួងដែលគួរប្រាថ្នាដល់ខ្ញុំ ឬឲ្យវត្ថុដែលសព្វសត្វត្រូវការ ។

កាលព្រះនាងឧព្វរីពោលយ៉ាងនេះហើយ តាបសក៏ពោល ២ គាថាថា

ពួកស្តេចទាំងអស់ សុទ្ធតែឈ្មោះព្រហ្មទត្ត ពួកស្តេចទាំងអស់

របស់ពួកជនអ្នកនៅក្នុងដែនបញ្ចាល សុទ្ធតែជារាជបុត្តនៃព្រះ
បាទចូឡនី ព្រះអង្គប្រសើរក្នុងរាជសម្បត្តិ នាងបានជាមហេ-
សីរបស់ពួកស្តេចទាំងអស់តាមលំដាប់មក ហេតុអ្វីបានជានាង
លះចោលពួកស្តេចជាន់មុន ហើយមកសោកស្តាយតែស្តេច
ជាន់ក្រោយវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វេវាហេសុំ** សេចក្តីថា ព្រះរាជាទាំង នោះ គឺទាំង ៨៦០០០ អង្គ សុទ្ធតែជាព្រះឱរសរបស់ព្រះបាទចូឡនី ព្រះនាមថា ព្រហ្មទត្ត ជាធំក្នុងដែនបញ្ចាល សេចក្តីវិសេស មានភាពជាព្រះរាជា ជាដើមនេះ មិនមានដល់ព្រះរាជាសូម្បីមួយអង្គក្នុងព្រះរាជាទាំងនោះ ។

បទថា **មហេសិត្តមការយិ** សេចក្តីថា នាងបានជាអគ្គមហេសីរបស់ស្តេចទាំងនោះតាមលំដាប់ អធិប្បាយថា ដោយលំដាប់ ។ បទថា **កស្មា** តាបសសួរថា នាងវៀរព្រះរាជាអង្គមុនៗ បណ្តាព្រះរាជាទាំងនេះដែលមិនប្លែកគ្នាដោយគុណ និងដោយជាព្រះស្វាមី ព្រះនាងបែរជា មកសោយព្រះកន្សែងដល់ព្រះរាជាអង្គក្រោយមួយអង្គប៉ុណ្ណោះ ព្រោះហេតុអ្វី គឺដោយហេតុអ្វី ។

ព្រះនាងឧព្វរី បានស្តាប់ដូច្នោះហើយ កើតសេចក្តីសង្វេគ ទើបពោលគាថានឹងតាបសទៀតថា

បពិត្រលោកអ្នកនិរទុក្ខ លោកពោលជាច្រើនដងហើយថានាង
ឯងជាមហេសីនៃស្តេច ( ទាំងពួង ) ក្នុងសង្សារចំពោះខ្ញុំ

ដែលកើតជាស្រីណា ខ្លួនរបស់ខ្ញុំដែលកើតជាស្រីនោះ ( ធ្លាប់កើតជាស្រី ) អស់កាលដ៏យូរ ( ឬក៏ធ្លាប់កើតជាប្រុសដែរ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាតុមេ** គឺកាលខ្លួន ( ខ្ញុំ ) ។ បទថា **ឥត្ថិភូតាយ** ប្រែថា កើតជាមនុស្សស្រី ។ បទថា **ទីឃរត្តាយ** ប្រែថា អស់កាលយូរ ពិតហើយ ក្នុងសេចក្ដីនេះ មានអធិប្បាយដូច្នេះថា ខ្ញុំកើតជាស្រីជាស្រីរហូតអស់កាលប៉ុណ្ណោះឬ ឬកើតជាបុរសខ្លះ ។ បទថា **យស្សា មេ ឥត្ថិភូតាយ** សេចក្ដីថា បពិត្រព្រះមហាមុនី លោកពោលដល់ គឺពោលដល់កាលដែលខ្ញុំជាស្រី ជាមហេសីក្នុងសង្សារច្រើនដល់ម្ល៉េះ ។ ម្យ៉ាងទៀតបាលីថា **អាហុ មេ ឥត្ថិភូតាយ** ដូច្នេះក៏មាន ។ បណ្ដាបទទាំងនោះ សព្ទថា **អា** ជានិបាត ប្រើក្នុងអនុស្សរណត្ថៈ ។ បទថា **អាហុ មេ** សេចក្ដីថា ខ្ញុំឯងបានរឭកដល់ គឺបានដឹងទូទៅដល់សេចក្ដីនេះ មានវាចាប្រកបសេចក្ដីថា ខ្ញុំជាស្រី គឺកើតជាស្រី ខ្ញុំកើតទៅមកៗ អស់កាលមានប្រមាណប៉ុណ្ណោះ ដោយអាការយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះខ្ញុំជាស្រី លោកធ្វើខ្ញុំឲ្យជាមហេសីរបស់ព្រះរាជាគ្រប់អង្គដោយលំដាប់ បពិត្រមហាមុនី លោកបានពោលដល់ខ្ញុំក្នុងសង្សារជាច្រើនឬ ។

តាបសកាលបានស្ដាប់ដូច្នោះហើយ កាលនឹងសម្ដែងថា ការកំណត់ពិតប្រាកដនេះ មិនមានក្នុងសង្សារថា ស្រីក៏ត្រូវជាស្រី ប្រុសក៏ត្រូវជាប្រុសនោះឡើយ ទើបពោលគាថាថា

នាងឯង ជួនកាលកើតជាស្រី ជួនកាលកើតជាប្រុស មិនតែប៉ុណ្ណោះ ជួនកាលបានទៅកាន់កំណើតបសុសត្វ កាលបើយ៉ាងនេះ ទីបំផុត ( នៃអត្តភាពទាំងឡាយ ) ដែលកន្លងទូវឥត្ថីភាពនិងបុរិសភាពនុ៎ះ រមែងមិនប្រាកដឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហុ ឥត្ថី អហុ បុរិសោ** សេចក្ដីថា ជួនកាល នាងកើតជាស្រី ជួនកាល នាងក៏ជាប្រុស និងជាប្រុសឬស្រីតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ដោយពិត កើតក្នុងកំណើតបសុសត្វ គឺជួនកាល ក៏ទៅកាន់ភាវៈជាបសុសត្វ ជួនកាល ក៏ទៅកើតជាសត្វតិរច្ឆាន ។ បទថា **ឯវ-មេតំ អតីតានំ បរិយន្តោ ន ទិស្សតិ** សេចក្ដីថា ក្នុងទីបំផុតនៃអត្តភាពដែលជាអតីតដែលកើតជាស្រី ជាប្រុស និងជាសត្វតិច្ឆានជាដើម យ៉ាងនេះ គឺតាមដែលពោលហើយនេះ រមែងមិនប្រាកដ ដល់បុគ្គលអ្នកឃើញដោយញាណចក្ខុ គឺដោយភាពឧស្សាហ៍ធំសម្រាប់ព្រះអង្គ គឺតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន ដោយពិត ទីបំផុតនៃអត្តភាពរបស់សត្វ ដែលអន្ទោលទៅមកក្នុងសង្សាររមែងមិនប្រាកដ គឺដឹងមិនបាននោះឯង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា

ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតគេមិនអាចដឹងបាន គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅមិនប្រាកដឡើយ ដូច្នេះ ។

ព្រះមហេសី បានស្តាប់ធម៌ដែលតាបសនោះសម្តែងអំពីសង្សារដែលមិនមានទីបំផុតនិងភាពដែលសត្វមានកម្មជារបស់ខ្លួន សម្តែងទុកហើយយ៉ាងនេះ មានហឫទយៈសង្វេគក្នុងសង្សារនិងមានចិត្តជ្រះថ្លាក្នុងធម៌ ប្រាសចាកកូនសរ គឺសេចក្តីសោក កាលនឹងប្រកាសសេចក្តីជ្រះថ្លានិងប្រាសចាកសេចក្តីសោករបស់ខ្លួន ទើបពោលគាថា ៣ ថា

លោកបានស្រោចស្រពខ្ញុំដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ សព្វឲ្យស្ងប់រម្ងាប់បាន ហើយញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងពួងឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចរលត់ភ្លើងកំពុងឆេះនូវថ្នាំងខ្លាញ់ លោកណា បានបន្ទោបង់នូវសេចក្តីសោកព្រោះប្តីចំពោះខ្ញុំដែលមានសេចក្តីសោកកំពុងគ្របសង្កត់ លោកនោះឈ្មោះថា បានដកនូវសរ គឺសេចក្តីសោកដែលអាស្រ័យនូវហឫទ័យរបស់ខ្ញុំ ។ ខ្ញុំនោះ ជាអ្នកមានសរ គឺសេចក្តីសោកដកចោលហើយ ជាអ្នកមានចិត្តត្រជាក់កើតហើយ មានទុក្ខរលត់ហើយ បពិត្រព្រះមហាមុនី ខ្ញុំលែងសោកស្តាយ លែងយំទួញហើយ ព្រោះស្តាប់ពាក្យរបស់លោក ដូច្នេះ ។

អត្ថនៃគាថានោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។

ឥឡូវនេះ ព្រះសាស្តា កាលទ្រង់សម្តែងបដិបទារបស់ព្រះនាងឧត្តរីដែលមានព្រះទ័យសង្វេគ ទើបត្រាស់គាថា ៤ ថា

នាងឧត្តរីបានស្តាប់ពាក្យសុភាសិតនោះ របស់តាបសជាស-

មណៈនោះហើយ ក៏ប្រដាប់បាត្រនឹងចីវរចូលកាន់ផ្នួស លុះនាងឧព្វរីនោះ ចេញចាកផ្ទះចូលកាន់ផ្នួសហើយ ក៏ចេញអំពីស្រុកដើរទៅកាន់ស្រុក កាន់និគមនិងរាជធានីទាំងឡាយ បានចម្រើនមេត្តាចិត្តដើម្បីកើតក្នុងព្រហ្មលោក ។ នាងឧព្វរីបានធ្វើមរណកាលក្នុងស្រុកឈ្មោះឧរុវេលៈ នាងឧព្វរីនោះ បានចម្រើនមេត្តាចិត្តដើម្បីកើតក្នុងព្រហ្មលោក ហើយញុំាងចិត្តឲ្យនឿយណាយ ក្នុងឥត្ថីភាព ក៏បានទៅកើត ក្នុងព្រហ្មលោកដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តស្ស** បានដល់ តាបសនោះ ។ បទថា **សុភាសិតំ** បានដល់ ពាក្យដែលជាសុភាសិត អធិប្បាយថា នូវធម៌ ។ បទថា **បព្វជិតា សន្តា** បានដល់ ចូលដល់បព្វជ្ជាឬបួសហើយ ជាអ្នកមានកាយវាចាស្ងប់ ។ បទថា **មេត្តចិត្តំ** នេះ ព្រះនាងឧព្វរីពោលដល់ចិត្តដែលកើតព្រមដោយមេត្តា គឺឈានដែលមានមេត្តាជាអារម្មណ៍ ដោយលើកឡើងជាប្រធាន ។ បទថា **ព្រហ្មលោកូបបត្តិយា** សេចក្ដីថា ព្រះនាងកាលចម្រើនមេត្តាចិត្តនោះ ក៏ចម្រើនដើម្បីចូលដល់ព្រហ្មលោក មិនមែនជាបាទនៃវិបស្សនាជាដើម ។ ពិតហើយ កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើង តាបសនិងបរិព្វាជកចម្រើនធម៌ មានព្រហ្មវិហារជាដើម ក៏ចម្រើនដើម្បីភវសម្បត្តិប៉ុណ្ណោះ ។

បទថា **គាមា គាមំ** បានដល់ ចេញអំពីស្រុកមួយចូលទៅកាន់ស្រុក

មួយ ។ បទថា **អាភាវេត្វា** ប្រែថា ចម្រើនហើយ គឺធ្វើឲ្យច្រើនហើយ ។ អាចារ្យពួកខ្លះពោលថា **អភាវេត្វា** ដូច្នេះក៏មាន ។ **អ** អក្សរ នៃបទថា **អភាវេត្វា** នៃអាចារ្យពួកខ្លះនោះ ត្រឹមតែជានិបាត ។ បទថា **ឥត្ថិចិត្តំ វិរាជេត្វា** សេចក្តីថា ប្រាសចាកការគិត គឺការមានអធ្យាស្រ័យ បានដល់ការពេញចិត្តក្នុងភាពជាស្រី គឺជាអ្នកមានចិត្តប្រាសចាកការត្រេកអរក្នុងភាពជាស្រី ។ បទថា **ព្រហ្មលោកូបគា** សេចក្តីថា បានជាអ្នកចូលដល់ព្រហ្មលោកដោយបដិសន្ធិ ។ ពាក្យដ៏សេសងាយយល់ទាំងអស់ហើយ ព្រោះមានន័យដូចពោលហើយខាងដើម ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បានធ្វើសេចក្តីសោករបស់ឧបាសិកានោះ ឲ្យជាចតុសច្ចទេសនាខាងលើ ។ ក្នុងកាលចប់សច្ចៈ ឧបាសិកានោះតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាមានប្រយោជន៍ដល់បរិស័ទដែលដល់ព្រមហើយដោយប្រការដូច្នេះ ។

**អដ្ឋកថា ឧព្វរីប្រេតចប់**

**ឧព្វរីវគ្គទី ២ ប្រដាប់ដោយរឿង ១៣**

**នៃអដ្ឋកថាខុទ្ទកនិកាយបេតវត្ថុ ចប់**

# ចូឡវគ្គទី៣

## រឿង អភិជ្ជមានប្រេតទី១

[ ២៦ ] ( កោលិយមហាមាត្យពោលថា ) អ្នកឯងជាប្រេតអាក្រាត តែពាក់កណ្ដាលកាយខាងលើជាអ្នកទ្រទ្រង់នូវកម្រងផ្កា គាក់តែងក្បាល ដើរលើទឹកទន្លេគង្គាមិនបែកខ្ញែកក្នុងទីនេះ ម្នាលប្រេត តើអ្នកនឹងទៅក្នុងស្រុកណា ទីនៅរបស់អ្នកនឹងមានក្នុងទីណា ។

ប្រេតនោះ បាននិយាយថា ខ្ញុំនឹងទៅស្រុកចុន្ទដ្ឋិលៈ ត្រង់ចន្លោះជិតស្រុកវាសកៈនិងក្រុងពារាណសី ។

ឯមហាមាត្យដែលល្បីឈ្មោះថា កោលិយៈ បានឃើញប្រេតនោះហើយ ក៏ឲ្យសដូវនិងបាយផង ឲ្យសំពត់លឿង ១ គូផង ដល់ប្រេត ។ កាលដែលទូកឈប់ ( កោលិយមហាមាត្យ ) បានប្រើខ្ញាន់ព្រះកេសឲ្យឲ្យ ( សំពត់ ១ គូដល់ស្នូម ) កាលដែលសំពត់ ១ គូ ដែលខ្ញាន់ព្រះ កេសឲ្យហើយ សំពត់នោះ ក៏ប្រាកដដល់ប្រេតមួយរំពេច ។ លំដាប់នោះ ប្រេតក៏ស្លៀកពាក់សំពត់ដ៏ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាងខ្លួន ទក្ខិណាទាន ក៏សម្រេចដល់ប្រេតដែលឋិតនៅក្នុងទីគួរសម្រេច ព្រោះហេតុនោះ បុគ្គលគួរឲ្យទក្ខិណាទានរឿយៗដើម្បីអនុគ្រោះដល់ប្រេតទាំងឡាយ ។

( ព្រះសង្គីតិកាចារ្យទាំងឡាយពោលថា ) ពួកប្រេតខ្លះស្លៀកពាក់កំណាត់សំពត់ចាស់ដាច់ដាចជ្រុះជ្រាយ ពួកប្រេតដទៃបិទបាំង ( កេរ្ដិ៍ខ្មាស ) ដោយសក់ ពួកប្រេតរមែងទៅដើម្បីបាយ ចៀសចេញទៅអំពីទិសទៅកាន់ទិស ។ ពួកប្រេតខ្លះ ក៏ទៅក្នុងទីឆ្ងាយ ( ដើម្បីនឹងស៊ី ) លុះមិនបាន

ក៏ត្រឡប់មកវិញ ស្រេកឃ្លាន ដើរទៅជ្រុលជ្រក ដួលស្រុសលើផែនដីពួកសត្វមិនបាន ធ្វើអំពើល្អក្នុងភពមុន ( រមែងក្តៅក្រហាយ ) ដូចជាត្រូវភ្លើងឆេះក្នុងទីដ៏ក្តៅថា ក្នុងកាលពីដើមពួកយើងមានធមិដ៏លាមក ជាម្ចាស់ផ្ទះជាមាតានៃទារកក្នុងត្រកូល ទោយព្រធមិទាំងឡាយមានគ្រប់គ្រាន់ តែពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ព្រោះថា ពួកយើងចាក់ចោលគ្រឿងស៊ីនិងគ្រឿងផឹកដ៏ច្រើន កាលដែលមានបព្វជិតប្រតិបត្តិត្រឹមត្រូវពួកយើងមិនបានប្រគេនវត្ថុបន្តិចបន្តួចសោះឡើយ ។ ពួកយើងស្រឡាញ់តែអកុសលកម្ម ជាអ្នកខ្ជិលប្រអូស ចំណូលតែវត្ថុឆ្ងាញ់ ជាអ្នកស៊ីច្រើន ឲ្យដុំភោជនត្រឹមតែមួយពំនូត តែងតិះដៀលចំពោះពួកជនអ្នកទទួល ។ ផ្ទះទាំងនោះ ទាសីទាំងនោះគ្រឿងអាភរណៈទាំងនោះ ជារបស់យើង ( ឥឡូវនេះ ) បានទៅពួកអ្នកដទៃប្រើប្រាស់របស់នោះ ឯពួកយើងបានតែចំណែកនៃសេចក្តីទុក្ខម្យ៉ាង ពួកជនដែលត្រូវគេមើលងាយរឿយៗ គឺជាងផែង ១ ជាងរថ ១ អ្នកទ្រុស្តមិត្ត ១ចណ្ឌាល ១ ជនកំព្រា ១ អ្នកកាត់កោរ ១ ។ ត្រកូលទាំងឡាយណាៗថោកទាបផង កំព្រាផង ( ពួកសត្វមិនបានធ្វើបុណ្យ ) តែងទៅកើតក្នុងត្រកូលទាំងឡាយនោះៗ នេះជាគតិនៃជនអ្នកកំណាញ់ ។ ពួកជនបានធ្វើអំពើល្អក្នុងកាលមុន ជាទាយកអ្នកប្រាសចាកសេចក្តីកំណាញ់ ពួកជននោះឈ្មោះថា ញុំាងឋានសួគ៌ឲ្យពេញលេញផង ឈ្មោះថា ញុំាងព្រៃនន្ទនៈឲ្យរុងរឿងផង ។ ពួកជនទាំងនោះ ជាអ្នកបរិភោគកាមតាមប្រាថ្នា ត្រេកអរក្នុងប្រាសាទឈ្មោះវេជយន្ត លុះច្យុតចាកទេវលោកនោះហើយ ក៏បានមកកើតក្នុង

ត្រកូលខ្ពង់ខ្ពស់ទាំងឡាយដែលមានភោគៈ ។ ពួកជនទាំងនោះបានកើតក្នុងត្រកូលមានយស មានខ្លួនគេបក់ដោយផ្លិតស្លាបក្ងោកទាំងឡាយ លើបល្ល័ង្កដែលគេក្រាលដោយសំពត់គោណកៈក្នុងផ្ទះមានកំពូលនិងប្រាសាទ ។ ជាអ្នកទ្រទ្រង់នូវកម្រងផ្កាមានខ្លួនប្រដាប់ហើយទៅអំពីខ្លួនមួយទៅកាន់ខ្លួនមួយ ( នៃញាតិនិងកីលៀងទាំងឡាយ ) កីលៀងទាំងឡាយ ជាអ្នកស្វែងរកសេចក្តីសុខឲ្យ តែងបម្រើទាំងល្ងាចទាំងព្រឹក ។ នន្ទនៈមហាវ៉នរបស់ពួកទេវតានៅក្នុងឋានត្រៃត្រិង្ស មិនមានសោក ជាទីត្រេកអរ នេះមិនមែនរបស់ពួកជនមិនបានធ្វើបុណ្យឡើយ នេះជារបស់ពួកជនដែលបានធ្វើបុណ្យ ពួកជនដែលមិនបានធ្វើបុណ្យ មិនមានសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខឡើយ ឯពួកជនដែលបានធ្វើបុណ្យ រមែងមានសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខពិតប្រាកដ ។ ពួកជនដែលចង់កើតជាមួយនឹងពួកទេវតានោះ ត្រូវធ្វើបុណ្យឲ្យច្រើន ព្រោះពួកជនដែលបានធ្វើបុណ្យហើយ តែងបរិបូណ៌ដោយភោគៈ រមែងរីករាយក្នុងឋានសួគ៌ ។

## ចប់ រឿងអភិជ្ជមានប្រេតទី ១ ។

# ចូឡវគ្គ ទី ៣

## អដ្ឋកថា អភិជ្ជមានប្រេត

[ ២៦ ] កាលព្រះសាស្ដាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រានប្រេតម្នាក់ ទើបត្រាស់គាថានេះ មានពាក្យផ្ដើមថា **អភិជ្ជមានេ វារិម្ហិ** ដូច្នេះ ជាដើម ។

បានឮថា ក្នុងនគរពារាណសី មានព្រានព្រៃម្នាក់ នៅក្នុងស្រុកឈ្មោះចុន្ទដ្ឋិលៈ រំលងវាសកគាមនិងច្នេរស្ទឹងគង្គាមួយផ្នែក ។ ព្រានព្រៃបរបាញ់សត្វក្នុងព្រៃ អាំងសាច់បរិភោគ សាច់ដែលសល់ វេចខ្ចប់វែកមកផ្ទះ ពួកក្មេងៗ ឃើញគាត់ត្រង់ទ្វារស្រុក ក៏រត់មក លាដៃសូមថា សូមឲ្យសាច់ខ្ញុំ សូមឲ្យសាច់ខ្ញុំ គាត់បានឲ្យសាច់ដល់កុមារទាំងនោះម្នាក់បន្តិចៗ ។ ថ្ងៃមួយគាត់មិនបានសាច់ ក៏បេះផ្ការាជព្រឹក្ស[១]ប្រដាប់ខ្លួន ពួកក្មេងៗ ឃើញគាត់ត្រង់ទ្វារស្រុក ក៏រត់មក លាដៃសូមថា សូមឲ្យសាច់ខ្ញុំ សូមឲ្យសាច់ខ្ញុំ គាត់បានឲ្យផ្ការាជព្រឹក្សដល់កុមារទាំងនោះម្នាក់មួយទងៗ ។

សម័យតមក គាត់ធ្វើកាលកិរិយាហើយ កើតក្នុងពពួកប្រេត ជាអ្នកអាក្រាតកាយ មានរូបគួរខ្ពើម ឃើញហើយគួរខ្លាច មិនស្គាល់បាយនិងទឹកសូម្បីតែការយល់សប្តិ ទ្រទ្រង់នូវផ្ការាជព្រឹក្សនិងផ្កាកុសុមៈលើក្បាល គិតថា អញនឹងបានរបស់តិចតួចក្នុងសម្នាក់ពួកញាតិក្នុងចុន្ទដ្ឋិលគាម កាលទឹកក្នុងស្ទឹងគង្គាហូរមិនដាច់ខ្សែ ក៏ដើរប្រាស់ខ្សែទឹកទៅ ។ គ្រានោះ អាមាត្យរបស់ព្រះបាទពិម្ពិសារឈ្មោះកោលិយៈ បង្ក្រាបបច្ចន្តជនបទដែលបះបោរឲ្យ

---

[១] - ក្នុងទីខ្លះថាផ្កាត្របែកព្រៃ ។

ស្ងប់រម្ងាប់ ហើយត្រឡប់មក ទើបបញ្ជូនពលបរិវារ មានពលដំរីនិងពលសេះជាដើមតាមផ្លូវគោក ខ្លួនឯងឡើងទូក ធ្វើដំណើរមកតាមស្ទឹងគង្គា ឃើញប្រេតនោះកំពុងដើរទៅយ៉ាងនោះ កាលសាកសួរ ទើបសួរដោយគាថាថា

អ្នកឯងជាប្រេតអាក្រាត តែពាក់កណ្តាលកាយខាងលើ ជាអ្នកទ្រទ្រង់នូវកម្រងផ្កា តាក់តែងក្បាល ដើរលើទឹកទន្លេគង្គា មិនបែកខ្ញែក ក្នុងទីនេះ ម្នាលប្រេត តើអ្នកនឹងទៅក្នុងស្រុកណា ទីនៅរបស់អ្នកនឹងមានក្នុងទីណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិជ្ជមានេ** បានដល់ មិនបែក គឺនៅជាដុំជាបន្ទុះដោយការដើរជាន់ ។ បទថា **វារិម្ហិ គង្គាយ** បានដល់ ទឹកក្នុងស្ទឹងគង្គា ។ បទថា **ឥធ** គឺក្នុងទីនេះ ។ បទថា **បុព្វឌ្ឍបេតោវ** សេចក្តីថា មានរាងកាយខាងមុខពាក់កណ្តាលមិនដូចប្រេត គឺដូចទេវបុត្ត មិនទាក់ទងក្នុងកំណើតប្រេត ដើម្បីចៀសវាងពាក្យសួរថា ដូចម្តេច ទើបលោកពោលថា ជាអ្នកទ្រទ្រង់នូវកម្រងផ្កា តាក់តែងក្បាល អធិប្បាយថា ប្រដាប់ដោយផ្កាលើក្បាល ។ បទថា **កត្ថ វាសោ ភវិស្សតិ** សេចក្តីថា ផ្ទះសម្បែងរបស់អ្នកនៅក្នុងស្រុកណា ឬក្នុងប្រទេសណា អ្នកចូរប្រាប់រឿងនោះ ។

ឥឡូវនេះ ដើម្បីសម្តែងពាក្យដែលប្រេតនោះនិងកោលិយអាមាត្យពោលក្នុងកាលនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយរចនាទុកថា

ប្រេតនោះ បាននិយាយថា ខ្ញុំនឹងទៅស្រុកចុន្ទដ្ឋិលៈ ត្រង់ចន្លោះជិតស្រុកវាសភៈនិងក្រុងពារាណសី ។

ឯមហាមាត្យដែលល្បីឈ្មោះថា កោលិយៈ បានឃើញប្រេតនោះហើយ ក៏ឲ្យសដូវនិងបាយផង ឲ្យសំពត់លឿង ១ គូផង ដល់ប្រេត ។ កាលដែលទូកឈប់ ( កោលិយមហាមាត្យ ) បានប្រើខ្ទាន់ព្រះកេសឲ្យ ឲ្យ ( សំពត់ ១ គូដល់ស្ទូម[១] ) កាលដែលសំពត់ ១ គូ ដែលខ្ទាន់ព្រះកេសឲ្យហើយ សំពត់នោះ ក៏ប្រាកដដល់ប្រេតមួយរំពេច ។ លំដាប់នោះប្រេត ក៏ស្លៀកពាក់សំពត់ដ៏ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាងខ្លួនទក្ខិណាទាន ក៏សម្រេចដល់ប្រេត ដែលឋិតនៅក្នុងទីគួរសម្រេច ព្រោះហេតុនោះបុគ្គលគួរឲ្យទក្ខិណាទានរឿយៗ ដើម្បីអនុគ្រោះដល់ប្រេតទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចុន្ទដ្ឋិលំ** បានដល់ ស្រុកដែលមានឈ្មោះយ៉ាងនោះ ។ បទថា **អន្តរេ វាសភគាមំ ពារាណសឹ ច សន្តិកេ** បានដល់ក្នុងវាងវាសភគាមនិងក្រុងពារាណសី ។ ពិតហើយ បទថា **អន្តរេ វាសភគាមំ ពារាណសឹ ច សន្តិកេ** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ព្រោះប្រកបដោយអន្តរាសព្ទ ។ ពិតហើយ ស្រុកនោះនៅក្នុងទីជិតក្រុងពារាណសី ។ ក្នុងសេចក្ដីនោះ មានអធិប្បាយដូច្នេះថា ក្នុងចន្លោះវាសភគាមនិងក្រុងពារាណសី ខ្ញុំនឹងទៅស្រុកឈ្មោះចុន្ទដ្ឋិលគាម មិនឆ្ងាយពីក្រុងពារាណសី ។

---

១ - កោលិយអាមាត្យឲ្យដល់ខ្ទាន់ព្រះកេស ( អដ្ឋកថា ) ។

បទថា **កោលិយោ ឥតិ វិស្សុតោ** បានដល់ មានឈ្មោះប្រាកដយ៉ាងនេះថា កោលិយៈ ។ បទថា **សត្តុំ ភត្តញ្ច** បានដល់ សដូវនិងភត្ត ។ បទថា **បីតកញ្ច យុគំ អទា** សេចក្តីថា បានឲ្យសំពត់មួយគូ ពណ៌លឿង គឺពណ៌ដូចមាស បើសួរថា បានឲ្យកាលណា ទើបពោលតបថា បានឲ្យក្នុងកាលដែលទូកឈប់ ។ បទថា **កប្បកស្ស អទាបយិ** មានវាចាប្រកប សេចក្តីថា បានបញ្ឈប់ទូកដែលកំពុងរសាត់ទៅ បានឲ្យដល់ឧបាសកដែលជាជាងកាត់សក់ម្នាក់ ក្នុងទីនោះ កាលកោលិយអាមាត្យឲ្យគូសំពត់នោះ ។ បទថា **ឋានេ** គឺដោយមួយរំពេច បានដល់ ក្នុងខណៈនោះឯង ។ បទថា **បេតស្ស ទិស្សថ** សេចក្តីថា បានប្រាកដក្នុងសរីរៈរបស់ប្រេត គឺសំពត់ស្លៀកនិងសំពត់ដណ្តប់ បានសម្រេចដល់ប្រេតនោះ ។ ដោយហេតុនោះ ទើបលោកពោលថា លំដាប់នោះ ប្រេតក៏ស្លៀកពាក់សំពត់ដ៏ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាងខ្លួន អធិប្បាយថា ស្លៀកដណ្តប់សំពត់ល្អហើយប្រដាប់តាក់តែងដោយអាភរណៈ គឺផ្កា ។ បទថា **ឋានេ ឋិតស្ស បេតស្ស ទក្ខិណា ឧបកប្បថ** សេចក្តីថា ព្រោះទក្ខិណានោះតាំងនៅក្នុងឋានៈ ដែលគួរដល់ទក្ខិណេយ្យបុគ្គល រមែងសម្រេច គឺបានដល់នូវការប្រកបជា ពិសេសដល់ប្រេតនោះ ។ បទថា **តស្មា ទជ្ជេថ បេតានំ អនុកម្បាយ បុនប្បុនំ** សេចក្តីថា គប្បីឲ្យទក្ខិណារឿយៗ ដើម្បីអនុគ្រោះប្រេត គឺដើម្បីឧទ្ទិសដល់ប្រេត ។

លំដាប់នោះ កោលិយមហាមាត្យ កាលនឹងអនុគ្រោះប្រេតនោះ ទើប

ឲ្យសម្រេចទានវិធី មកតាមក្រសែទឹក កាលព្រះអាទិត្យរះឡើង បានដល់ក្រុងពារាណសី ។ ឯព្រះមានព្រះភាគ ទ្រង់យាងមកតាមអាកាសដើម្បីអនុគ្រោះប្រេតនោះ បានប្រថាប់ឈរត្រង់ឆ្នេរស្ទឹងគង្គា ឯកោលិយមហាមាត្យចុះអំពីទូកហើយ ត្រេកអររីករាយ និមន្តព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព ។ កោលិយមហាមាត្យនោះ បានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ទើបឲ្យសាងសាខាមណ្ឌបក្នុងភូមិភាគដែលគួរជាទីត្រេកអរក្នុងខណៈនោះឯង ឲ្យតាក់តែងដោយសំពត់ច្រើនប្រភេទ វិចិត្រដោយពណ៌ផ្សេងៗ ទាំងខាងលើនិងទទឹងៗ ទាំង ៤ ទិស បានឲ្យក្រាលអាសនៈថ្វាយដល់ព្រះមានព្រះភាគក្នុងទីនោះ ។ ព្រះមានព្រះភាគគង់គង់លើអាសនៈដែលតាក់តែងទុក ។

លំដាប់នោះ មហាមាត្យក៏ចូលទៅគាល់ព្រះមានព្រះភាគ បូជាដោយសក្ការៈ មានផ្កាកម្រងនិងគ្រឿងក្រអូបជាដើម លុះថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ហើយក្រាបទូលពាក្យដែលខ្លួនពោល និងពាក្យឆ្លើយរបស់ប្រេតខាងដើមដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ភិក្ខុសង្ឃចូរមក ។ ដំណាលគ្នានឹងព្រះតម្រិះនោះឯង ភិក្ខុសង្ឃដែលពុទ្ធានុភាពដាស់តឿន ក៏នាំគ្នាមកចោមរោមព្រះធម្មរាជា ដូចហ្វូងហង្សមាស នាំគ្នាចោមរោមស្តេចហង្សធតរដ្ឋ ។ ក្នុងខណៈនោះឯង មហាជននាំគ្នាប្រជុំដោយគិតថា នឹងមានព្រះធម្មទេសនាក្រៃលែង ។ មហាមាត្យឃើញ

ការប្រព្រឹត្តទៅនោះ មានចិត្តជ្រះថ្លា ទើបអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយនិងភោជនីយដ៏ប្រណីត ។ ព្រះមានព្រះភាគទ្រង់សោយព្រះក្រយាហារស្រេចហើយ ដើម្បីអនុគ្រោះមហាជនទើបទ្រង់អធិដ្ឋានថា ចូរអ្នកស្រុកក្បែរក្រុងពារាណសី មកប្រជុំគ្នាចុះ ។ មហាជនទាំងអស់នោះ បានប្រជុំគ្នាដោយកម្លាំងឫទ្ធិ ទ្រង់បានធ្វើប្រេតជាច្រើនឲ្យប្រាកដដល់មហាមាត្យ ។ បណ្តាប្រេតទាំងនោះ ប្រេតពួកខ្លះ ស្លៀកសំពត់ចាស់រិចរាយ ពួកខ្លះយក សក់របស់ខ្លួនបិទអវយវៈដែលធ្វើសេចក្តីខ្មាសឲ្យកម្រើក ពួកខ្លះអាក្រាតកាយ មានរូបដូចក្នុងពេលកើត ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ មានស្បែកស្រោប មានរាងកាយត្រឹមតែរាងឆ្អឹង ត្រាច់ទៅក្នុងទីផ្សេងៗ ប្រាកដដល់មហាជនដោយប្រចក្ស ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់តាក់តែងឥទ្ធាភិសង្ខារ គឺបណ្តាលដោយឫទ្ធិ ដោយប្រការដែលប្រេតទាំងនោះប្រជុំព្រមគ្នា ប្រកាសបាបកម្មដែលខ្លួនធ្វើដល់មហាជន ព្រះសង្គីតិកាចារ្យកាលសម្តែងសេចក្តីនោះ ទើបពោលគាថាទាំងឡាយថា

ពួកប្រេតខ្លះស្លៀកពាក់កំណាត់សំពត់ចាស់ ដាច់ដាចធ្លុះធ្លាយ
ពួកប្រេតដទៃបិទបាំង ( កេរ្តិ៍ខ្មាស ) ដោយសក់ ពួកប្រេត
រមែងទៅដើម្បីបាយ ចៀសចេញទៅអំពីទិសទៅកាន់ទិស ។
ពួកប្រេតខ្លះ ក៏ទៅក្នុងទីឆ្ងាយ ( ដើម្បីនឹងស៊ី ) លុះមិនបាន
ក៏ត្រឡប់មកវិញ ស្រេកឃ្លាន ដើរទៅជ្រុលជ្រក ដួលស្រុស

លើផែនដី ពួកសត្វមិនបានធ្វើអំពើល្អក្នុងភពមុន ( រមែងក្ដៅក្រហាយ ) ដូចជាត្រូវភ្លើងឆេះក្នុងទីដ៏ក្ដៅថា ក្នុងកាលពីដើមពួកយើងមានធម៌ដ៏លាមក ជាម្ចាស់ផ្ទះ ជាមាតានៃទារកក្នុងត្រកូល ទ្រព្យធម៌ទាំងឡាយមានគ្រប់គ្រាន់ តែពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ព្រោះថា ពួកយើងចាក់ចោលគ្រឿងស៊ីនិងគ្រឿងផឹកដ៏ច្រើន កាលដែលមានបព្វជិត ប្រតិបត្តិត្រឹមត្រូវពួកយើងមិនបានប្រគេនវត្ថុ បន្តិចបន្តួចសោះឡើយ ។ ពួកយើងស្រឡាញ់តែអកុសលកម្ម ជាអ្នកខ្ជិលច្រអូស ចំណូលតែវត្ថុឆ្ងាញ់ ជាអ្នកស៊ីច្រើន ឲ្យដុំកោជនត្រឹមតែមួយពំនូតតែងតិះដៀលចំពោះពួកជនអ្នកទទួល ។ ផ្ទះទាំងនោះទាសីទាំងនោះ គ្រឿងអាភរណៈទាំងនោះ ជារបស់យើង ( ឥឡូវនេះ ) បានទៅពួកអ្នកដទៃប្រើប្រាស់របស់នោះ ឯពួកយើងបានតែចំណែកនៃសេចក្ដីទុក្ខម្យ៉ាង ពួកជនដែលត្រូវគេមើលងាយរឿយៗ គឺ ជាងផែង ១ ជាងរថ ១ អ្នកទ្រុស្តមិត្ត ១ ចណ្ឌាល ១ ជនកំព្រា ១ អ្នកកាត់កោរ ១ ។ ត្រកូលទាំងឡាយណាៗ ថោកទាបផង កំព្រាផង ( ពួកសត្វមិនបានធ្វើបុណ្យ ) តែងទៅកើតក្នុងត្រកូលទាំងឡាយនោះៗនេះជាគតិនៃជនអ្នកកំណាញ់ ។ ពួកជនបានធ្វើអំពើល្អក្នុងកាលមុនជាទាយកអ្នកប្រាសចាក សេចក្ដីកំណាញ់ ពួកជន

នោះឈ្មោះថា ញុំាងឋានសួគ៌ ឲ្យពេញលេញផង ឈ្មោះថា ញុំាងព្រៃនន្ទនៈឲ្យរុងរឿងផង ។ ពួកជនទាំងនោះ ជាអ្នកបរិភោគកាមតាមប្រាថ្នា ត្រេកអរក្នុងប្រាសាទឈ្មោះវេជយន្ត លុះច្យុតចាកទេវលោកនោះហើយ ក៏បានមកកើតក្នុងត្រកូលខ្ពង់ខ្ពស់ទាំងឡាយដែលមានភោគៈ ។ ពួកជនទាំងនោះបានកើតក្នុងត្រកូលមានយស មានខ្នួនគេបក់ដោយផ្ចិតស្លាបក្ងោកទាំងឡាយ លើបល្ល័ង្ក ដែលគេក្រាលដោយសំពត់គោណកៈ ក្នុងផ្ទះមានកំពូលនិងប្រាសាទ ។ ជាអ្នកទ្រទ្រង់នូវកម្រងផ្កាមានខ្នួនប្រជាប់ហើយ ទៅអំពីខ្នួនមួយទៅកាន់ខ្នួនមួយ ( នៃញាតិនិងកីលៀងទាំងឡាយ ) កីលៀងទាំងឡាយ ជាអ្នកស្វែងរកសេចក្តីសុខឲ្យ តែងបម្រើទាំងល្ងាចទាំងព្រឹក ។ នន្ទនៈមហាវ័នរបស់ពួកទេវតានៅក្នុងឋានត្រៃត្រិង្ស មិនមានសោកជាទីត្រេកអរ នេះមិនមែនរបស់ពួកជនមិនបានធ្វើបុណ្យឡើយ នេះជារបស់ពួកជន ដែលបានធ្វើបុណ្យ ពួកជនដែលមិនបានធ្វើបុណ្យ មិនមានសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខឡើយ ឯពួកជនដែលបានធ្វើបុណ្យរមែងមានសេចក្តីសុខក្នុងលោកនេះនិងលោកខាងមុខពិតប្រាកដ ។ ពួកជនដែលចង់កើតជាមួយនឹងពួកទេវតានោះត្រូវធ្វើបុណ្យឲ្យច្រើន ព្រោះពួកជន ដែលបានធ្វើបុណ្យហើយ តែងបរិបូណ៌ដោយភោគៈ

រមែងរីករាយក្នុងឋានសួគ៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាតុន្នវសនា** ប្រែថា ស្លៀកសំពត់ ដាច់ដាច ធ្លុះធ្លាយ ។ បទថា **ឯកេ** ប្រែថា ពួកខ្លះ ។ បទថា **កេសនិវាសនា** បានដល់ យកសក់នោះឯងបិទបាំងអវយវៈដែលគួរខ្មាស ។ បទថា **ភត្តាយ គច្ឆន្តិ** សេចក្ដីថា ឈប់ចំពោះទីណាមួយមិនបាន រមែងដើរទៅ ដើម្បីអាហារ ដោយទន្ទឹងថា ពួកយើងទៅអំពីនេះហើយ គប្បីបានអ្វីជា អាហារដែលគេបោលក្ដី កម្អួតក្ដី មន្ទិលគភ៌ជាដើមក្ដី ក្នុងទីណាមួយហ្ន៎ ។ បទថា **បក្កមន្តិ ទិសោទិសំ** សេចក្ដីថា ចៀសចាកទិសទៅកាន់ទិស អស់ទីច្រើនយោជន៍ ។

បទថា **ទូរេ** ប្រែថា ក្នុងទីឆ្ងាយ ។ បទថា **ឯកេ** បានដល់ ប្រេតពួកខ្លះ ។ បទថា **បធាវិត្វា** បានដល់ រត់ចូលទៅដើម្បីអាហារ ។ បទថា **អលទ្ធាវ និវត្តរេ** សេចក្ដីថា កាលមិនបានបាយ ឬទឹកណាមួយ ក៏នាំគ្នាត្រឡប់ ។ បទថា **បមុច្ឆិតា** សេចក្ដីថា សន្លប់ ព្រោះសេចក្ដីទុក្ខដែលកើតអំពីការឃ្លាននិងការស្រេកជាដើម ។ បទថា **ភន្តា** បានដល់ វិលទៅវិលមក ។ បទថា **ភូមិយំ បដិសុម្ភិតា** សេចក្ដីថា កាលសន្លប់នោះឯង ក៏ស្គាំងស្គម ដួលចុះលើផែនដី ដូចបុគ្គលឈរគ្រវែងដុំដីទៅដូច្នោះ ។

បទថា **តត្ថ** គឺក្នុងទីដែលខ្លួនដើរទៅ ។ បទថា **ភូមិយំ បដិសុម្ភិតា** សេចក្ដីថា ដួលចុះលើផែនដី ព្រោះមិនអាចតម្កល់ខ្លួនបាន ដោយសេចក្ដីទុក្ខដែលកើតអំពីការឃ្លានជាដើម ដូចធ្លាក់ទៅក្នុងជ្រោះ ដូច្នោះ ឬក្នុងទីដែលទៅ

នោះ ជាអ្នកអស់សង្ឃឹម ព្រោះមិនបានអាហារជាដើម ក៏ដួលចុះលើផែនដី ដូចត្រូវបុគ្គលណាមួយវាយត្រង់មុខ ។ បទថា **បុព្វេ អកតកល្យាណា** ប្រែថា ជាអ្នកមិនបានធ្វើគុណណាទុកក្នុងភពមុន ។ បទថា **អគ្គិឌឌ្ឍាវ អា-តបេ** សេចក្ដីថា ត្រូវភ្លើង គឺការស្រេកឃ្លានដុតរោលរមែងសោយទុក្ខយ៉ាងមហន្តដូចត្រូវភ្លើងដុតក្នុងទីក្ដៅនារដូវប្រាំង ។

បទថា **បុព្វេ** គឺក្នុងអតីតភព ។ បទថា **បាបធម្មា** បានដល់ ឈ្មោះថា ជាបុគ្គលមានសភាវៈដ៏លាមក ព្រោះមានសេចក្ដីប្រណែន និងសេចក្ដីកំ-ណាញ់ ជាដើម ។ បទថា **ឃរណី** បានដល់ ស្រីដែលជាមេផ្ទះ ។ បទថា **កុលមាតរោ** បានដល់ មាតានៃទារកក្នុងត្រកូល ឬជាមាតារបស់បុរសក្នុងត្រកូល ។ បទថា **ទីបំ** ប្រែថា ទីពឹង អធិប្បាយថា បុណ្យ ។ ពិតហើយ បុណ្យនោះ លោកហៅថា **បតិដ្ឋា** ( ទីពឹង ) ព្រោះជាទីពឹងរបស់សត្វទាំងឡាយ ក្នុងសុគតិ ។ បទថា **នាកម្ហ** ប្រែថា មិនធ្វើទុកហើយ ។

បទថា **បហូតំ** ប្រែថា ច្រើន ។ បទថា **អន្នបានម្បិ** បានដល់ បាយនិងទឹក ។ សព្ទថា **សុ** ក្នុងបទថា **អបិស្សុ អវកិរិយតិ** ត្រឹមតែជានិបាតអើ បាយនិងទឹក អញបោះចោល គឺចាក់ចោល ។ បទថា **សម្មគ្គតេ** បានដល់ កាលអញប្រព្រឹត្តត្រូវ គឺបដិបត្តិប្រពៃ ។ បទថា **បព្វជិតេ** ប្រែថា ដល់អ្នកបួស ។ ពិតហើយ បទថា **បព្វជិតេ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថចតុត្ថីវិភត្តិ ។ ម្យ៉ាងទៀត អធិប្បាយថា កាលបព្វជិតដែលប្រព្រឹត្តត្រូវ មានគឺកាលបានបព្វជិត ។ បទថា **ន ច កិញ្ចិ អនុម្ហសេ** សេចក្ដីថា ពួកប្រេត

ត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ពោលថា អញមិនបានឲ្យទេយ្យធម៌ សូម្បីតិចតួច ។

បទថា **អកម្មកាមា** សេចក្តីថា ឈ្មោះថា **អកម្មកាម** ព្រោះប្រាថ្នាអកុសលកម្ម ដែលសប្បុរសទាំងឡាយមិនគប្បីធ្វើ ឬឈ្មោះថា **កម្មកាម** ព្រោះប្រាសចាកកុសលកម្មដែលមនុស្សល្អគប្បីធ្វើ ។ ឈ្មោះថា **អកម្មកាម** ព្រោះមិនប្រាថ្នាកុសលកម្ម អធិប្បាយថា មិនមានឆន្ទៈក្នុងកុសលកម្ម ។ បទថា **អលសា** បានដល់ ជាបុគ្គលខ្ជិលច្រអូស គឺមិនមាន សេចក្តីព្យាយាមក្នុងការធ្វើកុសលកម្ម ។ បទថា **សាទុកាមា** បានដល់ ប្រាថ្នាវត្ថុដែលសុខស្រួលនិងឆ្ងាញ់ ។ បទថា **មហគ្ឃសា** បានដល់ អ្នកបរិភោគច្រើន ។ ដោយបទទាំង ២ លោកសម្តែងទុកថា បានទទួលភោជនដែលល្អនិងឆ្ងាញ់ហើយ មិនបានឲ្យរបស់ណាមួយដល់បុគ្គលដែលត្រូវការ បរិភោគឯងប៉ុណ្ណោះ ។ បទថា **អាលោបបិណ្ឌទាតារោ** បានដល់ ឲ្យនូវដុំបាយត្រឹមមួយពំនូត ។ បទថា **បដិគ្គហោ** បានដល់ ជាអ្នកទទួលដុំបាយនោះ ។ បទថា **បរិភាសិម្ហសេ** បានដល់ ពោលសង្កត់សង្កិន អធិប្បាយថា មើលងាយនិងចំអក ។

បទថា **តេ ឃរា** អធិប្បាយថា ក្នុងកាលមុន ពួកយើងបានធ្វើសេចក្តីស្រឡាញ់ថា ផ្ទះរបស់អញ ផ្ទះទាំងនោះ តាំងនៅដដែល ឥឡូវនេះ វត្ថុណាមួយ ក៏មិនសម្រេចដល់ពួកយើង ។ ក្នុងបទថា **តា ច ទាសិយោ តានេ-វាភរណានិ នោ** នេះ ក៏ន័យនេះដូចគ្នា ។ បណ្តាបទទាំងនោះ បទថា **នោ** ប្រែថា ដល់ពួកយើង ។ បទថា **តេ** បានដល់ មានផ្ទះជាដើមនោះ ។

បទថា **អញ្ញេ បរិចារេន្តិ** សេចក្តីថា ធ្វើនូវការប្រកបឲ្យវិសេសដោយការបរិភោគជាដើម ។ បទថា **មយំ ទុក្ខស្ស ភាគិនោ** ពួកប្រេតពោល តិះដៀលខ្លួនថា កាលមុន ពួកយើងខ្វល់ខ្វាយក្នុងការលេងតែម្យ៉ាង លះនូវសម្បត្តិដោយមិនចេះធ្វើឲ្យសម្បត្តិនោះជាប់តាមខ្លួន តែឥឡូវនេះ ពួកយើងជាអ្នកមានចំណែកនៃទុក្ខដែលកើតអំពីការស្រេកនិងការឃ្លាន ជាដើម ។

ឥឡូវនេះ ព្រោះហេតុដែលសត្វទាំងឡាយ ចុតិចាកកំណើតប្រេតហើយកើតក្នុងពួកមនុស្ស ក៏នឹងជាអ្នកមានជាតិអាក្រក់ មានការរស់នៅដ៏លំបាកដោយសេសសល់វិបាកនៃកម្មនោះឯងដោយច្រើន ព្រោះហេតុនោះដើម្បីនឹងសម្តែងសេចក្តីនោះ ទើបលោកពោល ២ គាថា ដោយន័យជាដើមថា **វេណី វា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វេណី វា** បានដល់ កើតក្នុងត្រកូលជាងផែង អធិប្បាយថា ជាងផែងឫស្សី ជាងផែងបបុស ។ **វា** សព្ទមានអត្ថមិនពិតប្រាកដ ។ បទថា **អវញ្ញា** ប្រែថា មើលងាយ អធិប្បាយថា ប្រមាថ ។ បាលីថា **វម្ភនា** ដូច្នេះក៏មាន អធិប្បាយថា ត្រូវអ្នកដទៃបៀតបៀន ។ បទថា **រថការី** បានដល់ ជាងស្បែក ។ បទថា **ទុត្ថិកា** បានដល់ អ្នកច្រើនដោយការប្រទូស្តមិត្ត គឺអ្នកបៀតបៀនមិត្ត ។ បទថា **ចណ្ឌាលី** ប្រែថា ជាបុគ្គលមានជាតិចណ្ឌាល ។ បទថា **កបណា** បានដល់ អ្នកសូមទានគឺអ្នកដែលគួរបានទទួលនូវករុណាក្រៃលែង ។ បទថា **កប្បកា** បានដល់ កើតក្នុងត្រកូលជាងកោរកាត់ ។ ក្នុងបទទាំងពួងមានវាចាប្រកបសេចក្តីថា មានរឿយៗ អធិប្បាយថា រមែងកើតក្នុងត្រកូលទាបទាំងនេះហើយទាំង

នេះទៀត ។

បទថា **តេសុ តេស្វេវ ជាយន្តិ** សេចក្តីថា កើតក្នុងប្រេតទាំងឡាយ ព្រោះមន្ទិល គឺសេចក្តីកំណាញ់ ចុតិចាកប្រេតហើយ កើតក្នុងត្រកូលមនុស្ស កំព្រាពួកដទៃ មានត្រកូលនាយព្រាននិងត្រកូលអ្នកចាក់សំរាមដែលខ្វះខាតច្រើននិងលំបាកក្រៃលែង ព្រោះជាត្រកូលថោកទាប ។ ដោយហេតុនោះ ទើបលោកពោលថា នេះជាគតិនៃជនអ្នកកំណាញ់ ដូច្នេះ ។

ព្រះសង្គីតិកាចារ្យ កាលសម្តែងគតិរបស់សត្វដែលមិនបានធ្វើបុណ្យទុកយ៉ាងនេះ ឥឡូវនេះ ដើម្បីសម្តែងគតិរបស់បុគ្គលដែលធ្វើបុណ្យទុក ទើបពោល ៧ គាថាថា ពួកជនបានធ្វើអំពើល្អក្នុងកាលមុន ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សគ្គំ តេ បរិបូរេន្តិ** សេចក្តីថា ទាយកទាំងឡាយ បានធ្វើកុសលគុណទុកក្នុងជាតិមុន ត្រេកអរក្រៃលែងក្នុងបុណ្យដែលពោលដោយការឲ្យទាន ប្រាសចាកសេចក្តីកំណាញ់ដែលជាមន្ទិល រមែងធ្វើស្ថានសួគ៌ គឺទេវលោកឲ្យបរិបូណ៌ ដោយរូបសម្បត្តិរបស់ខ្លួន និងដោយបរិវារសម្បត្តិ ។ បទថា **ឱភាសេន្តិ ច នន្ទនំ** សេចក្តីថា មិនមែនធ្វើនន្ទនវ័នឲ្យបរិបូណ៌តែម្យ៉ាងប៉ុណ្ណោះទេ ដោយពិតនោះ រមែងគ្របសង្កត់នន្ទនវ័នសូម្បីភ្លឺស្វាងតាមសភាវៈដោយរស្មីនៃដើមកប្បព្រឹក្សជាដើម និងឲ្យភ្លឺស្វាងដោយពន្លឺនៃសំពត់និងអាភរណៈនិងដោយរស្មីនៃរាងកាយរបស់ខ្លួន ។

បទថា **កាមកាមិនោ** សេចក្តីថា មានគ្រឿងប្រើប្រាស់តាមប្រាថ្នាក្នុងកាមគុណតាមដែលត្រូវការ ។ បទថា **ឧច្ចាកុលេសុ** បានដល់ ត្រកូលខ្ពស់

មានត្រកូលក្សត្រជាដើម ។ បទថា **សភោគេសុ** បានដល់ មានសម្បត្តិច្រើន ។ បទថា **តតោ ចុតា** បានដល់ កាលចុតិ ចាកទេវលោកនោះហើយ ។

បទថា **កូដាគារេ ច បាសាទេ** បានដល់ ក្នុងកូដាគារនិងប្រាសាទ ។ បទថា **ពីឋិតង្គា** បានដល់ មានសរីរៈត្រូវគេបក់ផាត់ ។ បទថា **មោរហត្ថេហិ** បានដល់ កាន់ផ្ចិតវាលវីជនីប្រដាប់ដោយកន្ទុយក្ងោក ។ បទថា **យសស្សិនោ** អធិប្បាយថា មានបរិវារគួរជាទីត្រេកអរ ។

បទថា **អង្កតោ អង្កំ គច្ឆន្តិ** សេចក្ដីថា ក្នុងពេលជាទារក ពួកញាតិនិងមេដោះនាំគ្នាបីព អធិប្បាយថា មិនបានជាន់ដី ។ បទថា **ឧបតិដ្ឋន្តិ** ប្រែថា រង់ចាំបម្រើ ។ បទថា **សុខេសិនោ** បានដល់ ប្រាថ្នាសេចក្ដីសុខ អធិប្បាយថា រង់ចាំបំបាត់ទុក្ខ មានប្រមាណតិចថា ការរងា ឬការក្ដៅកុំបីមាន ។ បទថា **ឥទំ យិទំ អកតបុញ្ញានំ** សេចក្ដីថា មហាឧទ្យានរបស់ទេវតាតាវត្តិង្ស ឈ្មោះថា នន្ទនវ័ន ក្បែរព្រៃធំនេះ មិនមែនទីសោកសៅ ជាទីគួរត្រេកអរនៃចិត្ត មិនមានដល់បុគ្គលដែលមិនបានធ្វើបុណ្យ អធិប្បាយថា អ្នកដែលមិនបានធ្វើបុណ្យទុកមិនអាចបាន ។

ដោយបទថា **ឥធ** នេះ លោកពោលសំដៅយកបុគ្គលដែលបានធ្វើបុណ្យជាពិសេសក្នុងមនុស្សលោកនេះ ។ម្យ៉ាងទៀត បទថា **ឥធ** គឺក្នុងបច្ចុប្បន្ន ។ បទថា **បរត្ថ** គឺក្នុងសម្បរាយភព ។

បទថា **តេសំ** បានដល់ ទេវតាទាំងឡាយតាមដែលពោលហើយនោះ ។

បទថា **សហាព្យាការមានធំ** បានដល់ ប្រាថ្នានូវភាពជាសម្លាញ់ ។ បទថា **ភោគសមង្គិនោ** បានដល់ ជាអ្នកប្រកបដោយភោគៈទាំងឡាយ អធិប្បាយថា ជាអ្នកត្រេកអរ ព្រោះដល់ព្រមដោយកាមគុណ ៥ ដែលជាទិព្វ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដោយពិស្តារ តាមសមគួរដល់អធ្យាស្រ័យរបស់មហាជនដែលប្រជុំគ្នាក្នុងទីនោះ មានកោលិយអាមាត្យជាប្រធាន ដែលមានចិត្តសង្វេគ កាលប្រេតទាំងនោះប្រកាសដល់គតិរបស់កម្មដែលខ្លួនធ្វើដោយទូទៅនិងគតិរបស់បុញ្ញកម្មដោយប្រការដូច្នេះ ។ ក្នុងកាលចប់ទេសនា សត្វ ៨៤០០០ ត្រាស់ដឹងធម៌ដូច្នេះឯង ។

## អដ្ឋកថា អភិជ្ជមានប្រេតចប់

# រឿង សានុវាសិប្រេត ទី២

[ ២៧ ] ( ព្រះធម្មសង្គាហកត្ថេរទាំងឡាយពោលថា ) ព្រះថេរឈ្មោះបោដ្ឋបាទ អ្នកកើតក្នុងក្រុងកុណ្ឌី បាននៅអាស្រ័យលើភ្នំឈ្មោះសានុវាសីជាអ្នករម្ងាប់បាប មានឥន្ទ្រិយចម្រើនហើយ ( ដោយអរិយមគ្គភាវនា ) ។ មាតាបិតានិងបងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកដល់នូវសេចក្តីលំបាក បានកើតក្នុងយមលោក ( នរក ) លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បេតលោក ព្រោះធ្វើបាបកម្ម ពួកប្រេតទាំងនោះ ជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រជាបត្រជួស មានកាយអាក្រាត ស្គមកំព្រឹង ស្ទុតរន្ធត់ ភ័យឡឹងឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ បងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកអាក្រាត តែម្នាក់ឯងក្នុងផ្លូវបុះតែជើងមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអវយវៈ ៤ គឺវារប្រញាប់ប្រញាល់ទៅបង្ហាញខ្លួនដល់ព្រះថេរៈ ។ ព្រះថេរៈមិនបានធ្វើទុកក្នុងចិត្តថា អ្នកនោះឈ្មោះនេះ ហើយក៏នៅស្ងៀម ដើរហួសទៅ ឯប្រេតនោះបានទូលព្រះថេរៈឲ្យដឹងច្បាស់ថា បពិត្រព្រះថេរៈ ខ្ញុំព្រះករុណាត្រូវជាបងបានទៅកាន់បេតលោកហើយ ។ បពិត្រលោកដ៏ចម្រើន មាតានិងបិតារបស់លោកដល់នូវសេចក្តីលំបាក កើតក្នុងយមលោក លុះច្យុតអំពីមនុស្សលោកនេះហើយក៏ទៅកាន់បេតលោក ព្រោះធ្វើកម្មដ៏លាមក មាតានិងបិតាទាំងនោះជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រជាបត្រជួស មានកាយអាក្រាតស្គមកំព្រឹង ស្ទុតរន្ធត់ ភ័យឡឹងឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ លោកជាអ្នកមានសេចក្តី

អាណិតអាសូរ សូមអនុគ្រោះឲ្យទាន ឧទ្ទិសទៅឲ្យយើងទាំងឡាយផង មាតានឹងបិតាទាំងនោះដែលមានកម្មអាក្រក់ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយទានដែលលោកម្ចាស់ឲ្យហើយ ។

ព្រះថេរៈផង ភិក្ខុទាំងឡាយដទៃ ១២ អង្គផង ដើរទៅបិណ្ឌបាត ហើយប្រជុំក្នុងទីជាមួយគ្នា ព្រោះហេតុនៃភត្តកិច្ច ។ ព្រះថេរៈបាននិយាយនឹងពួកភិក្ខុទាំងអស់នោះថា លោកទាំងឡាយ សូមឲ្យនូវភត្តដែលលោកទាំងឡាយបានហើយយ៉ាងណាដល់ខ្ញុំ ខ្ញុំនឹងធ្វើសង្ឃភត្តដើម្បីអនុគ្រោះដល់ពួកញាតិ ។

ភិក្ខុទាំងនោះ បានប្រគេន ( ភត្តទាំងនោះ ) ដល់ព្រះថេរៈ ព្រះថេរៈបាននិមន្តសង្ឃ លុះព្រះថេរៈបានឲ្យទានហើយ ក៏ឧទ្ទិសចំពោះមាតាបិតានិងបងថា សូមឲ្យទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមឲ្យពួកញាតិបានដល់នូវសេចក្តីសុខ ។

ភោជនក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ( ភោជននោះ ) ជាភោជនដ៏ស្អាត ថ្លៃថ្លា ឆ្ងាញ់ ជាម្ហូបមានឱជារសច្រើនក្នុងកាលខាងក្រោយអំពីកាលជាទីបាននូវភោជននោះមក ប្រេតជាបងមានសម្បុរល្អ មានកម្លាំង មានសេចក្តីសុខ បានបង្ហាញខ្លួន ( ដល់ព្រះថេរៈហើយពោលថា ) បពិត្រលោកដ៏ចម្រើន សូមលោករមិលមើលនូវភោជនដ៏ច្រើន ( ដែលពួកយើងបានហើយដោយអានុភាពនៃទានរបស់លោក ) ប៉ុន្តែពួកយើងអាក្រាតនៅឡើយ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវសំពត់ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានរើសកំណាត់សំពត់រេចជាយទាំងឡាយអំពីគំនរនៃសំរាម ហើយធ្វើកំណាត់សំពត់ឲ្យជាផ្ទាំង គឺធ្វើជាចីវរ បានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ ព្រះថេរៈបានឲ្យទានហើយ ឧទ្ទិសដល់បិតាមាតានិងបងថា ទាននេះចូរសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្ដីសុខ ។

សំពត់ទាំងឡាយ ក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស លំដាប់នោះ ( ប្រេតជាបង ) ក៏ស្លៀកដណ្ដប់សំពត់ដ៏ល្អ បានបង្ហាញខ្លួនដល់ព្រះថេរៈ ។ ( ប្រេតនោះ ) មានសម្បុរល្អ មានកម្លាំង មានសេចក្ដីសុខ ( បាននិយាយថា ) បពិត្រលោកដ៏ចម្រើន សំពត់ជាគ្រឿងបិទបាំងកាយក្នុងដែនរបស់ព្រះបាទនន្ទៈទាំងប៉ុន្មាន ( សំពត់ជាគ្រឿងបិទបាំងរបស់ពួកយើង ) ច្រើនលើសជាងសំពត់ជាគ្រឿងបិទបាំងកាយទាំងនោះ ។

សំពត់ទាំងឡាយ ជាគ្រឿងស្លៀកពាក់របស់ពួកយើង គឺកោសេយ្យ-ពស្ត្រ កម្ពលីយពស្ត្រ ខោមពស្ត្រ កប្បាសិកពស្ត្រ ជាសំពត់ជំទូលាយមានថ្លៃច្រើន ឯសំពត់ទាំងនោះ ក៏សំយុងចុះ ឰដ៏អាកាស ពួកយើងនឹងស្លៀកពាក់សំពត់ទាំងនោះតាមចិត្តស្រឡាញ់ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានផ្ទះដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈបានធ្វើកុដិប្រក់ដោយស្លឹក ហើយប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ លុះព្រះថេរៈ បានប្រគេនហើយ ឧទ្ទិសដល់បិតាមាតានិងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវ

សេចក្តីសុខចុះ ។

ផ្ទះទាំងឡាយ ផ្ទះកំពូលទាំងឡាយ ជាទីនៅដែលញែកចែកដែលចែកដោយប្រមាណស្មើគ្នា ក៏សម្រេច ( ដល់ពួកប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ។

( ប្រេតទាំងនោះពោលថា ) ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះ យ៉ាងណា ផ្ទះទាំងឡាយក្នុងមនុស្សលោកមិនដូច្នោះទេ តែផ្ទះទាំងឡាយក្នុងឋានទិព្វទាំងឡាយ យ៉ាងណា ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះយ៉ាងនោះដែរ ជាផ្ទះដ៏រុងរឿង អាចញុំាងទិសទាំង ៤ ឲ្យភ្លឺជុំវិញបាន ។ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានទឹកផឹក ដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈបានចាក់ទឹកបំពេញធម្មក្រក ហើយប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខ ។

ទឹកក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ស្រះបោក្ខរណីទាំងឡាយដែលបុញ្ញកម្មនិម្មិតល្អហើយ ជ្រៅ មានជ្រុង ៤ មានទឹកដ៏ត្រជាក់ មានកំពង់ល្អ ជាស្រះត្រជាក់ មានក្លិនក្រអូបប្រៀបមិនបានដេរដាស ដោយផ្កាឈូកនិងផ្កាឧប្បល ពេញដោយលម្អងលើទឹក ។ ប្រេតទាំងនោះងូត ផឹក ក្នុងស្រះបោក្ខរណីនោះហើយ បង្ហាញខ្លួនដល់ព្រះថេរៈថា

បពិត្រលោកដ៏ចម្រើន ( ពួកយើងបាន ) ទឹកច្រើនហើយ តែជើងទាំងឡាយរបស់ពួកយើងឈឺ ពុះពង ពួកយើងកាលដើរជាន់លើក្រួសរវាន លើស្បូវភ្ញាំងនិងបន្លា រមែងខ្ទើចៗ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវយានដោយប្រការណា សូមលោកខំព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានស្បែកជើងមានជាន់ ១ ហើយបានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈ បានប្រគេនហើយក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខ ។

ពួកប្រេតបានមកដោយរថក្នុងលំដាប់ដែលឧទ្ទិសហើយ ( និយាយថា ) បពិត្រលោកដ៏ចម្រើន ពួកយើងលោកបានអនុគ្រោះហើយ ដោយបាយផងដោយគ្រឿងបិទបាំងផង ដោយផ្ទះផង ដោយទានទាំង ២ គឺបានីយទាននិងយានទានផង បពិត្រលោកដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញ ប្រកបដោយសេចក្តីករុណាក្នុងលោក ។

## ចប់ រឿងសានុវាសីប្រេតទី ២ ។

# អដ្ឋកថា សានុវាសិប្រេត

[ ២៧ ] កាលព្រះសាស្ដាគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធប្រេតដែលជាញាតិ របស់ព្រះសានុវាសិត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កុណ្ឌិនាគរិយោ ថេរោ** ដូច្នេះជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានព្រះរាជឱរសរបស់ព្រះរាជាព្រះនាមថា **កិតវៈ** ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន កាលយាងត្រឡប់ ទ្រង់ទតឃើញព្រះបច្ចេកពុទ្ធមួយព្រះអង្គព្រះនាមថា **សុនេត្ត** កំពុងត្រាច់បិណ្ឌបាត ចេញអំពីព្រះនគរ ជាអ្នកស្រវឹងដោយសេចក្ដីស្រវឹងព្រោះភាពជាធំ មានចិត្តប្រទូស្តថា សមណៈត្រងោលនេះមិនធ្វើអញ្ជលីណាមួយដល់អញ ដើរទៅ ទ្រង់ចុះអំពីកដំរីហើយ សួរថា លោកបានបិណ្ឌបាតខ្លះឬ ក៏ទទួលបាត្រអំពីដៃ ហើយបោកត្រង់ផែនដីឲ្យបែកទៅ ។ លំដាប់នោះព្រះរាជឱរសនោះ មានអាឃាតក្នុងឋានៈដែលមិនគួរ មានចិត្តគិតប្រទូស្តព្រះបច្ចេកពុទ្ធនោះ ដែលមិនសម្ដែងវិការ ព្រោះលោកជាអ្នកមិនញាប់ញ័រក្នុងទីទាំងពួងជាអ្នកមានចិត្តផូរផង់ ប្រកបដោយសោមនស្សវេទនាផ្សាយទៅដោយអំណាចករុណាសម្លឹងមើល ក៏ត្រាស់ថា លោកមិនស្គាល់យើងដែលជារាជឱរសរបស់ព្រះបាទកិតវៈទេឬ លោកសម្លឹងមើលយើង នឹងធ្វើអ្វីយើងបានសើចចំអកចៀសចេញទៅ ។ លុះព្រះរាជឱរសចៀសចេញទៅប៉ុណ្ណោះ រាងកាយក៏ក្ដៅក្រហាយជាកម្លាំង ប្រៀបដូចកម្ដៅនៃភ្លើងនរក ។ ព្រោះវិបាកកម្មនោះ ព្រះរាជឱរសនោះ មានកាយត្រូវសេចក្ដីក្ដៅក្រហាយគ្របសង្កត់ ត្រូវទុក្ខវេទនាជាពន្លឹកចាក់ដោត ធ្វើកាលកិរិយាហើយ កើតក្នុងអវិចីមហានរក ។

ព្រះរាជឱរសនោះ ដេកផ្ងារផ្កាប់បម្រះនទៀល ទៅឆ្វេង ទៅស្តាំ ដោយប្រការដ៏ច្រើនក្នុងទីនោះគេះអស់ ៨៤០០០ ឆ្នាំ ចុតិអំពីអត្តភាពនោះ សោយទុក្ខដែលកើតអំពីការស្រេកឃ្លានក្នុងពួកប្រេត អស់កាល ប្រមាណមិនបាន ចុតិចាកអត្តភាពនោះហើយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងកេវដ្តគាម ក្បែរកុណ្ឌិនគរ កុមារនោះរឭកជាតិបាន ព្រោះហេតុនោះ កាលរឭកដល់សេចក្តីទុក្ខដែលខ្លួនធ្លាប់សោយក្នុងកាលមុន ចម្រើនវ័យហើយ មិនព្រមទៅចាប់ត្រីជាមួយពួកញាតិព្រោះខ្លាចបាប ។ កាលពួកញាតិទាំងនោះនាំគ្នាទៅ ក៏ពួនមិនប្រាថ្នានឹងចាប់ត្រី កុមារនោះ ក៏ទម្លាយសំណាញ់ ឬចាប់ត្រីរស់មកលែងក្នុងទឹក ពួកញាតិមិនពេញចិត្តក្នុងការធ្វើរបស់កុមារនោះ ក៏បណ្តេញចេញពីផ្ទះ ។ កុមារនោះមានបងប្រុសម្នាក់ដែលស្រឡាញ់គេខ្លាំង ។

សម័យនោះ ព្រះអានន្ទ អាស្រ័យកុណ្ឌិនគរ នៅក្នុងសានុបពិត ។ លំដាប់នោះ កូនអ្នកប្រមង់នោះ ត្រូវពួកញាតិបោះបង់ដើរទៅក្នុងទីគ្រប់កន្លែង ដល់ទីនោះហើយ ចូលទៅរកព្រះថេរៈក្នុងពេលឆាន់អាហារ ព្រះថេរៈសួរហើយ ដឹងថា ត្រូវការអាហារ ទើបឲ្យភត្តាហារដល់កុមារនោះ ។ កុមារបរិភោគអាហារស្រេចហើយ ដឹងរឿងនោះហើយ ដឹងថាកុមារនោះមានចិត្តជ្រះថ្លាក្នុងធម្មកថាទើបពោលថា តើអ្នកបួសដែរឬទេ កុមារឆ្លើយថាខ្ញុំបួស ។ ព្រះថេរៈកាលឲ្យកុមារបព្វជ្ជាហើយ នាំទៅគាល់ព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះអានន្ទត្ថេរថា ម្នាលអានន្ទ អ្នកគប្បីអនុគ្រោះសាមណេរនេះចុះ ។ ព្រោះសាមណេរមិនធ្លាប់ធ្វើកុសល ទើបជាអ្នកមាន

លាភតិច ។ លំដាប់នោះ ព្រះសាស្តា កាលទ្រង់អនុគ្រោះ ទើបណែនាំឲ្យសាមណេរដងទឹកចាក់ឲ្យពេញក្អម ដើម្បីឲ្យភិក្ខុឆាន់ ។ ឧបាសកនិងឧបាសិកាទាំងឡាយឃើញដូច្នោះ ក៏ផ្តើមតម្កល់និច្ចភត្តជាច្រើនដល់សាមណេរ ។

គ្រាតមក សាមណេរបានឧបសម្បទាហើយ បានសម្រេចអរហត្ត ជាព្រះថេរៈ មួយអន្លើដោយភិក្ខុ ១២ រូប បាននៅត្រង់សានុបព៌ត ។ ឯពួកញាតិរបស់ព្រះថេរៈប្រមាណ ៥០០ នាក់ មិនបានធ្វើកុសលកម្ម ធ្វើតែបាបធម៌ មានមច្ឆរិយៈជាដើម ធ្វើកាលកិរិយាហើយ កើតក្នុងពួកប្រេត ឯមាតាបិតារបស់ព្រះថេរៈ ពោលថា ក្នុងកាលមុនបុគ្គលនេះ ត្រូវពួកយើងបណ្តេញចេញចាកផ្ទះ ទើបមិនចូលទៅរកព្រះថេរៈ បញ្ជូនបងប្រុសជាទីស្រឡាញ់ពេញចិត្តក្នុងព្រះថេរៈទៅ ។ ក្នុងពេលដែលព្រះថេរៈចូលទៅបិណ្ឌបាត ប្រេតលុតជង្គង់ វារដោយដៃលើផែនដី ធ្វើអញ្ជលី បង្ហាញខ្លួន បានធ្វើគាថាថា **មាតា បិតា ច តេ ភន្តេ** ដូច្នេះជាដើម ។ ដើម្បីសម្តែងការសម្ពន្ធគ្នានៃគាថា ៥ ខាងដើម មានពាក្យថា **កុណ្ឌិនាគរិយោ ថេរោ** ដូច្នេះជាដើម ទើបព្រះសង្គីតិកាចារ្យរចនាទុកថា

ព្រះថេរឈ្មោះ បោដ្ឋបាទ អ្នកកើតក្នុងក្រុងកុណ្ឌិ បាននៅអាស្រ័យលើភ្នំឈ្មោះសានុវាសី ជាអ្នករម្ងាប់បាប មានឥន្រ្ទិយចម្រើនហើយ ( ដោយអរិយមគ្គភាវនា ) ។ មាតាបិតានិងបងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកដល់នូវសេចក្តីលំបាកបានកើតក្នុងយមលោក ( នរក ) លុះច្យុតអំពីមនុស្សលោក

នេះហើយ ក៏ទៅកាន់បេតលោក ព្រោះធ្វើបាបកម្ម ពួកប្រេត ទាំងនោះជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដួស មានកាយអាក្រាត ស្គមកំព្រឹង ស្ពុតរន្ធត់ភ័យ ឡើនឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យ គេឃើញឡើយ ។ បងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកអាក្រាត តែម្នាក់ឯងក្នុងផ្លូវចុះតែជើងមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអវយវៈ ៤ គឺវារប្រញាប់ប្រញាល់ទៅបង្ហាញ ខ្លួនដល់ព្រះថេរៈ ។ ព្រះថេរៈមិនបានធ្វើទុកក្នុងចិត្តថា អ្នកនោះ ឈ្មោះនេះ ហើយក៏នៅស្ងៀម ដើរហួសទៅ ឯប្រេតនោះបាន ទូលព្រះថេរៈឲ្យដឹងច្បាស់ថា បពិត្រព្រះថេរៈ ខ្ញុំព្រះករុណា ត្រូវជាបង បានទៅកាន់បេតលោកហើយ ។ បពិត្រលោកដ៏ចម្រើន មាតានិងបិតារបស់លោក ដល់នូវសេចក្តីលំបាកកើត ក្នុងយមលោក លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅ កាន់បេតលោក ព្រោះធ្វើកម្មដ៏លាមក មាតានិងបិតាទាំងនោះ ជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រដាប ត្រដួស មានកាយអាក្រាត ស្គមកំព្រឹង ស្ពុតរន្ធត់ ភ័យឡើន ឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេ ឃើញឡើយ ។ លោកជាអ្នកមានសេចក្តីអាណិតអាសូរសូម អនុគ្រោះឲ្យទាន ឧទ្ទិសទៅឲ្យយើងទាំងឡាយផង មាតានិង

បិតាទាំងនោះ ដែលមានកម្មអាក្រក់ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយទានដែលលោកម្ចាស់ឲ្យហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុណ្ឌិធានគិរិយោ ថេរោ** បានដល់ ព្រះ-ថេរៈដែលកើតធំធាត់ក្នុងនគរមានឈ្មោះយ៉ាងនេះ បាលីថា **កុណ្ឌិកនគរោ ថេរោ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **សានុវាសិនិវាសិកោ** បានដល់ ដែលមានប្រក្រតីនៅត្រង់សានុបព៌ត ។ បទថា **ចោដ្ឋបាទោតិ នាមេន** បានដល់ ព្រះថេរៈមានឈ្មោះថា ពោដ្ឋបាទ ។ បទថា **សមណោ** បានដល់ ជាអ្នកស្ងប់បាប ។ បទថា **ភាវិតិន្ទ្រិយោ** សេចក្តីថា ដែលអប់រំឥន្ទ្រិយជាដើមហើយ ដោយអរិយមគ្គភាវនា គឺជាព្រះអរហន្ត ។ បទថា **តស្ស** បានដល់ ព្រះសានុវាសិត្ថេរនោះ ។ បទថា **ទុគ្គតា** បានដល់ ទៅកាន់ទុគ្គតិ ។ បទថា **សូចិកដ្ឋា** បានដល់ ឈ្មោះថា **អដ្ឋកា** ព្រោះជាអ្នកសៅហ្មងដោយរបស់ស្អុយ គឺក្តៅក្រហាយ បានដល់ ត្រូវសេចក្តីស្រេកឃ្លានដែលបានឈ្មោះថា **សូចិកា** បៀតបៀនហើយ ។ អាចារ្យពួកខ្លះពោលថា **សូចិកណ្ឋា** ដូច្នេះក៏មាន អធិប្បាយថា ដែលមាន មាត់ប៉ុនគូថម្ជុល ។ បទថា **កិលន្តា** បានដល់ មានកាយនិងចិត្តលំបាក ។ បទថា **នគ្គិនោ** បានដល់ ជាអ្នកមានរូបកាយអាក្រាត គឺមិនមានកំណាត់សំពត់ ។ បទថា **កិសា** បានដល់ មានរាងកាយស្គម ព្រោះមានរាងកាយសល់ត្រឹមតែស្បែកដណ្តប់ឆ្អឹង ។ បទថា **ឧត្តសន្តា** បានដល់ ដល់នូវការតក់ស្លុត ព្រោះខ្លាចថា សមណៈនេះជាបុត្តរបស់អញ ។ បទថា **មហាត្តាសា** បានដល់ កើតមហា

ភ័យ ព្រោះអាស្រ័យកម្មដែលខ្លួនបានធ្វើក្នុងកាលមុន ។ បទថា **ន ទស្សេន្តិ** សេចក្តីថា មិនសម្តែងខ្លួន គឺមិនព្រមជួបមុខ ។ បទថា **កុព្វិនោ** បានដល់ ជាអ្នកមានកម្មទារុណ ។

បទថា **តស្ស ភាតា** បានដល់ ប្រេតជាបងប្រុសរបស់សានុវាសិត្ថេរ ។ បទថា **វិតរិត្វា** បានដល់ ជាអ្នកប្រញាប់ទៅហើយ អធិប្បាយថា មានភ័យកើតអំពីការតក់ស្លុត ព្រោះខ្លាច ម្យ៉ាងទៀត បាលីថា **វិតុរិត្វា** ដូច្នេះក៏មានអធិប្បាយថា ជាអ្នករួសរាន់ គឺប្រញាប់ទៅ ។ បទថា **ឯកបថេ** គឺក្នុងផ□ សម្រាប់ដើរបានតែម្នាក់ ។ បទថា **ឯកកោ** គឺទៅតែម្នាក់ឯង មិនមានសម្លាញ់ ។ បទថា **ចតុកុណ្ឌិកោ ភវិត្វាន** សេចក្តីថា ឈ្មោះថា **ចតុ-កុណ្ឌិកោ** ព្រោះសោយទុក្ខវេទនា គឺញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអង្គ ៤ អធិប្បាយថា ប្រើជង្គង់ទាំង ២ ដៃទាំង ២ ដើរទិងឈរ គឺវារទៅ អធិប្បាយថា មានសភាពយ៉ាងនោះ ។ ពិតហើយ ប្រេតនោះ បានធ្វើយ៉ាងនោះ ដោយគិតថា ការបិទបាំងអវយវៈដែលធ្វើសេចក្តីខ្មាសឲ្យកម្រើករមែងមានដោយប្រការនេះ ។ បទថា **ថេរស្ស ទស្សយីតុមំ** សេចក្តីថា អាងគឺបង្ហាញខ្លួនដល់ព្រះថេរៈ ។

បទថា **អមនសិកត្វា** បានដល់ មិនធ្វើទុកក្នុងចិត្ត គឺមិននឹកដល់យ៉ាងនេះថា បុគ្គលនេះឈ្មោះយ៉ាងនេះ ។ បទថា **សោ ច** បានដល់ ប្រេតនោះ ។ បទថា **ភាតា បេតគតោ អហំ** មានវាចាប្រកបសេចក្តីថា ប្រេតនោះពោលយ៉ាងនេះថា ខ្ញុំជាបងប្រុសក្នុងអត្តភាពដែលជាអតីត ឥឡូវនេះ ខ្ញុំជាប្រេត

មកក្នុងទីនេះ ដូច្នេះហើយ ទើបប្រកាសឲ្យព្រះថេរៈដឹង ។

ដើម្បីសម្តែងប្រការដែលឲ្យព្រះថេរៈដឹងបាន ទើបពោល ៣ គាថា ដោយន័យជាដើមថា **មាតា បិតា ច** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាតា បិតា ច តេ** ប្រែថា មាតានិងបិតារបស់លោក ។ បទថា **អនុកម្បស្សុ** សេចក្តីថា ចូរអនុគ្រោះ គឺសូមធ្វើសេចក្តីករុណា ។ បទថា **អធ្វាធិសាហិ** បានដល់ ចំពោះ ។ បទថា **នោ** បានដល់ ពួកយើង ។ បទថា **ទាវ ឧទ្ទិស្ស** បានដល់ ដោយទានដែលលោកឲ្យហើយ ។

ព្រះថេរៈ កាលបានស្តាប់ដូច្នេះហើយ ដើម្បីសម្តែងភាពដែលព្រះថេរៈនោះបដិបត្តិ ទើបព្រះធម្មសង្គាហកាចារ្យពោលគាថាទាំងឡាយថា

ព្រះថេរៈផង ភិក្ខុទាំងឡាយដទៃ ១២ អង្គផង ដើរទៅបិណ្ឌបាត ហើយប្រជុំក្នុងទីជាមួយគ្នា ព្រោះហេតុនៃភត្តកិច្ច ។ ព្រះថេរៈបាននិយាយនឹងពួកភិក្ខុ ទាំងអស់នោះថា លោកទាំងឡាយសូមឲ្យនូវភត្ត ដែលលោកទាំងឡាយ បានហើយយ៉ាងណា ដល់ខ្ញុំ ខ្ញុំនឹងធ្វើសង្ឃភត្តដើម្បីអនុគ្រោះដល់ពួកញាតិ ។

ភិក្ខុទាំងនោះ បានប្រគេន ( ភត្តទាំងនោះ ) ដល់ព្រះថេរៈ ព្រះថេរៈបាននិមន្តសង្ឃលុះព្រះថេរៈ បានឲ្យទានហើយក៏ឧទ្ទិសចំពោះមាតាបិតា និងបងថា សូមឲ្យទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមឲ្យពួកញាតិ បានដល់នូវសេចក្តី

សុខ ។

ភោជនក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ( ភោជននោះ ) ជាភោជនដ៏ស្អាត ថ្លៃថ្លាឆ្ងាញ់ ជាម្ហូបមានឱជារសច្រើន ក្នុងកាលខាងក្រោយអំពីកាលជាទីបាននូវភោជននោះមក ប្រេតជាបងមានសម្បុរល្អ មានកម្លាំង មានសេចក្តីសុខ បានបង្ហាញខ្លួន ( ដល់ព្រះថេរៈហើយពោលថា ) បពិត្រលោកដ៏ចម្រើន សូមលោករមិលមើលនូវភោជនដ៏ច្រើន ( ដែលពួកយើងបានហើយ ដោយអានុភាពនៃទានរបស់លោក ) ប៉ុន្តែពួកយើងអាក្រាតនៅឡើយ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវសំពត់ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានរើសកំណាត់សំពត់រេចជាយទាំងឡាយអំពីគំនរនៃសំរាម ហើយធ្វើកំណាត់សំពត់ឲ្យជាផ្ទាំង គឺធ្វើជាចីវរបានប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំង ៤ ។ ព្រះថេរៈបានឲ្យទានហើយ ឧទ្ទិសដល់បិតាមាតានិងបងថា ទាននេះចូរសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខ ។

សំពត់ទាំងឡាយ ក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស លំដាប់នោះ ( ប្រេតជាបង ) ក៏ស្លៀក

ដណ្តប់សំពត់ដ៏ល្អ បានបង្ហាញខ្លួនដល់ព្រះថេរៈ ។ ( ប្រេត នោះ ) មានសម្បុរល្អ មានកម្លាំង មានសេចក្តីសុខ ( បាន និយាយថា ) បពិត្រលោកដ៏ចម្រើន សំពត់ជាគ្រឿងបិទបាំង កាយក្នុងដែនរបស់ព្រះបាទនន្ទៈទាំងប៉ុន្មាន ( សំពត់ជាគ្រឿង បិទបាំងរបស់ពួកយើង ) ច្រើនលើសជាងសំពត់ជាគ្រឿងបិទ បាំងកាយទាំងនោះ ។

សំពត់ទាំងឡាយ ជាគ្រឿងស្លៀកពាក់របស់ពួកយើង គឺ កោសេយ្យពស្ត្រ កម្ពលីយពស្ត្រ ខោមពស្ត្រ កប្បាសិក-ពស្ត្រ ជាសំពត់ធំទូលាយ មានថ្លៃច្រើន ឯសំពត់ទាំងនោះ ក៏សំយុងចុះពួដ៏អាកាស ពួកយើងនឹងស្លៀកពាក់សំពត់ទាំង នោះតាមចិត្តស្រឡាញ់ បពិត្រលោកដ៏ចម្រើន ពួកយើងគួរ បានផ្ទះដោយប្រការណា សូមលោកព្យាយាម ដោយប្រការ នោះចុះ ។

ព្រះថេរៈបានធ្វើកុដិប្រក់ដោយស្លឹក ហើយប្រគេនដល់ព្រះ សង្ឃដែលមកអំពីទិសទាំង ៤ លុះព្រះថេរៈ បានប្រគេនហើយ ឧទ្ទិសដល់បិតាមាតានិងបងថា សូមទាននេះសម្រេចដល់ពួក ញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខចុះ ។

ផ្ទះទាំងឡាយ ផ្ទះកំពូលទាំងឡាយ ជាទីនៅដែលញែក ចែក ដែលចែកដោយប្រមាណស្មើគ្នា ក៏សម្រេច ( ដល់ពួក

ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ។

ប្រេតទាំងនោះពោលថា

ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះ យ៉ាងណា ផ្ទះទាំងឡាយក្នុងមនុស្សលោកមិនដូច្នោះទេ តែផ្ទះទាំងឡាយក្នុងឋានទិព្វទាំងឡាយ យ៉ាងណា ផ្ទះទាំងឡាយ របស់ពួកយើងក្នុងបេតលោកនេះ យ៉ាងនោះដែរ ជាផ្ទះដ៏រុងរឿងអាចញុំាងទិសទាំង ៤ ឲ្យភ្លឺជុំវិញបាន ។ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានទឹកផឹក ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈបានចាក់ទឹក បំពេញធម្មក្រក ហើយប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតាមាតា និងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខ ។

ទឹកក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ស្រះបោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មនិម្មិតល្អហើយ ជ្រៅ មានជ្រុង ៤ មានទឹកដ៏ត្រជាក់ មានកំពង់ល្អ ជាស្រះត្រជាក់ មានក្លិនក្រអូបប្រៀបមិនបាន ដេរដាសដោយផ្កាឈូកនឹងផ្កាឧប្បល ពេញដោយលម្អងលើទឹក ។ ប្រេតទាំងនោះ

ផ្ទូត ផឹក ក្នុងស្រះបោក្ខណីនោះហើយ បង្ហាញខ្លួនដល់ព្រះថេរៈថា បពិត្រលោកដ៏ចម្រើន ( ពួកយើងបាន ) ទឹកច្រើនហើយ តែជើងទាំងឡាយរបស់ពួកយើងឈឺ ពុះពង ពួកយើងកាលដើរជាន់លើក្រួសរវ៉ាន លើស្បូវក្លាំង និងបន្លា រមែងខ្ទិចៗ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវយានដោយប្រការណា សូមលោកខំព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានស្បែកជើងមានជាន់ ១ ហើយបានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយក៏ឧទ្ទិសចំពោះ បិតាមាតានិងបងថា សូមទាននេះសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្ដីសុខ ។

ពួកប្រេតបានមកដោយរថ ក្នុងលំដាប់ដែលឧទ្ទិសហើយ ( និយាយថា ) បពិត្រលោកដ៏ចម្រើន ពួកយើងលោកបានអនុគ្រោះហើយ ដោយបាយផង ដោយគ្រឿងបិទបាំងផង ដោយផ្ទះផង ដោយទានទាំង ២ គឺបានីយទាននិងយានទានផង បពិត្រលោកដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោកជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណាក្នុងលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ថេរោ ចរិត្វា បិណ្ឌាយ** សេចក្ដីថា ព្រះថេរៈត្រាច់ចារិកទៅបិណ្ឌបាត ។ បទថា **ភិក្ខូ អញ្ញេ ច ទ្វាទស** សេចក្ដីថា

ភិក្ខុដែលនៅជាមួយព្រះថេរៈនិងភិក្ខុ ១២ រូបដទៃទៀត ប្រជុំរួមក្នុងទីជាមួយគ្នា ។ បើមានពាក្យសួរជ្រៀតចូលមកថាព្រោះហេតុអ្វី ឆ្លើយថា ព្រោះចំណែកពិសេសនៃភត្តជាហេតុ អធិប្បាយថា ព្រោះភត្តកិច្ចជាហេតុ គឺព្រោះការឆាន់ជាហេតុ ។ បទថា **តេ** បានដល់ និងភិក្ខុទាំងនោះ ។ បទថា **យថាលទ្ធំ** ប្រែថា តាមដែលបាន ។ បទថា **ឧទាទ** ប្រែថា ចូរឲ្យ ។

បទថា **និយ្យាទយឹសុ** ប្រែថា បានឲ្យហើយ ។ បទថា **សង្ឃំ និមន្តយិ** សេចក្តីថា និមន្តភិក្ខុ ១២ រូបនោះឯង ដើម្បីប្រគេនភត្តនោះ ដោយចំពោះអំពីសង្ឃ ។ បទថា **អន្វាទិសិ** បានដល់ ឧទ្ទិសឲ្យ ។ បណ្តា ញាតិទាំងនោះ ដើម្បីសម្តែងញាតិ ដែលខ្លួនឧទ្ទិសឲ្យទាំងនោះ ទើបលោកពោលថា **មាតុ បិតុ ច ភាតុនោ ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** ក៏ឧទ្ទិសចំពោះមាតាបិតានិងបងថា សូមឲ្យទាននេះ សម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមឲ្យពួកញាតិ បានដល់នូវសេចក្តីសុខ ដូច្នេះ ។

បទថា **សមនន្តរានុទិដ្ឋេ** ប្រែថា មួយអន្លើដោយការឧទ្ទិសនោះឯង ។ បទថា **ភោជនំ ឧបបជ្ជថ** សេចក្តីថា ភោជនរមែងកើតដល់ប្រេតទាំងនោះ ។ ដើម្បីចៀសវាងនូវពាក្យសួរថា ភោជនដូចអ្វី ទើបលោកពោលថា ជាភោជនដ៏ស្អាត ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អនេករសព្យញ្ជនំ** បានដល់ ប្រកបដោយបាយមានរសផ្សេងៗ ឬមានរសច្រើនយ៉ាង និងមានម្ហូបច្រើនយ៉ាង ។ បទថា **តតោ** បានដល់ ខាងក្រោយអំពីការបានភោជន ។

បទថា **ឧទ្ធស្សយី ភាតា** សេចក្តីថា ប្រេតដែលជាបងប្រុសបង្ហាញខ្លួន

ដល់ព្រះថេរៈ ។ បទថា **វណ្ណវា ពលវា សុខី** សេចក្តីថា ព្រោះការបាន ភោជនទោះ រំពេចនោះឯង ប្រេតនោះបរិបូរដោយរូប បរិបូរដោយកម្លាំង មានសេចក្តីសុខនោះឯង ។ បទថា **បហូតំ ភោជនំ ភន្តេ** សេចក្តីថា លោក ដ៏ចម្រើន ភោជនសន្ទឹកសន្ធាប់មិនមែនតិចដែលខ្ញុំបានហើយដោយអានុភាព ទានរបស់លោក ។ បទថា **បស្ស ឧគ្គាម្ហសេ** សេចក្តីថា សូមលោកមើល ពួកខ្ញុំដែលជាសត្វអាក្រាត ព្រោះដូច្នោះ សូមលោកព្យាយាម ធ្វើសេចក្តី ព្យាយាមយ៉ាងនោះចុះ ។ បទថា **យថា វត្ថំ លភាមសេ** សេចក្តីថា សូម អ្នកទាំងឡាយព្យាយាមដោយប្រការ គឺដោយសេចក្តីព្យាយាម ដែលយើងខ្ញុំ គប្បីបានសំពត់ចុះ ។

បទថា **សង្ការកូដម្ហា** បានដល់ ចាកគំនរសំរាមក្នុងទីនោះៗ ។ បទថា **ឧច្ចិនិត្វាន** បានដល់ កាន់យកដោយអាការស្វែងរក ។ បទថា **ឩន្តកេ** បាន ដល់ កំណាត់សំពត់ដែលគេបោល មានជាយដាច់ដាច ព្រោះសំពត់ទាំង នោះ ឈ្មោះថា ជាសំពត់ចាស់ដាច់ដាច ព្រះថេរៈយកសំពត់ទាំងនោះធ្វើជា ចីវរប្រគេនសង្ឃ ព្រោះដូច្នោះ ទើបលោកពោលថា បានរើសកំណាត់សំពត់ រេចជាយទាំងឡាយអំពីគំនរនៃសំរាម ហើយធ្វើកំណាត់សំពត់ឲ្យជាផ្ទាំង គឺ ធ្វើជាចីវរ បានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សង្ឃេ ចាតុទ្ទិសេ អទា** សេចក្តីថា បាន ប្រគេនដល់សង្ឃដែលមកអំពីទិសទាំង ៤ ។ បទថា **សង្ឃេ ចាតុទ្ទិសេ អទា** នេះ ជាសត្តមីវិភត្តិចុះក្នុងអត្ថនៃចតុត្ថីវិភត្តិ ។

បទថា **សុវណ្ណវសនោ** ប្រែថា ជាអ្នកស្លៀកដណ្តប់សំពត់ល្អ ។ បទថា **ថេរស្ស ទស្សយិតុមំ** សេចក្តីថា បង្ហាញខ្លួន គឺធ្វើខ្លួនឲ្យឃើញ បានដល់ប្រាកដដល់ព្រះថេរៈ ។ សំពត់ឈ្មោះថា **បដិច្ឆទា** ព្រោះជាទីបិទបាំង ។

បទថា **កូដាគារនិវេសនា** បានដល់ ផ្ទះដែលជាប្រាសាទ និងទីនៅអាស្រ័យដទៃក្រៅអំពីប្រាសាទនោះ ។ ពិតហើយបទថា **កូដាគារនិវេសនា** នេះ លោកពោលជាលិង្គវិបល្លាស ។ បទថា **វិភត្តា** បានដល់ ដែលគេចែកដោយសណ្ឋាន ៤ ជ្រុងស្មើគ្នា ដោយកម្ពស់និងទំហំ ។ បទថា **ភាគសោមិតា** ប្រែថា កំណត់ជាចំណែកៗ ។ បទថា **នោ** បានដល់ របស់យើងខ្ញុំទាំងឡាយ ។ បទថា **ឥធ** បានដល់ ក្នុងបេតលោកនេះ ។ សព្ទថា **អបិ** ក្នុងបទថា **អបិ ទិព្វេសុ** នេះត្រឹមតែជានិបាតអធិប្បាយថា ក្នុងទេវលោក ។

បទថា **ករកំ** បានដល់ ធម្មក្រក ។ បទថា **បូរេត្វា** ប្រែថា ពេញដោយទឹក ។ បទថា **វារិកិញ្ជក្ខបូរិតា** បានដល់ លើទឹកក្នុងទីនោះៗដេរដាសដោយកេសរបទុមនិងឧប្បលជាដើម ។ បទថា **ផលន្តិ** ប្រែថា រមែងរីក អធិប្បាយថា បែកត្រង់កែងជើងនិងជុំវិញបាតជើងជាដើម ។

បទថា **អាហិណ្ឌមានា** បានដល់ ត្រាច់ទៅ ។ បទថា **ខញ្ជាម** ប្រែថា ខ្វើចៗ ។ បទថា **សក្ខរេ កុសកណ្ដកេ** បានដល់ ក្នុងភូមិភាគដែលមានដុំក្រួសនិងពន្លាកស្បូវភ្លាំង អធិប្បាយថា ជាន់លើដុំក្រួសនិងពន្លាកស្បូវភ្លាំង ។ បទថា **យានំ** បានដល់ យានឯណានីមួយ មានរថនិងរថអូសដោយដៃជាដើម ។ បទថា **សិវាដិកំ** បានដល់ ស្បែកជើង ១ ជាន់ ។

**ម** អក្ខរៈ ក្នុងបទថា **រថេន មាគម្មុំ** នេះ ធ្វើការភ្ជាប់បទ គឺមកដោយរថ ។ បទថា **ឧភយំ** ប្រែថា ដោយការឲ្យទាំង ២ គឺដោយការឲ្យយាននិងដោយការឲ្យបច្ច័យ ៤ មានកត្តជាដើម ពិតហើយ ក្នុងការឲ្យ ២ យ៉ាងនោះ សូម្បីការឲ្យភេសជ្ជៈ លោកក៏សង្គ្រោះដោយការឲ្យទឹកផឹក ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើមនោះឯង ។

ព្រះថេរៈក្រាបទូលរឿងនោះ ដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបត្រាស់ថា ប្រេតទាំងនេះរមែងសោយមហាទុក្ខក្នុងឥឡូវនេះ យ៉ាងណា សូម្បីអ្នកក៏ដូច្នោះ ជាប្រេតក្នុងអត្តភាពដែលជាលំដាប់ក្នុងអតីត រមែងសោយទុក្ខធំ ដូច្នេះហើយ កាលព្រះថេរៈទូលអារាធនា ទើបទ្រង់សម្ដែងសុត្តប្រេត ហើយទ្រង់សម្ដែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ មហាជនបានស្ដាប់រឿងនោះហើយ កើតនូវសេចក្ដីសង្វេគ បានជាអ្នកត្រេកអរក្នុងបុញ្ញកម្ម មានទាននិងសីលជាដើម ។

## អដ្ឋកថា សានុវាសិប្រេតចប់

# រឿង រថការីប្រេតទី៣

[ ២៨ ] ( មាណពនិយាយនឹងស្រីប្រេតថា ) បពិត្រនាងទេវីមានអានុភាពច្រើន នាងឡើងកាន់វិមាន មានសសរកែវពិទូរ្យដ៏រុងរឿងភ្លឺផ្លេកៗវិចិត្រដោយរតនៈច្រើនយ៉ាង ហើយនៅក្នុងវិមាននោះ ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត នៅក្នុងផ្លូវជាគន្លង ( របស់ខ្លួន ) ទាំងសម្បុររបស់នាងសោត ប្រាកដស្មើដោយមាស មានសភាពខ្ពង់ខ្ពស់ គួរឲ្យរមិលមើលក្រៃពេក បពិត្រ នាងមិនមានគេផ្ទឹមបាន នាងគង់លើបល្ល័ង្កដ៏ប្រសើរបំផុត នាងនៅតែម្នាក់ឯងនាងមិនមានប្តីសោះ ។ ឯស្រះបោក្ខរណីទាំងឡាយរបស់នាងនេះ មានកម្រងផ្កាច្រើនយ៉ាង មានផ្កាឈូកសច្រើនដោយជុំវិញ រោយរាយជុំវិញដោយកំទេចនៃមាសទាំងឡាយ ភក់និងចក ក៏មិនមានក្នុងស្រះបោក្ខរណីទាំងនោះ ។ សូម្បីហង្សទាំងនេះ គួររមិលមើល គួររីករាយនៃចិត្ត ក៏ហែលក្រឡឹងលើទឹកសព្វៗកាល ហង្សទាំងអស់មានសំឡេងមូល ដូចជាសំឡេងគឹកកងនៃស្គរទាំងឡាយ ប្រជុំគ្នាបន្លឺឡើងនូវសំឡេងដ៏ពីរោះ ។ នាងជាអ្នកមានយសរុងរឿងដោយយស ឈរផ្អែកលើទូក បពិត្រនាងមានរោមភ្នែកខ្មៅ វែង ង នាងសើច នាងពោល នូវពាក្យជាទីស្រឡាញ់ មានលម្អសព្វអវយវៈ រុងរឿងក្រៃពេក ។ វិមាននេះ ប្រាសចាកធូលី តាំងនៅលើផែនដីរាប ជាឧទ្យាន ញុំាងសេចក្តីត្រេកអរនិងសេចក្តីរីករាយឲ្យចម្រើន បពិត្រនារីគួររមិលមើលមិនថោកទាប ខ្ញុំប្រាថ្នាដើម្បីរីករាយក្នុងវិមានជាទីរីករាយនេះរបស់នាងជាមួយនឹងនាង ។

( នាងវិមានប្រេតពោលថា ) អ្នកចូរធ្វើនូវកម្មដែលឲ្យផលក្នុងឋានទិព្វ

នេះ ទាំងចិត្តរបស់អ្នកសោត ក៏ចូរឱនទៅក្នុងឋានទិព្វនេះ លុះអ្នកធ្វើនូវកម្ម ដែលគួរកើតក្នុងឋានទិព្វនេះហើយ ទើបអ្នកបាននូវខ្ញុំជាស្រីមានកាមតាមប្រាថ្នា ដោយប្រការយ៉ាងនេះ ។

មាណពនោះ បានទទួលស្តាប់ពាក្យនាងវិមានប្រេតនោះថា អើនាងស្រួលហើយ ហើយក៏បានធ្វើកម្មដែលឲ្យផលក្នុងឋានទិព្វនោះ លុះមាណពបានធ្វើកម្ម ដែលឲ្យផលក្នុងឋានទិព្វនោះហើយ ក៏បានទៅកើតជាមួយនឹងនាងវិមានប្រេតនោះ ។

## ចប់ រឿងរថការីប្រេត ទី ៣ ។

## ចប់ ភាណវារៈទី ២ ។

# អដ្ឋកថា រថការីប្រេត

[ ២៨ ] ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធស្រីប្រេតម្នាក់ ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **វេឡុរិយថម្ភំ រុចិរំ បភស្សរំ** ដូច្នេះជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងកាលនៃព្រះមានព្រះភាគទ្រង់ព្រះនាមថាកស្សបៈ ស្រីម្នាក់បរិបូណ៌ដោយសីលនិងអាចារ មានកល្យាណមិត្តជាទីអាស្រ័យ ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា បានសាងអាវាសមួយកន្លែង ល្អគួរមើល មានជញ្ជាំង សសរ ជណ្តើរនិងផ្ទៃដីដ៏វិចិត្រ ដែលចែកទុកដោយល្អ និមន្តភិក្ខុទាំងឡាយឲ្យអង្គុយក្នុងអាវាសនោះ អង្គាសដោយបណីតភោជន ហើយវេរដល់សង្ឃ ។ សម័យតមក នាងធ្វើកាលកិរិយាហើយ កើតជាវេមានិកប្រេត អាស្រ័យស្រះឈ្មោះរថការត្រង់ជើងភ្នំហិមពាន្ត ដោយអំណាចនៃកម្មឯណានីមួយ ។ ដោយអានុភាពបុណ្យ ដែលនាងថ្វាយអាវាសដល់សង្ឃ វិមានដែលសម្រេចដោយរតនៈគ្រប់យ៉ាងដ៏ធំ មានទីជុំវិញគួរជាទីត្រេកអរ គួរជាទីត្រេកត្រអាលក្រៃលែង ល្អដូចនន្ទនវ័ន កើតឡើងដល់នាង ក្បែរស្រះបោក្ខរណី ឯខ្លួននាងក៏មានពណ៌សម្បុរដូចមាស ល្អគួរសរសើរ ។

ប្រាសាទរបស់នាងមិនមានបុរស នាងសោយទិព្វសម្បត្តិក្នុងទីនោះកាលមិនមានបុរសក្នុងទីនោះអស់កាលយូរ ក៏កើតសេចក្តីអផ្សុក នាងពិចារណាថា ឧបាយនេះប្រើការបាន ក៏បេះផ្លែស្វាយទិព្វទម្លាក់ក្នុងស្ទឹង ។ ពាក្យទាំងអស់ គប្បីជ្រាបដោយន័យដែលពោលមកហើយក្នុងរឿងកណ្ណមុណ្ឌប្រេតនោះឯង ។ ក្នុងរឿងនេះ មានមាណពម្នាក់ អ្នកក្រុងពារាណសីឃើញផ្លែស្វាយ

មួយបណ្ដាស្វាយទាំងនោះក្នុងស្ទឹងគង្គា កាលពិចារណាទីមករបស់ផ្លែស្វាយ ទើបទៅកាន់ទីនោះដោយលំដាប់ បានឃើញស្ទឹង ទើបទៅកាន់លំនៅរបស់នាងដោយទំនងនោះ នាងឃើញដូច្នោះ ក៏នាំទៅកាន់លំនៅរបស់ខ្លួន ធ្វើបដិសណ្ឋារៈហើយអង្គុយ មាណពកាលឃើញភាពសម្បូរនៃលំនៅ របស់នាងកាលនឹងសួរ ទើបពោលគាថាទាំងនេះថា

បពិត្រនាងទេវី មានអានុភាពច្រើន នាងឡើងកាន់វិមាន មានសសរកែវពិទូរ្យ ដ៏រុងរឿងភ្លឺផ្លេកៗ វិចិត្រដោយរតនៈច្រើនយ៉ាង ហើយនៅក្នុងវិមាននោះ ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត នៅក្នុងផ្លូវជាគន្លង ( របស់ខ្លួន ) ទាំងសម្បុររបស់នាងសោតប្រាកដស្មើដោយមាស មានសភាពខ្ពង់ខ្ពស់គួរឲ្យរមិលមើលក្រៃពេក បពិត្រនាងមិនមានគេផ្ទឹមបាន នាងគង់លើបល្ល័ង្កដ៏ប្រសើរបំផុត នាងនៅតែម្នាក់ឯង នាងមិនមានប្ដីសោះ ។ ឯស្រះបោក្ខរណីទាំងឡាយ របស់នាងនេះមាន កម្រងផ្កាច្រើនយ៉ាង មានផ្កាឈូកសច្រើនដោយជុំវិញ រោយរាយជុំវិញដោយកំទេចនៃមាសទាំងឡាយ ភក់និងចក ក៏មិនមានក្នុងស្រះបោក្ខរណីទាំងនោះ ។ សូម្បីហង្សទាំងនេះ គួររមិលមើល គួររីករាយនៃចិត្ត ក៏ហែលក្រឡឹងលើទឹក សព្វៗកាល ហង្សទាំងអស់មានសំឡេងមូល ដូចជាសំឡេងគឹកកងនៃស្គរទាំងឡាយ ប្រជុំគ្នាបន្លឺឡើងនូវសំឡេងដ៏ពីរោះ ។ នាងជាអ្នកមានយស

រុងរឿងដោយយស ឈរផ្អែកលើទូក បពិត្រនាងមានរោម-
ភ្នែកខ្មៅ វែង ៗ នាងសើច នាងពោលនូវពាក្យជាទីស្រឡាញ់
មានលម្អសព្វអវយវៈរុងរឿងក្រៃពេក ។ វិមាននេះ ប្រាស
ចាកធូលី តាំងនៅលើផែនដីរាប ជាឱទ្យានញុំាងតម្រេកនិង
សេចក្តីរីករាយឲ្យចម្រើន បពិត្រនារីគួររមិលមើល មិនថោក
ទាប ខ្ញុំប្រាថ្នាដើម្បីរីករាយក្នុងវិមានជាទីរីករាយនេះរបស់នាង
ជាមួយនឹងនាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងវិមាននោះ ។ បទថា **អច្ឆសិ** បានដល់ អង្គុយក្នុងកាលដែលប្រាថ្នាហើយ ។ មាណពហៅប្រេតនោះថា **ទេវិ** ។ បទថា **មហានុភាវេ** បានដល់ ប្រកបដោយទិព្វានុភាពធំ ។ បទថា **បថន្ធុនិ** បានដល់ ផ្លូវឆ្ងាយដែលជាផ្លូវរបស់ខ្លួន អធិប្បាយថា ផ្លូវអាកាស ។ បទថា **បណ្ណរសេវ ចន្ទោ** សេចក្តីថា រុងរឿងដូចព្រះចន្ទដែលមានមណ្ឌលបរិបូណ៌ក្នុងថ្ងៃ ១៥ កើត ។

បទថា **វណ្ណោ ច តេ កនកស្ស សន្និភោ** សេចក្តីថា ពណ៌សម្បុររបស់នាងដូចមាសសិង្គីធិនធ្លៅ គួរជាទីត្រេកអរក្រៃពេក ។ ដោយហេតុនោះទើបមាណពពោលថា មានសភាពខ្ពង់ខ្ពស់គួរឲ្យរមិលមើលក្រៃពេកដូច្នេះ ។ បទថា **អតុលេ** បានដល់ គួរដល់ថ្លៃច្រើន ។ ម្យ៉ាងទៀត ពាក្យថា **អតុលេ** ជាពាក្យហៅទេវតា អធិប្បាយថា មានរូបមិនមានអ្នកណាដូច ។ បទថា **នត្ថិ ច តុយ្ហំ សាមិកោ** សេចក្តីថា ប្តីរបស់នាងមិនមានទេឬ ។

បទថា **បហូតមល្យា** បានដល់ មានផ្កាច្រើនប្រភេទ មានផ្កាឈូក និងផ្កាលំចង់ជាដើម ។ បទថា **សុវណ្ណចុណ្ណេហិ** ប្រែថា ដោយខ្សាច់មាស ។ បទថា **សមន្តមោត្ថតា** ប្រែថា ដេរដាសដោយជុំវិញ ។ បទថា **តត្ថ** បានដល់ ក្នុងស្រះបោក្ខរណីទាំងឡាយនោះ ។ បទថា **បង្កោ បណកោ ច** សេចក្ដីថា មិនមានភក់ឬចកសារាយក្នុងទឹក ។

បទថា **ហំសា ចិមេ ទស្សនីយា មនោរមា** សេចក្ដីថា ហង្សទាំងនេះ មើលហើយ កើតសេចក្ដីសុខ គួរជាទីត្រេកអរនៃចិត្ត ។ បទថា **អនុបរិយន្តិ** បានដល់ អន្ទោលទៅ ។ បទថា **សព្វទា** បានដល់ គ្រប់រដូវកាល ។ បទថា **សមយ្យ** ប្រែថា ប្រជុំគ្នា ។ បទថា **វគ្គុ** ប្រែថា ពីរោះ ។ បទថា **ឧបនទន្តិ** ប្រែថា ស្រែកយំ ។ បទថា **ពិន្ទុស្សរា** បានដល់ មានសំឡេងមិនស្អកស្អា គឺមានសំឡេងមូល ។ បទថា **ទុន្ទុភីនំ វ ឃោសោ** សេចក្ដីថា សំឡេងយំរបស់ពួកហង្សក្នុងស្រះបោក្ខរណីរបស់នាង ដូចគ្នានឹងសំឡេងស្គរ ព្រោះពីរោះ និងមានសំឡេងមូល ។

បទថា **ទទ្ទល្លមានា** បានដល់ រុងរឿងក្រៃលែង ។ បទថា **យសសា** បានដល់ ជាអ្នកមានទេវឫទ្ធិ ។ បទថា **នាវាយ** បានដល់ ក្នុងទូកកម្រោល ។ ពិតហើយ មាណពឃើញប្រេតនោះអង្គុយលើបល្ល័ង្កដែលមានតម្លៃច្រើនក្នុងទូកមាស កំពុងលេងទឹកក្នុងស្រះបោក្ខរណីដែលមានគុម្ពឈូក ទើបពោលយ៉ាងនោះ ។ បទថា **អវលម្ព** សេចក្ដីថា ផ្អែកត្រង់ខ្នើយ ។ ពាក្យថា **តិដ្ឋសិ** នេះ ជាពាក្យហាមការទៅ ព្រោះ **ឋាន** សព្ទ មានការហាមការទៅជាអត្ថ ។

បាលីថា **និសជ្ជសិ** ដូច្នេះក៏មាន គប្បីឃើញអត្ថនៃបទថា **និសជ្ជសិ** ជា **និសីទសិ** ប្រែថា អង្គុយនោះឯង ។ បទថា **អាឡារបម្ហេ** បានដល់ មានរោមភ្នែកខ្មៅវែង ៗ ។ បទថា **ហាសិតេ** ប្រែថា មានមុខរីករាយពន់ពេក ។ បទថា **បិយំវទេ** ប្រែថា និយាយគួរស្រឡាញ់ ។ បទថា **សព្វង្គកល្យាណិ** ប្រែថា ល្អដោយអវយវៈទាំងពួង គឺមានអវយវៈល្អគ្រប់ចំណែក ។ បទថា **វិរោចសិ** ប្រែថា រុងរឿងក្រៃលែង ។

បទថា **វិរជំ** ប្រែថា ប្រាសចាកធូលី គឺមិនមានទោស ។ បទថា **សមេ មិតំ** បានដល់ តាំងនៅត្រង់ផ្ទៃដីរាបស្មើឬតាំងនៅត្រង់ចំណែកដែលស្មើព្រោះល្អទាំង ៤ ចំណែក អធិប្បាយថា ល្អដោយជុំវិញ ។ បទថា **ឧយ្យានវន្តំ** បានដល់ ប្រកបដោយសួនឧទ្យានវន ។ បទថា **រតិនន្ទិវឌ្ឍនំ** សេចក្តីថា ឈ្មោះថា **រតិនន្ទិវឌ្ឍន** ព្រោះធ្វើនូវការត្រេកអរនិងការត្រេកត្រអាលចិត្តឲ្យចម្រើន អធិប្បាយថា ធ្វើសុខនិងបីតិឲ្យចម្រើន ។ ពាក្យថា **នារិ** ជាពាក្យហៅស្រីប្រេតនោះ ។ បទថា **អនោមទស្សនេ** បានដល់ ឃើញមិនគួរតិះដៀល ព្រោះមានអវយវៈតូចធំបរិបូណ៌ ។ បទថា **នន្ទនេ** បានដល់ ធ្វើនូវការត្រេកអរ ។ បទថា **ឥធ** ប្រែថា ក្នុងឧទ្យាននន្ទនវននេះឬក្នុងវិមាននេះ ។ បទថា **មោទិតុំ** មានវាចាប្រកបសេចក្តីថា ខ្ញុំប្រាថ្នាដើម្បីអភិរម្យ ។

កាលមាណពនោះពោលយ៉ាងនេះហើយ វេមានិកប្រេតនោះ កាលនឹងឆ្លើយជាមួយមាណពនោះ ទើបពោលថា

អ្នកចូរធ្វើនូវកម្ម ដែលឲ្យផលក្នុងឋានទិព្វនេះ ទាំងចិត្តរបស់

អ្នកសោត ក៏ចូរឱនទៅក្នុងឋានទិព្វនេះ លុះអ្នកធ្វើនូវកម្មដែល
គួររីករាយក្នុងឋានទិព្វនេះហើយ ទើបអ្នកបាននូវខ្ញុំជាស្រីមាន
កាមតាមប្រាថ្នា ដោយប្រការយ៉ាងនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ករោហិ កម្មំ ឥធ វេទនីយំ** សេចក្ដីថា ចូរអ្នកធ្វើ គឺគប្បីបានជួបនូវកុសលកម្មដែលឲ្យផល គឺឲ្យផលក្នុងទិព្វស្ថាននេះ ។ បទថា **ឥធ និហិតំ** បានដល់ បង្អោនចិត្តចូលទៅក្នុងវិមាននេះ ។ បាលីថា **ឥធ និន្នំ** ដូច្នេះក៏មាន អធិប្បាយថា ចិត្តរបស់អ្នកចូរបង្អោន គឺបង្អោនទៅក្នុងទីនេះ ។ បទថា **មមំ** ប្រែថា នូវខ្ញុំ ។ បទថា **លច្ឆសិ** ប្រែថា នឹងបាន ។

មាណពនោះ បានស្ដាប់ពាក្យរបស់វេមានិកប្រេតនោះហើយ ចេញអំពីទីនោះ ទៅកាន់ដែនដីមនុស្ស តាំងចិត្តទុកក្នុងទីនោះ ធ្វើបុញ្ញកម្មដែលកើតអំពីចិត្តនោះ មិនយូរប៉ុន្មាន ធ្វើកាលកិរិយាកើតក្នុងវិមាននោះ ចូលដល់ភាពជាសម្លាញ់ជាមួយនឹងប្រេតនោះ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលប្រកាសសេចក្ដីនោះ ទើបពោលគាថាចុងក្រោយថា

មាណពនោះ បានទទួលស្ដាប់ពាក្យនាងវិមានប្រេតនោះថា អើ
នាង ស្រួលហើយ ហើយក៏បានធ្វើកម្មដែលឲ្យផលក្នុងឋាន
ទិព្វនោះ លុះមាណពបានធ្វើកម្មដែលឲ្យផលក្នុងឋានទិព្វនោះ
ហើយក៏បានទៅកើតជាមួយនឹងនាងវិមានប្រេតនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាធុ** ជានិបាត ប្រើក្នុងអត្ថសម្បដិច្ឆនត្ថៈ ។

បទថា **តស្សា** បានដល់ នាងវេមានិកប្រេតនោះ ។ បទថា **បដិស្សុណិត្វា** បានដល់ ទទួលពាក្យរបស់ស្រីប្រេតនោះ ។ បទថា **តហឹ វេទនីយំ** បាន ដល់ កុសលកម្មដែលមានផលជាសុខដែលគប្បីបានទទួលនាងវេមានិកប្រេត នោះ ក្នុងវិមាននោះ ។ បទថា **សហាព្យតំ** គឺនូវការរួមគ្នា មានវាចាប្រកប សេចក្តីថា មាណពនោះ ចូលដល់ភាពជាសម្លាញ់ជាមួយនាងវេមានិកប្រេត នោះ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

កាលជនទាំងនោះ សោយទិព្វសម្បត្តិក្នុងវិមាននោះ អស់កាលយូរយ៉ាង នេះ បុរសក៏ធ្វើកាលកិរិយាព្រោះអស់កម្ម តែស្រីនោះព្រោះបុញ្ញកម្មរបស់ខ្លួន ដល់នូវខេត្តសម្បត្តិ ទើបនៅក្នុងវិមាននោះរហូតមួយពុទ្ធន្តរ ។ កាលព្រះមាន ព្រះភាគនៃយើង កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្រដ៏បវរ គង់នៅ ក្នុងជេតពនមហាវិហារដោយលំដាប់ ។ ថ្ងៃមួយព្រះមហាមោគ្គល្លានចារិកទៅ លើភ្នំ ឃើញវិមាននិងវេមានិកប្រេតនោះ ទើបសួរដោយគាថាជាដើមថា **វេ-ឡុរិយថម្ភំ រុចិរំ បភស្សរំ** ដូច្នេះ នាងវេមានិកប្រេតនោះ បាននិទានប្រវត្តិ របស់ខ្លួនទាំងអស់ដល់ព្រះមហាមោគ្គល្លានតាំងពីដើមដល់ចប់ ។ ព្រះថេរៈ បានស្តាប់ដូច្នោះហើយ មកកាន់ក្រុងសាវត្ថី ក្រាបទូលដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ដល់ បរិស័ទដែលដល់ហើយ មហាជនបានស្តាប់ដូច្នោះហើយ ជាអ្នកត្រេកអរក្នុង បុណ្យ មានទានជាដើម ដូច្នេះ ។

អដ្ឋកថា រថការីប្រេតចប់

# រឿង កុសប្រេត ទី៤

[ ២៩ ] ( ព្រះមោគ្គល្លានសួរថា ) ប្រេតម្នាក់ ( ពេយពាយ ) អង្កាម នៃស្រូវសាលី ( លើក្បាលខ្លួន ) ប្រេតម្នាក់ទៀត ( សំពងបំបែកក្បាល របស់ខ្លួនដោយដំបងដែក ) ឯស្រីនេះ ( ស៊ីតែ ) សាច់និងឈាមរបស់ខ្លួន ទាំងអ្នកសោត ក៏ស៊ីអាចម៍ មិនស្អាត មិនគួរឲ្យប្រាថ្នា នេះតើជាផលនៃកម្ម ដូចម្ដេច ។

( ភរិយារបស់ពាណិជ្ជបានទូលថា ) ក្នុងកាលមុន ប្រេតម្នាក់នេះ បាន ប្រហារមាតា ( ដោយព្រនង់ ) ឯប្រេតម្នាក់នេះ ជាពាណិជ្ជបោកប្រាស់ ប្រេត នេះរមែងស៊ីសាច់ទាំងឡាយ ហើយបញ្ឆោតដោយពាក្យមុសាវាទ ។

ខ្ញុំបានកើតជាមនុស្ស ក្នុងពួកមនុស្ស ជាអ្នកគ្រប់គ្រងផ្ទះ ជាឥស្សរនៃ ត្រកូលទាំងពួង ។

កាលដែលគ្រឿងឧបករណ៍មានគ្រប់គ្រាន់ ខ្ញុំក៏បានលាក់លៀមទុក មិន បានឲ្យវត្ថុតិចតួចអំពីគ្រឿងឧបករណ៍នេះ ( ដល់អ្នកដទៃ ) ខ្ញុំបិទបាំងដោយ ពាក្យមុសាវាទថា វត្ថុនេះក្នុងផ្ទះខ្ញុំមិនមានទេ ប្រសិនបើខ្ញុំលាក់វត្ថុដែលមាន សូមឲ្យអាចម៍មកជាភោជនរបស់ខ្ញុំចុះ ។ បាយនៃស្រូវសាលី មានក្លិនក្រអូប ឈ្ងុយ ក៏ក្លាយទៅជាអាចម៍ដើម្បីខ្ញុំ ដោយវិបាកនៃកម្មទាំងពីរ គឺ ( ការ លាក់លៀមទុកវត្ថុដែលមាន ១ ) និងមុសាវាទ ១ ។ ឯកម្មទាំងឡាយមិន មែនសោះសូន្យឡើយ ព្រោះថា កម្មមិនចេះវិនាសទៅ ខ្ញុំស៊ីផឹកនូវអាចម៍ មានក្លិនអាក្រក់ ( ជាលំនៅ ) នៃពួកដង្កូវ ។

**ចប់ រឿងកុសប្រេតទី ៤ ។**

# អដ្ឋកថា ភុសប្រេត

[ ២៩ ] កាលព្រះសាស្ដាគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធប្រេត ៤ នាក់ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ភុសានិ ឯកោ សា-លឹ បុនាបរោ** ដូច្នេះជាដើម ។

បានឮថា ក្នុងភូមិមួយ មិនឆ្ងាយអំពីក្រុងសាវត្ថី មានឈ្មួញម្នាក់ចិញ្ចឹមជីវិតដោយអនេសនាកម្ម មានការគៃដោយជញ្ជីងជាដើម កាន់យកសំដីស្រូវសាលី លាយដោយដី ធ្វើឲ្យធ្ងន់ជាងមុន លាយជាមួយស្រូវសាលីក្រហមហើយលក់ ។ កូនរបស់បុរសនោះមានចិត្តកម្រើក ( ខឹងក្រោធ ) ពោលថា ម៉ែមិនព្រមឲ្យកិត្តិយសដល់មិត្តសម្លាញ់របស់អញដែលមកកាន់ផ្ទះ បានកាន់យកខ្សែព្រ័ត្រ ២ សរសៃវាយក្បាលមាតា ។ ស្រីកូនប្រសាលួចស៊ីសាច់ ដែលអាំងទុកសម្រាប់ជនទាំងពួង ហើយកាលត្រូវជនទាំងនោះដេញដោល ក៏បានធ្វើសម្បថថា បើខ្ញុំបានស៊ីសាច់នោះ សូមឲ្យខ្ញុំខ្វេះសាច់ខ្នងខ្លួនឯងស៊ីគ្រប់ៗជាតិទៅចុះ ។ ចំណែកកិរិយារបស់ឈ្មួញនោះ កាលជនទាំងឡាយនាំគ្នាសូមឧបករណ៍ឯណានីមួយ ក៏ឆ្លើយថា មិនមាន កាលជនទាំងនោះរំអុក ក៏បានស្បថដោយមុសាវាទថា បើខ្ញុំពោលវត្ថុដែលមានថាមិនមានសោត សូមឲ្យខ្ញុំជាអ្នកមានលាមកជាអាហារក្នុងទីដែលកើតហើយចុះ ។

សម័យតមក ជនទាំង ៤ នាក់នោះ ធ្វើកាលកិរិយាហើយកើតជាប្រេតក្នុងព្រៃវិញ្ឈ: ( ព្រៃដែលមានផ្លូវកន្តារឆ្លងកាត់ ) ក្នុងជនទាំង ៤ នោះ ឈ្មួញកោងយកដៃទាំង ២ ក្បង់អង្កាមដែលឆេះដោយភ្លើង ដោយផលកម្ម ហើយរោយលើក្បាលរបស់ខ្លួនឯង សោយទុក្ខយ៉ាងមហន្ត កូនរបស់បុរសនោះប្រើ

ដំបងដែកវាយក្បាលខ្លួនឯង សោយទុក្ខមហិមា ស្រីកូនប្រសា ដោយផល នៃកម្មប្រើក្រចកទាំងឡាយដែលធំផង វែងផងមុតផង ខ្វារសាច់ខ្លួនខ្លួនឯង បរិភោគ សោយទុក្ខប្រមាណមិនបាន ។ ភរិយារបស់ឈ្មួញនោះបង្អោនបាយ ស្រូវសាលីដែលមានក្លិនក្រអូបបរិសុទ្ធប្រាសចាកមន្ទិលចូលទៅប៉ុណ្ណោះ ក៏ សម្រេចជាលាមក ដេរដាសដោយពួកដង្កូវច្រើនប្រភេទ មានក្លិនស្អុយគួរ ខ្ពើមក្រៃលែង ភរិយានោះយកដៃទាំង ២ ក្បង់លាមកនោះបរិភោគ សោយ ទុក្ខយ៉ាងទារុណ ។

កាលជនទាំង ៤ នាក់នោះ កើតក្នុងពួកប្រេត សោយទុក្ខដ៏ពន្លឹកដោយ អាការយ៉ាងនេះ ព្រះមហាមោគ្គល្លាន កាលចារិកទៅលើភ្នំ ថ្ងៃមួយ ទៅដល់ ទីនោះ ឃើញប្រេតទាំងនោះ ក៏សួរដល់កម្មដែលប្រេតទាំងនោះធ្វើ ដោយ គាថានេះថា

> ប្រេតម្នាក់ ( រោយរាយ ) អង្កាមនៃស្រូវសាលី ( លើក្បាល ខ្លួន ) ប្រេតម្នាក់ទៀត ( សំពងបំបែកក្បាលរបស់ខ្លួនដោយ ដំបងដែក ) ឯស្រីនេះ ( ស៊ីតែ ) សាច់និងឈាមរបស់ខ្លួន ទាំងអ្នកសោត ក៏ស៊ីអាចម៍ មិនស្អាត មិនគួរឲ្យប្រាថ្នានេះតើ ជាផលនៃកម្មដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភុសានិ** បានដល់ អង្កាម ។ បទថា **ឯកោ** ប្រែថា ប្រេតម្នាក់ ។ បទថា **សាលឹ** ប្រែថា ស្រូវសាលី ។ ពិតហើយ បទថា **សាលឹ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ អធិប្បាយថា រោយ

អន្លាមនៃស្រូវសាលីដែលភ្លើងកំពុងឆេះលើក្បាលរបស់ខ្លួន ។ បទថា **បុនា-បរោ** កាត់បទជា **បុន អបរោ** ប្រែថា ម្នាក់ទៀត ។ ពិតហើយ លោកពោលសំដៅដល់ បុរសដែលវាយក្បាលម្តាយ ហើយយកដំបងដែក វាយក្បាលខ្លួនឯង រហូតដល់បែក ។ បទថា **សកមំសលោហិតំ** មានវាចាប្រកបសេចក្តីថា រមែងស៊ីសាច់ខ្នងនិងឈាមខ្លួនឯង ។ បទថា **អកន្តំ** ប្រែថា មិនគួរគាប់ចិត្ត គឺគួរខ្ពើម ។ បទថា **កិស្ស អយំ វិបាកោ** សេចក្តីថា នេះជាផលនៃបាបកម្មប្រភេទណាដែលពួកអ្នកសោយក្នុងឥឡូវនេះ ។

កាលព្រះថេរៈសួរដល់កម្ម ដែលជនទាំងនោះធ្វើយ៉ាងនេះ ករិយារបស់ឈ្មួញកោងកាលប្រាប់ដល់កម្មដែលជនទាំងនោះធ្វើ ទើបពោលគាថាថា

ក្នុងកាលមុន ប្រេតម្នាក់នេះ បានប្រហារមាតា ( ដោយព្រនង់ ) ឯប្រេតម្នាក់នេះ ជាពាណិជ្ជបោកប្រាស់ ប្រេតនេះរមែងស៊ីសាច់ទាំងឡាយ ហើយបញ្ឆោតដោយពាក្យមុសាវាទ ។

ខ្ញុំបានកើតជាមនុស្សក្នុងពួកមនុស្ស ជាអ្នកគ្រប់គ្រងផ្ទះជាឥស្សរនៃត្រកូលទាំងពួង ។

កាលដែលគ្រឿងឧបករណ៍ មានគ្រប់គ្រាន់ ខ្ញុំក៏បានលាក់លៀមទុក មិនបានឲ្យវត្ថុតិចតួចអំពីគ្រឿងឧបករណ៍នេះ ( ដល់អ្នកដទៃ ) ខ្ញុំបិទបាំងដោយពាក្យមុសាវាទថា វត្ថុនេះក្នុងផ្ទះខ្ញុំមិនមានទេ ប្រសិនបើ ខ្ញុំលាក់វត្ថុដែលមាន សូមឲ្យអាចម៍មកជាភោជនរបស់ខ្ញុំចុះ ។ បាយនៃស្រូវសាលីមានក្លិនក្រអូប

ឈ្មុយ ក៏ក្លាយទៅជាអាចម៍ដើម្បីខ្ញុំ ដោយវិបាកនៃកម្មទាំងពីរ គឺ ( ការលាក់លៀមទុកវត្ថុដែលមាន ១ ) និងមុសាវាទ ១ ។ ឯកម្មទាំងឡាយ មិនមែនសោះសូន្យឡើយ ព្រោះថា កម្មមិនចេះវិនាសទៅ ខ្ញុំស៊ីផឹកនូវអាចម៍មានក្លិនអាក្រក់ ( ជាលំនៅ ) នៃពួកជន្ទ្វ ដូច្នេះ ។

ស្រីប្រេត កាលសម្តែងដល់កូនប្រុស ទើបពោលថា **អយំ** ក្នុងគាថានោះ ។ បទថា **ហឹសតិ** បានដល់ ប្រើកម្លាំងបៀតបៀន អធិប្បាយថា ប្រើដំបងវាយ ។ បទថា **កូដវាណិជោ** បានដល់ ឈ្មួញអាក្រក់ អធិប្បាយ ថាលក់ដូរដោយការបោកបញ្ឆោត ។ បទថា **មំសានិ ខាទិត្វា** សេចក្តីថា ស៊ីសាច់អាំងទូទៅរបស់អ្នកដទៃ ហើយបោកបញ្ឆោតជនទាំងនោះ ដោយមុសាវាទថា ខ្ញុំមិនបានស៊ី ។

បទថា **អគារិនី** បានដល់ ស្រីមេផ្ទះ ។ បទថា **សន្តេសុ** សេចក្តីថា កាលគ្រឿងឧបករណ៍ដែលជនពួកដទៃសូម ( ខ្ញុំ ) មាននោះឯង ។ បទថា **បរិគុហាមិ** ប្រែថា បិទបាំង ។ ពិតហើយ ពាក្យថា **បរិគុហាមិ** នេះ លោកពោលដោយ កាលវិបល្លាស ។ បទថា **មា ច កិញ្ចិ ឥតោ អទំ** សេចក្តីថា ខ្ញុំមិនបានឲ្យ សូម្បីត្រឹមតែវត្ថុណាមួយ ចាកវត្ថុដែលជារបស់ខ្ញុំ ដល់ជនដទៃដែលត្រូវការ ។ បទថា **ឆាទេមិ** សេចក្តីថា បិទបាំងដោយមុសាវាទថា វត្ថុនេះមិនមានក្នុងផ្ទះរបស់ខ្ញុំ ។

បទថា **គូថំ មេ បរិវត្តតិ** សេចក្តីថា ស្រូវសាលីមានក្លិនក្រអូប តែង

ក្លាយ គឺប្រែទៅជាលាមក ដោយអំណាចកម្មរបស់ខ្ញុំ ។ បទថា **អវញ្ឈានិ** បានដល់ មិនសូន្យទទេ គឺមិនឥតផល ។ បទថា **ន ហិ កម្មំ វិនស្សតិ** សេចក្តីថា កម្មតាមដែលខ្លួនសន្សំទុក មិនទាន់ឲ្យផលនឹងមិនសូន្យទៅណាឡើយ ។ បទថា **កិមិនំ** បានដល់ មានដង្កូវ គឺកើតជាពួកដង្កូវ ។ បទថា **មីឡ្ហំ** ប្រែថា លាមក ។ បទដ៏សេសមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើម ។

ព្រះថេរៈកាលស្តាប់ពាក្យរបស់ប្រេតនោះ យ៉ាងនេះហើយ ក៏បានក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទើបទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ទេសនានោះមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា កុសប្រេតចប់

# រឿង កុមារប្រេត ទី៤

[ ៣០ ] ( *ព្រះសង្គីតិកាចារ្យទាំងឡាយពោលថា* ) *ញាណរបស់ព្រះសុគត មានសភាពអស្ចារ្យ ដូចព្រះសាស្ដាទ្រង់ព្យាករនូវបុគ្គលថា បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យក្រាស់ បុគ្គលពួកខ្លះជាអ្នកមានបុណ្យស្ដើង ។ កុមារនេះដែលគេបោះបោលក្នុងព្រៃស្មសាន បានញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយទឹកដោះដែលហូរចេញអំពីមេដៃ ( នៃទេវតា ) អស់មួយរាត្រី ។ យក្សនិងភូតទាំងឡាយក្ដី ពស់ទាំងឡាយក្ដី មិនបៀតបៀនកុមារអ្នកមាន បុណ្យធ្វើហើយទេ សូម្បីតែពួកឆ្កែក៏មកលិទ្ធជើងទាំងគូរបស់កុមារនេះដែរ ពួកបក្សីក្អែក ពួកចចក ក៏មកចោមជុំវិញ ( កុមារនោះ ) ។ ហ្វូងសត្វស្លាបទាំងឡាយ ក៏នាំយកមន្ទិលគភ៌ចេញ ឯក្អែកទាំងឡាយ ក៏នាំយកអាចម៍ភ្នែកចេញ មនុស្សនិងអមនុស្សពួកខ្លះ មិនបានចាត់ចែងការរក្សានូវកុមារនេះទេ មិនបានចាត់ចែងនូវឱសថនិងការអប់ដោយគ្រាប់ស្ពៃ ( ដល់កុមារនេះទេ ) ។ សូម្បីតែពួកមនុស្សក៏មិនរៀននូវការប្រកបនូវនក្ខត្តឫក្ស ទាំងមិនបាន រោយរាយនូវធញ្ញជាតិគ្រប់មុខលើកុមារ ដែលមានសភាពដូច្នោះ ដែលដល់នូវសេចក្ដីលំបាក យ៉ាងក្រៃលែង គេនាំមកក្នុងពេលយប់ ហើយបោះបោលក្នុងព្រៃស្មសាន ព្រះពុទ្ធដែលទេវតានិងមនុស្សបូជា បានឃើញកុមារនោះ ដូចជាដុំនៃទឹកដោះខាប់ កំពុងតែញាប់ញ័រប្រកបដោយសេចក្ដីសង្ស័យ នៅសល់តែជីវិត លុះព្រះពុទ្ធមានប្រាជ្ញាស្មើដោយផែនដីបានឃើញហើយ ទើបទ្រង់ព្យាករថា កុមារនេះនឹងបានជាអ្នកមានត្រកូលដ៏ប្រសើរផង នឹងមានភោគៈផង ក្នុងនគរនេះ ។*

( ពួកឧបាសកបានសួរថា ) វត្តដូចម្តេច ព្រហ្មចរិយដូចម្តេច នេះជាផលនៃវត្តឬព្រហ្មចរិយដូចម្តេច ដែលកុមារនេះបានសន្សំល្អហើយ បានជាកុមារនេះ ដល់នូវសេចក្តីវិនាសដល់ម៉្លេះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម៉្លោះនោះវិញ ។

( ព្រះសង្គីតិកាចារ្យទាំងឡាយពោលថា ) ពួកជនបានធ្វើនូវការបូជាដ៏ឱឡារិកចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទារកនោះមានចិត្តវេរីវាយក្នុងការបូជានោះ ទារកនោះបានពោលវាចាអាក្រក់ ជាវាចាមិនគួរចង់ឮក្នុងទីប្រជុំនៃសប្បុរស ទារកនោះ បន្ទោបង់នូវសេចក្តីត្រិះរិះនោះចេញហើយ ក៏ត្រឡប់បាននូវសេចក្តីត្រេកអរនិងសេចក្តីជ្រះថ្លា ក្នុងកាលជាខាងក្រោយទារកនោះបានបម្រើព្រះតថាគត ព្រះអង្គគង់នៅក្នុងវត្តជេតពន ដោយយាគូ អស់ ៧ ថ្ងៃ ។ នោះជាវត្ត នោះជាព្រហ្មចរិយរបស់កុមារនោះ នេះជាផលនៃវត្តឬព្រហ្មចរិយនោះ ដែលកុមារនេះសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្តីវិនាសដល់ម៉្លេះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម៉្លោះនោះវិញ ។ លុះកុមារនោះឋិតនៅក្នុងមនុស្សលោកនេះអស់មួយរយឆ្នាំ ជាអ្នកបរិបូណ៌ដោយកាមទាំងពួង ដល់បែកធ្លាយរាងកាយទៅកាន់កពថ្មី ក៏បានជាកូននៃសក្កទេវរាជ ។

**ចប់ រឿងកុមារប្រេតទី ៥ ។**

# អដ្ឋកថា កុមារប្រេត

[ ៣០ ] *រឿងនៃកុមារប្រេតនេះ មានពាក្យផ្ដើមថា* **អច្ឆេររូបំ សុគតស្ស ញាណំ** *ដូច្នេះជាដើម ។ រឿងនោះមានអត្ថុប្បត្តិហេតុដូចម្ដេច ។*

*បានឮថា ក្នុងក្រុងសាវត្ថី ឧបាសកនិងឧបាសិកាជាច្រើន រួមគ្នាជាពួកដោយធម៌ សាងមណ្ឌបមួយទុកក្នុងព្រះនគរ តាក់តែងលម្អដោយសំពត់ច្រើនពណ៌ និមន្តព្រះសាស្ដានិងភិក្ខុសង្ឃមកអំពីព្រលឹម ឲ្យភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានគង់លើអាសនៈដែលក្រាលដោយកម្រាលដ៏វិចិត្រ មានថ្លៃច្រើន បូជាដោយសក្ការៈ មានគ្រឿងក្រអូបនិងផ្កាជាដើម ឲ្យមហាទានប្រព្រឹត្តទៅ ។ បុរសម្នាក់មានចិត្តត្រូវមន្ទិល គឺសេចក្ដីកំណាញ់ចោមរោម លុះឃើញដូច្នោះ អត់ធន់ចំពោះសក្ការៈនោះមិនបាន ក៏ពោលយ៉ាងនេះថា របស់ទាំងអស់នេះ ចាក់ចោលក្នុងគំនរសំរាមល្អជាង ការដែលឲ្យដល់សមណៈក្បាលត្រងោលទាំងនេះ មិនល្អឡើយ ។ ពួកឧបាសក ឧបាសិកាបានស្ដាប់ដូច្នោះ កើតសេចក្ដីសង្វេគ នាំគ្នាគិតថា ការដែលបុរសនេះខ្វល់ខ្វាយ ក្នុងការសាងបាបកម្ម ដែលជាហេតុឲ្យធ្វើខុសក្នុងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានយ៉ាងនេះចាត់ថាជាកម្មដ៏ធ្ងន់ហ្ន៎ ដូច្នេះហើយ ទើបបានប្រាប់រឿងនោះដល់មាតាបិតារបស់កុមារនោះ ហើយពោលថា ចូរអ្នកទៅសូមខមាទោសក្នុងព្រះមានព្រះភាគ មួយអន្ទើដោយព្រះសង្ឃសាវ័ក ។ មាតាទទួលពាក្យថា សាធុ ហើយ កាលសម្ដុតកូនឲ្យយល់ព្រម ទើបចូលទៅគាល់ព្រះមានព្រះភាគ និងសួរសុខទុក្ខភិក្ខុសង្ឃ សម្ដែងទោសដែលកូនធ្វើទុក ឲ្យខមាទោសហើយ បានធ្វើការបូជាដោយការថ្វាយបបរអស់ ៧ ថ្ងៃដល់ព្រះមានព្រះភាគនិងភិក្ខុសង្ឃ ។ ព្រោះ*

ហេតុនោះ មិនយូរប៉ុន្មានកុមារនោះ ក៏ធ្វើកាលកិរិយា កើតក្នុងផ្ទៃរបស់ស្រី គណិកាដែលចិញ្ចឹមជីវិតដោយកម្មសៅហ្មង ។ គ្រាន់តែកូនកើតឡើងប៉ុណ្ណោះ មាតាដឹងថាជាកូនប្រុស ក៏ឲ្យគេយកទៅបោះចោលត្រង់ព្រៃខ្មោច ។ កុមារនោះដែលកម្លាំងនៃបុណ្យរបស់ខ្លួនគ្រប់គ្រងរក្សាក្នុងទីនោះ មិនមានអ្វីបៀតបៀនឡើយ ដេកលក់ជាសុខ ដូចដេកលើភ្លៅមាតា ។ ឯអាចារ្យពួកខ្លះពោលថា ទេវតានាំគ្នារក្សាកុមារនោះ ។ លុះពេលទៀបភ្លឺ ព្រះសាស្តាចេញអំពីមហាករុណាសមាបត្តិទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទតឃើញកុមារនោះដែលត្រូវចោលក្នុងព្រៃ បានយាងទៅកាន់ព្រៃខ្មោច ក្នុងកាលព្រះអាទិត្យរះ ។ មហាជនជំនុំគ្នាថា ព្រះសាស្តាយាងមកក្នុងទីនេះ ប្រហែលជាមានហេតុអ្វីក្នុងទីនេះហើយ ។ ព្រះមានព្រះភាគត្រាស់ដល់បរិស័ទដែលប្រជុំគ្នាហើយថា កុមារនេះ មិនមានអ្នកណាស្គាល់ ឥឡូវនេះ ត្រូវបោះចោលក្នុងព្រៃខ្មោច មិនមានទីពឹងក៏ពិត តែកុមារនេះនឹងបានទទួលសម្បត្តិដ៏ឧឡារក្នុងអនាគត បច្ចុប្បន្ននិងអភិសម្បរាយកព ហើយត្រូវពួកមនុស្សទាំងនោះទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើនក្នុងជាតិមុន កុមារនេះធ្វើកម្មអ្វី ដូច្នេះទើបទ្រង់ប្រកាសកម្មដែលកុមារនេះធ្វើ និងសម្បត្តិដែលកុមារគប្បីបានទទួលក្នុងអនាគត ដោយន័យជាដើមថា

> ពួកជនបានធ្វើនូវការបូជាដ៏ឧឡារិកចំពោះព្រះសង្ឃ មានព្រះ
> ពុទ្ធជាប្រធាន ទារកនោះមានចិត្តរវើរវាយ ក្នុងការបូជានោះ
> ទារកនោះបានពោលវាចាអាក្រក់ ជាវាចាមិនគួរចង់ឮ ក្នុងទី

ប្រជុំនៃសប្បុរស ដូច្នេះ ។

ហើយទ្រង់សម្ដែងធម៌ដែលសមគួរដល់អធ្យាស្រ័យរបស់បរិស័ទ ដែលនាំគ្នាមកប្រជុំហើយ ក៏បានត្រាស់ព្រះធម្មទេសនា ដែលទ្រង់លើកឡើងមកសម្ដែងដោយព្រះអង្គឯងខាងលើ ។ លុះចប់សច្ចៈ សត្វ ៨៤០០០ បានត្រាស់ដឹងធម៌ ។ កុដុម្ពិកៈម្នាក់ មានទ្រព្យ ៨០ កោដិ បានទទួលកុមារនោះចំពោះព្រះភក្ត្រព្រះមានព្រះភាគថា នេះជាកូនរបស់ខ្ញុំ ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា កុមារនេះដែលបុញ្ញកម្ម មានប្រមាណប៉ុណ្ណោះរក្សាហើយ មហាជននាំគ្នាធ្វើការអនុគ្រោះ ដូច្នេះហើយ ទើបយាងទៅកាន់វិហារ ។

សម័យតមក កាលកុដុម្ពិកៈនោះ ធ្វើកាលកិរិយាហើយ កុមារក៏បានគ្រប់គ្រងទ្រព្យដែលកុដុម្ពិកៈនោះប្រគល់ឲ្យ បានជាគហបតី មានសម្បត្តិច្រើនក្នុងនគរនោះឯង បានជាអ្នកត្រេកអរក្នុងការឲ្យទានជាដើម ។ ថ្ងៃមួយ ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា គួរអស្ចារ្យ ព្រះសាស្ដាទ្រង់អនុគ្រោះសត្វទាំងឡាយ កុមារនេះក្នុងកាលនោះ ជាមនុស្សអនាថា តែឥឡូវនេះ សោយសម្បត្តិច្រើន ធ្វើបុណ្យយ៉ាងឱឡារិក ។ ព្រះសាស្ដាទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់ព្យាករថា ម្នាលភិក្ខុទាំងឡាយ កុមារនេះ មិនមែនមានសម្បត្តិត្រឹមតែប៉ុណ្ណោះឡើយ ដោយពិត ក្នុងកាលអស់អាយុ នឹងបានទៅកើតជាឱរសរបស់សក្កទេវរាជក្នុងជាន់តាវត្តិង្ស នឹងបានសម្បត្តិទិព្វដ៏ច្រើន ។ ភិក្ខុទាំងឡាយនិងមហាជនបានស្ដាប់ដូច្នោះហើយ គិតថា ព្រះមានព្រះភាគទ្រង់ព្រះនាមថាជាអ្នកឃើញកាលវែង ទ្រង់ឃើញហេតុនេះហើយ គ្រាន់តែកុមារ

នោះកើតមកប៉ុណ្ណោះ ត្រូវបោះបោលក្នុងព្រៃខ្មោច ទ្រង់យាងទៅក្នុងទីនោះ ធ្វើនូវការសង្គ្រោះ ដូច្នេះហើយ ទើបនាំគ្នាសរសើរញាណវិសេសរបស់ព្រះសាស្តា ហើយបានក្រាបទូលសួរប្រវត្តិរបស់កុមារនោះក្នុងអត្តភាពនោះ ព្រះសង្គីតិកាចារ្យទាំងឡាយកាលសម្តែងសេចក្តីនោះទើបពោលគាថា ៦ ថា

ញាណរបស់ព្រះសុគត មានសភាពអស្ចារ្យ ដូចព្រះសាស្តាទ្រង់ព្យាករនូវបុគ្គលថា បុគ្គលពួកខ្លះជាអ្នកមានបុណ្យក្រាស់ បុគ្គលពួកខ្លះជាអ្នកមានបុណ្យស្តើង ។ កុមារនេះដែលគេបោះបោលក្នុងព្រៃស្មសាន បានញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយទឹកដោះដែលហូរចេញអំពីមេដៃ ( នៃទេវតា ) អស់មួយរាត្រី ។ យក្សនិងភូតទាំងឡាយក្តី ពស់ទាំងឡាយក្តី មិនបៀតបៀនកុមារ អ្នកមានបុណ្យធ្វើហើយទេ សូម្បីតែពួកឆ្កែក៏មកលិទ្ធជើងទាំងគូរបស់កុមារនេះដែរ ពួកបក្សីក្អែក ពួកចចកក៏មកចោមជុំវិញ ( កុមារនោះ ) ។ ហ្វូងសត្វស្លាបទាំងឡាយ ក៏នាំយកមន្ទិលគភ៌ចេញ ឯក្អែកទាំងឡាយ ក៏នាំយកអាចម៍ភ្នែកចេញ មនុស្សនិងអមនុស្សពួកខ្លះ មិនបានចាត់ចែងការរក្សានូវកុមារនេះទេ មិនបានចាត់ចែងនូវឱសថនិងការអប់ដោយគ្រាប់ស្ពៃ ( ដល់កុមារនេះទេ ) ។ សូម្បីតែពួកមនុស្សក៏មិនរៀននូវការប្រកបនូវនក្ខត្តឫក្ស ទាំងមិនបានរោយរាយនូវធញ្ញជាតិគ្រប់មុខ លើកុមារ ដែលមានសភាពដូច្នោះ

ដែលដល់នូវសេចក្ដីលំបាកយ៉ាងក្រៃលែង គេនាំមកក្នុងពេល យប់ ហើយបោះចោលក្នុងព្រៃស្មសាន ព្រះពុទ្ធដែលទេវតា និងមនុស្សបូជា បានឃើញកុមារនោះ ដូចជាដុំនៃទឹកដោះខាប់ កំពុងតែញាប់ញ័រ ប្រកបដោយសេចក្ដីសង្ស័យ នៅសល់តែជីវិត លុះព្រះពុទ្ធមានប្រាជ្ញាស្មើដោយផែនដី បានឃើញហើយ ទើបទ្រង់ព្យាករថា កុមារនេះ នឹងបានជាអ្នកមានត្រកូលដ៏ប្រសើរផង នឹងមានភោគៈផង ក្នុងនគរនេះ ដូច្នេះ ។

ពួកឧបាសកដែលឈរក្នុងទីជិតព្រះសាស្ដាទូលសួរថា

វត្តដូចម្ដេច ព្រហ្មចរិយដូចម្ដេច នេះជាផលនៃវត្ត ឬព្រហ្មចរិយដូចម្ដេចដែលកុមារនេះបានសន្សំល្អហើយ បានជាកុមារនេះ ដល់នូវសេចក្ដីវិនាសដល់ម្ល៉េះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម្ល៉េះនោះវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **អច្ឆេររូបំ** បានដល់ មានសភាវៈគួរអស្ចារ្យ ។ បទថា **សុគតស្ស ញាណំ** បានដល់ ព្រះញាណនៃព្រះសម្មាសម្ពុទ្ធដែលមិនទូទៅដល់សាវកដទៃ ដែលលោកសំដៅយកព្រះសព្វញ្ញុតញ្ញាណ មានអាសយានុសយញ្ញាណជាដើមប៉ុណ្ណោះ ដើម្បីចៀសវាងពាក្យសួរថា ញាណនេះមិនមែនជាវិស័យរបស់សាវកដទៃដូចម្ដេច ទើបពោលថា **សត្ថា យថា បុគ្គលំ ព្យាកាសិ** ដូច្នេះ ។ ដោយពាក្យនោះ លោកសម្ដែងថា ភាពដែលព្រះញាណជាសភាវៈគួរអស្ចារ្យ រមែងដឹងបានដោយទេសនារបស់ព្រះសា-

ស្ដាប៉ុណ្ណោះ ។

ឥឡូវនេះ កាលទ្រង់សម្ដែងព្យាករណ៍ ទើបត្រាស់ថា បុគ្គលពួកខ្លះជាអ្នកមានបុណ្យក្រាស់ បុគ្គលពួកខ្លះជាអ្នកមានបុណ្យស្ដើង ដូច្នេះ សេចក្ដីនៃពាក្យនោះ មានអធិប្បាយដូច្នេះថា បុគ្គលពួកខ្លះក្នុងលោកនេះ មានកុសលធម៌ច្រើន ជាអ្នកវិនាសចាកជាតិជាដើម ដោយអំណាចអកុសលដែលខ្លួនធ្វើហើយជាបច្ច័យក៏មាន ពួកខ្លះមានបុណ្យតិចក៏មាន ពួកខ្លះមានបុញ្ញធម្មតិចជាងក៏មាន ជាអ្នកជាំក្រៃលែង ព្រោះភាពដែលបុណ្យនោះរុងរឿងច្រើន ដោយហេតុមានខេត្តសម្បត្តិជាដើមក៏មាន ។

បទថា **សីវថិកាយ** ប្រែថា ក្នុងព្រៃស្មសាន ។ បទថា **អង្គុដ្ឋស្នេហេន** បានដល់ ដោយទឹកដោះដែលហូរអំពីម្រាមដៃ អធិប្បាយថា ដោយទឹកដោះដែលហូរចេញអំពីម្រាមដៃរបស់ទេវតា ។ បទថា **ន យក្ខភូតា ន សរីសបា** សេចក្ដីថា សត្វពួកណាមួយ ទោះជាបិសាច ភូត យក្ខ ពស់ធំ ពស់តូច ដែលត្រាច់ទៅ ឬដើរទៅ ក៏មិនបៀតបៀន គឺមិនប្រទូស្ដ ។

បទថា **បលិហឹសុ ចរណេ** សេចក្ដីថា លិទ្ធជើងទាំង ២ ដោយអណ្ដាតរបស់ខ្លួន ។ បទថា **ធង្កា** ប្រែថា ហ្វូងសត្វក្អែក ។ បទថា **បរិវត្តយន្តិ** សេចក្ដីថា ដើរក្រឡឹងរក្សាទៅមកៗ ដើម្បីឲ្យដឹងថា មិនមានរោគ និងគិតថា បុគ្គលណាមួយ កុំគប្បីបៀតបៀនកុមារនេះ ។ បទថា **គព្ភាសយំ** ប្រែថា មន្ទិលគភ៌ ។ បទថា **បក្ខិគណា** បានដល់ ហ្វូងបក្សី មានត្មាត និងត្រដក់ត្រំរង់ជាដើម ។ បទថា **ហរន្តិ** ប្រែថា កម្ចាត់ទៅ ។ បទថា **អក្ខិមលំ**

បានដល់ ពពីកក្អែក ។

បទថា **កេចិ** បានដល់ ពួកមនុស្សនិងអមនុស្សចាត់ចែងរក្សា ។ បទថា **ឱសធំ** បានដល់ ថ្នាំដែលកម្ចាត់រោគក្នុងកាលនោះនិងកាលតទៅ ។ ដោយបទថា **សាសបធូបនំ វា** លោកសម្តែងថា បុគ្គលដែលធ្វើថ្នាំដោយគ្រាប់ស្ពៃ ដើម្បីរក្សាកុមារដែលទើបនឹងកើតនោះ មិនមាន ។ បទថា **ឥក្ខត្ត-យោគម្បិ ច អគ្គហេសុំ** សេចក្តីថា មិនកាន់យកដោយការប្រកបឫក្ស អធិប្បាយថា បុគ្គលណាមួយ មិនធ្វើកម្មកំណើតឲ្យដល់កុមារយ៉ាងនេះថា កុមារនេះកើតក្នុងឫក្សនោះ តិថីនោះ យាមនោះ ។ បទថា **សព្វធញ្ញានិបិ អាកិរីសុ** សេចក្តីថា កាលនឹងធ្វើមង្គល មិនបានធ្វើការរោយធញ្ញជាតិ មានស្រូវសាលីជាដើម ដែលលាយដោយប្រេងគ្រាប់ស្ពៃ ដោយអំណាចការមិនមានរោគ ។

បទថា **ឯតាទិសំ** ប្រែថា បែបនោះ ។ បទថា **ឧត្តមកិច្ឆបត្តំ** សេចក្តីថា បានទទួលការលំបាកយ៉ាងក្រៃលែង គឺបានទទួលទុក្ខយ៉ាងក្រៃលែង ។ បទថា **រត្តាភតំ** បានដល់ ដែលគេនាំមកក្នុងរាត្រី ។ បទថា **នោនីតបិណ្ឌំ វិយ** បានដល់ ដូចគ្នានឹងដុំសប្បិ លោកពោលយ៉ាងនោះ ព្រោះត្រឹមតែជាដុំសាច់ ។ បទថា **បវេធមានំ** បានដល់ ញាប់ញ័រដោយ ភារៈដែលមានកម្លាំងតិច ។ បទថា **សសំសយំ** សេចក្តីថា ឈ្មោះថា មានសេចក្តីសង្ស័យ ព្រោះមានសេចក្តីសង្ស័យថា កុមារនោះមានជីវិតឬហ្ន៎ ។ បទថា **ជីវិត-សាវសេសំ** បានដល់ នៅសល់ត្រឹមតែជីវិតតែម្យ៉ាង ព្រោះមិនមានទ្រព្យ

ដែលជាហេតុផ្គត់ផ្គង់ជីវិត ។

បទថា **អគ្គកុលិកោ ភវិស្សតិ ភោគវា** ច សេចក្តីថា ជាបុគ្គលមានត្រកូលខ្ពស់ គឺមានត្រកូលឧត្តមដែលមានភោគជាហេតុ គឺដោយអំណាចភោគៈ ។

គាថាថា **កិស្ស វតំ** ជាដើមនេះ គប្បីជ្រាបថា ឧបាសកនៅក្នុងសម្នាក់របស់ព្រះសាស្តា ក្រាបទូលដោយអំណាចពាក្យសួរដល់កម្ម ដែលកុមារធ្វើទុក គាថានោះឯងឧបាសកដែលប្រជុំគ្នាក្នុងព្រៃបានពោលហើយ ។ បណ្តាបទទាំងនោះ បទថា **កិស្ស** កាត់បទជា **កឹ អស្ស** ប្រែថា គប្បីធ្វើកម្មអ្វី ។ បទថា **វតំ** បានដល់ ការសមាទានវត្ត ។ បទថា **កិស្ស** មានវាចាប្រកបការផ្លាស់វិភត្តិទៀតថា វត្ត និងព្រហ្មចរិយៈដូចម្តេច ដែលកុមារប្រព្រឹត្តល្អហើយ ។ បទថា **ឯតាទិសំ** សេចក្តីថា ឈ្មោះថា ឯតាទិសៈ ព្រោះកើតក្នុងផ្ទៃស្រីពេស្យា ត្រូវបោលក្នុងព្រៃខ្មោច ។ បទថា **ព្យសនំ** ប្រែថា សេចក្តីវិនាស ។ បទថា **តាទិសំ** បានដល់ បែបនោះ អធិប្បាយថា មានប្រការដូចពោលហើយ ដោយន័យជាដើមថា រស់នៅអស់រាត្រីដោយទឹកដោះដែលហូរចេញអំពីម្រាមដៃ ដោយន័យជាដើមថា កុមារនេះនឹងបានជាអ្នកមានត្រកូលដ៏ប្រសើរផង នឹងមានភោគៈផង ក្នុងនគរនេះ ដូច្នេះ ។ បទថា **ឥទ្ធិ** បានដល់ ទេវឫទ្ធិ អធិប្បាយថា ទិព្វសម្បត្តិ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រូវឧបាសកទាំងនោះសួរហើយ ទ្រង់បានព្យាករក្នុងវេលានោះ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលនឹងសម្តែង បាន

ពោលគាថា ៤ ថា

ពួកជនបានធ្វើនូវការបូជា ដ៏ឧឡារិកចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទារកនោះមានចិត្តរវើរវាយ ក្នុងការបូជានោះ ទារកនោះបានពោលវាចាអាក្រក់ ជាវាចាមិនគួរបង់ឮ ក្នុងទីប្រជុំនៃសប្បុរស ទារកនោះ បន្ទោបង់នូវសេចក្ដីត្រិះរិះនោះចេញហើយ ក៏ត្រឡប់បាននូវសេចក្ដីត្រេកអរនឹងសេចក្ដីជ្រះថ្លា ក្នុងកាលជាខាងក្រោយ ទារកនោះបានបម្រើព្រះតថាគតព្រះអង្គគង់នៅក្នុងវត្តជេតពន ដោយយាគូ អស់ ៧ ថ្ងៃ ។ នោះជាវត្ត នោះជាព្រហ្មចរិយរបស់កុមារនោះ នេះជាផលនៃវត្តឬព្រហ្មចរិយនោះ ដែលកុមារនេះសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្ដីវិនាសដល់ម្ល៉េះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម្ល៉េះ នោះវិញ ។ លុះកុមារនោះឋិតនៅក្នុងមនុស្សលោកនេះអស់មួយរយឆ្នាំជាអ្នកបរិបូណ៌ដោយកាមទាំងពួង ដល់បែកធ្លាយរាងកាយទៅកាន់ភពថ្មី ក៏បានជាកូននៃសក្កទេវរាជ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជនតា** បានដល់ ប្រជុំជន អធិប្បាយថា គណៈនៃឧបាសក ។ បទថា **តត្រ** បានដល់ ក្នុងការបូជានោះ ។ បទថា **អស្ស** បានដល់ ទារកនោះ ។ បទថា **ចិត្តស្សហុ អញ្ញថត្តំ** សេចក្ដីថា ក្នុងភពមុន ចិត្តរបស់បុគ្គលនោះ មានភាវៈដទៃ គឺមិនអើពើ មិនគោរព

មិនស្តាប់បង្គាប់ ។ បទថា **អសព្ភំ** បានដល់ បានពោលវាចាគ្រោតគ្រាត ដែលមិនគួរស្តាប់ក្នុងទីប្រជុំនៃសាធុជន ។ បទថា **សោ** បានដល់ កុមារនោះ ។ បទថា **តំ វិតក្កំ** បានដល់ វិតក្កដ៏លាមកនោះ ។ បទថា **បរិភោគយិត្វា** បានដល់ ស្ងប់រម្ងាប់ដោយបញ្ញត្ត ( ការឲ្យសិក្សា ) ដែលមាតាធ្វើ ។ បទថា **បីតឹ បសាទំ បដិលទ្ធា** បានដល់ ត្រឡប់បាន គឺធ្វើបីតិនិងការជ្រះថ្លាឲ្យកើត ។ បទថា **យាគុយា ឧបដ្ឋាសិ** បានដល់ ទំនុកបម្រុងដោយការប្រគេនបបរ ។ បទថា **សត្តរត្តំ** ប្រែថា អស់ ៧ ថ្ងៃ ។

បទថា **តស្ស វតំ តំ បន ព្រហ្មចរយំ** សេចក្តីថា សេចក្តីជ្រះថ្លា និងការឲ្យនៃចិត្តរបស់ខ្លួន មានប្រការដូចពោលហើយខាងដើមនោះជាវត្ត និងជាព្រហ្មចរិយៈរបស់កុមារនេះ អធិប្បាយថា មិនមានវត្តដទៃ ។ បទថា **ឋត្វាន** សេចក្តីថា តាំងនៅក្នុងមនុស្សលោកនោះឯងដរាបដល់អស់អាយុ ។ បទថា **អភិសម្បរាយំ** បានដល់ ក្នុងភពថ្មី ។ បទថា **សហព្យតំ គច្ឆតិ វាសវស្ស** បានដល់ ចូលដល់ភាពជាសម្លាញ់ ដោយភាពជាបុត្តនៃសក្កទេវរាជ ។ ពាក្យថា **សហព្យតំ គច្ឆតិ វាសវស្ស** នេះ ជាពាក្យបច្ចុប្បន្នកាល ប្រើក្នុងអត្ថដែលជាអនាគត ។ ពាក្យដ៏សេសក្នុងបទទាំងពួងមានអត្ថងាយយល់ហើយ ។

អដ្ឋកថា កុមារប្រេតចប់

# រឿង សេរិនីប្រេតទី៦

[ ៣១ ] *( ឧបាសកបានសួរស្រីប្រេតថា ) ម្នាលនាងស្គមមានធ្អឹងជំនីរគោម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ ជាស្រីស្គម រើមរវាមដោយសរសៃ នាងជាអ្វី មកឈរក្នុងទីនេះ ។*

*( ស្រីប្រេតឆ្លើយថា ) បពិត្រអ្នកដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្ដីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក ( លុះច្យុត ) អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ។*

*( ឧបាសកសួរថា ) អំពើអាក្រក់ដូចម្ដេចដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត នាង ( ច្យុត ) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោកដោយផលនៃកម្មដូចម្ដេច ។*

*( ស្រីប្រេតឆ្លើយថា ) ខ្ញុំបានរើសទ្រព្យគេកន្ទះមាសកៈ ត្រង់កំពង់ទាំងឡាយដែលមិនមានទោស គឺមិនមានអ្នកណាមួយឃាត់ខាំង កាលដែលទេយ្យធម៌ទាំងឡាយកំពុងមានគ្រប់គ្រាន់ ខ្ញុំមិនបានធ្វើនូវទីពឹង ចំពោះខ្លួនសោះ ។ ខ្ញុំស្រេកទឹក ចូលទៅរកស្ទឹង ស្ទឹងក៏ប្រែទៅជាទទេ ខ្ញុំចូលទៅជ្រកម្លប់ ក្នុងកាលកំពុងក្ដៅ ស្រមោលក៏ប្រែទៅជាក្ដៅ ។ ឯខ្យល់ដែលដូចភ្លើងសោតក៏ក្ដៅកាយមកដល់ខ្ញុំ បពិត្រអ្នកដ៏ចម្រើន ខ្ញុំគួរ ( រង ) ទុក្ខមានសម្រេកជាដើមនេះ និងបាបកម្មដទៃដ៏លាមកលើសលុបជាងសេចក្ដីទុក្ខមានសម្រេកជាដើមនោះ ។ អ្នកគួរទៅកាន់ហត្ថិនីបុរី ហើយជម្រាបមាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្ដីលំបាក កើតក្នុងយមលោកបានធ្វើនូវកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក។*

ទ្រព្យដែលខ្ញុំទុកក្នុងទីទុំះមាន តែខ្ញុំមិនបានប្រាប់ទ្រព្យនោះ ( ឯទ្រព្យទាំងនោះ ) ចំនួន ៤ សែនកហាបណៈ ក្រោមបល្ល័ង្ក ( របស់ខ្ញុំ ) ។ មាតារបស់ខ្ញុំនោះ ចូរឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំលុះឲ្យទានហើយ ចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ។

ឧបាសកនោះ ទទួលស្តាប់ពាក្យប្រេតនោះថា ប្រពៃហើយ រួចក៏ទៅកាន់ហត្ថិនីបុរី បានប្រាប់ដល់មាតារបស់ស្រីប្រេតនោះថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះ ទៅកាន់បេតលោក កូនស្រីរបស់នាងនោះ បានផ្តាំនឹងខ្ញុំក្នុងបេតលោកនោះថាអ្នកអញ្ជើញទៅកាន់ហត្ថិនីបុរី ហើយជម្រាបដល់មាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាកកើតក្នុងយមលោក បានធ្វើកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីទុំះមាន តែខ្ញុំមិនបានប្រាប់នូវទ្រព្យនោះ (ឯទ្រព្យទាំងនោះ ) ចំនួន ៤ សែនកហាបណៈ នៅខាងក្រោមបល្ល័ង្ក ( របស់ខ្ញុំ ) ។ សូមមាតាឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំ លុះឲ្យទានហើយ សូមឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ។

ក៏ក្នុងលំដាប់នោះ មាតានោះបានឲ្យទាន លុះឲ្យហើយ បានឧទ្ទិសនូវ

ទក្ខិណាទានដល់ស្រីប្រេតនោះ ស្រីប្រេតក៏បានដល់នូវសេចក្ដីសុខផង មាតានោះចិញ្ចឹមជីវិតដោយងាយផង ។

## ចប់ រឿងសេរិនីប្រេត ទី ៦ ។

# អដ្ឋកថា សេរិណីប្រេត

[ ៣១ ] កាលព្រះសាស្ដាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធសេរិនីប្រេត ទើបត្រាស់គាថានេះ មានពាក្យផ្ដើមថា **នគ្គា ទុព្វណ្ណរូបាសិ** ដូច្នេះជាដើម ។

បានឮថា ក្នុងហត្ថិនីបុរី ក្នុងដែនកុរុរដ្ឋ មានស្រីម្នាក់ ឈ្មោះសេរិនី បានជាអ្នកអាស្រ័យរូបចិញ្ចឹមជីវិត ។ ភិក្ខុទាំងឡាយចេញអំពីទីផ្សេងៗ បានមកប្រជុំគ្នាក្នុងហត្ថិនីបុរីនោះ ដើម្បីធ្វើឧបោសថ ។ មានភិក្ខុជាច្រើនមកប្រជុំគ្នាទៀត ។ មនុស្សទាំងឡាយឃើញដូច្នោះ ទើបត្រៀមគ្រឿងឧបករណ៍ក្នុងការបំពេញទានជាច្រើន មានគ្រាប់ល្ងនិងអង្ករជាដើមនិងមានសប្បិ នវនីតនិងទឹកឃ្មុំជាដើម បំពេញមហាទាន ។ សម័យនោះ នាងគណិកានោះ មិនមានសទ្ធា មិនមានសេចក្ដីជ្រះថ្លា មានចិត្តចោមរោមដោយមន្ទិល គឺសេចក្ដីកំណាញ់ សូម្បីត្រូវពួកមនុស្សទាំងនោះបបួលថា មកចូរអនុមោទនាទាននេះ ក៏ប្រកាសការមិនជ្រះថ្លាដល់មនុស្សទាំងនោះថា ប្រយោជន៍អ្វីដោយទានដែលឲ្យ ដល់ពួកសមណៈត្រងោល កិរិយាបរិច្ចាគទ្រព្យបន្តិចបន្តួចនឹងមានអំពី

ណា ។

សម័យក្រោយមក នាងធ្វើកាលកិរិយាហើយ កើតជាប្រេតត្រង់ខ្នងប្រឡាយនៃបច្ចន្តនគរមួយកន្លែង ។ លំដាប់នោះ ឧបាសកអ្នកក្រុងហត្ថិនីបុរីម្នាក់ទៅកាន់នគរនោះដើម្បីជួញដូរក្នុងវេលាទៀបភ្លឺនៃរាត្រីបានទៅកាន់ខ្នងប្រឡាយដោយប្រយោជន៍បែបនោះ ។ នាងឃើញឈ្នួញក្នុងទីនោះ ក៏ចាំបាន តែខ្លួនជាបុគ្គលអាក្រាត មានរាងកាយសល់តែស្បែកដណ្ដប់ឆ្អឹង ឃើញគួរខ្លាចក្រៃពេក បានឈរបង្ហាញខ្លួនក្នុងទីមិនឆ្ងាយ ។ ឧបាសកនោះ ឃើញប្រេតនោះហើយ កើតសេចក្ដីខ្លាចសួរដោយគាថាថា

ម្នាលនាងស្គម មានឆ្អឹង ជំនីរគាម នាងជាស្រីអាក្រាត មាន
រូបមានសម្បុរអាក្រក់ ជាស្រីស្គម រីមរវាមដោយសរសៃនាង
ជាអ្វី មកឈរក្នុងទីនេះ ដូច្នេះ ។

ឯស្រីប្រេត ទើបប្រកាសខ្លួនដល់ឧបាសកនោះ ដោយគាថាថា

បពិត្រអ្នកដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្ដីលំបាក
កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក ( លុះច្យុត )
អំពីមនុស្សលោកនេះហើយបានទៅកាន់បេតលោក ដូច្នេះ ។

ប្រេតនោះត្រូវឧបាសកនោះសួរដល់កម្មដែលខ្លួនធ្វើទៀតដោយគាថាថា

អំពើអាក្រក់ដូចម្ដេចដែលនាងបានធ្វើហើយ ដោយកាយ វាចា
ចិត្ត នាង ( ច្យុត ) អំពីមនុស្សលោកនេះ បានទៅកាន់
បេតលោកដោយផលនៃកម្មដូចម្ដេច ដូច្នេះ ។

ស្រីប្រេតក៏ប្រាប់កម្មដែលខ្លួនធ្វើ និងប្រយោជន៍ដែលឧបាសកគប្បីធ្វើឲ្យដល់ខ្លួន ទើបពោលគាថា ៦ ថា

ខ្ញុំបានរើសទ្រព្យគេកន្ទះមាសកៈ ត្រង់កំពង់ទាំងឡាយ ដែលមិនមានទោស គឺមិនមានអ្នកណាមួយឃាត់ខាំង កាលដែលទេយ្យធម៌ទាំងឡាយកំពុងមានគ្រប់គ្រាន់ ខ្ញុំមិនបានធ្វើនូវទីពឹងចំពោះខ្លួនសោះ ។ ខ្ញុំស្រេកទឹក ចូលទៅរកស្ទឹង ស្ទឹងក៏ប្រែទៅជាទទេ ខ្ញុំចូលទៅជ្រកម្លប់ក្នុងកាលកំពុងក្តៅស្រមោលក៏ប្រែទៅជាក្តៅ ។ ឯខ្យល់ដែលដូចភ្លើងសោត ក៏ក្តៅកាយមកដល់ខ្ញុំ បពិត្រអ្នកដ៏ចម្រើន ខ្ញុំគួរ ( រង ) ទុក្ខ មានសម្រេកជាដើមនេះ និងបាបកម្មដទៃដ៏លាមកលើសលុបជាងសេចក្តីទុក្ខ មានសម្រេកជាដើមនោះ ។ អ្នកគួរទៅកាន់ហត្ថិនីបុរីហើយជម្រាបមាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុ៎ះមាន តែខ្ញុំមិនបានប្រាប់ទ្រព្យនោះ ( ឯទ្រព្យទាំងនោះ ) ចំនួន ៤ សែន កហាបណៈ ក្រោមបល្ល័ង្ក ( របស់ខ្ញុំ ) ។ មាតារបស់ខ្ញុំនោះ ចូរឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំលុះឲ្យទានហើយ ចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវ

សេចក្ដីសុខ បានសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនាវដេសុ តិត្ថេសុ** សេចក្ដីថា ក្នុងទឹកដីដែលជាកំពង់នៃស្ទឹងនិងស្រះទឹកជាដើម ដែលបុគ្គលណាមួយមិនហួងហែង គឺក្នុងទីដែលពួកមនុស្សងូតនិងធ្វើកិច្ចដោយទឹកបែបនោះ ។ បទថា **វិចិនឹ អឌ្ឍមាសកំ** សេចក្ដីថា ខ្ញុំត្រូវសេចក្ដីលោភគ្របសង្កត់ ដោយគិតថាធ្វើម្ដេចហ្ន៎ អញគប្បីបានរបស់អ្វីមួយក្នុងទីនេះដែលពួកមនុស្សភ្លេច ដូច្នេះ គយគន់ គឺស្វែងរក សូម្បីទ្រព្យកន្លះមាសកៈ ។ ម្យ៉ាងទៀត បទថា **អនាវដេសុ តិត្ថេសុ** សេចក្ដីថា កាលសមណព្រាហ្មណ៍ ដែលជាទីពឹងរបស់សត្វទាំងឡាយ ដោយភាពជាហេតុនៃសេចក្ដីបរិសុទ្ធ ដែលទាក់ទងដោយសេចក្ដីព្យាយាមរបស់ពួកសត្វដែលមិនមានបុគ្គលហួងហែងដោយការចូលទៅរកមាន ។ បទថា **វិចិនឹ អឌ្ឍមាសកំ** សេចក្ដីថា ខ្ញុំមានចិត្តត្រូវមន្ទិលគឺសេចក្ដីកំណាញ់ចោមរោម ទើបមិនបានឲ្យទ្រព្យណាមួយដល់បុគ្គលណាមួយ ទើបរក្សាទ្រព្យទុកជាពិសេសកន្លះមាសក មិនសន្សំបុណ្យទុក ដោយហេតុនោះ ទើបប្រេតពោលថា កាលដែលទេយ្យធម៌ទាំងឡាយ កំពុងមានគ្រប់គ្រាន់ ខ្ញុំមិនបានធ្វើនូវទីពឹងចំពោះខ្លួនសោះ ដូច្នេះ ជាដើម ។ បទថា **តសិតា** បានដល់ ជាអ្នកស្រេកហើយ ។ បទថា **រិត្តកា** សេចក្ដីថា ស្ទឹងដែលល្មមក្អែកផឹកបាន ហូរទៅ ត្រឡប់ក្លាយជាស្ទឹងទទេ គ្មានទឹក មានត្រឹមតែខ្សាច់ ព្រោះកម្មអាក្រក់របស់ខ្ញុំ ។ បទថា **ឧណ្ហាសុ** បានដល់ ក្នុងវេលាក្ដៅ ។ បទថា **អា-**

**តតោ បរិវត្តតិ** *សេចក្តីថា ទីដែលមានមូប់ កាលខ្ញុំចូលទៅក៏ក្លាយជាក្តៅ ។ បទថា* **អគ្គិវណ្ណោ** *បានដល់ មានសម្ផស្ស ដូចភ្លើង ។ ដោយហេតុនោះ ទើបប្រេតពោលថា* **ឧហាន្តោ ឧបវាយតិ** *ដូច្នេះជាដើម ។ ស្រីប្រេតហៅឧបាសកនោះដោយគោរពថា* **ភន្តេ** *ក្នុងបទថា* **ឯតញ្ច ភន្តេ អរហាមិ** *នេះ អធិប្បាយថា បពិត្រលោកដ៏ចម្រើន ខ្ញុំសមគួរសោយទុក្ខដែលកើតអំពីសេចក្តីស្រេកជាដើម តាមដែលពោលហើយនេះ និងទុក្ខដទៃដ៏លាមកទារុណជាងនោះ ព្រោះខ្ញុំបានធ្វើកម្មអាក្រក់ដែលកើតអំពីការធ្វើនោះ ។ បទថា* **វេទ្ទេសិ** *ប្រែថា គប្បីប្រាប់ ។*

*បទថា* **ឯត្ថ និក្ខិត្តំ អនក្ខាតំ** *សេចក្តីថា ខ្ញុំមិនបានប្រាប់ថា ទ្រព្យមានប្រមាណប៉ុណ្ណេះទុកក្នុងទីនេះ ។ ឥឡូវនេះ ស្រីប្រេតកាលនឹងសម្តែងប្រមាណនៃទ្រព្យនោះនិងទីដែលរក្សាទ្រព្យនោះទុកទើបពោលថា ( ឯទ្រព្យទាំងនោះ ) ចំនួន ៤ សែនកហាបណៈ ក្រោមបល្ល័ង្ក ( របស់ខ្ញុំ ) ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **បល្លង្កស្ស** *បានដល់ គ្រែសម្រាប់ដេករបស់ខ្លួនក្នុងកាលមុន ។ បទថា* **តតោ** *សេចក្តីថា សូមមាតាកាន់យកទ្រព្យមួយចំណែកអំពីទ្រព្យ ដែលខ្ញុំកប់ទុក ហើយចូរឲ្យទានឧទ្ទិសដល់ខ្ញុំ ។ បទថា* **តស្សា** *បានដល់ មាតារបស់ខ្ញុំ ។*

*កាលស្រីប្រេតនោះពោលយ៉ាងនេះ ឧបាសកនោះទទួលពាក្យរបស់ស្រីប្រេតនោះហើយ ពិចារណាករណីយកិច្ចរបស់ខ្លួនក្នុងទីនោះ ទើបទៅកាន់ហត្ថិនីនគរ ប្រាប់រឿងនោះដល់មាតារបស់នាង ដើម្បីសម្តែងរឿងនោះ ទើប*

ព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

ឧបាសកនោះ ទទួលស្តាប់ពាក្យប្រេតនោះថា ប្រពៃហើយ រួចក៏ទៅកាន់ហត្ថិនីបុរី បានប្រាប់ដល់មាតារបស់ស្រីប្រេតនោះថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះ ទៅកាន់បេតលោក កូនស្រីរបស់នាងនោះ បានផ្តាំនឹងខ្ញុំក្នុងបេតលោកនោះថាអ្នកអញ្ជើញទៅកាន់ហត្ថិនីបុរីហើយជម្រាបដល់មាតារបស់ខ្ញុំថាខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុ៎ះមាន តែខ្ញុំមិនបានប្រាប់ នូវទ្រព្យនោះ ( ឯទ្រព្យទាំងនោះ ) ចំនួន ៤ សែនកហាបណៈ នៅខាងក្រោមបល្ល័ង្ក ( របស់ខ្ញុំ ) ។ សូមមាតាឲ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផងដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំលុះឲ្យទានហើយ សូមឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាងក្នុងកាលនោះ ។

ក៏ក្នុងលំដាប់នោះ មាតានោះបានឲ្យទាន លុះឲ្យហើយ បានឧទ្ទិសនូវទក្ខិណាទានដល់ស្រីប្រេតនោះ ស្រីប្រេតក៏បាន

ដល់នូវសេចក្តីសុខផង មាតានោះចិញ្ចឹមជីវិតដោយងាយផង ដូច្នេះ ។

គាថាទាំងនោះ យល់បានងាយហើយ ។ មាតារបស់នាងបានស្តាប់ដូច្នោះហើយ បានថ្វាយទានដល់ភិក្ខុសង្ឃ ឧទ្ទិសឲ្យដល់នាង ព្រោះហេតុនោះ នាងក៏តាំងនៅក្នុងភាពបរិបូរដោយគ្រឿងឧបករណ៍ដែលបានមក បង្ហាញខ្លួនដល់មាតា ប្រាប់ហេតុនោះឲ្យជ្រាប មាតាប្រាប់ដល់ភិក្ខុទាំងឡាយ ភិក្ខុទាំង-ឡាយ ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ទេសនានោះមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា សេរិនីប្រេតចប់

# រឿង មិគលុទ្ទកប្រេត ទី ៧

[ ៣២ ] ( ព្រះនារទត្ថេរសួរវេមានិកប្រេតថា ) អ្នកនៅក្នុងមានទរៈនារីបោមរោម រុងរឿងដោយកាមគុណទាំងឡាយ គួរឲ្យត្រេកត្រអាលក្នុងពេលយប់ ( រងទុក្ខ ) ក្នុងពេលថ្ងៃ អ្នកបានធ្វើកម្មអ្វីក្នុងជាតិមុន ។

( ប្រេតបានឆ្លើយថា ) កាលពីដើមខ្ញុំជាព្រានម្រឹគ មានដៃប្រឡាក់ដោយឈាម ជាអ្នកអាក្រក់ នៅក្នុងក្រុងរាជគ្រឹះ មានភ្នំដូចជាក្រោល ជាទីគួរត្រេកអររីករាយ ។ ខ្ញុំមានចិត្តប្រទូស្តចំពោះពួកសត្វច្រើន ជាសត្វមិនធ្វើកំហុស ( នឹងនរណាមួយ ) អាក្រក់ក្រៃពេក ត្រេកអរតែក្នុងការបៀតបៀនចំពោះសត្វដទៃ មិនសង្រួម គ្រប់កាលទាំងពួង ។ សំឡាញ់របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសកមានសទ្ធា គាត់អនុគ្រោះ បានឃាត់ខ្ញុំរឿយៗថា អ្នកកុំធ្វើអំពើអាក្រក់ឡើយ នែអ្នក អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នាសេចក្តីសុខក្នុងបរលោក អ្នកចូរវៀរបង់នូវការមិនសង្រួម គឺការសម្លាប់សត្វ ។ ខ្ញុំបានស្តាប់ពាក្យសំឡាញ់នោះ ជាអ្នកប្រាថ្នានូវសេចក្តីសុខ អ្នកអនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរយារ មិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ ( របស់គាត់ ) ទាំងអស់ ។ សំឡាញ់នោះ ជាអ្នកមានប្រាជ្ញាល្អ ស្មើដោយផែនដី បានតម្កល់ខ្ញុំក្នុងសេចក្តីសង្រួមម្តងទៀតដោយសេចក្តីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះសម្លាប់ពួកសត្វតែក្នុងវេលាថ្ងៃ ជាអ្នកសង្រួម វៀរចាកការសម្លាប់សត្វក្នុងវេលាយប់ ខ្ញុំរក្សាខ្លួនបានតែក្នុងវេលាយប់ វេលាថ្ងៃទៅកាន់ទុគ្គតិ ( ឆ្កែទាំងឡាយ ) ខាំស៊ី ។ ខ្ញុំបានសោយសម្បត្តិមិនមែនជា

របស់មនុស្សក្នុងវេលាយប់ ( ដោយអំណាច ) កុសលកម្មនោះ វេលាថ្ងៃពួកឆ្កែមានចិត្តខ្ញាញ់ស្ទុះមកចោមខាំដោយជុំវិញ ពួកសត្វណាមានការប្រកបរឿយៗ ប្រកបជានិច្ចក្នុងសាសនារបស់ព្រះសុគត ខ្ញុំសម្គាល់ថា ពួកសត្វនោះតែងបាននូវព្រះនិព្វាន ឈ្មោះអមតៈ ជាធម្មជាតិសុទ្ធ គឺមិនលាយឡំដោយលោកិយសុខ ជាបទមិនមានបច្ច័យប្រជុំតាក់តែងបានឡើយ ។

ចប់ រឿង មិគលុទ្ទប្រេតទី ៧ ។

# អដ្ឋកថា បឋមមិគលុទ្ទប្រេត

[ ៣២ ] កាលព្រះសាស្តាគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធមិគលុទ្ទប្រេត ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **នរនារិបុរក្ខតោ យុវា** ដូច្នេះ ជាដើម ។

បានឮថា ក្នុងក្រុងរាជគ្រឹះ មានព្រានព្រៃម្នាក់ ត្រាច់បរបាញ់សត្វចិញ្ចឹមជីវិតទាំងយប់ទាំងថ្ងៃ ។ ព្រាននោះ មានឧបាសកម្នាក់ជាមិត្ត ។ ឧបាសកនោះ កាលមិនអាចឲ្យនាយព្រាននោះ ត្រឡប់ចាកអំពើអាក្រក់ទាំងយប់ទាំងថ្ងៃបាន ទើបដឹកនាំក្នុងបុណ្យកុសល ក្នុងកាលរាត្រីថា មកសម្លាញ់ ចូរអ្នកវៀរចាកបាណាតិបាតក្នុងពេលយប់ ។ ព្រានព្រៃវៀរចាកបាណាតិបាតក្នុងវេលាយប់ ធ្វើតែបាណាតិបាតក្នុងវេលាថ្ងៃប៉ុណ្ណោះ ។

សម័យតមក ព្រានព្រៃធ្វើកាលកិរិយាហើយ កើតជាវេមានិកប្រេតជិត

ក្រុងរាជគ្រឹះ សោយទុក្ខយ៉ាងធំ អស់ពេលថ្ងៃ ដល់ព្រមដោយការបម្រើដោយកាមគុណ ៥ ក្នុងវេលាយប់ ។ ព្រះនារទៈឃើញដូច្នោះ ទើបសួរដោយគាថានេះថា

អ្នកនៅក្នុង មាននរៈនារីចោមរោម រុងរឿងដោយកាមគុណ
ទាំងឡាយគួរឲ្យត្រេកត្រអាលក្នុងពេលយប់ ( រងទុក្ខ ) ក្នុង
ពេលថ្ងៃ អ្នកបានធ្វើកម្មអ្វី ក្នុងជាតិមុន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នរនារិបុរក្ខតោ** សេចក្ដីថា ដែលទេវបុត្តទេពធីតាបម្រើ នាំគ្នាចោមរោមចូលទៅអង្គុយជិត ។ បទថា **យុវា** ប្រែថា នៅកំលោះ ។ បទថា **រជនីយេហិ** បានដល់ ដែលជាហេតុឲ្យប្រាថ្នា គឺជាហេតុឲ្យកើតតម្រេក ។ បទថា **កាមគុណេហិ** បានដល់ ដោយចំណែកនៃកាម ។ បទថា **សោភសិ** អធិប្បាយថា រមែងរុងរឿងដោយការដល់ព្រមក្នុងពេលយប់ ។ ដោយហេតុនោះ ទើបព្រះនារទៈពោលថា សោយទុក្ខក្នុងពេលថ្ងៃ ដូច្នេះ អធិប្បាយថា សោយទុក្ខ គឺការបង្អៀតបង្អល់ មានប្រការផ្សេងៗ ក្នុងពេលថ្ងៃ ។ ម្យ៉ាងទៀត បទថា **រជនិ** បានដល់ ក្នុងវេលាយប់ ។ បទថា **យេហិ** ត្រឹមតែជានិបាត ។ បទថា **កិមកាសិ បុរិមាយ ជាតិយា** សេចក្ដីថា ក្នុងជាតិមុនអំពីជាតិនេះ អ្នកបានធ្វើកម្មអ្វីដែលជាផ្លូវឲ្យសោយសុខនិងទុក្ខយ៉ាងនេះ ចូរអ្នកប្រាប់កម្មនោះចុះ ។

ប្រេតបានស្ដាប់ដូច្នោះ កាលប្រាប់កម្មដែលខ្លួនធ្វើ ទើបពោលគាថាទាំងនេះថា

កាលពីដើមខ្ញុំជាព្រានម្រឹគ មានដៃប្រឡាក់ដោយឈាម ជាអ្នកអាក្រក់នៅក្នុងក្រុងរាជគ្រឹះ មានក្អំដូចជាក្រោល ជាទីគួរត្រេកអររីករាយ ។ ខ្ញុំមានចិត្តប្រទូស្តចំពោះពួកសត្វច្រើនជាសត្វមិនធ្វើកំហុស ( នឹងនរណាមួយ ) អាក្រក់ក្រៃពេក ត្រេកអរតែក្នុងការបៀតបៀនចំពោះសត្វដទៃ មិនសង្រួមគ្រប់កាលទាំងពួង ។ សំឡាញ់របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសក មានសទ្ធា គាត់អនុគ្រោះ បានឃាត់ខ្ញុំរឿយៗថា អ្នកកុំធ្វើអំពើអាក្រក់ឡើយ នែអ្នក អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នាសេចក្ដីសុខក្នុងបរលោក អ្នកចូរវៀរបង់នូវការមិនសង្រួម គឺការសម្លាប់សត្វ ។ ខ្ញុំបានស្ដាប់ពាក្យសំឡាញ់នោះ ជាអ្នកប្រាថ្នានូវសេចក្ដីសុខ អ្នកអនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរយារ មិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ ( របស់គាត់ ) ទាំងអស់ ។ សំឡាញ់នោះ ជាអ្នកមានប្រាជ្ញាល្អ ស្មើដោយផែនដី បានតម្កល់ខ្ញុំក្នុងសេចក្ដីសង្រួមម្ដងទៀត ដោយសេចក្ដីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះសម្លាប់ពួកសត្វតែក្នុងវេលាថ្ងៃ ជាអ្នកសង្រួមវៀរចាកការសម្លាប់សត្វក្នុងវេលាយប់ ខ្ញុំរក្សាខ្លួនបានតែក្នុងវេលាយប់ វេលាថ្ងៃទៅកាន់ទុគ្គតិ ( ឆ្កែទាំងឡាយ )

ខាំស៊ី ។ ខ្ញុំបានសោយសម្បត្តិមិនមែនជារបស់មនុស្សក្នុងវេលាយប់ ( ដោយអំណាច ) កុសលកម្មនោះ វេលាថ្ងៃពួកឆ្កែមានចិត្តខ្ញាញ់ស្ទុះមកចោមខាំដោយជុំវិញ ពួកសត្វណាមានការប្រកបរឿយៗ ប្រកបជានិច្ចក្នុងសាសនារបស់ព្រះសុគត ខ្ញុំសម្គាល់ថា ពួកសត្វនោះតែងបាននូវព្រះនិព្វាន ឈ្មោះអមតៈជាធម្មជាតិសុខុម គឺមិនលាយឡំដោយលោកិយសុខ ជាបទមិនមានបច្ច័យប្រជុំតាក់តែងបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លុទ្ទោ** បានដល់ ជាបុគ្គលឃោរឃៅ ។ បទថា **លោហិតបាណី** បានដល់ មានបាតដៃប្រឡាក់ឈាម គឺដោយការសម្លាប់សត្វរឿយៗ ។ បទថា **ទារុណោ** ប្រែថា ខ្លាំងក្លា អធិប្បាយថា បៀតបៀនខ្លួនឯង ។ បទថា **អវិរោធករេសុ** បានដល់ ក្នុងម្រឹគនិងបក្សីជាដើមដែលមិនធ្វើការក្រោធដោយប្រការណាមួយ ។ បទថា **អសំយមា** ប្រែថា ជាអ្នកមិនសង្រួម គឺជាបុគ្គលទ្រុស្តសីល ។ បទថា **សកលានុសាសនី** សេចក្ដីថា នូវអនុសាសនីទាំងពួង គឺវៀរបង់បាណាតិបាតសព្វកាល ។ បទថា **ចិរបាបាភិរតោ** បានដល់ ជាអ្នកត្រេកអរក្រៃលែងក្នុងបាបអស់កាលយូរ ។

បទថា **សំយមេ** គឺក្នុងសុចរិត ។ បទថា **និវេសយិ** ប្រែថា ឲ្យតាំងនៅហើយ ។ ពាក្យថា បើអ្នកសម្លាប់សត្វក្នុងពេលថ្ងៃ ឯពេលយប់ ចូរវៀរបង់ នេះជាពាក្យសម្ដែងអាការនៃការតាំងមាំ ។ បានឮថា នាយព្រាននោះ

បានជាអ្នកប្រកបការសម្លាប់សត្វរឿយៗក្នុងពេលយប់ ដោយការដាក់អន្ទាក់និងបាញ់ដោយព្រួញជាដើម ។

បទថា **ទិវា ខជ្ជាមិ ទុក្ខតោ** សេចក្តីថា ឥឡូវនេះ ខ្ញុំដល់ទុគ្គតិ ដោយទុក្ខយ៉ាងមហន្ត ត្រូវសុនខទំពាស៊ីក្នុងពេលថ្ងៃ ។ បានឮថា ក្នុងពេលថ្ងៃប្រេតនោះ បានសោយផលដែលគប្បីឃើញស្មើដោយកម្ម ព្រោះប្រេតនោះឲ្យឆ្កែខាំម្រឹគក្នុងពេលថ្ងៃ ឆ្កែធំៗស្ទុះទៅ ធ្វើសរីរៈឲ្យសល់តែរាងឆ្អឹង តែលុះដល់ពេលយប់ រាងកាយនោះត្រឡប់ជាប្រក្រតី សោយទិព្វសម្បត្តិ ព្រោះហេតុនោះទើបលោកពោលថា

ខ្ញុំបានសោយសម្បត្តិមិនមែនជារបស់មនុស្ស ក្នុងវេលាយប់
( ដោយអំណាច ) កុសលកម្មនោះ វេលាថ្ងៃពួកឆ្កែមាន
ចិត្តខ្ទាញ់ស្ទុះមកចោមខាំដោយជុំវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិហាសា** សេចក្តីថា ជាអ្នកមានចិត្តក្តៅក្រហាយ គឺដូចត្រូវសេចក្តីចង្អៀតចង្អល់ចង ។ បទថា **សមន្តា ខាទិតុំ** បានដល់រត់ទៅដើម្បីទំពាស៊ីរាងកាយរបស់ខ្ញុំដោយជុំវិញ ។ សេចក្តីនេះលោកពោលសំដៅយកពេលដែលពួកឆ្កែទាំងនោះ ចូលទៅក្បែរ នាំសេចក្តីខ្លាចមកឲ្យខ្ជួនយ៉ាងក្រៃលែង ឆ្កែទាំងនោះស្ទុះទៅ ធ្វើរាងកាយឲ្យសល់ត្រឹមតែឆ្អឹង ហើយទើបទៅ ។

ក្នុងគាថាចុងក្រោយថា **យេ ច តេ សតតានុយោគិនោ** មានសេចក្តីសង្ខេបដូចតទៅនេះថា ខ្ញុំជាអ្នកវៀរចាកហេតុត្រឹមតែមិនសម្លាប់សត្វក្នុងពេល

យប់ គង់បានសោយទិព្វសម្បត្តិដល់ម៉្លេះ ពួកបុរសណា ជាអ្នកខ្វល់ខ្វាយ មាំទាំ គឺប្រកបព្យាយាមរឿយៗ គឺសព្វកាល ក្នុងអធិសីលជាដើម ក្នុងព្រះសាសនារបស់ព្រះមានព្រះភាគសុគតសាស្តា បុរសទាំងនោះ ជាអ្នកមានបុណ្យ នឹងសម្រេចអមតធម៌ដែលបានឈ្មោះថា អសង្ខតបទ មិនលាយឡំដោយលោកិយសុខតែម្យ៉ាងប៉ុណ្ណោះ គឺបុរសទាំងនោះ រមែងមិនមានការហាមក្នុងការសម្រេចអមតបទនោះ ។

កាលប្រេតនោះពោលយ៉ាងនេះហើយ ព្រះថេរៈក៏ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលដល់ព្រមហើយ ពាក្យទាំងអស់មានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា បឋមមិគលុទ្ទប្រេតចប់

# រឿង ទុតិយមិគលុទ្ទកប្រេត ទី៨

[ ៣៣ ] ( ព្រះនារទត្ថេរសួរប្រេតថា ) អ្នកត្រេកអរលើបល្ល័ង្កដែលក្រាលដោយសំពត់គោណកៈ ក្នុងប្រាសាទដែលជាផ្ទះកំពូល គេប្រគំហើយដោយតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ។ កាលជិតព្រះអាទិត្យរះឡើង ក្នុងទីបំផុតនៃរាត្រីនោះ អ្នកត្រូវគេបោះបង់ចោល ក្នុងព្រៃស្មសាន ដល់នូវសេចក្តីទុក្ខច្រើន ។ អំពើអាក្រក់ដូចម្តេចដែលអ្នកបានធ្វើហើយដោយកាយ វាចា ចិត្ត អ្នកដល់នូវសេចក្តីទុក្ខនេះ តើដោយផលនៃកម្មដូចម្តេច ។

( ប្រេតនោះឆ្លើយថា ) កាលពីដើម ខ្ញុំជាព្រានម្រឹគ ជាអ្នកអាក្រក់មិនសង្រួម នៅក្នុងក្រុងរាជគ្រឹះ មានភ្នំដូចជាក្រោល គួរត្រេកអរពីកពាយ ។ សំឡាញ់របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសកមានសទ្ធា មានភិក្ខុមួយអង្គជាជីតុនរបស់សំឡាញ់ខ្ញុំនោះ ជាសាវករបស់ព្រះគោតម ។ ភិក្ខុនោះ អនុគ្រោះ បានឃាត់ខ្ញុំរឿយៗថា កុំធ្វើអំពើអាក្រក់ឡើយ នែអ្នក អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នាសេចក្តីសុខក្នុងបរលោក អ្នកចូរវៀរបង់នូវការមិនសង្រួម គឺការសម្លាប់សត្វ ។ ខ្ញុំបានស្តាប់ពាក្យរបស់ភិក្ខុនោះលោកប្រាថ្នាសេចក្តីសុខ អនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរយារ មិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ ( របស់លោក ) ទាំងអស់ ។ ភិក្ខុនោះ លោកមានប្រាជ្ញាល្អស្មើដោយផែនដី បានតម្កល់ខ្ញុំក្នុងសេចក្តីសង្រួមម្តងទៀតដោយសេចក្តីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះសម្លាប់ពួកសត្វតែក្នុងវេលាថ្ងៃ ជាអ្នកសង្រួម វៀរចាកការសម្លាប់សត្វក្នុងវេលាយប់ ខ្ញុំរក្សាខ្លួន

បានតែក្នុងវេលាយប់ វេលាថ្ងៃទៅកាន់ទុគ្គតិ ( ឆ្កែទាំងឡាយ ) ខាំស៊ី ។ ខ្ញុំសោយសម្បត្តិទិព្វ ( ដោយអំណាច ) នៃកុសលកម្មនោះក្នុងវេលាយប់ វេលាថ្ងៃពួកឆ្កែមានចិត្តខ្ញាញ់ ស្ទុះមកចោមខាំដោយជុំវិញ ពួកសត្វណាមានការប្រកបរឿយៗ ប្រកបជានិច្ចក្នុងសាសនារបស់ព្រះសុគត ខ្ញុំសម្គាល់ថា ពួកសត្វនោះ តែងបាននូវព្រះនិព្វានឈ្មោះអមតៈ ជាធម្មជាតសុទ្ធ គឺមិនលាយឡំដោយលោកិយសុខ ជាបទមិនមានបច្ច័យប្រជុំតាក់តែងបានឡើយ ។

## ចប់ រឿងទុតិយមិគលុទ្ទប្រេតទី ៨ ។

# អដ្ឋកថា ទុតិយមិគលុទ្ទប្រេត

[ ៣៣ ] កាលព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធមិគលុទ្ទប្រេតម្នាក់ទៀត ទើបត្រាស់ពាក្យផ្តើមថា **កូដាគារេ ច បា-សាទេ** ដូច្នេះជាដើម ។

បានឮថា ក្នុងក្រុងរាជគ្រឹះ មាណពឈ្មោះមាគវិកៈម្នាក់ ជាអ្នកដល់ព្រមដោយសម្បត្តិ លះភោគសុខ ចេញបាញ់ម្រឹគទាំងយប់ទាំងថ្ងៃ ។ ឧបាសកម្នាក់ជាសម្លាញ់របស់ព្រានព្រៃនោះ អាស្រ័យសេចក្តីករុណា ទើបទូន្មានថា នែសម្លាញ់ ចូរអ្នកវៀរចាកបាណាតិបាត អ្នកកុំធ្វើវត្ថុដែលមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរឡើយ ។ ព្រាននោះមិនបានអើពើក្នុងឱវាទនោះឡើយ ។ លំដាប់នោះ ឧបាសកនោះ ក៏សូមព្រះវីណាស្រពជាថេរៈជាអ្នក

ចម្រើនចិត្តមួយរូបថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សម្តែងធម៌ដល់បុរសឈ្មោះនោះ ធ្វើយ៉ាងណាឲ្យគេវៀរចាកបាណាតិបាត ។

ថ្ងៃមួយ ព្រះថេរៈនោះត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បានឈរត្រង់ទ្វារផ្ទះរបស់ព្រាន ។ មាតុគាមនោះឃើញព្រះថេរៈហើយ មានសេចក្តីរាប់អានច្រើន និមន្តឲ្យចូលទៅក្នុងផ្ទះ បានចាត់ចែងអាសនៈប្រគេន ។

ព្រះថេរៈអង្គុយលើអាសនៈដែលគេរៀបចំហើយ ។ ឯមាណពនោះ ក៏ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយ ព្រះថេរៈប្រកាសទោសក្នុងបាណាតិបាតនិងអានិសង្សក្នុងការវៀរចាកបាណាតិបាត ដល់ព្រានព្រៃនោះ ព្រានព្រៃលុះបានស្តាប់ដូច្នេះហើយ ក៏មិនប្រាថ្នានឹងវៀរចាកបាណាតិបាតនោះ ។ លំដាប់នោះ ព្រះថេរៈក៏ពោលថា បើអ្នកមិនអាចវៀរដោយប្រការទាំងពួងបានសោត ជាបឋម ក៏ចូរវៀរក្នុងវេលាយប់ចុះ ព្រានទទួលពាក្យថា សាធុ ហើយទើបវៀរក្នុងពេលយប់ ចាកបាណាតិបាតនោះ ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងបន្ទាប់មកនោះឯង ឯក្នុងគាថាព្រះនារទត្ថេរបានសាកសួរ ប្រេតនោះដោយគាថា ៣ ថា

អ្នកត្រេកអរលើបល្ល័ង្ក ដែលក្រាលដោយសំពត់គោណកៈក្នុងប្រាសាទដែលជាផ្ទះកំពូល គេប្រគំហើយដោយតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ។ កាលជិតព្រះអាទិត្យរះឡើងក្នុងទីបំផុតនៃរាត្រីនោះ អ្នកត្រូវគេបោះបង់ចោលក្នុងព្រៃស្មសាន ដល់នូវសេចក្តីទុក្ខច្រើន ។អំពើអាក្រក់ដូចម្តេចដែលអ្នកបានធ្វើហើយ

ដោយកាយ វាចា ចិត្ត អ្នកដល់នូវសេចក្តីទុក្ខនេះ តើដោយ
ផលនៃកម្មដូចម្តេច ដូច្នេះ ។

លំដាប់នោះ ប្រេតក៏ប្រាប់សេចក្តីនោះដល់ព្រះថេរៈដោយគាថាទាំងឡាយ
ថា

កាលពីដើម ខ្ញុំជាព្រានម្រឹគ ជាអ្នកអាក្រក់ មិនសង្រួម នៅក្នុង
ក្រុងរាជគ្រឹះ មានក្តីដូចជាក្រោល គួរត្រេកអរវីករាយ ។ សំឡាញ់
របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសកមានសទ្ធា មាន
ភិក្ខុមួយអង្គជាជីតុន របស់សំឡាញ់ខ្ញុំនោះ ជាសាវ័ករបស់ព្រះ
គោតម ។ ភិក្ខុនោះ អនុគ្រោះ បានឃាត់ខ្ញុំរឿយៗថា កុំធ្វើ
អំពើអាក្រក់ឡើយ នៃអ្នក អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នក
ប្រាថ្នាសេចក្តីសុខក្នុងបរលោក អ្នកចូរវៀរបង់នូវការមិនសង្រួម
គឺការសម្លាប់សត្វ ។ ខ្ញុំបានស្តាប់ពាក្យរបស់ភិក្ខុនោះ លោក
ប្រាថ្នាសេចក្តីសុខ អនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេក
អរក្នុងបាបយូរយារ មិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀន
ប្រដៅ ( របស់លោក ) ទាំងអស់ ។ ភិក្ខុនោះ លោកមានប្រាជ្ញា
ល្អ ស្មើដោយផែនដី បានតម្កល់ខ្ញុំក្នុងសេចក្តីសង្រួមម្តងទៀត
ដោយសេចក្តីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វ ក្នុងវេលាថ្ងៃ
ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះសម្លាប់ពួកសត្វតែ
ក្នុងវេលាថ្ងៃ ជាអ្នកសង្រួម វៀរចាកការសម្លាប់សត្វក្នុងវេលា

យប់ ខ្ញុំរក្សាខ្លួនបានតែក្នុងវេលាយប់ វេលាថ្ងៃទៅកាន់ទុគ្គតិ ( ឆ្កែទាំងឡាយ ) ខាំស៊ី ។ ខ្ញុំសោយសម្បត្តិទិព្វ ( ដោយអំណាច ) នៃកុសលកម្មនោះក្នុងវេលាយប់ វេលាថ្ងៃពួកឆ្កែមានចិត្តខ្ទាញ់ស្ទុះមកចោមខាំដោយជុំវិញ ពួកសត្វណាមានការប្រកបរឿយៗ ប្រកបជានិច្ចក្នុងសាសនារបស់ព្រះសុគត ខ្ញុំសម្គាល់ថាពួកសត្វនោះតែងបាននូវព្រះនិព្វានឈ្មោះអមតៈ ជាធម្មជាតសុទ្ធ គឺមិនលាយឡំដោយលោកិយសុខ ជាបទមិនមានបច្ច័យប្រជុំតាក់តែងបានឡើយ ដូច្នេះ ។

អត្ថនៃគាថានោះ មានន័យដូចពោលហើយខាងដើមនោះឯង ។

## អដ្ឋកថា ទុតិយមិគលុទ្ទកប្រេតចប់

# រឿង កូដវិនិច្ឆយប្រេត ទី ៩

[ ៣៤ ] ( ព្រះនារទត្ថេរសួរប្រេតថា ) អ្នកពាក់នូវកម្រងផ្កា ជួតក្បាល ពាក់សង្វារ ខ្លួនរបស់អ្នកប្រោះព្រំដោយខ្លឹមចន្ទន៍ អ្នកមានសម្បុរមុខថ្លា ល្អ ដូចជាសម្បុរនៃព្រះអាទិត្យ ។ បរិវារទាំងឡាយរបស់អ្នកដែលរាប់បញ្ចូលក្នុង បរិសទ្យមិនមែនជាមនុស្ស គឺនាងកញ្ញា មួយម៉ឺន ជាស្រីបម្រើរបស់អ្នក ។ នាងកញ្ញាទាំងនោះ ទ្រទ្រង់នូវសង្វារមាស ស្អិតស្អាងដោយសំពត់មាស អ្នក ជាបុគ្គលមានអានុភាពច្រើន មានរូបអាចញ៉ាំងពួកជនអ្នកមើលឲ្យព្រឺរោម ។ អ្នកខ្វារសាច់ខ្នងរបស់ខ្លួន ស៊ីដោយខ្លួនឯង តើអំពើអាក្រក់ដូចម្តេចដែលអ្នក ធ្វើដោយកាយ វាចា ចិត្ត អ្នកខ្វារសាច់ខ្នងរបស់ខ្លួនស៊ីដោយខ្លួនឯង តើដោយ ផលនៃកម្មដូចម្តេច ។

( ប្រេតនោះបានឆ្លើយថា ) ខ្ញុំបានប្រព្រឹត្តដើម្បីសេចក្តីវិនាសខ្លួនដោយការ ញុះញង់នឹងមុសាវាទផង ដោយការបន្ទំនឹងបោកប្រាស់ផង ក្នុងជីវលោក ។ ខ្ញុំបានទៅកាន់បរិស័ទ មិនធ្វើនូវហេតុមានប្រយោជន៍ ក្នុងកាលពិតដែលតាំង ឡើងប្រាកដ បែរជាប្រព្រឹត្តតាមនូវហេតុដែលមិនមានប្រយោជន៍វិញ ក្នុងជីវ លោកនោះ ។ ប្រេតណាស៊ីសាច់ខ្នង ប្រេតនោះឈ្មោះថាស៊ីខ្លួនឯង ដូចជាខ្ញុំ ស៊ីសាច់ខ្នងរបស់ខ្លួន ក្នុងថ្ងៃនេះដែរ ។

បពិត្រព្រះនារទៈ រឿងនេះលោកម្ចាស់បានឃើញដោយព្រះអង្គឯងស្រាប់ ហើយ ជនទាំងឡាយណា ជាអ្នកអនុគ្រោះ ជនទាំងនោះ ជាអ្នកឈ្លាសវៃ គប្បីពោលថា អ្នកកុំនិយាយពាក្យញុះញង់ផង កុំនិយាយពាក្យកុហកផង អ្នក កុំស៊ីនូវសាច់ខ្នងឡើយ ។

ចប់ រឿងកូដវិនិច្ឆយប្រេតទី ៩ ។

# អដ្ឋកថា កូដវិនិច្ឆយប្រេត

[ ៣៤ ] កាលព្រះសាស្តាគង់នៅក្នុងវត្តវេឡុវនមហាវិហារ ទ្រង់ប្រារព្ធប្រេតអ្នកវិនិច្ឆ័យក្តីកោង ទើបត្រាស់ពាក្យផ្តើមថា **មាលី កិរិដី កាយូរី** ដូច្នេះជាដើម ។

ក្នុងកាលនោះ ព្រះបាទពិម្ពិសាររក្សាឧបោសថមួយខែ ៦ ថ្ងៃ មនុស្សជាច្រើន ក៏យកតម្រាប់តាមព្រះរាជា នាំគ្នារក្សាឧបោសថ ។ ព្រះរាជាត្រាស់សួរពួកមនុស្ស ដែលមកកាន់សម្នាក់របស់ព្រះអង្គថា អ្នករក្សាឧបោសថដែរឬ ឬមិនរក្សាទេ ។ ក្នុងបណ្តាមនុស្សទាំងនោះ ចៅក្រមម្នាក់ ជាអ្នកមានវាចាញុះញង់ បោកបញ្ឆោត ជាអ្នកទទួលសំណូក កាលមិនអាចពោលថា ទូលបង្គំមិនបានរក្សាឧបោសថ ក៏ក្រាបទូលថា ទូលបង្គំរក្សាឧបោសថ ។ គ្រានោះ សម្លាញ់របស់គាត់ក៏ពោលនឹងគាត់ដែលចេញអំពីទីជិតព្រះរាជាថា នែសម្លាញ់ ថ្ងៃនេះអ្នករក្សាឧបោសថឬ បុរសនោះឆ្លើយថា អើសម្លាញ់ ព្រោះការខ្លាច ទើបខ្ញុំពោលយ៉ាងនោះ ចំពោះព្រះភក្ត្រព្រះរាជា តែខ្ញុំមិនបានរក្សាឧបោសថទេ ។

លំដាប់នោះ សម្លាញ់នោះក៏ពោលនឹងបុរសនោះថា បើដូច្នោះ ជាបឋមចូរឯងរក្សាឧបោសថកន្លះថ្ងៃ ក្នុងថ្ងៃនេះ ចូរឯងសមាទានអង្គឧបោសថចុះ ។ បុរសនោះទទួលពាក្យសម្លាញ់ថា សាធុ ហើយទៅកាន់ផ្ទះ មិនបរិភោគអ្វីឡើយ ខ្ពុរមាត់អធិដ្ឋានឧបោសថ គាត់រក្សាឧបោសថក្នុងពេលយប់ ត្រូវខ្យល់ចាក់ដោតផ្ទៃដ៏មានកម្លាំង ព្រោះមានពោះទទេ គាត់ដាច់អាយុសង្ខារ បន្ទាប់អំពីចុតិ ទៅកើតជាវេមានិកប្រេតត្រង់ចង្កេះភ្នំ ។ ពិតហើយ ប្រេតនោះ មាន

វិមាន មានស្រីបុំមួយម៉ឺននាក់ជាបរិវារនិងទិព្វសម្បត្តិដ៏ច្រើន ដោយហេតុត្រឹមតែការរក្សាឧបោសថមួយរាត្រី ។ តែព្រោះខ្លួនជាអ្នកកាត់ក្តីកោង ពោលវាចាញុះញង់ ក៏ខ្វារសាច់ខ្នងឯងបរិភោគ ។ ព្រះនារទៈចុះអំពីភ្នំគិជ្ឈកូដ ឃើញប្រេតនោះ ទើបសួរដោយគាថា ៤ ថា

អ្នកពាក់នូវកម្រងផ្កា ជួតក្បាល ពាក់សង្វារ ខ្លួនរបស់អ្នកប្រស់ព្រំដោយខ្លឹមចន្ទន៍ អ្នកមានសម្បុរមុខថ្លា ល្អដូចជាសម្បុរនៃព្រះអាទិត្យ ។ បរិវារទាំងឡាយរបស់អ្នកដែលរាប់បញ្ចូលក្នុងបរិសទ្យមិនមែនជាមនុស្ស គឺនាងកញ្ញា មួយម៉ឺន ជាស្រីបម្រើរបស់អ្នក ។ នាងកញ្ញាទាំងនោះ ទ្រទ្រង់នូវសង្វារមាសស្អិតស្អាងដោយ សំពត់មាស អ្នកជាបុគ្គលមានអានុភាពច្រើន មានរូបអាចញុំាងពួកជនអ្នកមើលឲ្យព្រឺរោម ។ អ្នកខ្វារសាច់ខ្នងរបស់ខ្លួន ស៊ីដោយខ្លួនឯង តើអំពើអាក្រក់ដូចម្តេចដែលអ្នកធ្វើដោយកាយ វាចា ចិត្ត អ្នកខ្វារសាច់ខ្នងរបស់ខ្លួនស៊ីដោយខ្លួនឯង តើដោយផលនៃកម្មដូចម្តេច ។

ប្រេតនោះបានឆ្លើយថា

ខ្ញុំបានប្រព្រឹត្ត ដើម្បីសេចក្តីវិនាសខ្លួន ដោយការញុះញង់នឹងមុសាវាទផង ដោយការបន្លំនឹងបោកប្រាស់ផង ក្នុងជីវលោក ។ ខ្ញុំបានទៅកាន់បរិស័ទ មិនធ្វើនូវហេតុមានប្រយោជន៍ ក្នុងកាលពិតដែលតាំងឡើងប្រាកដ បែរជាប្រព្រឹត្តតាមនូវហេតុ ដែល

មិនមានប្រយោជន៍វិញ ក្នុងជីវលោកនោះ ។ ប្រេតណាស៊ីសាច់ខ្នង ប្រេតនោះឈ្មោះថាស៊ីខ្លួនឯង ដូចជាខ្ញុំស៊ីសាច់ខ្នងរបស់ខ្លួន ក្នុងថ្ងៃនេះដែរ ។

បពិត្រព្រះនារទៈ រឿងនេះ លោកម្ចាស់ បានឃើញដោយព្រះអង្គឯងស្រាប់ហើយ ជនទាំងឡាយណា ជាអ្នកអនុគ្រោះជនទាំងនោះ ជាអ្នកឈ្លាសវៃ គប្បីពោលថា អ្នកកុំនិយាយពាក្យញុះញង់ផង កុំនិយាយពាក្យកុហកផង អ្នកកុំស៊ីនូវសាច់ខ្នងឡើយ ដូច្នេះ ។

ឯប្រេតនោះ បានឆ្លើយសេចក្ដីនោះ ៣ គាថា ដល់ព្រះនារទត្ថេរនោះហើយ ។

បណ្ដាបទទាំងនោះ បទថា **មាលី** បានដល់ ទ្រទ្រង់នូវកម្រងផ្កា អធិប្បាយថា ប្រដាប់ដោយផ្កាទិព្វ ។ បទថា **កិរីដី** ប្រែថា ជាអ្នកពាក់នូវជដា ( ឆ្នូត ) ។ បទថា **កាយូរី** ប្រែថា ជាអ្នកពាក់កងមាស អធិប្បាយថា ប្រដាប់ដោយគ្រឿងប្រដាប់ដៃ ។ បទថា **គត្តា** ប្រែថា អវយវៈ គឺសរីរៈ ។ បទថា **ចន្ទនុស្សទា** ប្រែថា លាបដោយលម្អិតខ្លឹមចន្ទន៍ ។ បទថា **សុរិយវណ្ណោវ សោភសិ** សេចក្ដីថា អ្នកមានពណ៌សម្បុរដូចពណ៌នៃព្រះអាទិត្យដែលទើបរះ រមែងរុងរឿង ។ បាលីថា **អរុណវណ្ណី បភាសសិ** ដូច្នេះក៏មាន ។ បទថា **អរុណំ** សេចក្ដីថា មានពណ៌ស្មើដោយទេវអរុណ ( ព្រះអាទិត្យ ) ដែលជាស្ដេចនៃអវកាស ។

បទថា **ចារិសជ្ជា** បានដល់ ដែលទាក់ទងក្នុងបរិស័ទ អធិប្បាយថា ជាអ្នកឧបដ្ឋាក ។ បទថា **ត្វំ** ប្រែថា អ្នក ។ បទថា **លោមហំសនរូបវា** បានដល់ ប្រកបដោយរូបដែលឲ្យកើតការព្រឺរោមព្រឺស្បែកដល់អ្នកឃើញ ។ ពិតហើយ ពាក្យថា **លោមហំសនរូបវា** នេះ លោកពោលទុក ព្រោះការដល់ព្រមដោយភាពជាអ្នកមានអានុភាពច្រើន ។ បទថា **ឧក្កុដ្ឋ** ប្រែថា កាត់ អធិប្បាយថា ខ្វះខ្វារ ។

បទថា **អចារិសំ** បានដល់ បានប្រព្រឹត្តហើយ គឺបានប្រព្រឹត្តទៅហើយ ។ បទថា **បេសុញ្ញមុសាវាទេន** ប្រែថា ដោយភាពជាអ្នកញុះញង់ និងពោលកុហក ។ បទថា **និកតិវញ្ចនាយ ច** បានដល់ ដោយការស៊ីសំណូក គឺដោយការបោកបញ្ឆោត ដោយធ្វើឲ្យប្លែកដល់ជនដទៃ ដោយសម្ដែងវត្ថុក្លែងក្លាយ ។

បទថា **សច្ចកាលេ** គឺក្នុងកាលដែលសមគួរដើម្បីនឹងពោលពាក្យសច្ចៈ ។ បទថា **អត្ថំ** បានដល់ ប្រយោជន៍ មានប្រយោជន៍ក្នុងបច្ចុប្បន្នជាដើម ។ បទថា **ធម្មំ** បានដល់ ហេតុ គឺវត្ថុដែលគួរ ។ បទថា **និរាកត្វា** បានដល់ បោល គឺលះបង់ ។ បទថា **សោ** បានដល់ សត្វប្រព្រឹត្តវចីទុច្ចរិត មានការញុះញង់ជាដើម ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

អដ្ឋកថា កូដវិនិច្ឆយប្រេតចប់

# រឿង ធាតុវិវណ្ណប្រេត ទី ១០

[ ៣៥ ] ( ព្រះមហាកស្សបៈសួរធាតុវិវណ្ណប្រេតថា ) អ្នកឋិតនៅ ឰដ៏អាកាស មានក្លិនអាក្រក់ ស្អុយផ្សាយទៅផង ពួកដង្កូវរុកស៊ីមាត់របស់អ្នកដែលមានក្លិនស្អុយផង តើអ្នកបានធ្វើអំពើដូចម្តេច ក្នុងកាលមុន ។ ព្រោះតែផ្សាយក្លិនអាក្រក់ទើងមាត់ដែលដង្កូវរុកស៊ីនោះ ( បានជាពួកសត្វដែលកម្មជាស់តឿន ) កាន់គ្រឿងសស្ត្រាមកវះ ( មាត់អ្នក ) រឿយៗហើយស្រោចដោយទឹកខារ ( ទឹកក្រុត ) រួចវះញយៗថែមទៀត ។ អំពើអាក្រក់ដូចម្តេចដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត អ្នករងទុក្ខនេះ តើដោយផលនៃកម្មដូចម្តេច ។

( ធាតុវិវណ្ណប្រេតនោះឆ្លើយថា ) បពិត្រលោកអ្នកនិរទុក្ខ ខ្ញុំជាឥស្សរៈលើទ្រព្យនិងធញ្ញជាតិដ៏ច្រើនក្រៃលែង ( នៅ ) ក្នុងក្រុងរាជគ្រឹះ មានក្តីដូចជាក្រោល គួរត្រេកអររីករាយ ។ ( កាលពីជាតិមុន ) ស្រីនេះជាប្រពន្ធរបស់ខ្ញុំផង ស្រីនេះជាធីតារបស់ខ្ញុំផង ស្រីនេះជាកូនប្រសាររបស់ខ្ញុំផង ខ្ញុំបានឃាត់ ( ស្រីនោះ ) ដែលនាំផ្កាពុំសែន ផ្កាឧប្បល និងគ្រឿងលាបមានតម្លៃ ទៅកាន់ព្រះស្តូប បាបនោះឯងដែលខ្ញុំបានធ្វើហើយ ។ ពួកយើងចំនួន ៨៦០០០ នាក់ រងទុក្ខវេទនាចំពោះខ្លួន ៗ ឆេះនៅក្នុងនរកយ៉ាងខ្លាំង ព្រោះតិះដៀលនូវការបូជាចំពោះស្រះស្តូប ពួកជនណា ប្រកាសនូវទោសក្នុងការបូជាចំពោះព្រះអរហន្តសម្មាសម្ពុទ្ធដែលប្រព្រឹត្តទៅដោយការបូជានូវព្រះស្តូប ( ដូចជាខ្ញុំ ) សូមលោកម្ចាស់ញុំាងពួកជននោះ កុំឲ្យឃ្លាតចេញចាកបុណ្យនោះឡើយ សូមលោកម្ចាស់មើលពួកស្រីទាំងនេះដែលទ្រទ្រង់កម្រងផ្កា មាន

ខ្លួនប្រដាប់ហើយ កំពុងមកតាមអាកាសផង ។ ពួកស្រីទាំងនោះ បានសម្រេច ( សម្បត្តិទិព្វ ) មានយសបរិវារ កំពុងសោយផលនៃការបូជាដោយកម្រងផ្កា សេចក្តីព្រឺរោមក៏កើតឡើង ព្រោះឃើញហេតុជាអស្ចារ្យ ចំឡែកនោះ ។ ពួកអ្នកមានប្រាជ្ញា តែងធ្វើនមស្ការថ្វាយបង្គំសរសើរព្រះមហាមុនីនោះ ខ្ញុំនោះលុះទៅអំពីបេតលោកនេះ ហើយបាននូវកំណើតជាមនុស្ស ជាអ្នកលែងធ្វេសប្រហែស នឹងធ្វើការបូជាចំពោះព្រះស្តូបរឿយៗដោយពិត ។

## ចប់ រឿងធាតុវិវណ្ណប្រេតទី ១០ ។

## ឧទ្ទាន

និយាយអំពីរឿងអភិជ្ជមានប្រេត ១ រឿងសានុវាសិប្រេត ១ រឿងរថការីប្រេត ១ រឿងភុសប្រេត ១ រឿងកុមារប្រេត ១ រឿងសេរិនីប្រេត ១ រឿងមិគលុទ្ទប្រេត ២ លើក រឿងកូដវិនិច្ឆយកប្រេតដែលស៊ីសាច់ខ្នងរបស់ខ្លួន ១ រឿងធាតុវិវណ្ណប្រេតឃាត់ការបូជា ១ ព្រោះហេតុនោះទើបចាត់ជាវគ្គ ។

## ចប់ ចូឡវគ្គទី ៣ ។

# អដ្ឋកថា ធាតុវិវណ្ណប្រេត

[ ៣៥ ] រឿងរបស់ប្រេតតិះដៀលព្រះធាតុនេះ មានពាក្យផ្តើមថា **អន្ត-លិក្ខស្មឹ តិដ្ឋន្តោ** ដូច្នេះជាដើម ។

កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានក្នុងចន្លោះនៃដើមរាំងទាំងគូនាសាលវនោទ្យាននៃមល្លក្សត្រដែលជាទីចៀងចូលសម្រាក ក្នុងនគរកុសិនារា ធ្វើនូវការចែកព្រះធាតុ ព្រះបាទអជាតសត្តុទ្រង់កាន់យកចំណែកព្រះធាតុដែលទ្រង់បាន ទ្រង់រឭកដល់ពុទ្ធគុណ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ហើយឲ្យការបូជាដ៏ឧឡារប្រព្រឹត្តទៅ ។

ពួកមនុស្សក្នុងទីនោះ រាប់មិនបាន ប្រមាណមិនកើត នាំគ្នាធ្វើចិត្តឲ្យជ្រះថ្លា បានចូលដល់ស្ថានសួគ៌ ។ បុរសប្រមាណ ៨៦០០០ នាក់ ក្នុងទីនោះ មានចិត្តវិបល្លាស ព្រោះភាពជាអ្នកមិនមានសទ្ធា និងព្រោះការឃើញខុសដែលខ្លួនឲ្យកើតអស់កាលយូរប្រទូស្តចិត្តរបស់ខ្លួន សូម្បីក្នុងខណៈដែលជាទីតាំងនៃការជ្រះថ្លា ហើយកើតក្នុងពួកប្រេត ។ ភរិយា ធីតា កូនប្រសារបស់កុដុម្ពិកៈដែលដល់ព្រមដោយសម្បត្តិម្នាក់ ក្នុងក្រុងរាជគ្រឹះ នោះឯងមានចិត្តជ្រះថ្លា នាំគ្នាគិតថា នឹងបូជាព្រះធាតុ ទើបកាន់យកសក្ការៈ មានផ្កាក្រអូបនិងគ្រឿងក្រអូបជាដើម ទៅកាន់ទីបញ្ចុះព្រះធាតុ ។ កុដុម្ពិកៈនោះគិតថា ប្រយោជន៍អ្វីដោយការបូជាធ្អឹង ទើបជេរស្រីទាំងនោះ តិះដៀលការបូជាព្រះធាតុ ។ ស្រីទាំងនោះ ក៏មិនជឿពាក្យរបស់កុដុម្ពិកៈនោះ នាំគ្នាទៅក្នុងទីនោះ ធ្វើការបូជាព្រះធាតុ មកកាន់ផ្ទះ ត្រូវរោគគ្របសង្កត់ មិនយូរប៉ុន្មានក៏ធ្វើកាលកិរិយាទៅកើតក្នុងទេវលោក ឯកុដុម្ពិកៈនោះ ត្រូវសេចក្តីក្រោធ

គ្របសង្កត់ មិនយូរប៉ុន្មាន ធ្វើកាលកិរិយាហើយ ទៅកើតក្នុងពួកប្រេតព្រោះបាបកម្មនោះ ។

ថ្ងៃមួយ ព្រះមហាកស្សបៈគាក់តែងឥទ្ធាភិសង្ខារ ដោយប្រការដែលពួកមនុស្សឃើញប្រេតទាំងនោះ និងទេវតាទាំងនោះ ដើម្បីអនុគ្រោះក្នុងសត្វទាំងឡាយ ។ កាលធ្វើយ៉ាងនោះហើយ ឈរក្នុងលានព្រះចេតិយ សួរប្រេតដែលតិះដៀលព្រះធាតុនោះ ៣ គាថា ប្រេតនោះបានព្យាករដល់ព្រះថេរៈហើយ ។ ព្រះថេរៈសួរថា

អ្នកឋិតនៅឰដ៏អាកាស មានក្លិនអាក្រក់ ស្អុយផ្សាយទៅផង ពួកដង្កូវរុកស៊ីមាត់របស់អ្នក ដែលមានក្លិនស្អុយផង តើអ្នកបានធ្វើអំពើដូចម្តេច ក្នុងកាលមុន ។ ព្រោះតែផ្សាយក្លិនអាក្រក់នឹងមាត់ដែលដង្កូវរុកស៊ីនោះ ( បានជាពួកសត្វដែលកម្មដាស់តឿន ) កាន់គ្រឿងសស្ត្រាមកវះ ( មាត់អ្នក ) រឿយៗ ហើយស្រោចដោយទឹកខារ ( ទឹកក្រូត ) រួចវះញយៗថែមទៀត ។ អំពើអាក្រក់ដូចម្តេចដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត អ្នករងទុក្ខនេះ តើដោយផលនៃកម្មដូចម្តេច ។

ប្រេតនោះឆ្លើយថា

បពិត្រលោកអ្នកនិរទុក្ខ ខ្ញុំជាឥស្សរៈ លើទ្រព្យនិងធញ្ញជាតិដ៏ច្រើនក្រៃលែង ( នៅ ) ក្នុងក្រុងរាជគ្រឹះ មានក្តីដូចជាក្រោល គួរត្រេកអររីករាយ ។ ( កាលពីជាតិមុន ) ស្រីនេះ

ជាប្រពន្ធរបស់ខ្ញុំផង ស្រីនេះជាធីតារបស់ខ្ញុំផង ស្រីនេះជាកូនប្រសាររបស់ខ្ញុំផង ខ្ញុំបានឃាត់ ( ស្រីនោះ ) ដែលនាំផ្កាពុំសែន ផ្កាឧប្បល និងគ្រឿងលាបមានតម្លៃ ទៅកាន់ព្រះស្តូបបាបនោះឯងដែលខ្ញុំបានធ្វើហើយ ។ ពួកយើងចំនួន ៨៦០០០ នាក់ រងទុក្ខវេទនាចំពោះខ្លួនៗ ឆេះនៅក្នុងនរកយ៉ាងខ្លាំង ព្រោះតិះដៀលនូវការបូជាចំពោះស្រះស្តូប ពួកជនណាប្រកាសនូវទោសក្នុងការបូជាចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ ដែលប្រព្រឹត្តទៅដោយការបូជានូវព្រះស្តូប ( ដូចជាខ្ញុំ ) សូមលោកម្ចាស់ញ៉ាំងពួកជននោះ កុំឲ្យឃ្លាតចេញចាកបុណ្យនោះឡើយ សូមលោកម្ចាស់មើលពួកស្រីទាំងនេះដែលទ្រទ្រង់កម្រងផ្កា មានខ្លួនប្រដាប់ហើយ កំពុងមកតាមអាកាសផង ។ ពួកស្រីទាំងនោះ បានសម្រេច ( សម្បត្តិទិព្វ ) មានយសបរិវារ កំពុងសោយផលនៃការបូជាដោយកម្រងផ្កា សេចក្តីព្រឺរោមក៏កើតឡើងព្រោះឃើញហេតុជាអស្ចារ្យ ចំឡែកនោះ ។ ពួកអ្នកមានប្រាជ្ញា តែងធ្វើនមស្ការថ្វាយបង្គំសរសើរព្រះមហាមុនីនោះ ខ្ញុំនោះ លុះទៅអំពីបេតលោកនេះ ហើយបាននូវកំណើតជាមនុស្ស ជាអ្នកលែងធ្វេសប្រហែល នឹងធ្វើការបូជាចំពោះព្រះស្តូបរឿយៗដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧគ្គត្ថោ** បានដល់ ដែលមានក្លិនមិនគួរប្រា-

ថា អធិប្បាយថា មានក្លិនដូចក្លិនគំរង់ ដោយហេតុនោះ ព្រះមហាកស្សបត្ថេរពោលថា **បូតិ វាយសិ** ស្អុយផ្សាយទៅ ដូច្នេះ ។ បទថា **តតោ** សេចក្តីថា ក្រៅអំពីក្លិនស្អុយផ្សាយទៅ មានពួកដង្កូវដញ្ជែងគ្នារូងជញ្ជក់ ។ បទថា **សត្ថំ គហេត្វាន ឱក្កន្តន្តិ បុនប្បុនំ** សេចក្តីថា សត្វទាំងឡាយត្រូវកម្មជាស់តឿន ទើបយកសស្ត្រាដែលសំលៀងមុត ពុះមុខដំបៅនោះរឿយៗ ។ បទថា **ខារេន បរិប្ផោសិត្វា ឱក្កន្តន្តិ បុនប្បុនំ** សេចក្តីថា ត្រូវស្រោចដោយទឹកខារក្នុងទីដែលធូតវះសាច់នោះ ។

បទថា **ឥស្សរោ ធនធញ្ញស្ស សុបហូតស្ស** សេចក្តីថា ជាធំ គឺជាម្ចាស់របស់ទ្រព្យនិងធញ្ញាហារច្រើនក្រៃលែង អធិប្បាយថា ជាបុគ្គលស្តុកស្តម្ភមានទ្រព្យច្រើន ។

បទថា **តស្សាយំ មេ ភរិយា ច ធីតា ច សុណិសា ច** សេចក្តីថា ក្នុងអត្តភាពមុន បុគ្គលនេះជាភរិយា ជាធីតា ជាកូនប្រសាររបស់ខ្ញុំនោះ ។ ប្រេតពោលថា ស្រីទាំងនោះជាទេពធីតាឈរក្នុងអាកាស ។ បទថា **បច្ចគ្ឃំ** បានដល់ ជារបស់ថ្មី ។ បទថា **ថូបំ ហរន្តិយោ វារេសឹ** សេចក្តីថា ខ្ញុំតិះដៀលព្រះធាតុ ឃាត់នូវស្រីទាំងនោះដែលបង្អោនចូលទៅដើម្បីបូជាព្រះស្តូប ដោយពាក្យថា **តំ ចាហំ បកតំ មយា** នេះ ប្រេតដល់នូវការក្តៅក្រហាយ ពោលថា សេចក្តីអាក្រក់ក្នុងការតិះដៀលព្រះធាតុនោះ ខ្ញុំបានធ្វើ គឺប្រព្រឹត្តនិច្ច ។

បទថា **ឆឡាសីតិសហស្សានិ** បានដល់ ប្រមាណ ៨៦០០០ នាក់ ។

ប្រេតពោលសរុបប្រេតទាំងនោះជាមួយខ្លួនថា **មយំ** ប្រែថា ពួកយើង ។ បទថា **បច្ចត្តវេទនា** បានដល់ ទុក្ខវេទនាដែលកំពុងគ្របសង្កត់ជាផ្នែកៗ ។ ដោយបទថា **និរយេ** ប្រេតពោលបេតវិស័យឲ្យដូចគ្នានឹងនរក ព្រោះមានទុក្ខច្រើន ។

បទថា **យេ ច ខោ ថូបបូជាយ វត្តន្តេ អរហតោ មហោ** សេចក្ដីថា ប្រេតប្រកាសភាពដែលខ្លួនជាអ្នកដល់នូវសេចក្ដីវិនាសធំ ដោយសម្ដែងអានអ្នកដទៃថា កាលការបូជា និងកាលឆ្លងឧទ្ទិសចំពោះស្តូបរបស់ព្រះអរហន្តសម្មាសម្ពុទ្ធកំពុងប្រព្រឹត្តទៅ ជនពួកណា ប្រកាសអាទីនវ គឺទោសក្នុងការបូជាព្រះស្តូបដូចខ្ញុំ ។ ការប្រកាសនោះ គប្បីអូសទាញបុគ្គលទាំងនោះ គឺគប្បីធ្វើបុគ្គលទាំងនោះឲ្យសាបសូន្យចាកបុណ្យនោះ បានដល់គប្បីធ្វើបុគ្គលទាំងនោះឲ្យកើតខាងក្រៅ ( កើតក្នុងបិត្តិវិស័យ ) ។ បទថា **អាយន្តិយោ** បានដល់ ដែលមកតាមអាកាស ។ បទថា **មាលាវិបាកំ** បានដល់ វិបាកគឺផលនៃការបូជាដោយផ្កាដែលធ្វើទុកក្នុងព្រះស្តូប ។ បទថា **សមិទ្ធា** បានដល់ សម្រេចដោយទិព្វសម្បត្តិ ។ បទថា **តា យសស្សិនិយោ** បានដល់ស្រីទាំងនោះមានបរិវារ ។

បទថា **តញ្ច ទិស្វាន** សេចក្ដីថា ឃើញផលវិសេសដ៏ឧឡារក្រៃលែងដែលគួរអស្ចារ្យមិនធ្លាប់មាន ឲ្យកើតការព្រឺរោមព្រឺស្បែក របស់បុណ្យដែលកើតអំពីការបូជាដ៏តិចតួចនោះ ។ បទថា **ឆមោ ករោន្តិ សប្បញ្ញា វន្ទន្តិ តំ មហាមុនឹ** សេចក្ដីថា បពិត្រលោកម្ចាស់កស្សបៈដ៏ចម្រើន ស្រីទាំងនេះរមែងថ្វាយបង្គំ រមែងអភិវាទបុគ្គលដែលជាបុញ្ញក្ខេត្តដ៏ឧត្តម អធិប្បាយថា ធ្វើការ

ថ្វាយបង្គំនិងនមស្ការលោកម្ចាស់ ។

លំដាប់នោះ ប្រេតនោះមានចិត្តសង្វេគ កាលសម្តែងកម្មដែលខ្លួនគប្បីធ្វើតទៅដែលគួរដល់ការសង្វេគ ទើបពោលគាថាថា **សោហំ នូន** ដូច្នេះ ជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

ព្រះមហាកស្សបៈ ដែលប្រេតពោលយ៉ាងនេះ ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។

អដ្ឋកថាធាតុវិវណ្ណប្រេតចប់

ចូឡវគ្គទី ៣ ប្រដាប់ដោយរឿង ១០

ក្នុងបេតវត្ថុនៃអដ្ឋកថាខុទ្ទកនិកាយចប់

# មហាវគ្គ ទី៤

## រឿង អម្ពសក្ខរប្រេត ទី១

[ ៣៦ ] *( ព្រះសង្គីតិកាចារ្យពោលថា ) មាននគរ ១ ឈ្មោះវេសាលី របស់អ្នកដែនវជ្ជី ក្នុងក្រុងវេសាលីនោះ មានស្តេចលិច្ឆវី ព្រះនាមអម្ពសក្ខរៈ បានទតឃើញប្រេតនៅខាងក្រៅក្រុង ស្តេចមានព្រះហឫទ័យចង់ដឹងហេតុ បានត្រាស់សួរប្រេតនោះក្នុងទីនោះឯងថា បុគ្គល ( ដែលគេចាក់ស្នួយឡើងលើដែកអណ្តោត ) នេះ ដេកឬអង្គុយ ក៏មិនបាន ការឈានទៅមុខនិងការឈានថយក្រោយ ក៏មិនបាន ការស៊ីផឹក លិទ្ធភក្ស សំពត់ ភោគៈទាំងស្រីជាអ្នកបម្រើរបស់បុគ្គលនេះ ក៏មិនមានទៀត ។ ពួកជនណា ដែលជាញាតិសំឡាញ់ដែលឃើញហើយ ឮហើយ ជាអ្នកមានចិត្តល្អ អនុគ្រោះនៃបុគ្គលណា ដែលមានក្នុងកាលពីដើម ឥឡូវនេះ ពួកញាតិជាដើមនោះ ក៏មិនបានឃើញបុគ្គលនោះដែរ ព្រោះខ្លួនឃ្លាតឆ្ងាយពីបុគ្គលនោះ បុគ្គលទុរគតរមែងមិនមានពួកមិត្ត ពួកមិត្តតែងលះបង់ចោល ព្រោះដឹងថាខ្វះខាត ពួកមិត្តរមែងចោមរោម ព្រោះឃើញប្រយោជន៍ ឯបុគ្គលខ្ពង់ខ្ពស់ ( ដោយភោគសម្បត្តិ ) តែងមានមិត្តច្រើន ។ បុគ្គលសាបសូន្យចាកប្រយោជន៍ លំបាកដោយភោគៈទាំងអស់ មានខ្លួនប្រឡាក់ដោយឈាម មានខ្លួនធ្លុះធ្លាយ រលត់ជីវិតទៅ ក្នុងថ្ងៃនេះ ឬថ្ងៃស្អែក ដូចតំណក់ទឹកសន្សើម ( ដែលជាប់នៅលើចុងស្មៅ ) ។ សរីរៈប្រាកដដូច្នេះ ដល់នូវសេចក្តីលំបាកដ៏ក្រៃលែង គេដោតស្នួយឡើងលើឈើអណ្តោត ដែលគេធ្វើដោយមែកស្តៅ កាលបើយ៉ាងហ្នឹងហើយ ម្នាលយក្ស ចុះហេតុអ្វីបានជាអ្នកពោលថា នៃអ្នកដ៏ចម្រើន អ្នក*

ចូររស់នៅចុះ ( ព្រោះ ) ការរស់នៅជាការប្រសើរ ។

( ប្រេតឆ្លើយថា ) បុរសនុ៎ះ ( កាលពីជាតិមុន ) ជាសាលោហិតរបស់ខ្ញុំ ខ្ញុំរឭកឃើញជាតិក្នុងកាលមុន បពិត្រព្រះរាជា លុះខ្ញុំឃើញហើយក៏មានសេចក្តីករុណាដូច្នេះថា បុរសមានធម៌ដ៏លាមកនេះ កុំធ្លាក់ចុះក្នុងនរកឡើយ ។ បពិត្រលិច្ឆវិរាជ បុរសនោះជាអ្នកធ្វើអំពើអាក្រក់ កាលច្យុតចាកអត្តភាពនេះហើយ នឹងកើតក្នុងនរកដែលសម្បូរដោយសត្វមានសភាពគួរឲ្យស្អប់ មានកម្តៅភ្លើងដ៏ខ្លាំង មានទុក្ខក្តៅផ្សា ជាគ្រឿងធ្វើភ័យឲ្យកើត ។ ដែកអណ្តាតនេះឯង ប្រសើរជាងនរកនោះ ដោយគុណមានចំណែកដ៏ច្រើន បុរសនេះ កុំធ្លាក់ក្នុងនរក មានទុក្ខតែម្យ៉ាង មានទុក្ខដ៏ក្តៅផ្សា ជាគ្រឿងធ្វើភ័យឲ្យកើត មានទុក្ខដ៏ក្លៀវក្លាតែម្យ៉ាង បុរសអ្នកដល់នូវសេចក្តីទុក្ខនោះស្តាប់ពាក្យខ្ញុំនេះបានហើយ គប្បីវៀរបង់នូវអំពើលាមកចេញ ហេតុដូច្នោះ បានជាខ្ញុំមិននិយាយក្នុងសម្នាក់នៃ ( បុគ្គលនេះ ) ថា ការរលត់ទៅនៃជីវិត នេះចូរកុំមានដល់ខ្ញុំ ក្នុងទីជាមួយគ្នាឡើយ ។

( ព្រះបាទលិច្ឆវីសួរថា ) ប្រយោជន៍របស់បុរសនេះ ខ្ញុំដឹងហើយ យើងចង់សួរប្រយោជន៍ដទៃទៀតចំពោះអ្នក បើអ្នកមិនបើកឱកាសឲ្យយើងទេយើងក៏មិនហ៊ានសួរអ្នកដែរ អ្នកកុំគប្បីខឹងនឹងយើង ។

( ប្រេតតបថា ) សេចក្តីប្តេជ្ញារបស់យើង មានហើយក្នុងកាលនោះ ដោយពិតថា មិនប្រាប់ដល់បុគ្គលដែលមិនជ្រះថ្លា ( នឹងគ្នា ) អ្នកចូរធ្វើទុកក្នុងចិត្តថា យើងមិនចង់ប្រាប់ទេ តែជាមនុស្សមានពាក្យគួរជឿបាន ដូច្នេះ

ហើយសួរខ្ញុំចុះ តាមសេចក្តីពិតដែលអាច ( នឹងប្រាប់បាន ) ។

( ស្តេចលិច្ឆវីត្រាស់ថា ) យើងឃើញនូវហេតុណាមួយដោយចក្ខុ យើងត្រូវជឿហេតុនោះទាំងអស់ ប្រសិនបើយើងឃើញហើយ យើងមិនជឿហេតុនោះទេ ម្នាលយក្ស អ្នកត្រូវធ្វើនិយស្សកម្ម ( ការបន្ទោយយស ) ដល់យើងចុះ ។

( ប្រេតតបថា ) ពាក្យប្តេជ្ញានុ៎ះ ជាពាក្យប្តេជ្ញាដ៏ពិតរបស់ព្រះអង្គចុះ បើព្រះអង្គត្រូវការចង់ដឹង មានហឫទ័យមិនប្រទូស្ត ស្តាប់ធម៌ណា ជាធម៌ដែលព្រះអង្គធ្លាប់ស្តាប់ហើយក្តី មិនធ្លាប់ស្តាប់ហើយក្តី លុះព្រះអង្គស្តាប់ធម៌នោះហើយ ចូរបាននូវសេចក្តីជ្រះថ្លា កាលបើខ្ញុំដឹងយ៉ាងណា នឹងក្រាបទូលនូវហេតុនោះទាំងអស់ ។

( ស្តេចលិច្ឆវីសួរថា ) អ្នកមានសេះសប្រដាប់ហើយ ហើយចូលទៅក្នុងទីជិតនៃបុរសដែលគេដោតដោយឈើអណ្តោត ឯយានជំនិះនេះ ជារបស់អស្ចារ្យគួរមើលមើល នេះជាផលនៃកម្មអ្វី ។

( ប្រេតតបថា ) មានជង្ហុក ១ ត្រង់ផ្លូវរអិលនៅកណ្តាលក្រុងវេសាលីនោះ ថ្ងៃមួយខ្ញុំមានចិត្តជ្រះថ្លា បានយកក្បាលគោធ្វើជាស្ពាន ដាក់ត្រង់ជង្ហុកនោះ ។ យើងក្តី ពួកមនុស្សឯទៀតៗក្តី បានដាក់ជើង លើស្ពាននោះហើយ ទើបដើរទៅបាន យានជំនិះនេះដ៏អស្ចារ្យ គួរមើលមើល នេះជាផលនៃកម្មនោះឯង ។

( ស្តេចលិច្ឆវីសួរថា ) ចុះអ្នកមានសម្បុរភ្លឺទៅសព្វទិស អ្នកមានក្លិន

ផ្សព្វផ្សាយទៅសព្វទិសបាន អ្នកបានទូវឫទ្ធិជាយក្ស មានអានុភាពច្រើន តែជាអ្នកអាក្រាត នេះជាវិបាកនៃកម្មអ្វី ។

( ប្រេតឆ្លើយថា ) ខ្ញុំជាមនុស្សមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច និយាយទៅនឹងជនដោយពាក្យពីរោះផ្អែមល្ហែម នេះជាផលនៃកម្មនោះឯង បានជាសម្បុររបស់ខ្ញុំភ្លឺជានិច្ចដូចជាទិព្វ ។ ខ្ញុំបានឃើញយសសក្តិ និងកេរ្តិ៍ឈ្មោះរបស់ពួកជនអ្នកតាំងនៅក្នុងធម៌ ក៏មានចិត្តជ្រះថ្លា ហើយប្រឹក្សា នេះជាផលនៃកម្មនោះឯង បានជាខ្ញុំមានក្លិនដូចជាទិព្វផ្សព្វផ្សាយទៅជានិច្ចបាន ។ ខ្ញុំបានយកសំពត់ពួកសំឡាញ់កំពុងងូតទឹកក្នុងកំពង់ លាក់លើគោក ខ្ញុំត្រូវការនឹងសើចលេង មិនមានចិត្តប្រទូស្តទេ ព្រោះតែកម្មនោះ បានជាខ្ញុំអាក្រាត ទាំងការចិញ្ចឹមជីវិតក៏លំបាកពន់ពេក ។

( ស្តេចលិច្ឆវីត្រាស់សួរថា ) បើបុគ្គលណា លេងធ្វើបាប អ្នកប្រាជ្ញទាំងឡាយបានសម្តែង នូវផលនៃកម្មរបស់បុគ្គលនោះ ប្រាកដដូច្នេះ ចុះបើបុគ្គលណា មិនលេងធ្វើបាបទេ អ្នកប្រាជ្ញ ទាំងឡាយ បានសម្តែងនូវផលនៃកម្មនោះដូចម្តេច ។

( ប្រេតតបថា ) បើពួកមនុស្សណា មានតម្រិះក្នុងចិត្តប្រទូស្តហើយសៅហ្មងដោយកាយនឹងវាចា មនុស្សទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក្នុងបរលោក រមែងទៅកើតក្នុងនរកឥតមានសង្ស័យឡើយ ។ ចំណែកពួកមនុស្សដទៃ ប្រាថ្នានូវសុគតិ ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះមនុស្សទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅក្នុងបរលោក រមែងទៅ

កើតក្នុងសុគតិ ឥតមានសង្ស័យឡើយ ។

( ស្ដេចលិច្ឆវីត្រាស់ថា ) យើងបានពិចារណាហើយ គប្បីជឿពាក្យនោះដូចម្ដេច នេះជាផលនៃកល្យាណកម្មនិងបាបកម្មទេតើ យើងឃើញដូចម្ដេចគប្បីជឿ នរណាគប្បីធ្វើខ្ញុំឲ្យជឿពាក្យនោះបាន ។

( ប្រេតតបថា ) ព្រះអង្គទតឃើញហើយ ឮហើយ សូមជឿទៅចុះ នេះជាផលនៃកល្យាណកម្មនិងបាបកម្ម កាលបើកល្យាណកម្មនិងបាបកម្មទាំងពីរមិនមានទេ ពួកសត្វគប្បីមានសុគតិឬទុគ្គតិដូចម្ដេចបាន ។ ប្រសិនបើពួកសត្វមិនគប្បីធ្វើកល្យាណកម្ម និងបាបកម្មក្នុងមនុស្សលោកនេះទេ ពួកសត្វក៏មិនបានសុគតិឬទុគ្គតិ ទាំងមិនបានថោកទាប ឬខ្ពង់ខ្ពស់ក្នុងមនុស្សលោកឡើយ ។ ពួកសត្វធ្វើកល្យាណកម្មនិងបាបកម្មក្នុងមនុស្សលោកនេះ ព្រោះហេតុណា ហេតុនោះ បានជាពួកសត្វទៅសុគតិខ្លះ ទុគ្គតិខ្លះ ថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ ក្នុងមនុស្សលោក ។ ពួកអ្នកប្រាជ្ញបានសម្ដែងនូវផលទាំងពីរនៃកម្មទាំងឡាយដែលជាគ្រឿងសោយនូវសុខនិងទុក្ខ ពួកទេវតាតែងចោមរោមដោយពិត ពួកពាលជាអ្នកមិនបានឃើញនូវផលទាំងពីរហើយរមែងឆេះនៅ ( ក្នុងអបាយទាំងឡាយមាននរកជាដើម ) ។ បុញ្ញកម្មដែលធ្វើដោយខ្លួនឯងមិនមានអ្នកឲ្យគ្រឿងស្លៀកពាក់ ទីដេក ទីអង្គុយ បាយនិងទឹក ហើយឧទ្ទិសចំពោះខ្ញុំក៏មិនមានដែរ ហេតុនោះបានជាខ្ញុំមានកាយអាក្រាត ទាំងការប្រព្រឹត្តចិញ្ចឹមជីវិតក៏លំបាក ។

( ព្រះបាទលិច្ឆវីត្រាស់សួរថា ) ម្នាលយក្ស ហេតុតិចតួចដែលអ្នកគួរ

បានទូវគ្រឿងស្លៀកពាក់ មានដែរឬ អ្នកចូរប្រាប់ដល់យើង ហេតុណាដែលនាំឲ្យយើងជឿបាន យើងនឹងស្តាប់នូវពាក្យតាមហេតុនោះ ។

( ប្រេតតបថា ) ក្នុងក្រុងវេសាលីនេះ មានភិក្ខុ ១ រូប ឈ្មោះកប្បិតកៈ មានឈាន មានសីលធម៌ល្អ ជាព្រះអរហន្ត មានចិត្តផុតស្រឡះចាកអកុសល មានឥន្ទ្រិយស្រគត់ស្រគំ សង្រួមក្នុងបាតិមោក្ខ ត្រជាក់ត្រជំសម្រេចនូវការយល់ដ៏ខ្ពង់ខ្ពស់ មានសំដីទន់ភ្លន់ ដឹងនូវពាក្យពោល មានសំដីផ្អែមល្ហែម និងមានព្រះភក្ត្រផូរផង់ ចេះចាំធម៌អាចដោយប្រពៃ ផុតស្រឡះហើយដោយល្អ ជាបុញ្ញក្ខេត្ត ស្ងប់ស្ងាត់ចាកកិលេស ជាទក្ខិណេយ្យបុគ្គលរបស់ទេវតានិងមនុស្សទាំងឡាយ ជាសប្បុរស ប្រាសចាកផ្សែង គឺវិតក្កៈ វិចារៈ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ផុតស្រឡះចាកភពទាំងពួង មានសរគឺរាគៈទៅប្រាសហើយ មិនមានសេចក្តីសម្គាល់ថាអញ មិនវៀចវេរ មិនមានឧបធិកិលេស អស់ធម៌ជាគ្រឿងយឺតយូរគ្រប់យ៉ាង បានសម្រេចវិជ្ជា ៣ មានសេចក្តីរុងរឿង ។ លោកនោះ មិនល្បីនាមប្រាកដទេ ទុកជាឃើញក៏មិនងាយនឹងស្គាល់ ពួកមនុស្សអ្នកនៅក្នុងដែនវជ្ជី តែងនាំគ្នាហៅថាមុនីដូច្នេះ ទាំងដឹងថា លោកជាបុគ្គលគួរបូជា មិនមានសេចក្តីញាប់ញ័រ គឺកិលេស មានកល្យាណធម៌ ប្រព្រឹត្តនៅក្នុងលោក ។ បើព្រះអង្គឲ្យសំពត់ ១ គូ្ត ២ គូ្ត ដល់ព្រះថេរៈនោះ ឧទ្ទិសដល់ខ្ញុំ ខ្ញុំនឹងគប្បីបានសំពត់ដែលលោកទទួលហើយនោះផង ព្រះអង្គនឹងទតឃើញខ្ញុំដែលស្លៀកសំពត់ហើយផង ។

( ព្រះបាទលិច្ឆវីត្រាស់សួរថា ) ឥឡូវនេះ យើងនឹងទៅជួបព្រះសមណៈនៅក្នុងប្រទេសណា សមណៈនោះគប្បីបន្ទោបង់នូវសេចក្ដីសង្ស័យផង នូវសេចក្ដីងឿងឆ្ងល់ផង នូវសេចក្ដីយល់ខុស ដែលជាសត្រូវរបស់យើងផង ក្នុងថ្ងៃនេះបានឬទេ ។

ប្រេតតបថា សមណៈនុ៎ះគង់នៅឯប្រទេសឈ្មោះ កបិនច្ចនា មានពួកទេវតាច្រើនចោមរោម លោកមាននាមថា សច្ចៈ ជាអ្នកមិនប្រមាទក្នុងធម៌ជាគ្រឿងអស្ចារ្យរបស់ខ្លួន សម្ដែងធម្មិកថា ។

( ព្រះបាទលិច្ឆវីត្រាស់សួរថា ) បើដូច្នោះ ឥឡូវនេះ យើងនឹងទៅធ្វើឲ្យសមណៈស្លៀកដណ្ដប់ ដោយគូសំពត់ អ្នកចូរមើលសំពត់ទាំងនោះ ដែលលោកបានទទួលហើយ ឯយើងគប្បីមើលនូវអ្នកស្លៀកសំពត់ ។

( ប្រេតតបថា ) ព្រះអង្គកុំចូលទៅរកបព្វជិត ក្នុងកាលមិនគួរឡើយ ខ្ញុំសូមអង្វរ ធម៌នោះមិនមែនជាធម៌របស់ព្រះអង្គជាស្ដេចលិច្ឆវីទេ ខ្ញុំចូលទៅក្នុងកាលគួរនោះ ទើបឃើញលោកគង់នៅក្នុងទីស្ងាត់នោះឯង ។

ស្ដេចលិច្ឆវីនោះ ពោលពាក្យដូច្នោះហើយ ក៏មានពួកទាសៈចោមរោមយាងចូលទៅក្នុងទីនោះ លុះចូលទៅក្រុងនោះហើយ ទ្រង់យាងចូលទៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គវិញ ។ លំដាប់នោះ ស្ដេចលិច្ឆវីធ្វើនូវកិច្ចទាំងឡាយជារបស់គ្រហស្ថ ក្នុងវេលាព្រឹកហើយ ក៏ស្រង់ផង សោយនូវសុគន្ធរសផង រួចបាននូវឱកាស ក៏ជ្រើសរើសនូវសំពត់បាន ៨ គូ អំពីហិប ហើយក៏ឲ្យពួកទាសៈកាន់យកតាមទៅ ។ ស្ដេចលិច្ឆវីនោះ ចូលទៅឯប្រទេសនោះ

បានឃើញសមណៈនោះ អ្នកមានចិត្តស្ងប់រម្ងាប់ កំពុងវិលត្រឡប់ពីគោចរ ជាបុគ្គលត្រជាក់ត្រជំ គង់នៅក្រោមម្លប់ឈើ ។ លុះស្តេចលិច្ឆវីចូលទៅដល់ហើយ ក៏ពោលទៅនឹងសមណៈនោះ រួចហើយក៏សួរនូវការមិនមានអាពាធ នឹងការនៅជាសុខសប្បាយ ( ហើយទូល ) ថា បពិត្រលោកដ៏ចម្រើន ខ្ញុំជាស្តេចលិច្ឆវីក្នុងក្រុងវេសាលី អ្នកផងតែងស្គាល់ខ្ញុំថា ជាស្តេចលិច្ឆវី ឈ្មោះអម្ពសក្ខរៈ ។ បពិត្រលោកដ៏ចម្រើន សូមលោកទទួលសំពត់ទាំង ៨ គូរបស់ខ្ញុំនេះចុះ បពិត្រលោកដ៏ចម្រើន ខ្ញុំសូមប្រគេនដល់លោក ខ្ញុំមកក្នុងទីនេះ ព្រោះប្រយោជន៍នោះឯង គួរឲ្យខ្ញុំមានចិត្តត្រេកអរ ។

( ព្រះថេរៈតបថា ) ពួកសមណព្រាហ្មណ៍ ដែលមកអំពីទីឆ្ងាយ តែងតែចៀសវាងនូវនិវេសន៍របស់ព្រះអង្គ បាត្រទាំងឡាយតែងធ្លាក់បែក សង្ឃាដិទាំងឡាយតែងតែរហែកដាច់ដាចក្នុងនិវេសន៍របស់ព្រះអង្គ ។ ម្យ៉ាងទៀត ពួកសមណៈដទៃ មានក្បាលសំយុងចុះ រមែងធ្លាក់ចុះ ដោយជើងទាំងឡាយពោលគឺជើង ( របស់ព្រះអង្គ ) កាលបើព្រះអង្គ បៀតបៀននូវបព្វជិតប្រាកដដូច្នោះហើយ ពួកសមណៈរមែងដល់នូវអំពើដែលព្រះអង្គធ្វើ ។ ព្រះអង្គមិនដែលឲ្យប្រេងសូម្បីដោយចុងស្បូវផង មិនប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវផង ព្រះអង្គសមាទានកាន់យកតែអាជ្ញារបស់មនុស្សអន្ធពាលដោយព្រះអង្គឯង បុគ្គលបែបហ្នឹងឈ្មោះថាកំណាញ់ស្វិតស្វាញ ជាអ្នកមិនសង្រួម ។ កាលបើយ៉ាងហ្នឹង តើព្រះអង្គឃើញនូវហេតុអ្វីតាមដោយហេតុអ្វី បានជាព្រះអង្គធ្វើនូវការចែករំលែកជាមួយនឹងអាត្មាភាព ។

( ស្តេចត្រាស់ថា ) បពិត្រលោកដ៏ចម្រើន លោកពោលពាក្យណា ខ្ញុំក៏ទទួលស្តាប់នូវពាក្យនោះ ។

( ព្រះថេរៈតបថា ) ព្រះអង្គធ្វើពួកសមណព្រាហ្មណ៍ឲ្យវង្វេងហើយ ។

( ស្តេចត្រាស់ថា ) បពិត្រលោកដ៏ចម្រើន ខ្ញុំជាបុគ្គលត្រូវការនឹងលេង មិនមានចិត្តប្រទូស្តឡើយ ខ្ញុំធ្វើអំពើអាក្រក់នេះមែនហើយ បុគ្គលក្មេងក្តី កំលោះក្តី ដែលមានទ្រព្យតិច តែងទទួលទុក្ខព្រោះតែសទ្បំបាបដោយការលេង ជាបុគ្គលមានចំណែកនៃភាពជាអ្នកអាក្រាត អ្វីដែលដល់នូវទុក្ខយ៉ាងធ្ងន់ជាងភាពអាក្រាតនោះ របស់ប្រេតនោះ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំឃើញប្រេតនោះ គួរឲ្យកើតសង្វេគទើបឲ្យទាន ព្រោះសង្វេគនោះជាបច្ច័យ បពិត្រលោកដ៏ចម្រើន សូមលោកទទួលសំពត់ទាំង ៨ គូចុះ ទក្ខិណាទាន(ដែលខ្ញុំប្រគេនហើយ ) នេះ សូមឲ្យបានស្រេចដល់យក្សចុះ ។

( ព្រះថេរៈតបថា ) ការមិនចេះអស់ ចូរមានដល់ព្រះអង្គ កាលឲ្យទាន ដែលអ្នកប្រាជ្ញមានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ ដោយប្រការដ៏ច្រើន ដោយពិត ឯអាត្មានឹងទទួលសំពត់របស់ព្រះអង្គទាំង ៨ គូ សូមទក្ខិណាទាន សម្រេចដល់យក្សចុះ ។

លំដាប់នោះឯង ស្តេចលិច្ឆវីនោះ ក៏ជម្រះសម្អាត ហើយប្រគេនសំពត់ ៨ គូដល់ព្រះថេរៈ ព្រះថេរៈបានទទួលសំពត់ ៨ គូនោះហើយ ស្តេចលិច្ឆវី បានឃើញនូវយក្សស្លៀកដណ្តប់សំពត់ ។ ស្តេចលិច្ឆវី បានទតឃើញប្រេតនោះ មានខ្លួនប្រោះព្រំដោយខ្លឹមចន្ទន៍ ហើយឡើងជិះសេះអាជានេយ្យមានរូប

ដ៏ប្រសើរ មានគ្រឿងប្រដាប់គ្រប់គ្រាន់ មានសំពត់ស្លៀកដណ្ដប់ដ៏ស្អាតមានបរិស័ទចោមរោម ដល់នូវឫទ្ធិជាយក្សយ៉ាងធំ ។ លុះស្ដេចលិច្ឆវីនោះទតឃើញប្រេតនោះហើយ ក៏មានព្រះហឫទ័យសោមនស្ស ខ្ពស់អណ្ដែតឡើងមានព្រះហឫទ័យត្រេកអរ មានសភាពដ៏ប្រសើរល្អ មានចក្ខុ ព្រោះបានឃើញនូវកម្មមានផលដ៏ធំផង ធ្វើឲ្យជាក់ច្បាស់នូវប្រេតដែលខ្លួនបានឃើញដោយខ្លួនឯង ។ ស្ដេចលិច្ឆវីបានចូលទៅរកប្រេតនោះ ហើយមានព្រះបន្ទូលថា យើងនឹងឲ្យទាន ដល់ពួកសមណព្រាហ្មណ៍ ឯវត្ថុបន្ទិចបន្តួចដែលយើងមិនត្រូវឲ្យមិនមានទេ ម្នាលយក្ស អ្នកមានឧបការៈដល់យើងច្រើនណាស់ ។

( ប្រេតតបថា ) បពិត្រស្ដេចលិច្ឆវី ព្រះអង្គបានឲ្យទានទាំងឡាយចំពោះតែបច្ច័យមួយ ការឲ្យទាននេះ មិនមែនសោះសូន្យឡើយ ខ្ញុំជាអមនុស្សធ្វើជាសាក្សីជាមួយព្រះអង្គជាមនុស្ស ។

( ស្ដេចលិច្ឆវីតបថា ) អ្នកជាគតិ ជាផៅពង្ស ជាការនាំមុខនិងជាមិត្តសំឡាញ់ និងជាទេវតារបស់យើង យើងសូមប្រណម្យអញ្ជលីចំពោះអ្នក ម្នាលយក្ស យើងចង់ឃើញអ្នកម្ដងទៀត ។

( ប្រេតតបថា ) បើព្រះអង្គជាអ្នកមិនមានសទ្ធា ជាបុគ្គលកំណាញ់ មានចិត្តវិបត្តិហើយ ព្រះអង្គបានឃើញខ្ញុំដោយហេតុនោះឯង ទុកជាខ្ញុំឃើញ ក៏មិននិយាយរកចំពោះព្រះអង្គដែរ ។ បើព្រះអង្គជាអ្នកគោរពក្នុងធម៌ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះ ជាអណ្ដូងរបស់ពួកសមណព្រាហ្មណ៍យ៉ាងនេះ ទើបព្រះអង្គអាចឃើញខ្ញុំបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំឃើញ

ហើយនិយាយចំពោះព្រះអង្គថា ព្រះអង្គចូរដោះបុរសនេះ អំពីឈើអណ្តោត ឲ្យធាប់ទៅ យើងបានធ្វើជាសាក្សី ព្រោះហេតុតែបុរសណា យើងរមែងដឹង ព្រោះហេតុតែបុរស ដែលគេដោតដោយឈើអណ្តោត យើងទាំងនោះបានធ្វើ ជាសាក្សីដល់គ្នានឹងគ្នា ។ បើបុរសដែលដោតលើឈើអណ្តោតនេះ បានរួច ធាប់ គប្បីប្រព្រឹត្តធម៌ដោយគោរព ទើបបុរសនោះ រួចអំពីនរកនោះបាន កម្ម នោះនឹងទៅជាកម្មដែលបុរសនោះគប្បីទទួលក្នុងភពដទៃ ។ សូមព្រះអង្គស្តេច ចូលទៅរកកប្បិតកភិក្ខុ ហើយចាត់ចែងភោជនាហារ ក្នុងកាលដ៏គួរជាមួយនឹង លោក ហើយអង្គុយចំពោះមុខលោក ដោយព្រះអង្គឯង ហើយចូរសួរលោក ចុះ លោកគង់ប្រាប់សេចក្តីនេះដល់ព្រះអង្គ ។ សូមព្រះអង្គចូលទៅរកភិក្ខុនោះ ហើយសួរចុះ ព្រោះភិក្ខុនោះត្រូវការបុណ្យ មិនមានចិត្តប្រទូស្តទេ ភិក្ខុនោះដឹង យ៉ាងណា ក៏នឹងប្រាប់នូវធម៌ទាំងអស់យ៉ាងនោះ ដែលព្រះអង្គស្តាប់ហើយក្តី មិនដែលស្តាប់ហើយក្តី កាលបើព្រះអង្គស្តាប់ លោកនឹងសម្តែងប្រាប់នូវធម៌ ផង នូវសុគតិផង ។

ស្តេចលិច្ឆវីនោះ ចរចានឹងគ្នាក្នុងទីស្ងាត់ ក្នុងទីនោះ ហើយធ្វើឲ្យជាសាក្សី ជាមួយនឹងអមនុស្ស ហើយចៀសចេញទៅកាន់សំណាក់នៃស្តេចលិច្ឆវីទាំង-ឡាយ លំដាប់នោះ ស្តេចបានពោលចំពោះបរិសទ្យដែលមកប្រជុំគ្នា ។

( ស្តេចលិច្ឆវីត្រាស់ថា ) អ្នកដ៏ចម្រើនទាំងឡាយ ចូរស្តាប់ពាក្យយើង មួយម៉ាត់ យើងនឹងបាននូវពរ យើងនឹងបាននូវប្រយោជន៍ បុរសដែលត្រូវ គេដោតដោយឈើអណ្តោត ជាអ្នកមានកម្មអាក្រក់ មានអាជ្ញាតាំងទុកហើយ

មានសភាពជាមនុស្សជាប់ដោយអាជ្ញា ។ បុរសដែលត្រូវឈើអណ្តោតដោត ហើយ មិនរស់មិនស្លាប់ អស់ ២០ រាត្រីប៉ុណ្ណោះ ឥឡូវនេះ យើងនឹងដោះ បុរសនោះ សូមសង្ឃយល់តាមសេចក្តីគាប់ចិត្ត ( របស់យើង ) ចុះ ។

( ប្រេតតបថា ) សូមព្រះអង្គដោះលែងបុរសដែលជាប់ដោយឈើ អណ្តោតនោះផង បុរសដទៃផងឲ្យឆាប់ទៅ នរណាពោលនឹងព្រះអង្គដែល កំពុងធ្វើដូច្នោះ ព្រះអង្គយល់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ ឥឡូវសង្ឃយល់ តាមសព្វព្រះទ័យហើយ ។

ស្តេចនោះបានចូលទៅប្រទេសនោះ ហើយបានដោះលែងបុរសដែលគេ ដោតដោយឈើអណ្តោតមួយរំពេច ហើយប្រាប់ទៅបុរសនោះថា នែសំឡាញ់ មានធុរៈស្មើ ចូរអ្នកកុំភ័យឡើយ ហើយក៏ប្រគល់ឲ្យទៅពួកពេទ្យអ្នកថែរក្សា ។ ទើបស្តេចលិច្ឆវីយាងចូលទៅរកកប្បិតកភិក្ខុហើយ ចាត់ចែងភោជនាហារក្នុង កាលដ៏គួរ មួយអន្លើនឹងកប្បិតកភិក្ខុនោះ ស្តេចលិច្ឆវីអ្នកត្រូវការដោយហេតុ ទើបចូលទៅគង់ជិតហើយ សួរកប្បិតកភិក្ខុនោះដែលអង្គុយនៅទីនោះ ដោយ ព្រះឱស្ឋព្រះអង្គឯងថា បុរសដែលគេដោតដោយឈើអណ្តោត ( ហ្នឹង ) ជាអ្នកធ្វើកម្មអាក្រក់ ត្រូវគេដាក់អាជ្ញាហើយ មានសភាពជាអ្នកជាប់ដោយ អាជ្ញា បុរសដែលត្រូវឈើអណ្តោតដោតហើយ មិនរស់មិនស្លាប់អស់ ២០ រាត្រីប៉ុណ្ណោះ ។ បពិត្រលោកដ៏ចម្រើន ឥឡូវនេះ បុរសនោះ ខ្ញុំបានដោះ លែងតាមពាក្យយក្សនុ៎ះហើយ ហេតុតិចតួចដែលបុរសនោះ មិនគប្បីទៅនរក មានដែរឬ ។ បពិត្រលោកដ៏ចម្រើន បើមានហេតុ គឺហេតុដែលគួរជឿបាន

សូមលោកប្រាប់ដល់យើង យើងស្តាប់ហើយ យើង ( នឹងជឿតាមពាក្យរបស់លោក ) ការវិនាសនៃកម្មទាំងនោះ ក៏មិនមាន សេចក្តីវិនាសរបស់បុរសនោះ ក៏មិនមានក្នុងទីនេះ ព្រោះមិនបានទទួលនូវផល ។ បើបុរសនោះគប្បីប្រព្រឹត្តនូវធម៌ទាំងឡាយ មិនប្រមាទទាំងយប់ទាំងថ្ងៃដោយគោរព ទើបបុរសនោះគប្បីរួចចាកនរកនោះបាន កម្មនោះនឹងជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។ ប្រយោជន៍របស់បុរសនុ៎ះ ខ្ញុំបានដឹងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អនុគ្រោះខ្ញុំ ក្នុងកាលឥឡូវនេះ បពិត្រលោកមានប្រាជ្ញាដ៏ក្រាស់ សូមលោកម្ចាស់ ទូន្មានប្រៀនប្រដៅខ្ញុំ គួរកុំឲ្យខ្ញុំទៅនរកបាន ។

( ព្រះថេរៈតបថា ) ព្រះអង្គមានព្រះហឫទ័យជ្រះថ្លា ចូរដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ ក្នុងថ្ងៃនេះឯង មួយទៀត ព្រះអង្គចូរសមាទាននូវសិក្ខាបទទាំង ៥ កុំឲ្យដាច់ធ្លុះធ្លាយឡើយ ។ ចូរព្រះអង្គវៀរចាក បាណាតិបាតឲ្យឆាប់ ចូរវៀរចាកទ្រព្យដែលគេមិនឲ្យក្នុងលោកចេញ កុំសោយនូវទឹកស្រវឹងផង កុំកុហកផង ចូរត្រេកអរតែនឹងមហេសីរបស់ព្រះអង្គផង ។ សូមព្រះអង្គ សមាទាននូវឧបោសថសីលដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះជាកុសល ឲ្យផលជាសុខចុះ ។

សូមព្រះអង្គប្រទាននូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ បាយនឹងទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះពួកបុគ្គលអ្នកមានចិត្តត្រង់ បុណ្យរមែងចម្រើនសព្វៗកាល មួយទៀត សូមព្រះអង្គញុំាងពួកភិក្ខុអ្នកបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សុត ឲ្យឆ្អែតដោយ

បាយនិងទឹក បុណ្យរមែងចម្រើនសព្វៗកាល ។ កាលបើបុរសនោះប្រព្រឹត្ត នូវធម៌ទាំងឡាយ មិនប្រមាទទាំងយប់ទាំងថ្ងៃ ដោយគោរពយ៉ាងនេះហើយ ទើបរួចចាកនរកបាន កម្មនោះនឹងទៅជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។

( ស្តេចលិច្ឆវីមានព្រះឱង្ការថា ) ខ្ញុំមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ ក្នុងថ្ងៃនេះឯង មួយទៀត ខ្ញុំសមាទាននូវសិក្ខាបទទាំង ៥ មិនឲ្យដាច់ធ្លុះធ្លាយ ខ្ញុំវៀរចាកបាណាតិបាត យ៉ាងឆាប់ ខ្ញុំវៀរចាកអទិន្នាទានក្នុងលោក ខ្ញុំមិនផឹកទឹកស្រវឹង មិននិយាយពាក្យមុសា ខ្ញុំត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន ។ ខ្ញុំសមាទាននូវឧបោសថសីលដ៏ឧត្តម ប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ នេះជាកុសល ឲ្យផលជាសុខ ។

ខ្ញុំឲ្យនូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ ទីដេក ទីអង្គុយ បាយ ទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះពួកភិក្ខុអ្នកបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ខ្ញុំជាអ្នកត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយ មិនកម្រើកឡើយ ។

( បណ្តាពួកឧបាសក ) ក្នុងក្រុងវេសាលី ស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ ជាឧបាសកម្នាក់ ប្រាកដដូច្នោះ ក្នុងក្រុងវេសាលី ជាអ្នកមានសទ្ធាផង មានចិត្តទន់ភ្លន់ផង ជាអ្នកធ្វើនូវឧបការៈ ទំនុកបម្រុង ភិក្ខុសង្ឃដោយគោរព ក្នុងកាលនោះផង ។ បុរសដែលត្រូវគេដោតដោយឈើអណ្តោត ឥតមានរោគ មានតែសិរីនឹងសុខ បានចូលទៅកាន់ផ្នួស ជនទាំង ២ នាក់ ក៏បានសម្រេចនូវសាមញ្ញផលទាំងឡាយ ( តាមសមគួរ ) ព្រោះអាស្រ័យនឹងព្រះថេរៈ

ឈ្មោះកប្បិតកៈដ៏ឧត្តម ។ ការសេពគប់នឹងពួកសប្បុរស អ្នកស្ងប់ អ្នកដឹង ដូច្នេះ រមែងមានផលច្រើន បុរសដែលដេកលើឈើអណ្ដែត បានសម្រេចនូវផលដ៏ប្រសើរ ឯស្ដេចលិច្ឆវីអម្ពសក្ខរៈ បានសម្រេចផលតូច ( សោតាបត្តិផល ) ។

**ចប់ រឿងអម្ពសក្ខរប្រេតទី ១ ។**

# មហាវគ្គទី៤

## អដ្ឋកថា អម្ពសក្ខរប្រេត

[ ៣៦ ] រឿងអម្ពសក្ខរប្រេតនេះ មានពាក្យផ្ដើមថា **វេសាលី នាម នគរត្ថិ វជ្ជីនំ** ដូច្នេះជាដើម ។

រឿងនោះកើតឡើងដូចម្ដេច កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពនមហាវិហារ ស្ដេចលិច្ឆវីព្រះនាមថា អម្ពសក្ខរៈ ជាមិច្ឆាទិដ្ឋិបុគ្គល ជានត្ថិកវាទ គ្រងរាជសម្បត្តិក្នុងនគរវេសាលី ។

សម័យនោះ ក្នុងព្រះនគរវេសាលី មានភក់ត្រង់ក្បែរផ្សាររបស់ឈ្មួញម្នាក់ ។ ជនជាច្រើនទៅក្នុងទីនោះ លោតឆ្លងទៅបានដោយលំបាក អ្នកខ្លះប្រឡាក់ភក់ ។ ឈ្មួញនោះឃើញដូច្នោះ គិតថា ជនទាំងនេះកុំបីជាន់ភក់ ទើបយកឆ្អឹងក្បាលគោ ដែលមានចំណែកប្រៀបដូចពណ៌នៃស័ង្ខ ប្រាសចាកក្លិនស្អុយមកដាក់ត្រង់ភក់ ជាប្រក្រតីបុរសនោះជាអ្នកមានសីល មិនក្រោធ មាន

វាចាពីរោះ ប្រកាសគុណរបស់បុគ្គលដទៃតាមសេចក្តីពិត ។

ថ្ងៃមួយ កាលសម្លាញ់របស់ខ្លួនងូតទឹក មិនក្រឡេកមើល ដោយការប្រហែសធ្វេស ទើបលាក់សំពត់ ដោយបំណងនឹងសើចលេង ធ្វើឲ្យបុរសនោះលំបាក ទើបឲ្យទៅវិញ ។ ក្មួយរបស់បុរសនោះ ជាចោរលួចទ្រព្យមកអំពីផ្ទះអ្នកដទៃ មកទម្លាក់ត្រង់រានរបស់បុរសនោះឯង ។ ម្ចាស់កណ្ឌៈ កាលពិនិត្យមើល ទើបបង្ហាញក្មួយរបស់បុរសនោះមួយអន្លើដោយកស្តុតាង ដល់ព្រះរាជា ព្រះរាជាបញ្ជាថា ចូរកាត់ក្បាលបុរសនេះ ឯក្មួយរបស់គេ ចូរដោតដោយឈើអណ្តោត ។ ពួករាជបុរសបានធ្វើដូច្នោះ បុរសនោះ ធ្វើកាលកិរិយាហើយ កើតក្នុងកុម្ភទេវតា មានសេះអាជានេយ្យទិព្វ មានពណ៌ស មានសម្ពុះស្មើចិត្ត ព្រោះយកក្បាលគោធ្វើស្ពាននិងព្រោះការពោលសរសើរគុណរបស់បុគ្គលមានគុណ ក្លិនទិព្វផ្សាយចេញអំពីកាយរបស់បុរសនោះ តែបុរសនោះ បានជាអ្នកអាក្រាតកាយ ព្រោះលួចសាដកលាក់ទុក ។ កុម្ភទេវតានោះពិចារណាកម្មដែលខ្លួនធ្វើក្នុងកាលមុន ឃើញក្មួយរបស់ខ្លួន ត្រូវដោតដោយទំនងនោះ ត្រូវសេចក្តីករុណាជាស់តឿន ទើបឡើងសេះមនោមយៈ ក្នុងកាលរាត្រី មកកាន់ទីដែលក្មួយនោះដោតដោយឈើអណ្តោត ទើបឈរក្នុងទីមិនឆ្ងាយ ពោលរាល់ថ្ងៃថា នែបា ចូរមានជីវិតនៅចុះ ជីវិតប៉ុណ្ណោះជារបស់ប្រសើរ ។

សម័យនោះ ព្រះបាទអម្ពសក្ខរៈ នៅលើកដំរីដ៏ប្រសើរ ទ្រង់ប្រពាសព្រះនគរ ទ្រង់ឃើញស្រីម្នាក់ដែលបើកបង្អួចក្នុងផ្ទះមួយ កំពុងមើលសម្បត្តិ

របស់ព្រះរាជា ទ្រង់មានចិត្តប្រតិព័ទ្ធ ទើបឲ្យសញ្ញាដល់បុរសដែលអង្គុយខាងក្រោយអាសនៈថា ចូរអ្នកទៅពិចារណាមើលក្នុងផ្ទះនេះ គឺមើលស្រីនេះ ដូច្នេះហើយ យាងចូលព្រះរាជនិវេសន៍របស់ព្រះអង្គដោយលំដាប់ បញ្ជូនបុរសនោះទៅ ដោយឲ្យដឹងថា ស្រីនោះមានប្ដីឬនៅ ។ បុរសនោះទៅ ដឹងថា ស្រីនោះមានប្ដីហើយ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាកាលទ្រង់គិតរកឧបាយគ្រប់គ្រងស្រីនោះ ទើបត្រាស់ឲ្យហៅស្វាមីរបស់នាងមក ហើយត្រាស់ថា មក ចូរឧបដ្ឋាកយើង ។ បុរសនោះ មិនប្រាថ្នា ក៏ទទួលឧបដ្ឋាកព្រះរាជា ព្រោះខ្លាចដោយគិតថា បើអញមិនធ្វើតាមព្រះតម្រាស់របស់ព្រះរាជា ទ្រង់នឹងដាក់រាជទណ្ឌ ទើបទៅឧបដ្ឋាកព្រះរាជារាល់ៗថ្ងៃ ឯព្រះរាជាក៏បានប្រទានរង្វាន់ដល់បុរសនោះ ។ លុះកន្លងទៅ ២-៣ ថ្ងៃ ក៏បានត្រាស់នឹងបុរសដែលមកបម្រើអំពីព្រលឹមថា នែអ្នក ចូរអ្នកទៅចុះ ទីនោះមានស្រះបោក្ខរណីមួយ ចូរនាំដីពណ៌អរុណ និងផ្កាឧប្បលក្រហមមកអំពីស្រះបោក្ខរណីនោះមក បើមិនអាចមកក្នុងថ្ងៃនេះ ជីវិតរបស់អ្នកមិនមាន ។ កាលបុរសនោះចេញទៅហើយ ព្រះរាជាក៏ត្រាស់នឹងអ្នកយាមទ្វារថា ថ្ងៃនេះ កាលព្រះអាទិត្យមិនទាន់លិច ក៏ចូរបិទទ្វារគ្រប់ទិស ។

ស្រះបោក្ខរណីនោះ នៅក្នុងទីបំផុត ៣០០ យោជន៍អំពីក្រុងវេសាលី ។ បុរសនោះត្រូវមរណភ័យគំរាម ទើបដល់ស្រះបោក្ខរណីនោះអំពីព្រលឹមនោះឯង ដោយសម្ទុះរហ័សដូចខ្យល់ ។ ព្រោះបានស្ដាប់មកអំពីមុនថា ស្រះបោក្ខរណីនោះ អមនុស្សហួងហែង ព្រោះការខ្លាច ទើបដើរក្រឡែលជុំវិញ ដោយ

គិតថា ក្នុងទីនេះ មានអន្តរាយណាមួយ ឬមិនមានហ្ន៎ អមនុស្សដែលរក្សាស្រះបោក្ខរណី ឃើញបុរសនោះហើយ កើតសេចក្តីករុណា កាឡាខ្លួនជាមនុស្សចូលទៅរក ហើយពោលថា នែបុរសដ៏ចម្រើន អ្នកមកទីនេះដើម្បីប្រយោជន៍អ្វី បុរសនោះក៏បានតំណាលរឿងនោះ ឲ្យអមនុស្សនោះស្តាប់ទើបអមនុស្សពោលថា បើដូច្នោះ អ្នកចូរកាន់យកតាមត្រូវការចុះ ដូច្នេះហើយ ទើបបង្ហាញរូបទិព្វនៃខ្លួន ហើយអន្តរធានទៅ ។

បុរសនោះកាន់យកដីពណ៌អរុណ និងផ្កាឧប្បលក្រហម ក្នុងស្រះបោក្ខរណីនោះ ដល់ទ្វារនគរក្នុងកាលព្រះអាទិត្យមិនទាន់លិច ។ អ្នកយាមទ្វារឃើញបុរសនោះហើយ កាលបុរសនោះកំពុងប្រាប់នោះឯង ក៏បិទទ្វារ កាលទ្វារបិទ បុរសនោះ ក៏ចូលមិនបាន ឃើញបុរសដែលដេកលើឈើអណ្តោតក្បែរទ្វារ ក៏បានធ្វើឲ្យជាបន្ទាល់ថា មនុស្សទាំងនេះ កាលខ្ញុំមកដល់ក្នុងកាលព្រះអាទិត្យមិនទាន់លិច កំពុងប្រាប់នោះឯង ក៏បិទទ្វារ ចូរអ្នកដឹងចុះថា ខ្ញុំមកទាន់ពេលវេលា ខ្ញុំមិនមានទោសឡើយ ។ បុរសដែលដេកលើឈើអណ្តោតបានស្តាប់ដូច្នោះ ក៏ពោលថា ខ្ញុំត្រូវគេដោតដោយឈើអណ្តោត គេនឹងសម្លាប់ បែរមុខទៅរកសេចក្តីស្លាប់ នឹងធ្វើជាសាក្សីឲ្យអ្នកបានដូចម្តេច តែក្នុងទីនេះប្រេតម្នាក់មានឫទ្ធិច្រើន មកក្បែរខ្ញុំ ចូរអ្នកធ្វើប្រេតនោះឲ្យជាបន្ទាល់ចុះ ។ បុរសនោះសួរថា ខ្ញុំឃើញប្រេតមានឫទ្ធិច្រើននោះបានដូចម្តេច បុរសដែលនៅលើឈើអណ្តោត ពោលថា ចូរអ្នករង់ចាំទីនេះឯង អ្នកនឹងឃើញដោយខ្លួនឯង បុរសនោះឈរក្នុងទីនោះ ឃើញប្រេតនោះមកក្នុងមជ្ឈិមយាម ទើបសូមឲ្យធ្វើជា

សាក្សី ។ លុះរាត្រីអស់ហើយ កាលព្រះរាជាត្រាស់ថា អ្នកកន្ទងអាជ្ញារបស់យើង ព្រោះដូច្នោះ យើងនឹងដាក់រាជទណ្ឌដល់អ្នក បុរសនោះក៏ទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនបានកន្ទងអាជ្ញារបស់ព្រះអង្គទេ ទូលបង្គំមកក្នុងទីនេះ ក្នុងកាលព្រះអាទិត្យមិនទាន់អស្តង្គត ព្រះរាជាត្រាស់សួរថា ក្នុងសេចក្តីនោះ អ្នកណាជាបន្ទាល់ឲ្យអ្នក បុរសនោះ ក៏អាងដល់ប្រេតអាក្រាតដែលមកកាន់សម្នាក់របស់បុរស ដែលដោតដោយឈើអណ្តោតនោះ ថាជាសាក្សី កាលព្រះរាជា ត្រាស់សួរថា សេចក្តីនោះនឹងជឿបានដូចម្តេច ទើបទូលថា ថ្ងៃនេះក្នុងវេលារាត្រី សូមទ្រង់បញ្ជូនបុរសដែលគួរជឿបានទៅជាមួយទូលបង្គំចុះ ។ ព្រះរាជាស្តាប់ដូច្នោះ ក៏យាងទៅក្នុងទីនោះ មួយអន្លើដោយបុរសនោះដោយព្រះអង្គឯង ហើយប្រថាប់ឈរ កាលប្រេតមកក្នុងទីនោះពោលថា ចូររស់នៅចុះអ្នកដ៏ចម្រើន ជីវិតប៉ុណ្ណោះប្រសើរជាង ព្រះរាជាក៏ត្រាស់សួរប្រេតនោះដោយគាថា ៥ ដោយន័យថា **សេយ្យា និសជ្ជា នយិមស្ស អត្ថិ** ដូច្នេះជាដើម ។ តាំងអំពីនេះជាដើមទៅ ដើម្បីសម្តែងសម្ពន្ធនៃគាថាទាំងនោះ ព្រះសង្គីតិកាចារ្យបាន តាំងគាថាថា **វេសាលី នាម នគរត្ថិ វជ្ជីនំ** សេចក្តីថា

មាននគរ ១ ឈ្មោះវេសាលី របស់អ្នកដែនវជ្ជី ក្នុងក្រុងវេសាលីនោះ មានស្តេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ បានទតឃើញប្រេតនៅខាងក្រៅក្រុង ស្តេចមានព្រះហឫទ័យចង់ដឹងហេតុ បានត្រាស់សួរប្រេតនោះក្នុងទីនោះឯងថា បុគ្គល ( ដែលគេចាក់សួយឡើងលើដែកអណ្តោត ) នេះ ដេកឬអង្គុយ ក៏មិន

បាន ការឈានទៅមុខនិងការឈានថយក្រោយ ក៏មិនបាន ការស៊ីផឹក លិទ្ធភក្ស សំពត់ ភោគៈ ទាំងស្រីជាអ្នកបម្រើ របស់បុគ្គលនេះ ក៏មិនមានទៀត ។ ពួកជនណាដែលជាញាតិ សំឡាញ់ដែលឃើញហើយ ឮហើយ ជាអ្នកមានចិត្តល្អ អនុគ្រោះ នៃបុគ្គលណាដែលមានក្នុងកាលពីដើម ឥឡូវនេះ ពួកញាតិជាដើមនោះ ក៏មិនបានឃើញបុគ្គលនោះដែរ ព្រោះខ្លួនឃ្លាតឆ្ងាយពីបុគ្គលនោះ បុគ្គលទុរគត រមែងមិនមានពួកមិត្ត ពួកមិត្តតែងលះបង់ចោល ព្រោះដឹងថាខ្វះខាត ពួកមិត្តរមែងចោមរោម ព្រោះឃើញប្រយោជន៍ ឯបុគ្គលខ្ពង់ខ្ពស់ ( ដោយភោគសម្បត្តិ ) តែងមានមិត្តច្រើន ។ បុគ្គលសាបសូន្យចាកប្រយោជន៍ លំបាកដោយភោគៈទាំងអស់ មានខ្លួនប្រឡាក់ដោយឈាម មានខ្លួន ធុះធ្លាយ រលត់ជីវិតទៅក្នុងថ្ងៃនេះ ឬថ្ងៃស្អែក ដូចតំណក់ទឹកសន្សើម ( ដែលជាប់នៅលើចុងស្មៅ ) ។ សរីរៈប្រាកដដូច្នេះ ដល់នូវសេចក្តីលំបាកដ៏ក្រៃលែង គេដោតស្នួយឡើងលើឈើអណ្តោតដែលគេធ្វើដោយមែកស្តៅ កាលបើយ៉ាងហ្នឹងហើយ ម្នាលយក្ស ចុះហេតុអ្វីបានជាអ្នកពោលថា នែអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ( ព្រោះ ) ការរស់នៅជាការប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងនគរវេសាលីនោះ ។

បទថា **នគរស្ស ពាហិរំ** បានដល់ ខាងក្រៅព្រះនគរ គឺកើតប្រព្រឹត្តទៅទាក់ទងគ្នាខាងក្រៅនៃនគរវេសាលីនោះឯង ។ បទថា **តត្ថេវ** គឺក្នុងទីដែលខ្លួនឃើញប្រេតនោះឯង ។ បទថា **តំ** យោគជា **តំ បេតំ** ប្រែថា នូវប្រេតនោះ ។ បទថា **ការុណាត្តិកោ** បានដល់ ទ្រង់មានសេចក្តីត្រូវការដោយហេតុដើម្បីផលដូចពោលហើយថា នៃអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ( ព្រោះ ) ការរស់នៅជាការប្រសើរ ដូច្នេះ ។

បទថា **សេយ្យា និសជ្ជា នយិមស្ស អត្ថិ** សេចក្តីថា ការដេក មានការសណ្តូកខ្លួនជាលក្ខណៈ ការអង្គុយ មានការពត់ភ្លែនជាលក្ខណៈ រមែងមិនមានដល់បុគ្គលដែលត្រូវដោតដោយឈើអណ្តោតនេះបាន ។ បទថា **អភិក្កមោ នត្ថិ បដិក្កមោ ច** សេចក្តីថា ការទៅ មានការឈានទៅមុខជាលក្ខណៈ សូម្បីត្រឹមបន្តិចបន្តួច ក៏មិនមានដល់បុគ្គលនេះ ។ បទថា **បរិចារិកា សាបិ** សេចក្តីថា សូម្បីស្រីដែលបម្រើឥន្ទ្រិយដែលមានលក្ខណៈ ដូចជាការបរិភោគ ការផឹក ការទំពា ការស្លៀកសំពត់និងការប្រើប្រាស់ ជាដើមនោះ ក៏មិនមានដល់បុរសនេះ ។ ម្យ៉ាងទៀត បាលីថា **បរិហារណា សាបិ** ដូច្នេះក៏មាន អធិប្បាយថា សូម្បីស្រីដែលបរិហារឥន្ទ្រិយ ដោយអំណាចនៃការបរិភោគ មានរបស់ស៊ីជាដើម មិនមានដល់បុរសនេះ ព្រោះជាអ្នកប្រាសចាកជីវិត អាចារ្យពួកខ្លះពោលថា **បរិចារណា សាបិ** ដូច្នេះក៏មាន ។

បទថា **ទិដ្ឋសុតា សុហជ្ជា អនុកម្បកា យស្ស អហេសុំ បុព្វេ** សេចក្តីថា បុគ្គលដែលមានខ្លួនជាសម្លាញ់ធ្លាប់ឃើញគ្នាមកនិងមិនធ្លាប់ឃើញ

គ្នាមកជាមិត្ត មានការអាណិតអាសូរ មានក្នុងកាលមុន ។ បទថា **ឧត្តុម្បិ** សេចក្តីថា បុគ្គលទាំងនោះ សូម្បីសួរសុខទុក្ខ ក៏មិនមាន តើការនៅរួមគ្នានឹងមានមកអំពីណា ។ បទថា **វិរាជិតត្តោ** បានដល់ មានសភាវៈដែលញាតិជាដើមលះបង់ហើយ ។ បទថា **ជនេន តេន** បានដល់ ដែលជន មានជនជាញាតិជាដើមនោះ ។

បទថា **ន ទុគ្គតស្ស ភវន្តិ មិត្តា** សេចក្តីថា ឈ្មោះថា មិត្តរមែងមិនមានដល់បុគ្គលដែលប្រាសចាកវិញ្ញាណទៅហើយ គឺស្លាប់ទៅហើយ ព្រោះបុគ្គលនោះឆ្ងងផុតចាកកិច្ចដែលមិត្តគប្បីធ្វើចំពោះមិត្ត ។ បទថា **ជហន្តិ មិត្តា វិកលំ វិទិត្វា** សេចក្តីថា បុគ្គលដែលស្លាប់ហើយ ចូរលើកទុក ពួកមិត្តលុះដឹងបុរសសូម្បីនៅមានជីវិត តែប្រាសចាកភោគសម្បត្តិក៏គង់លះបង់បុរសនោះចោលដោយគិតថា របស់ណាមួយដែលគួរកាន់យក អំពីបុរសនេះរមែងមិនមានឡើយ ។ បទថា **អត្ថញ្ច ទិស្វា បរិវារយន្តិ** សេចក្តីថា ឃើញទ្រព្យដែលជាប្រយោជន៍ដែលជារបស់បុគ្គលនោះហើយ ពោលវាចាគួរស្រឡាញ់ ឃើញដល់មុខ នាំគ្នាចោមរោមបុគ្គលដែលស្តុកស្តម្ភ ដោយភោគសម្បត្តិនោះ ។ បទថា **ពហូ មិត្តា ឧគ្គតត្តស្ស ហោន្តិ** សេចក្តីថា បុគ្គលដែលមានសេចក្តីសម្រេច មានសភាពស្តុកស្តម្ភដោយទ្រព្យសម្បត្តិ រមែងមានមិត្តច្រើន នេះជាលោកសភាវៈ ។

បទថា **និហីនត្តោ សព្វភោគេហិ** បានដល់ បុគ្គលដែលមានខ្លួនសាបសូន្យចាកវត្ថុដែលជាគ្រឿងឧបភោគបរិភោគទាំងអស់ ។ បទថា **កិច្ឆោ** បាន

ដល់ ជាអ្នកដល់នូវសេចក្ដីទុក្ខ ។ បទថា **សម្មក្ខិតោ** បានដល់ ជាអ្នកមានរាងកាយប្រឡាក់ដោយឈាម ។ បទថា **សម្បរិភិន្នគត្តោ** បានដល់ ជាអ្នកមានខ្លួនត្រូវឈើអណ្ដាតទម្លាយខាងក្នុង ។ បទថា **ឧស្សាវពិន្ទូវ បលិម្ប-មានោ** បានដល់ ដូចតំណក់ទឹកសន្សើមដែលជាប់លើចុងស្មៅ ។ បទថា **អជ្ជ សុវេ** សេចក្ដីថា ជីវិតរបស់បុរសនេះនឹងរលត់សូន្យក្នុងថ្ងៃនេះឬក្នុងថ្ងៃស្អែកនេះ បន្ទាប់អំពីនោះទៅ ក៏ប្រព្រឹត្តទៅមិនបាន ។ បទថា **ឧត្តាសិតំ** បានដល់ ត្រូវឈើអណ្ដាតដោត គឺច្កាង ។ បទថា **បុចិមន្ទស្ស សូលេ** បានដល់ លើឈើអណ្ដាតដែលធ្វើដោយមែកស្ដៅ ។ បទថា **កេនេន វណ្ណេន** ប្រែថា ដោយហេតុអ្វី ។ បទថា **ជីវ ភោ ជីវិតមេវ សេយ្យោ** សេចក្ដីថា បុរសដ៏ចម្រើន ចូរអ្នករស់នៅចុះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអ្នកត្រូវឈើអណ្ដាតដោត នៅមានជីវិតក្នុងទីនេះ ក៏គង់ប្រសើរជាង ល្អជាងជីវិតរបស់បុគ្គលដែលចុតិអំពីលោកនេះ រាប់រយដង រាប់ពាន់ដង ។

ប្រេតនោះ ត្រូវព្រះរាជាត្រាស់សួរហើយយ៉ាងនេះ កាលនឹងប្រកាសបំណាងរបស់ខ្លួន ទើបពោលគាថា ៤ ថា

បុរសនុ៎ះ ( កាលពីជាតិមុន ) ជាសាលោហិតរបស់ខ្ញុំ ខ្ញុំរឭកឃើញជាតិក្នុងភពមុន បពិត្រព្រះរាជា លុះខ្ញុំឃើញហើយ ក៏មានសេចក្ដីករុណាដូច្នេះថា បុរសមានធម៌ដ៏លាមកនេះកុំធ្លាក់ចុះក្នុងនរកឡើយ ។ បពិត្រលិច្ឆវិរាជ បុរសនោះជាអ្នកធ្វើអំពើអាក្រក់ កាលច្យុតចាកអត្តភាពនេះហើយ នឹងកើតក្នុង

នរកដែលសម្បូរដោយសត្វមានសភាពគួរឲ្យស្ញើប មានកម្តៅភ្លើងដ៏ខ្លាំង មានទុក្ខក្តៅផ្សា ជាគ្រឿងធ្វើភ័យឲ្យកើត ។ ដែកអណ្តាតនេះឯង ប្រសើរជាងនរកនោះដោយគុណមានចំណែកដ៏ច្រើន បុរសនេះកុំធ្លាក់ក្នុងនរក មានទុក្ខតែម្យ៉ាង មានទុក្ខដ៏ក្តៅផ្សា ជាគ្រឿងធ្វើភ័យឲ្យកើត មានទុក្ខដ៏ក្លៀវក្លាតែម្យ៉ាង បុរសអ្នកដល់នូវសេចក្តីទុក្ខនោះ ស្តាប់ពាក្យខ្ញុំនេះបានហើយ គប្បីវៀរបង់នូវអំពើលាមកចេញ ហេតុដូច្នោះ បានជាខ្ញុំមិននិយាយក្នុងសម្នាក់នៃ ( បុគ្គលនេះ ) ថា ការរលត់ទៅនៃជីវិតនេះ ចូរកុំមានដល់ខ្ញុំ ក្នុងទីជាមួយគ្នាឡើយ ដូច្នេះ ។

ព្រោះហេតុនោះ ទើបខ្ញុំពោលថា ចូរអ្នករស់នៅចុះ ការមានជីវិតជារបស់ប្រសើរ ។

បណ្តាបទទាំងនោះ បទថា **សាលោហិតោ** បានដល់ មានលោហិតស្មើគ្នា គឺជាប់គ្នាដោយកំណើត អធិប្បាយថា ជាញាតិនឹងគ្នា ។ បទថា **បុរិមាយ ជាតិយា** គឺក្នុងអត្តភាពមុន ។ បទថា **មា ចាបធម្មោ និរយំ បតាយំ** មានវាចាប្រកបសេចក្តីថា ទូលបង្គំបានឃើញបុរសនេះហើយ មានសេចក្តីករុណាថា សូមកុំឲ្យបុរសមានធម៌លាមកនេះ ធ្លាក់នរកឡើយ គឺកុំឲ្យបុរសនេះដល់នរកឡើយ ។

បទថា **សត្តុស្សទំ** សេចក្តីថា កកកុញដោយសត្វដែលធ្វើកម្មអាក្រក់ម្យ៉ាងទៀត កកកុញដោយហេតុដ៏គ្រោតគ្រាត មានចំណាង ៥ ប្រការជាដើម

និងកម្មករណៈ ៧ យ៉ាង គឺចំណង ៥ ប្រការ ១ ប្រកលោហៈក្តៅចូលក្នុងមាត់ ១ ឲ្យឡើងលើភ្នំដែលពេញដោយរងើកភ្លើង ១ បោះចូលក្នុងឆ្នាំងដែក ១ ឲ្យចូលទៅកាន់ព្រៃដែលមានស្លឹកជាដាវ ១ ឲ្យចុះឬបោះទៅក្នុងទឹកស្ទឹងវេត្តរណី ១ បោះទម្លាក់ក្នុងមហានរក ១ អធិប្បាយថា សន្សំច្រើនឡើងៗ ។ បទថា **មហាភិតាបំ** បានដល់ ទុក្ខធំ ឬការក្តៅក្រហាយដែលកើតអំពីគំនរភ្លើងធំ ។ បទថា **កដុកំ** បានដល់ មិនគួរប្រាថ្នា ។ បទថា **ភយានកំ** ប្រែថា ឲ្យកើតការខា□ ។

បទថា **អនេកភាគេន គុណេន** បានដល់ ដោយអានិសង្សច្រើនចំណែក ។ បទថា **អយមេវ សេយ្យោ និរយេន តេន** សេចក្តីថា ឈើអណ្តាតនេះឯងប្រសើរជាងនរក ដែលជាទីកើតរបស់បុរសនេះ ។ ពិតហើយ បទថា **និរយេន** នេះ ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃបញ្ចមីវិភត្ត ។ បទថា **ឯកន្តតិព្វំ** សេចក្តីថា មានសេចក្តីទុក្ខដ៏ខ្លាំងក្លា ដោយចំណែកមួយពិត គឺជាទុក្ខធំយ៉ាងពិតប្រាកដ ។

បទថា **ឥទញ្ច សុត្វា វចនំ មមេសោ** សេចក្តីថា បុរសនេះគប្បីស្តាប់ពាក្យរបស់អញដែលពោលហើយដោយន័យជាដើមថា **ឥតោ ចុតោ** ប្រែថា ឃ្លាតចាកអត្តភាពនេះហើយ ជាអ្នកចូលដល់នូវសេចក្តីទុក្ខ ដូចជាចូលដល់ទុក្ខក្នុងនរកតាមពាក្យរបស់ខ្ញុំ ។ បទថា **វិជហេយ្យ ចាណំ** សេចក្តីថា គប្បីលះបង់ជីវិតរបស់ខ្លួន ។ បទថា **តស្មា** ប្រែថា ព្រោះហេតុនោះ ។ បទថា **មា មេកតោ** អធិប្បាយថា ខ្ញុំមិនពោលពាក្យនេះក្នុងទីជិតនៃបុរស

នេះដោយបំណងថាសូមជីវិតរបស់បុរសនេះកុំរលត់តែម្យ៉ាងព្រោះខ្ញុំឡើយ ។ ដោយពិត ខ្ញុំពោលត្រឹមតែប៉ុណ្ណោះថា អ្នកចូររស់នៅចុះ ( ព្រោះ ) ការរស់នៅជាការប្រសើរ ដូច្នេះ ។

កាលប្រេតប្រកាសបំណងយ៉ាងនេះ ទ្រង់ធ្វើឱកាសដើម្បីសួរប្រវត្តិរបស់ប្រេតនោះទៀត ទើបត្រាស់គាថាថា

ប្រយោជន៍របស់បុរសនេះខ្ញុំដឹងហើយយើងចង់សួរប្រយោជន៍

ដទៃទៀតចំពោះអ្នក បើអ្នកមិនបើកឱកាសឲ្យយើងទេ យើង

ក៏មិនហ៊ានសួរអ្នកដែរ អ្នកកុំគប្បីខឹងនឹងយើង ។

ប្រេតនោះក្រាបទូលថា

សេចក្តីប្តេជ្ញារបស់យើងមានហើយក្នុងកាលនោះ ដោយពិត

ថា មិនប្រាប់ដល់បុគ្គលដែលមិនជ្រះថ្លា ( នឹងគ្នា ) អ្នកចូរ

ធ្វើទុកក្នុងចិត្តថាយើងមិនចង់ប្រាប់ទេ តែជាមនុស្សមានពាក្យ

គួរជឿបាន ដូច្នេះ ហើយសួរខ្ញុំចុះ តាមសេចក្តីពិតដែលអាច

( នឹងប្រាប់បាន ) ដូច្នេះ ។

នេះជាគាថាត្រាស់ និងគាថាឆ្លើយរវាងព្រះរាជានិងប្រេត ។

បណ្តាបទទាំងនោះ បទថា **អញ្ញាតោ** ប្រែថា ខ្ញុំដឹងហើយ ។ បទថា **ឥច្ឆាមសេ** ប្រែថា ខ្ញុំរមែងប្រាថ្នា ។ បទថា **ណោ** ប្រែថា ដល់ពួកយើង ។ បទថា **ឆ ច កុជ្ឈិតព្វំ** សេចក្តីថា មិនគួរធ្វើសេចក្តីក្រោធថា មនុស្សទាំងនេះ បានសួរវត្ថុណាមួយ ។

បទថា **អទ្ធា** ប្រែថា ដោយចំណែកមួយ ។ បទថា **បដិញ្ញា មេ** សេចក្ដីថា បើពោលដោយការដឹង ខ្ញុំមានប្ដេជ្ញា គឺឲ្យឱកាសថា សូមទ្រង់សួរចុះ ។ បទថា **តទា អហុ** គឺមានក្នុងកាលនោះ គឺក្នុងការឃើញគ្រាដំបូង ព្រោះធ្វើយ៉ាងនេះ គឺព្រោះហេតុនេះ ។ បទថា **ឆាចិក្ខណា អប្បសន្នស្ស ហោតិ** សេចក្ដីថា មិនប្រាប់ដល់បុគ្គលដែលមិនជ្រះថ្លា ។ ពិតហើយ បុគ្គលជ្រះថ្លាប៉ុណ្ណោះ រមែងពោលវត្ថុណាមួយដល់បុគ្គលជ្រះថ្លា ។ តែក្នុងពេលនោះទ្រង់មិនជ្រះថ្លាក្នុងទូលបង្គំ ហើយទូលបង្គំក៏មិនមានសេចក្ដីជ្រះថ្លាក្នុងទ្រង់ ព្រោះហេតុនោះ ទើបទ្រង់មិនមានសេចក្ដីប្រាថ្នានឹងពោលប្ដេជ្ញា ។ តែឥឡូវនេះ ខ្ញុំមិនប្រាថ្នាទ្រង់ មានវាចាដែលឲ្យទ្រង់គប្បីជឿបាន ព្រោះដូច្នោះ ទើបខ្ញុំជាបុគ្គលមិនប្រាថ្នា ( នឹងប្រាប់ ) ទាំងមានវាចាគួរជឿ ។ បទថា **បុច្ឆស្សុ មំ កាមំ យថា វិសយ្ហំ** អធិប្បាយថា សូមទ្រង់សាកសួររឿងតាមដែលទ្រង់ប្រាថ្នាជាមួយខ្ញុំចុះ ខ្ញុំនឹងក្រាបទូលតាមសមគួរដល់កម្លាំងនិងការដឹងរបស់ខ្លួនដោយប្រការដែលខ្ញុំអាចក្រាបទូលបាន ។

កាលប្រេតឲ្យឱកាសដល់ការសួរយ៉ាងនេះ ព្រះរាជាក៏ត្រាស់គាថាថា

> យើងឃើញនូវហេតុណាមួយដោយចក្ខុ យើងត្រូវជឿហេតុ
> នោះទាំងអស់ ប្រសិនបើយើងឃើញហើយ យើងមិនជឿហេតុ
> នោះទេ ម្នាលយក្ស អ្នកត្រូវធ្វើនិយស្សកម្ម ( ការបន្ទោយ
> យស ) ដល់យើងចុះ ដូច្នេះ ។

ពាក្យនៃគាថានោះ មានអធិប្បាយដូចតទៅនេះថា យើងឃើញវត្ថុណា

ទីមួយដោយក្អែក យើងគួរជឿវត្ថុនោះទាំងអស់ ដោយប្រការនោះឯង បើយើងឃើញវត្ថុនោះហើយមិនជឿ ម្នាលទេវតា សូមអ្នកដាក់ទោសដោយនិយសកម្មនិងនិគ្គហកម្មដល់យើងចុះ ។ ម្យ៉ាងទៀត បទថា **យំ កិញ្ចាហំ ចក្ខុនា បស្សិស្សាមិ** សេចក្ដីថា យើងនឹងឃើញវត្ថុណាទីមួយដោយចក្ខុ ព្រោះមិនជាអារម្មណ៍នៃចក្ខុ ទើបមិនឃើញ ។ បទថា **សព្វម្បិ តាហំ អភិសទ្ទហេយ្យំ** សេចក្ដីថា យើងគួរជឿវត្ថុដែលបានឃើញ បានឮឬវត្ថុដទៃ អធិប្បាយថា ពិតហើយ យើងមានការជឿយ៉ាងនោះក្នុងអ្នក ឯអត្ថនៃបទក្រោយ ក៏មានអត្ថតាមដែលពោលហើយនោះឯង ។ ប្រេតបានស្ដាប់ដូច្នោះ ទើបពោលគាថាថា

ពាក្យប្ដេជ្ញានុ៎ះ ជាពាក្យប្ដេជ្ញាដ៏ពិតរបស់ព្រះអង្គចុះ បើព្រះអង្គត្រូវការចង់ដឹង មានហឫទ័យមិនប្រទូស្ដ ស្ដាប់ធម៌ណា ជាធម៌ដែលព្រះអង្គធ្លាប់ស្ដាប់ហើយក្ដី មិនធ្លាប់ស្ដាប់ហើយក្ដី លុះព្រះអង្គស្ដាប់ធម៌នោះហើយ ចូរបាននូវសេចក្ដីជ្រះថ្លាកាល បើខ្ញុំដឹងយ៉ាងណា នឹងក្រាបទូលនូវហេតុនោះទាំងអស់ដូច្នេះ ។

ខាងមុខអំពីនេះទៅ ព្រះរាជានិងប្រេត មានគាថាឆ្លើយឆ្លងគ្នាដូច្នេះថា ព្រះបាទអម្ពសក្ខរៈត្រាស់ថា

អ្នកមានសេះសប្រដាប់ហើយ ហើយចូលទៅ ក្នុងទីជិតនៃបុរស ដែលគេដោតដោយឈើអណ្ដោត ឯយានជំនិះនេះជារបស់អស្ចារ្យគួរមើលមើល នេះជាផលនៃកម្មអ្វី ។

ប្រេតតបថា

មានជង្ហុក ១ ត្រង់ផ្លូវអិលនៅកណ្តាលក្រុងវេសាលីនោះ ថ្ងៃមួយខ្ញុំមានចិត្តជ្រះថ្លា បានយកក្បាលគោធ្វើជាស្ពាន ដាក់ត្រង់ជង្ហុកនោះ ។ យើងក្តី ពួកមនុស្សឯទៀតៗក្តី បានដាក់ជើងលើស្ពាននោះហើយ ទើបដើរទៅបាន យានជំនិះនេះដ៏អស្ចារ្យគួរមើលមើល នេះជាផលនៃកម្មនោះឯង ។

ស្តេចលិច្ឆវីសួរថា

ចុះអ្នកមានសម្បុរភ្លឺទៅសព្វទិស អ្នកមានក្លិនផ្សព្វផ្សាយទៅសព្វទិសបាន អ្នកបាននូវឫទ្ធិជាយក្ស មានអានុភាពច្រើន តែជាអ្នកអាក្រាត នេះជាវិបាកនៃកម្មអ្វី ។

ប្រេតឆ្លើយថា

ខ្ញុំជាមនុស្សមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច និយាយទៅនឹងជនដោយពាក្យពីរោះផ្អែមល្ហែម នេះជាផលនៃកម្មនោះឯងបានជាសម្បុររបស់ខ្ញុំភ្លឺជានិច្ចដូចជាទិព្វ ។ ខ្ញុំបានឃើញយសសក្តិនឹងកេរ្តិ៍ឈ្មោះរបស់ពួកជនអ្នកតាំងនៅក្នុងធម៌ ក៏មានចិត្តជ្រះថ្លា ហើយប្រឹក្សា នេះជាផលនៃកម្មនោះឯង បានជាខ្ញុំមានក្លិនដូចជាទិព្វ ផ្សព្វផ្សាយទៅជានិច្ចបាន ។ ខ្ញុំបានយកសំពត់ពួកសំឡាញ់ កំពុងងូតទឹកក្នុងកំពង់ លាក់លើគោក ខ្ញុំត្រូវការនឹងសើចលេង មិនមានចិត្តប្រទូស្តទេ ព្រោះតែកម្មនោះ

បានជាខ្ញុំអាក្រាត ទាំងការចិញ្ចឹមជីវិតក៏លំបាកពន់ពេក ។

ស្តេចលិច្ឆវីត្រាស់សួរថា

បើបុគ្គលណា លែងធ្វើបាប អ្នកប្រាជ្ញទាំងឡាយបានសម្តែងនូវផលនៃកម្មរបស់បុគ្គលនោះ ប្រាកដដូច្នេះ ចុះបើបុគ្គលណាមិនលែងធ្វើបាបទេ អ្នកប្រាជ្ញទាំងឡាយ បានសម្តែងនូវផលនៃកម្មនោះដូចម្តេច ។

ប្រេតតបថា

បើពួកមនុស្សណា មានតម្រិះក្នុងចិត្តប្រទូស្តហើយ សៅហ្មងដោយកាយនិងវាចា មនុស្សទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក្នុងបរលោករមែងទៅកើតក្នុងនរកឥតមានសង្ស័យឡើយ ។ ចំណែកពួកមនុស្សដទៃ ប្រាថ្នានូវសុគតិ ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះ មនុស្សទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក្នុងបរលោក រមែងទៅកើតក្នុងសុគតិ ឥតមានសង្ស័យឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សច្ចប្បដិញ្ញា តវ មេសា ហោតុ** សេចក្តីថា សូមប្រេជ្ញារបស់ទ្រង់ ជាសច្ចៈសម្រាប់ខ្ញុំថា យើងគប្បីជឿវត្ថុទាំងអស់នោះ ។ បទថា **សុត្វាន ធម្មំ លភ សុប្បសាទំ** សេចក្តីថា ទ្រង់ស្តាប់ពាក្យដែលខ្ញុំពោលហើយ សូមបាននូវការជ្រះថ្លាដ៏ល្អ ។ បទថា **អញ្ញត្ថិកោ** បានដល់ មានបំណងនឹងដឹង ។ បទថា **យថា បជានំ** បានដល់ តាមដែលអ្នក

ដទៃដឹង អធិប្បាយថា តាមដែលទ្រង់ដឹងហើយ ឬតាមដែលទូលបង្គំដឹង ហើយ ។

បទថា **កិស្សេតំ កម្មស្ស អយំ វិបាកោ** សេចក្តីថា នុ៎ះជាផលនៃកម្ម អ្វី គឺនេះជាវិបាកនៃកម្មអ្វី ។ ម្យ៉ាងទៀត បទថា **ឯតំ** ត្រឹមតែជានិបាត ។ យោជនាថា **កិស្ស កម្មស្ស** ( នៃកម្មអ្វី ) ។ អាចារ្យពួកខ្លះពោលថា **កិស្ស តេ** ( ជាផលកម្មអ្វីរបស់អ្នក ) ។

បទថា **ចិក្ខល្លមគ្គេ** បានដល់ ក្នុងផ្លូវដែលមានភក់ ។ បទថា **ឆវកំ** បានដល់ ជង្ហុក ។ បទថា **ឯកោហំ** កាត់បទជា **ឯកំ អហំ** ។ បទថា **ឆវកស្មឹ និក្ខិបឹ** សេចក្តីថា ខ្ញុំយកលលាដ៍ក្បាលគោមួយ ដាក់ក្នុងជង្ហុកដែល មានភក់ ដោយប្រការដែលអ្នកដំណើរមិនជាន់ភក់ ។ បទថា **តស្ស** បាន ដល់ យកក្បាលគោធ្វើជាស្ពាន ។ បទថា **ធម្មេ ឋិតានំ** បានដល់ ប្រព្រឹត្ត ជាធម៌ ប្រព្រឹត្តស្ងប់ ។ បទថា **មន្តេមិ** បានដល់ ពោល គឺប្រារព្ធដល់ ។ បទថាឲ្យ **ខិឌ្ឌត្ថិកោ** បានដល់ បំណងនឹងសើចលេង ។បទថា **នោ ច បទុដ្ឋ-ចិត្តោ** បានដល់ មិនមានចិត្តប្រទូស្តម្ចាស់សំពត់ អធិប្បាយថា មិនមាន បំណងនឹងលួចផង មិនបំណងធ្វើឲ្យវិនាសផង ។

បទថា **អកីឡមានោ** បានដល់ មិនបំណងលេង គឺមានចិត្តប្រទូស្ត ព្រោះការលោភជាដើមឡើយ ។ បទថា **កឹ តស្ស កម្មស្ស វិបាកមាហុ** សេចក្តីថា បណ្ឌិតទាំងឡាយពោលវិបាកទុក្ខដ៏ខ្លោចផ្សានៃបាបកម្មនោះ គឺ ធ្វើទុកយ៉ាងនោះ ដរាបណា ។ បទថា **ទុដ្ឋសង្កប្បមនោ** បានដល់ ជាអ្នក

មានវិតក្កផ្សេងៗ ដែលចិត្តប្រទូស្ត ដោយអំណាចការត្រិះរិះក្នុងកាមជាដើម ដោយពាក្យថា **ទុដ្ឋសង្កប្បមនា** នោះ លោកពោលដល់មនោទុច្ចរិត ។ បទថា **កាយេន វាចាយ ច សង្កិលិដ្ឋា** បានដល់ មានសេចក្តីសៅហ្មងដោយកាយនិងវាចា ដោយអំណាចបាណាតិបាតជាដើម ។ បទថា **អាសមានា** បានដល់ សង្ឃឹម គឺត្រូវការ ។

កាលប្រេតសម្តែងចែកកម្ម និងផលនៃកម្មដោយសង្ខេបយ៉ាងនេះហើយ ព្រះរាជាទ្រង់មិនជឿសេចក្តីនោះ ទើបត្រាស់គាថាថា

យើងបានពិចារណាហើយ គប្បីដឹងពាក្យនោះដូចម្តេច នេះជាផលនៃកល្យាណកម្មនិងបាបកម្មទេតើ យើងឃើញ ដូចម្តេចគប្បីជឿ នរណាគប្បីធ្វើខ្ញុំឲ្យជឿពាក្យនោះបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ កិន្តិ ជានេយ្យមហំ អវេច្ច** សេចក្តីថា យើងគប្បីជឿដោយមិនមានអ្នកដទៃជាបច្ច័យ ដល់វិបាកនៃកម្មល្អនិងកម្មអាក្រក់ដែលអ្នកបានពោលចែកទុកដោយន័យជាដើមថា បើពួកមនុស្សណាមានតម្រិះក្នុងចិត្តប្រទូស្តហើយ សៅហ្មងដោយកាយនិងវាចា ដូច្នេះ និងដោយន័យជាដើមថា ចំណែកពួកមនុស្សដទៃប្រាថ្នានូវសុគតិ ដូច្នេះ នោះបានដូចម្តេច គឺដោយហេតុអ្វី ។ បទថា **កិំ វាហំ ទិស្វា អភិសទ្ទហេយ្យំ** សេចក្តីថា យើងឃើញអ្វីជាកស្តុតាងដែលប្រចក្ស គប្បីជឿបាន ។ បទថា **កោ វាបិ មំ សទ្ទហាបេយ្យ ឯតំ** សេចក្តីថា បុគ្គលណាជាវិញ្ញូជន គឺជាបណ្ឌិត គប្បីឲ្យយើងជឿសេចក្តីនោះ អ្នកចូរបង្ហាញនូវបុគ្គលនោះ ។

ប្រេតស្តាប់ដូច្នោះ កាលនឹងប្រាប់រឿងនោះដល់ព្រះរាជា ទើបបានពោល គាថាថា

ព្រះអង្គទតឃើញហើយ ឮហើយ សូមជឿទៅចុះ នេះជា ផលនៃកល្យាណកម្ម និងបាបកម្ម កាលបើកល្យាណកម្មនិង បាបកម្មទាំងពីរមិនមានទេ ពួកសត្វគប្បីមានសុគតិឬទុគ្គតិដូច ម្តេចបាន ។ ប្រសិនបើពួកសត្វ មិនគប្បីធ្វើកល្យាណកម្មនិង បាបកម្មក្នុងមនុស្សលោកនេះទេ ពួកសត្វ ក៏មិនបានសុគតិឬ ទុគ្គតិ ទាំងមិនបានថោកទាប ឬខ្ពង់ខ្ពស់ ក្នុងមនុស្សលោក ឡើយ ។ ពួកសត្វធ្វើកល្យាណកម្ម និងបាបកម្មក្នុងមនុស្ស លោកនេះ ព្រោះហេតុណា ហេតុនោះ បានជាពួកសត្វទៅ សុគតិខ្លះ ទុគ្គតិខ្លះ ថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ ក្នុងមនុស្ស លោក ។ ពួកអ្នកប្រាជ្ញបានសម្តែងនូវផលទាំងពីរនៃកម្មទាំង-ឡាយដែលជាគ្រឿងសោយនូវសុខ និងទុក្ខ ពួកទេវតាតែង ចោមរោមដោយពិត ពួកពាល ជាអ្នកមិនបានឃើញនូវផល ទាំងពីរហើយរមែងឆេះនៅ ( ក្នុងអបាយទាំងឡាយមាននរក ជាដើម ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិស្វា ច** បានដល់ ទ្រង់បានឃើញដោយ ប្រចក្សផង ។ បទថា **សុត្វា** បានដល់ ទ្រង់ស្តាប់ធម៌ហើយ ទ្រង់ដឹង គឺ ទ្រង់ដឹងតាមន័យ តាមគន្លងនៃធម៌នោះ ។ បទថា **កល្យាណបាបស្ស** សេច

ក្តីថា សូមទ្រង់ជឿចុះថា សុខនេះជាវិបាកនៃកុសលកម្ម ទុក្ខនេះជាវិបាកនៃអកុសលកម្ម ។ បទថា **ឧភយេ អសន្តេ** សេចក្តីថា កាលកម្មទាំង ២ គឺកម្មល្អនិងកម្មអាក្រក់មាន ។ បទថា **សិយា នុ សត្តា សុគតា ទុគ្គតា វា** សេចក្តីថា សត្វទាំងនេះ ទៅកាន់សុគតិឬទុគ្គតិឬជាអ្នកស្តុមស្តួកក្នុងសុគតិឬជាអ្នកក្រីក្រក្នុងទុគ្គតិ ដូច្នេះ គប្បីមានឬ គឺគប្បីកើតបានដូចម្តេច ។

ឥឡូវនេះ ប្រេតប្រកាសអត្ថតាមដែលពោលហើយ ដោយប្លែកគ្នា និងដោយអនុលោមតាមគ្នា ដោយ ២ គាថាថា **នោ ចេត្ត កម្មានិ** និង **យស្មា ច កម្មានិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ហីនា បណីតា** បានដល់ជាបុគ្គលអាក្រក់និងល្អដោយត្រកូល រូបរាង ការមិនមានរោគនិងបរិវារជាដើម ។

បទថា **ទ្វយជ្ជ កម្មានំ វិបាកមាហុ** សេចក្តីថា សត្វទាំងឡាយរមែងពោល គឺសម្តែងវិបាកនៃសុចរិតនិងទុច្ចរិតនៃកម្មទាំង ២ យ៉ាង ក្នុងថ្ងៃនេះ គឺក្នុងឥឡូវនេះ ។ ដើម្បីចៀសវាងពាក្យសួរថា សេចក្តីនោះគឺអ្វី ទើបពោលថា **សុខស្ស ទុក្ខស្ស ច វេទនីយំ** ដែលជាគ្រឿងសោយនូវសុខនិងទុក្ខដូច្នេះ អធិប្បាយថា គួរសោយឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ។ បទថា **តា ទេវតាយោ បរិចារយន្តិ** សេចក្តីថា ពួកជនដែលបានទទួលវិបាកដែលឲ្យនូវសេចក្តីសុខដោយចំណែកមួយរមែងជាទេវតាក្នុងទេវលោក ពេញប្រៀបដោយទិព្វសុខ បម្រើនូវឥន្ទ្រិយទាំងឡាយ ។ បទថា **បជានន្តិ ពាលា ទ្វយតំ អបស្សិនោ** សេចក្តីថា ជនពួកណាជាបុគ្គលពាល មិនឃើញ គឺមិនជឿកម្ម

*និងផលនៃកម្មទាំង ២ ជនទាំងនោះរមែងជាអ្នកខ្វល់ខ្វាយក្នុងបាបកាលសោយវិបាកដែលឲ្យនូវសេចក្ដីទុក្ខរមែងឆេះ គឺរមែងបានទទួលទុក្ខព្រោះកម្មក្នុងនរកជាដើម ។*

*ប្រេតសំដៅយកការសាកសួរថា អ្នកជឿកម្ម និងផលនៃកម្មយ៉ាងនេះ ព្រោះហេតុអ្វីទើបសោយទុក្ខមានភាពបែបនេះ ទើបពោលគាថាថា*

*បុញ្ញកម្ម ដែលធ្វើដោយខ្លួនឯង មិនមានអ្នកឲ្យគ្រឿងស្លៀក*
*ពាក់ ទីដេក ទីអង្គុយ បាយនិងទឹក ហើយឧទ្ទិសចំពោះខ្ញុំក៏*
*មិនមានដែរ ហេតុនោះ បានជាខ្ញុំមានកាយអាក្រាតទាំងការ*
*ប្រព្រឹត្តចិញ្ចឹមជីវិតក៏លំបាក ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ន មត្ថិ កម្មានិ សយំកតានិ** *សេចក្ដីថា ព្រោះហេតុដែលបុញ្ញកម្ម ដែលខ្លួនឯងធ្វើក្នុងកាលមុន ដែលជាហេតុឲ្យបានទទួលនូវគ្រឿងស្លៀកដណ្ដប់ជាដើមក្នុងឥឡូវនេះ មិនមានប្រាកដដល់ខ្ញុំឡើយ ។ បទថា* **ទត្វាបិ មេ នត្ថិ យោ អាទិសេយ្យ** *សេចក្ដីថា បុគ្គលណា គប្បីឲ្យទានដល់សមណព្រាហ្មណ៍ ហើយគប្បីឧទ្ទិសចំណែកបុណ្យ ដល់ខ្ញុំព្រះអង្គថា សូមបុណ្យនេះសម្រេចដល់ប្រេតនោះ បុគ្គលនោះរមែងមិនមាន ។ បទថា* **តេនម្ហិ នគ្គោ កសិរា ច វុត្តិ** *សេចក្ដីថា ព្រោះហេតុទាំង ២ នោះ ទើបខ្ញុំបត្ដិជាអ្នកអាក្រាតកាយ មិនមានសំពត់ក្នុងកាលឥឡូវនេះ ទាំងមានភាពជាអ្នករស់នៅយ៉ាងលំបាក ។*

*ព្រះរាជា ទ្រង់ស្ដាប់ដូច្នេះហើយ កាលបំណងឲ្យប្រេតនោះបានគ្រឿង*

ស្បៀកដណ្តប់ជាដើម ទើបត្រាស់ថា

ម្នាលយក្ស ហេតុតិចតួចដែលអ្នកគួរបាននូវគ្រឿងស្បៀកពាក់មានដែរឬ អ្នកចូរប្រាប់ដល់យើង ហេតុណាដែលនាំឲ្យយើងជឿបាន យើងនឹងស្តាប់នូវពាក្យតាមហេតុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេន** សេចក្តីថា ហេតុណាមួយដែលជាហេតុឲ្យអ្នកបាននូវគ្រឿងស្បៀកដណ្តប់ គប្បីមានឬហ្ន៎ ។ បទថា **យេនត្ថិ** កាត់បទជា **យេ អត្ថិ** ប្រែថា បើមាន ។

លំដាប់នោះ ប្រេតកាលនឹងទូលប្រាប់ហេតុនោះដល់ព្រះរាជា ទើបពោលគាថាថា

ក្នុងក្រុងវេសាលីនេះ មានភិក្ខុ ១ រូប ឈ្មោះកប្បិតកៈ មានឈាន មានសីលធម៌ល្អ ជាព្រះអរហន្ត មានចិត្តផុតស្រឡះចាកអកុសល មានឥន្ទ្រិយស្រគត់ស្រគំ សង្រួមក្នុងបាតិមោក្ខត្រជាក់ត្រជុំ សម្រេចនូវការយល់ដ៏ខ្ពង់ខ្ពស់ មានសំដីទន់ភ្លន់ដឹងនូវពាក្យពោល មានសំដីផ្អែមល្ហែមនិងមានព្រះភក្ត្រផូរផង់ចេះចាំធម៌អាចដោយប្រពៃ ផុតស្រឡះហើយដោយល្អ ជាបុញ្ញក្ខេត្ត ស្ងប់ស្ងាត់ចាកកិលេស ជាទក្ខិណេយ្យបុគ្គលរបស់ទេវតានិងមនុស្សទាំងឡាយ ជាសប្បុរស ប្រាសចាកផ្សែងគឺវិតក្កៈ វិចារៈ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ផុតស្រឡះចាកភពទាំងពួង មានសរគឺរាគៈទៅប្រាសហើយ មិនមាន

សេចក្ដីសម្គាល់ថាអញ មិនវៀចវេរ មិនមានឧបធិក្កិលេស អស់ធម៌ជាគ្រឿងយឺតយូរគ្រប់យ៉ាង បានសម្រេចវិជ្ជា ៣ មានសេចក្ដីរុងរឿង ។ លោកនោះ មិនល្បីនាមប្រាកដទេ ទុកជាឃើញក៏មិនងាយនឹងស្គាល់ ពួកមនុស្សអ្នកនៅក្នុងដែនវជ្ជីតែងនាំគ្នាហៅថាមុនីដូច្នេះ ទាំងដឹងថា លោកជាបុគ្គលគួរបូជា មិនមានសេចក្ដីញាប់ញ័រគឺកិលេស មានកល្យាណធម៌ ប្រព្រឹត្តនៅក្នុងលោក ។ បើព្រះអង្គឲ្យសំពត់ ១ គូក្ដី ២ គូក្ដី ដល់ព្រះថេរៈនោះ ឧទ្ទិសដល់ខ្ញុំ ខ្ញុំនឹងគប្បីបានសំពត់ដែលលោកទទួលហើយនោះផង ព្រះអង្គនឹងទតឃើញខ្ញុំ ដែលស្លៀកសំពត់ហើយផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កប្បិតកោ ណាម** ប្រេតពោលសំដៅយកឧបជ្ឈាយ៍របស់ព្រះឧបាលិត្ថេរ ក្នុងជដិល ១០០០ អង្គ ។ បទថា **ឥធ** បានដល់ ក្នុងទីជិតនគរវេសាលីនេះ ។ បទថា **ឈាយី** បានដល់ ជាអ្នកបានឈានដែលសម្បយុត្តដោយអរហត្តផល ។ បទថា **សីតិភូតោ** បានដល់ ជាអ្នកដល់នូវភាពត្រជាក់ ដោយការចូលទៅស្ងប់នូវសេចក្ដីក្រវល់ក្រវាយ និងការក្ដៅក្រហាយនៃកិលេសទាំងពួង ។ បទថា **ឧត្តមទិដ្ឋិបត្តោ** បានដល់ជាអ្នកសម្រេចសម្មាទិដ្ឋិដ៏ឧត្តម គឺអរហត្តផល ។

បទថា **សណ្ហោ** ប្រែថា ជាអ្នកមានវាចាពីរោះ ។ បទថា **សុវចោ** ប្រែថា ជាអ្នកប្រដៅងាយ ។ បទថា **ស្វាគមោ** ប្រែថា ជាអ្នកមកល្អទៅ

ល្អ ។ បទថា **សុប្បដិមុត្តកោ** បានដល់ ជាអ្នកមានវាចារួចផុតដោយល្អ អធិប្បាយថា ជាអ្នកមានប្រក្រតីពោលរួចផុត ។ បទថា **អរណវិហារី** ប្រែថា ជាអ្នកមានប្រក្រតីនៅដោយមេត្តាវិហារធម៌ ។

បទថា **សន្តោ** បានដល់ ជាអ្នកស្ងប់កិលេស ។ បទថា **វិធូមោ** បានដល់ ជាអ្នកប្រាសចាកផ្សែង គឺមិច្ឆាវិតក្ក ។ បទថា **អនីឃោ** ប្រែថា ជាអ្នកមិនមានទុក្ខ ។ បទថា **និរាសោ** ប្រែថា ជាអ្នកមិនមានតណ្ហា ។ បទថា **មុត្តោ** បានដល់ ជាអ្នករួចផុតចាកកពទាំងពួង ។ បទថា **វិសល្លោ** ប្រែថា ជាអ្នកប្រាសចាកសរ មានរាគៈជាដើម ។ បទថា **អមមោ** ប្រែថា ជាអ្នកប្រាសចាកការប្រកាន់ថាអញ ថាអ្នកដទៃ ។ បទថា **អវង្កោ** បានដល់ ជាអ្នកប្រាសចាកការកោង មានការវៀចវេរដោយកាយជាដើម ។ បទថា **និរូបធិ** បានដល់ ដែលលះឧបធិ មានកិលេសជាគ្រឿងតាក់តែង ជាដើម ។ បទថា **សព្វបបញ្ចខីណោ** បានដល់ ជាអ្នកអស់នូវធម៌ជាគ្រឿងយឺតយូរ មានតណ្ហាជាដើម ។ បទថា **ជុតិមា** បានដល់ រុងរឿងដោយញាណដ៏កំពូល ។ បទថា **អប្បញ្ញាតោ** បានដល់ ឈ្មោះថា ដែលមិនប្រាកដ ព្រោះជាអ្នកប្រាថ្នាតិចក្រៃលែង និងព្រោះជាអ្នកបិទបាំងនូវគុណ ។

បទថា **ទិស្វាបិ ន ច សុជានោ** សេចក្តីថា សូម្បីឃើញដោយភាពជ្រាលជ្រៅ ក៏មិនយល់បានល្អថា មានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានបញ្ញាយ៉ាងនេះ ។ បទថា **ជានន្តិ តំ យក្ខភូតា អនេជំ** សេចក្តីថា យក្សនិងភូតរមែងស្គាល់លោកពិតប្រាកដ ដែលជាអ្នកប្រាសចាកតណ្ហា ជាព្រះ

អរហន្ត ។ បទថា **កល្យាណធម្មំ** បានដល់ ជាអ្នកមានគុណ មានកល្យាណសីលជាដើម ។

បទថា **តស្ស** បានដល់ ដល់ព្រះកប្បិតកមហាថេរៈនោះ ។ បទថា **ឯកយុគំ** បានដល់ គូនៃសំពត់ ១ ។ បទថា **ទុវេ វា** បានដល់ ឬគូសំពត់ ២ គូ ។ បទថា **មមុទ្ទិស្សិត្វាន** បានដល់ ឧទ្ទិសដល់ខ្ញុំ ។ បទថា **បដិគ្គ-ហីតានិ ច តានិ អស្ស** សេចក្ដីថា គូនៃសំពត់ទាំងនោះគប្បីជារបស់ដែលព្រះថេរៈនោះទទួលហើយ ។ បទថា **សន្នទ្ធទុស្សំ** បានដល់ ដែលធ្វើការស្លៀកសំពត់ អធិប្បាយថា បានសំពត់ហើយ គឺស្លៀកដណ្ដប់សំពត់ហើយ ។

លំដាប់នោះព្រះរាជា ក៏ត្រាស់សួរដល់លំនៅរបស់ព្រះថេរៈថា

ឥឡូវនេះ យើងនឹងទៅជួបព្រះសមណៈនៅក្នុងប្រទេសណា
សមណៈនោះគប្បីបន្ទោបង់នូវសេចក្ដីសង្ស័យផង នូវសេចក្ដី
ងឿងឆ្ងល់ផង នូវសេចក្ដីយល់ខុសដែលជាសត្រូវរបស់យើង
ផង ក្នុងថ្ងៃនេះបានឬទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កស្មឹ បទេសេ** ប្រែថា ក្នុងប្រទេសណា ។ បទថា **យោ មជ្ជ** កាត់បទជា **យោ អជ្ជ** ចំណែក **ម** អក្ខរៈ ត្រឹមតែធ្វើការភ្ជាប់បទ ។

លំដាប់នោះ ប្រេតឆ្លើយដោយគាថាថា

សមណៈនុ៎ះ គង់នៅឯប្រទេសឈ្មោះ កបិនច្ចនា មានពួក
ទេវតាច្រើនចោមរោម លោកមាននាមថា សច្ចៈ ជាអ្នកមិន

ប្រមាទ ក្នុងធម៌ជាគ្រឿងអស្ចារ្យរបស់ខ្លួន សម្តែងធម្មិកថា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កបិនច្ឆាយំ** បានដល់ ក្នុងប្រទេសដែលបានវោហារថា **កបិនច្ឆា** ព្រោះជាទីច្រៀងរាំរបស់ពួកស្វា ។ បទថា **សច្ចនាមោ** បានដល់ ជាអ្នកមានឈ្មោះតាមពិត គឺមានឈ្មោះមិនខុសអំពីសេចក្តីពិតដោយគុណ មានជាអ្នកបានឈាន ជាអ្នកមានសីលបរិសុទ្ធ ជាព្រះអរហន្ត ជាអ្នករួចផុត ជាដើម ។

កាលប្រេតពោលយ៉ាងនោះ ព្រះរាជាមានព្រះបំណងនឹងយាងទៅកាន់សម្នាក់របស់ព្រះថេរៈក្នុងខណៈនោះឯង ទើបត្រាស់គាថាថា

បើដូច្នោះ ឥឡូវនេះ យើងនឹងទៅធ្វើឲ្យសមណៈស្លៀកដណ្តប់
ដោយគូសំពត់ អ្នកចូរមើលសំពត់ទាំងនោះ ដែលលោកបាន
ទទួលហើយ ឯយើងគប្បីមើលនូវអ្នកស្លៀកសំពត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កស្សាមិ** ប្រែថា នឹងធ្វើ ។

លំដាប់នោះ ប្រេតកាលសម្តែងថា ព្រះថេរៈរមែងសម្តែងធម៌ដល់ទេវតាទាំងឡាយ ព្រោះដូច្នោះ ពេលនេះ មិនមែនជាពេលដែលគួរចូលទៅរក ទើបពោលគាថាថា

ព្រះអង្គកុំចូលទៅរកបព្វជិត ក្នុងកាលមិនគួរឡើយ ខ្ញុំសូម
អង្វរ ធម៌នោះមិនមែនជាធម៌របស់ព្រះអង្គជាស្តេចលិច្ឆវីទេ ខ្ញុំ
ចូលទៅក្នុងកាលគួរនោះ ទើបឃើញលោកគង់នៅក្នុងទីស្ងាត់

នោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាធុ** ជានិបាត ប្រើក្នុងអត្ថថា ទូលសូម ។ បទថា **តេ លិច្ឆវិ ឯស ធម្មោ** សេចក្ដីថា បពិត្រស្ដេចលិច្ឆវី ការចូលទៅរកបព្វជិតក្នុងកាលដែលមិនសមគួរនេះ មិនជាទំនៀមរបស់ព្រះអង្គ ដែលជាស្ដេច ។ បទថា **តត្ថេវ** គឺក្នុងទីនោះឯង ។

កាលប្រេតពោលយ៉ាងនេះ ព្រះរាជាទ្រង់ទទួលពាក្យហើយ យាងទៅព្រះរាជនិវេសន៍របស់ព្រះអង្គ ឲ្យមនុស្សកាន់គូសំពត់ ៨ ក្នុងកាលដែលសមគួរ ហើយចូលទៅរកព្រះថេរៈ ប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង ធ្វើបដិសណ្ឋារៈ ហើយត្រាស់ថា លោកដ៏ចម្រើន សូមលោកម្ចាស់ទទួលគូសំពត់ ៨ នេះ ។ ព្រះថេរៈបានស្ដាប់ដូច្នោះ ដើម្បីនឹងសន្ទនា ទើបទូលថា បពិត្រមហារាជ កាលមុនទ្រង់មិនបំពេញទាន មានតែការបៀតបៀនសមណព្រាហ្មណ៍ប៉ុណ្ណោះ មានបំណងថ្វាយសំពត់ដ៏ប្រណីតដូចម្ដេចបាន ។ ព្រះរាជាទ្រង់បានស្ដាប់ដូច្នោះហើយ កាលត្រាស់ប្រាប់ហេតុដល់ព្រះថេរៈ ទើបត្រាស់ប្រាប់ការដែលប្រេតមក និងរឿងដែលប្រេតពោលជាមួយព្រះអង្គ ដល់ព្រះថេរៈ ទើបបានប្រគេនសំពត់ ហើយឧទ្ទិសដល់ប្រេត ។ ដោយហេតុនោះ ទើបប្រេតស្លៀកសំពត់ជាទិព្វ ប្រដាប់តាក់តែង ប្រាកដខាងមុខព្រះថេរៈនិងព្រះរាជា ។ ព្រះរាជាកាលទ្រង់ឃើញដូច្នោះហើយ ទ្រង់ពេញព្រះទ័យ ត្រេកអរក្នុងព្រះទ័យ កើតបីតិសោមនស្សត្រាស់ថា យើងឃើញផលនៃកម្មដោយប្រចក្សហើយ ឥឡូវនេះ យើងនឹងមិនធ្វើអាក្រក់ ធ្វើតែបុណ្យប៉ុណ្ណោះ ដូច្នេះ

ហើយ ទ្រង់បានធ្វើសាក្សីជាមួយប្រេតនោះ ប្រេតក្រាបទូលថា បពិត្រស្តេចលិច្ឆវី តាំងអំពីថ្ងៃនេះទៅ បើទ្រង់លះអធម៌ ប្រព្រឹត្តធម៌សោត កាលបើដូច្នេះខ្ញុំនឹងជាបន្ទាល់ដល់ទ្រង់ ខ្ញុំនឹងមកកាន់សម្នាក់របស់ព្រះអង្គ សូមទ្រង់ដោះលែងបុរសដែលដោតដោយឈើអណ្តោតឲ្យឆាប់ កាលបើដូច្នេះ បុរសនោះក៏នឹងបាននូវជីវិត ប្រព្រឹត្តធម៌ផុតចាកទុក្ខ ហើយសូមទ្រង់ចូលមករកព្រះថេរៈតាមកាលដ៏គួរ ស្តាប់ធម៌ បំពេញបុណ្យ ដូច្នេះហើយ ក៏ទៅ ។

លំដាប់នោះ ព្រះរាជាថ្វាយបង្គំព្រះថេរៈហើយ ចូលទៅកាន់ព្រះនគរ ឲ្យប្រជុំបរិស័ទលិច្ឆវី ឲ្យមនុស្សទាំងនោះអនុញ្ញាតឲ្យបុរសនោះផុតពីឈើអណ្តោត ត្រាស់នឹងគ្រូពេទ្យថា ចូរព្យាបាលបុរសនេះឲ្យជាសះស្បើយ ។ កាលចូលទៅរកព្រះថេរៈ ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ បុគ្គលដែលធ្វើកម្មជាហេតុទៅកាន់នរកហើយ គប្បីផុតចាកនរកបានដែរឬហ្ន៎ ។ ព្រះថេរៈទូលថា ផុតបាន មហាបពិត្រ បើបុគ្គលនោះធ្វើបុណ្យឲ្យច្រើន ទើបឲ្យព្រះរាជាតាំងនៅក្នុងសរណៈនិងសីល ។ ព្រះរាជាតាំងនៅក្នុងសរណៈនិងសីលនោះហើយ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ បានជាព្រះសោតាបន្ន ។ ឯបុរសដែលដោតដោយឈើអណ្តោត កាលជាសះស្បើយ ក៏កើតសេចក្តីសង្វេគ បួសក្នុងពួកភិក្ខុ មិនយូរមិនប៉ុន្មានក៏សម្រេចអរហត្ត ។ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលសម្តែងរឿងនោះ ទើបពោលគាថាទាំងឡាយថា

ស្តេចលិច្ឆវីនោះ ពោលពាក្យដូច្នោះហើយ ក៏មានពួកទាសៈ
ចោមរោម យាងចូលទៅក្នុងទីនោះ លុះចូលទៅក្រុងនោះ

ហើយ ទ្រង់យាងចូលទៅក្នុងព្រះរាជនិវេសន៍ របស់ព្រះអង្គវិញ ។ លំដាប់នោះ ស្តេចលិច្ឆវី ធ្វើនូវកិច្ចទាំងឡាយជារបស់គ្រហស្ថក្នុងវេលាព្រឹកហើយ ក៏ស្រង់ផង សោយនូវសុគន្ធ-រសផង រួចបាននូវឱកាស ក៏ជ្រើសរើសនូវសំពត់បាន ៨ គូ អំពីហិបហើយ ក៏ឲ្យពួកទាសៈកាន់យកតាមទៅ ។ ស្តេចលិច្ឆវីនោះ ចូលទៅឯប្រទេសនោះ បានឃើញសមណៈនោះ អ្នកមានចិត្តស្ងប់រម្ងាប់ កំពុងវិលត្រឡប់ពីគោចរ ជាបុគ្គលត្រ-ជាក់ត្រជុំ គង់នៅក្រោមម្លប់ឈើ ។ លុះស្តេចលិច្ឆវីចូលទៅដល់ហើយ ក៏ពោលទៅនឹងសមណៈនោះ រួចហើយក៏សួរនូវការមិនមានអាពាធនិងការនៅជាសុខសប្បាយ (ហើយទូល) ថា បពិត្រលោកដ៏ចម្រើន ខ្ញុំជាស្តេចលិច្ឆវីក្នុងក្រុងវេសាលី អ្នកផងតែងស្គាល់ខ្ញុំថា ជាស្តេចលិច្ឆវីឈ្មោះ អម្ពសក្ករៈ ។ បពិត្រលោកដ៏ចម្រើន សូមលោកទទួលសំពត់ទាំង ៨ គូ របស់ខ្ញុំនេះចុះ បពិត្រលោកដ៏ចម្រើន ខ្ញុំសូមប្រគេនដល់លោក ខ្ញុំមកក្នុងទីនេះ ព្រោះប្រយោជន៍នោះឯង គួរឲ្យខ្ញុំមានចិត្តត្រេកអរ ។

ព្រះថេរៈតបថា

ពួកសមណព្រាហ្មណ៍ដែលមកអំពីទីឆ្ងាយ តែងតែចៀសវាង នូវនិវេសន៍ របស់ព្រះអង្គ បាត្រទាំងឡាយ តែងធ្លាក់បែក

សង្ឃាដិទាំងឡាយតែងតែរហែកដាច់ដាច ក្នុងនិវេសន៍របស់ព្រះអង្គ ។ម្យ៉ាងទៀត ពួកសមណៈដទៃ មានក្បាលសំយុងចុះ រមែងធ្លាក់ចុះដោយជើងទាំងឡាយ ពោលគឺជើង ( របស់ព្រះអង្គ ) កាលបើព្រះអង្គបៀតបៀននូវបព្វជិតប្រាកដដូច្នោះហើយ ពួកសមណៈ រមែងដល់នូវអំពើដែលព្រះអង្គធ្វើ ។ព្រះអង្គមិនដែលឲ្យប្រេង សូម្បីដោយចុងស្បូវផង មិនប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវផង ព្រះអង្គសមាទាន កាន់យកតែអាជ្ញារបស់មនុស្សអន្ធពាល ដោយព្រះអង្គឯង បុគ្គលបែបហ្នឹងឈ្មោះថាកំណាញ់ស្វិតស្វាញ ជាអ្នកមិនសង្រួម ។ កាលបើយ៉ាងហ្នឹង តើព្រះអង្គ ឃើញនូវហេតុអ្វី តាមដោយហេតុអ្វីបានជាព្រះអង្គធ្វើនូវការចែករំលែក ជាមួយនឹងអាត្មាភាព ។

ស្តេចត្រាស់ថា

បពិត្រលោកដ៏ចម្រើន លោកពោលពាក្យណា ខ្ញុំក៏ទទួលស្តាប់នូវពាក្យនោះ ។

ព្រះថេរៈតបថា

ព្រះអង្គធ្វើពួកសមណព្រាហ្មណ៍ ឲ្យវង្វេងហើយ ។

ស្តេចត្រាស់ថា

បពិត្រលោកដ៏ចម្រើន ខ្ញុំជាបុគ្គលត្រូវការនឹងលេង មិនមានចិត្តប្រទូស្តឡើយ ខ្ញុំធ្វើអំពើអាក្រក់នេះមែនហើយ បុគ្គលក្មេង

ក្តី កំលោះក្តី ដែលមានទ្រព្យតិច តែងទទួលទុក្ខព្រោះតែសន្សំបាបដោយការលេង ជាបុគ្គលមានចំណែកនៃភាពជាអ្នកអាក្រាត អ្វីដែលដល់នូវទុក្ខយ៉ាងធ្ងន់ ជាងភាពអាក្រាតនោះរបស់ប្រេតនោះ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំឃើញប្រេតនោះគួរឲ្យកើតសង្វេគ ទើបឲ្យទាន ព្រោះសង្វេគនោះជាបច្ច័យ បពិត្រលោកដ៏ចម្រើន សូមលោកទទួលសំពត់ទាំង ៨ គូចុះ ទក្ខិណាទាន ( ដែលខ្ញុំប្រគេនហើយ ) នេះ សូមឲ្យបានស្រេចដល់យក្សចុះ ។

ព្រះថេរៈតបថា

ការមិនចេះអស់ ចូរមានដល់ព្រះអង្គ កាលឲ្យទាន ដែលអ្នកប្រាជ្ញមានព្រះពុទ្ធជាដើមទ្រង់សរសើរហើយ ដោយប្រការដ៏ច្រើនដោយពិត ឯអាត្មានឹងទទួលសំពត់របស់ព្រះអង្គទាំង ៨ គូ សូមទក្ខិណាទានសម្រេចដល់យក្សចុះ ។

លំដាប់នោះឯង ស្តេចលិច្ឆវីនោះ ក៏ជម្រះសម្អាត ហើយប្រគេនសំពត់ ៨ គូដល់ព្រះថេរៈ ព្រះថេរៈបានទទួលសំពត់ ៨ គូនោះហើយ ស្តេចលិច្ឆវី បានឃើញនូវយក្ស ស្លៀកដណ្តប់សំពត់ ។ ស្តេចលិច្ឆវី បានទតឃើញប្រេតនោះ មានខ្លួនប្រោះព្រំដោយខ្លឹមចន្ទន៍ ហើយឡើងជិះសេះអាជានេយ្យមានរូបដ៏ប្រសើរ មានគ្រឿងប្រដាប់គ្រប់គ្រាន់ មានសំពត់

ស្បៀកដណ្ដប់ដ៏ស្អាត មានបរិស័ទចោមរោម ដល់នូវឫទ្ធិជាយក្សយ៉ាងធំ ។ លុះស្ដេចលិច្ឆវីនោះ ទតឃើញប្រេតនោះហើយ ក៏មានព្រះហឫទ័យសោមនស្ស ខ្ពស់អណ្ដែតឡើងមានព្រះហឫទ័យត្រេកអរ មានសភាពដ៏ប្រសើរល្អ មានចក្ខុព្រោះបានឃើញនូវកម្មមានផលដ៏ធំផង ធ្វើឲ្យជាក់ច្បាស់នូវប្រេតដែលខ្លួនបានឃើញដោយខ្លួនឯង ។ ស្ដេចលិច្ឆវី បានចូលទៅរកប្រេតនោះ ហើយមានព្រះបន្ទូលថា យើងនឹងឲ្យទានដល់ពួកសមណព្រាហ្មណ៍ ឯវត្ថុបន្តិចបន្តួច ដែលយើងមិនត្រូវឲ្យ មិនមានទេ ម្នាលយក្ស អ្នកមានឧបការៈដល់យើងច្រើនណាស់ ។

ប្រេតតបថា

បពិត្រស្ដេចលិច្ឆវី ព្រះអង្គបានឲ្យទានទាំងឡាយ ចំពោះតែបច្ច័យមួយ ការឲ្យទាននេះ មិនមែនសោះសូន្យឡើយ ខ្ញុំជាអមនុស្សធ្វើជាសាក្សីជាមួយព្រះអង្គជាមនុស្ស ។

ស្ដេចលិច្ឆវីតបថា

អ្នកជាគតិ ជាផៅពង្ស ជាការនាំមុខ និងជាមិត្តសំឡាញ់និងជាទេវតារបស់យើង យើងសូមប្រណម្យអញ្ជលី ចំពោះអ្នក ម្នាលយក្ស យើងចង់ឃើញអ្នកម្ដងទៀត ។

ប្រេតតបថា

បើព្រះអង្គជាអ្នកមិនមានសទ្ធា ជាបុគ្គលកំណាញ់ មានចិត្តវិបត្តិហើយ ព្រះអង្គបានឃើញខ្ញុំដោយហេតុនោះឯង ទុក្ខជាខ្ញុំឃើញ ក៏មិននិយាយរកចំពោះព្រះអង្គដែរ ។ បើព្រះអង្គជាអ្នកគោរពក្នុងធម៌ ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះជាអណ្តូងរបស់ពួកសមណព្រាហ្មណ៍ យ៉ាងនេះ ទើបព្រះអង្គអាចឃើញខ្ញុំបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំឃើញហើយនិយាយចំពោះព្រះអង្គថា ព្រះអង្គចូរដោះបុរសនេះ អំពីឈើអណ្តោតឲ្យឆាប់ទៅ យើងបានធ្វើជាសាក្សី ព្រោះហេតុតែបុរសណា យើងរមែងដឹង ព្រោះហេតុតែបុរសដែលគេដោតដោយឈើអណ្តោត យើងទាំងនោះបានធ្វើជាសាក្សី ដល់គ្នានឹងគ្នា ។ បើបុរសដែលដោតលើឈើអណ្តោតនេះ បានរួចឆាប់ គប្បីប្រព្រឹត្តធម៌ដោយគោរព ទើបបុរសនោះរួចអំពីនរកនោះបាន កម្មនោះនឹងទៅជាកម្មដែលបុរសនោះ គប្បីទទួលក្នុងភពដទៃ ។ សូមព្រះអង្គ ស្តេចចូលទៅរកកប្បិតកភិក្ខុ ហើយចាត់ចែងភោជនាហារក្នុងកាលដ៏គួរ ជាមួយនឹងលោក ហើយអង្គុយចំពោះមុខលោក ដោយព្រះអង្គឯង ហើយចូរសួរលោកចុះ លោកគង់ប្រាប់សេចក្តីនេះដល់ព្រះអង្គ ។ សូមព្រះអង្គចូលទៅរកភិក្ខុនោះ ហើយសួរចុះ ព្រោះភិក្ខុនោះត្រូវការបុណ្យ មិនមានចិត្តប្រទូស្តទេ ភិក្ខុនោះ ដឹងយ៉ាងណា

ក៏នឹងប្រាប់នូវធម៌ទាំងអស់យ៉ាងនោះ ដែលព្រះអង្គស្តាប់ហើយក្តី មិនដែលស្តាប់ហើយក្តី កាលបើព្រះអង្គស្តាប់ លោកនឹងសម្តែងប្រាប់នូវធម៌ផង នូវសុគតិផង ។

ស្តេចលិច្ឆវីនោះ ចរចានឹងគ្នាក្នុងទីស្ងាត់ ក្នុងទីនោះ ហើយធ្វើឲ្យជាសាក្សី ជាមួយនឹងអមនុស្ស ហើយចៀសចេញទៅកាន់សំណាក់នៃស្តេចលិច្ឆវីទាំងឡាយ លំដាប់នោះស្តេចបានពោលចំពោះបរិសទ្យដែលមកប្រជុំគ្នា ។

ស្តេចលិច្ឆវីត្រាស់ថា

អ្នកដ៏ចម្រើនទាំងឡាយ ចូរស្តាប់ពាក្យយើងមួយម៉ាត់ យើងនឹងបាននូវពរ យើងនឹងបាននូវប្រយោជន៍ បុរសដែលត្រូវគេដោតដោយឈើអណ្តោត ជាអ្នកមានកម្មអាក្រក់ មានអាជ្ញាតាំងទុកហើយ មានសភាពជាមនុស្សជាប់ដោយអាជ្ញា ។ បុរសដែលត្រូវឈើអណ្តោតដោតហើយ មិនរស់ មិនស្លាប់ អស់ ២០ រាត្រីប៉ុណ្ណោះ ឥឡូវនេះ យើងនឹងដោះបុរសនោះ សូមសង្ឃយល់តាមសេចក្តីគាប់ចិត្ត ( របស់យើង ) ចុះ ។

ប្រេតតបថា

សូមព្រះអង្គ ដោះលែងបុរស ដែលជាប់ដោយឈើអណ្តោតនោះផង បុរសដទៃផងឲ្យឆាប់ទៅ នរណាពោលនឹងព្រះអង្គដែលកំពុងធ្វើដូច្នោះ ព្រះអង្គយល់យ៉ាងណា ចូរធ្វើយ៉ាងនោះ

ចុះ ឥឡូវសង្ឃយល់តាមសព្វព្រះទ័យហើយ ។

ស្តេចនោះបានចូលទៅប្រទេសនោះ ហើយបានដោះលែងបុរស ដែលគេដោតដោយឈើអណ្តោតមួយរំពេច ហើយប្រាប់ទៅបុរសនោះថា នែសំឡាញ់មានធុរៈស្មើ ចូរអ្នកកុំភ័យឡើយ ហើយក៏ប្រគល់ឲ្យទៅពួកពេទ្យអ្នកថែរក្សា ។ ទើបស្តេចលិច្ឆវីយាងចូលទៅរកកប្បិតកភិក្ខុ ហើយចាត់ចែងភោជនាហារក្នុងកាលដ៏គួរ មួយអន្លើនឹងកប្បិតកភិក្ខុនោះ ស្តេចលិច្ឆវីអ្នកត្រូវការដោយហេតុ ទើបចូលទៅគង់ជិតហើយ សួរកប្បិតកភិក្ខុនោះ ដែលអង្គុយនៅទីនោះ ដោយព្រះឱស្ឋព្រះអង្គឯងថា បុរសដែលគេដោតដោយឈើអណ្តោត ( ហ្នឹង ) ជាអ្នកធ្វើកម្មអាក្រក់ ត្រូវគេដាក់អាជ្ញាហើយ មានសភាពជាអ្នកជាប់ដោយអាជ្ញា បុរសដែលត្រូវឈើអណ្តោតដោតហើយមិនរស់មិនស្លាប់អស់ ២០ រាត្រីប៉ុណ្ណោះ ។ បពិត្រលោកដ៏ចម្រើនឥឡូវនេះ បុរសនោះ ខ្ញុំបានដោះលែងតាមពាក្យយក្សនុ៎ះហើយ ហេតុតិចតួចដែលបុរសនោះមិនគប្បីទៅនរក មានដែរឬ ។ បពិត្រលោកដ៏ចម្រើន បើមានហេតុ គឺហេតុដែលគួរជឿបាន សូមលោកប្រាប់ដល់យើង យើងស្តាប់ហើយយើង ( នឹងជឿតាមពាក្យរបស់លោក ) ការវិនាសនៃកម្មទាំងនោះក៏មិនមាន សេចក្តីវិនាសរបស់បុរសនោះ ក៏មិនមានក្នុងទីនេះ

ព្រោះមិនបានទទួលនូវផល ។ បើបុរសនោះ គប្បីប្រព្រឹត្តនូវធម៌ទាំងឡាយ មិនប្រមាទ ទាំងយប់ទាំងថ្ងៃដោយគោរព ទើបបុរសនោះ គប្បីរួចចាកនរកនោះបាន កម្មនោះនឹងជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។ ប្រយោជន៍របស់បុរសនុ៎ះ ខ្ញុំបានដឹងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អនុគ្រោះខ្ញុំ ក្នុងកាលឥឡូវនេះ បពិត្រលោកមានប្រាជ្ញាដ៏ក្រាស់ សូមលោកម្ចាស់ទូន្មានប្រៀនប្រដៅខ្ញុំ គួរកុំឲ្យខ្ញុំទៅនរកបាន ។ ព្រះថេរៈតបថា

ព្រះអង្គមានព្រះហឫទ័យជ្រះថ្លា ចូរដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាសរណៈ ក្នុងថ្ងៃនេះឯង មួយទៀត ព្រះអង្គចូរសមាទាន នូវសិក្ខាបទទាំង ៥ កុំឲ្យដាច់ធ្លុះធ្លាយឡើយ ។ ចូរព្រះអង្គវៀរចាក បាណាតិបាតឲ្យធាប់ ចូរវៀរចាកទ្រព្យដែលគេមិនឲ្យក្នុងលោកចេញ កុំសោយនូវទឹកស្រវឹងផង កុំកុហកផង ចូរត្រេកអរតែនឹងមហេសី របស់ព្រះអង្គផង ។ សូមព្រះអង្គ សមាទាននូវឧបោសថសីលដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះ ជាកុសលឲ្យផលជាសុខចុះ ។

សូមព្រះអង្គប្រទាននូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ បាយនិងទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះពួកបុគ្គល អ្នកមានចិត្តត្រង់ បុណ្យរមែង

ចម្រើនសព្វៗកាល មួយទៀត សូមព្រះអង្គ ញុំាងពួកភិក្ខុ អ្នកបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ឲ្យ ឆ្អែតដោយបាយ និងទឹក បុណ្យមែងចម្រើនសព្វៗ កាល ។ កាលបើបុរសនោះ ប្រព្រឹត្តនូវធម៌ទាំងឡាយ មិនប្រមាទទាំង យប់ទាំងថ្ងៃ ដោយគោរពយ៉ាងនេះហើយ ទើបរួចចាកនរក បាន កម្មនោះនឹងទៅជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។

ស្តេចលិច្ឆវីមានព្រះឱង្ការថា

ខ្ញុំមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជា សរណៈ ក្នុងថ្ងៃនេះឯង មួយទៀត ខ្ញុំសមាទាននូវ សិក្ខាបទ ទាំង ៥ មិនឲ្យដាច់ធ្លុះធ្លាយ ខ្ញុំវៀរចាកបាណាតិបាត យ៉ាង ដាច់ ខ្ញុំវៀរចាកអទិន្នាទានក្នុងលោក ខ្ញុំមិនផឹកទឹកស្រវឹងមិន និយាយពាក្យមុសា ខ្ញុំត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន ។ ខ្ញុំ សមាទាន នូវឧបោសថសីលដ៏ឧត្តម ប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ នេះជាកុសល ឲ្យផលជាសុខ ។

ខ្ញុំឲ្យនូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ ទីដេក ទីអង្គុយ បាយ ទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះ ពួកភិក្ខុ អ្នកបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ខ្ញុំជាអ្នកត្រេកអរ ក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយ មិន កម្រើកឡើយ ។

( បណ្ដាពួកឧបាសក ) ក្នុងក្រុងវេសាលី ស្ដេចលិច្ឆវីព្រះនាមអម្ពសក្ខរៈ ជាឧបាសកម្នាក់ ប្រាកដដូច្នោះ ក្នុងក្រុងវេ-សាលី ជាអ្នកមានសទ្ធាផង មានចិត្តទន់ភ្លន់ផង ជាអ្នកធ្វើនូវឧបការៈ ទំនុកបម្រុងភិក្ខុសង្ឃដោយគោរព ក្នុងកាលនោះផង ។ បុរសដែលត្រូវគេដោតដោយឈើអណ្ដោត ឥតមានរោគ មានតែសិរីនិងសុខ បានចូលទៅកាន់ផ្នួស ជនទាំង ២ នាក់ ក៏បានសម្រេចនូវសាមញ្ញផលទាំងឡាយ ( តាមសមគួរ ) ព្រោះអាស្រ័យនឹងព្រះថេរៈឈ្មោះកប្បិតកៈដ៏ឧត្តម ។ ការសេពគប់នឹងពួកសប្បុរស អ្នកស្ងប់ អ្នកដឹង ដូច្នេះ រមែងមានផលច្រើន បុរសដែលដេកលើឈើអណ្ដោតបានសម្រេចនូវផលដ៏ប្រសើរ ឯស្ដេចលិច្ឆវីអម្ពសក្ខរៈ បានសម្រេចផលតូច ( សោតាបត្តិផល ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាសូបគច្ឆន្តំ** ប្រែថា ចូលទៅកាន់ទីប្រ-ថាប់ ។ បទថា **គិហិកិច្ចានិ** បានដល់ កិច្ចដោយទ្រព្យដែលអ្នកគ្រប់គ្រងផ្ទះគប្បីធ្វើ ។ បទថា **វិចេយ្យ** បានដល់ គប្បីជ្រើសរើសយកសំពត់ល្អៗ ។ បទថា **បដិក្កន្តំ** បានដល់ ត្រឡប់អំពីបិណ្ឌបាត ។ ដោយហេតុនោះ ទើបលោកពោលថា កំពុងវិលត្រឡប់ពីគោចរ ។ បទថា **អវោច** សេចក្ដីថា ព្រះរាជាបានត្រាស់ថា បពិត្រលោកដ៏ចម្រើន ខ្ញុំជាស្ដេចលិច្ឆវីក្នុងក្រុងវេសាលី ជាដើម ។

បទថា **វិនាលយន្តិ** បានដល់ រមែងហែកបំផ្លាញ ។ បទថា **ឆាត-កុមារិកាហិ** បានដល់ ត្រូវប៉ូវថៅ គឺជើង ។ បទថា **ឆាតយន្តិ** ប្រែថា រមែងឲ្យដួលចុះ ។

បទថា **តិណោន** ប្រែថា ដោយចុងស្បូវ ។ បទថា **មូឡ្ហស្ស មគ្គម្បិន ចាវទាសិ** សេចក្តីថា ទ្រង់មិនបានប្រាប់សូម្បីផ្លូវដល់អ្នកវង្វេងផ្លូវ ដោយគិតថា បុរសនេះចូរវង្វេងក្នុងផ្លូវនេះ ដោយអាការយ៉ាងនេះ ។ ពិតហើយព្រះរាជានេះជាអ្នកច្រើនដោយការលេង ។ បទថា **សយមាទិយាសិ** សេចក្តីថា ខ្លួនឯងដណ្តើមយកឈើប្រត់អំពីដៃរបស់មនុស្សខ្វាក់ ។ បទថា **សំវិភាគំ ករោសិ** សេចក្តីថា ទ្រង់បែងចំណែកមួយអំពីវត្ថុដែលខ្លួនបរិភោគឲ្យ ។

ដោយបទថា **បច្ចេមិ ភន្តេ យំ ត្វំ វទេសិ** នេះ ព្រះរាជាទ្រង់សម្តែងថា លោកដ៏ចម្រើន ខ្ញុំដឹងចំពោះពាក្យដែលលោកពោលដោយន័យជាដើមថា បាត្រទាំងឡាយតែងធ្លាក់បែក វត្ថុទាំងអស់នោះឯង ខ្ញុំធ្វើនិងឲ្យអ្នកដទៃធ្វើ ។ បទថា **ឯតម្បិ** បានដល់ វត្ថុនេះខ្ញុំធ្វើ ក៏បំណាងនឹងលេង ។

បទថា **ខិឌ្ឌាយ** ប្រែថា ដោយការលេង ។ បទថា **បសវិត្វា** ប្រែថា បង្ក ( សន្សំ ) ហើយ ។ បទថា **វេទេតិ** ប្រែថា រមែងសោយ ។ បទថា **អសមត្តភោគី** ប្រែថា មានភោគៈមិនបរិបូណ៌ ដើម្បីនឹងសម្តែងថា ប្រេតមិនជាអ្នកមានភោគៈបរិបូណ៌នោះឯង ទើបត្រាស់ថា បុគ្គលក្មេងក្តី កំលោះក្តីជាដើម ។ បទថា **ឧគ្គនិយស្ស** បានដល់ ជាអ្នកអាក្រាត ។ បទថា **កឹសុ តតោ ទុក្ខតរស្ស ហោតិ** សេចក្តីថា ឈ្មោះថា ទុក្ខអ្វីដែលជាទុក្ខជាង

*ការអាក្រាតកាយនោះ មានដល់ប្រេតនោះ ។ បទថា* **យក្ខស្សិមា គច្ឆន្តុ ទក្ខិណាយោ** *សេចក្តីថា សូមទក្ខិណា គឺសំពត់ដែលខ្ញុំឲ្យនេះសម្រេចដល់ប្រេត ។*

*បទថា* **ពហុធា បសដ្ឋំ** *សេចក្តីថា ដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរទុកដោយប្រការសន្ធឹកសន្ធាប់ ។ បទថា* **អក្ខយធម្មមត្ថុ** *បានដល់ សូមទានវត្ថុនេះកុំបីអស់ទៅជាធម្មតា ។ បទថា* **អាចមយិត្វា** *បានដល់ ខ្ពុរមាត់មុនលាងដៃនិងជើង ។*

*បទថា* **ចន្ទនសារលិត្តំ** *ប្រែថា លាបដោយខ្លឹមចន្ទន៍ ។ បទថា* **ឧឡារវណ្ណំ** *ប្រែថា មានរូបដ៏ប្រសើរ ។ បទថា* **បរិវារិតំ** *បានដល់ ចោមរោមដោយបរិវារដែលមានការប្រព្រឹត្តតាម ។ បទថា* **យក្ខមហិទ្ធិបត្តំ** *បានដល់ ដែលមានយក្ខឫទ្ធិ គឺទេវឫទ្ធិធំ ។ បទថា* **តមេនមវោច** *កាត់បទជា* **តមេនំ អវោច** *បានត្រាស់ពាក្យនេះ ( ដល់ប្រេតនោះ ) ។*

*ដោយបទថា* **ឯកាទេសំ អទាសិ** *ព្រះរាជាត្រាស់សំដៅដល់ការឲ្យសំពត់ជាចំណែកមួយក្នុងបណ្តាបច្ច័យ ៤ ។ បទថា* **សក្ខី** *បានដល់ ភាពជាបន្ទាល់ ។ បទថា* **មមាសិ** *កាត់បទជា* **មេ អាសិ** *។ បទថា* **ទេវតា មេ** *មានវាចាប្រកបសេចក្តីថា អ្នកបានជាទេវតារបស់យើង ។*

*បទថា* **វិប្បដិបន្នចិត្តោ** *បានដល់ ដែលមានចិត្តប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិ អធិប្បាយថា ដែលលះបដិបទាត្រូវ ប្រព្រឹត្តបដិបទាមិនត្រូវ ។ បទថា* **យតោនិទានំ** *បានដល់ មានវត្ថុណាជានិមិត្ត គឺមកកាន់សម្នាក់របស់បុគ្គលណាជា*

ហេតុ ។

បទថា **សំវិភជិត្វា** បានដល់ ធ្វើនូវការចែករំលែកទាន ។ បទថា **សយំ មុក្ខេន្ធបដិសជ្ជ បុច្ឆ** សេចក្តីថា សូមព្រះអង្គកុំបញ្ជូនមនុស្សដទៃទៅ សូមទ្រង់ចូលទៅអង្គុយសាកសួរក្នុងទីចំពោះមុខ ។

បទថា **សន្និសជ្ជំ** ប្រែថា អង្គុយប្រជុំគ្នា ។ បទថា **លភិស្សាមិ អត្ថំ** សេចក្តីថា យើងនឹងបានប្រយោជន៍ដែលយើងប្រាថ្នា ។ បទថា **បណិហិត-ទណ្ឌោ** បានដល់ បានតាំងអាជ្ញាក្នុងខ្លួនទុក ។ បទថា **អនុសត្តរូបោ** បានដល់ មានជីវិតបានព្រោះព្រះរាជា ។ បទថា **វីសតិរត្តិមត្តា** សេចក្តីថា កន្លងទៅ ២០ រាត្រី ។ បទថា **តាហំ** កាត់ជា **តំ អហំ** ។ បទថា **យថា មតី** បានដល់ តាមការពេញចិត្តរបស់យើង ។

បទថា **ឯតញ្ច អញ្ញញ្ច** សេចក្តីថា បុរសនេះត្រូវឈើអណ្តាតដោត បុរសដទៃត្រូវដាក់រាជអាជ្ញា ។ បទថា **លហុំ បមុញ្ច** ប្រែថា ដោះលែងដោយរហ័ស ។ បទថា **កោ តំ វទេថ តថា ករោន្តំ** សេចក្តីថា បុគ្គលណាក្នុងដែនវជ្ជីនេះ គប្បីប្រាប់បុគ្គលធ្វើកម្មដែលត្រូវតាមធម៌នោះថា មិនឲ្យដោះលែង អធិប្បាយថា ទោះបីជាបុគ្គលណាមួយក៏មិនបានដើម្បីពោលយ៉ាងនោះ ។

បទថា **តិកិច្ឆការាណញ្ច** បានដល់ អ្នកព្យាបាល ( គ្រូពេទ្យ ) ។

បទថា **យក្ខស្ស វចោ** បានដល់ ពាក្យរបស់ប្រេត លោកសម្តែងថា លោកដ៏ចម្រើន ខ្ញុំបានធ្វើយ៉ាងនោះតាមពាក្យរបស់ប្រេតនោះ ។

បទថា **ធម្មាធិ** បានដល់ ធម៌ គឺបុណ្យដែលអាចគ្របសង្កត់កម្មអាក្រក់ដែលបានធ្វើក្នុងកាលមុន ។ បទថា **កម្មំ សិយា អញ្ញត្រ វេទនីយំ** បានដល់កម្មអាក្រក់ដែលនាំឲ្យកើតផលនោះ ឈ្មោះថាជាអហោសិកម្ម ឯកម្មដែលឲ្យផលឲ្យកើតក្នុងភពតៗទៅ រមែងជាផលដែលគប្បីសោយក្នុងភពដទៃ គឺភពជាបន្តក្នុងកាលប្រព្រឹត្តទៅក្នុងសង្សារវដ្ត ។

បទថា **ឥមញ្ច** ព្រះថេរៈពោល ព្រោះធ្វើអធិប្បាយថា ពាក្យដែលខ្ញុំពោលជិតឬប្រចក្សដល់សិក្ខានោះ ។ បទថា **អរិយំ អដ្ឋង្គវេនុបេតំ** សេចក្តីថា ឧបោសថសីលដ៏ឧត្តមដែលបុគ្គលនោះចូលដល់ គឺប្រកបដោយអង្គ ៨ មានចេតនាដែលវៀរចាកបាណាតិបាតជាដើម ឈ្មោះថា ប្រសើរ ព្រោះអត្ថថា បរិសុទ្ធ ។ បទថា **កុសលំ** បានដល់ មិនមានទោស ។ បទថា **សុខិន្ទ្រិយំ** ប្រែថា មានសុខជាផល ។

បទថា **សទា បុញ្ញំ បវឌ្ឍតិ** សេចក្តីថា កាលបុគ្គលធ្វើបុណ្យតែម្តងហើយមិនផ្អែតក្នុងចិត្តថា ត្រឹមតែដោយបុណ្យប្រមាណប៉ុណ្ណេះ ហើយទើបបំពេញសុចរិតជាបន្ត បុណ្យនៃបុគ្គលនោះ រមែងចម្រើនសព្វកាល ឬកាលបុគ្គលនោះ បំពេញសុចរិតតៗមក ផលបុណ្យ គឺបុណ្យរមែងចម្រើន គឺពេញប្រៀបក្រៃលែងឡើង ។

កាលព្រះថេរៈពោលយ៉ាងនេះ ព្រះរាជាមានព្រះទ័យសង្វេគចាកទុក្ខក្នុងអបាយ មានការជ្រះថាក្នុងព្រះរតនត្រ័យ បុញ្ញធម៌ចម្រើនក្រៃលែងឡើង បន្តអំពីនោះ ទើបសមាទានសរណៈនិងសីល ត្រាស់ពាក្យជាដើមថា ខ្ញុំសូម

ដល់ព្រះពុទ្ធថាជាសរណៈក្នុងថ្ងៃនេះឯង ។

បណ្ដាបទទាំងនោះ បទថា **ឯតាធិសោ** បានដល់ មានរូបតាមដែលពោលហើយនេះ ។ បទថា **វេសាលិយំ អញ្ញតរោ ឧបាសកោ** សេចក្ដីថា ជាឧបាសកមួយរូបក្នុងបណ្ដាឧបាសកច្រើនពាន់ក្នុងក្រុងវេសាលី ។ បទថា **សទ្ធោ** ជាដើម លោកពោលដើម្បីសម្ដែងភាពដែលព្រះបាទអម្ពសក្ខរៈនោះកើតដោយប្រការដទៃចាកភាវៈដែលមានក្នុងកាលមុន ព្រោះអាស្រ័យកល្យាណមិត្ត ។ ពិតហើយ ក្នុងកាលមុន ព្រះបាទអម្ពសក្ខរៈនោះ ជាអ្នកមិនមានសទ្ធា ជាមនុស្សគ្រោតគ្រាត ជេរភិក្ខុទាំងឡាយ មិនមែនជាឧបដ្ឋាករបស់សង្ឃ តែឥឡូវនេះ ជាអ្នកមានសទ្ធាទន់ភ្លន់ និងជាអ្នកឧបដ្ឋាកភិក្ខុសង្ឃក្នុងកាលនោះដោយគោរព ។ បណ្ដាបទទាំងនោះ បទថា **ការករោ** ប្រែថា ជាអ្នកធ្វើឧបការៈ ។

បទថា **ឧភោបិ** បានដល់ ជនទាំង ២ គឺបុរសដែលត្រូវដោតដោយឈើអណ្ដោតនិងព្រះរាជា ។ បទថា **សាមញ្ញផលានិ អជ្ឈគុំ** បានដល់ ជាអ្នកសម្រេចសាមញ្ញផលតាមសមគួរ ។ ដើម្បីសម្ដែងតាមសមគួរ ទើបលោកពោលពាក្យនេះទុកថា បុរសដែលដេកលើឈើអណ្ដោត បានសម្រេចនូវផលដ៏ប្រសើរ ( អរហត្តផល ) ឯស្ដេចលិច្ឆវីអម្ពសក្ខរៈបានសម្រេចផលតូច ( សោតាបត្តិផល ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ផលំ កនិដ្ឋំ** លោកសំដៅដល់ សោតា-បត្តិផល តែក្នុងទីនេះ កាលពោលដោយអត្ថ ពាក្យដែលលោកមិនបានចែក

ជីងបានឆាយហើយ ។

ព្រះកប្បិតកៈបានទៅដល់ក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះសាស្តា បានក្រាបទូលភាពដែលព្រះរាជា ប្រេត និងខ្ទនពោលហើយយ៉ាងនេះ ដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយសម្តែងធម៌ដល់បរិស័ទ ដែលដល់ព្រមហើយ ទេសនាមានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

## អដ្ឋកថា អម្ពសក្ខរប្រេតចប់

# រឿង សេរិស្សកប្រេត ទី ២

[ ៣៧ ] ការប្រជុំនៃយក្សនិងពាណិជ្ជទាំងឡាយ អ្នកទាំងឡាយចូរស្តាប់

។ បេ ។

( អ្នកប្រាជ្ញគប្បីមើលក្នុងរឿងទី ១០ នៃសុនិក្ខិត្តវគ្គទី ៧ ក្នុងវិមានវត្ថុចុះ ) ។

ចប់ រឿង សេរិស្សកប្រេតទមី ២ ។

# អដ្ឋកថា សេរិស្សកប្រេត

[ ៣៧ ] រឿងសេរីសកប្រេតនេះ មានពាក្យផ្តើមថា **សុណោថ យក្ខស្ស វាណិជានញ្ច** ដូច្នេះ ។ ព្រោះហេតុដែលរឿងនោះ មិនពិសេសជាងរឿងសេរីសកវិមាន ដូច្នោះពាក្យដែលគួរពោលក្នុងអត្ថុប្បត្តិហេតុនិងក្នុងគាថានោះ ព្រះអដ្ឋកថាចារ្យបានពោលទុកហើយក្នុងអដ្ឋកថាវិមានវត្ថុ ឈ្មោះបរមត្ថទីបនី ដូច្នោះគប្បីជ្រាបដោយន័យ ដែលបានពោលទុកហើយ ក្នុងអដ្ឋកថាវិមានវត្ថុនោះឯង ដូច្នេះ ។

អដ្ឋកថា សេរិស្សកប្រេតចប់

# រឿង ឆត្តិកាប្រេត ទី ៣

[ ៣៨ ] ព្រះរាជាព្រះនាមបិង្គលកៈ ជាធំក្នុងសុរដ្ឋប្រទេស ស្តេចទៅកាន់គំនាល់នៃព្រះបាទមោរិយៈ ( ព្រះបាទធម្មាសោក ) ហើយស្តេចត្រឡប់មកសុរដ្ឋប្រទេសវិញ ។ ព្រះរាជាស្តេចយាងកាត់កក់ ក្នុងវេលាថ្ងៃត្រង់ដ៏ក្តៅ ក៏បានទតឃើញផ្លូវ គួរជាទីត្រេកអរ ជាផ្លូវដែលប្រេតទាំងឡាយនិម្មិតហើយ ទើបព្រះរាជាទ្រង់ត្រាស់នឹងនាយសារថីថា ផ្លូវនេះ គួរជាទីត្រេកអរ ជាផ្លូវដ៏ក្សេមក្សាន្ត ប្រកបដោយសួស្តី ជាផ្លូវមិនមានឧបទ្រពឡើយ ម្នាលសារថី ចូរអ្នកទៅតាមផ្លូវនេះវិញ ( ព្រោះយើង ) ទៅតាមផ្លូវនេះ ជិតដល់សុរដ្ឋប្រទេសហើយ ដូច្នេះ រួចព្រះបាទបិង្គលកៈក្នុងសុរដ្ឋប្រទេស ក៏បានទៅតាមផ្លូវនោះ ជាមួយនឹងសេនាប្រកបដោយអង្គ ៤ ។

បុរសមានសភាពតក់ស្លុត បានក្រាបទូលស្តេចក្នុងសុរដ្ឋប្រទេស ដូច្នេះថា យើងដើរទៅតាមផ្លូវមិនស្រួល ជាទីស្ញប់ស្ញែងព្រឺព្រួចរោម ។ ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ យើងដើរទៅតាមផ្លូវមិនស្រួលក្នុងទីជិតនៃពួកយមបុរសប្រេត ឯក្លិនអមនុស្ស បក់មក ទាំងមានសំឡេងគឹកកងដ៏ខ្លាំង ដ៏អាក្រក់ ក៏ឮមក ។

ព្រះរាជាក្នុងសុរដ្ឋប្រទេស ទ្រង់មានសេចក្តីតក់ស្លុត ទើបត្រាស់ទៅនឹងនាយសារថីដូច្នេះថា យើងដើរទៅពារផ្លូវមិនស្រួល នាំឲ្យស្ញប់ស្ញែង នាំឲ្យព្រឺព្រួចរោម ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ ។ យើងដើរទៅពារផ្លូវមិនស្រួល ក្នុងទីជិតនៃពួកយមបុរសហើយ ឯក្លិនសរីរៈអមនុស្សក៏បក់មក ទាំងសំឡេងគឹកកងរំពងអាក្រក់ក៏ឮមក ។

( ទ្រង់ត្រាស់ដូច្នេះហើយ ) ក៏ឡើងគង់លើជំរំ ហើយទតមើលទៅទិស ទាំង ៤ បានឃើញដើមជ្រៃមួយដើមជារុក្ខជាតផឹកនូវទឹកដោយជើង បរិបូណ៌ ដោយម្លប់ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ព្រះ រាជាត្រាស់ទៅនឹងនាយសារថីថា ដើមឈើធំ ប្រហែលមេឃ មានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ នុ៎ះជាឈើអ្វី ។

សារថីក្រាបទូលថា បពិត្រមហារាជ នោះជាដើមជ្រៃ ជារុក្ខជាតផឹក នូវទឹកដោយជើង បរិបូណ៌ដោយម្លប់ ប្រហែលមេឃមានណពិខៀវ ជាឈើ មានសម្បុរដូចផ្ទៃមេឃ ។

ព្រះរាជាក្នុងសុរដ្ឋប្រទេស ស្តេចទៅត្រង់ដើមឈើធំ ប្រហែលមេឃមាន ពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ។ ព្រះរាជាស្តេចចុះអំពីកជំរំ ហើយ ចូលសំដៅទៅរកដើមឈើ ទ្រង់គង់ក្រោមម្លប់ឈើជាមួយនឹងអាមាត្យនិងជន ជាបរិសទ្យក៏បានទតឃើញកំពង់ទឹកដ៏ពេញនិងនំទាំងឡាយដ៏វិចិត្រ ។

( ប្រេតនោះ ) ក្លែងខ្លួនជាបុរសមានភេទដូចជាទេវតា ស្អិតស្អាងគ្រឿង អាភរណៈទាំងពួង ហើយចូលទៅនិយាយនឹងព្រះរាជា ជាធំក្នុងសុរដ្ឋប្រទេស ដូច្នេះថា បពិត្រមហារាជ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ដំណើរ ព្រះអង្គស្តេចមក ឈ្មោះថា មកអំពីទីមិនឆ្ងាយ បពិត្រព្រះអរិន្ទមរាជ សូម ព្រះ សម្មតិទេពទ្រង់សោយនូវវិសុទ្ធិរស ទ្រង់សោយនូវនំទាំងឡាយ ។

ព្រះរាជាក្នុងសុរដ្ឋប្រទេស ព្រមទាំងអាមាត្យនិងជនជាបរិសទ្យ បាន សោយនូវព្រះវិសុទ្ធិរសផង សោយនូវនំទាំងឡាយផង លុះសោយរួចហើយ

ទ្រង់ត្រាស់សួរដូច្នេះថា អ្នកជាទេវតាឬជាគន្ធព្វឬមួយជាសក្កបុរិន្ទទៈ យើងមិនស្គាល់ បានជាសួរអ្នក យើងស្គាល់អ្នកដូចម្តេចបាន ។

( ប្រេតតបថា ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ បពិត្រមហារាជជាស្តេចក្នុងសុរដ្ឋប្រទេស ខ្ញុំជាប្រេតទេតើ មកនៅក្នុងទីនេះ ។

ព្រះរាជត្រាស់ថា ចុះអ្នកឯង មានសីលធម៌ដូចម្តេច មានសមាចារដូចម្តេច ក្នុងសុរដ្ឋបុរី អ្នកឯងនេះ មានអានុភាពច្រើន ព្រោះអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរដូចម្តេចខ្លះ ។

( ប្រេតតបថា ) បពិត្រព្រះអរិន្ទមៈមហារាជ ជាស្តេចចម្រើនក្នុងដែន សូមព្រះអង្គព្រមទាំងពួកអាមាត្យនិងព្រាហ្មណ៍ បុរោហិត ទ្រង់ព្រះសណ្តាប់ពាក្យខ្ញុំនោះ ។ បពិត្រព្រះទេព ខ្ញុំនៅក្នុងសុរដ្ឋប្រទេស ជាបុរសមានចិត្តអាក្រក់ មានសេចក្តីយល់ខុស ទ្រុស្តសីល កំណាញ់ ជេរប្រទេចផ្តាសាពួកជនដែលកំពុងឲ្យ កំពុងធ្វើ ហាមឃាត់ពួកជនច្រើន ធ្វើអន្តរាយដល់ពួកជនដទៃ ដែលកំពុងឲ្យ ( ខ្ញុំរមែងនិយាយរឿយៗថា ) ផលរបស់ទានមិនមានទេ តើផលនៃការសង្រួម គឺសីលនឹងមានមកពីណា អាចារ្យមិនមាន អ្នកណានឹងទូន្មានបុគ្គលដែលគេមិនទាន់ទូន្មាននោះបាន ។ ពួកសត្វសឹងតែស្មើៗគ្នាទេ ចាំបាច់មានបុគ្គល ជាអ្នកគោរពក្រោតក្រែងត្រកូលរៀមច្បង ( ធ្វើអ្វីទៀត ) កម្លាំងក្តី សេចក្តីព្យាយាមក្តី មិនមានហើយ តើការប្រឹងប្រែងរបស់បុរស មានមកអំពីទីណា ។ ផលរបស់ទានមិនមានទេ បុគ្គលមិនអាចធ្វើ

សត្វដែលមានពៀរឲ្យស្អាតបាន សត្វបានសេចក្ដីសុខទុក្ខដែលត្រូវបាន កើតពីសេចក្ដីប្រែប្រួលតែងដឹកនាំទៅ ( មិនមែនព្រោះកម្មដែលខ្លួនធ្វើទេ ) ។ មាតាបិតា បងប្អូនមិនមាន លោកដទៃក្រៅពីលោកនេះមិនមាន ការឲ្យទានមិនមាន ការបូជាមិនមាន ការតម្កល់ទាន ( ចំពោះសមណព្រាហ្មណ៍ ) ក៏មិនមាន ។ អ្នកណាកាត់ក្បាលបុរសមិនឈ្មោះថាសម្លាប់បុរសទេ ( ព្រោះ ) គ្មានអ្នកណាសម្លាប់ ( អ្នកណា ) តិចតួចទេ ទុកដូចជាបៀតបៀនក្នុងចន្លោះនៃកាយទាំង ៧ ( មានផែនដីជាដើម ) ដែរ ។ ជីវៈជាសភាវៈផ្ដាច់មិនបាន ទម្លាយមិនបាន ( ព្រោះ ) ជួនកាលមានជ្រុង ៨ ជួនកាលមូលជាដុំ ( មានកំពស់ ) ៥០០ យោជន៍ អ្នកណា ក៏មិនអាចនឹងផ្ដាច់បង់ជីវៈបានឡើយ ។ កាលបើអំបោះហុងគេបោះចោលទៅ អំបោះហុងនោះរមែងរលា យ៉ាងណាមិញ ជីវៈនោះក៏រលាយ៉ាងនោះដែរ ។ បុរសបុគ្គលចេញពីស្រុក ចូលទៅកាន់ស្រុកដទៃទៀត យ៉ាងណាមិញ ជីវៈនោះ ( ចេញពីកាយនេះ ) ចូលទៅកាន់កាយដទៃយ៉ាងនោះដែរ ។ បុរសបុគ្គលចេញពីផ្ទះ ចូលទៅកាន់ផ្ទះដទៃ យ៉ាងណាមិញ ជីវៈនោះ ចូលទៅកាន់កាយដទៃទៀត ក៏យ៉ាងនោះដែរ ។ ពួកពាល ពួកបណ្ឌិត នឹងធ្វើសង្សារវដ្ដឲ្យអស់ទៅ ធ្វើទុក្ខឲ្យផុតបាន ទាល់តែអស់មហាកប្បទាំងឡាយ ៨ លាន ៤ សែន ។ សុខនឹងទុក្ខទាំងឡាយ វាល់បានដោយទោណៈទាំងឡាយផង ដោយកញ្ជើទាំងឡាយផង ជិនបុរសរមែងជ្រាបសព្វ ពួកសត្វក្រៅនេះប្រកបដោយសេចក្ដីវង្វេង ។ កាលមុនខ្ញុំជាអ្នកយល់យ៉ាងនេះ ជាអ្នកប្រកបដោយសេចក្ដីវង្វេង មានសេចក្ដីវង្វេង

គ្របសង្កត់ មានសេចក្ដីយល់ខុស ទ្រុស្ដសីល កំណាញ់ ប្រទេចផ្ដាសា ( សមណៈនិងព្រាហ្មណ៍ ) ។ ខាងអាយ ៦ ខែទៀត ខ្ញុំនឹងធ្វើកាលកិរិយា ។ ខ្ញុំមុខជានឹងធ្លាក់នរក មានការក្ដៅក្រហាយដ៏ពន្លឹកដោយពិត ជានរកមានជ្រុង ៤ មានទ្វារ ៤ ដូចជាវាស់ដោយចំណែកដែលចែកស្មើគ្នា ជានរកមានកំពែងដែកព័ទ្ធជុំវិញ គ្របដោយដែក ។ ភូមិនៃនរកនោះជាវិការៈនៃដែក រន្ទាលប្រាលឆ្អៅ ប្រកបដោយភ្លើង ផ្សព្វផ្សាយទៅ ១០០ យោជន៍ជុំវិញសព្វកាល ។ កន្លងទៅ ១ សែនឆ្នាំ ឮសូរសំឡេងកងរំពងក្នុងកាលនោះ ។ បពិត្រមហារាជ ចំណែក ១ សែនកោដិឆ្នាំ ជាគ្រឿងកំណត់ ( អាយុរបស់សត្វដែលឆេះនៅក្នុងនរកនុ៎ះ ) ពួកជនដែលជាមិច្ឆាទិដ្ឋិ ទ្រុស្ដសីល តិះដៀលព្រះអរិយៈ តែងឆេះនៅក្នុងនរកអស់ ១ សែនកោដិឆ្នាំ ។ ខ្ញុំនឹងវេទនាក្នុងនរកនោះ អស់កាលជាយូរអង្វែង ( ព្រោះ ) ផលនៃបាបកម្មហេតុនោះ បានជាខ្ញុំសោកសៅដ៏ក្រៃលែង ។ បពិត្រអរិន្ទមមហារាជ អ្នកចម្រើនក្នុងដែន ព្រះអង្គចូរស្ដាប់ដំណើរនោះ បពិត្រមហារាជ ធីតារបស់ខ្ញុំឈ្មោះនាងឧត្តរា សេចក្ដីចម្រើនចូលមានដល់ព្រះអង្គ ។ នាងឧត្តរាតែងធ្វើនូវកម្មដ៏ចម្រើន ជាអ្នកត្រេកអរក្នុងនិច្ចសីលនិងឧបោសថសីល ត្រេកអរក្នុងទាន ជាអ្នកចែករំលែកទាន ជាអ្នកដឹងនូវពាក្យ ( នៃស្មូម ) មិនមានកំណាញ់ ធ្វើមិនឲ្យដាច់ក្នុងសិក្ខាបទ ជាកូនប្រសាក្នុងត្រកូលដទៃ ជាឧបាសិកានៃព្រះសក្យមុនីសម្ពុទ្ធដ៏មានសិរី ។ ភិក្ខុបរិបូណ៌ដោយសីល ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ជាអ្នកសង្រួមចក្ខុ មានស្មារតីគ្រប់គ្រងទ្វារ បិទបាំង

កាយដោយប្រពៃ ត្រាច់ទៅតាមលំដាប់ប្រេក បានទៅកាន់លំនៅរបស់នាង នោះ ។ បពិត្រមហារាជ សេចក្តីចម្រើនចូរមានដល់ព្រះអង្គ នាងឧត្តរា បាន ឃើញភិក្ខុនោះហើយ បានប្រគេននូវបានីយករកៈ ( តម្រងទឹក ) ដ៏ពេញ ផង នូវនំទាំងឡាយដ៏វិចិត្រផង ( ហើយឧទ្ទិសផលមកឲ្យខ្ញុំយ៉ាងនេះថា ) បពិត្រលោកដ៏ចម្រើន បិតារបស់ខ្ញុំចែកឋានទៅហើយ ទាននេះ សូមសម្រេច ដល់បិតារបស់ខ្ញុំនោះ ។ ផលក៏សម្រេចក្នុងពេលជាលំដាប់ដែលឧទ្ទិសហើយ ខ្ញុំជាអ្នកបានកាមតាមប្រាថ្នា បរិភោគដូចជាស្តេចវេស្សវណ ។ បពិត្រអរិន្ទម មហារាជ ព្រះអង្គអ្នកចម្រើនក្នុងដែន សូមព្រះអង្គស្តាប់នូវដំណើរនោះ ព្រះ ពុទ្ធគេហៅថា បុគ្គលប្រសើរជាងសត្វលោក ព្រមទាំងទេវលោក បពិត្រព្រះ បាទអរិន្ទមៈ សូមព្រះអង្គព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយាដល់នូវ ព្រះពុទ្ធនោះជាសរណៈចុះ ។ ពួកបុរសបុគ្គលបានដល់ព្រះនិព្វាន ដោយសា តែមគ្គប្រកបដោយអង្គ ៨ ប្រការ បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវធម៌ ( អដ្ឋង្គិកមគ្គ ) នោះជាសរណៈចុះ ។ ព្រះអរិយបុគ្គល ៤ ពួក ប្រតិបត្តិក្នុងមគ្គ ព្រះ អរិយបុគ្គល ៤ ពួកឋិតនៅក្នុងផល ព្រះសង្ឃទាំងនុ៎ះ លោកជាអ្នកស្លូត ត្រង់ តាំងនៅមាំក្នុងបញ្ញានិងសីល បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គព្រម ទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវព្រះសង្ឃនោះជាសរណៈចុះ ។

សូមព្រះអង្គ វៀរចាកបាណាតិបាត ឲ្យដាច់ៗ សូមព្រះអង្គ
វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោក សូម

ព្រះអង្គកុំសោយនូវទឹកស្រវឹង កុំមានព្រះឱង្ការកុហក សូម
ព្រះអង្គត្រេកអរតែនឹងព្រះអគ្គមហេសីរបស់ព្រះអង្គ ។

( ព្រះរាជាត្រាស់ថា ) ម្នាលយក្ស អ្នកជាអ្នកប្រាថ្នាសេចក្ដីចម្រើនដល់យើង ម្នាលទេវតា អ្នកជាអ្នកប្រាថ្នាប្រយោជន៍ដល់យើង យើងធ្វើតាមពាក្យរបស់អ្នកហើយ អ្នកជាអាចារ្យរបស់យើង ។ យើងសូមដល់ព្រះពុទ្ធជាសរណៈផង ដល់ព្រះធម៌ជាសរណៈផង ដល់ព្រះសង្ឃដ៏ប្រសើរជាងមនុស្សនិងទេវតា ជាសរណៈផង ។

យើងវៀរចាកបាណាតិបាត យ៉ាងឆាប់រហ័យ យើងលះបង់
ការកាន់យកទ្រព្យ ដែលគេមិនបានឲ្យក្នុងលោក យើងលែង
ផឹកទឹកស្រវឹង លែងនិយាយកុហក យើងជាអ្នកត្រេកអរតែ
នឹងប្រពន្ធរបស់ខ្លួន ។

ម្នាលប្រេត យើងត្រេកអរក្នុងសាសនា របស់ព្រះពុទ្ធទាំងឡាយ បាច ( នូវទិដ្ឋិដ៏អាក្រក់ចោលដូចជាអង្កាម ) ក្នុងទីមានខ្យល់ធំផង បន្សាត់ចោលនូវទិដ្ឋិអាក្រក់ ( ដូចជាសំរាម ) ក្នុងទន្លេ មានខ្សែទឹករហ័សផង ។ លុះព្រះបាទបិង្គលៈ ជាស្ដេចក្នុងដែនសុរដ្ឋ មានព្រះឱង្ការដូច្នេះហើយក៏បានវៀរចាកការយល់ដ៏លាមកចោលចេញ ធ្វើនូវកិរិយាថ្វាយបង្គំព្រះមានព្រះភាគរួចក៏បែរព្រះភក្ត្រចំទៅទិសខាងកើត ឡើងគង់លើរថទៅ ។

**ចប់ រឿងនន្ទិកាប្រេតទី ៣ ។**

# អដ្ឋកថា ធនិ្ទកាប្រេត

[ ៣៨ ] ក្នុងនន្ទកប្រេតនេះ មានពាក្យផ្តើមថា **រាជា បិង្គលកោ ណាម** ដូច្នេះ ជាដើម ។

អត្ថុប្បត្តិហេតុនៃរឿងនោះដូចម្តេច ។

រាប់អំពីព្រះសាស្តាបរិនិព្វានកន្លងទៅបាន ២០០ ឆ្នាំ ក្នុងសុរដ្ឋវិស័យ មានព្រះរាជាមួយអង្គព្រះនាមថា បិង្គលៈ ។ សេនាបតីរបស់ព្រះរាជានោះ ឈ្មោះថា នន្ទកៈ ជាមនុស្សមិច្ឆាទិដ្ឋិ មានការយល់ឃើញខុស ត្រាច់លើកតម្កើងការយល់ខុសផ្សេងៗ ដោយន័យជាដើមថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ដូច្នេះ ។ ធីតារបស់នន្ទកៈនោះ ជាឧបាសិកាឈ្មោះឧត្តរា នន្ទកៈលើកឲ្យត្រកូលដែលស្មើគ្នា ។ ឯនន្ទកសេនាបតីធ្វើកាលកិរិយាហើយ កើតជាវេមានិកប្រេត ត្រង់ដើមជ្រៃធំ ក្នុងព្រៃដែលមានផ្លូវកន្តារឆ្លងកាត់ ។ កាលនន្ទកគហបតី នោះធ្វើកាលកិរិយាហើយ នាងឧត្តរាបានប្រគេនក្អមទឹកពេញដោយទឹកក្រអូបនិងស្អាតត្រជាក់និងផ្តិលដែលពេញដោយនំ ដល់ព្រមដោយពណ៌ ក្លិននិងរសដែលផ្សំដោយនំកុម្មាស ដល់ព្រះខីណាស្រពមួយរូបដោយឧទ្ទិសថា សូមទក្ខិណានេះ សម្រេចដល់បិតារបស់ខ្ញុំចុះ ។ ទឹកដែលជាទិព្វ និងនំដ៏ច្រើនប្រមាណមិនបានប្រាកដដល់ប្រេតនោះ ព្រោះទាននោះ ។ ប្រេតឃើញដូច្នោះ ក៏គិតយ៉ាងនេះថា អញធ្វើកម្មលាមកហ្ន៎ បានឲ្យមហាជនយល់ខុសដោយន័យជាដើមថា ទានដែលទាយកឲ្យហើយរមែងមិនមានផល ដូច្នេះ ឥឡូវនេះ ស្តេចបិង្គលៈយាងទៅទូន្មានដល់ព្រះបាទធម្មាសោក ទ្រង់ប្រទានឱវាទហើយ នឹងត្រឡប់មក ណ្ហើយចុះ អញនឹងបន្ទោបង់នត្ថិកទិដ្ឋិ ។ មិន

យូរប៉ុន្មាន ព្រះបាទបិង្គលៈបានទូន្មានដល់ព្រះបាទធម្មាសោក កាលទឹងយានត្រឡប់ ទើបទ្រង់យានទៅតាមផ្លូវនោះ ។

លំដាប់នោះ ប្រេតនោះនិម្មិតផ្លូវនោះឲ្យបែរមុខទៅកាន់លំនៅរបស់ខ្លួន ។ ក្នុងពេលថ្ងៃត្រង់ ព្រះរាជាយានតាមផ្លូវនោះ ។ កាលព្រះរាជាយានទៅ ផ្លូវខាងមុខប្រាកដ តែផ្លូវខាងក្រោយមិនប្រាកដ ដល់ព្រះអង្គ ។ បុរសដែលដើរក្រោយគេ ឃើញផ្លូវបាត់ទៅ ទើបខ្លាច ស្រែកដោយសំឡេងខ្លាំង រត់ទៅក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ក៏មានព្រះទ័យតក់ស្លុត មានព្រះទ័យសង្វេគ ប្រថាប់នៅលើកដំរី ទតមើលទិសទាំង ៤ ឃើញដើមជ្រៃជាលំនៅរបស់ប្រេត ទើបយានបែរព្រះភក្ត្រទៅកាន់ដើមជ្រៃនោះ មួយអន្លើដោយចតុរង្គិនីសេនា ។ កាលព្រះរាជាយានដល់ទីនោះ ដោយលំដាប់ ប្រេតប្រដាប់ដោយអាភរណៈទាំងពួង ចូលទៅគាល់ព្រះរាជា ធ្វើបដិសណ្ឋារៈថ្វាយនំនិងទឹក ។ ព្រះរាជា មួយអន្លើដោយរាជបរិវារ ទ្រង់ស្រពស្រង់ សោយនំ ហើយសោយទឹក រម្ងាប់ការហត់នឿយក្នុងផ្លូវ ទើបត្រាស់សួរប្រេតដោយន័យជាដើមថា អ្នកជាទេវតា ឬជាគន្ធព្វ ប្រេតបានក្រាបទូលរឿងរបស់ខ្លួនតាំងពីដើមដល់ចប់ ទើបដោះព្រះរាជា ចាកភាពជាមិច្ឆាទិដ្ឋិ ឲ្យតាំងនៅក្នុងសរណៈនិងសីល ដើម្បីសម្តែងរឿងនោះ ព្រះសង្គីតិកាចារ្យទាំងឡាយ ក៏ពោលនូវគាថាទាំងឡាយថា

ព្រះរាជាព្រះនាមបិង្គលកៈ ជាធំក្នុងសុរដ្ឋប្រទេស ស្តេចទៅ
កាន់គំនាល់នៃព្រះបាទមោរិយៈ ( ព្រះបាទធម្មាសោក ) ហើយ

ស្តេចត្រឡប់មកសុរដ្ឋប្រទេសវិញ ។ ព្រះរាជាស្តេចយាងកាត់កក់ ក្នុងវេលាថ្ងៃត្រង់ដ៏ក្តៅ ក៏បានទតឃើញផ្លូវគួរជាទីត្រេកអរ ជាផ្លូវដែលប្រេតទាំងឡាយនិម្មិតហើយ ទើបព្រះរាជាទ្រង់ត្រាស់នឹងនាយសារថីថា ផ្លូវនេះគួរជាទីត្រេកអរ ជាផ្លូវដ៏ក្សេមក្សាន្ត ប្រកបដោយសួស្តី ជាផ្លូវមិនមានឧបទ្រពឡើយ ម្នាលសារថី ចូរអ្នកទៅតាមផ្លូវនេះវិញ ( ព្រោះយើង ) ទៅតាមផ្លូវនេះ ជិតដល់សុរដ្ឋប្រទេសហើយដូច្នេះ រួចព្រះបាទបិង្គលកៈក្នុងសុរដ្ឋប្រទេស ក៏បានទៅតាមផ្លូវនោះ ជាមួយនឹងសេនាប្រកបដោយអង្គ ៤ ។

បុរសមានសភាពតក់ស្លុត បានក្រាបទូលស្តេច ក្នុងសុរដ្ឋប្រទេស ដូច្នេះថា យើងដើរទៅតាមផ្លូវមិនស្រួល ជាទីស្ញប់ស្ញែង ព្រឺព្រួចរោម ។ ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ យើងដើរទៅតាមផ្លូវមិនស្រួល ក្នុងទីជិតនៃពួកយមបុរសប្រេត ឯក្លិនអមនុស្សបក់មក ទាំងមានសំឡេងគឹកកងដ៏ខ្លាំង ដ៏អាក្រក់ ក៏ឮមក ។

ព្រះរាជាក្នុងសុរដ្ឋប្រទេស ទ្រង់មានសេចក្តីតក់ស្លុត ទើបត្រាស់ទៅនឹងនាយសារថី ដូច្នេះថា យើងដើរទៅពារផ្លូវមិនស្រួលនាំឲ្យស្ញប់ស្ញែង នាំឲ្យព្រឺព្រួចរោម ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ ។ យើងដើរទៅពារផ្លូវមិនស្រួល

ក្នុងទីជិតនៃពួកយមបុរសហើយ ឯក្និនសរីរៈអមនុស្ស ក៏បក់មក ទាំងសំឡេងគឹកកងរំពងអាក្រក់ ក៏ឮមក ។ ទ្រង់ត្រាស់ដូច្នេះហើយ ក៏ឡើងគង់លើដំរី ហើយទតមើលទៅទិសទាំង ៤ បានឃើញ ដើមជ្រៃមួយដើម ជាវុក្ខជាតផឹកនូវទឹកដោយ ជើង បរិបូណ៌ដោយម្លប់ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ព្រះរាជាត្រាស់ទៅនឹងនាយសារថីថា ដើមឈើធំប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ នុ៎ះជាឈើអ្វី ។

សារថីក្រាបទូលថា

បពិត្រមហារាជ នោះជាដើមជ្រៃ ជាវុក្ខជាតផឹកនូវទឹកដោយ ជើង បរិបូណ៌ដោយម្លប់ប្រហែលមេឃ មានណព៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ។

ព្រះរាជា ក្នុងសុរដ្ឋប្រទេស ស្តេចទៅត្រង់ដើមឈើធំប្រហែលមេឃ មានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ។ ព្រះរាជា ស្តេចចុះអំពីកដំរី ហើយចូលសំដៅទៅរកដើមឈើ ទ្រង់គង់ក្រោមម្លប់ឈើជាមួយនឹងអាមាត្យ និងជនជាបរិសទ្យ ក៏បានទតឃើញកំពង់ទឹកដ៏ពេញ និងនំទាំងឡាយដ៏វិចិត្រ ។

( ប្រេតនោះ ) ក្លែងខ្លួនជាបុរស មានភេទដូចជាទេវតា ស្អិតស្អាងគ្រឿងអាភរណៈទាំងពួង ហើយចូលទៅនិយាយនឹង

ព្រះរាជា ជាធំក្នុងសុរដ្ឋប្រទេស ដូច្នេះថា បពិត្រមហារាជ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ដំណើរព្រះអង្គស្តេចមក ឈ្មោះថាមកអំពីទីមិនឆ្ងាយ បពិត្រព្រះអរិន្ទមរាជ សូមព្រះសម្មតិទេព ទ្រង់សោយនូវវិសុទ្ធិរស ទ្រង់សោយនូវនំទាំងឡាយ ។

ព្រះរាជាក្នុងសុរដ្ឋប្រទេស ព្រមទាំងអាមាត្យ និងជនជាបរិសទ្យ បានសោយនូវព្រះវិសុទ្ធិរសផង សោយនូវនំទាំង-ឡាយផង លុះសោយរួចហើយ ទ្រង់ត្រាស់សួរដូច្នេះថា អ្នកជាទេវតាឬជាគន្ធព្វឬមួយជាសក្កបុរិន្ទទៈ យើងមិនស្គាល់ បានជាសួរអ្នក យើងស្គាល់អ្នកដូចម្តេចបាន ។

នន្ទកប្រេតតបថា

ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ បពិត្រមហារាជជាស្តេចក្នុងសុរដ្ឋប្រទេស ខ្ញុំជាប្រេតទេតើ មកនៅក្នុងទីនេះ ។

ព្រះរាជត្រាស់សួរថា

ចុះអ្នកឯង មានសីលធម៌ដូចម្តេច មានសមាចារដូចម្តេចក្នុងសុរដ្ឋបុរី អ្នកឯងនេះ មានអានុភាពច្រើន ព្រោះអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរដូចម្តេចខ្លះ ។

នន្ទកប្រេតតបថា

បពិត្រព្រះអរិន្ទមៈមហារាជ ជាស្តេចចម្រើនក្នុងដែន សូមព្រះអង្គព្រមទាំងពួកអាមាត្យ និងព្រាហ្មណ៍ បុរោហិត ទ្រង់ព្រះសណ្តាប់ពាក្យខ្ញុំនោះ ។ បពិត្រព្រះទេព ខ្ញុំនៅក្នុងសុរដ្ឋប្រទេស ជាបុរសមានចិត្តអាក្រក់ មានសេចក្តីយល់ខុស ទ្រុស្តសីល កំណាញ់ ជេរប្រទេចផ្តាសាពួកជនដែលកំពុងឲ្យ កំពុងធ្វើ ហាមឃាត់ពួកជនច្រើន ធ្វើអន្តរាយដល់ពួកជនដទៃ ដែលកំពុងឲ្យ ( ខ្ញុំរមែងនិយាយរឿយៗថា ) ផលរបស់ទានមិនមានទេ តើផលនៃការសង្រួម គឺសីលនឹងមានមកពីណា អាចារ្យមិនមាន អ្នកណានឹងទូន្មានបុគ្គល ដែលគេមិនទាន់ទូន្មាននោះបាន ។ ពួកសត្វសឹងតែស្មើៗ គ្នាទេ ចាំបាច់មានបុគ្គលជាអ្នកគោរពក្រោតក្រែងត្រកូលរៀមច្បង ( ធ្វើអ្វីទៀត ) កម្លាំងក្តី សេចក្តីព្យាយាមក្តី មិនមានហើយ តើការប្រឹងប្រែងរបស់បុរស មានមកអំពីទីណា ។ ផលរបស់ទានមិនមានទេ បុគ្គលមិនអាចធ្វើសត្វដែលមានពៀរឲ្យស្អាតបាន សត្វបានសេចក្តីសុខទុក្ខដែលត្រូវបាន កើតពីសេចក្តីប្រែប្រួលតែងដឹកនាំទៅ ( មិនមែនព្រោះកម្មដែលខ្លួនធ្វើទេ ) ។ មាតាបិតា បងប្អូនមិនមាន លោកដទៃក្រៅពីលោកនេះមិនមាន ការឲ្យទានមិនមាន ការបូជាមិនមាន ការតម្កល់ទាន ( ចំពោះសមណព្រាហ្មណ៍ ) ក៏មិនមាន ។ អ្នកណាកាត់ក្បាល

បុរសមិនឈ្មោះថាសម្លាប់បុរសទេ ( ព្រោះ ) គ្មានអ្នកណាសម្លាប់ ( អ្នកណា ) តិចតួចទេ ទុកដូចជាបៀតបៀនក្នុងចន្លោះនៃកាយទាំង ៧ ( មានផែនដីជាដើម ) ដែរ ។ ជីវៈជាសភាវៈផ្តាច់មិនបាន ទម្លាយមិនបាន ( ព្រោះ ) ជួនកាលមានជ្រុង ៨ ជួនកាលមូលជាដុំ ( មានកំពស់ ) ៥០០ យោជន៍ អ្នកណា ក៏មិនអាចនឹងផ្តាច់បង់ជីវៈបានឡើយ ។ កាលបើអំបោះហុង គេបោះចោលទៅ អំបោះហុងនោះរមែងរលាយយ៉ាងណាមិញ ជីវៈនោះក៏រលាយយ៉ាងនោះដែរ ។ បុរសបុគ្គល ចេញពីស្រុក ចូលទៅកាន់ស្រុកដទៃទៀត យ៉ាងណាមិញ ជីវៈនោះ ( ចេញពីកាយនេះ ) ចូលទៅកាន់កាយដទៃយ៉ាងនោះដែរ ។ បុរសបុគ្គល ចេញពីផ្ទះ ចូលទៅកាន់ផ្ទះដទៃ យ៉ាងណាមិញ ជីវៈនោះចូលទៅកាន់កាយដទៃទៀត ក៏យ៉ាងនោះដែរ ។ ពួកពាល ពួកបណ្ឌិត នឹងធ្វើសង្សារវដ្តឲ្យអស់ទៅ ធ្វើទុក្ខឲ្យផុតបាន ទាល់តែអស់មហាកប្បទាំងឡាយ ៨ លាន ៤ សែន ។ សុខនិងទុក្ខទាំងឡាយ វាល់បានដោយទោណៈទាំងឡាយផង ដោយកញ្ចើទាំងឡាយផង ជិនបុរសរមែងជ្រាបសព្វ ពួកសត្វក្រៅនេះ ប្រកបដោយសេចក្តីវង្វេង ។ កាលមុន ខ្ញុំជាអ្នកយល់យ៉ាងនេះ ជាអ្នកប្រកបដោយសេចក្តីវង្វេង មានសេចក្តីវង្វេងគ្របសង្កត់ មានសេចក្តី

យល់ខុស ទ្រុស្តសីល កំណាញ់ ប្រទេចផ្តាសា ( សមណៈនិងព្រាហ្មណ៍ ) ។ ខាងអាយ ៦ ខែទៀត ខ្ញុំនឹងធ្វើកាលកិរិយា ។ ខ្ញុំមុខជានឹងធ្លាក់នរក មានការក្តៅក្រហាយដ៏ពន្លឹកដោយពិត ជានរកមានជ្រុង ៤ មានទ្វារ ៤ ដូចជាវាស់ដោយចំណែកដែលចែកស្មើគ្នា ជានរកមានកំពែងដែកព័ទ្ធជុំវិញ គ្របដោយដែក ។ ភូមិនៃនរកនោះជាវិការៈនៃដែក រន្ទាលប្រាលក្តៅ ប្រកបដោយភ្លើង ផ្សព្វផ្សាយទៅ ១០០ យោជន៍ជុំវិញ សព្វកាល ។ កន្លងទៅ ១ សែនឆ្នាំ ឮសូរសំឡេងកងរំពង ក្នុងកាលនោះ ។ បពិត្រមហារាជ ចំណែក ១ សែនកោដិឆ្នាំ ជាគ្រឿងកំណត់ ( អាយុរបស់សត្វដែលឆេះនៅក្នុងនរកនុ៎ះ ) ពួកជនដែលជាមិច្ឆាទិដ្ឋិ ទ្រុស្តសីល តិះដៀលព្រះអរិយៈ តែងឆេះនៅក្នុងនរក អស់ ១ សែនកោដិឆ្នាំ ។ ខ្ញុំនឹងវេទនា ក្នុងនរកនោះ អស់កាល ជាយូរអង្វែង ( ព្រោះ ) ផលនៃបាបកម្ម ហេតុនោះបានជាខ្ញុំសោកសៅដ៏ក្រៃលែង ។ បពិត្រអរិន្ទមមហារាជ អ្នកចម្រើនក្នុងដែន ព្រះអង្គចូរស្តាប់ដំណើរនោះ បពិត្រមហារាជ ធីតារបស់ខ្ញុំឈ្មោះនាងឧត្តរា សេចក្តីចម្រើនចូលមានដល់ព្រះអង្គ ។ នាងឧត្តរាតែងធ្វើនូវកម្មដ៏ចម្រើន ជាអ្នកត្រេកអរក្នុងនិច្ចសីលនិងឧបោសថសីល ត្រេកអរក្នុងទាន ជាអ្នកចែករំលែកទាន ជាអ្នក

ដឹងនូវពាក្យ ( នៃស្នូម ) មិនមានកំណាញ់ ធ្វើមិនឲ្យដាច់ក្នុងសិក្ខាបទ ជាកូនប្រសាក្នុងត្រកូលដទៃ ជាឧបាសិកានៃព្រះសក្យមុនីសម្ពុទ្ធដ៏មានសិរី ។ ភិក្ខុបរិបូណ៌ដោយសីល ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ជាអ្នកសង្រួមចក្ខុ មានស្មារតីគ្រប់គ្រងទ្វារ បិទបាំងកាយដោយប្រពៃ ត្រាច់ទៅតាមលំដាប់ប្រក បានទៅកាន់លំនៅរបស់នាងនោះ ។ បពិត្រមហារាជសេចក្តីចម្រើន ចូរមានដល់ព្រះអង្គ នាងឧត្តរាបានឃើញភិក្ខុនោះហើយ បានប្រគេននូវបានីយករកៈ ( តម្រងទឹក ) ដ៏ពេញផង នូវនំទាំងឡាយដ៏វិចិត្រផង ( ហើយឧទ្ទិសផលមកឲ្យខ្ញុំយ៉ាងនេះថា ) បពិត្រលោកដ៏ចម្រើន បិតារបស់ខ្ញុំចែកឋានទៅហើយ ទាននេះសូមសម្រេចដល់បិតារបស់ខ្ញុំនោះ ។ ផលក៏សម្រេច ក្នុងពេលជាលំដាប់ដែលឧទ្ទិសហើយ ខ្ញុំជាអ្នកបានកាមតាមប្រាថ្នា បរិភោគដូចជាស្តេចវេស្សវ័ណ ។ បពិត្រអរិន្ទមមហារាជ ព្រះអង្គអ្នកចម្រើនក្នុងដែន សូមព្រះអង្គស្តាប់នូវដំណើរនោះ ព្រះពុទ្ធគេហៅថា បុគ្គលប្រសើរ ជាងសត្វលោកព្រមទាំងទេវលោក បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គព្រមទាំងព្រះរាជបុត្រាបុត្រីព្រះអគ្គជាយា ដល់នូវព្រះពុទ្ធនោះជាសរណៈចុះ ។ ពួកបុរសបុគ្គលបានដល់ព្រះនិព្វានដោយសារតែមគ្គប្រកបដោយអង្គ ៨ ប្រការ បពិត្រព្រះបាទអ-

រិន្ទមៈ សូមព្រះអង្គ ព្រមទាំងព្រះរាជបុត្រាបុត្រីព្រះអគ្គជាយា ដល់នូវធម៌ ( អដ្ឋង្គិកមគ្គ ) នោះជាសរណៈចុះ ។ ព្រះអរិយបុគ្គល ៤ ពួក ប្រតិបត្តិក្នុងមគ្គ ព្រះអរិយបុគ្គល ៤ ពួកឋិតនៅក្នុងផល ព្រះសង្ឃទាំងនុ៎ះ លោកជាអ្នកស្លូត ត្រង់ តាំងនៅមាំក្នុងបញ្ញានិងសីល បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវព្រះសង្ឃនោះ ជាសរណៈចុះ ។ សូមព្រះអង្គវៀរចាកបាណាតិបាតឲ្យឆាប់ៗ សូមព្រះអង្គវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោក សូមព្រះអង្គកុំសោយនូវទឹកស្រវឹង កុំមានព្រះឱស្ការកុហក សូមព្រះអង្គត្រេកអរ តែនឹងព្រះអគ្គមហេសីរបស់ព្រះអង្គ ។

ព្រះរាជាត្រាស់ថា

ម្នាលយក្ស អ្នកជាអ្នកប្រាថ្នាសេចក្តីចម្រើន ដល់យើង ម្នាលទេវតា អ្នកជាអ្នកប្រាថ្នាប្រយោជន៍ ដល់យើង យើងធ្វើតាមពាក្យរបស់អ្នកហើយ អ្នកជាអាចារ្យរបស់យើង ។ យើងសូមដល់ព្រះពុទ្ធជាសរណៈផង ដល់ព្រះធម៌ជាសរណៈផង ដល់ព្រះសង្ឃដ៏ប្រសើរជាងមនុស្សនិងទេវតាជាសរណៈផង ។

យើងវៀរចាកបាណាតិបាត យ៉ាងឆាប់រហ័យ យើងលះ

បង់ការកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោក យើងលែងផឹកទឹកស្រវឹងលែងនិយាយកុហក យើងជាអ្នកត្រេកអរតែនឹងប្រពន្ធរបស់ខ្លួន ។

ម្នាលប្រេត យើងត្រេកអរ ក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយបាច ( នូវទិដ្ឋិដ៏អាក្រក់ចោលដូចជាអង្កាម ) ក្នុងទីមានខ្យល់ធំផង បន្សាត់ចោលនូវទិដ្ឋិអាក្រក់ ( ដូចជាសំរាម ) ក្នុងទន្លេ មានខ្សែទឹករហ័សផង ។ លុះព្រះបាទបិង្គលៈ ជាស្តេចក្នុងដែនសុរដ្ឋ មានព្រះឱង្ការដូច្នេះហើយ ក៏បានវៀរចាកការយល់ដ៏លាមកចោលចេញ ធ្វើនូវកិរិយាថ្វាយបង្គំព្រះមានព្រះភាគ រួចក៏បែរព្រះភក្ត្រចំទៅទិសខាងកើត ឡើងគង់លើរថទៅ ។

បណ្តាបទទាំងនោះ បទថា **រាជា បិង្គលកោ នាម សុរដ្ឋានំ អធិបតិ អហុ** សេចក្តីថា មានព្រះរាជាមួយអង្គ ជាឥស្សរៈនៃសុរដ្ឋប្រទេស ប្រាកដនាមថា បិង្គលៈ ព្រោះមានភ្នែកលឿង ។ ដោយបទថា **មោរិយានំ** លោកពោលសំដៅដល់ព្រះបាទមោរិយធម្មាសោក ។ បទថា **សុរដ្ឋំ បុនរាគមា** សេចក្តីថា បានយាងត្រឡប់មកតាមផ្លូវជាទីទៅកាន់សុរដ្ឋប្រទេស ឆ្ពោះទៅកាន់សុរដ្ឋប្រទេស ។ បទថា **បណ្ហំ** បានដល់ ភូមិភាគដែលទន់ ( ភក់ ) ។ បទថា **វណ្ណុបថំ** បានដល់ ផ្លូវមានខ្សាច់ដែលប្រេតនិម្មិត ។ បទថា **ខេមោ** ប្រែថា ផុតភ័យ ។ បទថា **សោវត្ថិកោ** បានដល់ នាំមកនូវសួស្តី ។

បទថា **សិវោ** ប្រែថា មានឧបទ្ទវក្ខាយ ។ បទថា **សុរដ្ឋានំ សន្តិកេ ឥតោ** បានដល់ ពួកយើងកាលទៅតាមផ្លូវនេះ នឹងដល់ទីជិតសុរដ្ឋនោះឯង ។

បទថា **សោរដ្ឋោ** បានដល់ ជាអ្នកជំក្នុងសុរដ្ឋប្រទេស ។ បទថា **ឧត្តិគ្គរចោ** បានដល់ ជាអ្នកមានការតក់ស្លុតជាសភាវៈ ។ បទថា **ភឹសនំ** បានដល់ កើតនូវការភ័យខ្លាច ។ បទថា **លោមហំសនំ** បានដល់ កើតនូវការព្រឺរោមព្រឺស្បែក ព្រោះជាផ្លូវគួរស្បើម ។ បទថា **យមបុរិសាន សន្តិ-កេ** បានដល់ នៅក្នុងទីជិតពួកប្រេត ។ បទថា **អមានុសោ វាយតិ គន្ធោ** សេចក្តីថា ក្លិនរបស់ពួកប្រេតរមែងផ្សាយទៅ ។ បទថា **ឃោសោ សុយ្យតិ ទារុណោ** សេចក្តីថា ខ្ញុំព្រះអង្គបានឮសំឡេងដ៏ពន្លឹក គួរស្បប់ស្បែងនៃពួកសត្វដែលធ្វើហេតុក្នុងនរកដោយចំពោះ ។

បទថា **ធានបំ** បានដល់ ដើមឈើដែលមានឈ្មោះថា **ធានប** ព្រោះផឹកទឹកតាមដើមនិងឫស ។ បទថា **ឆាយាសម្បន្នំ** ប្រែថា មានម្លប់ត្រជាក់ល្អ ។ បទថា **នីលព្ភវណ្ណសទិសំ** បានដល់ មានពណ៌ខៀវស្រងាត់ ដូចពណ៌នៃផ្ទៃមេឃ ។ បទថា **មេឃវណ្ណសិរីនិភំ** បានដល់ មានពណ៌និងសណ្ឋានស្រដៀងពពក ។

បទថា **បូរំ ធានីយសរកំ** បានដល់ ភាជនៈទឹកដែលពេញដោយទឹក ។ បទថា **បូវេ** បានដល់ របស់ទំពា ។ បទថា **វិត្តោ** សេចក្តីថា ស្តេចសុរដ្ឋបានឃើញនំដែលដាក់ពេញផ្តិលទាំងនោះ ដែលឲ្យកើតការត្រេកអរ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត ។

សព្ទថា **អថោ** ក្នុងបទថា **អថោ តេ អនុភាគតំ** នេះ ត្រឹមតែជានិបាត ឬបទថា **អថោ** ប្រើក្នុងអត្ថនៃអវធារណៈ អធិប្បាយថា ពួកយើងទទួល ដោយបំណងថា បពិត្រមហារាជ ទ្រង់យាងមកល្អ មិនមែនមកអាក្រក់ទេ ដោយពិត ទ្រង់យាងមកល្អហើយ ។ បទថា **អរិន្ទម** បានដល់ ជាអ្នកកម្ចាត់សត្រូវ ។ បទថា **អមច្ចា ចារិសជ្ជា** មានវាចាប្រកបសេចក្តីថា ពួកអាមាត្យនិងរាជបរិវារចូរស្តាប់ ឯព្រាហ្មណ៍ជាបុរោហិតរបស់ទ្រង់ ចូរស្តាប់ពាក្យនោះចុះ ។

បទថា **សុរដ្ឋស្មឹ អហំ** កែជា **សុរដ្ឋទេសេ អហំ** ប្រែថា ខ្ញុំ ... ក្នុងសុរដ្ឋប្រទេស ។ នាយសារថីហៅព្រះរាជាថា **ទេវ** ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ ជាអ្នកឃើញខុសដោយនត្ថិកទិដ្ឋិ ។ បទថា **ទុស្សីលោ** បានដល់ ដែលមិនមានសីល ។ បទថា **កទរិយោ** បានដល់ អ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ។ បទថា **បរិភាសកោ** បានដល់ ជាអ្នកជេរសមណព្រាហ្មណ៍ ។ បទថា **វារយិស្សំ** ប្រែថា បានឃាត់ហើយ ។ បទថា **អន្តរាយករោ អហំ** មានវាចាប្រកបសេចក្តីថា ខ្ញុំជាអ្នកធ្វើអន្តរាយចំពោះជន ដែលកំពុងឲ្យទាន ដែលធ្វើឧបការៈ ខ្ញុំហាមប្រាមជនជាច្រើនចាកបុណ្យ ដែលសម្រេចដោយទានរបស់ជនដទៃ ដែលកំពុងឲ្យទាន ។

បទថា **វិបាកោ នត្ថិ ទានស្ស** ជាដើម ជាបទសម្តែងអាការដែលបុរសជាអតីតប្រេតហាមហើយ ។ បណ្តាបទទាំងនោះ ដោយបទថា **វិបាកោ នត្ថិ ទានស្ស** នេះ សេចក្តីថា ហាមនូវវិបាកថា កាលបុគ្គលនោះឲ្យទាន

*វិបាកគឺផលដែលគប្បីបានទទួលតទៅ រមែងមិនមាន ។ បទថា* **សំយមស្ស ក្កុតោ ផលំ** *សេចក្តីថា ផលនៃសីលនិងមានមកអំពីណា អធិប្បាយថា ផលនៃសីលនោះរមែងមិនមានដោយប្រការទាំងពួង ។ បទថា* **នត្ថិ អាចរិយោ នាម** *សេចក្តីថា បុគ្គលណាដែលឈ្មោះថាជាអាចារ្យដែលឲ្យសិក្សាអាចារ និងសមាចារ រមែងមិនមាន អធិប្បាយថា ពោលដោយសភាវៈនោះឯង សត្វទាំងឡាយដែលទូន្មានខ្លួនហើយ ឬមិនទាន់បានទូន្មានខ្លួនរមែងមានដោយ ហេតុនោះ ទើបលោកពោលថា អ្នកណានឹងទូន្មានបុគ្គលដែលមិនទាន់បាន ទូន្មាន ដូច្នេះ ។*

*បទថា* **សមតុល្យានិ ភូតានិ** *សេចក្តីថា សត្វទាំងអស់នេះជាអ្នកស្មើ គ្នានឹងគ្នា អធិប្បាយថា បុគ្គលមានការប្រព្រឹត្តឱនលំទោនចំពោះអ្នកជំនឹង មានមកអំពីណា គឺឈ្មោះថាបុណ្យព្រោះការប្រព្រឹត្តឱនលំទោនចំពោះអ្នកជា ធំ រមែងមិនមាន ។ បទថា* **នត្ថិ ពលំ** *សេចក្តីថា សត្វទាំងឡាយតាំងនៅ ក្នុងកម្លាំងរបស់ខ្លួនឯណាធ្វើសេចក្តីព្យាយាម រមែងសម្រេចនូវសម្បត្តិទាំង-ឡាយ ចាប់តាំងអំពីភាពជាបុគ្គលប្រសើរដោយរូបសម្រស់ ក្នុងពួកមនុស្ស រហូតដល់ភាពជាព្រះអរហន្ត គាត់រមែងហាមកម្លាំងនៃសេចក្តីព្យាយាមនោះ ។ បទថា* **វីរិយំ វា នត្ថិ កុតោ ឧដ្ឋានពោរិសំ** *នេះ គាត់ពោលបានដោយ អំណាចការបដិសេធវាទៈ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា នេះជាការ ប្រព្រឹត្តទៅដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីព្យាយាមរបស់ បុរសមិនមាន ។ បទថា* **នត្ថិ ទានផលំ នាម** *សេចក្តីថា ឈ្មោះថា ផល*

នៃទានណាមួយរមែងមិនមាន អធិប្បាយថា កិរិយាបរិច្ចាគទេយ្យធម៌រមែងគ្មានផលនោះឯង ដូចផេះដែលគេកប់ទុក ។ បទថា **វេរំ** ក្នុងបទថា **ន វិសោធេតិ វេរំ** នេះ សេចក្តីថា រមែងមិនធ្វើបុគ្គលដែលមានពៀរ គឺបុគ្គលធ្វើបាបដោយអំណាចពៀរនិងដោយអំណាចអកុសលធម៌ មានបាណាតិបាតជាដើមឲ្យបរិសុទ្ធដោយវត្ថុមានទាននិងសីលជាដើម គឺក្នុងកាលណាមួយ ក៏មិនធ្វើឲ្យបរិសុទ្ធបាន ។ បទថា **វិបាកោ នត្ថិ ទានស្ស** ជាដើម ជាបទសម្តែងអាការដែលខ្លួនឃាត់អ្នកដទៃចាកទានជាដើម ក្នុងកាលមុន តែបទថា ឈ្មោះថា ផលនៃទានរមែងមិនមានជាដើម គប្បីឃើញថា ជាបទសម្តែងការប្រកាន់ខុសរបស់ខ្លួន ។ បទថា **លព្ភេយ្យំ** ប្រែថា គប្បីបាន ។ ដើម្បីចៀសវាងនូវពាក្យសួរថា គប្បីបានដូចម្តេច ទើបលោកឆ្លើយថា កើតពីសេចក្តីប្រែប្រួលតែងដឹកនាំទៅ អធិប្បាយថា សត្វនេះ កាលបានទទួលសេចក្តីសុខ ឬសេចក្តីទុក្ខ រមែងបានដោយអំណាច ការប្រែប្រួលនៃជោគនោះឯង ។ មិនមែនព្រោះកម្មដែលខ្លួនធ្វើឡើយ និងមិនមែនព្រោះព្រះឥស្សរនិម្មិតឡើយ ។ ដោយបទថា **នត្ថិ មាតា បិតា ភាតា** លោកពោលសំដៅដល់ការមិនមានផលនៃការបដិបត្តិប្រពៃនិងការបដិបត្តិខុសក្នុងមាតាជាដើម ។ បទថា **លោកោ នត្ថិ ឥតោ បរំ** សេចក្តីថា ឈ្មោះថា បរលោកណាមួយចាកឥធលោកនេះ រមែងមិនមាន អធិប្បាយថា សត្វរមែងដាច់សូន្យទៅក្នុងទីនោះៗឯង ។ បទថា **ទិន្នំ** បានដល់ មហាទាន ។ បទថា **ហុតំ** បានដល់ សក្ការៈដើម្បីភ្ញៀវ លោកពោលសំដៅដល់ មិនមានផលទាំង ២ នោះ ទើបឃាត់ថា

**នត្ថិ** ( មិនមាន ) ។ បទថា **សុនិហិតំ** ប្រែថា តម្កល់ទុកល្អហើយ ។ បទថា **ន វិជ្ជតិ** សេចក្តីថា ឈ្មោះថា ការឲ្យទានដល់សមណព្រាហ្មណ៍ដែលជនទាំងឡាយពោលថា ជាកំណាប់ទ្រព្យដែលជាគ្រឿងជាប់តាមនោះ រមែងមិនមានផល អធិប្បាយថា ទានដែលឲ្យដល់សមណព្រាហ្មណ៍នោះ ត្រឹមតែជារឿងដែលពោលដោយវាចាប៉ុណ្ណោះ ។

បទថា **ន កោចិ កញ្ចិ ហនតិ** សេចក្តីថា បុរសណាគប្បីសម្លាប់បុរសដទៃ គឺគប្បីកាត់ក្បាលរបស់បុរសដទៃ ក្នុងសេចក្តីនោះ កាលពោលដោយបរមត្ថ បុគ្គលណាមួយរមែងមិនសម្លាប់បុគ្គលណាមួយបាន គឺរមែងដូចអ្នកសម្លាប់ ព្រោះកាត់នូវកាយទាំង ៧ ។ ដើម្បីចៀសវាងពាក្យសួរថា ការប្រហារដោយសស្ត្រា ដូចម្តេច ទើបលោកឆ្លើយថា ទុកដូចជាបៀតបៀន ( សស្ត្រាចូលទៅ ) ក្នុងចន្លោះនៃកាយទាំង ៧ ដូច្នេះ អធិប្បាយថា សស្ត្រាចូលទៅក្នុងចន្លោះ គឺក្នុងចន្លោះរបស់កាយទាំង ៧ មានបឋវីជាដើម ព្រោះដូច្នោះ ទើបសត្វ ដូចជាត្រូវសស្ត្រា មានដាវជាដើមកាត់ផ្តាច់ តែសូម្បីកាយដ៏សេសរមែងមិនដាច់ទៅ ព្រោះមានសភាវៈទៀង ដូចមានជីវៈដូច្នោះ ។

បទថា **អច្ឆេជ្ជាភេជ្ជោ ហិ ជីវោ** សេចក្តីថា ជីវៈនៃសត្វទាំងនេះមិនអាចកាត់បាន មិនអាចទម្លាយបាន ដោយសស្ត្រាជាដើម ព្រោះមានសភាវៈទៀង ។ បទថា **អដ្ឋំសោ គុឡបរិមណ្ឌលោ** សេចក្តីថា ជីវៈនោះ ជួនកាលមាន ៨ ជ្រុង ជួនកាលមូលដូចដុំស្ករអំពៅ ។ បទថា **យោជនានំ សតំ បញ្ច** សេចក្តីថា ជីវៈនោះដល់នូវការមិនញាប់ញ័រកម្ពស់ប្រមាណ ៥០០

យោជន៍ ។ ដោយបទថា **កោ ជីវំ ឆេត្តុមរហតិ** នេះ លោកពោលថា បុគ្គលណាគួរកាត់ជីវៈដែលទៀនពិត គឺមិនមានវិការ ដោយសស្រ្តាជាដើម គឺជីវៈនោះ បុគ្គលណា ក៏មិនអាចធ្វើឲ្យកម្រើកបាន ។

បទថា **សុត្តគុឡេ** បានដល់ ដុំអំបោះដែលគេរុំទុក ។ បទថា **ខិត្តេ** បានដល់ បន្សាត់ទៅដោយអំណាចអំបោះដែលរលាចេញ ។ បទថា **និព្វេឋេន្តំ បលាយតិ** សេចក្តីថា ហុងអំបោះដែលអំបោះរលា ដែលគេបោះទៅអំពីលើភ្នំ ឬអំពីលើដើមឈើ រមែងរមៀលទៅបាន តែកាលអំបោះអស់ក៏ទៅមិនបាន ។ បទថា **ឯវមេវំ** សេចក្តីថា ហុងអំបោះនោះដែលអំបោះកំពុងរលាទើបរមៀលទៅបាន កាលអស់អំបោះរមែងទៅមិនបាន យ៉ាងណា ជីវៈក៏ដូច្នោះដូចគ្នា កាលរលាហុងអំបោះ គឺភាវៈរបស់សត្វ រមែងគេចទៅបាន គឺរមែងប្រព្រឹត្តទៅបាន អស់កាលដែលពោលបានថា ទាល់តែអស់មហាកប្បទាំងឡាយ ៨ លាន ៤ សែន ផុតអំពីនោះទៅ ប្រព្រឹត្តទៅមិនបានឡើយ ។

បទថា **ឯវមេវ ច សោ ជីវោ** សេចក្តីថា បុគ្គលខ្លះ ចេញអំពីផ្ទះដែលជាលំនៅរបស់ខ្លួនហើយ ចូលទៅកាន់ស្រុកដទៃ ចេញអំពីស្រុកនោះដោយករណីឯណាទីមួយ ជីវៈនោះ ក៏ដូច្នោះដូចគ្នា ចេញអំពីសរីរៈនេះហើយ ក៏ទៅកាន់សរីរៈដទៃទៀត ដោយអំណាចកំណត់កាល ។ បទថា **ពោន្ទិ** បានដល់ រាងកាយ ។

បទថា **ចុល្លាសីតិ** ប្រែថា ៨៤ ។ បទថា **មហាកប្បិនោ** បានដល់ មហាកប្ប ។ ក្នុងមហាកប្បនោះ អាចារ្យទាំងឡាយពោលថា កាលទេវតា

*វិសេសនាំយកតំណក់ទឹក ដោយចុងស្បូវ ១០០ ឆ្នាំម្តង ចេញអំពីស្រះធំមានអនោតត្តស្រះជាដើម ដោយសេចក្តីព្យាយាមនេះ កាលស្រះនោះរីងអស់ ៧ ដង ឈ្មោះថា ជាមហាកប្ប ១ ទើបពោលថា ៨ លាន ៤ សែនមហាកប្ប នេះជាប្រមាណនៃសង្សារ ។ បទថា* **យេ ពាលា យេ ច បណ្ឌិតា** *សេចក្តីថា សត្វទាំងឡាយ ទោះជាពាលឬបណ្ឌិតទាំងអស់នោះ ។ បទថា* **សំសារំ ខេបយិត្វាន** *សេចក្តីថា ញុំាំងសង្សារដែលកំណត់ដោយកាលតាមដែលពោលហើយឲ្យអស់ទៅដោយអំណាចការកើតរឿយៗ ។ បទថា* **ទុក្ខស្សន្តំ ករិស្សរេ** *សេចក្តីថា នឹងធ្វើនូវការអស់នៃវដ្តទុក្ខ ។ មិច្ឆាទិដ្ឋិបុគ្គលនោះ មានការយល់ថា ទាំងបណ្ឌិតក៏មិនអាចជម្រះខ្លួនឲ្យបរិសុទ្ធក្នុងចន្លោះបានបន្ទាប់អំពីនោះសូម្បីពួកជនពាល ក៏ប្រព្រឹត្តទៅមិនបានឡើយ ។*

*បទថា* **មិតានិ សុខទុក្ខានិ ទោណេហិ បិដកេហិ ច** *សេចក្តីថា ឈ្មោះថា សុខទុក្ខនៃសត្វទាំងឡាយដូចជាវាល់ដោយនាឡិ ដោយកញ្ជើ បានដល់ ដោយភាជនៈជាគ្រឿងវាល់សុខទុក្ខរបស់សត្វទាំងឡាយនោះៗ កើតអំពីការប្រែប្រួលទៅនៃជោគ ជាការប្រមាណបានដោយចំពោះ ព្រោះប្រមាណបានដោយកំណត់តាមកាលដែលពោលហើយនោះឯង ។ ព្រះជិនៈរមែងជ្រាបរឿងនេះ គឺលោកដែលតាំងនៅក្នុងជិនភូមិ រមែងដឹងច្បាស់ដោយឥតសេសសល់ ព្រោះឈានកន្លងសង្សារបាន ឯពួកសត្វក្រៅអំពីនេះ ដែលវង្វេងរមែងវិលវល់ក្នុងសង្សារ ។*

*បទថា* **ឯវំទិដ្ឋិ បុរេ អាសឹ** *សេចក្តីថា កាលមុនខ្ញុំបានជាបុគ្គលនត្ថិក-*

*ទិដ្ឋិតាមដែលពោលហើយ ។ បទថា* **សម្មូឡ្ហោ មោហចារុតោ** *បានដល់ បុគ្គលដែលវង្វេង ព្រោះសម្មោហៈដែលជាហេតុនៃទិដ្ឋិតាមដែលពោលហើយ អធិប្បាយថា ជាបុគ្គលដែលត្រូវមោហៈ កើតព្រមដោយទិដ្ឋិនោះគ្របសង្កត់ គឺដូចពូជនៃស្បូវក្លាំងបិទបាំង ។*

*នន្ទកប្រេត កាលសម្តែងបាបកម្មដែលខ្លួនធ្វើ ដោយអំណាចទិដ្ឋិអាក្រក់ ដែលកើតឡើងដល់ខ្លួនក្នុងកាលមុនយ៉ាងនេះហើយ ឥឡូវនេះ កាលសម្តែងផលនៃបាបកម្មដែលខ្លួនត្រូវសោយក្នុងអនាគតនោះ ទើបពោលពាក្យជាដើមថា ខាងអាយ ៦ ខែទៀត ខ្ញុំនឹងធ្វើកាលកិរិយា ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **វស្សានិ សតសហស្សានិ** *បានដល់ ១ សែនឆ្នាំ បាលីដ៏សេសថា* **អតិក្កមិត្វា** *ប្រែថា កន្លង បណ្ឌិតគប្បីនាំមកភ្ជាប់ជាមួយគ្នា ។ម៉្យាងទៀត បទថា* **វស្សានិ សតសហស្សានិ** *នេះ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ អធិប្បាយថា កាល ១ សែនឆ្នាំកន្លងទៅហើយ ។ បទថា* **យោសោ សុយ្យតិ តាវទេ** *សេចក្តីថា ក្នុងខណៈពេលវេលាមានប្រមាណប៉ុណ្ណោះ កន្លងទៅនោះឯង ប្រេតបានឮសំឡេងក្នុងនរកនោះ យ៉ាងនេះថា អ្នកនិរ្ទុក្ខទាំងឡាយ ពេលវេលារបស់ពួកអ្នកឆេះក្នុងនរកនេះ កន□ទៅ ១ សែនឆ្នាំហើយ ។ បទថា* **លក្ខោ ឃសោ មហា-រាជ សតភាគវស្សកោដិយោ** *សេចក្តីថា បពិត្រមហារាជ ១០០ ចំណែកកោដិឆ្នាំ ចាត់ជាកំណត់ គឺជាកំណត់អាយុរបស់សត្វទាំងឡាយដែលឆេះក្នុងនរក ។ លោកពោលពាក្យអធិប្បាយនេះថា ១០ ទសកៈជា ១០០ ដប់រយ*

ជា ១០០០ មួយរយពាន់ជា ១ សែន មួយរយសែនជា ១ កោដិ មួយសែនកោដិឆ្នាំដោយអំណាចកោដិទាំងនោះ ចាត់ជា **សតភាគវស្សកោដិយោ** ( ១០០ សែនកោដិឆ្នាំ ) **សតភាគវស្សកោដិយោ** នោះឯង គប្បីជ្រាបដោយការគណនាឆ្នាំនរក មិនមែនសម្រាប់មនុស្សឬទេវតា ។ មួយសែនកោដិឆ្នាំដ៏ច្រើនបែបនេះ ជាអាយុរបស់សត្វនរក ដោយហេតុនោះ ទើបលោកពោលថា **កោដិសតសហស្សានិ និរយេ បច្ចរេ ជនា** ដូច្នេះ ។ សត្វទាំងឡាយឆេះក្នុងនរកបែបនោះ ព្រោះបាបកម្មបែបណា ដើម្បីសម្ដែងបាប-កម្មបែបនោះដោយពាក្យចុងក្រោយ ទើបលោកពោលថា ពួកជនដែលជាមិច្ឆាទិដ្ឋិ ទ្រុស្តសីល តិះដៀលព្រះអរិយៈ ដូច្នេះ ។ បទថា **វេទិស្សំ** ប្រែថា ខ្ញុំនឹងបានសោយ ។

នន្ទកប្រេត កាលសម្ដែងផលនៃអំពើអាក្រក់ ដែលខ្លួនគប្បីសោយក្នុងអនាគតយ៉ាងនេះហើយ ឥឡូវនេះ បំណាំងនឹងទូលរឿងដែលព្រះរាជាត្រាស់សួរថា អ្នកឯងនេះ មានអានុភាពច្រើន ព្រោះប្រព្រឹត្តធម៌ដ៏ប្រសើរដូចម្ដេចខ្លះ ដូច្នេះហើយនឹងឲ្យព្រះរាជាតាំងនៅក្នុងសរណៈ និងសីល ទើបពោលពាក្យជាដើមថា **តំ សុណោហិ មហារាជ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សីលេសុបោសថេ រតា** បានដល់ ត្រេកអរហើយក្នុងនិច្ចសីលនិងឧបោសថសីល ។ បទថា **អទា** ប្រែថា បានឲ្យហើយ ។ បទថា **តំ ធម្មំ** បានដល់ មគ្គមានអង្គ ៨ និងអមតបទនោះ ។

ព្រះរាជាកាលប្រេតដឹកនាំឲ្យសមាទានសីលនិងសរណៈ យ៉ាងនេះហើយ

មានព្រះទ័យជ្រះថ្លា ជាដំបូងទើបប្រារព្ធដល់ឧបការៈ ដែលប្រេតនោះធ្វើដល់ព្រះអង្គ កាលតាំងនៅក្នុងសរណៈជាដើម ទើបពោលគាថា ៣ ថា អ្នកជាអ្នកប្រាថ្នាសេចក្តីចម្រើន ដូច្នេះហើយ កាលទ្រង់ប្រកាសដល់ភាពដែលទ្រង់លះទិដ្ឋិអាក្រក់ដែលទ្រង់កាន់យកក្នុងកាលមុន ទើបត្រាស់គាថាថា **ឱ-ដ្ឋុណាមិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឱដ្ឋុណាមិ មហាវាតេ** សេចក្តីថា ម្នាលទេវតា យើងនឹងបាច គឺកម្ចាត់ទិដ្ឋិអាក្រក់នោះ ក្នុងទីដែលមានខ្យល់ គឺធម្ម-ទេសនារបស់អ្នក ដូចបាចអង្កាមក្នុងទីខ្យល់ខ្លាំងដែលកំពុងបក់ ។ បទថា **នទិយា វា សីឃគាមិយា** អធិប្បាយថា ខ្ញុំនឹងលះទិដ្ឋិអាក្រក់ ដូចបន្សាត់ស្មៅ កំណាត់ឈើ ស្លឹកឈើ និងកម្ទេចកម្ទីក្នុងស្ទឹងធំ ដែលមានក្រសែខ្លួលខ្លាញ់ ។ បទថា **វមាមិ បាបិកំ ទិដ្ឋឹ** សេចក្តីថា ខ្ញុំនឹងលះទិដ្ឋិអាក្រក់ដែលនៅក្នុងចិត្តរបស់ខ្ញុំ ។ ព្រះរាជាពោលហេតុក្នុងសេចក្តីនេះថា ត្រេកអរហើយក្នុងព្រះសាសនា ដូច្នេះ ។ មានវាចាប្រកបសេចក្តីថា ព្រោះហេតុដែលខ្ញុំត្រេកអរ គឺត្រេកអរក្រៃលែងក្នុងព្រះសាសនា របស់ព្រះមានព្រះភាគសម្មាសម្ពុទ្ធទាំងឡាយដែលនាំអមតៈមកដោយចំណែកមួយ ដូច្នោះ ខ្ញុំនឹងខ្ជាក់ពិស គឺទិដ្ឋិនោះ ។

គាថាចុងក្រោយថា **ឥទំ វត្វាន** ដូច្នេះ ព្រះសង្គីតិកាចារ្យទាំងឡាយបានរចនាទុកហើយ ។ បណ្តាបទទាំងនោះ បទថា **ចាមោក្ខោ** បានដល់បែរមុខទៅកាន់ទិសខាងកើត ។ បទថា **រថមារុយ្ហ** សេចក្តីថា ព្រះរាជា

យានឡើងកាន់រាជរថដែលជាព្រះទីន័ង ដល់ព្រះនគររបស់ព្រះអង្គក្នុងថ្ងៃនោះឯង ដោយអានុភាពរបស់ទេវតា ហើយយាងចូលព្រះរាជវាំង ។ សម័យក្រោយមក ព្រះរាជាត្រាស់ប្រាប់រឿងនោះដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក៏ប្រាប់រឿងនោះដល់ព្រះថេរៈទាំងឡាយ ព្រះថេរៈទាំងឡាយ ក៏លើកឡើងកាន់សង្គាយនា ក្នុងតតិយសង្គីតិ ។

## អដ្ឋកថា នន្ទិកាប្រេត ចប់

# រឿង រេវតីប្រេត ទី ៤

[ ៣៩ ] ម្នាលរេវតី ជាស្រីមានធម៌ដ៏លាមកក្រៃលែង នាងចូរក្រោកឡើង

ៗ បេ ៗ

រឿងរេវតីប្រេតទី ៤ នេះ គប្បីមើលក្នុងរឿងទី ២ នៃមហារថវគ្គទី ៥ ក្នុងវិមានវត្ថុចុះ ។

ចប់ រឿងរេវតីប្រេតទី ៤ ។

# អដ្ឋកថា រេវតីប្រេត

[ ៣៩ ] រឿងនាងរេវតីនេះ មានពាក្យផ្តើមថា **ឧដ្ឋេហិ រេវតេ សុបាបធម្មេ** ដូច្នេះជាដើម ។ ព្រោះហេតុដែលរឿងនោះ មិនមានពិសេសជាងរេវតីវិមានវត្ថុ ព្រោះដូច្នោះ ពាក្យដែលគួរពោលក្នុងអត្ថុប្បត្តិហេតុក្នុងគាថានោះ ពាក្យនោះ គប្បីជ្រាបដោយន័យដែលពោលក្នុងអដ្ឋកថាវិមានវត្ថុ ឈ្មោះថាបរមត្ថទីបនីនោះឯង រឿងនេះ សូម្បីព្រះសង្គីតិកិចារ្យទាំងលើកឡើងកាន់សង្គាយនា ក្នុងបាលីវិមានវត្ថុ ដោយអំណាចទន្និយទេវបុត្ត ក៏គប្បីជ្រាបថា លើកឡើងកាន់សង្គាយនាក្នុងបាលី បេតវត្ថុថា រេវតីបេតវត្ថុ ដោយអំណាចគាថាដែលទាក់ទងដោយនាងរេវតី ។

អដ្ឋកថា រេវតីប្រេតចប់

# រឿង ឧច្ឆុប្រេត ទី ៩

[ ៤០ ] ( ប្រេតទូលសួរព្រះមោគ្គល្លានថា ) ព្រៃអំពៅធំនេះ កើតឡើងដល់ខ្ញុំ ( ហាក់ដូច ) ជាផលបុណ្យច្រើនណាស់ដែរ តែឥឡូវនេះខ្ញុំមិនបានបរិភោគអំពៅនោះសោះ បពិត្រលោកដ៏ចម្រើន សូមលោកប្រាប់ខ្ញុំ តើផលនេះជាផលកម្មអ្វី ។ មួយទៀត ខ្ញុំដល់នូវសេចក្តីចង្អៀតចង្អល់ ចង់បរិភោគ ( ក៏បរិភោគមិនកើត ) ខ្ញុំខំប្រឹងខ្នះខ្នែងដើម្បីបរិភោគនូវរសនៃអំពៅតិចតួច ខ្ញុំនោះមានអត្តភាពដាច់ហើយ ជាបុគ្គលកម្សត់ ប្រកបដោយទុក្ខ នេះជាផលនៃកម្មអ្វី ។ មួយទៀត ខ្ញុំជាបុគ្គលចង្អៀតចង្អល់ ដួលដេកបម្រះនទៀលលើផែនដី ដូចត្រីនៅលើគោកដ៏ក្តៅ ទឹកភ្នែកទាំងឡាយរបស់ខ្ញុំ ហូរចេញអំពីចម្ងាយ បពិត្រលោកដ៏ចម្រើន សូមលោកមេត្តាប្រាប់ នេះជាផលនៃកម្មអ្វី ។ ខ្ញុំឃ្លានផង លំបាកផង ស្រេកផង តក់ស្លុតផង មិនបានសេចក្តីសុខស្រួលទេ បពិត្រលោកដ៏ចម្រើន ខ្ញុំសូមសួរសេចក្តីនុ៎ះ ចំពោះនឹងលោកម្ចាស់ ធ្វើម្តេចហ្ន៎ ខ្ញុំគប្បីបានបរិភោគអំពៅ ( នេះ ) ។

( ព្រះមោគ្គល្លានមានថេរវាចាថា ) កាលពីដើម អ្នកកើតជាមនុស្សបានធ្វើបាបកម្មដោយខ្លួនឯង ក្នុងកាលមុន អាត្មារៀបរាប់សេចក្តីនោះប្រាប់អ្នក អ្នកស្តាប់ហើយត្រូវដឹងសេចក្តីនោះចុះ ។ ( កាលនោះ ) អ្នកកំពុងដើរស៊ីអំពៅ មានបុរសម្នាក់ដើរពីក្រោយខ្នងអ្នក បុរសនោះ ប្រាថ្នាចង់បានអំពៅនោះ ហើយនិយាយសូម អ្នកមិនបាននិយាយពាក្យតិចតួចនឹងបុរសនោះទេ ។ ឯបុរសនោះ បាននិយាយសូមចំពោះអ្នកដែលមិននិយាយរក បាននិយាយនឹងអ្នកថា អ្នកចូរឲ្យអំពៅដល់ខ្ញុំ អ្នកក៏បានឲ្យអំពៅ ១ ដើម តាមក្រោយ

ខ្នង ដល់បុរសនោះ នេះជាផលរបស់បាបកម្មនោះឯង ។ ហ៎ បើដូច្នោះ អ្នកគប្បីទៅចាប់អំពៅពីក្រោយខ្នងចុះ លុះចាប់បានហើយ ចូរស៊ីឲ្យឆ្អែតចុះ អ្នកគង់មានចិត្តត្រេកអរ រីករាយ អណ្តែតឡើង ស្រោះស្រាយ ព្រោះតែបានបរិភោគអំពៅនោះ ។ បុរសនោះ ទៅចាប់យកអំពៅអំពីក្រោយខ្នងរបស់ខ្លួន លុះចាប់យកបានហើយ ក៏ស៊ីអំពៅនោះ ទាល់តែឆ្អែតឆ្អន់ រួចបុរសនោះមានចិត្តត្រេកអរ រីករាយ អណ្តែតឡើង ស្រស់ស្រាយ ។

## ចប់ រឿងឧច្ឆុប្រេតទី ៥ ។

# អដ្ឋកថា ឧច្ឆុប្រេត

[ ៤០ ] រឿងឧច្ឆុប្រេតនេះ មានពាក្យផ្តើមថា **ឥទំ មម ឧច្ឆុវនំ មហន្តំ** ដូច្នេះជាដើម ។

អត្ថុប្បត្តិហេតុនៃរឿងនោះដូចម្តេច កាលព្រះមានព្រះភាគគង់នៅវត្តវេឡុវនមហាវិហារ បុរសម្នាក់ចងបាច់អំពៅ ដើរស៊ីអំពៅមួយដើមទៅ ។ លំដាប់នោះ ឧបាសកម្នាក់ ជាអ្នកមានសីល មានកល្យាណធម៌ មួយអន្លើដោយកូនតូចដើរទៅអំពីខាងក្រោយ ។ កុមារឃើញអំពៅហើយ ក៏យំទារថា ចូរឲ្យ ឧបាសកឃើញកូនយំ កាលនឹងសង្គ្រោះបុរសនោះ ទើបចរចានឹងបុរសនោះ ឯបុរសនោះ មិនចរចាអ្វីជាមួយឧបាសកនោះ មិនឲ្យអំពៅដល់កុមារ ។ ឧបាសកក៏បង្ហាញក្មេងនោះ ហើយពោលថា កុមារនេះយំខ្លាំង សូម

អ្នកឲ្យអំពៅដល់ក្មេងនេះមួយកំណាត់ បុរសនោះបានស្តាប់ដូច្នោះ អត់ធន់មិនបាន កើតនូវការអាក់អន់ ទើបបោះអំពៅមួយកំណាត់ទៅក្រោយ ដោយមិនអើពើ ។

សម័យតមក បុរសនោះធ្វើកាលកិរិយាហើយ កើតក្នុងពួកប្រេត ដោយភាវៈនៃសេចក្តីលោភដែលគ្របសង្កត់មកយូរ ។ ឈ្មោះថា ផលនៃកម្មនោះរមែងឃើញដូចគ្នានឹងកម្មរបស់ខ្លួន ព្រោះហេតុនោះ ទើបកើតជាចម្ការអំពៅធំ ពេញដោយអំពៅ មានដើមប៉ុនៗអង្រែ មានពណ៌ដូចផ្កាអញ្ចន់ ពេញទីប្រមាណ ៨ ករីស លុះប្រេតនោះចូលទៅកាន់យក ព្រោះចង់បរិភោគអំពៅក៏វាយប្រេតនោះ ព្រោះហេតុនោះ ប្រេតនោះក៏ដួលសន្លប់ ។

ថ្ងៃមួយ ព្រះមហាមោគ្គល្លានចូលទៅបិណ្ឌបាត កាន់ក្រុងរាជគ្រឹះ បានឃើញប្រេតនោះត្រង់រវាងផ្លូវ ។ ប្រេតឃើញព្រះថេរៈហើយ ទើបសួរដល់កម្មដែលខ្លួនធ្វើ ។ គាថាសួរនិងគាថាឆ្លើយដែលប្រេត និងព្រះថេរៈពោលដូច្នេះថា

> ព្រៃអំពៅធំនេះ កើតឡើងដល់ខ្ញុំ ( ហាក់ដូច ) ជាផល
> បុណ្យច្រើនណាស់ដែរ តែឥឡូវនេះ ខ្ញុំមិនបានបរិភោគអំពៅ
> នោះសោះ បពិត្រលោកដ៏ចម្រើន សូមលោកប្រាប់ខ្ញុំ តើផល
> នេះជាផលកម្មអ្វី ។ មួយទៀត ខ្ញុំដល់នូវសេចក្តីចង្អៀតចង្អល់
> ចង់បរិភោគ ( ក៏បរិភោគមិនកើត ) ខ្ញុំខំប្រឹងខ្នះខ្នែងដើម្បី
> បរិភោគនូវរសនៃអំពៅតិចតួច ខ្ញុំនោះមានអត្តភាពដាច់ហើយ

ជាបុគ្គល កម្សត់ ប្រកបដោយទុក្ខ នេះជាផលនៃកម្មអ្វី ។ មួយទៀត ខ្ញុំជាបុគ្គលចង្អៀតចង្អល់ ដួលដេកបម្រះននៀល លើផែនដី ដូចត្រីនៅលើគោកដ៏ក្តៅ ទឹកភ្នែកទាំងឡាយរបស់ខ្ញុំ ហូរចេញអំពីចម្ងាយ បពិត្រលោកដ៏ចម្រើន សូមលោកមេត្តាប្រាប់ នេះជាផលនៃកម្មអ្វី ។ ខ្ញុំឃ្លានផង លំបាកផង ស្រេកផង តក់ស្លុតផង មិនបានសេចក្តីសុខស្រួលទេ បពិត្រលោកដ៏ចម្រើន ខ្ញុំសូមសួរសេចក្តីនុ៎ះ ចំពោះនឹងលោកម្ចាស់ធ្វើម្តេចហ្ន៎ ខ្ញុំគប្បីបានបរិភោគអំពៅ ( នេះ ) ។

ព្រះមហាមោគ្គល្លានត្ថេរពោលថា

កាលពីដើម អ្នកកើតជាមនុស្ស បានធ្វើបាបកម្មដោយខ្លួនឯង ក្នុងកាលមុន អាត្មារៀបរាប់សេចក្តីនោះប្រាប់អ្នក អ្នកស្តាប់ហើយត្រូវដឹងសេចក្តីនោះចុះ ។ ( កាលនោះ ) អ្នកកំពុងដើរស៊ីអំពៅ មានបុរសម្នាក់ដើរពីក្រោយខ្នងអ្នក បុរសនោះប្រាថ្នាចង់បានអំពៅនោះ ហើយនិយាយសូម អ្នកមិនបាននិយាយពាក្យតិចតួចនឹងបុរសនោះទេ ។ ឯបុរសនោះ បាននិយាយសូមចំពោះអ្នកដែលមិននិយាយរក បាននិយាយនឹងអ្នកថា អ្នកចូរឲ្យអំពៅដល់ខ្ញុំ អ្នកក៏បានឲ្យអំពៅ ១ ដើមតាមក្រោយខ្នង ដល់បុរសនោះ នេះជាផល របស់បាបកម្មនោះឯង ។ ហ៎ បើដូច្នោះ អ្នកគប្បីទៅចាប់អំពៅពីក្រោយ

ខ្ទង់ចុះ លុះចាប់បានហើយ ចូរស៊ីឲ្យឆ្អែតចុះ អ្នកគង់មានចិត្ត ត្រេកអរ រីករាយ អណ្តែតឡើង ស្រោះស្រាយ ព្រោះតែបានបរិភោគអំពៅនោះ ។ បុរសនោះ ទៅចាប់យកអំពៅ អំពីក្រោយខ្នងរបស់ខ្លួន លុះចាប់យកបានហើយ ក៏ស៊ីអំពៅនោះទាល់តែឆ្អែតឆ្អន់ រួចបុរសនោះ មានចិត្តត្រេកអរ រីករាយ អណ្តែតឡើង ស្រស់ស្រាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិស្ស** អធិប្បាយថា នៃកម្មដូចម្តេច ។ បទថា **វិហញ្ញាមិ** បានដល់ ខ្ញុំវង្វេងក្តៅក្រហាយគឺដល់ការបង្អៀតបង្អល់ ។ម្យ៉ាងទៀត បទថា **វិហញ្ញាមិ** បានដល់ រមែងបៀតបៀន អធិប្បាយថា រមែងបៀតបៀនដោយពិសេស ។ បទថា **ឃដ្ដាមិ** បានដល់ ត្រូវអំពៅមុត អធិប្បាយថា ត្រូវស្ទីកអំពៅចូត ដូចសស្ត្រាដ៏មុត ដូចដាវវះ ។ បទថា **វាយមាមិ** បានដល់ ខ្ញុំធ្វើសេចក្តីព្យាយាមដើម្បីបរិភោគអំពៅ ។ បទថា **បរិសក្កាមិ** បានដល់ ខ្នះខ្នែង ។ បទថា **បរិភុញ្ជិតុំ** សេចក្តីថា ដើម្បីបរិភោគអំពៅ អធិប្បាយថា ដើម្បីទឹងទំពាអំពៅ ។ បទថា **ឆិន្នថាមោ** ប្រែថា អស់កម្លាំង គឺកម្លាំងដាច់ទៅ អធិប្បាយថា កម្លាំងអស់ទៅ ។ បទថា **កបណោ** បានដល់ ជាបុគ្គលក្រីក្រ ។ បទថា **លាលបាមិ** សេចក្តីថា ខ្ញុំត្រូវទុក្ខគ្របសង្កត់ ទើបរវើរវាយផ្សេងៗ ។

បទថា **វិឃាតោ** ប្រែថា មានការបង្អៀតបង្អល់ ឬត្រូវកម្ចាត់កម្លាំង ។ បទថា **បរិបតាមិ ឆមាយំ** សេចក្តីថា កាលមិនអាចតម្កល់ខ្លួនបាន ក៏ដួល

ចុះលើផែនដី ។ បទថា **បរិវត្តាមិ** បានដល់ រមែងវិលទៅ ។ បទថា **វារិ-ចរោវ** ប្រែថា ដូចត្រី ។ បទថា **ឃម្មេ** បានដល់ លើគោកដ៏ក្តៅដោយកម្តៅ ។ បទថា **សន្តស្សិតោ** បានដល់ ស្រេកខ្លាំង ព្រោះបបូរមាត់ **ក** និងពិតាន ដល់នូវការស្ងួត ។ បទថា **សាតសុខំ** បានដល់ សេចក្តីសុខដែលជាសេចក្តីសុខសាន្ត ។ បទថា **ន វិន្ទេ** បានដល់ រមែងមិនបាន ។ បទថា **តំ** ប្រែថា និងអ្នក ។ បទថា **វិជាន** ប្រែថា ចូរដឹង ។ បទថា **បយាតោ** ប្រែថា ផ្តើមទឹងទៅ ។ បទថា **អនុគច្ឆិ** បានដល់ ដើរតាម ។ បទថា **បច្ចាសន្តោ** បានដល់ បំណងចំពោះ ។ បទថា **ឃតំ** ក្នុងបទថា **តស្សេតំ កម្មស្ស** នេះ ត្រឹមតែជានិបាត អធិប្បាយថា នៃកម្មនោះ ។ បទថា **បិដ្ឋិតោ គណ្ហេយ្យា-សិ** សេចក្តីថា គប្បីកាន់យកអំពៅអំពីខាងក្រោយខ្នងរបស់ខ្លួន នោះឯង ។ បទថា **បមោទិតោ** បានដល់ ត្រេកអរ ។

បទថា **គហេត្វាន តំ ខាទិ យាវទត្ថំ** សេចក្តីថា ប្រេតកាន់យកអំពៅ ដោយទំនង ដែលព្រះថេរៈប្រាប់ ហើយទំពាស៊ីតាមគាប់ចិត្ត កាន់យកបាច់អំពៅធំ បង្អោនចូលទៅប្រគេនព្រះថេរៈ ព្រះថេរៈកាលអនុគ្រោះ ទើបឲ្យប្រេតនោះ កាន់យកបាច់អំពៅនោះ ទៅកាន់វេឡុវនមហាវិហារ បានថ្វាយដល់ព្រះមានព្រះភាគ មួយអន្ទើដោយភិក្ខុសង្ឃ ឆាន់អំពៅនោះហើយធ្វើអនុមោទនា ប្រេតមានចិត្តជ្រះថ្លា ថ្វាយបង្គំហើយក៏ទៅ តាំងអំពីកាលនោះមក ប្រេតក៏បរិភោគអំពៅតាមត្រូវការ ។

សម័យតមក ប្រេតនោះ ធ្វើកាលកិរិយាហើយ កើតក្នុងទេវតាជាន់

តាវត្តិង្ស ។ ប្រវត្តិរបស់ប្រេតនេះ បានប្រាកដក្នុងមនុស្សលោក លំដាប់នោះ ពួកមនុស្សចូលទៅគាល់ព្រះសាស្តា ទូលសួររឿងនោះ ព្រះសាស្តាត្រាស់រឿងនោះដល់មនុស្សទាំងនោះដោយពិស្តារ ហើយទ្រង់សម្តែងធម៌ ។ ពួកមនុស្សបានស្តាប់ធម៌នោះហើយ បានជាអ្នកវៀរចាកសេចក្តីកំណាញ់ដូច្នេះ ។

## អដ្ឋកថា ឧច្ឆុប្រេតចប់

# រឿងកុមារប្រេតទី៦

[ ៤១ ] ( ព្រះមានព្រះភាគត្រាស់ថា ) តថាគតឮថា ក្រុងឈ្មោះសាវត្ថីនៅក្បែរព្រៃហិមពាន្ត ក្នុងក្រុងនោះមានកុមារ ២ នាក់ ជាព្រះរាជបុត្តរបស់ ( ព្រះបាទបសេនទិកោសល ) ។ ព្រះរាជបុត្តទាំង ២ អង្គនោះជាអ្នកប្រមាទ ជាអ្នកមានសេចក្តីត្រេកអរក្នុងកាមគុណទាំងឡាយជាទីត្រេកអរ ជាប់ជំពាក់នឹងសេចក្តីសុខជាបច្ចុប្បន្ន ព្រះរាជបុត្តទាំងនោះ មិនបានឃើញសេចក្តីសុខទៅក្នុងអនាគតកាលឡើយ ។ ព្រះរាជបុត្តទាំងនោះ ទៅកាន់លោកខាងមុខ ចាកអត្តភាពជាមនុស្ស ព្រះរាជបុត្តទាំង ២ នោះ មិនប្រាកដរូប ស្រែកប្រកាសតែអំពើអាក្រក់របស់ខ្លួនក្នុងកាលមុន ។ កាលទក្ខិណេយ្យបុគ្គលទាំងឡាយមានច្រើន កាលទេយ្យធម៌មាន ពួកយើងមិនអាចដើម្បីធ្វើខ្លួនឲ្យមានសួស្តីតិចតួច ជាទីនាំមកនូវសេចក្តីសុខសោះ ។ អំពើអាក្រក់អ្វី ជាអំពើអាក្រក់ជាងអំពើរបស់យើងនោះ ពួកយើងច្យុតចាករាជត្រកូល មកកើតជាប្រេតវិស័យ ( ក្នុងទីនេះ ) ប្រកបដោយសេចក្តីស្រេកនិងការឃ្លាន ។ ពួកមនុស្សជាម្ចាស់គេក្នុងលោកនេះ ពុំមែនជាម្ចាស់ក្នុងលោកឯណោះទៀតទេ បានខ្ពស់ហើយ ត្រឡប់ទាបវិញ ( ព្រោះតណ្ហា ) តែងស្លាប់ដោយសេចក្តីស្រេកឃ្លាន ។ នរជនដឹងទោស ដែលកើតអំពីសេចក្តីប្រកាន់ថាធំ យ៉ាងនេះហើយគប្បី លះនូវសេចក្តីស្រវឹងថាធំចោលចេញ ទើបទៅឋានសួគ៌ នរជននោះជាអ្នកប្រកបដោយប្រាជ្ញា ដល់បែកធ្លាយរាងកាយរមែងកើតក្នុងឋានសួគ៌ ។

ចប់ រឿងកុមារប្រេតទី ៦ ។

# អដ្ឋកថា កុមារប្រេត

[ ៤១ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេត ២ នាក់ ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **សាវត្ថី ឆាម ឆគរំ** ដូច្នេះ ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី ព្រះបាទកោសលមានឱរស ២ អង្គ គួរឲ្យពេញចិត្ត កំពុងនៅក្នុងបឋមវ័យ ស្រវឹងក្នុងវ័យក្មេង ធ្វើការគប់រកនូវកិរិយាអ្នកដទៃ ធ្វើកាលកិរិយាហើយ កើតជាប្រេត អាស្រ័យលើខ្នងប្រឡាយ ។ ក្នុងពេលរាត្រី ប្រេតទាំងនោះនាំគ្នាស្រែកយំ ដោយសំឡេងគួរខ្លាច ពួកមនុស្សស្តាប់សំឡេងនោះ នាំគ្នាភិតភ័យ គិតថា កាលពួកយើងធ្វើយ៉ាងនេះ អពមង្គលនេះតែងស្ងប់ ទើបនាំគ្នាថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាសកនិងឧបាសិកាទាំងឡាយ ព្រោះបានឮសំឡេងនោះ អន្តរាយណាមួយរមែងមិនមានដល់ពួកអ្នកឡើយ ដើម្បីត្រាស់ប្រាប់ហេតុនៃសំឡេងនោះ បានសម្តែងធម៌ដល់មនុស្សទាំងនោះ ទើបត្រាស់គាថាថា

> តថាគតឮថា ក្រុងឈ្មោះសាវត្ថីនៅក្បែរព្រៃហិមពាន្ត ក្នុងក្រុងនោះមានកុមារ ២ នាក់ ជាព្រះរាជបុត្តរបស់ ( ព្រះបាទបសេនទិកោសល ) ។ ព្រះរាជបុត្តទាំង ២ អង្គនោះជាអ្នកប្រមាទ ជាអ្នកមានសេចក្តីត្រេកអរ ក្នុងកាមគុណទាំងឡាយ ជាទីត្រេកអរ ជាប់ជំពាក់នឹងសេចក្តីសុខជាបច្ចុប្បន្ន ព្រះរាជ-

បុត្តទាំងនោះ មិនបានឃើញសេចក្ដីសុខទៅក្នុងអនាគតកាលឡើយ ។ ព្រះរាជបុត្តទាំងនោះ ទៅកាន់លោកខាងមុខ ចាកអត្តភាពជាមនុស្ស ព្រះរាជបុត្តទាំង ២ នោះ មិនប្រាកដរូបស្រែកប្រកាសតែអំពើអាក្រក់របស់ខ្លួនក្នុងកាលមុន ។ កាលទក្ខិណេយ្យបុគ្គលទាំងឡាយមានច្រើន កាលទេយ្យធម៌មានពួកយើងមិនអាចដើម្បីធ្វើខ្លួនឲ្យមានសួស្ដីតិចតួច ជាទីនាំមកនូវសេចក្ដីសុខសោះ ។ អំពើអាក្រក់អ្វី ជាអំពើអាក្រក់ជាងអំពើរបស់យើងនោះ ពួកយើងច្យុតចាករាជត្រកូល មកកើតជាប្រេតវិស័យ ( ក្នុងទីនេះ ) ប្រកបដោយសេចក្ដីស្រេកនិងការឃ្លាន ។ ពួកមនុស្សជាម្ចាស់គេក្នុងលោកនេះ ពុំមែនជាម្ចាស់ក្នុងលោកឯណោះទៀតទេ បានខ្ពស់ហើយ ត្រឡប់ទាបវិញ ( ព្រោះតណ្ហា ) តែងស្លាប់ដោយសេចក្ដីស្រេកឃ្លាន ។ នរជនដឹងទោស ដែលកើតអំពីសេចក្ដីប្រកាន់ថាធំ យ៉ាងនេះហើយគប្បីលះនូវសេចក្ដីស្រវឹងថាធំចោលចេញ ទើបទៅឋានសួគ៌ នរជននោះជាអ្នកប្រកបដោយប្រាជ្ញា ដល់បែកធ្លាយរាងកាយរមែងកើតក្នុងឋានសួគ៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥតិ មេ សុតំ** សេចក្ដីថា តថាគតបានឃើញដោយញាណរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ដោយពិត តថាគតបានស្ដាប់មកយ៉ាងនេះដោយប្រាកដក្នុងលោក ។ បទថា **កាមស្សាទា ភិ-**

**ឆន្ទិនោ** បានដល់ មានប្រក្រតីត្រេកអរ ដោយអំណាចការត្រេកអរក្នុងកាមគុណ ។ បទថា **បច្ចុប្បន្នសុខេ គិទ្ធា** បានដល់ ជាអ្នកជាប់ គឺចំពាក់ក្នុងអារម្មណ៍ជាទីស្រឡាញ់ ដែលត្រឹមតែជាសុខក្នុងបច្ចុប្បន្ន ។ បទថា **ន តេ បស្សឹសុនាគតំ** សេចក្តីថា ព្រះរាជកុមារទាំង ២ អង្គនោះ មិនគិតដល់សុខដែលខ្លួនត្រូវលះទុច្ចរិត ប្រព្រឹត្តសុចរិត ហើយគប្បីបានក្នុងទេវតានិងមនុស្សក្នុងអនាគត គឺក្នុងកាលតទៅ ។

បទថា **តេធ ឃោសេន្តុទិស្សន្តា** សេចក្តីថា ប្រេតទាំងនោះ កាលមុនជារាជឱរស មានរូបមិនប្រាកដ ទ្រហោយំក្នុងទីជិតក្រុងសាវត្ថីនេះ ។ ដើម្បីចៀសវាងពាក្យសួរថា យំរៀបរាប់ដូចម្តេច ទើបលោកពោលថា ស្រែកប្រកាសតែអំពើអាក្រក់របស់ខ្លួនក្នុងកាលមុន ដូច្នេះ ។

ឥឡូវនេះ ដើម្បីនឹងសម្តែងចែកហេតុនៃការខ្សឹកខ្សួល របស់ប្រេតទាំងនោះ ដោយហេតុនិងផល ទើបលោកពោលថា កាលទក្ខិណេយ្យបុគ្គលទាំងឡាយមានច្រើន ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ពហូសុ វត សន្តេសុ** បានដល់ កាលទក្ខិណេយ្យបុគ្គលជាច្រើនមាន ។ បទថា **ទេយ្យធម្មេ ឧបដ្ឋិតេ** សេចក្តីថា កាលទេយ្យធម៌ដែលគួរឲ្យ ជារបស់ខ្លួនដែលធ្វើទុកហើយក្នុងទីជិត អធិប្បាយថាដែលនឹងបាន ។ បទថា **បរិត្តំ សុខាវហំ** មានវាចាប្រកបសេចក្តីថា ខ្ញុំមិនអាចធ្វើបុណ្យ ដែលជាហេតុនាំមកនូវសេចក្តីសុខក្នុងអនាគត សូម្បីមាននូវប្រមាណតិចតួច ហើយធ្វើខ្លួនឲ្យមានសួស្តី គឺឲ្យប្រាសចាកឧបទ្រវន្តរាយ ។

បទថា **កឹ តតោ ចាបកំ អស្ស** សេចក្តីថា គប្បីមានកម្មអ្វី គឺកម្មដទៃដែលឈ្មោះថា អាក្រក់ គឺអាក្រក់ជាងកាមនោះ ។ បទថា **យំ នោ រាជកុលា ចុតា** សេចក្តីថា ព្រោះបាបកម្មឯណា ទើបខ្ញុំចុតិអំពីរាជត្រកូល កើតនៅក្នុងបិត្តិវិស័យនេះ គឺកើតក្នុងពួកប្រេត ដល់ព្រមដោយការស្រេកឃ្លានត្រាច់ទៅ ។

បទថា **សាមិនោ ឥធ ហុត្វាន** សេចក្តីថា កាលមុន រាជបុត្តត្រាច់ទៅជាម្ចាស់ទ្រព្យក្នុងទីណាក្នុងលោកនេះ តែមិនជាម្ចាស់ក្នុងទីនោះឯង ។ ដោយបទថា **មនុស្សា ឧណ្ណតោនតា** លោកសម្តែងថា ក្នុងកាលជាមនុស្ស រាជកុមារទាំងនោះជាម្ចាស់ទ្រព្យ ធ្វើកាលកិរិយាហើយ ភាពជាម្ចាស់ ក៏វិនាសដោយអំណាចកម្មបន្ទាត់ទៅ ដល់នូវការស្រេកឃ្លាន ចូរឃើញប្រក្រតីនៃសង្សារ ។

បទថា **ឯតមាទីនវំ ញត្វា ឥស្សរមទសម្ភវំ** សេចក្តីថា នរជនដឹងនូវទោស ពោលគឺការកើតក្នុងអបាយដែលកើតដោយសេចក្តីស្រវឹងក្នុងភាពជាធំនេះហើយលះនូវសេចក្តីស្រវឹងក្នុងភាពជាធំចេញ ខ្វល់ខ្វាយតែក្នុងបុណ្យ ។ បទថា **ភវេ សគ្គគតោ នរោ** សេចក្តីថា គប្បីទៅកាន់ស្ថានសួគ៌ គឺទេវលោក ប៉ុណ្ណោះ ។

ព្រះសាស្តា កាលត្រាស់បវត្តិរបស់ប្រេតទាំងនោះ ដោយប្រការដូច្នេះ ហើយទ្រង់ឲ្យឧទ្ទិសទានដែលមនុស្សទាំងឡាយនោះ ធ្វើដល់ពួកប្រេតទាំងនោះ ហើយទ្រង់សម្តែងធម៌ សមគួរដល់អធ្យាស្រ័យរបស់បរិស័ទ ដែលប្រជុំគ្នា

ទេសនានោះ មានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា កុមារប្រេតចប់

# រឿង រាជបុត្តប្រេត ទី ៧

[ ៤២ ] ( ព្រះមានព្រះភាគត្រាស់សម្តែងរឿងរាជបុត្តប្រេតនេះថា ) ផលរបស់បាបកម្មទាំងឡាយដែលរាជបុត្តធ្វើហើយក្នុងកាលពីដើម គប្បីញ៉ាំញីនូវចិត្ត ព្រោះរូប សំឡេង ក្លិន រស ផ្សព្វនិងធម្មារម្មណ៍ ។ រាជបុត្តចូលចិត្តនឹងការរាំ ការច្រៀង ការត្រេកអរនិងការសើចចំអកឡកឡឺយដ៏ច្រើន ដើរលេងក្នុងឧទ្យាន រួចចូលទៅក្រុងរាជគ្រឹះវិញ ។ រាជបុត្តនោះ បានឃើញឥសី ( ព្រះបច្ចេកពុទ្ធ ) ឈ្មោះសុនេត្តៈ លោកមានចិត្តទូន្មានហើយ មានចិត្តតម្កល់មាំ ប្រាថ្នាតិច ប្រកបដោយហិរិ ត្រេកអរតែនឹងចង្ហាន់ក្នុងបាត្រដោយការស្វែងរក ។

ក្សត្រចុះពីកដំរីហើយសួរថា បពិត្រលោកដ៏ចម្រើន បានចង្ហាន់ដែរឬទេ ហើយទទួលយកបាត្ររបស់លោក លើកឡើងឲ្យខ្ពស់ បោកបំបែកបាត្រលោកលើដីរដិបរដុប ហើយសើចលេង ដើរចេញទៅ ( និយាយថា ) ខ្ញុំជាកូនរបស់ព្រះបាទកិតវៈ នែភិក្ខុ លោកនឹងធ្វើអ្វីដល់ខ្ញុំ ។ ផលដ៏ក្តៅក្រហាយរបស់បាបកម្មដ៏អាក្រក់នោះឯង នាំរាជបុត្តឲ្យរងទុក្ខពេញពោរក្នុងនរក ។ រាជបុត្តបានធ្វើអំពើអាក្រក់ ក៏ដល់នូវសេចក្តីទុក្ខក្រៃលែង ក្នុងនរក ប្រាំបួនសែន ( ៩០០០០០ ) ឆ្នាំ ។ ជនពាលទុកជាដេកផ្ងារក្តី ផ្កាប់ក្តី ផ្អៀងទៅខាងឆ្វេងខាងស្តាំក្តី ជើងឡើងលើក្តី ឈរក្តី រមែងឆេះអស់កាលដ៏យូរ ។ ជនពាលបានធ្វើអំពើអាក្រក់ ក៏ទទួលទុក្ខដ៏ក្រៃលែងក្នុងនរក ច្រើនពាន់ឆ្នាំផង ច្រើនម៉ឺនឆ្នាំផង ។ បុគ្គលអ្នកមានបាបកម្ម តែងទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែងជាទុក្ខក្តៅផ្សា ប្រាកដដូច្នោះ ព្រោះតែប្រទូស្តនឹងឥសី អ្នកមិនបានប្រទូស្ត

មានវត្តល្អ ។ រាជបុត្តនោះទទួលនូវសេចក្តីទុក្ខដ៏ច្រើន ក្នុងនរកនោះអស់ឆ្នាំទាំងឡាយដ៏ច្រើន ច្យុតចាកនរកនោះមក មកកើតជាប្រេត មានសេចក្តីស្រេកឃ្លានបៀតបៀនហើយ ។ បុរសបុគ្គលដឹងទោសជាដែនកើតនៃសេចក្តីស្រវឹង ព្រោះឥស្សរិយយស យ៉ាងនេះហើយ គប្បីលះបង់នូវសេចក្តីស្រវឹងព្រោះតែឥស្សរិយយស ហើយប្រព្រឹត្តបន្ទាបបន្ទន់កាយ ។ ជនណាជាបុគ្គលដែលគេសរសើរក្នុងបច្ចុប្បន្ន ជាអ្នកគោរពក្នុងព្រះពុទ្ធ ជននោះជាអ្នកប្រកបដោយប្រាជ្ញា លុះបែកធ្លាយរាងកាយទៅ រមែងកើតក្នុងឋានសួគ៌ ។

## ចប់ រឿងរាជបុត្តប្រេតទី ៧ ។

# អដ្ឋកថា រាជបុត្តប្រេត

[ ៤២ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធរាជបុត្តប្រេត ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **បុព្វេ កតានំ កម្មានំ** ដូច្នេះជាដើម ។

ក្នុងរឿងនោះ ក្នុងអតីតកាល ឱរសរបស់ព្រះបាទកិតវៈ ខុសក្នុងព្រះបច្ចេកពុទ្ធក្នុងអតីត ឆេះក្នុងនរកច្រើនពាន់ឆ្នាំ ដោយសេសនៃវិបាករបស់កម្មនោះឯង ទៅកើតក្នុងពួកប្រេត លោកបំណងយករាជបុត្តប្រេតនោះក្នុងទីនេះ ។ រឿងរបស់រាជបុត្តប្រេតនោះ មកដោយពិស្តារ ក្នុងរឿងសានុវាសិប្រេតខាងដើមនោះឯង ព្រោះដូច្នោះ គួរកាន់យកដោយន័យដែលពោលហើយក្នុងរឿងសានុវាសិប្រេតនោះឯង ។ ពិតហើយ ក្នុងកាលនោះ កាលព្រះថេរៈពោលប្រវត្តិរបស់ប្រេតដែលជាញាតិរបស់ខ្លួន ទើបព្រះសាស្តាត្រាស់ថាមិនមែនប្រេតជាញាតិរបស់អ្នកតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីអ្នក ក៏ធ្លាប់ទៅអំពីលោកនេះ កើតជាប្រេត សោយទុក្ខធំក្នុងអត្តភាពដែលជាអតីតដោយលំដាប់ ដូច្នេះ កាលព្រះថេរៈនោះទូលអារាធនាហើយ ទើបត្រាស់បេតវត្ថុនេះថា

ផលរបស់បាបកម្មទាំងឡាយ ដែលរាជបុត្តធ្វើហើយក្នុងកាលពីដើម គប្បីញាំញីនូវចិត្តព្រោះរូប សំឡេង ក្លិន រស ផស្សនិងធម្មារម្មណ៍ ។ រាជបុត្ត ចូលចិត្តនឹងការរាំ ការច្រៀង ការត្រេកអរ និងការសើចចំអកឡកឡឺយដ៏ច្រើន ដើរលេងក្នុងឧទ្យាន រួចចូលទៅក្រុងរាជគ្រឹះវិញ ។ រាជបុត្តនោះ បាន

ឃើញឥសី ( ព្រះបច្ចេកពុទ្ធ ) ឈ្មោះសុនេត្តៈ លោកមានចិត្តទូន្មានហើយ មានចិត្តតម្កល់មាំ ប្រាថ្នាតិច ប្រកបដោយហិរិ ត្រេកអរតែនឹងចង្ហាន់ក្នុងបាត្រដោយការស្វែងរក ។

ក្សត្រចុះពីកដំរីហើយសួរថា បពិត្រលោកដ៏ចម្រើន បានចង្ហាន់ដែរឬទេ ហើយទទួលយកបាត្ររបស់លោក លើកឡើងឲ្យខ្ពស់ បោកបំបែកបាត្រលោក លើដីរដិបរដុប ហើយសើចលេង ដើរចេញទៅ ( និយាយថា ) ខ្ញុំជាកូនរបស់ព្រះបាទកិតវៈ នែភិក្ខុ លោកនឹងធ្វើអ្វីដល់ខ្ញុំ ។ ផលដ៏ក្តៅក្រហាយរបស់បាបកម្មដ៏អាក្រក់នោះឯង នាំរាជបុត្តឲ្យរងទុក្ខពេញពោរក្នុងនរក ។ រាជបុត្តបានធ្វើអំពើអាក្រក់ ក៏ដល់នូវសេចក្តីទុក្ខក្រៃលែងក្នុងនរក ប្រាំបួនសែន ( ៩០០០០០ ) ឆ្នាំ ។ ជនពាលទុកជាដេកផ្ងារក្តី ផ្កាប់ក្តី ផ្អៀងទៅខាងឆ្វេង ខាងស្តាំក្តី ជើងឡើងលើក្តី ឈរក្តី រមែងឆេះអស់កាលដ៏យូរ ។ ជនពាលបានធ្វើអំពើអាក្រក់ ក៏ទទួលទុក្ខដ៏ក្រៃលែងក្នុងនរកច្រើនពាន់ឆ្នាំផង ច្រើនម៉ឺនឆ្នាំផង ។ បុគ្គលអ្នកមានបាបកម្ម តែងទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែង ជាទុក្ខក្តៅផ្សា ប្រាកដដូច្នោះព្រោះតែប្រទូស្តនឹងឥសីអ្នកមិនបានប្រទូស្ត មានវត្តល្អ ។ រាជបុត្តនោះទទួលនូវសេចក្តីទុក្ខដ៏ច្រើនក្នុងនរកនោះ អស់ឆ្នាំទាំងឡាយដ៏ច្រើន ច្យុតចាកនរកនោះមក មកកើតជាប្រេត មាន

សេចក្តីស្រេកឃ្លានបៀតបៀនហើយ ។ បុរសបុគ្គលដឹងទោស ជាដែនកើតនៃសេចក្តីស្រវឹងព្រោះឥស្សរិយយស យ៉ាងនេះ ហើយ គប្បីលះបង់នូវសេចក្តីស្រវឹងព្រោះតែឥស្សរិយយស ហើយប្រព្រឹត្តបន្ទាបបន្ទន់កាយ ។ ជនណាជាបុគ្គលដែលគេ សរសើរក្នុងបច្ចុប្បន្ន ជាអ្នកគោរពក្នុងព្រះពុទ្ធ ជននោះជាអ្នក ប្រកបដោយប្រាជ្ញា លុះបែកធ្លាយរាងកាយទៅ រមែងកើត ក្នុងឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វេ កតានំ កម្មានំ វិបាកោ មថយេ មនំ** សេចក្តីថា ផលនៃអកុសលកម្មដែលព្រះរាជឱរសធ្វើទុកក្នុងជាតិមុនកើត ជាផលដ៏ក្រៃលែង ញាំញី គ្របសង្កត់ចិត្តរបស់អន្ធពាល អធិប្បាយថា គប្បី ញុំាងប្រយោជន៍ខ្លួនឲ្យកើតឡើង បំណងនឹងធ្វើសេចក្តីវិនាសឲ្យដល់អ្នកដទៃ ។

ឥឡូវនេះ គប្បីសម្តែងផលនៃអកុសលកម្មនោះ ដែលជាគ្រឿងញាំញី ចិត្ត មួយអន្លើដោយអារម្មណ៍ ទើបពោលពាក្យជាដើមថា **រូបេ សទ្ទេ** ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ បទថា **រូបេ** បានដល់ ព្រោះហេតុនៃរូប អធិប្បាយថា ព្រោះបានរូបាអារម្មណ៍តាមដែលប្រាថ្នា ដែលគួរពេញចិត្ត ជា និមិត្ត ។ សូម្បីក្នុងបទថា **សទ្ទេ** ជាដើម ក៏មានន័យដូចគ្នា ។ កាលទ្រង់ សម្តែងកំណត់សេចក្តី ដែលពោលហើយដោយទូទៅ ដោយជាសេចក្តីមិន ទូទៅយ៉ាងនេះទើបត្រាស់ពាក្យថា **ឆដ្ឋំ គីតំ** ដូច្នេះជាដើម ។ បណ្តាបទទាំង នោះ បទថា **រតី** បានដល់ នូវការត្រេកអរក្នុងកាម ។ បទថា **ខិឌ្ឌំ** បាន

ដល់ ការលេងដោយសម្ពាញ់ ជាដើម ។ បទថា **គិរិព្វជំ** បានដល់ នគររាជគ្រឹះ ។

បទថា **ឥសី** សេចក្ដីថា ឈ្មោះថា ឥសី ព្រោះអត្ថថា ជាអ្នកស្វែងរកគុណធំ មានសីលក្ខន្ធជាដើមដែលជារបស់ព្រះអសេក្ខៈ ។ បទថា **សុនេត្តំ** បានដល់ ព្រះបច្ចេកពុទ្ធដែលមានព្រះនាមយ៉ាងនេះ ។ បទថា **អត្តទន្តំ** បានដល់ ជាអ្នកមានចិត្តទូន្មានហើយ ដោយការទូន្មានដ៏ឧត្ដម ។ បទថា **សមាហិតំ** បានដល់ ជាអ្នកមានចិត្តតាំងមាំហើយ ដោយសមាធិដែលសម្បយុត្តដោយអរហត្តផល ។ បទថា **ឧញ្ឆេ បត្តគតេ រតំ** បានដល់ ជាអ្នកត្រេកអរ គឺសន្ដោសក្នុងអាហារដែលនៅក្នុងបាត្រ គឺដែលទាក់ទងក្នុងបាត្រ ដែលបានមកដោយការស្វែងរក គឺដោយការត្រាច់បិណ្ឌបាត ។

បទថា **លទ្ធា ភន្តេតិ ចាព្រវិ** សេចក្ដីថា ត្រាស់ដើម្បីឲ្យកើតនូវការស្និទ្ធស្នាលថា បពិត្រលោកដ៏ចម្រើន បានចង្ហាន់ដែរឬទេ ។ បទថា **ឧច្ចំ បគ្គយ្ហ** បានដល់ លើកបាត្រឡើងឲ្យខ្ពស់ ។ បទថា **ថណ្ឌិលេ បត្តំ ភិន្ទិត្វា** បានដល់ បោកបំបែកនូវបាត្រក្នុងប្រទេសដែលរឹង ។ បទថា **អបក្កមិ** បានដល់ ចៀសទៅបន្តិច ព្រះរាជឱរសកាលចៀសចេញទៅបន្តិច ទើបត្រាស់ថា ខ្ញុំជាកូនរបស់ព្រះបាទកិតវៈ នែភិក្ខុ លោកនឹងធ្វើអ្វីដល់ខ្ញុំ ដូច្នេះ ព្រះបច្ចេកពុទ្ធសម្លឹងមើលដោយករុណាថា បុគ្គលអន្ធពាល ធ្វើនូវសេចក្ដីវិនាសដ៏ធំឲ្យដល់ខ្លួន ដោយហេតុដែលមិនសមគួរឡើយ ។

បទថា **ផរុសស្ស** ប្រែថា គ្រោតគ្រាត ។ បទថា **កដុកោ** បានដល់

មិនគួរប្រាប្ថា ។ បទថា **យំ** យោគជា **វិចាកំ** ប្រែថា វិបាកណា ។ បទថា **សម្មប្បិតោ** បានដល់ គិតហើយ ។ បទថា **ឆឡេវ ចតុរាសីតិ វស្សានិ ឆហុតានិ** ច សេចក្ដីថា ដេកផ្ងារ ដេកផ្កាប់ ដេកផ្អៀងឆ្វេង ដេកផ្អៀងស្ដាំ យកជើងឡើងលើ ក្បាលចុះក្រោម និងឈរ មួយឥរិយាបថៗ ៨៤០០០ ឆ្នាំ រួមជា ៦ ដង ម្ដងៗ ៨៤០០០ ដោយហេតុនោះ ទើបលោកពោលថា

ជនពាល ទុកជាដេកផ្ងារក្ដី ផ្កាប់ក្ដី ផ្អៀងទៅខាងឆ្វេង ខាង
ស្ដាំក្ដី ជើងឡើងលើក្ដី ឈរក្ដី រមែងឆេះអស់កាលដ៏យូរ ។

ព្រោះហេតុដែលមានច្រើនម៉ឺនឆ្នាំ ដូច្នោះ ទើបលោកហៅថា **ឆហុតានិ** ប្រែថា ច្រើនម៉ឺនឆ្នាំ ។ បទថា **ភុសំ ទុក្ខំ និគច្ឆិន្តោ** ប្រែថា ជួបនូវសេចក្ដីទុក្ខក្រៃលែង ។

បទថា **បូគានិ** បានដល់ ក្នុងការប្រជុំនៃឆ្នាំ តែក្នុងគាថានេះនិងគាថាដើម គប្បីឃើញថា ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃអច្ចន្តសំយោគ ប្រែថា រហូត ។

បទថា **ឯតាទិសំ** គឺបែបនេះ ។ បទថា **កដុកំ** បានដល់ ទុក្ខធ្ងន់នេះ ជាការសម្ដែងចេញនៃនបុំសលិង្គ ដូចក្នុងប្រយោគថា **ឯកមន្តំ និសីទិ** អង្គុយក្នុងចំណែកម្ខាង ជាដើម ។ មានវាចាប្រកបសេចក្ដីថា បុគ្គលមានការងារដ៏លាមកនាំគ្នាប្រទូស្ត គឺបៀតបៀនឥសី ( ព្រះបច្ចេកពុទ្ធ ) ដែលមិនប្រទូស្ត មិនក្រោធ ជាអ្នកមានវត្តល្អ រមែងជួបនូវទុក្ខមានសភាព បែបនេះ ដែលជាទុក្ខដ៏ផ្សាក្ដៅក្រៃលែង ។

បទថា **សោ** បានដល់ រាជបុត្តប្រេតនោះ ។ បទថា **តត្ថ** គឺក្នុងនរក ។ បទថា **វេទយិត្វា** ប្រែថា សោយ ។ បទថា **ឆាម** បានដល់ ដោយភាពជាបុគ្គលប្រាកដដោយជាក់ច្បាស់ ។ បទថា **តតោ ចុតោ** បានដល់ ចុតិអំពីនរក ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ព្រះមានព្រះភាគ ទ្រង់ឲ្យមហាជនដែលប្រជុំគ្នាក្នុងទីនោះ កើតនូវសេចក្តីសង្វេគ ដោយកថាពោលដោយរាជបុត្តប្រេតយ៉ាងនេះហើយ ទើបប្រកាសសច្ចៈក្រៃលែងឡើង ។ ក្នុងកាលចប់សច្ចៈ មហាជនសម្រេចសោតាបត្តិផលជាដើម ដូច្នេះឯង ។

## អដ្ឋកថា រាជបុត្តប្រេតចប់

# រឿង គូថខាទកប្រេត ទី៨

[ ៤៣ ] ( ព្រះមោគ្គល្លានឃើញប្រេតនោះហើយសួរថា ) អ្នកដែលអាត្មាឃើញហើយតើជាអ្វី ងើបអំពីរណ្តៅអាចម៍ ហើយឋិតនៅ អ្នកឯងជាបុគ្គលមានបាបកម្មឥតសង្ស័យ ហេតុអ្វីក៏ស្រែក ។

( ប្រេតតបថា ) បពិត្រលោកដ៏ចម្រើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

( ព្រះមោគ្គល្លានសួរថា ) អំពើអាក្រក់ដូចម្តេចដែលប្រេតឯងធ្វើហើយដោយកាយ វាចា ចិត្ត អ្នកឯងបានទទួលទុក្ខលំបាកនេះ ព្រោះផលបាបកម្មដូចម្តេច ។

( ប្រេតតបថា ) លោកជាចៅអាវាសរបស់ខ្ញុំ ជាអ្នកឫស្យា ជាអ្នកកំណាញ់ត្រកូល ស្វិតស្វាញ ជេរប្រទេច នៅអាស្រ័យក្នុងផ្ទះរបស់ខ្ញុំ ។ លុះខ្ញុំឮពាក្យលោកចៅអាវាសនោះហើយ ក៏ជេរប្រទេចភិក្ខុទាំងឡាយ ព្រោះហេតុតែផលកម្មនៃការជេរនោះ បានជាខ្ញុំស្លាប់អំពីលោកនេះទៅ ទៅកើតជា ប្រេត ។

( ព្រះមោគ្គល្លានសួរថា ) ភិក្ខុដែលមិនមែនជាមិត្តចូលទៅរកត្រកូលរបស់អ្នក ដោយតាំងភេទខ្លួនជាមិត្ត ភិក្ខុអ្នកអប្បឥតប្រាជ្ញា លុះបែកធ្លាយរាងកាយស្លាប់ទៅ តើទៅកាន់គតិដូចម្តេចក្នុងលោកខាងមុខ ។

( ប្រេតតបថា ) ខ្ញុំឋិតនៅលើទីបំផុតនៃក្បាល នៃភិក្ខុអ្នកមានបាបកម្មនោះ ឯភិក្ខុអ្នកមានបាបកម្មនោះ ទៅកើតជាប្រេត ជាបរិវាររបស់ខ្ញុំ ( នេះឯង ) ។ បពិត្រលោកដ៏ចម្រើន ពួកជនឯទៀតបន្ទោបង់នូវឧច្ចារៈណា ឧច្ចារៈនោះឯង ទៅជាភោជនរបស់ខ្ញុំ ( រាល់ៗថ្ងៃ ) ខ្ញុំបន្ទោបង់នូវឧច្ចារៈ ណា

ភិក្ខុទៅអាវាសនោះ ចិញ្ចឹមជីវិតនឹងឧច្ចារៈនោះ ( រាល់ៗថ្ងៃ ) ។

## ចប់ រឿងគូថខាទកប្រេតទី ៨ ។

## អដ្ឋកថា បឋមគូថខាទកប្រេត

[ ៤៣ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធគូថខាទកប្រេតម្នាក់ ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **គូថកូបតោ ឧគ្គន្ត្វា** ដូច្នេះ ជាដើម ។

បានឮថា ក្នុងភូមិមួយមិនឆ្ងាយអំពីក្រុងសាវត្ថីប៉ុន្មាន មានកុដុម្ពិកៈម្នាក់សាងវិហារឧទ្ទិសថ្វាយភិក្ខុដែលជាជីតុនរបស់ខ្លួន ។ ភិក្ខុទាំងឡាយមកអំពីជនបទផ្សេងៗ នៅអាស្រ័យក្នុងវិហារនោះ ។ មនុស្សទាំងឡាយឃើញភិក្ខុទាំងនោះហើយ មានចិត្តជ្រះថ្លា ឧបដ្ឋាកដោយបច្ច័យដ៏ប្រណីត ។ ភិក្ខុជីតុនអត់ធន់នឹងបច្ច័យនោះមិនបាន ជាអ្នកត្រូវសេចក្តីប្រណែនគ្របសង្កត់ កាលនឹងពោលទោសភិក្ខុទាំងនោះ ទើបបានឲ្យកុដុម្ពិកៈ លើកទោសឡើង ។ កុដុម្ពិកៈ សង្កត់សង្កិនជេរប្រទេចភិក្ខុទាំងនោះ មួយអន្លើដោយភិក្ខុជាជីតុននោះ ។ សម័យតមក ភិក្ខុដែលជាជីតុនធ្វើកាលកិរិយាហើយ កើតជាប្រេតក្នុងបង្គន់ក្នុងវត្តនោះឯង ។ ឯកុដុម្ពិកៈធ្វើកាលកិរិយាហើយ កើតជាប្រេតនៅពីលើប្រេតដែលជាជីតុននោះឯង ។ លំដាប់នោះ ព្រះមហាមោគ្គល្លាន ឃើញប្រេតនោះហើយ កាលនឹងសួរ ទើបពោលគាថាថា

អ្នកដែលអាត្មាឃើញហើយ តើជាអ្វី ងើបអំពីរណ្ដៅអាចម៍ ហើយឋិតនៅ អ្នកឯងជាបុគ្គលមានបាបកម្មឥតសង្ស័យ ហេតុអ្វី ក៏ស្រែក ដូច្នេះ ។

ប្រេតបានស្ដាប់ដូច្នោះហើយ ទើបពោលដល់ខ្លួនដោយគាថាថា

បពិត្រលោកដ៏ចម្រើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ដូច្នេះ ។

លំដាប់នោះ ទើបព្រះថេរៈសួរកម្មដែលប្រេតនោះធ្វើ ដោយគាថាថា

អំពើអាក្រក់ដូចម្ដេច ដែលប្រេតឯងធ្វើហើយ ដោយកាយ វាចា ចិត្ត អ្នកឯងបានទទួលទុក្ខលំបាកនេះ ព្រោះផលបាបកម្មដូចម្ដេច ដូច្នេះ ។

ប្រេតនោះ បានប្រាប់កម្មដែលខ្លួនធ្វើដោយគាថា ២ ថា

លោកជាចៅអាវាសរបស់ខ្ញុំ ជាអ្នកឫស្យា ជាអ្នកកំណាញ់ត្រកូល ស្វិតស្វាញ ជេរប្រទេច នៅអាស្រ័យក្នុងផ្ទះរបស់ខ្ញុំ ។ លុះ ខ្ញុំឮពាក្យលោកចៅអាវាសនោះហើយ ក៏ជេរប្រទេចភិក្ខុទាំងឡាយ ព្រោះហេតុតែផលកម្មនៃការជេរនោះ បានជាខ្ញុំស្លាប់អំពីលោកនេះទៅ ទៅកើតជាប្រេត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហុ អាវាសិកោ មយ្ហំ** បានដល់ ភិក្ខុមួយរូបជាចៅអាវាស បាននៅប្រចាំក្នុងអាវាសរបស់ខ្ញុំ គឺក្នុងវត្តដែលខ្ញុំបាន

សាន ។ បទថា **អជ្ឈាសិតោ មយ្ហំ ឃរេ** សេចក្តីថា លោកបានអាស្រ័យក្នុងផ្ទះរបស់ខ្ញុំ ដោយភាពជាជីតុន ដោយអំណាចការនៅដោយតណ្ហា ។

បទថា **តស្ស** បានដល់ ភិក្ខុដែលជាជីតុននោះ ។ បទថា **ភិក្ខវោ** ប្រែថា នូវភិក្ខុទាំងឡាយ ។ បទថា **បរិភាសិស្សំ** ប្រែថា ជេរហើយ ។ បទថា **បេតលោកំ ឥតោ គតោ** សេចក្តីថា ចូលដល់កំណើតប្រេត គឺជាប្រេតដោយអាការយ៉ាងនេះ ។

ព្រះថេរៈ បានស្តាប់ដូច្នោះហើយ កាលនឹងសួរដល់គតិរបស់ប្រេតក្រៅពីនេះ ទើបពោលគាថាថា

> ភិក្ខុដែលមិនមែនជាមិត្ត ចូលទៅរកត្រកូលរបស់អ្នក ដោយតាំងភេទខ្លួនជាមិត្ត ភិក្ខុអ្នកអប្បឥតប្រាជ្ញា លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តើទៅកាន់គតិដូចម្តេច ក្នុងលោកខាងមុខដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិត្តវណ្ណេន** បានដល់ ដោយមិត្តក្លែងក្លាយ គឺដោយភាពជាមិត្តប្លម ។ ប្រេតកាលប្រាប់រឿងនោះដល់ព្រះថេរៈ ទើបពោលគាថា ២ ថា

> ខ្ញុំឋិតនៅលើទីបំផុតនៃក្បាលនៃភិក្ខុ អ្នកមានបាបកម្មនោះ ឯភិក្ខុ អ្នកមានបាបកម្មនោះ ទៅកើតជាប្រេត ជាបរិវាររបស់ខ្ញុំ (នេះឯង) ។ បពិត្រលោកដ៏ចម្រើន ពួកជនឯទៀតបន្ទោបង់នូវឧច្ចារៈណា ឧច្ចារៈនោះឯង ទៅជាភោជនរបស់ខ្ញុំ

( រាល់ៗថ្ងៃ ) ខ្ញុំបន្ទោបង់នូវឧច្ចារៈណា ភិក្ខុចៅអាវាសនោះ
ចិញ្ចឹមជីវិតនឹងឧច្ចារៈនោះ ( រាល់ៗថ្ងៃ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្សេវ** បានដល់ ប្រេតនោះឯង ជាភិក្ខុជីតុនក្នុងកាលមុនរបស់ខ្ញុំ ។ បទថា **ចាបកម្មស្ស** បានដល់ មានការប្រព្រឹត្ត លាមក ។ បទថា **សីសេ តិដ្ឋាមិ មត្ថកេ** សេចក្តីថា ខ្ញុំឈរលើសីសៈ កាលឈរ ឈរលើអំបែងក្បាលនោះឯង អធិប្បាយថា មិនមែនឈរលើអាកាស កម្ពស់ស្មើក្បាលនោះឡើយ ។ បទថា **បរវិសយំ បត្តោ** បានដល់ អាស្រ័យមនុស្សលោកហើយដល់បេតវិស័យជាដែនដទៃ ។ បទថា **មមេវ** បានដល់ របស់ខ្ញុំនោះឯង ។ បណ្ឌិតគប្បីនាំយក បាលីដ៏សេសមកភ្ជាប់ដោយពាក្យថា ទៅកើតជាប្រេត ហើយជាបរិវាររបស់ខ្ញុំ ។

បទថា **យំ ភទន្តេ ហទន្តញ្ញេ** សេចក្តីថា បពិត្រព្រះមហាមោគ្គល្លានជនដទៃរមែងបន្ទោបង់ឧច្ចារៈក្នុងវច្ចកុដិនេះ ។ បទថា **ឯតំ មេ ហោតិ ភោជនំ** សេចក្តីថា ឧច្ចារៈនោះ ជាអាហាររបស់ខ្ញុំរាល់ៗថ្ងៃ ។ បទថា **យំ ហទាមិ** សេចក្តីថា ខ្ញុំបន្ទោបង់ឧច្ចារៈដែលខ្ញុំបរិភោគចូលទៅ ។ បទថា **ឯតំ សោ ឧបជីវតិ** សេចក្តីថា ប្រេតជាជីតុនោះចិញ្ចឹមជីវិត គឺញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការបរិភោគឧច្ចារៈរបស់ខ្ញុំរាល់ៗថ្ងៃ ។

ក្នុងជនទាំងនោះ កុដុម្ពិកៈជេរភិក្ខុអ្នកមានសីលជាទីស្រឡាញ់ថា ការបរិភោគលាមករបស់ពួកលោក ប្រសើរជាងការបរិភោគអាហារយ៉ាងនេះ ។ ឯភិក្ខុជាជីតុន បបួលកុដុម្ពិកៈនោះក្នុងការពោលដូច្នោះ ខ្លួនឯងក៏ជេរយ៉ាងនោះ

ដោយហេតុនោះ ទើបប្រេតនោះ មានការចិញ្ចឹមជីវិតដែលគួរតិះដៀលជាង កុដុម្ពិកៈនោះ ។ ព្រះមហាមោគ្គល្លានក្រាបទូលរឿងនោះ ដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងទោសក្នុងផរុសវាចា សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ ទេសនានោះមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

## អដ្ឋកថា បឋមគូថខាទកប្រេតចប់

# រឿង គូថខាទកប្រេត ទី ៩

[ ៤៤ ] ( ព្រះមោគ្គល្លានបានឃើញស្រីប្រេតហើយសួរថា ) នាងឯង ដែលអាត្មាឃើញហើយ តើជាអ្វី ងើបអំពីរណ្ដៅអាចម៍ ហើយឋិតនៅ នាងឯងមានបាបកម្មឥតមានសង្ស័យ ហេតុអ្វីចេះតែស្រែក ។

( នាងប្រេតនោះតបថា ) បពិត្រលោកម្ចាស់ដ៏ចម្រើនខ្ញុំជាស្រីប្រេត ជាអ្នកទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ហើយច្យុតចាកមនុស្សលោកនេះ ទៅកាន់បេតលោក ។

( ព្រះមោគ្គល្លានសួរថា ) អំពើអាក្រក់ដូចម្ដេច ដែលនាងធ្វើហើយ ដោយកាយ វាចា ចិត្ត បានជានាងរងទុក្ខនេះ ព្រោះផលកម្មអ្វី ។

( ស្រីប្រេតតបថា ) លោកចៅអាវាសរបស់ខ្ញុំ ជាអ្នកឫស្យា កំណាញ់ត្រកូល ស្វិតស្វាញ ជេរប្រទេច អាស្រ័យនៅក្នុងផ្ទះរបស់ខ្ញុំ ។ លុះខ្ញុំឮពាក្យលោកចៅអាវាសនោះហើយ ក៏ជេរប្រទេចភិក្ខុទាំងឡាយ ព្រោះហេតុតែផលកម្មនៃការជេរនោះ បានជាខ្ញុំស្លាប់អំពីលោកនេះទៅ ទៅកាន់បេតលោក ។

( ព្រះមោគ្គល្លានសួរថា ) ចុះភិក្ខុដែលមិនមែនជាមិត្តអ្នកចូលទៅត្រកូលរបស់នាងដោយភេទថាដូចជាមិត្ត ភិក្ខុអ្នកអប្បឥតប្រាជ្ញានោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តើទៅកាន់គតិដូចម្ដេច ក្នុងបរលោក ។

( ស្រីប្រេតតបថា ) ខ្ញុំឋិតនៅលើទីផុតនៃក្បាលរបស់ភិក្ខុអ្នកមានបាបកម្មនោះទៅកើតជាប្រេត ហើយជាបរិវាររបស់ខ្ញុំ ។ បពិត្រលោកដ៏ចម្រើន ពួកជនឯទៀតៗបន្ទោបង់នូវឧច្ចារៈណា ឧច្ចារៈនោះឯង ទៅជាភោជនរបស់ខ្ញុំ ( រាល់ៗថ្ងៃ ) ខ្ញុំបន្ទោបង់នូវឧច្ចារៈណា ភិក្ខុចៅអាវាសនោះ ចិញ្ចឹមជីវិត

នឹងឧច្ចារៈនោះ ( រាល់ៗថ្ងៃ ) ។

ចប់ រឿងគូថខាទកប្រេត ទី ៩ ។

# អដ្ឋកថា ទុតិយគូថខាទកប្រេត

[ ៤៤ ] កាលព្រះសាស្ដាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេតបរិភោគលាមកម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **គូថកូបតោ ឧគ្គន្ត្វា** ដូច្នេះ ជាដើម ។

រឿងរបស់ស្រីប្រេតនោះ ដូចគ្នានឹងរឿងមុននោះឯង តែក្នុងរឿងនោះ មកដោយអំណាចឧបាសកថា ឧបាសកបានសាងវិហារ តែក្នុងរឿងនេះ មានសេចក្ដីប្លែកគ្នាថា ឧបាសិកាបានសាងវិហារ ។ ពាក្យដ៏សេសក្នុងផ្ទៃរឿងនិងក្នុងគាថា មិនមានទីដែលមិនធ្លាប់ពោលទុកឡើយ ។

អដ្ឋកថា ទុតិយគូថខាទកប្រេតចប់

# រឿង គណាប្រេត ទី ១០

[ ៤៥ ] ( ព្រះមោគ្គល្លានសួរថា ) នែអ្នករាល់គ្នា អ្នកទាំងឡាយមានកាយអាក្រាត មានសរីរៈមានសម្បុរមិនស្អាត ស្គមរវាមដោយសរសៃ មានឆ្អឹងជំនីររគាមម៉េះ តើអ្នកទាំងឡាយជាអ្វី ។

( ពួកប្រេតតបថា ) បពិត្រលោកដ៏ចម្រើន យើងខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក លះបង់លោកនេះទៅកាន់បេតលោក ព្រោះតែធ្វើបាបកម្ម ។

( ព្រះមោគ្គល្លានសួរថា ) ចុះអ្នករាល់គ្នា បានធ្វើអំពើអាក្រក់ដូចម្ដេចដោយកាយ វាចា ចិត្ត លះលោកនេះ ទៅកាន់បេតលោក ព្រោះផលកម្មអ្វី ។

( ពួកប្រេតទូលថា ) ពួកយើងបានរើសទ្រព្យកន្ទះមាសក នៅនាកំពង់ទឹកដែលឥតទោស ( គ្មានម្ចាស់ថែរក្សា ) នាកាលទេយ្យធម៌ទាំងឡាយមាន ពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ពួកយើងជាបុគ្គលស្រេកទឹកនាំគ្នាចូលទៅរកស្ទឹង ទើបឯស្ទឹងនោះក៏ខ្វៃប្រែទៅជាស្ទឹងទទេ ក្នុងកាលក្ដៅ ពួកយើងនាំគ្នាចូលទៅរកម្លប់ ម្លប់នោះក៏ខ្វៃប្រែទៅជាកម្ដៅដ៏ក្ដៅវិញ ។ ខ្យល់មានសណ្ឋានដូចជាភ្លើងដ៏ក្ដៅ បក់មករកពួកយើង បពិត្រលោកដ៏ចម្រើន ពួកយើងទទួលនូវបាបនោះផង ទទួលនូវបាបកម្មដទៃពីនោះផង ។

ទុកជាពួកយើងដើរទៅកាន់យោជន៍ទាំងឡាយ ជាបុគ្គលឃ្លាន ចង់ស៊ីអាហារ ក៏រកទទួលទានមិនបាន ហើយក៏ត្រឡប់វិលវិញដោយគិតថា ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏ចម្រើន ពួកយើងជាបុគ្គលឃ្លានជ្រុលជ្រប់ ដួលដេកលើផែនដី បម្រះនទៀល ផ្ងារផ្កាប់ លើផែន

ដី ។ លុះពួកយើងដួលនៅក្នុងទីនោះហើយ ក៏ក្រោកឡើង ដួលប្រុសទៅលើផែនដីនោះវិញ ទើបទន្ទិចដើមទ្រូងផង ទន្ទិចក្បាលផង ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏ចម្រើន ពួកយើងគួរទទួលនូវបាបកម្មនោះផង ទទួលនូវបាបកម្មដទៃពីនោះផង នាកាលទេយ្យធម៌ទាំងឡាយមាន ពួកយើងមិនបានធ្វើនូវទីពឹងដល់ខ្លួនសោះ ។ បើដូច្នោះ ពួកយើងលុះរដោះចាកប្រេតនេះទៅ សូមបានកើតជាមនុស្សជាអ្នក បរិបូណ៌ដោយសីល ធ្វើកុសលឲ្យបានច្រើនអំពីជីវិតក្តីទៅ ។

## ចប់ រឿងគណប្រេតទី ១០ ។

## អដ្ឋកថា គណប្រេត

[ ៤៥ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេតជាច្រើន ទើបត្រាស់ព្រះគាថានេះ មានពាក្យផ្តើមថា **នគ្គា ទុព្វណ្ណរូបាថ** ដូច្នេះ ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី មនុស្សជាច្រើន ជាគណៈ មិនមានសទ្ធា មិនមានការជ្រះថ្លា មានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់ចោមរោម ជាអ្នកបែរមុខអំពីសុចរិតមានទានជាដើម មានជីវិតនៅយូរ ព្រោះកាយបែកធ្លាយទៅ ទើបកើតក្នុងកំណើតប្រេតក្បែរព្រះនគរ ។ ថ្ងៃមួយ ព្រះមហាមោគ្គល្លានកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងសាវត្ថី ឃើញពួកប្រេតក្នុងវាំងផ្លូវ ក៏សួរដោយគាថាថា

*នែអ្នករាល់គ្នា អ្នកទាំងឡាយ មានកាយអាក្រាត មានសរីរៈ*
*មានសម្បុរមិនស្អាត ស្គមរាំមដោយសរសៃ មានឆ្អឹងជំនីរ*
*រគោមម៉្រះ តើអ្នកទាំងឡាយជាអ្វី ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **ទុព្វណ្ណរូបាថ** សេចក្តីថា អ្នកមានរូបរាងមានពណ៌សម្បុរគួរខ្ពើម ។ បទថា **កេ នុ តុម្ហេត្ថ** បានដល់ ពួកអ្នកជាអ្នកណាហ្ន៎ ព្រះមហាមោគ្គល្លានហៅប្រេតទាំងនោះដោយសមគួរដល់ខ្លួនថា **មារិសា** ( អ្នកនិរទុក្ខ ) ។

ប្រេតបានស្តាប់ដូច្នោះ ទើបនាំគ្នាប្រកាសភាពដែលខ្លួនជាប្រេត ដោយគាថាថា

*បពិត្រលោកដ៏ចម្រើន យើងខ្ញុំជាប្រេតទុគ៌ត កើតក្នុងយម-*

លោក លះបង់លោកនេះ ទៅកាន់បេតលោក ព្រោះតែធ្វើបាបកម្ម ដូច្នេះ ។

ត្រូវព្រះថេរៈសួរដល់កម្មដែលខ្លួនធ្វើទៀត ដោយគាថាថា

ចុះអ្នករាល់គ្នា បានធ្វើអំពើអាក្រក់ដូចម្តេច ដោយកាយ វាចា ចិត្ត លះលោកនេះ ទៅកាន់បេតលោក ព្រោះផលកម្មអ្វី ដូច្នេះ ។

ប្រេតបានពោលកម្មដែលខ្លួនធ្វើដោយគាថាថា

ពួកយើងបានរើសទ្រព្យកន្ទះមាសក នៅនាកំពង់ទឹកដែលឥតទោស ( គ្មានម្ចាស់ថែរក្សា ) នាកាលទេយ្យធម៌ទាំងឡាយមាន ពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ពួកយើងជាបុគ្គលស្រេកទឹកនាំគ្នាចូលទៅរកស្ទឹង ទើបឯស្ទឹងនោះក៏ខ្វែប្រែទៅជាស្ទឹងទទេ ក្នុងកាលក្តៅពួកយើងនាំគ្នាចូលទៅរកម្លប់ ម្លប់នោះក៏ខ្វែប្រែទៅជាកម្តៅដ៏ក្តៅវិញ ។ ខ្យល់មានសណ្ឋានដូចជាភ្លើងដ៏ក្តៅ បក់មករកពួកយើង បពិត្រលោកដ៏ចម្រើន ពួកយើងទទួលនូវបាបនោះផង ទទួលនូវបាបកម្មដទៃពីនោះផង ។

ទុកជាពួកយើងដើរទៅកាន់យោជន៍ទាំងឡាយ ជាបុគ្គលឃ្លាន ចង់ស៊ីអាហារ ក៏រកទទួលទានមិនបាន ហើយក៏ត្រឡប់វិលវិញដោយគិតថា ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏ចម្រើនពួកយើងជាបុគ្គលឃ្លានជ្រុលជ្រប់ ដួល

ដេកលើផែនដី បម្រះនទៀល ផ្ងារផ្កាប់លើផែនដី ។ លុះពួក
យើងដួលនៅក្នុងទីនោះហើយ ក៏ក្រោកឡើង ដួលប្រសទៅ
លើផែនដីនោះវិញ ទើបទង្គិចដើមទ្រូងផង ទង្គិចក្បាលផង ឱ
ហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏-
ចម្រើន ពួកយើងគួរទទួលនូវបាបកម្មនោះផង ទទួលនូវបាប
កម្មដទៃពីនោះផង នាកាលទេយ្យធម៌ទាំងឡាយមាន ពួក
យើង មិនបានធ្វើនូវទីពឹងដល់ខ្លួនសោះ ។ បើដូច្នោះ ពួក
យើងលុះរដោះចាកប្រេតនេះទៅសូមបានកើតជាមនុស្សជាអ្នក
បរិបូណ៌ដោយសីល ធ្វើកុសលឲ្យបានច្រើន អំពីជីវិតក្តីទៅ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ យោជនានិ គច្ឆាម** សេចក្តីថា ពួក
ខ្ញុំទៅបានច្រើនយោជន៍ ។ សេចក្តីនេះដូចម្តេច គឺជាអ្នកឃ្លានចង់បរិភោគអា
ហារ អធិប្បាយថា ពួកខ្ញុំត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ អស់កាលយូរ
ចង់បរិភោគ គឺចង់ភក្សរសអាហារ ទោះបីទៅយ៉ាងនេះ ក៏មិនបានអាហារ
ណាមួយឡើយ នាំគ្នាត្រឡប់មក ។ បទថា **អប្បបុញ្ញតា** បានដល់ ពួកខ្ញុំ
មិនមានបុណ្យ គឺមិនបានធ្វើគុណ គឺសេចក្តីល្អ ។

បទថា **ឧត្តានា បដិកិរាម** សេចក្តីថា បុគ្គលខ្លះជាអ្នកដេកផ្ងារ ប្រព្រឹត្ត
ទៅដូចអវយវៈតូចធំខ្ចាត់ខ្ចាយទៅ ។ បទថា **អវកុជ្ជា បតាមសេ** សេចក្តី
ថា ជួនកាលក៏ដេកផ្កាប់មុខ ។ បទថា **តេ ច** បានដល់ ពួកខ្ញុំនោះ ។

បទថា **ឳរំ សីសញ្ច យន្តេម** សេចក្តីថា ដេកផ្កាប់ មិនអាចក្រោកឡើងបាន ត្រឡប់ត្រឡិន ជួបនូវទុក្ខវេទនា យកទ្រូង និងក្បាលទង្គិចគ្នា ។ ពាក្យដ៏សេសមានន័យដូចពោលហើយខាងដើមនោះឯង ។

ព្រះថេរៈទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ ដល់បរិស័ទ ដែលដល់ព្រមហើយ ។ មហាជនស្តាប់ធម៌នោះហើយ លះមន្ទិល គឺសេចក្តីកំណាញ់ បានជាបុគ្គលត្រេកអរក្នុងសុចរិត មានទានជាដើមដូច្នេះឯង ។

## អដ្ឋកថា គណាប្រេតចប់

# រឿង ចាដលិបុត្តប្រេត ទី ១១

[ ៤៦ ] ( វេមានិកប្រេតពោលថា ) ពួកសត្វនរកក្តី ពួកកំណើតតិរច្ឆានក្តី ពួកប្រេតក្តី ពួកអសុរក្តី ពួកមនុស្សនឹងទេវតាក្តី នាងបានឃើញឬទេ នាងបានឃើញផលកម្មដែលខ្លួនបានធ្វើហើយដោយខ្លួនឯងដែរឬទេ ខ្ញុំនឹងនាំនាងទៅបាដលិបុត្ត មិនមានអ្នកចោមព័ទ្ធបាន បើនាងទៅដល់បាដលិបុត្តនោះហើយ ចូរធ្វើកុសលកម្មចុះ ។

នាងនោះតបថា បពិត្រយក្ស អ្នកជាបុគ្គលប្រាថ្នាប្រយោជន៍ឲ្យខ្ញុំ បពិត្រទេវតា អ្នកជាបុគ្គលប្រាថ្នាសេចក្តីចម្រើនឲ្យខ្ញុំ ខ្ញុំនឹងធ្វើតាមសំដីរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ។ ពួកសត្វនរកក្តី ពួកកំណើតតិរច្ឆានក្តី ពួកប្រេតក្តី ពួកអសុរក្តី ពួកមនុស្សនិងទេវតាក្តី ខ្ញុំបានឃើញហើយ ខ្ញុំបានឃើញផលកម្មរបស់ខ្លួនដោយខ្លួនឯង ខ្ញុំនឹងធ្វើបុណ្យទាំងឡាយឲ្យច្រើន ។

ចប់ រឿងបាដលិបុត្តប្រេតទី ១១ ។

# អដ្ឋកថា ចាដលិបុត្តប្រេត

[ ៤៦ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធវេមានិកប្រេតម្នាក់ ទើបត្រាស់ព្រះគាថានេះ មានពាក្យផ្ដើមថា **ទិដ្ឋា តយា និរយា តិរច្ឆានយោនិ** ដូច្នេះជាដើម ។

បានឮថា ឈ្មួញអ្នកក្រុងសាវត្ថី និងអ្នកក្រុងបាដលិបុត្តជាច្រើន ចេញសំពៅទៅកាន់សុវណ្ណភូមិ បណ្ដាឈ្មួញទាំងនោះ ឈ្មួញម្នាក់ជាឧបាសកមានជំងឺ មានចិត្តប្រតិព័ទ្ធក្នុងមាតុគ្រាម បានធ្វើកាលកិរិយាហើយ ។ គាត់សូម្បីបានធ្វើកុសល ក៏មិនចូលដល់ទេវលោក កើតត្រឹមតែវេមានិកប្រេត កណ្ដាលមហាសមុទ្ទ ព្រោះជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងមាតុគ្រាម ។ ស្រីដែលវេមានិកប្រេតនោះមានចិត្តប្រតិព័ទ្ធ ក៏ចេញសំពៅទៅកាន់សុវណ្ណភូមិ ។ លំដាប់នោះ ប្រេតនោះ បំណងនឹងចាប់ស្រីនោះ ទើបរាំងមិនឲ្យសំពៅទៅ ។ លំដាប់នោះ ឈ្មួញទាំងឡាយពិចារណាថា ព្រោះហេតុអ្វីហ្ន៎ ទើបសំពៅមិនទៅ ទើបឲ្យចាប់ស្លាក ដើម្បីរកមនុស្សកាឡកណ្ណី ស្លាកបានធ្លាក់ដល់ស្រីនោះឯងអស់វារៈ ៣ ដង ដោយឫទ្ធិរបស់អមនុស្ស ។ ពួកឈ្មួញឃើញស្រីដែលវេមានិកប្រេតមានចិត្តប្រតព័ទ្ធនោះ ទើបទម្លាក់ក្បូនឫស្សីក្នុងសមុទ្រ ឲ្យស្រីនោះចុះទៅលើក្បូនឫស្សីនោះ គ្រាន់តែស្រីនោះចុះទៅ សំពៅក៏បែរមុខទៅកាន់សុវណ្ណភូមិដោយរហ័ស ។ អមនុស្សលើកស្រីនោះឡើងកាន់វិមានរបស់ខ្លួន អភិរម្យជាមួយស្រីនោះ ។

កាលកន្លងទៅមួយឆ្នាំ ស្រីនោះក៏កើតអផ្សុក កាលនឹងសូមប្រេតនោះទើបពោលថា ខ្ញុំនៅទីនេះមិនបានសាងប្រយោជន៍ ដើម្បីសម្បរាយភព បពិត្រ

លោកនិទ្ទិក្ខ សូមលោកនាំខ្ញុំទៅកាន់បាដលិបុត្ត ប្រេតនោះ ត្រូវស្រីនោះអង្វរ ទើបពោលគាថាថា

ពួកសត្វនរកក្តី ពួកកំណើតតិរច្ឆានក្តី ពួកប្រេតក្តី ពួកអសុរក្តី ពួកមនុស្សនឹងទេវតាក្តី នាងបានឃើញឬទេ នាងបានឃើញផលកម្មដែលខ្លួនបានធ្វើហើយដោយខ្លួនឯងដែរឬទេ ខ្ញុំនឹងនាំនាងទៅបាដលិបុត្ត មិនមានអ្នកចោមព័ទ្ធបាន បើនាងទៅដល់បាដលិបុត្តនោះហើយ ចូរធ្វើកុសលកម្មចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋា តយា និរយា** បានដល់ សូម្បីសត្វនរកពួកខ្លះ នាងក៏ឃើញហើយ ។ បទថា **តិរច្ឆានយោនិ** មានវាចាប្រកបសេចក្តីថា សូម្បីតិរច្ឆាន មាននាគនិងគ្រុឌជាដើម ដែលមានអានុភាពច្រើន នាងក៏ឃើញហើយ ។ បទថា **បេតា** បានដល់ ប្រេតដែលស្រេកឃ្លានជាដើម ។ បទថា **អសុរា** បានដល់ អសុរ មានកាឡកញ្ជិកាសុរជាដើម ។ បទថា **ទេវា** បានដល់ ទេវតាជាន់ចាតុម្មហារាជពួកខ្លះ ។ បានឮថា ប្រេតនោះនាំស្រីនោះទៅមើលបច្ចេកនរកជាដើម ក្នុងចន្លោះៗដោយអានុភាពរបស់ខ្លួន ដោយហេតុនោះ ទើបលោកពោលយ៉ាងនេះ ។ បទថា **សយមទ្ទស កម្មវិបាកមត្តនោ** សេចក្តីថា ស្រីនោះ ទៅឃើញសត្វនរកជាដើមដោយពិសេស ក៏ស្មើនឹងបានឃើញនូវវិបាកកម្មដែលខ្លួនធ្វើទុកឯងដោយប្រចក្ស ។ បទថា **នេស្សាមិ តំ បាដលិបុត្តមក្ខតំ** សេចក្តីថា ឥឡូវនេះ ខ្ញុំនឹងនាំនាងទៅកាន់បាដលិបុត្ត ដោយរាងកាយរបស់មនុស្សនោះឯង ដោយសួស្តី

គឺមិនមានអន្តរាយ ។ តែនាងកាលដល់បាដលិបុត្តហើយ ចូរធ្វើកុសលកម្ម ឲ្យច្រើន អធិប្បាយថា ចូរប្រកបសេចក្ដីខ្វល់ខ្វាយ ត្រេកអរក្នុងបុណ្យព្រោះនាងឃើញវិបាករបស់កម្មដោយប្រចក្សហើយ ។

លំដាប់នោះ ស្រីនោះកាលបានស្ដាប់ពាក្យរបស់ប្រេតនោះ មានសេចក្ដីត្រេកអរពោលគាថាថា

នាងនោះតបថា បពិត្រយក្ស អ្នកជាបុគ្គលប្រាថ្នាប្រយោជន៍ឲ្យខ្ញុំ បពិត្រទេវតា អ្នកជាបុគ្គលប្រាថ្នាសេចក្ដីចម្រើនឲ្យខ្ញុំ ខ្ញុំនឹងធ្វើតាមសំដីរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ។ ពួកសត្វនរកក្ដី ពួកកំណើតតិរច្ឆានក្ដី ពួកប្រេតក្ដី ពួកអសុរក្ដី ពួកមនុស្សនិងទេវតាក្ដី ខ្ញុំបានឃើញហើយ ខ្ញុំបានឃើញផលកម្មរបស់ខ្លួន ដោយខ្លួនឯង ខ្ញុំនឹងធ្វើបុណ្យទាំងឡាយ ឲ្យច្រើនដូច្នេះ ។

លំដាប់នោះ ប្រេតនោះ ក៏នាំស្រីនោះទៅតាមអាកាស ដាក់នៅត្រង់កណ្ដាលបាដលិបុត្ត ហើយចៀសចេញទៅ ។ លំដាប់នោះ ញាតិនិងមិត្តជាដើមរបស់ស្រីនោះ ឃើញស្រីនោះហើយ មានចិត្តត្រេកអរថា កាលមុនពួកយើងបានឮមកថា នាងត្រូវគេបណ្ដែតក្នុងមហាសមុទ្រស្លាប់ហើយ នាងគឺស្រីនោះឯង ពួកយើងឃើញហើយហ្ន៎ មកដោយសួស្ដី ហើយមកប្រជុំគ្នាសួរដល់ប្រវត្តិរបស់នាង ។ លំដាប់នោះ នាងក៏បាននិទានរឿងទាំងអស់ដែលខ្លួនឃើញនិងខ្លួនសោយមកដល់ញាតិនិងមិត្តជាដើមនោះ ។ ឈ្មួញអ្នកក្រុង

សាវត្ថីទាំងនោះ ចូលទៅគាល់ព្រះសាស្តាក្នុងកាលដែលបានដល់ក្រុងសាវត្ថី ដោយលំដាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបសម្តែងធម៌ដល់បរិស័ទ ៤ មហាជនបានស្តាប់ធម៌នោះហើយ កើតនូវសេចក្តីសង្វេគ ត្រេកអរក្នុងកុសលធម៌ មានទានជាដើម ដូច្នេះឯង ។

## អដ្ឋកថា បាដលិបុត្តប្រេតចប់

# រឿង អម្ពវនប្រេត ទី១២

[ ៤៧ ] ( ពួកពាណិជ្ជសួរថា ) ស្រះបោក្ខរណីរបស់នាងនេះ ជាទីត្រេកអរដោយប្រពៃផង មានផ្ទៃដ៏ស្មើផង មានកម្ពស់ល្អផង មានទឹកច្រើនផង មានផ្ការីកល្អផង មានហ្វូងកន្ទន់ហើរចៀលច្ចាត់ផង ស្រះបោក្ខរណីជាទីពេញចិត្តនេះ នាងបានដោយហេតុដូចម្ដេច ។ មួយទៀត អម្ពវនរបស់នាងនេះ ជាទីត្រេកអរ ដោយប្រពៃផង កាន់ផ្លែគ្រប់រដូវផង មានផ្ការីកជានិច្ច មានហ្វូងកន្ទន់ច្រើនចោមរោមផង តើវិមាននេះ នាងបានមកដោយហេតុអ្វី ។

( វេមានិកប្រេតតបថា ) ខ្ញុំបានស្រះបោក្ខរណីជាទីត្រេកអរ និងអម្ពវនវិមានជាទីត្រេកអរនេះ ព្រោះតែធីតារបស់ខ្ញុំ បានប្រគេនទឹកស្វាយទុំនិងបបរនិងម្ហូបដ៏ត្រជាក់ជាទីត្រេកអរក្នុងទីនេះ ។

( ធីតាពោលថា ) ចូរអ្នកសំឡឹងមើលផលរបស់ទាននិងការទូន្មាននូវឥន្ទ្រិយនិងការសង្រួមដែលឃើញច្បាស់ដោយខ្លួនឯង ខ្ញុំ ( ពីដើម ) ជាទាសី ឥឡូវបានជាកូនប្រសារស្រីក្នុងត្រកូលរបស់លោកនិងជាធំត្រួតត្រាផ្ទះរបស់លោក ។ ( ថ្ងៃនោះព្រះមានព្រះភាគទ្រង់ប្រមើលមើលឃើញឧបនិស្ស័យនៃស្រីនោះហើយត្រាស់ថា ) របស់ដែលមិនត្រេកអរ រមែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទ ដោយសភាពនៃរបស់ជាទីត្រេកអរ របស់ដែលមិនស្រឡាញ់រមែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទ ដោយសភាពនៃ របស់ជាទីស្រឡាញ់ ទុក្ខតែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទ ដោយសភាពនៃសេចក្ដីសុខ ។

ចប់ រឿងអម្ពវនប្រេតទី ១២ ។

# អដ្ឋកថា អម្ពវនប្រេត

[ ៤៧ ] កាលព្រះសាស្តាគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអម្ពប្រេត ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **អយញ្ច តេ បោក្ខរណី សុរម្មា** ដូច្នេះ ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី មានគហបតីម្នាក់ ជាអ្នកសាបសូន្យចាកភោគសម្បត្តិ ភរិយារបស់គហបតីនោះក៏ស្លាប់ គាត់មានកូនម្នាក់ប៉ុណ្ណោះ ។ គាត់បានឲ្យធីតានោះទៅកាន់ផ្ទះមិត្តរបស់ខ្លួន ខ្ចីប្រាក់មក ១០០ កហាបណៈ ទិញរបស់របរដាក់រទេះទៅជួញដូរ ។ មិនយូរប៉ុន្មាន ក៏បានទ្រព្យ ៥០០ កហាបណៈដែលជាប្រាក់ចំណេញ ព្រមទាំងដើមទុន ហើយត្រឡប់មកមួយអន្លើដោយរទេះ ។ ក្នុងចន្លោះផ្លូវ ពួកចោរស្ទាក់ប្លន់រទេះ ។ ពួកអ្នករទេះ ក៏រត់បែកខ្ញែកគ្នាទៅ ។ ឯគហបតីនោះ លាក់កហាបណៈត្រង់គុម្ពឈើមួយកន្លែង ហើយពួនក្នុងទីមិនឆ្ងាយ ពួកចោរចាប់គហបតីនោះសម្លាប់ចោល ព្រោះជាប់ជំពាក់ក្នុងទ្រព្យ គហបតីនោះក៏កើតជាប្រេតក្នុងទីនោះឯង ។

ឈ្មួញបានទៅកាន់ក្រុងសាវត្ថី ប្រាប់រឿងនោះ ឲ្យធីតារបស់បុរសនោះជ្រាប ។ ធីតានោះទោមនស្សក្រៃលែង ទ្រហោយំ ព្រោះការស្លាប់របស់ឪពុក និងព្រោះភ័យក្នុងការចិញ្ចឹមជីវិត ។ លំដាប់នោះ កុដុម្ពិកៈជាសម្លាញ់របស់បិតាទារិកានោះ ក៏ពោលលួងលោមនាងថា ធម្មតាភាជនៈដីទាំងអស់ មានការបែកជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏មានការបែកធ្លាយក្នុងទីបំផុតយ៉ាងនោះដូចគ្នា ធម្មតាការស្លាប់ រមែងមានទូទៅដល់សព្វសត្វ និងមិនមានការប្តូរផ្លាស់បានឡើយ ព្រោះដូច្នោះ នាងកុំសោយសោក

កុំបរិទេវៈដល់ឪពុកពេកឡើយ យើងនឹងជាបិតារបស់នាង នាងចូរជាធីតារបស់យើង យើងនឹងធ្វើកិច្ចជំនួសបិតារបស់នាង នាងកុំទោមនស្សឡើយ ចូរត្រេកអរក្នុងផ្ទះនេះ ឲ្យដូចផ្ទះរបស់បិតានាងចុះ ។ ស្រីនោះ ស្ងប់នូវសេចក្ដីសោក ធ្វើតាមពាក្យរបស់កុដុម្ពិកៈនោះ កើតនូវការគោរពនិងការរាប់អានច្រើនក្នុងកុដុម្ពិកៈនោះ ដូចក្នុងបិតាដែលជាអ្នកមានប្រក្រតីធ្វើនូវការខ្វល់ខ្វាយប្រព្រឹត្តតាមកុដុម្ពិកៈនោះ ដោយការៈដែលខ្លួនជាបុគ្គលកំព្រា ប្រាថ្នាធ្វើកិច្ចដើម្បីអ្នកស្លាប់ឧទ្ទិសដល់បិតា ទើបបបរ ហើយផ្សំដោយរសផ្លែស្វាយទុំមានរសឆ្ងាញ់ មានពណ៌ដូចមនោសិលា ដាក់ថាសសំរិទ្ធ ឲ្យទាសីកាន់យកយាគូនិងផ្លែស្វាយ ទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្ដា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ធ្វើសេចក្ដីអនុគ្រោះដោយការទទួលទក្ខិណារបស់ខ្ញុំ ព្រះសាស្ដាមានព្រះទ័យដែលព្រះមហាករុណាដាស់តឿន កាលនឹងធ្វើមនោរថរបស់នាងឲ្យពេញ បានសម្ដែងអាការគង់ ។ នាងត្រេកអរ បានក្រាលសំពត់បរិសុទ្ធស្អាត បង្អោនចូលទៅក្នុងបវរពុទ្ធាសនៈដែលចាត់ចែង ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលក្រាលហើយ ។

លំដាប់នោះ ស្រីនោះក៏បង្អោនយាគូចូលទៅថ្វាយព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ទទួលយាគូហើយ លំដាប់នោះ ក៏ប្រគេនយាគូដល់ភិក្ខុទាំង-ឡាយឧទ្ទិសសង្ឃ ហើយលាងដៃ បង្អោនផ្លែស្វាយចូលទៅថ្វាយព្រះមានព្រះភាគទៀត ។ ព្រះមានព្រះភាគ ទ្រង់សោយផ្លែស្វាយទាំងនោះ ។ នាងថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូល យ៉ាងនេះថា បពិត្រព្រះអង្គដ៏

ចម្រើន ទក្ខិណាដែលខ្ញុំបំពេញឲ្យប្រព្រឹត្តទៅដោយការថ្វាយកម្រាល យាគូ និងផ្លែស្វាយនោះ សូមដល់បិតារបស់ខ្ញុំចុះ ។ ព្រះមានព្រះភាគត្រាស់ថា ចូរសម្រេចយ៉ាងនោះចុះ ហើយទ្រង់ធ្វើអនុមោទនា ។ នាងថ្វាយបង្គំព្រះមានព្រះភាគហើយធ្វើប្រទក្សិណចៀសចេញទៅ ។ លុះនាងឧទ្ទិសចំណែកបុណ្យ ប្រេតនោះក៏បានចម្ការស្វាយ វិមាន ដើមកប្បព្រឹក្ស និងស្រះបោក្ខរណី មួយអន្លើដោយទិព្វសម្បត្តិដ៏ធំកន្លង ។

សម័យក្រោយមក ឈ្មួញទាំងនោះ កាលទៅជួញ បានធ្វើដំណើរតាមផ្លូវនោះឯង ស្នាក់នៅមួយរាត្រី ក្នុងទីដែលខ្លួនធ្លាប់ស្នាក់នៅពីមុន ។ ប្រេតម្ចាស់វិមាននោះឃើញឈ្មួញទាំងនោះហើយ ទើបបង្ហាញខ្លួនដល់ឈ្មួញទាំងនោះ មួយអន្លើដោយចម្ការនិងវិមានជាដើម ។ ឈ្មួញទាំងនោះ ឃើញដូច្នោះ កាលនឹងសួរដល់សម្បត្តិដែលប្រេតនោះបាន ទើបពោលគាថា ២ ថា

ស្រះបោក្ខរណី របស់នាងនេះ ជាទីត្រេកអរដោយប្រពៃផង
មានផ្ទៃដ៏ស្មើផង មានកំពស់ល្អផង មានទឹកច្រើនផង មាន
ផ្ការីកល្អផង មានហ្វូងកន្លង់ហើរឆ្មៀលធ្ងាត់ផង ស្រះបោក្ខ-
រណីជាទីពេញចិត្តនេះ អ្នក[១]បានដោយហេតុដូចម្តេច ។ មួយ
ទៀត អម្ពវនរបស់អ្នកនេះ ជាទីត្រេកអរដោយប្រពៃផង កាន់
ផ្លែគ្រប់រដូវផង មានផ្ការីកជានិច្ច មានហ្វូងកន្លង់ច្រើនចោម
រោមផង តើវិមាននេះ នាងបានមកដោយហេតុអ្វី ដូច្នេះ ។

១-បិដកខ្មែរជា នាង ។

បណ្ដាបទទាំងនោះ បទថា **សុរម្មា** ប្រែថា គួរជាទីត្រេកអរ ។ បទថា **សមា** ប្រែថា មានផ្ទៃដីរាបស្មើ ។ បទថា **សុតិត្ថា** បានដល់ មានកំពង់ល្អ ព្រោះមានជណ្ដើរធ្វើហើយដោយកែវ ។ បទថា **មហោទកា** ប្រែថា មានទឹកច្រើន ។ បទថា **សព្វោតុកំ** បានដល់ នាំមកនូវសេចក្ដីសុខគ្រប់រដូវកាលដោយដើមឈើដែលដេរដាសដោយផ្កានិងផ្លែជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា កាន់ផ្លែគ្រប់រដូវ ដូច្នេះ ។ បទថា **សុបុប្ផិតំ** បានដល់ មានផ្ការីកស្គុសស្គាយជានិច្ច ។

ប្រេតបានស្ដាប់ដូច្នោះ កាលប្រាប់ដល់ហេតុនៃការបានស្រះបោក្ខរណីជាដើម ទើបពោលថា

ខ្ញុំបានស្រះបោក្ខរណីជាទីត្រេកអរ និងអម្ពវនវិមានជាទីត្រេក-
អរនេះ ព្រោះតែធីតារបស់ខ្ញុំបានប្រគេនទឹកស្វាយទុំនិងបបរ
និងម្លប់ដ៏ត្រជាក់ជាទីត្រេកអរក្នុងទីនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេន មេ ឥធ លព្ភតិ** សេចក្ដីថា ព្រោះទានដែលធីតារបស់ខ្ញុំថ្វាយស្វាយទុំ ទឹកនិងបបរដល់ព្រះមានព្រះភាគនិងភិក្ខុសង្ឃឧទ្ទិសដល់ខ្ញុំ ទើបខ្ញុំបានស្វាយទុំដែលចេញផ្លែគ្រប់រដូវកាល ក្នុងចម្ការស្វាយទិព្វនេះ ទឹកទិព្វក្នុងស្រះបោក្ខរណីជាទីត្រេកអរនៃចិត្តដែលជាទិព្វនេះ និងបានស្រះបោក្ខរណីមានម្លប់ត្រជាក់គួរជាទីត្រេកអរនៃចិត្តក្នុង ចម្ការ វិមាននិងដើមកប្បព្រឹក្សជាដើមក្នុងទីនេះដោយការប្រគេនបបរ និងកម្រាល អធិប្បាយថា រមែងសម្រេច ។

ប្រេតនោះកាលពោលយ៉ាងនេះហើយ ទើបនាំឈ្នួញទាំងនោះទៅបង្ហាញទ្រព្យ ៥០០ កហាបណៈនោះ ពោលថា សូមអ្នកទទួលយកពាក់កណ្តាលនៃចំណែកនេះ ចូរឲ្យដល់ធីតាខ្ញុំពាក់កណ្តាល ដោយបំណាងថា ចូរនាងសងបំណុលដែលខ្ញុំខ្ចីគេមកពាក់កណ្តាល ហើយរស់នៅដោយសេចក្តីសុខចុះ ។ ឈ្នួញដល់ក្រុងសាវត្ថី ដោយលំដាប់ហើយ ទើបប្រាប់ដល់ធីតារបស់ប្រេតនោះ រួចបានឲ្យចំណែកដែលប្រេតនោះបានឲ្យដល់ខ្លួនដល់នាងនោះឯង ។ ទារិកាបានសងទ្រព្យ ១០០ កហាបណៈដល់ម្ចាស់បំណុល ក្រៅពីនោះបានឲ្យដល់កុដុម្ពិកៈ ដែលជាសម្លាញ់បិតាខ្លួន ឯខ្លួនឯង ធ្វើការខ្វល់ខ្វាយនៅអាស្រ័យ ។ កុដុម្ពិកៈនោះ បានឲ្យទ្រព្យដល់នាងវិញនោះឯង ដោយពោលថា ចូរជាទ្រព្យរបស់នាងទាំងអស់ចុះ ហើយរៀបការនាង ជាមួយកូនប្រុសច្បងរបស់ខ្លួន ។

កាលកន្លងទៅ នាងក៏បានកូនប្រុសម្នាក់ កាលប្រឡែងនឹងកូន ទើបពោលគាថានេះថា

ចូរអ្នកសំឡឹងមើលផលរបស់ទាន និងការទូន្មាន នូវឥន្ទ្រិយ
និងការសង្រួមដែលឃើញច្បាស់ដោយខ្លួនឯង ខ្ញុំ ( ពីដើម )
ជាទាសី ឥឡូវបានជាកូនប្រសារស្រីក្នុងត្រកូលរបស់លោក
និងជាធំត្រួតត្រាផ្ទះរបស់លោក ដូច្នេះ ។

ថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលការចាស់ក្លានៃញាណរបស់នាងក៏ទ្រង់ផ្សាយព្រះរស្មីទៅ សម្តែងព្រះអង្គឲ្យប្រាកដដូចប្រថាប់នៅក្នុងទីចំពោះ

មុខ ហើយត្រាស់ព្រះគាថានេះថា

របស់ដែលមិនត្រេកអរ រមែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទ
ដោយសភាពនៃរបស់ជាទីត្រេកអរ របស់ដែលមិនស្រឡាញ់
រមែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទ ដោយសភាពនៃរបស់ជា
ទីស្រឡាញ់ ទុក្ខតែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទ ដោយ
សភាពនៃសេចក្តីសុខ ដូច្នេះ ។

ក្នុងកាលចប់គាថា នាងតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃទី ២ នាងបានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយបានសម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ ទេសនានោះ មានប្រយោជន៍ដល់មហាជនដូច្នេះឯង ។

## អដ្ឋកថា អម្ពវនប្រេតចប់

# រឿង អក្ខរុក្ខប្រេត ទី ១៣

[ ៤៨ ] ( ភូមទេវតានិយាយថា ) បុរសបុគ្គលឲ្យរបស់ណា របស់នោះមិនមាន ( ផលត្រឹមតែប៉ុណ្ណោះ ) ទេ បុគ្គលគប្បីឲ្យទាន លុះឲ្យទានហើយ រមែងឆ្លងទុក្ខទាំង ២ យ៉ាង ( ទុក្ខក្នុងបច្ចុប្បន្ននិងបរលោក ) រមែងបានប្រទះសុខទាំង ២ ព្រោះតែទាននោះ ចូរអ្នកភ្ញាក់រឭក ចូរអ្នកកុំធ្វេសប្រហែស ( ក្នុងទាន ) ឡើយ ។

ចប់ រឿងអក្ខរុក្ខប្រេតទី ១៣ ។

# អដ្ឋកថា អក្ខរុក្ខប្រេត

[ ៤៨ ] រឿងអក្ខទាយកប្រេតនេះ មានពាក្យផ្ដើមថា **យំ ទទាតិ ន តំ ហោតិ** ដូច្នេះ ជាដើម ។ រឿងនោះមានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី មានឧបាសកអ្នកក្រុងសាវត្ថីម្នាក់ យករទេះជាច្រើនដាក់ទំនិញទៅលក់ឯប្រទេសក្រៅ លក់ដូរទំនិញរបស់ខ្លួន ក្នុងប្រទេសនោះហើយ ក៏ទិញយកទំនិញអំពីប្រទេសនោះត្រឡប់មក ធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ។ ឧបាសកនោះធ្វើដំណើរមកតាមផ្លូវ រទេះក៏បាក់ក្នុងព្រៃ ។ លំដាប់នោះ បុរសម្នាក់បានយកដឹងនិងពូថៅដើម្បីកាប់ឈើ ចេញអំពីផ្ទះរបស់ខ្លួន ត្រាច់ទៅក្នុងព្រៃ ដល់ទីនោះ ជួបឧបាសកដែលកំពុងទោមនស្ស ព្រោះរទេះបាក់ភ្លៅ ទើបគិតថា ឈ្មួញនេះ លំបាក

ក្នុងព្រៃ ព្រោះផ្លូវរទេះបាក់ អាស្រ័យសេចក្តីអនុគ្រោះ ទើបកាប់ឈើមកអបភ្លៅរទេះឲ្យមាំទាំ ហើយប្រកបរទេះឲ្យធ្វើដំណើរទៅ ។

សម័យក្រោយមកបុរសនោះ ធ្វើកាលកិរិយាហើយ កើតជាភុម្មទេវតាក្នុងព្រៃនោះឯង ពិចារណាដល់កម្មរបស់ខ្លួន ក្នុងវេលារាត្រី ក៏ទៅកាន់ផ្ទះឧបាសកនោះ ឈរត្រង់ទ្វារផ្ទះ ពោលគាថា

បុរសបុគ្គលឲ្យរបស់ណារបស់នោះ មិនមាន ( ផលត្រឹមតែប៉ុណ្ណោះ ) ទេ បុគ្គលគប្បីឲ្យទាន លុះឲ្យទានហើយ រមែងឆ្លងទុក្ខទាំង ២ យ៉ាង ( ទុក្ខក្នុងបច្ចុប្បន្ននិងបរលោក ) រមែងបានប្រទះសុខទាំង ២ ព្រោះតែទាននោះ ចូរអ្នកភ្ញាក់រឭក ចូរអ្នកកុំធ្វេសប្រហែស ( ក្នុងទាន ) ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ ទទាតិ ន តំ ហោតិ** សេចក្តីថា ទាយករមែងឲ្យទេយ្យធម៌ណា ទេយ្យធម៌នោះឯង រមែងមានដោយភាពជាផលនៃទាននោះក្នុងបរលោក ដោយពិត ទានដទៃដែលមានផលគួរប្រាថ្នាគួរពេញចិត្ត មានច្រើននោះឯង ព្រោះដូច្នោះ អ្នកទាំងឡាយចូរឲ្យទាន គឺចូរឲ្យទានដោយប្រការណាមួយនោះឯង ។ ភុម្មទេវតាពោលហេតុក្នុងសេចក្តីនោះថា កាលឲ្យហើយរមែងរួចផុតចាកទុក្ខនិងការវិនាសទាំង ២ អធិប្បាយថា កាលឲ្យទានហើយរមែងផុតទុក្ខនិងសេចក្តីវិនាសទាំងបច្ចុប្បន្នទាំងសម្បរាយភព ។ ក្នុងពាក្យថា **ឧភយំ តេន ទានេន គច្ឆតិ** នេះ គប្បីប្រកបសេចក្តីដូច្នេះថា ព្រោះការឲ្យនោះ បុគ្គលនោះរមែងចូលដល់ គឺរមែងជួបនូវ

សុខទាំង ២ គឺសុខក្នុងបច្ចុប្បន្ន និងសុខក្នុងសម្បរាយភព ទាំងរមែងជួបហិតសុខ ទាំងដល់ខ្លួននិងអ្នកដទៃ ។ បទថា **ជាគរថ មា បមជ្ជថ** សេចក្តីថា ចូរក្រោករឮកដើម្បីញុំាងទាន ដែលឃាត់នូវអនត្ថៈទាំង ២ ញុំាងនូវប្រយោជន៍ទាំង ២ ឲ្យសម្រេច ឲ្យដល់ព្រមយ៉ាងនេះ ចូរត្រៀមឧបករណ៍នៃទាន ហើយចូរកុំប្រមាទក្នុងទាននោះ ។ ក្នុងទីនេះ ដើម្បីសម្តែងដល់ការអើពើ ទើបលោកពោលម្តងទៀត ។

ឈ្មួញពិចារណាដល់កិច្ចរបស់ខ្លួនហើយ ត្រឡប់ដល់ក្រុងសាវត្ថីដោយលំដាប់ ក្នុងថ្ងៃទី ២ ទើបចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ទើបក្រាបទូលរឿងនោះ ដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ។ ទេសនានោះមានប្រយោជន៍ដល់មហាជន ដូច្នេះ ។

## អដ្ឋកថា អគ្គរុក្ខប្រេតចប់

# រឿង ភោគសំហារប្រេត ទី១៤

[ ៤៩ ] ( ពួកស្រីប្រេតស្រែកថា ) ពួកយើងបានប្រមូលភោគៈទាំង-ឡាយដោយសមខ្វះ ដោយមិនសមខ្វះ ពួកជនឯទៀតតែងបរិភោគភោគៈទាំងនោះ ឯពួកយើងគ្រាន់តែបានចំណែកនៃសេចក្តីទុក្ខ ។

ចប់ រឿងភោគៈសំហារប្រេតទី ១៤ ។

# អដ្ឋកថា ភោគសំហារប្រេត

[ ៤៩ ] រឿងនាងភោគសំហារប្រេតនេះ មានពាក្យផ្តើមថា **មយំ ភោគេ សំហរិម្ហា** ដូច្នេះ ជាដើម ។ រឿងនោះមានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា កាលព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវនមហាវិហារ ស្រី ៤ នាក់ក្នុងក្រុងរាជគ្រឹះ ធ្វើនូវការលក់ដូរដោយសប្បិ ទឹកឃ្មុំ ប្រេងនិងស្រូវជាដើម ដោយរង្វាល់កោងជាដើម ប្រមូលទ្រព្យចិញ្ចឹមជីវិត ដោយមិនមែនឧបាយ ។ ខាងមុខអំពីស្លាប់ព្រោះកាយបែកធ្លាយ ស្រីទាំងនោះទៅកើតជាប្រេត ត្រង់ខ្នងប្រឡាយ ។ ក្នុងពេលរាត្រី ស្រីប្រេតទាំងនោះត្រូវសេចក្តីទុក្ខគ្របសង្កត់ ស្រែកទ្រហោយំដោយសំឡេងរងំគួរខ្លាចដោយគាថាថា

> ពួកយើងបានប្រមូលភោគៈទាំងឡាយដោយសមខ្វះ ដោយមិន
> សមខ្វះ ពួកជនឯទៀតតែងបរិភោគភោគៈទាំងនោះ ឯពួកយើង
> គ្រាន់តែបានចំណែកនៃសេចក្តីទុក្ខ ដូច្នេះ ។

មនុស្សទាំងឡាយស្តាប់សំឡេងនោះហើយ ភិតភ័យតក់ស្លុត កាលរាត្រីអស់ហើយ បានរៀបចំមហាទានដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន និមន្តព្រះសាស្តានិងភិក្ខុសង្ឃអង្គាសដោយខាទនីយៈ និងភោជនីយាហារដ៏ប្រណីត ចូលទៅគាល់ព្រះមានព្រះភាគដែលសោយព្រះក្រយាហារស្រេចហើយ ទ្រង់ដកព្រះហស្តចាកបាត្រហើយ ទើបក្រាបទូលឲ្យទ្រង់ជ្រាបដល់រឿងនោះ ។ ព្រះមានព្រះភាគបានត្រាស់ថា ម្នាលឧបាសកនិងឧបាសិកាទាំងឡាយ សំឡេងនោះ មិនមានអន្តរាយណាមួយដល់អ្នកទាំងឡាយឡើយ ដ្បិតប្រេតទាំង ៤ នោះ ត្រូវសេចក្តីទុក្ខគ្របសង្កត់ ពោលដល់កម្មអាក្រក់ដែលខ្លួនធ្វើយំដោយសំឡេងសោកសៅ ដោយគាថានេះថា

ពួកយើងបានប្រមូលភោគៈទាំងឡាយដោយសមខ្លះ ដោយមិនសមខ្លះ ពួកជនឯទៀតតែងបរិភោគភោគៈទាំងនោះ ឯពួកយើង គ្រាន់តែបានចំណែកនៃសេចក្តីទុក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភោគេ** បានដល់ ឧបករណ៍វិសេសនៃទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត មានសំពត់និងអាភរណៈជាដើម ដែលបានឈ្មោះថា **ភោគ** ព្រោះអត្ថថា បុគ្គលគប្បីប្រើប្រាស់ ។ បទថា **សំហរិម្ហា** សេចក្តីថា ជាបុគ្គលមានចិត្តដែលមន្ទិល គឺសេចក្តីកំណាញ់គ្របសង្កត់រួបរួមទុកមិនឲ្យទ្រព្យដល់បុគ្គលណាម្នាក់ឡើយ ។ បទថា **សមេន វិសមេន ច** បានដល់ ដោយប្រព្រឹត្តតាមធម៌និងមិនតាមធម៌ ម្យ៉ាងទៀត សេចក្តីថា ឥឡូវនេះ បុគ្គលដទៃៗ ប្រើប្រាស់ភោគៈនោះដែលខ្ញុំប្រមូលមិនប្រកបដោយធម៌ ដែល

ជាការប្រកបដោយធម៌មិនពិត ។ បទថា **មយំ ទុក្ខស្ស ភាគិនី** សេចក្តីថា ឯពួកយើង ឥឡូវនេះ ជាអ្នកមានចំណែកនៃទុក្ខធំ ដែលទាក់ទងក្នុងកំណើតប្រេត គឺសោយទុក្ខធំ ព្រោះខ្លួនមិនបានធ្វើសុចរិតណាមួយ ធ្វើតែទុច្ចរិត ។

ព្រះមានព្រះភាគ ត្រាស់គាថាដែលស្រីប្រេតនោះពោលហើយយ៉ាងនេះ ក៏ត្រាស់ប្រវត្តិរបស់ប្រេតទាំងនោះ ហើយទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ដល់បរិស័ទដែលដល់ព្រមហើយ ទ្រង់ប្រកាសនូវសច្ចៈឲ្យក្រៃលែងក្នុងកាលចប់សច្ចៈ មហាជនសម្រេចសោតាបត្តិផលជាដើម ដូច្នេះ ។

## អដ្ឋកថា ភោគសំហរប្រេតចប់

# រឿង សេដ្ឋិបុត្តប្រេត ទី១៥

[ ៥០ ] ( ពួកសត្វនរកស្រែកថា ) ពួកយើងឆេះនៅក្នុងនរកពេញប្រាំមួយម៉ឺន ( ៦០០០០ ) ឆ្នាំគ្រប់គ្រាន់ តើទីបំផុតនឹងមានក្នុងវេលាណា ។ ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុតមកពីណា ទីបំផុតនឹងមិនប្រាជកដល់យើងឡើយ ម្នាលអ្នក ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។ ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន យើងមិនបានឲ្យ កាលទេយ្យធម៌មាន យើងមិនបានធ្វើទីពឹងដល់ខ្លួនសោះ ។ ប្រសិនបើខ្ញុំ បានរដោះរួចចាកនរកនេះទៅ បានកើតជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឲ្យច្រើន អំពីកាលដ៏នក្តីទៅ ។

ចប់ រឿងសេដ្ឋិបុត្តប្រេតទី ១៥ ។

# អដ្ឋកថា សេដ្ឋិបុត្តប្រេត

[ ៥០ ] រឿងប្រេតដែលជាកូនសេដ្ឋីនេះ មានពាក្យផ្ដើមថា **សដ្ឋិវស្ស-សហស្សានិ** ដូច្នេះ ជាដើម ។ រឿងនេះមានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន ក្រុងសាវត្ថី សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់ប្រដាប់តាក់តែងហើយ ទ្រង់ឡើងកាន់កដំរីដ៏ប្រសើរ ប្រពាសព្រះនគរដោយឫទ្ធិដ៏ធំ ដោយរាជានុភាពដ៏ធំ ទ្រង់ទតឃើញស្រីម្នាក់ មានចំណែកប្រៀបដោយទេពអប្សរ ព្រោះបរិបូណ៌ដោយរូប បើកបង្អួចលើប្រាសាទមួយ សម្លឹងមើលការតាក់តែងអង្គរបស់ព្រះរាជា ព្រះរាជាមានចិត្តចោមរោម ដោយកិលេសមួយរំពេច ក្នុងអារម្មណ៍ដែលមិនធ្លាប់ឃើញ សូម្បីមានស្នំក្នុងរាជវាំងដែលជាអ្នកសម្បូរដោយគុណ មានត្រកូល រូបនិងអាចារជាដើម ក៏នៅតែមានចិត្តប្រតិព័ទ្ធក្នុងស្រីនោះ ដោយចិត្តដែលយុំគ្រងបានលំបាក ជាធម្មជាតកើតរហ័សជាសភាវៈ ទើបបានឲ្យសញ្ញាដល់អ្នកអង្គុយខាងក្រោយថា ចូរអ្នកពិចារណាមើលប្រាសាទនេះ និងស្រីនេះ ហើយយាងចូលទៅកាន់ព្រះរាជវាំង រឿងដទៃទាំងអស់ គប្បីជ្រាបដោយន័យដែលពោលមកហើយក្នុងអម្ពសក្ខរប្រេតនោះឯង ។

ឯសេចក្ដីប្លែកគ្នា មានដូចតទៅនេះ ។ ក្នុងរឿងនោះ បុរសមកក្នុងពេលដែលព្រះអាទិត្យមិនទាន់អស្ដង្គត ឆ្មាំទ្វារក៏បិទទ្វារនគរ ទើបដាក់ដីពណ៌អរុណនិងផ្កាឧប្បលដែលខ្លួននាំមកត្រង់ទ្វារព្រះនគរ ហើយចូលទៅកាន់វត្តជេតពនមហាវិហារ ដើម្បីដេក ។ ឯព្រះរាជាយាងចូលព្រះក្រឡាបន្ទំដ៏មានសិរី ក្នុងគ្រាមជ្ឈិមយាម ទ្រង់បានឮសំឡេង ៤ ម៉ាត់ថា **ស ទ ន សោ** ដោយ

សំឡេងគ្រលួច ហាក់ដូចជាចេញអំពីបំពង់កដ៏ធំ ។ បានឮថា ក្នុងអតីតកាល សេដ្ឋីបុត្ត ៤ នាក់ អ្នកក្រុងសាវត្ថី ស្រវឹងដោយសេចក្ដីស្រវឹងក្នុងភោគទ្រព្យ បានសាងបាបកម្មច្រើន ដោយអំណាចកម្មដែលប្រព្រឹត្តខុសក្នុងកិរិយារបស់អ្នកដទៃក្នុងកាលនៅជាយុវវ័យ ក្រោយមកធ្វើកាលកិរិយាហើយកើតក្នុងលោហកុម្ភី ឆេះក្នុងថ្នាំងនោះ អណ្តែតដល់មាត់ថ្នាំង បំណងនឹងពោលម្នាក់មួយគាថា ក៏ពោលបានត្រឹមអក្ខរៈមួយតួ ខាងដើមនៃគាថាទាំងនោះដែលខ្ទបខ្ទីឡើងជិតនគរនោះឯងបានទទួលទុក្ខវេទនា លិចចុះទៅបាតថ្នាំងវិញ ។

ឯព្រះរាជាទ្រង់ស្តាប់សំឡេងនោះ ទ្រង់តក់ស្លុត ទ្រង់ព្រឺរោមព្រឺស្បែក ទ្រង់ឲ្យរាត្រីដែលនៅសល់កន្លងទៅបានដោយលំបាក លុះរាត្រីអស់ហើយ ក៏ហៅបុរោហិតមក ហើយត្រាស់រឿងនោះ បុរោហិតគិតកាញ់រកលាភ ដឹងថាព្រះរាជាភ័យខ្លាច ទើបគិតថា ឧបាយជាហេតុឲ្យកើតលាភដល់អញនិងដល់ពួកព្រាហ្មណ៍កើតឡើងហើយ ទើបទូលថា បពិត្រមហារាជ ឧបទ្រវន្តរាយនេះ កើតឡើងហើយហ្ន៎ សូមទ្រង់បូជាយញ្ញ ប្រកបដោយពួក ៤ នៃវត្ថុទាំងពួង ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់បុរោហិតនោះហើយ ទើបត្រាស់នឹងអាមាត្យទាំងឡាយថា អើ ពួកលោកចូរត្រៀមឧបករណ៍មួយមុខ ៤ នៃវត្ថុទាំងអស់ ។ ព្រះនាងមល្លិកាទេវី បានស្តាប់ដូច្នោះ ក៏ទូលព្រះរាជាយ៉ាងនេះថា បពិត្រមហារាជ ព្រោះហេតុអ្វី ទើបទ្រង់ស្តាប់ពាក្យបុរោហិតនោះ ហើយមានបំណងធ្វើកិច្ច គឺការបៀតបៀនសត្វដ៏ច្រើន ទ្រង់គួរទូលសួរព្រះមានព្រះភាគ ដែលមានព្រះញាណប្រព្រឹត្តទៅមិនទើសទាក់ក្នុងទីទាំងពួង មិនមែនឬ

ទ្រង់គួរបដិបត្តិដូចព្រះមានព្រះភាគទ្រង់ព្យាករដល់ព្រះអង្គ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ព្រះទេវីហើយ យាងទៅគាល់ព្រះសាស្តា ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ហេតុអំពីសំឡេងនោះមិនជាអន្តរាយដល់ទ្រង់ឡើយ ដូច្នេះហើយ ទើបត្រាស់ប្រវត្តិរបស់សត្វដែលកើតក្នុងលោហកុម្ភីទាំងនោះ តាំងអំពីដើមដល់ចប់ ទើបបានត្រាស់គាថាដែលប្រេតទាំងនោះបំណាំងនឹងពោលម្នាក់មួយគាថាៗ ឲ្យបរិបូណ៌ថា

**សដ្ឋិវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ**
**និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ។**

ពួកយើងឆេះនៅក្នុងនរកពេញប្រាំមួយម៉ឺន ( ៦០០០០ ) ឆ្នាំគ្រប់គ្រាន់ តើទីបំផុតនឹងមានក្នុងវេលាណា ។

**នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ**
**តថា ហិ បកតំ បាបំ តុយ្ហំ មយ្ហញ្ច មារិសា។**

ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុតមកពីណា ទីបំផុតនឹងមិនប្រាដកដល់យើងឡើយ ម្នាលអ្នក ព្រោះតែខ្ញុំក្តីអ្នកក្តី បានធ្វើបាប ។

**ទុជ្ជីវិតមជីវិម្ហ យេ សន្តេ ន ទទម្ហសេ**
**សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហ អត្តនោ ។**

ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន យើងមិន

បានឲ្យ កាលទេយ្យធម៌មាន យើងមិនបានធ្វើទីពឹងដល់ខ្លួន សោះ ។

**សោហំ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ**

**វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុន្តិ**[១]។

ប្រសិនបើខ្ញុំបានរដោះរួចចាកនរកនេះទៅ បានកើតជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឲ្យច្រើន អំពីកាល ដ៏ឥតក្តីទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សដ្ឋិវស្សសហស្សានិ** ប្រែថា ៦ ម៉ឺនឆ្នាំ ។ បានឮថា សត្វដែលកើតក្នុងលោហកុម្ភីនរកនោះ លិចចុះទៅខាងក្រោមអស់ ៣ ម៉ឺនឆ្នាំ អណ្តែតឡើងមកលើដល់មាត់ឆ្នាំង ៣ ម៉ឺនឆ្នាំដូចគ្នា ។ ដោយសញ្ញានោះ ប្រេតនោះបំណងនឹងពោលគាថាថា **សដ្ឋិវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ** ពួកយើងឆេះក្នុងនរក ៦ ម៉ឺនឆ្នាំបរិបូណ៌ដោយប្រការទាំងពួងដូច្នេះទើបពោលថា **ស** ជួបនូវទុក្ខវេទនាពន់ប្រមាណ ផ្កាប់មុខចុះ ។ ព្រះមានព្រះភាគ បានត្រាស់គាថានោះឲ្យបរិបូណ៌ដល់ព្រះរាជា ក្នុងគាថាដ៏សេសក៏ន័យនេះ ។ បណ្តាបទទាំងនោះ បទថា **កទា អន្តោ ភវិស្សតិ** សេចក្តីថា កាលពួកយើងឆេះក្នុងលោហកុម្ភីនរក តើកាលណាហ្ន៎ ទីបំផុតនៃទុក្ខនេះដល់ទីបញ្ចប់ ។

បទថា **នត្ថិ ហិ** សេចក្តីថា ទីបំផុតនៃទុក្ខនេះ រមែងមិនមានដល់អ្នក

---

១ គាថានេះយើងកាន់យកតាមអដ្ឋកថា ។

និងខ្ញុំ ទីបំផុតមិនប្រាកដ យ៉ាងណា គប្បីពោលផ្ទាស់វិកត្តិថា អ្នកនិងខ្ញុំបាន ធ្វើកម្មដ៏លាមកទុក ដូច្នោះ គឺដោយប្រការនោះ ។

បទថា **ទុជ្ជីវិតំ** បានដល់ មានជីវិតដែលវិញ្ញូជនគប្បីតិះដៀល ។ បទ ថា **យេ សន្តេ** សេចក្តីថា ពួកយើងកាលទេយ្យធម៌មាន គឺប្រាកដ ។ បទថា **ន ទទម្ហសេ** ប្រែថា មិនបានឲ្យហើយ ។ ដើម្បីនឹងធ្វើអត្ថដែល ពោលហើយនោះឲ្យប្រាកដច្បាស់ ទើបលោកពោលថា កាលទេយ្យធម៌មាន យើងមិន បានធ្វើទីពឹងដល់ខ្លួនសោះ ដូច្នេះ ។

បទថា **សោហំ** កាត់បទជា **សោ អហំ** ប្រែថា ខ្ញុំនោះ ។ សព្ទថា **នូន** ជានិបាត ចុះក្នុងអត្ថថា បរិវិតក្ក ។ បទថា **ឥតោ** បានដល់ ចាកលោ-ហកុម្ភីនរកនេះ ។ បទថា **គន្ត្វា** បានដល់ ទៅផុតហើយ ។ បទថា **យោនឹ លទ្ធាន មានុសឹ** បានដល់ បានកំណើតមនុស្ស គឺអត្តភាពមនុស្ស ។ បទថា **វទញ្ញូ** បានដល់ មានកិរិយាបរិច្ចាគជាប្រក្រតី ឬជាអ្នកដឹងនូវវាចាអ្នកសុំ ។ បទថា **សីលសម្បន្នោ** បានដល់ ដល់ព្រមដោយសីលនិងអាចារ ។ បទថា **កាហាមិ កុសលំ ពហុំ** សេចក្តីថា ខ្ញុំមិនដល់នូវសេចក្តីប្រមាទ ដូចក្នុង កាលមុន នឹងធ្វើ គឺសន្សំកុសលបុញ្ញកម្មទុកឲ្យច្រើន គឺឲ្យគ្រប់គ្រាន់ ។

ព្រះសាស្តា កាលត្រាស់គាថាទាំងនេះហើយ ទើបទ្រង់សម្តែងធម៌ដោយ ពិស្តារ កាលចប់ទេសនា បុរសអ្នកនាំជីឥដ្ឋនិងផ្កាឧប្បលក្រហមតាំងនៅក្នុង សោតាបត្តិផល ព្រះរាជាតាំងនៅក្នុងសេចក្តីសង្វេគ ទ្រង់លះនូវការសម្ផឹងក្នុង ស្រីដែលអ្នកដទៃហួងហែង បានជាអ្នកត្រេកអរតែក្នុងភរិយាខ្លួន ដូច្នេះ ។

អដ្ឋកថា សេដ្ឋិបុត្តប្រេតចប់

# រឿង សដ្ឋីកូដសហស្សប្រេត ទី១៦

[ ៥១ ] ( ថ្ងៃមួយព្រះមោគ្គល្លានសួរថា ) ហេតុអ្វីអ្នកដូចមនុស្សឆ្កួត ស្ទុះចុះស្ទុះឡើង ដូចម្រឹគភ្ញាក់ផ្អើល អ្នកមានបាបកម្មមិនមានសង្ស័យ ហេតុអ្វីក៏អ្នកស្រែក ។

( ប្រេតតបថា ) បពិត្រលោកដ៏ចម្រើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក ទៅពីមនុស្សលោកនេះទៅកាន់បេតលោក ព្រោះតែធ្វើបាបកម្ម ។ មានញញួរដែកពេញចំនួនប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ តែងធ្លាក់លើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះ ទម្លាយនូវក្បាលរបស់ខ្ញុំ ។

( ព្រះមោគ្គល្លានសួរថា ) ចុះអ្នកបានធ្វើអំពើអាក្រក់ដោយកាយ វាចា ចិត្ត ដូចម្ដេច បានជាអ្នកលះលោកនេះ ទៅកើតក្នុងបេតលោក ព្រោះផលកម្មអ្វី ។ ញញួរដែកពេញប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះវាយទម្លាយក្បាល ។

( ប្រេតតបថា ) កាលណោះ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធ ព្រះនាមសុនេត្ត លោកមានឥន្ទ្រិយចម្រើនដោយអរិយមគ្គ គង់ក្រោមម្លប់ឈើលោកមានឈាន ឥតមានភ័យកិតមកពីទីណាទេ ។ ខ្ញុំបាញ់ទម្លាយព្រះកេសលោកដោយការប្រហារដោយក្រួស សេចក្ដីទុក្ខនេះ សម្រេចដល់ខ្ញុំ ព្រោះតែផលកម្មនៃការប្រហារនោះ ។ ( ព្រោះហេតុនោះ ) បានជាញញួរដែក ពេញប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះវាយទម្លាយក្បាលរបស់ខ្ញុំ ។

( ព្រះមោគ្គល្លានតបថា ) ម្នាលបុរសអាក្រក់ សមតាមសេចក្ដីប្រ-

ព្រឹត្តរបស់អ្នកហើយ ត្រង់ដែលញញួរដែកពេញប្រាំមួយហ្មឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះ ក៏វាយទម្លាយក្បាលរបស់អ្នក ។

ចប់ រឿងសដ្ឋិកូដសហស្សប្រេត ទី ១៦ ។

ឧទ្ទាន នៃមហាវគ្គ ទី ៤ នោះគឺ

និយាយអំពីរឿងអម្ពសក្ខរប្រេត ១ សេរិស្សកប្រេត ១ នន្ទិកាប្រេត ១ រេវតីប្រេត ១ ឧច្ឆុខាទកប្រេត ១ កុមារប្រេត ១ រាជបុត្រប្រេត ១ គូថខាទកប្រេត ២ លើក គណៈប្រេត ១ បាដលិបុត្តប្រេត ១ អម្ពវនប្រេត ១ អក្ខរុក្ខប្រេត ១ ភោគៈសំហរប្រេត ១ សេដ្ឋិបុត្តប្រេត ១ សដ្ឋិកូដសហស្សប្រេត ១ ហេតុនោះ បានជាលោកហៅថាវគ្គ ។

**ចប់ មហាវគ្គទី ៤ ។**

**ចប់ បេតវត្ថុ ។**

# អដ្ឋកថា សដ្ឋិក្ខុដសហស្សប្រេត

[ ៥១ ] កាលព្រះសាស្តាគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេតម្នាក់ ទើបត្រាស់គាថានេះ មានពាក្យផ្តើមថា **កឹ នុ ឧម្មត្តរូបោវ** ដូច្នេះជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ ជាអ្នកជំនាញក្នុងការផ្ទាត់គ្រាប់ក្រួស ចូលដល់នូវភាពជាអ្នកសម្រេចនូវសិប្បៈក្នុងការផ្ទាត់គ្រាប់ក្រួសនោះ ។ គេអង្គុយក្រោមដើមជ្រៃក្បែរទ្វារព្រះនគរ ធ្វើស្លឹកជ្រៃជារូបដំរី រូបសេះ រូបមនុស្ស រូបរថ រូបផ្ទះកំពូល រូបទង់ និងរូបក្អមទឹកដែលមានទឹកពេញជាដើម ដោយការផ្ទាត់គ្រាប់ក្រួស ។ ពួកក្មេងក្នុងព្រះនគរបានឲ្យទ្រព្យមួយមាសកខ្លះ កន្លះមាសកខ្លះ ដើម្បីជាប្រយោជន៍ដល់ការលេងរបស់ខ្លួន ឲ្យបុរសនោះសម្តែងសិប្បៈទាំងនោះតាមគាប់ចិត្ត ។

សម័យថ្ងៃមួយ ព្រះបាទពារាណសីចេញអំពីព្រះនគរ ចូលទៅកាន់គល់ជ្រៃនោះ ឃើញការចែករូបផ្សេងៗ ជារូបដំរីជាដើម ដែលជាប់លើស្លឹកជ្រៃ ទើបត្រាស់សួរពួកមនុស្សថា នរណាហ្ន៎ធ្វើការចែករូបផ្សេងៗយ៉ាងនេះ ត្រង់ស្លឹកជ្រៃទាំងឡាយនេះ ពួកមនុស្សបង្អុលឲ្យទតបុរសខ្វិននោះ ហើយទូលថា បពិត្រព្រះអង្គ បុរសនេះជាអ្នកធ្វើ ។ ព្រះរាជាឲ្យហៅបុរសខ្វិននោះមក ហើយត្រាស់យ៉ាងនេះថា នែអ្នក អ្នកអាចយកអាចម៍ពពែ ដាក់ឲ្យពេញពោះរបស់បុរសម្នាក់ដែលយើងបង្អុលបង្ហាញ ជាអ្នកពោលនឹងយើងបានដែរឬហ្ន៎ ។ បុរសខ្វិនទូលថា បានព្រះអង្គ ។ ព្រះរាជានាំបុរសខ្វិននោះ ចូលទៅកាន់ព្រះរាជវាំងរបស់ព្រះអង្គ ទ្រង់ចុញទ្រាន់នឹងបុរោហិតដែលនិយាយច្រើន ទើប

ត្រាស់ឲ្យហៅបុរោហិតមក អង្គុយប្រឹក្សាគ្នាក្នុងឱកាសដែលស្ងាត់ជាមួយបុរោហិតនោះ ព័ទ្ធដោយវាំងនន ទើបត្រាស់ឲ្យហៅបុរសខ្វិនមក ។ បុរសខ្វិនកាន់យកអាចម៍ពពែប្រមាណមួយនាឡិមក ដឹងអាការរបស់ព្រះរាជា អង្គុយបែរមុខទៅរកបុរោហិត កាលបុរោហិតហាមាត់ ក៏ផ្ទាត់អាចម៍ពពែម្តងមួយដុំៗចូលក្នុងមាត់របស់បុរោហិត តាមចន្លោះវាំងនន ។ បុរោហិតមិនអាចខ្ជាក់ព្រោះខ្មាស ក៏លេបចូលទៅទាំងអស់ ។ លំដាប់នោះ ព្រះរាជាទ្រង់ទុកឲ្យបុរោហិតមានពោះពេញដោយអាចម៍ពពែ ទើបត្រាស់ថា ទៅចុះព្រាហ្មណ៍ លោកបានផលនៃការនិយាយច្រើនហើយ ចូរលោកផឹកទឹកដែលផ្សំដោយផែ□និងស្លឹកប្រយង្គុប្រចាប់ជាដើម ហើយបន្ទោបង់ចេញ ដោយអាការយ៉ាងនេះ លោកនឹងមានសួស្តី ។ ដោយការធ្វើរបស់បុរសខ្វិននោះ ព្រះរាជាពេញព្រះទ័យ បានព្រះរាជទានស្រុកសួយ ១៤ ។ បុរសខ្វិន កាលបានស្រុកសួយ ១៤ ហើយ ធ្វើខ្លួនឲ្យមានសេចក្តីសុខស្កប់ស្កល់ មួយអន្លើដោយបរិវារ ក៏ឲ្យឆ្អែតស្កប់ស្កល់ដូចគ្នា ឲ្យទ្រព្យដែលសមគួរដល់សមណព្រាហ្មណ៍ជាដើម មិនធ្វើឲ្យប្រយោជន៍បច្ចុប្បន្ននិងអនាគតវិនាសទៅ ចិញ្ចឹមជីវិតដោយសេចក្តីសុខ ទាំងឲ្យរង្វាន់ដល់បុគ្គលដែលមកកាន់សម្នាក់ខ្លួន ហើយសិក្សា ។

លំដាប់នោះ បុរសម្នាក់ចូលទៅកាន់សម្នាក់បុរសខ្វិន ពោលយ៉ាងនេះថា លោកអាចារ្យ សូមលោកអាចារ្យឲ្យខ្ញុំសិក្សាសិប្បៈនេះផង ខ្ញុំមិនត្រូវការដោយបំណាច់និងរង្វាន់ទេ ។ បុរសខ្វិននោះឲ្យបុរសនោះសិក្សាសិប្បៈនោះ បុរសនោះសិក្សាសិប្បៈបានហើយ បំណងនឹងសាកល្បងសិប្បៈ ដើរទៅ យក

គ្រឿងពិឃាត គឺដុំក្រួស ទម្លាយសិរសារបស់ព្រះបច្ចេកពុទ្ធព្រះនាមថា សុនេត្ត: ដែលកំពុងគង់ក្បែរឆ្នេរស្ទឹងគង្គា ព្រះបច្ចេកពុទ្ធបរិនិព្វានត្រង់ឆ្នេរស្ទឹងគង្គារនោះឯង ពួកមនុស្សដឹងរឿងរបស់បុរសនោះ ក៏យកដុំដីជាដើមគប់បុរសនោះឲ្យអស់ជីវិតក្នុងទីនោះឯង ។ បុរសនោះ ធ្វើកាលកិរិយាហើយ កើតក្នុងអវីចិមហានរក ឆេះក្នុងនរកច្រើនពាន់ឆ្នាំ សេសសល់ផលកម្មនោះឯងក្នុងពុទ្ធុប្បាទកាលនេះ ក៏មកកើតជាប្រេត ក្បែរក្រុងរាជគ្រឹះ ។ វិបាកដែលគប្បីឃើញសមគ្នានឹងកម្មនោះគប្បីមាន ព្រោះហេតុនោះញញួរដែកប្រមាណ ៦ ម៉ឺន ដែលកម្លាំងកម្មសាងឡើង សំពងអំបែងក្បាលទាំងព្រឹក ទាំងថ្ងៃត្រង់និងពេលល្ងាច ។ ប្រេតនោះ មានក្បាលបែកខ្ទេចខ្ទី ទទួលនូវទុក្ខវេទនាដ៏ពន្លឹក ដួលចុះត្រង់ផែនដី កាលញញួរដែកប្រាសទៅ ក្បាលក៏កើតឡើងដូចដើម ។

ថ្ងៃមួយ ព្រះមហាមោគ្គល្លានចុះអំពីភ្នំគិជ្ឈកូដ ឃើញប្រេតនោះ សាកសួរដោយគាថានេះថា

ហេតុអ្វីអ្នកដូចមនុស្សឆ្កួត ស្ទុះចុះស្ទុះឡើង ដូចម្រឹគភ្ញាក់ផ្អើល
អ្នកមានបាបកម្មមិនមានសង្ស័យ ហេតុអ្វីក៏អ្នកស្រែក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧម្មត្តរូបោវ** សេចក្តីថា អ្នកដូចមានភាវៈនៃមនុស្សឆ្កួត គឺដូចមនុស្សដែលដល់នូវភាពជាមនុស្សឆ្កួត ។ បទថា **មិគោ ភន្តោវ ធាវសិ** សេចក្តីថា អ្នករត់ឆ្វេឆ្វាទៅខាងនោះខាងនេះ ដូចម្រឹគដែលភ្ញាក់ផ្អើល ។ ពិតហើយ កាលញញួរដែកទាំងនោះសំពង ប្រេតមិនឃើញ

វិធីទប់ទល់ ក៏វត់ទៅខាងនោះខាងនេះ ដោយគិតថា ការប្រហារបែបនេះ មិនគប្បីមានហ្ន៎ ញញួរដែកទាំងនោះ ត្រូវកម្លាំងកម្មបន្សាត់ទៅ ទើបសំពងត្រង់អំបែងក្បាលរបស់ប្រេតនោះដែលឈរក្នុងទីណាមួយ ។ បទថា **កឹ នុ សន្ធាយសេ តុវំ** សេចក្តីថា អ្នកស្រែកធ្វើអ្វីហ្ន៎ គឺអ្នកត្រាច់ស្រែកគ្រលួចពន់ពេក ។

ប្រេតបានស្តាប់ដូច្នោះ បានឆ្លើយដោយគាថា ២ ថា

បពិត្រលោកដ៏ចម្រើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក
ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះតែធ្វើបាប
កម្ម ។ មានញញួរដែកពេញចំនួនប្រាំមួយម៉ឺន ( ៦០០០០ )
ដ៏គ្រប់គ្រាន់ តែងធ្លាក់លើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះ
ទម្លាយនូវក្បាលរបស់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សដ្ឋិ ក្ដូដសហស្សានិ** ប្រែថា ញញួរដែកប្រមាណ ៦ ម៉ឺន ។ បទថា **បរិបុណ្ណានិ** បានដល់ មិនលើស មិនខ្វះ ។ បទថា **សព្វសោ** គឺដោយចំណែកទាំងពួង បានឮថា ក្បាលរបស់ប្រេតនោះប៉ុនកំពូលភ្នំធំ កើតល្មមឲ្យញញួរ ៦ ម៉ឺនទូង ។ ញញួរដែកទាំងនោះ ទូងក្បាលរបស់ប្រេតនោះ មិនមានចន្លោះសូម្បីប៉ុនចុងរោមទ្រាយ ព្រោះហេតុនោះ ប្រេតនោះទើបស្រែកថ្ងូរ ដោយហេតុនោះ ទើបលោកពោលថា មានញញួរដែកពេញចំនួនប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ តែងធ្លាក់លើក្បាលរបស់ខ្ញុំ ដូច្នេះ ។

លំដាប់នោះ ព្រះថេរៈកាលនឹងសួរកម្មដែលប្រេតធ្វើនោះ ទើបពោល

គាថា ២ ថា

ចុះអ្នកបានធ្វើអំពើអាក្រក់ដោយ កាយ វាចា ចិត្ត ដូចម្តេច បានជាអ្នកលះលោកនេះ ទៅកើតក្នុងបេតលោក ព្រោះផលកម្មអ្វី ។ ញញួរដែកពេញប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះវាយទម្លាយក្បាល ដូច្នេះ ។

ប្រេតកាលប្រាប់កម្មដែលខ្លួនធ្វើដល់ព្រះថេរៈនោះ ទើបពោលគាថា ៣ ថា

កាលណោះ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធ ព្រះនាមសុនេត្ត លោកមានឥន្ទ្រិយចម្រើនដោយអរិយមគ្គ គង់ក្រោមម្លប់ឈើ លោកមានឈាន ឥតមានភ័យភិតមកពីទីណាទេ ។ ខ្ញុំបាញ់ទម្លាយព្រះកេសលោក ដោយការប្រហារដោយក្រួស សេចក្តីទុក្ខនេះសម្រេចដល់ខ្ញុំព្រោះតែផលកម្មនៃការប្រហារនោះ ។ ( ព្រោះហេតុនោះ ) បានជាញញួរដែកពេញប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះវាយទម្លាយក្បាលរបស់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្ពុទ្ធំ** បានដល់ ព្រះបច្ចេកសម្ពុទ្ធ ។ បទថា **សុនេត្តំ** បានដល់ ព្រះបច្ចេកពុទ្ធមានឈ្មោះយ៉ាងនេះ ។ បទថា **ភាវិ-តិន្ទ្រិយំ** បានដល់ ដែលមានឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមដែលអប់រំហើយ

ដោយអរិយមគ្គភាវនា ។

បទថា **សាលិត្តកប្បហារេន** សេចក្តីថា ប្រកបនូវការផ្ចាត់ដុំក្រួស ដោយធ្នូ ឬផ្ចាត់ដោយម្រាមដៃនោះឯង ដែលហៅថា **សាលិត្តក** ( សិប្ប ) ។ ពិតហើយ បាលីថា **សក្ខរាយ បហារេន** ដូច្នេះក៏មាន ។ បទថា **ភិន្ទិស្សំ** ប្រែថា បានទម្លាយ ។ ព្រះថេរៈកាលបានស្តាប់ដូច្នោះហើយ កាលនឹងសម្តែងថា ឥឡូវនេះ អ្នកបានទទួលផលនេះនៃកម្មចាស់ ដែលសមគួរដល់កម្ម ដែលខ្លួនធ្វើនោះឯង ទើបពោលគាថាចុងក្រោយថា

ម្នាលបុរសអាក្រក់ សមតាមសេចក្តីប្រព្រឹត្តរបស់អ្នកហើយ ត្រង់ដែលញញួរដែកពេញប្រាំមួយហ្មឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះ ក៏វាយទម្លាយក្បាលរបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មេន** បានដល់ ព្រោះហេតុដែលសមគួរ ។ បទថា **តេ** ប្រែថា ដល់អ្នក លោកសម្តែងថា ផលនេះសមគួរពិត ដល់បាបកម្ម ដែលអ្នកធ្វើខុសក្នុងព្រះបច្ចេកពុទ្ធនោះធ្វើហើយ រមែងបង្អោនចូលទៅរកអ្នក ព្រោះហេតុនោះ ផលនៃបាបកម្មនោះឯង ដែលបុគ្គលណាមួយទោះជាទេវតា មារ ព្រហ្ម ឬសូម្បីព្រះសម្មាសម្ពុទ្ធក៏រាំងមិនបាន ។

កាលពោលយ៉ាងនេះហើយ បន្ទាប់អំពីនោះ ទើបត្រាច់ទៅបិណ្ឌបាតក្នុងព្រះនគរ ធ្វើភត្តកិច្ចស្រេចហើយ ក្នុងវេលាល្ងាច ទើបចូលទៅគាល់ព្រះមុនី ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿង

នោះឲ្យជាអត្ថុប្បត្តិហេតុ កាលទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលដល់ព្រមហើយ ទើបប្រកាសគុណានុភាពនៃព្រះបច្ចេកពុទ្ធ និងការមិនមើលងាយកម្មមហាជនកើតនូវសេចក្តីសង្វេគ លះនូវបាបកម្មហើយ ជាអ្នកត្រេកអរក្នុងបុណ្យ មានទានជាដើម ដូច្នេះឯង ។

អដ្ឋកថា សដ្ឋិកូដសហស្សប្រេត ចប់

មហាវគ្គទី ៤ ប្រដាប់ដោយរឿង ១៦

ក្នុងបេតវត្ថុនៃអដ្ឋកថា ខុទ្ទកនិកាយ ចប់

# និគមនកថា

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ អត្ថវណ្ណនាដែលប្រកាសផលដ៏ក្តៅរបស់កម្ម ដែលជាហេតុឲ្យសត្វធ្វើអាក្រក់ កើតជាប្រេតដោយប្រចក្សដោយបុច្ឆា វិសជ្ជនា និងដោយនិយាមនៃទេសនា ធ្វើនូវសេចក្តីសង្វេគឲ្យកើតដល់សប្បុរសទាំងឡាយ ខ្ញុំអាស្រ័យន័យរបស់បុរាណដ្ឋកថា ទើបផ្តើមដើម្បីប្រកាសអត្ថនៃរឿង ដែលលោកអ្នកស្វែងរកគុណធំ ឈ្លាសក្នុងពាក្យកំណាត់ដឹងរឿងបានយ៉ាងល្អ ចងក្រងទុក ដោយឈ្មោះថា **បេតវត្ថុ** ដែលប្រកាសអត្ថយ៉ាងល្អទុកក្នុងបេតវត្ថុនោះ តាមសមគួរក្នុងរឿងនោះៗ ដោយឈ្មោះ ឈ្មោះថា **បរមត្ថទីបនី** វិនិច្ឆ័យមិនសាំញ៉ាំ ចប់បរិបូណ៌ហើយ ដោយព្រះបាលីប្រមាណ ១៥ ភាណវារ ។ ដូច្នោះ បុណ្យនោះ ដែលខ្ញុំរចនាបរមត្ថទីបនីនេះ បានទទួលហើយដោយបុញ្ញានុភាពនោះ សូមសត្វទាំងពួងឈមចុះកាន់សាសនា របស់ព្រះលោកនាថ ជាអ្នកមានចំណែកនៃវិមុត្តិរសដោយបដិបទាមានសីលជាដើម ដ៏បរិសុទ្ធ សូមសាសនារបស់ព្រះពុទ្ធ តាំងនៅក្នុងលោកអស់កាលយូរ សូមឲ្យសត្វទាំងឡាយ មានការគោរពក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធអង្គនោះជានិច្ចនិរន្តរ សូមភ្លៀងបង្អុរចុះលើផ្ទៃមហាប្រឹថពីត្រូវតាមរដូវកាល សូមបុគ្គលដែលត្រេកអរក្នុងព្រះសទ្ធម្ម គ្រប់គ្រងសត្វលោកដោយធម៌ហោង ។

បេតវត្ថុដែលរចនាដោយព្រះភទ្ទន្តាចរិយធម្មបាល
ជាបព្វជិតដ៏ប្រសើរក្នុងពួកមុនីក្នុងពទរតិត្ថវិហារ
( ក្នុងកំពង់ពុទ្រា ) ចប់ ដោយបរិបូណ៌
ដោយប្រការដូច្នេះ ។

# ក្បាលទី ៤០

# សុត្តន្តបិដក ខាលីប្រែ -៥៦

សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

## បេតវត្ថុ ឧរគវគ្គទី១


រឿងខេត្តូបមាប្រេតទី ១ .......... .......... .......... .......... ...... ២
អដ្ឋកថា ខេត្តូបមាប្រេត .......... .......... .......... .......... ...... ៧
រឿងសូករប្រេតទី ២ .......... .......... .......... .......... ...... ១៨
អដ្ឋកថា សូករប្រេត .......... .......... .......... .......... ...... ១៨
រឿងបូតិមុខប្រេតទី ៣ .......... .......... .......... .......... ........ ២៤
អដ្ឋកថា បូតិមុខប្រេត .......... .......... .......... .......... ........ ២៥
រឿងបិដ្ឋធីតលិកប្រេតទី ៤ .......... .......... .......... .......... ........ ៣២
អដ្ឋកថា បិដ្ឋធីតលិកប្រេត .......... .......... .......... .......... ........ ៣៣
រឿងតិរោកុឌ្ឌប្រេតទី ៥ .......... .......... .......... .......... ...... ៣៩
អដ្ឋកថា តិរោកុឌ្ឌប្រេត .......... .......... .......... .......... ...... ៤១
រឿងបញ្ចបុត្តខាទិកប្រេតទី ៦ .......... .......... .......... .......... ..... ៦៥
អដ្ឋកថា បញ្ចបុត្តខាទិកប្រេត .......... .......... .......... .......... ..... ៦៦
រឿងសត្តបុត្តខាទិកប្រេតទី ៧ .......... .......... .......... .......... ..... ៧៤
អដ្ឋកថា សត្តបុត្តខាទិកប្រេត .......... .......... .......... .......... ..... ៧៥
រឿងគោណប្រេតទី ៨ .......... .......... .......... .......... ....... ៧៩
អដ្ឋកថា គោណប្រេត .......... .......... .......... .......... ...... ៨០
រឿងមហាបេសការប្រេតទី ៩ .......... .......... .......... .......... .. ៨៧

អដ្ឋកថា មហាបេសការប្រេត .......... .......... .......... .............. ៨៨
រឿងខលាតប្រេតទី ១០ .......... .......... .......... ............. ៩៥
អដ្ឋកថា ខល្លាដិយប្រេត .......... .......... .......... .............. ៩៧
រឿងនាគប្រេតទី ១១ .......... .......... .......... ........... ១០៩
អដ្ឋកថា នាគប្រេត .......... .......... .......... ........... ១១១
រឿងឧរគប្រេតទី ១២ .......... .......... .......... .......... ១២៣
អដ្ឋកថា ឧរគប្រេត .......... .......... .......... ........... ១២៦

## ឧព្វរីវគ្គ ទី២

រឿងសំសារមោចកប្រេតទី ១ .......... .......... .......... .......... ១៣៦
អដ្ឋកថា សំសារមោចកប្រេត .......... .......... .......... ........... ១៣៩
រឿងប្រេតជាមាតានៃព្រះសារីបុត្តទី ២ .......... .......... .......... .......... ១៥៨
អដ្ឋកថា សារីបុត្តត្ថេរមាតុប្រេត .......... .......... .......... ......... ១៦០
រឿងនាងមត្តាប្រេតទី ៣ .......... .......... .......... .......... ១៦៨
អដ្ឋកថា នាងមត្តាប្រេត .......... .......... .......... .......... ១៧៣
រឿងនន្ទាប្រេតទី ៤ .......... .......... .......... .......... ១៨៨
អដ្ឋកថា នន្ទាប្រេត .......... .......... .......... .......... ១៩១
រឿងមដ្ឋកុណ្ឌលិប្រេតទី ៥ .......... .......... .......... .......... ១៩៦
អដ្ឋកថា មដ្ឋកុណ្ឌលិប្រេត .......... .......... .......... .......... ១៩៦
រឿងកណ្ហប្រេតទី ៦ .......... .......... .......... ........... ១៩៨
អដ្ឋកថា កណ្ហប្រេត .......... .......... .......... .......... ២០១
រឿងធនបាលប្រេតទី ៧ .......... .......... .......... .......... ២១៣
អដ្ឋកថា ធនបាលសេដ្ឋិប្រេត .......... .......... .......... ........... ២១៥
រឿងចូឡសេដ្ឋិប្រេតទី ៨ .......... .......... .......... ........... ២២៥

អដ្ឋកថា ចូឡសេដ្ឋិប្រេត .......... .......... .......... .......... ២២៧
រឿងអង្កុរប្រេតទី ៩ .......... .......... .......... ........... ២៣៦
អដ្ឋកថា អង្កុរប្រេត .......... .......... .......... ............ ២៤៥
រឿងនាងឧត្តរមាតុប្រេតទី ១០ .......... .......... .......... ........... ២៩៤
អដ្ឋកថា ឧត្តរមាតុប្រេត .......... .......... .......... ........... ២៩៥
រឿងសុត្តប្រេតទី ១១ .......... .......... .......... ......... ៣០២
អដ្ឋកថា សុត្តប្រេត .......... .......... .......... .......... ៣០៣
រឿងកណ្ណមុណ្ឌប្រេតទី ១២ .......... .......... .......... .......... ៣១៣
អដ្ឋកថា កណ្ណមុណ្ឌប្រេត .......... .......... .......... .......... ៣១៦
រឿងឧព្វរីប្រេតទី ១៣ .......... .......... .......... ......... ៣៣១
អដ្ឋកថា ឧព្វរីប្រេត .......... .......... .......... ......... ៣៣៥

## ចូឡវគ្គទី៣

រឿងអភិជ្ជមានប្រេតទី ១ .......... .......... .......... .......... ៣៤៨
អដ្ឋកថា អភិជ្ជមានប្រេត .......... .......... .......... ........... ៣៥១
រឿងសានុវាសិប្រេតទី ២ .......... .......... .......... ........... ៣៦៦
អដ្ឋកថា សានុវាសិប្រេត .......... .......... .......... .......... ៣៧១
រឿងរថការីប្រេតទី ៣ .......... .......... .......... ........... ៣៨៦
អដ្ឋកថា រថការីប្រេត .......... .......... .......... ........... ៣៨៨
រឿងកុសប្រេតទី ៤ .......... .......... .......... .......... ៣៩៥
អដ្ឋកថា កុសប្រេត .......... .......... .......... ........... ៣៩៦
រឿងកុមារប្រេតទី ៥ .......... .......... .......... .......... ៤០១
អដ្ឋកថា កុមារប្រេត .......... .......... .......... .......... ៤០៣
រឿងសេរិនីប្រេតទី ៦ .......... .......... .......... ........... ៤១៣

អដ្ឋកថា សេរិនីប្រេត .......... .......... .......... ........... ៤១៥
រឿង មិគលុទ្ទប្រេតទី ៧ .......... .......... .......... ........... ៤២២
អដ្ឋកថា មិគលុទ្ទប្រេត .......... .......... .......... ........... ៤២៣
រឿងទុតិយមិគលុទ្ទប្រេតទី ៨ .......... .......... .......... .......... ៤២៩
អដ្ឋកថា ទុតិយមិគលុទ្ទប្រេត .......... .......... .......... ........... ៤៣០
រឿងកូដវិនិច្ឆយកប្រេតទី ៩ .......... .......... .......... ........... ៤៣៤
អដ្ឋកថា កូដវិនិច្ឆយិកប្រេត .......... .......... .......... ........... ៤៣៥
រឿងធាតុវិវណ្ណប្រេតទី ១០ .......... .......... .......... ............ ៤៣៩
អដ្ឋកថា ធាតុវិវណ្ណប្រេត .......... .......... .......... ............ ៤៤១

## មហាវគ្គ ទី៤

រឿងអម្ពសក្ខរប្រេតទី ១ .......... .......... .......... .......... ៤៤៧
អដ្ឋកថា អម្ពសក្ខរប្រេត .......... .......... .......... ........... ៤៦១
រឿងសេរិស្សកប្រេតទី ២ .......... .......... .......... ............ ៥០៥
អដ្ឋកថា សេរិស្សកប្រេត .......... .......... .......... ............ ៥០៥
រឿងនន្ទិកាប្រេតទី ៣ .......... .......... .......... ............ ៥០៦
អដ្ឋកថា នន្ទិកាប្រេត .......... .......... .......... .......... ៥១៣
រឿងរេវតីប្រេតទី ៤ .......... .......... .......... ........... ៥៣៥
អដ្ឋកថា រេវតីប្រេត .......... .......... .......... ........... ៥៣៥
រឿងឧច្ឆុប្រេតទី ៥ .......... .......... .......... ........... ៥៣៦
អដ្ឋកថា ឧច្ឆុប្រេត .......... .......... .......... ........... ៥៣៧
រឿងកុមារប្រេតទី ៦ .......... .......... .......... ......... ៥៤៣
អដ្ឋកថា កុមារប្រេត .......... .......... .......... .......... ៥៤៤
រឿងរាជបុត្តប្រេតទី ៧ .......... .......... .......... .......... ៥៤៩

អដ្ឋកថា រាជបុត្តប្រេត .......... .......... .......... ......... ៥៥១

រឿងគូថខាទកប្រេតទី ៨ .......... .......... .......... ........ ៥៥៧

អដ្ឋកថា គូថខាទកប្រេត .......... .......... .......... ........ ៥៥៨

រឿងគូថខាទកប្រេតទី ៩ .......... .......... .......... .......... ៥៦៣

អដ្ឋកថា ទុតិយគូថខាទកប្រេត .......... .......... .......... ......... ៥៦៤

រឿងគណាប្រេតទី ១០ .......... .......... .......... ....... ៥៦៥

អដ្ឋកថា គណាប្រេត .......... .......... .......... ....... ៥៦៧

រឿងបាដលិបុត្តប្រេតទី ១១ .......... .......... .......... ...... ៥៧១

អដ្ឋកថា បាដលិបុត្តប្រេត .......... .......... .......... ...... ៥៧២

រឿងអម្ពវនប្រេតទី ១២ .......... .......... .......... ........ ៥៧៦

អដ្ឋកថា អម្ពវនប្រេត .......... .......... .......... ........ ៥៧៧

រឿងអក្ខរុក្ខប្រេតទី ១៣ .......... .......... .......... ........ ៥៨៣

អដ្ឋកថា អក្ខរុក្ខប្រេត .......... .......... .......... ........ ៥៨៣

រឿងភោគសំហរប្រេតទី ១៤ .......... .......... .......... ....... ៥៨៦

អដ្ឋកថា ភោគសំហរប្រេត ........... .......... .......... ....... ៥៨៦

រឿងសេដ្ឋិបុត្តប្រេតទី ១៥ .......... .......... .......... ....... ៥៨៩

អដ្ឋកថា សេដ្ឋិបុត្តប្រេត .......... .......... .......... ...... ៥៩០

រឿង សដ្ឋិកូដសហស្សប្រេតទី ១៦ .......... .......... .......... ....... ៥៩៥

អដ្ឋកថា សដ្ឋិកូដសហស្សប្រេត .......... .......... .......... ......... ៥៩៧